# មេរៀនសម្រាប់ការយល់ដឹង និង ការបណ្តុះបណ្តាលអំពី ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

library.ncdd.gov.kh
013571

# បុព្វកថា

គោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការរបស់រាជរដ្ឋាភិបាលកម្ពុជា គឺជាគោលនយោបាយដែលឯកឧត្តម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.អ.ប បានពិពណ៌នាថាជាការអភិវឌ្ឍផ្នែករដ្ឋធម្មនុញ្ញយ៉ាងជ្រាលជ្រៅ និងយ៉ាងសំខាន់បំផុតនៅប្រទេសកម្ពុជា ចាប់តាំងពីការអនុម័តរដ្ឋធម្មនុញ្ញនៅឆ្នាំ១៩៩៣ ។ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដែលត្រូវបានអនុម័ត នៅខែឧសភា ឆ្នាំ២០០៨ គឺជាក្របខ័ណ្ឌច្បាប់ដែលអនុញ្ញាតឱ្យអនុវត្តគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ ។

ជាមួយនឹងការអនុម័តច្បាប់នេះ នៅពេលថ្មីៗនេះរាជរដ្ឋាភិបាលមានភារកិច្ចបណ្តុះបណ្តាល និងផ្តល់ការអប់រំជាសាធារណៈអំពីច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។ ភារកិច្ចដ៏ធំនេះត្រូវបានឆ្លុះបញ្ចាំង ក្នុងកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ២០១០-២០១៩ (កម្មវិធីជាតិ) ដែលបានអនុម័តដោយរាជរដ្ឋាភិបាលកម្ពុជាកាលពីថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១០។ កំណែទម្រង់នេះត្រូវមានការបណ្តុះបណ្តាល និងការអប់រំនៅគ្រប់ថ្នាក់ ហើយអ្នកទទួលផលពីការបណ្តុះបណ្តាលនេះមានចាប់ពីមន្ត្រីជាន់ខ្ពស់នៅតាមក្រសួង ស្ថាប័នរហូតដល់សមាជិកក្រុមប្រឹក្សា គណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មន្ត្រីរាជការនៅថ្នាក់ក្រោមជាតិ បុគ្គលិករបស់ក្រុមប្រឹក្សា និងអ្នកពាក់ព័ន្ធមិនមែនរដ្ឋាភិបាល ។

ដើម្បីជួយសម្រួលដល់ការយល់ដឹង និងការបណ្តុះបណ្តាលអំពីច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មេរៀនចំនួន១៦លើប្រធានបទជាគន្លឹះនៅក្នុងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងអនុក្រឹត្យជាច្រើនត្រូវបានរៀបចំ។ មេរៀននីមួយៗនៅក្នុងចំណោមមេរៀនទាំង១៦នេះ មានលក្ខណៈខ្លី និងងាយអានដោយមានសេចក្តីពន្យល់ និងឧទាហរណ៍ដើម្បីរំលេចចំណុចសំខាន់ៗ។ មេរៀនទាំងនេះអាចត្រូវប្រើប្រាស់ដោយគ្រូឧទ្ទេស ប៉ុន្តែក៏អាចប្រើប្រាស់ដោយបុគ្គលដែលមានការចាប់អារម្មណ៍លើការរៀនសូត្រ និង ស្វែងយល់ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌផងដែរ ។

មេរៀនទាំងនេះ មានលក្ខណៈសមស្របសម្រាប់ការបណ្តុះបណ្តាលក្រុមជាគោលដៅ។ នៅពេលការបណ្តុះបណ្តាលក្រុមជាគោលដៅត្រូវបានកំណត់ហើយ គ្រូឧទ្ទេសត្រូវជ្រើសរើសមេរៀន (ឬផ្នែកខ្លះនៃមេរៀន) ដែលពាក់ព័ន្ធ នឹងក្រុមជាគោលដៅនោះ។ បន្ទាប់មកគ្រូឧទ្ទេសត្រូវរៀបចំប្លង់មេរៀនស្របទៅតាមមេរៀន ដោយគិតអំពីរយៈពេលនៃការបណ្តុះបណ្តាល និងការងារសំខាន់ៗបំផុតដែលត្រូវលើកឡើង ។ តារាងដ្យាក្រាម និងក្រាហ្វិច ដែលមានសារៈប្រយោជន៍ត្រូវបានដាក់បញ្ចូលនៅក្នុងមេរៀន ដែលអាចត្រូវប្រើប្រាស់ជាឯកសារសម្រាប់

ចែកជូនសិក្ខាកាម និងសម្រាប់ធ្វើការបង្ហាញ។ ដូចគ្នានេះដែរមេរៀននីមួយៗមានបញ្ចូលគំនិតផ្សេងៗ សម្រាប់ការធ្វើលំហាត់ជាក្រុម អាស្រ័យលើក្រុមជាគោលដៅ។

យើងសង្ឃឹមថា មេរៀនទាំងនេះនឹងជួយដល់ការអនុវត្តកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ជួយដល់ ការពង្រឹងលទ្ធិប្រជាធិបតេយ្យនៅមូលដ្ឋាន និងជួយកែលម្អកម្រិតជីវភាពរស់នៅរបស់ប្រជាជនកម្ពុជាទាំងអស់។ (**យើងរួមគ្នាធ្វើឱ្យការអភិវឌ្ឍមានចីរភាព**)

# មាតិកា


| | |
|---|---|
| ១ | សេចក្តីណែនាំបង្ហាញអំពីច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ |
| ២ | ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ |
| ៣ | រចនាសម្ព័ន្ធរដ្ឋបាលថ្នាក់ក្រោមជាតិ |
| ៤ | រដ្ឋបាលឯកភាព |
| ៥ | តួនាទី សិទ្ធិអំណាច និង មុខងាររបស់ក្រុមប្រឹក្សា |
| ៦ | តួនាទី និង មុខងាររបស់អភិបាល និង គណៈអភិបាល |
| ៧ | គណៈកម្មាធិការរបស់ក្រុមប្រឹក្សា |
| ៨ | បុគ្គលិករបស់ក្រុមប្រឹក្សា |
| ៩ | កិច្ចប្រជុំ របស់ក្រុមប្រឹក្សា និងបទបញ្ជាផ្ទៃក្នុង |
| ១០ | ទំនាក់ទំនងអន្តររដ្ឋបាល- រាជរដ្ឋាភិបាល និងក្រុមប្រឹក្សានៅថ្នាក់ក្រោមជាតិ |
| ១១ | ទំនាក់ទំនងអន្តររដ្ឋបាល- ក្រុមប្រឹក្សាខេត្ត ក្រុង ស្រុក ឃុំ និងសង្កាត់ |
| ១២ | តួនាទី និងរចនាសម្ព័ន្ធរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ |
| ១៣ | ការផ្ទេរមុខងារទៅឱ្យក្រុមប្រឹក្សា |
| ១៤ | ការកសាងផែនការ |
| ១៥ | វិមជ្ឈការសារពើពន្ធ និង ការគ្រប់គ្រងហិរញ្ញវត្ថុ |
| ១៦ | ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា |

## កំណត់សំគាល់

### ពាក្យ "ក្រុមប្រឹក្សា"

នៅក្នុងមេរៀនទាំងអស់នៃឯកសារបណ្តុះបណ្តាលនេះ លើកលែងតែមានបញ្ជាក់ផ្សេងពីនេះពាក្យ "**ក្រុមប្រឹក្សា**" សំដៅលើ ក្រុមប្រឹក្សាទាំងអស់ដូចខាងក្រោមៈ

- ក្រុមប្រឹក្សារាជធានីភ្នំពេញ
- ក្រុមប្រឹក្សាខេត្ត
- ក្រុមប្រឹក្សាក្រុង
- ក្រុមប្រឹក្សាស្រុក និង
- ក្រុមប្រឹក្សាខណ្ឌ

ពាក្យថា "ក្រុមប្រឹក្សា" សំដៅលើក្រុមប្រឹក្សាឃុំ សង្កាត់ **តែនៅពេល**មានការបញ្ជាក់ច្បាស់លាស់ប៉ុណ្ណោះ ។

## វគ្គទី ១

១. សេចក្តីផ្តើម

២. ការស្វែងយល់អំពីវិមជ្ឈការ និងវិសហមជ្ឈការ

៣. និន្នាការអន្តរជាតិនៅក្នុងវិមជ្ឈការ

៤. សាវតារគោលនយោបាយនៅកម្ពុជា

៥. និដ្ឋភាពសំខាន់ៗនៃច្បាប់គ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

## ផ្នែកទី ១: សេចក្តីផ្តើម

**សាវតា**

✓ គោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការរបស់រាជរដ្ឋាភិបាលកម្ពុជា **ជាការអភិវឌ្ឍផ្នែករដ្ឋធម្មនុញ្ញយ៉ាងជ្រាលជ្រៅ និងយ៉ាងសំខាន់បំផុតនៅប្រទេសកម្ពុជា** ចាប់តាំងពីការអនុម័តរដ្ឋធម្មនុញ្ញនៅឆ្នាំ១៩៩៣។

✓ បេះដូងនៃគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការរបស់រាជរដ្ឋាភិបាល គឺ**ការផ្ទេរមុខងារការទទួលខុសត្រូវ និងធនធានដល់ក្រុមប្រឹក្សាដែលជាប់ឆ្នោតនៅថ្នាក់ក្រោមជាតិ**។

✓ **ទិសដៅនៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ** គឺដើម្បី
- ពង្រឹង និងពង្រីកលទ្ធិប្រជាធិតេយ្យនៅមូលដ្ឋាន
- លើកកម្ពស់ការអភិវឌ្ឍមូលដ្ឋាន និងកាត់បន្ថយភាពក្រីក្រ

  (ក្របខ័ណ្ឌយុទ្ធសាស្ត្រស្តីពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ទំព័រទី៨ ឆ្នាំ២០០៥)

✓ ជាដំបូង រាជរដ្ឋាភិបាលបានដាក់ឱ្យអនុវត្ត**កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការនៅថ្នាក់ឃុំ សង្កាត់**។ នៅ ឆ្នាំ២០០១ រដ្ឋសភាបានអនុម័តច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ និងច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់។ នៅដើមឆ្នាំ២០០២ ប្រជាពលរដ្ឋបានបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ទាំង១.៦២១ នៅទូទាំងប្រទេស។ ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់លើកទីពីរត្រូវបានធ្វើឡើង នៅឆ្នាំ២០០៧។

✓ ជាមួយនឹងជោគជ័យនៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការនៅថ្នាក់ឃុំ សង្កាត់ រាជរដ្ឋាភិបាលបាន**ពង្រីក គោលនយោបាយរបស់ខ្លួន តាមរយៈការរៀបចំឱ្យមានការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សានៅថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ**។

✓ នៅឆ្នាំ២០០៥ រាជរដ្ឋាភិបាលបានដាក់ចេញឯកសារគោលនយោបាយមានឈ្មោះថា ***ក្របខ័ណ្ឌយុទ្ធសាស្ត្រស្តីពី កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ*** ដោយគូសបញ្ជាក់ចក្ខុវិស័យរបស់ខ្លួនសម្រាប់ពង្រីកកំណែទម្រង់ នេះ។

✓ **ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ** គឺជាក្របខ័ណ្ឌច្បាប់ដែលមានលក្ខណៈចាំបាច់ដើម្បីអនុវត្តចក្ខុវិស័យដែលបានគូសបញ្ជាក់នៅក្នុងក្របខ័ណ្ឌយុទ្ធសាស្ត្រស្តីពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ។

## កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ និងអភិបាលកិច្ចល្អ/ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ

✓ រាជរដ្ឋាភិបាល បានទទួលស្គាល់អភិបាលកិច្ចល្អថាជា**បុរេល័ក្ខខ័ណ្ឌសំខាន់បំផុត ដើម្បីទ្រទ្រង់ការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយចីរភាពសម្រាប់ប្រជាជនកម្ពុជា**។ កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ត្រូវបានទទួលស្គាល់ថាជាយុទ្ធសាស្ត្រមួយ ដើម្បីលើកកំពស់អភិបាលកិច្ចល្អ (ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ ២០០៦ -២០១០ ទំព័រ ៨-៩ យុទ្ធសាស្ត្រចតុកោណទំព័រ៦)។

✓ ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ ដែលអាចប្រើបានមានន័យដូចគ្នានឹងអភិបាលកិច្ចល្អ ត្រូវបានដាក់បញ្ចូលទៅក្នុងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ថាជាគោលការណ៍យ៉ាងសំខាន់។ ច្បាប់ ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ បញ្ជាក់យ៉ាងច្បាស់ថា ក្រុមប្រឹក្សាថ្មីត្រូវប្រឹងប្រែងដើម្បី បង្កើត ជម្រុញ និងធ្វើឱ្យមានចីរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅក្នុងតំបន់របស់ខ្លួន។

> ចំពោះព័ត៌មានបន្ថែមស្តីពីការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ សូមអានមេរៀនទី ២។

## តើកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការអាចរួមចំណែកចំពោះអភិបាលកិច្ចល្អ/ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យដោយរបៀបណា?

✓ ក្រុមប្រឹក្សាទាំងអស់តំណាងឱ្យប្រជាពលរដ្ឋរបស់ខ្លួន និងជាអ្នកការពារ និងបម្រើផលប្រយោជន៍របស់ប្រជាពលរដ្ឋទាំងអស់នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ ដូច្នេះ ក្រុមប្រឹក្សាត្រូវបម្រើប្រជាពលរដ្ឋ**ទាំងអស់** (មាត្រា ៦, មាត្រា ៦១, មាត្រា ១១៣ នៃអនុក្រឹត្យលេខ២១៦ អ.ន.ក្រ.បក ស្តីពីតួនាទី ភារកិច្ច និង

ទំនាក់ទំនងការងារ របស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក ) ។

✓ ដើម្បីដឹងឱ្យបានប្រសើរបំផុតក្នុងការបម្រើតម្រូវការរបស់ប្រជាពលរដ្ឋរបស់ខ្លួន ក្រុមប្រឹក្សាទាំងអស់ត្រូវកៀរគរការចូលរួមចំណែកជាមួយប្រជាពលរដ្ឋរបស់ខ្លួន ( **ការចូលរួមចំណែករបស់ប្រជាពលរដ្ឋ**) ។

✓ កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ គឺជាការនាំយក**រដ្ឋបាលទៅដាក់ឱ្យនៅកៀកនឹងប្រជាពលរដ្ឋ**។ ការនាំយករដ្ឋបាលទៅដាក់ឱ្យនៅកៀកនឹងប្រជាពលរដ្ឋ មានន័យថាប្រជាពលរដ្ឋមានឱកាសកាន់តែធំទូលាយដើម្បី **បញ្ចេញសម្លេងរបស់ខ្លួន**នៅក្នុងអភិបាលកិច្ចមូលដ្ឋាន ដើម្បី**ធ្វើឱ្យមានឥទ្ធិពល**ទៅលើសេចក្តីសម្រេចដែល មានផលប៉ះពាល់មកលើជីវភាពរស់នៅរបស់គាត់ និងធ្វើឱ្យរដ្ឋបាលរបស់ខ្លួន**មានគណនេយ្យភាពតាមបែបប្រជាធិបតេយ្យ**លើគោលនយោបាយ សេចក្តីសម្រេច និងសកម្មភាពរបស់ខ្លួន និងរបៀបប្រើប្រាស់ ឬមិនប្រើ ប្រាស់សិទ្ធិអំណាចរបស់រដ្ឋបាល និងធនធានសាធារណៈ។ ក្រៅពីនេះ នៅពេលរដ្ឋបាលស្ថិតនៅកៀកនឹង ប្រជាពលរដ្ឋ វាអាចមានភាពងាយស្រួលសម្រាប់ស្ត្រី និងក្រុមងាយរងគ្រោះ ( ដូចជាជនក្រីក្រ) ចូលរួម និងធ្វើ ឱ្យមានឥទ្ធិពលដល់អភិបាលកិច្ចមូលដ្ឋាន។

**គណនេយ្យភាពតាមបែបប្រជាធិបតេយ្យសំដៅលើ**

*តំណាងជាប់ឆ្នោតដែលមានគណនេយ្យភាពតាមបែបប្រជាធិបតេយ្យ ប្រកាន់យកជម្រើសដោយផ្អែកលើព័ត៌មានបែងចែកធនធានដ៏មានកម្រិត និងអនុវត្តមុខងារ និងភារកិច្ចរបស់ខ្លួនដើម្បីជាប្រយោជន៍សាធារណៈ និងដើម្បីឆ្លើយតបនឹងតម្រូវការដែលបានលើកឡើងនៅមូលដ្ឋាន។*

*គណនេយ្យភាពតាមបែបប្រជាធិបតេយ្យកើតមានឡើងនៅពេលប្រជាពលរដ្ឋ អាចកំណត់ផលវិបាកទៅលើតំណាងជាប់ឆ្នោតចំពោះជម្រើសដែលតំណាងជាប់ឆ្នោតប្រកាន់យក របៀបដែលតំណាងជាប់ឆ្នោតបែងចែកធនធានដ៏មានកម្រិត និងចំពោះ ការអនុវត្តមុខងារ និងភារកិច្ចរបស់ខ្លួន។*

ដូច្នេះ គណនេយ្យភាពតាមបែបប្រជាធិបតេយ្យពាក់ព័ន្ធនឹង

- ប្រជាពលរដ្ឋ មានឱកាសដើម្បីឱ្យ**សម្លេង**របស់គាត់ ត្រូវបានស្តាប់ឮ ស្វែងយល់ និងពិចារណាដោយក្រុមប្រឹក្សា
- ប្រជាពលរដ្ឋ **វាយតម្លៃ**លើសកម្មភាពរបស់ក្រុមប្រឹក្សា និងការប្រើប្រាស់មូលនិធិសាធារណៈដោយក្រុមប្រឹក្សា **ផ្តល់មតិ ត្រឡប់មកវិញ** និង**ទាមទារ**ឱ្យចាត់វិធានការនៅពេលមិនពេញចិត្តនឹងការងាររបស់ក្រុមប្រឹក្សា (រួមទាំងការងាររដ្ឋបាល)
- ការបែងចែកច្បាស់លាស់រវាង**ជម្រើសផ្នែកនយោបាយ** ដែលក្រុមប្រឹក្សាជាប់ឆ្នោតត្រូវប្រកាន់យកក្នុងនាមប្រជាពលរដ្ឋ របស់ខ្លួនពីការងារផ្នែករដ្ឋបាល ឬបច្ចេកទេសរបស់គណៈអភិបាល និងបុគ្គលិករបស់ក្រុមប្រឹក្សា

- ការបង្កើតបទបញ្ជា និងដំណើរការដើម្បីធានាថា ក្រុមប្រឹក្សាប្រកាន់យក**ជម្រើសអំពីអាទិភាព និងធ្វើសេចក្ដីសម្រេចដោយផ្អែកលើភស្តុតាង**
- ការធានាឱ្យមាន**ឱកាសផ្នែកនយោបាយ**សម្រាប់ក្រុមប្រឹក្សាពិភាក្សា និង**ជជែកវែកញែក**នៅពេលកំណត់អាទិភាពក្នុងនាម ប្រជាពលរដ្ឋរបស់ខ្លួន
- ការផ្ដល់ដល់ក្រុមប្រឹក្សានូវ**អាណត្តិច្បាស់លាស់** ដែលរួមមាន**សិទ្ធិអំណាច និងឆន្ទានុសិទ្ធិ** ដើម្បីដោះស្រាយតម្រូវការ និង កង្វល់ពិតប្រាកដរបស់ប្រជាពលរដ្ឋ
- ការផ្ដល់ដល់ក្រុមប្រឹក្សានូវ**ធនធានតាមឆន្ទានុសិទ្ធិគ្រប់គ្រាន់** ដើម្បីដោះស្រាយតម្រូវការ និងកង្វល់ទាំងនោះ
- ការផ្ដល់ដល់ប្រជាពលរដ្ឋនូវយន្តការ ដើម្បី**កំណត់ផលវិបាក**ទៅលើតំណាងជាប់ឆ្នោតរបស់ខ្លួន នៅពេលតំណាងជាប់ឆ្នោតទាំងនោះ មិនឆ្លើយតបនឹងតម្រូវការរបស់ខ្លួន ។

## តើកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការអាចរួមចំណែកចំពោះការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយចីរភាពតាមរបៀបណា?

✓ ការនាំយករដ្ឋបាលឱ្យទៅនៅកៀកនឹងប្រជាពលរដ្ឋ ក៏គួរមានន័យផងដែរថា រដ្ឋបាលអាច**យល់កាន់តែច្បាស់អំពី តម្រូវការពិតប្រាកដ**របស់ប្រជាជននៅមូលដ្ឋាន។ នៅពេលរដ្ឋបាលមូលដ្ឋាន យល់ពីតម្រូវការពិតប្រាកដរបស់ប្រជាពលរដ្ឋនៅមូលដ្ឋាន ហើយនៅពេលដែលរដ្ឋបាលនេះមានសិទ្ធិអំណាច មុខងារ និងធនធានគ្រប់គ្រាន់ រដ្ឋបាលអាច**ឆ្លើយតបកាន់តែប្រសើរ**ទៅនឹងតម្រូវការទាំងនោះ ។

✓ តាមវិធីនេះ កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការអាចរួមចំណែកចំពោះអភិបាលកិច្ចដែលមានការឆ្លើយតបកាន់តែប្រសើរ និងចំពោះការផ្ដល់សេវាកាន់តែច្រើន រួមទាំងសេវាទាក់ទងនឹងការអភិវឌ្ឍសេដ្ឋកិច្ច។ ជាលទ្ធផល អភិបាលកិច្ច និងការផ្ដល់សេវាដែលមានការឆ្លើយតបកាន់តែប្រសើរ និងកាន់តែច្រើន នឹងរួមចំណែក ចំពោះការអភិវឌ្ឍសេដ្ឋកិច្ចកាន់តែមានចីរភាព និងចំពោះការកាត់បន្ថយភាពក្រីក្រ ។

## ផ្នែកទី ២ : ការស្វែងយល់អំពីវិមជ្ឈការ និងវិសហមជ្ឈការ

- ✓ ទាំងនៅក្នុង និងក្រៅប្រទេសកម្ពុជា មានការផ្តល់និយមន័យ និងការយល់ដឹងខុសៗគ្នាជាច្រើន ថាតើវិមជ្ឈការ និងវិសហមជ្ឈការមានន័យដូចម្តេច។
- ✓ ខាងក្រោមនេះ គឺជានិយមន័យវិមជ្ឈការ និងវិសហមជ្ឈការដែលត្រូវបានអនុម័តដោយគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប)។

### វិមជ្ឈការ

រាជរដ្ឋាភិបាល **ប្រគល់** ឱ្យក្រុមប្រឹក្សានៅថ្នាក់ក្រោមជាតិនូវ**ភាពជាម្ចាស់**លើ**មុខងារ សិទ្ធិអំណាច និងធនធាន** ដើម្បីឆ្លើយតបនឹងតម្រូវការរបស់មូលដ្ឋាន។ ក្រុមប្រឹក្សា ត្រូវមានគណនេយ្យភាពចំពោះប្រជាជននៅមូលដ្ឋានលើបញ្ហាទាំងនេះ។

### វិសហមជ្ឈការ

រាជរដ្ឋាភិបាល ក្រសួង ឬស្ថាប័នរបស់រាជរដ្ឋាភិបាល**ធ្វើប្រតិភូកម្ម**មុខងារ និងធនធាន**ឱ្យអង្គភាពនៅថ្នាក់ក្រោមរបស់ខ្លួន ឬឱ្យក្រុមប្រឹក្សា**នៅថ្នាក់ណាមួយ ដើម្បី**អនុវត្តក្នុងនាមរាជរដ្ឋាភិបាល** ក្រសួង ឬស្ថាប័នរបស់រដ្ឋាភិបាល។

អង្គភាព ឬក្រុមប្រឹក្សា ត្រូវមានគណនេយ្យភាពចំពោះរាជរដ្ឋាភិបាល ក្រសួង ឬ ស្ថាប័នរបស់រដ្ឋាភិបាលអនុលោមទៅតាមល័ក្ខខ័ណ្ឌនៃប្រតិភូកម្ម។

## ឧទាហរណ៍

✓ តារាងខាងក្រោមផ្តល់ឧទាហរណ៍អំពីមុខងារគ្រប់គ្រងមត្តេយ្យសិក្សាសហគមន៍ ដើម្បីឆ្លុះបញ្ចាំងភាពខុសគ្នា រវាង:

- **វិមជ្ឈការ**
- **វិសហមជ្ឈការ**ទៅក្រុមប្រឹក្សា ដែលនឹងត្រូវអោយឈ្មោះថា **ប្រតិភូកម្ម**
- **វិសហមជ្ឈការ**ឱ្យអង្គភាពរបស់ក្រសួងខ្សែបណ្តោយ

| | |
|---|---|
| វិមជ្ឈការ | ក្រសួងអប់រំយុវជន និងកីឡា ធ្វើវិមជ្ឈការមុខងារត្រួតពិនិត្យការផ្ដល់សេវា មត្តេយ្យសិក្សាសហគមន៍ទៅឱ្យក្រុមប្រឹក្សាស្រុក។ មុខងារនេះ គឺជាមុខងារ ផ្ទាល់ខ្លួនរបស់ក្រុមប្រឹក្សាស្រុក។ ធនធានសម្រាប់អនុវត្តមុខងារនេះ ក៏ត្រូវផ្ទេរ ឱ្យក្រុមប្រឹក្សាស្រុកដែរ។ បុគ្គលិករបស់ក្រុមប្រឹក្សាស្រុកអនុវត្តមុខងារនេះ។ ក្រុមប្រឹក្សាស្រុក អាចណែនាំបុគ្គលិករបស់ខ្លួនឱ្យអនុវត្តមុខងារនេះទៅតាម ការយល់ឃើញសមស្របរបស់ក្រុមប្រឹក្សា ដោយអនុលោមទៅតាមរដ្ឋធម្មនុញ្ញ ច្បាប់ លិខិតបទដ្ឋាននានា និងគោលការណ៍ផ្សេងៗទៀតដែលដាក់ចេញដោយ ក្រសួងអប់រំយុវជន និងកីឡា ។ |
| ប្រតិភូកម្ម (ធ្វើប្រតិភូកម្មឱ្យក្រុមប្រឹក្សា) | ក្រសួងអប់រំយុវជន និងកីឡា ធ្វើប្រតិភូកម្មមុខងារត្រួតពិនិត្យការផ្ដល់សេវា មត្តេយ្យសិក្សាសហគមន៍ទៅឱ្យក្រុមប្រឹក្សាស្រុក។ មុខងារនេះ នៅតែជាមុខងាររបស់ក្រសួងអប់រំយុវជន និងកីឡា។ ក្រុមប្រឹក្សាស្រុក មានតួនាទី អនុវត្តមុខងារនេះក្នុងនាមក្រសួង។ ធនធានសម្រាប់អនុវត្តមុខងារនេះ ក៏ត្រូវផ្ទេរទៅឱ្យក្រុមប្រឹក្សាស្រុកផងដែរ។ បុគ្គលិករបស់ក្រុមប្រឹក្សាស្រុក អនុវត្តមុខងារនេះ។ ក្រសួងអាចផ្ដល់ជាការណែនាំលំអិតអំពីរបៀបដែលក្រុមប្រឹក្សា អាចអនុវត្តមុខងារនេះបាន ។ |
| វិសហមជ្ឈការ (ទៅអង្គភាពក្រសួងខ្សែបណ្ដោយ) | ក្រសួងអប់រំយុវជន និងកីឡា ធ្វើវិសហមជ្ឈការមុខងារត្រួតពិនិត្យការផ្ដល់សេវាមត្តេយ្យសិក្សាសហគមន៍ដល់មន្ទីរ និងការិយាល័យខ្សែបណ្ដោយរបស់ក្រសួង។ ក្រសួង ក៏នឹងផ្ដល់ធនធានដើម្បីអនុវត្តមុខងារនេះដែរ។ បុគ្គលិក របស់មន្ទីរ ឬការិយាល័យខ្សែបណ្ដោយរបស់ក្រសួងអនុវត្តមុខងារនេះ។ ក្រសួង អាចផ្ដល់ជាការណែនាំលំអិតអំពីរបៀបដែលមន្ទីរ ឬការិយាល័យខ្សែបណ្ដោយ អាចអនុវត្តមុខងារនេះបាន ។ |

តារាងខាងក្រោម ផ្តល់ទស្សនទានមួយទៀតលើភាពខុសគ្នារវាង**វិមជ្ឈការ ប្រតិភូកម្ម** (វិសហមជ្ឈការទៅក្រុមប្រឹក្សា) និងវិសហមជ្ឈការទៅអង្គភាពខ្សែបណ្តោយរបស់ក្រសួង។

| | **រក្សាទុកមុខងារនៅថ្នាក់ជាតិ** | **ធ្វើវិសហមជ្ឈការមុខងារទៅអង្គភាពខ្សែបណ្តោយ** | **ធ្វើប្រតិភូកម្មមុខងារទៅក្រុមប្រឹក្សា (ធ្វើវិសហមជ្ឈការទៅក្រុមប្រឹក្សា)** | **ធ្វើវិមជ្ឈការមុខងារទៅក្រុមប្រឹក្សា** |
|---|---|---|---|---|
| **ឆន្ទានុសិទ្ធិផ្នែកគោលនយោបាយ** | ក្រសួងមានឆន្ទានុសិទ្ធិផ្នែកគោលនយោបាយ | ក្រសួងមានឆន្ទានុសិទ្ធិផ្នែកគោលនយោបាយ | ក្រសួងមានឆន្ទានុសិទ្ធិផ្នែកគោលនយោបាយ * | ក្រសួង មានឆន្ទានុសិទ្ធិផ្នែកគោលនយោបាយ |
| **ការទទួលខុសត្រូវចំពោះការអនុវត្ត** | ក្រសួងអនុវត្ត | មន្ទីរ ឬការិយាល័យស្រុកអនុវត្ត | ក្រុមប្រឹក្សាអនុវត្ត | ក្រុមប្រឹក្សាអនុវត្ត |
| **ការត្រួតពិនិត្យមូលនិធិ** | ក្រសួងទទួលមូលនិធិ<br>ក្រសួងសំរេចលើរបៀបចំណាយមូលនិធិ | ក្រសួងទទួលមូលនិធិ<br>ក្រសួងសំរេចលើរបៀបចំណាយមូលនិធិ | ក្រុមប្រឹក្សា ទទួលមូលនិធិពីក្រសួង<br>ក្រសួង អាចសំរេចលើរបៀបដែលក្រុមប្រឹក្សាត្រូវចំណាយមូលនិធិ * | ក្រុមប្រឹក្សាទទួលមូលនិធិពីថ្នាក់ជាតិដោយផ្ទាល់<br>ក្រុមប្រឹក្សាសំម្រេចលើរបៀបចំណាយមូលនិធិ |
| **ការត្រួតពិនិត្យបុគ្គលិក** | ក្រសួងមានបុគ្គលិករបស់ខ្លួន ផ្ទាល់ ហើយក្រសួងត្រួតពិនិត្យ បុគ្គលិករបស់ខ្លួន | បុគ្គលិករបស់មន្ទីរ និងការិយាល័យស្រុក គឺជាបុគ្គលិករបស់ក្រសួង ហើយក្រសួងត្រួតពិនិត្យបុគ្គលិក | បុគ្គលិក ត្រូវផ្ទេរទៅក្រុមប្រឹក្សា ដើម្បីអនុវត្តមុខងារ<br>ក្រុមប្រឹក្សា ត្រួតពិនិត្យបុគ្គលិករបស់ខ្លួន | បុគ្គលិក ត្រូវផ្ទេរឱ្យក្រុមប្រឹក្សា ដើម្បីអនុវត្តមុខងារ<br>ក្រុមប្រឹក្សា ត្រួតពិនិត្យបុគ្គលិករបស់ខ្លួន |

*ការផ្ទេរមុខងារឱ្យក្រុមប្រឹក្សា តាមរយៈប្រគល់ ឬប្រតិភូកម្ម ត្រូវជំរុញការអភិវឌ្ឍបែបប្រជាធិបតេយ្យដោយៈ

- ផ្តល់**សិទ្ធិអំណាចជាអតិបរមាអោយក្រុមប្រឹក្សា** ដើម្បីឱ្យក្រុមប្រឹក្សាអាចគ្រប់គ្រង និងអនុវត្តមុខងារ
- តម្រូវឱ្យក្រុមប្រឹក្សា គ្រប់គ្រង និងអនុវត្តមុខងារដោយមាន**ការឆ្លើយតប** និងមានគណនេយ្យភាពចំពោះប្រជាពលរដ្ឋរបស់ខ្លួន។ (ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មាត្រា ២២៥)។

## ផ្នែកទី ៣: និន្នាការអន្តរជាតិនៅក្នុងវិមជ្ឈការ

នៅទូទាំងពិភពលោក មាននិន្នាការយ៉ាងច្បាស់ក្នុងការប្រែក្លាយពីរដ្ឋាភិបាលបែបមជ្ឈការទៅជារដ្ឋាភិបាល បែបវិមជ្ឈការ។ បច្ចុប្បន្ននេះ ប្រទេសភាគច្រើននៅលើពិភពលោកមានរចនាសម្ព័ន្ធបែបវិមជ្ឈការ។

នៅក្នុងចន្លោះពីឆ្នាំ១៩៩០ ដល់ឆ្នាំ២០០០ គេឃើញមានប្រទេសជាច្រើនបានធ្វើដំណើរការកំណែទម្រង់ វិមជ្ឈការ និងវិសហមជ្ឈការ។ ឧទាហរណ៍មានដូចជាប្រទេសហ្វីលីពីន ឥណ្ឌូនេស៊ី បូលីវី អេឌ្យូឌ័រ ម៉ាលី អាហ្វ្រិក ខាងត្បូង ប៉ូឡូញ និងរ៉ូម៉ានី ។ល។

**ហេតុអ្វីបានជារដ្ឋាភិបាលសម្រេចធ្វើវិមជ្ឈការអំណាច មុខងារ និង ធនធានឱ្យអាជ្ញាធរមូលដ្ឋាន ?**

វិមជ្ឈការ គឺជាយុទ្ធសាស្ត្រដើម្បី**កែលម្អអភិបាលកិច្ច** ហើយជាញឹកញាប់ គឺជាផ្នែកមួយនៃដំណើរការប្រជាធិបតេយ្យភាវូបនីយកម្ម (ដូចជាករណីប្រទេសកម្ពុជា)។

ពិភពលោកកាន់តែមានភាពសាំញ៉ាំជាមួយនឹងបញ្ហាដែលមានការកើនឡើងជាប្រចាំ។ ដូច្នេះ ការទទួលខុសត្រូវរបស់ថ្នាក់កណ្តាល ក៏មានការកើនឡើងដែរ។ **បញ្ហាចម្រុះ និងសាំញ៉ាំ** មិនអាចដោះស្រាយនៅថ្នាក់កណ្តាល

វិមជ្ឈការ នាំឱ្យមានអ្នកធ្វើសេចក្តីសំរេចនៅមូលដ្ឋាន ដែលត្រូវធ្វើសកម្មភាពដើម្បីជាប្រយោជន៍ដល់ប្រជាពលរដ្ឋរបស់ខ្លួន។ ការមានអ្នកធ្វើសេចក្តីសំរេចនៅមូលដ្ឋានមានន័យថា ប្រជាពលរដ្ឋមាន**ឱកាសងាយស្រួលក្នុងការពិភាក្សា និងធ្វើឱ្យមានឥទ្ធិពលទៅលើសេចក្តីសម្រេច** ដែលឆ្លើយតបទៅនឹងតម្រូវការ និងអាទិភាពរបស់គាត់។

ការមានក្រុមប្រឹក្សានៅមូលដ្ឋានមានន័យថា ប្រជាពលរដ្ឋស្រួលមើលឃើញអ្វីដែលអាជ្ញាធរបានធ្វើ និងមិនបានធ្វើ និងរបៀបប្រើប្រាស់ធនធាន (**តម្លាភាព**)។ ជាមួយនឹងឱកាសធ្វើឱ្យមានឥទ្ធិពលទៅលើការធ្វើសេចក្តីសម្រេចចិត្ត និងជាមួយតម្លាភាពដែលបានកែលម្អ ប្រជាពលរដ្ឋគួរទទួលបាននូវការឆ្លើយតប និងគណនេយ្យភាពកាន់ តែប្រសើរឡើងពីក្រុមប្រឹក្សាដែលបានជាប់ឆ្នោត។

វិមជ្ឈការ ក៏ជាយុទ្ធសាស្ត្រ**កែលម្អការផ្តល់សេវាផងដែរ** ។ – ការនាំយកអភិបាលកិច្ចទៅកៀកនឹងប្រជាពលរដ្ឋ នឹងជម្រុញឱ្យមានភាពងាយស្រួលក្នុងការកំណត់តម្រូវការសេវានៅមូលដ្ឋាន និងការរៀបចំយុទ្ធសាស្ត្រ ដើម្បីឆ្លើយតបនឹងតម្រូវការទាំងនេះ ដោយផ្អែកលើល័ក្ខខ័ណ្ឌ និងស្ថានភាពជាក់ស្តែងនៅមូលដ្ឋាន។

## ផលប្រយោជន៍ជាសក្តានុពលនៃវិមជ្ឈការ

- ការធ្វើឱ្យលទ្ធិប្រជាធិបតេយ្យកាន់តែស៊ីជំរៅ
- រួមចំណែកចំពោះការកាត់បន្ថយភាពក្រីក្រ
- ឱកាសសម្រាប់ការរីកចំរើនសេដ្ឋកិច្ចនៅមូលដ្ឋាន
- ការបង្កើនតម្លាភាព និង គណនេយ្យភាពរបស់រដ្ឋាភិបាល
- ការបង្កើនការចូលរួមជាសាធារណៈនៅក្នុងការធ្វើសេចក្តីសម្រេចផ្នែកនយោបាយ
- ឱកាសកាន់តែច្រើនសម្រាប់ប្រជាជនចូលរួមនៅក្នុងការធ្វើសេចក្តីសម្រេចផ្នែកនយោបាយ (ដូចជា ស្ត្រី ជនក្រីក្រ និងជនជាតិដើមភាគតិច)
- ការឆ្លើយតបកាន់តែច្រើនចំពោះតម្រូវការជាអាទិភាព និងផលប្រយោជន៍នៅមូលដ្ឋាន
- ការដោះស្រាយបញ្ហាមានលក្ខណៈកាន់តែសមស្របទៅនឹងល័ក្ខខ័ណ្ឌ និងស្ថានភាពជាក់ស្តែងនៅមូលដ្ឋាន
- ការកែលម្អនៅក្នុងការផ្តល់សេវាសាធារណៈ
- ការកែលម្អប្រសិទ្ធភាពរដ្ឋបាលសាធារណៈ
- ជម្រើសកាន់តែច្រើននៅក្នុងចំណោមសមត្ថកិច្ច

## ផ្នែកទី ៤: សាវតាគោលនយោបាយនៅកម្ពុជា

ខាងក្រោមនេះ គឺជាសេចក្តីសង្ខេបអំពីឯកសារគោលនយោបាយសំខាន់ៗ ដែលកំណត់រូបរាងកំណែទម្រង់អភិបាលកិច្ចនៅថ្នាក់ក្រោមជាតិរបស់រាជរដ្ឋាភិបាល និង *ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ* (ច្បាប់រៀបចំអង្គការ)។ ទំនាក់ទំនងរវាងឯកសារគោលនយោបាយទាំងនេះចំពោះកំណែទម្រង់វិមជ្ឈការ និង វិសហមជ្ឈការ ត្រូវបានរំលេចឡើង។ ក្រៅពីនេះ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ត្រូវបានពិពណ៌នាដោយសង្ខេប។

### យុទ្ធសាស្ត្រចតុកោណ

របៀបវារៈគោលនយោបាយរបស់រាជរដ្ឋាភិបាលសម្រាប់ឆ្នាំ២០០៨ ដល់ឆ្នាំ ២០១៣ ត្រូវបានកំណត់នៅ ក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២សម្រាប់កំណើន ការងារ សមធម៌ និងប្រសិទ្ធភាព។ ស្នូលកណ្តាលនៃយុទ្ធសាស្ត្រចតុកោណ **គឺអភិបាលកិច្ចល្អ** ដែលត្រូវបានទទួលស្គាល់ថាជាបុរេល័ក្ខខ័ណ្ឌសំខាន់បំផុតសម្រាប់ការអភិវឌ្ឍ សេដ្ឋកិច្ចប្រកបដោយចីរភាព សមធម៌ និងយុត្តិធម៌។ យុទ្ធសាស្ត្រចតុកោណចែងថា អភិបាលកិច្ចល្អ **មានការពាក់ ព័ន្ធនឹងការចូលរួមយ៉ាងទូលំទូលាយ ការជំរុញការចែករំលែកព័ត៌មាន គណនេយ្យភាព តម្លាភាព សមភាព សាមគ្គីភាព និងនីតិរដ្ឋ។**

ដើម្បីសម្រេចបានអភិបាលកិច្ចល្អនៃយុទ្ធសាស្ត្រចតុកោណ រាជរដ្ឋាភិបាលផ្តោតការយកចិត្តទុកដាក់ទៅលើ កំណែទម្រង់វិស័យចំនួនបួនគឺ ការប្រយុទ្ធប្រឆាំងអំពើពុករលួយ កំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ កំណែទម្រង់រដ្ឋបាលសាធារណៈ និងកំណែទម្រង់កងកំលាំងប្រដាប់អាវុធ។ នៅក្នុងវិស័យកំណែទម្រង់រដ្ឋបាលសាធារណៈ រាជរដ្ឋា ភិបាលទទួលស្គាល់វិមជ្ឈការថាមានសារៈសំខាន់ជាសារវន្តចំពោះ**ការពង្រឹងលទ្ធិប្រជាធិបតេយ្យ ការកែលម្អគុណភាពនៃសេវាសាធារណៈនៅក្នុងវិស័យទាំងអស់** និង**ការកែ លម្អការអភិវឌ្ឍមូលដ្ឋានដោយមានការចូលរួម** (យុទ្ធសាស្ត្រចតុកោណដំណាក់កាលឆ្នាំ ២០០៤-២០០៨ ទំព័រ៨)។

## **ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ២០០៦-២០១០ និង បច្ចុប្បន្នភាពឆ្នាំ២០០៩-២០១៣**

ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ គឺជាឯកសារគោលនយោបាយរួមដែលមានគោលដៅយុទ្ធសាស្ត្រ និងសកម្មភាពជាអាទិភាពរបស់រាជរដ្ឋាភិបាលនៅក្នុងវិស័យនីមួយៗ ជាមួយនឹងទស្សនៈកាត់បន្ថយភាពក្រីក្រ និងសម្រេចបានគោលដៅអភិវឌ្ឍន៍សហស្សវត្សរបស់កម្ពុជា។ ស្របនឹងយុទ្ធសាស្ត្រចតុកោណ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិទទួលស្គាល់ថា **អភិបាលកិច្ចល្អ** គឺជាគន្លឹះសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចសង្គមប្រកបដោយចីរភាព និងសមធម៌។ ផែនការ យុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ក៏ទទួលស្គាល់ផងដែរថា កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ គឺជាមធ្យោបាយសម្រាប់កែលម្អ និងបង្កើនការផ្តល់សេវាសាធារណៈ និងពង្រឹងការអភិវឌ្ឍនៅមូលដ្ឋាន។ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ផ្តោតសារៈសំខាន់ទៅលើការធានាឱ្យមាន**ហិរញ្ញវត្ថុគ្រប់គ្រាន់ និងមានចំណូលផ្ទាល់ខ្លួនសម្រាប់ក្រុមប្រឹក្សាថ្មី** (ផែនការយុទ្ធសាស្ត្រ អភិវឌ្ឍជាតិបច្ចុប្បន្នកម្មឆ្នាំ២០០៩-២០១៣ ទំព័រ១០-១១ និង៤១-៤២) ។

## **ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់**

រាជរដ្ឋាភិបាល **បានចាប់ផ្តើមកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការរបស់ខ្លួននៅថ្នាក់ឃុំ សង្កាត់**។ នៅឆ្នាំ២០០១ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ និងច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវបានអនុម័ត។ ការបោះឆ្នោតនៅឆ្នាំ២០០២ បានបង្កើតឱ្យមានក្រុមប្រឹក្សាឃុំ សង្កាត់នៅទូទាំងប្រទេស។ ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់លើកទីពីរ ត្រូវបានធ្វើឡើងនៅឆ្នាំ២០០៧។

ក្រុមប្រឹក្សាឃុំ សង្កាត់ មាន**តួនាទីពីរយ៉ាង** គឺបម្រើឱ្យកិច្ចការនៅមូលដ្ឋាន ដើម្បីជាប្រយោជន៍ដល់ប្រជាពលរដ្ឋរបស់ខ្លួន និងធ្វើជាភ្នាក់ងាររបស់រដ្ឋ ដោយអនុវត្តមុខងារដែលបានធ្វើប្រតិភូកម្ម។ ក្រុមប្រឹក្សាបានទទួល**ការផ្ទេរមូលនិធិពីថ្នាក់ជាតិ** ដែលតាមរយៈមូលនិធិនេះ ឃុំ សង្កាត់ បានអនុវត្តគម្រោងដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋ ដែលភាគច្រើនជាគម្រោងហេដ្ឋារចនាសម្ព័ន្ធរូបវន្តខ្នាតតូចៗនៅមូលដ្ឋានដែលផ្តួចផ្តើមដោយមូលដ្ឋានផ្ទាល់។

បទពិសោធន៍ និងមេរៀនដែលទទួលបានមកពីការបង្កើតឱ្យមានក្រុមប្រឹក្សាឃុំ សង្កាត់ បានរួមចំណែកចំពោះចក្ខុវិស័យថ្មី និងកាន់តែធំទូលាយរបស់រាជរដ្ឋាភិបាលស្តីពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ដូចដែលបានឆ្លុះបញ្ចាំងនៅក្នុងក្របខ័ណ្ឌយុទ្ធសាស្ត្រស្តីពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ (សូមអានខាងក្រោម) និងច្បាប់ស្តីពី ការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

## ក្របខ័ណ្ឌយុទ្ធសាស្ត្រស្តីពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ខែមិថុនា ឆ្នាំ២០០៥

ក្របខ័ណ្ឌយុទ្ធសាស្ត្រស្តីពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការខែមិថុនា ឆ្នាំ២០០៥ គឺជាឯកសារគន្លឹះនៃគោលនយោបាយរបស់រាជរដ្ឋាភិបាល ដែលគូសបញ្ជាក់ចក្ខុវិស័យសម្រាប់កំណែទម្រង់អភិបាលកិច្ចនៅថ្នាក់ក្រោមជាតិ។ រាជរដ្ឋាភិបាល នឹងបង្កើតប្រព័ន្ធគ្រប់គ្រងនៅថ្នាក់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ដោយឈរលើ "គោលការណ៍នៃការចូលរួមតាមលក្ខណៈប្រជាធិបតេយ្យ" ហើយត្រូវដំណើរការប្រកបដោយតម្លាភាព និងគណនេយ្យភាពដើម្បីជំរុញកិច្ចអភិវឌ្ឍមូលដ្ឋាន និងការផ្តល់សេវាសាធារណៈដើម្បីឆ្លើយតបនឹងតម្រូវការរបស់ប្រជាពលរដ្ឋ ព្រមទាំងការចូលរួមកាត់បន្ថយភាពក្រីក្រនៅក្នុងដែនដីរបស់ខ្លួន (ទំព័រ៦)។

ក្របខ័ណ្ឌយុទ្ធសាស្ត្របញ្ជាក់ថា កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ មានបំណងជំនះការលំបាកមួយចំនួននៅថ្នាក់ក្រោមជាតិ។ ការលំបាកទាំងនោះមាន :

- ប្រព័ន្ធគ្រប់គ្រងនៅថ្នាក់ក្រោមជាតិនាពេលបច្ចុប្បន្នមានលក្ខណៈជាមជ្ឈការ ដោយមន្ទីរវិស័យអនុវត្តគោលនយោបាយ និងផែនការពីក្រសួងសាមីរបស់ខ្លួន
- ការស្ថិតនៅដោយឡែកពីគ្នានេះ ធ្វើអោយការសម្របសម្រួលតាមខ្សែទទឹងនៅថ្នាក់ក្រោមជាតិ ជួបការលំបាកលើមុខងារមួយចំនួន ដោយសារការអនុវត្តនៅថ្នាក់ក្រោមជាតិមានលក្ខណៈត្រួតលើគ្នា ឬមានភាពមិនច្បាស់លាស់ដែលនាំឱ្យមានការលំបាកបន្ថែមទៀតនៅក្នុងការសម្របសម្រួល និងការផ្តល់សេវាសាធារណៈ
- ជាលទ្ធផល ថ្នាក់ក្រោមជាតិមិនអាចរៀបចំផែនការ និងថវិកា ឬគ្រប់គ្រងបុគ្គលិកប្រកបដោយប្រសិទ្ធភាព ឬប្រសិទ្ធផលឡើយ ។

## ក្របខ័ណ្ឌយុទ្ធសាស្ត្រ - គោលដៅយុទ្ធសាស្ត្រចំនួនពីរ

ក្របខ័ណ្ឌយុទ្ធសាស្ត្រ លើកឡើងពីគោលដៅយុទ្ធសាស្ត្រជាទូទៅចំនួនពីរនៅក្នុងកំណែទម្រង់អភិបាលកិច្ចនៅថ្នាក់ក្រោមជាតិគឺ :

- ដើម្បីពង្រឹង និងពង្រីកលទ្ធិប្រជាធិបតេយ្យនៅមូលដ្ឋាន និង
- ការជំរុញកិច្ចអភិវឌ្ឍនៅមូលដ្ឋាន និងរួមចំណែកចំពោះការកាត់បន្ថយភាពក្រីក្រ ( ទំព័រ ៨)

## ក្របខ័ណ្ឌយុទ្ធសាស្ត្រ - ទិសដៅរយៈពេលវែង

ដើម្បីសម្រេចបានការអភិវឌ្ឍដែលមានមូលដ្ឋានធំទូលាយ និងប្រកបដោយចីរភាព និងដើម្បីពង្រឹងមូលដ្ឋានគ្រឹះសេដ្ឋកិច្ចនៅមូលដ្ឋានអោយបានខ្លាំងក្លា ដើម្បីឱ្យប្រជាពលរដ្ឋគ្រប់រូបមានឱកាសស្មើគ្នាក្នុងការចូលរួមនៅក្នុងការអភិវឌ្ឍមូលដ្ឋាន ការគ្រប់គ្រងបរិស្ថាន និងធនធានធម្មជាតិយ៉ាងមានប្រសិទ្ធភាព និងការផ្តល់សេវាប្រកបដោយគុណភាពដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋ និងការកាត់បន្ថយភាពក្រីក្រដោយផ្តោតទៅលើក្រុមជនងាយរងគ្រោះ ជនជាតិដើមភាគតិច ស្ត្រី និងកុមារ( ទំព័រ ១១) ។

## ក្របខ័ណ្ឌយុទ្ធសាស្ត្រ - គោលការណ៍ជាគន្លឹះ

ក្របខ័ណ្ឌយុទ្ធសាស្ត្រចែងថា កំណែទម្រង់ នឹងត្រូវអភិវឌ្ឍដោយផ្អែកលើគោលការណ៍ជាគន្លឹះដូចខាងក្រោម:

- **ភាពជាតំណាងតាមបែបប្រជាធិបតេយ្យ:** តួនាទីរបស់ក្រុមប្រឹក្សាដែលត្រូវបោះឆ្នោតជ្រើសរើសឡើងគ្រប់ថ្នាក់ នឹងត្រូវពង្រឹង និងពង្រីកអនុលោមទៅតាមគោលការណ៍នៃលទ្ធិប្រជាធិបតេយ្យ
- **ការចូលរួមរបស់ប្រជាជន:** ប្រព័ន្ធ និងនីតិវិធី នឹងត្រូវដាក់ឱ្យអនុវត្តដើម្បីធានាឱ្យបានថា ប្រជាពលរដ្ឋអាចចូលរួមនៅក្នុងការធ្វើសេចក្តីសម្រេចចិត្ត (រួមទាំងបុរស និងស្ត្រី និងក្រុមជនងាយរងគ្រោះ ដូចជាជនក្រីក្រ) ។
- **គណនេយ្យភាពនៃវិស័យសាធារណៈ:** កំណែទម្រង់ និងពង្រឹងគណនេយ្យភាពនៅគ្រប់លំដាប់ថ្នាក់រដ្ឋបាល និង សម្រួលការចូលរួមពិនិត្យមើលរបស់ប្រជាពលរដ្ឋក្នុងកិច្ចការរដ្ឋបាល និងហិរញ្ញវត្ថុ ។

- **ប្រសិទ្ធភាព:** ដោយនាំយកសេវាសាធារណៈទៅដាក់ឱ្យនៅជិតនឹងប្រជាពលរដ្ឋ និង បង្កើនឱកាសសម្រាប់ប្រជាពលរដ្ឋចូលរួមនៅក្នុងការធ្វើសេចក្តីសម្រេចចិត្ត មានន័យថាតម្រូវការ និងអាទិភាពនៅមូលដ្ឋានអាចត្រូវ ឆ្លើយតបកាន់តែមានប្រសិទ្ធភាព។
- **រួមចំណែកចំពោះការកាត់បន្ថយភាពក្រីក្រ:** សមត្ថភាពនៅមូលដ្ឋានកាន់តែខ្លាំង អាចគាំទ្រសកម្មភាពកាត់បន្ថយភាពក្រីក្រ ជាពិសេសស្ត្រី ក្រុមជនងាយរងគ្រោះ និងជនជាតិដើមភាគតិច (ទំព័រ ៨ និង ៩)។

## ផ្នែកទី ៥ : ទិដ្ឋភាពសំខាន់ៗ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

# ទិដ្ឋភាពសំខាន់ៗ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលធានី ខេត្ត ក្រុង ស្រុក ខណ្ឌ



**ក្រុមប្រឹក្សាដែលត្រូវបោះឆ្នោតជ្រើសរើសឡើង**

- ✓ ក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ **ត្រូវបោះឆ្នោតជ្រើសរើសឡើង*ជាអសកល*ដោយក្រុមប្រឹក្សាឃុំ សង្កាត់**នៅក្នុងដែនដីរបស់ខ្លួន ( មាត្រា ១៤ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ . មាត្រា ២៧ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា រាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក និង ក្រុមប្រឹក្សាខណ្ឌ)

- ✓ ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាថ្មីលើកដំបូងបានប្រព្រឹត្តទៅនៅខែឧសភា ឆ្នាំ២០០៩។

| |
|---|
| ចំពោះព័ត៌មានបន្ថែមស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា សូមអានមេរៀនទី ១៦ |

- ✓ ក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវបន្តបោះឆ្នោតជ្រើសរើសដោយប្រជាពលរដ្ឋផ្ទាល់ (ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើស ក្រុមប្រឹក្សាឃុំ សង្កាត់ មាត្រា២) ។
- ✓ ក្រុមប្រឹក្សា មាន**អាណត្តិ៥ឆ្នាំ** ( មាត្រា ១៥ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងមាត្រា ១១ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់) ។

- ✓ **ក្រុមប្រឹក្សាដែលត្រូវបោះឆ្នោតជ្រើសរើសឡើងថ្មី ជំនួសរដ្ឋបាលដែលត្រូវតែងតាំង**នៅរាជធានីភ្នំពេញ ខេត្ត ក្រុង ស្រុក និងខណ្ឌ (មាត្រា ២៧៧ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងមាត្រា ៦, ៧ នៃប្រកាសលេខ ១២៤៩ ស្តីការកិច្ចប្រជុំចូលកាន់តំណែង) ។

- ✓ ចាប់ពីខែឧសភា ឆ្នាំ២០០៩ រដ្ឋបាល**គ្រប់ថ្នាក់នៅថ្នាក់ក្រោមជាតិ**នៅកម្ពុជាមានក្រុមប្រឹក្សាដែលត្រូវ**បោះឆ្នោតជ្រើសរើសឡើង** ។ ក្រុមប្រឹក្សាដែលត្រូវបោះឆ្នោតជ្រើសរើសឡើងនីមួយៗ មាន**សិទ្ធិអំណាច មុខងារ និងហិរញ្ញ វត្ថុរបស់ខ្លួនផ្ទាល់**។ នៅក្នុងវិសាលភាពនៃសិទ្ធិអំណាច មុខងារ និងហិរញ្ញវត្ថុរបស់ក្រុមប្រឹក្សា ក្រុមប្រឹក្សា មានឆន្ទានុសិទ្ធិប្រកាន់យកជម្រើស និងធ្វើសេចក្តីសម្រេចក្នុងនាមប្រជាពលរដ្ឋរបស់ខ្លួន។

## ការរៀបចំរដ្ឋបាលដែនដីក្រោមច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ




## ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ

✓ គោលបំណងរបស់ក្រុមប្រឹក្សានីមួយៗ គឺដើម្បីបង្កើត ជំរុញ និង ធ្វើឱ្យមានចីរភាពដល់ការអភិវឌ្ឍបែបប្រជាធិបតេយ្យ ( មាត្រា ២. ១១. ២០ នៃច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ) ។

✓ ការអភិវឌ្ឍបែបប្រជាធិបតេយ្យ **មានតំលៃស្មើគ្នានឹងអភិបាលកិច្ចល្អ** ។ សមាសភាគនៃការអភិវឌ្ឍបែបប្រជាធិបតេយ្យដែលមានចែងនៅក្នុងច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌមានលក្ខណៈដូចគ្នា នឹងគោលការណ៍ជាគន្លឹះនៃអភិបាលកិច្ចល្អ ។

✓ **ការអភិវឌ្ឍបែបប្រជាធិបតេយ្យ** មានសមាសភាគដូចខាងក្រោម:

- **ភាពតំណាងជាសាធារណៈ** ក្រុមប្រឹក្សាតំណាងឱ្យប្រជាពលរដ្ឋរបស់ខ្លួន ហើយបំពេញការងារបំរើឱ្យផលប្រយោជន៍ប្រជាពលរដ្ឋរបស់ខ្លួន ។
- **ស្វ័យភាពរបស់មូលដ្ឋានៈ** ក្រុមប្រឹក្សា មានសិទ្ធិអំណាចគ្រប់គ្រាន់ដើម្បីឆ្លើយតបនឹងតម្រូវការពិតប្រាកដរបស់ប្រជាពលរដ្ឋរបស់ខ្លួន ។

- **ការពិគ្រោះយោបល់ និងការចូលរួម:** ប្រជាពលរដ្ឋទាំងអស់មានឱកាសប្រកបដោយអត្ថន័យ ដើម្បីលើកឡើងពីតម្រូវការផលប្រយោជន៍និងអាទិភាពរបស់ខ្លួន ហើយប្រជាពលរដ្ឋ មានឱកាសប្រកបដោយអត្ថន័យ ដើម្បីចែករំលែកមតិយោបល់របស់ខ្លួនអំពីរបៀបដោះស្រាយតម្រូវការ ផលប្រយោជន៍ និងអាទិភាពទាំងនេះ។ ក្រុមប្រឹក្សានីមួយៗ ត្រូវអភិវឌ្ឍយន្តការ ដើម្បីពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋ របស់ខ្លួន រួមទាំងការចាត់តាំងសមាជិកក្រុមប្រឹក្សាឱ្យបំពេញភារកិច្ចទំនាក់ទំនងជាមួយប្រជាពលរដ្ឋនៅក្នុង ដែនសមត្ថកិច្ចរបស់ខ្លួន (មាត្រា ១៤, ៧០, ១៣២ នៃអនុក្រឹត្យលេខ២១៦)។

> **ទាំងលទ្ធិប្រជាធិបតេយ្យ និង ការអភិវឌ្ឍ គឺជាតំលៃដែលមានចែងនៅក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា**
>
> - **តើលទ្ធិប្រជាធិបតេយ្យមានន័យដូចម្តេចចំពោះអ្នក ?**
> - **តើការអភិវឌ្ឍមានន័យដូចម្តេចចំពោះអ្នក ?**
> - ***ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ* មានន័យដូចម្តេចចំពោះអ្នក ?**

> **គណនេយ្យភាពតាមបែបប្រជាធិបតេយ្យសំដៅលើ**
>
> តំណាងជាប់ឆ្នោតដែលមានគណនេយ្យភាពតាមបែបប្រជាធិបតេយ្យ ប្រកាន់យកជម្រើសផ្អែកលើព័ត៌មាន បែងចែកធនធានដែលខ្លួនមាន និងអនុវត្តភារកិច្ច និងមុខងាររបស់ខ្លួន ដើម្បីជាប្រយោជន៍សាធារណ: និងឆ្លើយតបចំពោះតម្រូវការដែលបានលើកឡើងនៅមូលដ្ឋាន។
>
> មានគណនេយ្យភាពតាមបែបប្រជាធិបតេយ្យ នៅពេលប្រជាជនអាចកំណត់ផលវិបាកទៅលើតំណាងជាប់ឆ្នោតរបស់ខ្លួនចំពោះជម្រើសដែលតំណាងជាប់ឆ្នោតបានប្រកាន់យកចំពោះរបៀបដែលតំណាងជាប់ឆ្នោតបែងចែកធនធានដែលខ្លួនមាន និងចំពោះការអនុវត្តភារកិច្ច និងមុខងាររបស់ខ្លួន។

- **ការឆ្លើយតប និង គណនេយ្យភាព តាមបែបប្រជាធិបតេយ្យ:** ក្រុមប្រឹក្សា ឆ្លើយតបនឹងតម្រូវការផលប្រយោជន៍ និងអាទិភាពរបស់ប្រជាពលរដ្ឋ របស់ខ្លួន។ ក្រុមប្រឹក្សា មានគណនេយ្យភាពចំពោះ សេចក្តីសម្រេចរបស់ខ្លួន និង ផលប៉ះពាល់ នៃសេចក្តីសម្រេចរបស់ខ្លួន។
- **ការលើកស្ទួយសមធម៌ :** ក្រុមប្រឹក្សា ធានាឱ្យបានថា ប្រជាពលរដ្ឋទាំងអស់របស់ខ្លួន រួមទាំងបុរស ស្ត្រី យុវជន ជនក្រីក្រ ជនជាតិដើមភាគតិច មានឱកាស ប្រកបដោយអត្ថន័យដើម្បី *ចូលរួមនៅក្នុងអភិបាលកិច្ចមូលដ្ឋាន* និង *ទទួលបានផលប្រយោជន៍ស្មើគ្នាពី* អភិបាលកិច្ចមូលដ្ឋាន

- **តម្លាភាព និងសុចរិតភាព** - ជាតំណាងរបស់ប្រជាពលរដ្ឋ ក្រុមប្រឹក្សាត្រូវមានតម្លាភាពនៅក្នុងសេចក្តីសម្រេចចិត្ត និងកិច្ចការរបស់ខ្លួន ហើយក្រុមប្រឹក្សាត្រូវបំពេញការងារដោយមានសុចរិតភាពខ្ពស់បំផុត។

- **វិធានការប្រឆាំងអំពើពុករលួយ និងការរំលោភអំណាច**- សមាជិកក្រុមប្រឹក្សា មិនត្រូវមានការពាក់ព័ន្ធនឹងអំពើពុករលួយ ឬការរំលោភអំណាចរបស់ខ្លួនឡើយ ហើយសមាជិកក្រុមប្រឹក្សាត្រូវរាយការណ៍អំពីករណីនៃអំពើពុករលួយ ឬការរំលោភអំណាចនៅក្នុងតំបន់របស់ខ្លួន (មាត្រា ១២, ៤៧ ដល់ ៤៩ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ)។

> ចំពោះព័ត៌មានបន្ថែមស្តីពីការអភិវឌ្ឍបែបប្រជាធិប-តេយ្យ សូមអានមេរៀនទី ២

## អភិបាលកិច្ចនៅជនបទ និងនៅទីប្រជុំជន

✓ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ កំណត់រចនាសម្ព័ន្ធ និងប្រព័ន្ធអភិបាលកិច្ចខុសៗគ្នាសម្រាប់តំបន់ទីប្រជុំជន និងតំបន់ជនបទ។ វិសោធនកម្មរដ្ឋធម្មនុញ្ញ ត្រូវបានអនុម័តលើមាត្រា ១៤៥ និង ១៤៦ នៃរដ្ឋធម្មនុញ្ញដែលកំណត់ភាពខុសគ្នារវាងទីប្រជុំជន និងជនបទ។

✓ នៅរាជធានីភ្នំពេញ មានអភិបាលកិច្ចបីថ្នាក់គឺ រាជធានីភ្នំពេញ ខណ្ឌ និង សង្កាត់ ។ ដើម្បីឱ្យមានការអភិវឌ្ឍដែល មានលក្ខណៈស៊ីសង្វាក់គ្នា និងមានលក្ខណៈឯកភាពគ្នានៅតំបន់ប្រជុំជននៃរាជធានីភ្នំពេញ ខណ្ឌ និង សង្កាត់ ត្រូវ ស្ថិតនៅក្រោមការត្រួតពិនិត្យ និងការគ្រប់គ្រងរបស់ក្រុមប្រឹក្សារាជធានីភ្នំពេញ (មាត្រា ៤ , ១០៦ , ១០៧នៃ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ)។

✓ ខេត្ត ត្រូវចែកចេញជាក្រុងទីប្រជុំជន និងស្រុកជនបទ។ ក្រុង ចែកចេញជាសង្កាត់។ ដើម្បីធានាឱ្យមានការអភិវឌ្ឍដែលមានលក្ខណៈស៊ីសង្វាក់គ្នា និងមានលក្ខណៈឯកភាពគ្នានៅក្នុងក្រុង សង្កាត់ ត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យ និងការគ្រប់គ្រងរបស់ក្រុមប្រឹក្សាក្រុង (មាត្រា ៥, ១១០, ១១១ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ)។

✓ ស្រុក ទោះបីជាភាគច្រើន មានលក្ខណៈជាជនបទក្តី ស្រុកអាចមានសង្កាត់មួយ ឬច្រើនបន្ថែមពីលើឃុំ។ ដូច្នេះ ស្រុក ត្រូវចែកចេញជាឃុំ និងសង្កាត់ ( មាត្រា ៥ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ) ។

✓ តំបន់ទីប្រជុំជន និងតំបន់ជនបទ ត្រូវតែកំណត់ និងបោះព្រំប្រទល់ដែលជាជំហានទីមួយនៅក្នុងការអនុវត្ត បទបញ្ញត្តិនៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ទាក់ទងនឹងអភិបាលកិច្ចនៅជនបទ និងនៅទីប្រជុំជន។ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ប្រមើលមើលថា ព្រំប្រទល់ អាចត្រូវបង្កើតឡើង លុបចេញ ឬកែសម្រួលនៅរាជធានីភ្នំពេញ ខេត្ត ក្រុង ស្រុក ឬ ខណ្ឌ ( មាត្រា ៦ និង ៧នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ) ។

✓ ក្រោមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ទីរួមខេត្តទាំងអស់ ត្រូវបានកំណត់រួចហើយថាជាក្រុង។ ដូចគ្នានេះដែរ តំបន់ប្រជុំជនបន្ថែមមួយចំនួន ត្រូវបានកំណត់ថាជាក្រុង រួមមានក្រុងសួងនៅខេត្ត កំពង់ចាម ក្រុងបាវិតនៅខេត្តស្វាយរៀង និងក្រុងប៉ោយប៉ែតនៅខេត្តបន្ទាយមានជ័យ។

✓ នៅពេលបច្ចុប្បន្ន កម្ពុជាមាន

- រាជធានីភ្នំពេញ
- ២៣ ខេត្ត
- ២៦ ក្រុង
- ១៥៩ ស្រុក
- ៩ ខណ្ឌ
- ១.៤១៤ ឃុំ និង
- ២០៤ សង្កាត់

( អនុក្រឹត្យលេខ ១៨ ស្តីពីចំនួនសមាជិកក្រុមប្រឹក្សា)

## ហេតុអ្វីត្រូវបែងចែករវាងអភិបាលកិច្ចទីប្រជុំជន និងជនបទ?

កម្ពុជាកំពុងមានការរីកចំរើននៅតំបន់ប្រជុំជនយ៉ាងខ្លាំង។ តំបន់ទីប្រជុំជន កំពុងពង្រីកខ្លួនយ៉ាងរហ័សដោយ សារកំណើនប្រជាជន និងចំណាកស្រុកពីជនបទទៅកាន់ទីប្រជុំជន។ ដំណើរការនៃការប្រែក្លាយទៅជាទីប្រជុំជននេះ អាចត្រូវរំពឹងថានឹងមានការកើនឡើងនៅពេលខាងមុខ។

តំបន់ប្រជុំជននីមួយៗ គឺជាតំបន់តាមភូមិសាស្ត្រ សង្គម សេដ្ឋកិច្ច និងនយោបាយ ដោយមានដង់ស៊ីតេប្រជាជនខ្ពស់ និងការប្រាស្រ័យទាក់ទង ព្រមទាំងការពឹងផ្អែកគ្នាទៅវិញទៅមក។ ជាលក្ខណៈសេដ្ឋកិច្ច តំបន់ប្រជុំជន ពឹងផ្អែកលើសកម្មភាពមិនមែនកសិកម្មដែលអាចរួមមានផលិតកម្ម ឧស្សាហកម្ម និងសេវា។ តំបន់ជនបទមាន លក្ខណៈខុសពីនេះដោយទុនសង្គម និងការប្រាស្រ័យទាក់ទងមានការពាក់ព័ន្ធច្រើនជាមួយភូមិ ហើយការពឹងផ្អែកផ្នែក សេដ្ឋកិច្ច មានមូលដ្ឋានជាចម្បងលើកសិកម្ម។

តំបន់ជនបទ និងទីប្រជុំជន មានលក្ខណៈខុសពីគ្នា និងមានតម្រូវការ និងអាទិភាពផ្សេងគ្នា។ ទោះបីជានៅពេលមានតម្រូវការ និងអាទិភាពប្រហាក់ប្រហែលគ្នាក្តី ក៏ត្រូវការឱ្យមានយន្តការខុសគ្នាដើម្បីឆ្លើយតបឱ្យបានសមស្រប។

ដ្យាក្រាមខាងក្រោម បង្ហាញពីតំបន់ប្រជុំជន និងតំបន់ជនបទក្រោមច្បាប់រៀបចំអង្គការ។ តំបន់ប្រជុំជន ត្រូវបាន បង្ហាញជាពណ៌ក្រហម។ ខេត្ត ទោះបីជាមាន**ពណ៌ខ្មៅ**ក្តី ក៏មានផ្នែកទីប្រជុំជន និងជនបទ។




## រដ្ឋបាលឯកភាព

✓ ភ្នំពេញ និងគ្រប់ខេត្ត ក្រុង ស្រុក និងខណ្ឌ មានរដ្ឋបាលឯកភាព ( មាត្រា ២ នៃច្បាប់ស្តីពីការគ្រប់គ្រង រដ្ឋបាល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ)។

✓ រដ្ឋបាលឯកភាព មាន**គោលបំណង**ជាគន្លឹះចំនួនពីរគឺ :

- ដើម្បី**រួមចំណែកចំពោះការសម្រេចបានការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ**
- ដើម្បីពង្រឹងអង្គឯកភាពរបស់រដ្ឋ ដើម្បី**សម្របសម្រួលនូវរាល់សកម្មភាពរដ្ឋបាលសាធារណៈ** នៅក្នុងដែនដីរបស់ខ្លួន (មាត្រា ២ និង ៨ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ)។




**រដ្ឋបាលឯកភាព មានសមាសធាតុដូចខាងក្រោម:**

- ✓ ជាស្នូលកណ្តាលនៃរដ្ឋបាលឯកភាព គឺ**ក្រុមប្រឹក្សាដែលត្រូវបោះឆ្នោតជ្រើសរើសឡើង** ដោយមាន**មុខងារ និង ធន ធានរបស់ខ្លួនផ្ទាល់** និងមាន**សិទ្ធិធ្វើសេចក្តីសម្រេច**សម្រាប់ដែនដីរបស់ខ្លួន (មាត្រា ២៩ ដល់ ៣៤ និងសន្ទានុក្រម នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ) ។
- ✓ គណៈកម្មាធិការរបស់ក្រុមប្រឹក្សា ដែលផ្តល់យោបល់ដល់ក្រុមប្រឹក្សា (មាត្រា ១១៤ និង១១៥ នៃច្បាប់ស្តីពីការ គ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ) ។
- ✓ **គណៈអភិបាល** ដែលត្រូវតែងតាំងឡើង ដោយមានអភិបាលដែលតែងតាំងធ្វើជាប្រធាន ហើយមានការទទួលខុសត្រូវក្នុងការជួយក្រុមប្រឹក្សាឱ្យបំពេញភារកិច្ចរបស់ខ្លួន។ គណៈអភិបាល ក៏ជួយក្រុមប្រឹក្សាឱ្យធ្វើសមាហរណកម្មផែនការ និងថវិការបស់ក្រសួង និងស្ថាប័នរបស់រដ្ឋាភិបាលនៅក្នុងដែនដីរបស់ខ្លួនផងដែរ (មាត្រា ១៥៥ ដល់ ១៧០ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ) ។
- ✓ **អភិបាល**ដែលត្រូវតែងតាំង មានសិទ្ធិអំណាចត្រួតពិនិត្យ សម្របសម្រួល និងដឹកនាំមន្ទីរ អង្គភាពខ្សែបណ្តោយ របស់ក្រសួង និងស្ថាប័នផ្សេងៗរបស់រដ្ឋាភិបាលនៅក្នុងដែនដីរបស់ក្រុមប្រឹក្សា (មាត្រា ១៥៤ នៃច្បាប់ស្តីពីការ គ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ) ។

- ✓ សិទ្ធិអំណាចរបស់**ក្រុមប្រឹក្សាក្នុងការសម្របសម្រួល**ផែនការ និងថវិការបស់ខ្លួនជាមួយផែនការ និងថវិការបស់ក្រសួង និងស្ថាប័នរបស់រដ្ឋាភិបាលដែលផ្តល់សេវានៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន តាមរយៈ **គណៈកម្មាធិការ សម្របសម្រួលបច្ចេកទេស** ( មាត្រា ១២៤ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ) ។
- ✓ លទ្ធភាពរបស់**ក្រុមប្រឹក្សាក្នុងការពិភាក្សា**ជាមួយក្រសួង និងស្ថាប័នរបស់រដ្ឋាភិបាលដែលផ្តល់សេវានៅក្នុងតំបន់ លើអាទិភាព សកម្មភាព និងថវិកា ពិសេសដើម្បីឆ្លើយតបកាន់តែប្រសើរទៅនឹងតម្រូវការរបស់ប្រជាជននៅ មូលដ្ឋាន។
- ✓ **ផែនការអភិវឌ្ឍន៍** និង**ថវិកា**របស់ក្រុមប្រឹក្សា ដែលមានបញ្ចូលសេវា និងសកម្មភាពរបស់ក្រុមប្រឹក្សា រួមជាមួយសេវា និងសកម្មភាពរបស់ក្រសួង និងស្ថាប័នរបស់រដ្ឋាភិបាលដែលដំណើរការនៅក្នុងដែនដីរបស់ក្រុមប្រឹក្សា ( មាត្រា ៣៦, ១២៤, ១៦៦ នៃច្បាប់ស្តីពីការគ្រប់គ្រង រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ) ។

| |
|---|
| ចំពោះព័ត៌មានបន្ថែមស្តីពីរដ្ឋបាលឯកភាព<br>សូមអានមេរៀនទី ៤ |

## អំណាចបញ្ញត្តិ និងអំណាចប្រតិបត្តិ

- ✓ ក្រុមប្រឹក្សា មានអំណាចបញ្ញត្តិ និងអំណាចប្រតិបត្តិ ( មាត្រា ៣០ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ) ។
- ✓ ក្រុមប្រឹក្សា ប្រើប្រាស់អំណាចបញ្ញត្តិរបស់ខ្លួន ដោយការធ្វើ**ដីកា**។ ដីកា គឺជាវិធានខាងផ្លូវច្បាប់ដែលបានអនុម័តដោយក្រុមប្រឹក្សា ហើយដែលត្រូវអនុវត្ត ( មាត្រា ៣២, ៥៣ ដល់ ៦១ នៃច្បាប់ស្តីពីការគ្រប់គ្រង រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ) ។
- ✓ ក្រុមប្រឹក្សា ប្រើប្រាស់សិទ្ធិអំណាចប្រតិបត្តិរបស់ខ្លួនដោយ**ធ្វើសេចក្តីសម្រេច** នៅក្នុងអង្គប្រជុំរបស់ក្រុមប្រឹក្សា ហើយ**ត្រូវធានាថាសេចក្តីសម្រេចរបស់ខ្លួនត្រូវបានអនុវត្ត** ( មាត្រា ៣១ និង ៣៣ នៃច្បាប់ស្តីពីការគ្រប់គ្រង រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ) ។
- ✓ នៅពេលក្រុមប្រឹក្សាអនុវត្តអំណាចបញ្ញត្តិ និងអំណាចប្រតិបត្តិរបស់ខ្លួន ក្រុមប្រឹក្សាប្រកាន់យក**ជម្រើសផ្នែកនយោបាយ**ក្នុងនាមប្រជាពលរដ្ឋរបស់ខ្លួន។ ក្រុមប្រឹក្សា គួរអនុវត្តអំណាចទាំងនេះ បន្ទាប់ពីបានផ្តល់ឱកាសដល់ **ប្រជាពលរដ្ឋ**ឱ្យ**សម្តែង**ទស្សនៈរបស់ខ្លួន និងបន្ទាប់ពីក្រុមប្រឹក្សាបានពិចារណាទស្សនៈទាំងនេះ។

ក្រុមប្រឹក្សា គួរធ្វើសេចក្តីសម្រេចរបស់ខ្លួន ដោយពិចារណាទៅលើសម្លេងរបស់ប្រជាពលរដ្ឋ និង**ភស្តុតាង** ពីទិន្នន័យ ការសិក្សា និងព័ត៌មានអំពីជោគជ័យនិងបរាជ័យពីមុន។ គណៈអភិបាល និងបុគ្គលិករបស់ក្រុមប្រឹក្សា មានតួនាទីផ្តល់ភស្តុតាង នោះដល់ក្រុមប្រឹក្សា ( មាត្រា ២៩, ៨៦, ១៤៧ នៃអនុក្រឹត្យលេខ២១៦ អ.ន.ក្រ.បក ស្តីពីតួនាទី ភារកិច្ច និង ទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក ) ។

✓ នៅពេលក្រុមប្រឹក្សាអនុវត្តអំណាចបញ្ញត្តិ និងអំណាចប្រតិបត្តិរបស់ខ្លួន សមាជិកក្រុមប្រឹក្សា នឹងត្រូវការឱ្យមាន **ឱកាសផ្នែកនយោបាយ** ដើម្បី**វាយតម្លៃ**ចំណុចល្អនៃជំហរខុសៗគ្នា ដើម្បីពិភាក្សា ជជែកវែកញែក និងដើម្បីធ្វើ **សេចក្តីសម្រេច ។**

✓ ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាឃុំ សង្កាត់ មាន**អំណាចដោយឡែករបស់ខ្លួនដើម្បីធ្វើសេចក្តីសម្រេច** ដើម្បីអនុវត្តមុខងាររបស់ខ្លួន និងដើម្បីប្រើប្រាស់ធនធានរបស់ខ្លួនក្នុងការបង្កើតជំរុញ ធ្វើឱ្យមានចីរភាពការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅក្នុងតំបន់របស់ខ្លួន ( មាត្រា ១៧៤ នៃអនុក្រឹត្យលេខ២១៦ អ.ន.ក្រ.បក ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក ) ។

ចំពោះព័ត៌មានបន្ថែមស្តីពីសិទ្ធិអំណាចរបស់ក្រុមប្រឹក្សា សូមអានមេរៀនទី ៥

## មុខងារតាមអាណត្តិទូទៅ

✓ មានការគ្រោងទុកថា ក្រុមប្រឹក្សានឹងមាន**អាណត្តិទូទៅ និងមានមុខងារជាជម្រើស**បន្ថែមពីលើការទទួលបានមុខងារតាមវិស័យជាក់លាក់ ។

✓ **វិសាលភាពនៃអាណត្តិទូទៅ** គឺត្រូវស្ថិតនៅក្រោមក្របខ័ណ្ឌនៃច្បាប់ជាតិ ។ ដូចនេះរដ្ឋបាលថ្នាក់ក្រោមជាតិមាន ស្វ័យភាពដើម្បី:

- ធ្វើការអភិវឌ្ឍ និងចេញសេចក្តីសម្រេចនានាលើកិច្ចការផ្នែកសេដ្ឋកិច្ច និងសង្គមនៅមូលដ្ឋាន
- លើកកម្ពស់ការអភិវឌ្ឍសេដ្ឋកិច្ចនៅមូលដ្ឋាន ដោយមានភាពជាដៃគូជាមួយផ្នែកឯកជន និងអង្គការសង្គម ស៊ីវិលនៅមូលដ្ឋាន។

- រក្សាទុកសេវាការពារផ្នែកសង្គមសម្រាប់ជនក្រីក្រ និងក្រុមជនងាយរងគ្រោះបំផុតនៅក្នុងមូលដ្ឋានរបស់ខ្លួន
- អភិវឌ្ឍ និងថែទាំហេដ្ឋារចនាសម្ព័ន្ធ ដែលមិនត្រូវបានចាត់ទុកថាជាការទទួលខុសត្រូវដោយឡែករបស់ទីភ្នាក់ងារផ្សេងទៀតនិង
- អនុវត្តភារកិច្ចផ្សេងទៀតដូចជាច្បាប់ និងគោលនយោបាយរបស់ជាតិជាប្រយោជន៍ផ្នែកសុខុមាលភាពរបស់សហគមន៍របស់ខ្លួន។

✓ ក្រុមប្រឹក្សា នឹងមាន**ស្វ័យភាព**នៅក្នុងការអនុវត្តមុខងារតាមអាណត្តិជាទូទៅទាំងនេះ អនុលោមទៅតាមការកំណត់នៅក្នុងរដ្ឋធម្មនុញ្ញ ច្បាប់ និងលិខិតបទដ្ឋានជាធរមានផ្សេងទៀត។

✓ ក្រុមប្រឹក្សា នឹងតម្រូវឱ្យមាន**មូលនិធិឆន្ទានុសិទ្ធិ (មូលនិធិផ្ទេរគ្មានភ្ជាប់លក្ខខណ្ឌ)** ដើម្បីមានលទ្ធភាពអនុវត្តមុខងារទាំងនេះ។

## មុខងាររដ្ឋបាល និង មុខងារតាមវិស័យ

✓ បន្ទាប់ពីការបោះឆ្នោត ក្រុមប្រឹក្សាថ្មី ត្រូវជំនួសរដ្ឋបាលដែលត្រូវតែងតាំងនៅក្នុងដែនដីរបស់ខ្លួន។ ក្រុមប្រឹក្សា និង គណៈអភិបាល **នឹងជំនួសមុខងាររបស់អភិបាល** ដែលត្រូវតែងតាំងនៅមុនពេលបោះឆ្នោតជ្រើសរើស របស់ក្រុមប្រឹក្សា។ ក្រៅពីនេះ **បុគ្គលិកដែលកំពុងបំពេញការងារនៅក្នុងអង្គភាពរដ្ឋបាល**រាជធានីភ្នំពេញ ខេត្ត ក្រុង ស្រុក និង ខណ្ឌ **នឹងត្រូវរៀបចំជាថ្មី**ដល់ក្រុមប្រឹក្សាដែលជាប់ឆ្នោតថ្មី (មាត្រា ២៧៧, ២៧៨, ២៨១ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មាត្រា ៦, ៧ នៃប្រកាសលេខ ១២៤៩ ស្តីពីកិច្ច ប្រជុំចូលកាន់តំណែង មាត្រា ២០៦ នៃអនុក្រឹត្យលេខ២១៦ អ.ន.ក្រ.បក ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនង ការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាល ស្រុក)។

✓ នៅពេលខាងមុខ ក្រុមប្រឹក្សារាជធានីភ្នំពេញ ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក និងក្រុមប្រឹក្សាឃុំនឹងទទួលបានមុខងារតាមវិស័យជាក់លាក់ដើម្បីអនុវត្ត។

ចំពោះព័ត៌មានបន្ថែមអំពីការផ្ទេរមុខងារ សូមអានមេរៀនទី ១៣

នៅពេលក្រុមប្រឹក្សាទទួល**មុខងារ** ក្រុមប្រឹក្សាទាំងនេះក៏នឹងទទួលបាន**ហិរញ្ញវត្ថុ** **បុគ្គលិក** និង**ទ្រព្យសម្បត្តិ** ចាំបាច់ផងដែរដើម្បីអនុវត្តមុខងារនោះ ( មាត្រា ២៩, ២១៣, ២១៤, ២១៧, ២២០, ២២២ ដល់ ២៧៣ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ) ។

**ឧទាហរណ៍ ៖ មុខងារវិស័យអប់រំ**

អាចមានការប្រមើលមើលថា ក្រុមប្រឹក្សានឹងទទួលបានមុខងារឱ្យ*បង្កើត និងប្រតិបត្តិសាលាមត្តេយ្យ*។ ប្រសិនបើមុខងារនោះ ត្រូវបានផ្ទេរឱ្យក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សានៅថ្នាក់នេះក៏ទទួលបានផងដែរនូវ៖

- *ហិរញ្ញវត្ថុ* ដើម្បីបង្កើត និងដំណើរការសាលាមត្តេយ្យជាប្រចាំ
- *បុគ្គលិក ដូចជាគ្រូសាលាមត្តេយ្យដែលមានស្រាប់*
- *ទ្រព្យសម្បត្តិដែលពាក់ព័ន្ធនឹងសាលាមត្តេយ្យដូចជា ឧបករណ៍បង្រៀន របស់របរក្មេងលេង និងប្រហែលជាអាគារសាលាមត្តេយ្យដែលមានស្រាប់ផងដែរ ។*

## វិមជ្ឈការសារពើពន្ធ –

- ✓ ប្រសិនបើប្រគល់មុខងារអោយក្រុមប្រឹក្សាអនុវត្តដោយមិនមានហិរញ្ញវត្ថុអមជាមួយ គឺគ្មានន័យអ្វីឡើយ។ ការ មិនមានធនធានគ្រប់គ្រាន់ និងមានឆន្ទានុសិទ្ធិ ក្រុមប្រឹក្សានឹងមិនអាចអនុវត្ត**ឆន្ទានុសិទ្ធិ**ចាំបាច់ ដើម្បីធ្វើ សេចក្តីសម្រេចដែលឆ្លើយតបទៅនឹងតម្រូវការពិតប្រាកដរបស់ប្រជាពលរដ្ឋខ្លួនឡើយ។

- ✓ ដូច្នេះ ក្រុមប្រឹក្សាទាំងអស់ត្រូវមានធនធានហិរញ្ញវត្ថុដើម្បីអនុវត្តមុខងារ ភារកិច្ចតាមច្បាប់ និងសម្រាប់ ទូទាត់ ការចំណាយផ្នែករដ្ឋបាលរបស់ខ្លួន។ ក្រៅពីនេះ ក្រុមប្រឹក្សាត្រូវមានមូលនិធិគ្រប់គ្រាន់ ដើម្បីអនុវត្ត សកម្មភាព ដែលឆ្លើយតបទៅនឹងតម្រូវការពិតប្រាកដនៅមូលដ្ឋាន និង**អនុវត្តមុខងារ និងភារកិច្ចសម្រាប់ ជំរុញដល់ការ អភិវឌ្ឍតាមបែបប្រជាធិបតេយ្យ** (មាត្រា ២៤២ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ)។

- ✓ ក្រុមប្រឹក្សារាជធានីភ្នំពេញ និងក្រុមប្រឹក្សាខេត្ត ក្រុង និងស្រុកទាំងអស់ (ប៉ុន្តែមិនមែនក្រុមប្រឹក្សាខណ្ឌ) មាន **ថវិកាផ្ទាល់**របស់ខ្លួន ហើយមានលទ្ធភាពទទួលបាន**ប្រាក់ចំណូលពីរប្រភេទយ៉ាងសំខាន់គឺ:**

> កិច្ចការទាក់ទងនឹងវិមជ្ឈការសារពើពន្ធ និងការគ្រប់គ្រងហិរញ្ញវត្ថុ ត្រូវកំណត់ដោយច្បាប់ និងលិខិតបទដ្ឋាន។
>
> ជាការសំខាន់ដែលត្រូវមើលខ្លឹមសារនៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ គឺដើម្បីឱ្យមានភាពខុសគ្នាពិតប្រាកដនៅក្នុងជីវភាពប្រជាពលរដ្ឋរបស់ខ្លួន ក្រុមប្រឹក្សាត្រូវមាន**ហិរញ្ញវត្ថុគ្រប់គ្រាន់ ពីការផ្ទេររបស់ជាតិ** និងពី**ចំណូលរបស់ខ្លួនផ្ទាល់** (ផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិឆ្នាំ ២០០៩-២០១៣ ទំព័រ ៤១ និង៤២)។

  - **ប្រភពចំណូលនៅមូលដ្ឋាន** រួមមានពន្ធនៅមូលដ្ឋាន ឈ្នួល កម្រៃ សេវា និងចំណូលមិនមែនសារពើព័ន្ធផ្សេងទៀត (ដែលនឹងត្រូវកំណត់ដោយច្បាប់ និងលិខិតបទដ្ឋានបន្ថែម)
  - **ប្រភពចំណូលពីថ្នាក់ជាតិ** រួមមាន ចំណូលដែលត្រូវចែករំលែកជាមួយក្រុមប្រឹក្សា និង មូលនិធិផ្ទេរពីថវិការដ្ឋព្រមទាំងថ្លៃសេវាបានមកពីមុខងារដែលអនុវត្តដោយក្រុមប្រឹក្សាក្នុងនាមក្រសួងស្ថាប័នរបស់រាជរដ្ឋាភិបាល (ក៏នឹងកំណត់ដោយច្បាប់ និងលិខិតបទដ្ឋានបន្ថែមទៀតផងដែរ) (មាត្រា ២៤៤,២៤៦ ដល់ ២៥១ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ)។

- ✓ ក្រុមប្រឹក្សាខណ្ឌ ទទួល**ចរិកា**របស់ខ្លួនពីក្រុមប្រឹក្សារាជធានីភ្នំពេញ។ ក្រុមប្រឹក្សាសង្កាត់នៅរាជធានីភ្នំពេញ ឬនៅក្នុងក្រុង ទទួលចរិការបស់ខ្លួនពីក្រុមប្រឹក្សារាជធានី ឬពីក្រុមប្រឹក្សាក្រុង (មាត្រា ៤៤, ២៤៤ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ)។

> ចំពោះព័ត៌មានបន្ថែមអំពីហិរញ្ញវត្ថុរបស់ក្រុមប្រឹក្សា សូមអានមេរៀនទី ១៥

- ✓ ក្រុមប្រឹក្សាឃុំ និងក្រុមប្រឹក្សាសង្កាត់នៅក្នុងស្រុកបន្តមាន**ចរិកា**របស់ខ្លួនផ្ទាល់ ដូចមានចែងនៅក្នុងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ (ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ មាត្រា ៧៣)។

*ច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលនៅថ្នាក់ក្រោមជាតិ* នឹងត្រូវអនុម័ត ដើម្បីដោះស្រាយទិដ្ឋភាពជាច្រើននៃវិមជ្ឈការសារពើពន្ធ និងការគ្រប់គ្រងហិរញ្ញវត្ថុ (មាត្រា ៤៤-៤៦, ១៣៧, ២៤៤, ២៤៥, ២៤៨, ២៥៣, ២៥៥ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ)។


ការចាត់ចែងផ្នែករដ្ឋបាលថ្មី
រាជធានីភ្នំពេញ
ក្រុមប្រឹក្សា
មានមុខងារ ហិរញ្ញវត្ថុ/ថវិកា
បុគ្គលិក និង ទ្រព្យសម្បត្តិរបស់ខ្លួន
(រដ្ឋបាលឯកភាព)
ខេត្ត
ក្រុមប្រឹក្សា
មានមុខងារ ហិរញ្ញវត្ថុ/ថវិកា
បុគ្គលិក និង ទ្រព្យសម្បត្តិរបស់ខ្លួន
(រដ្ឋបាលឯកភាព)
ខណ្ឌ
ក្រុមប្រឹក្សា
មិនមានមុខងារ ហិរញ្ញវត្ថុ/ថវិកា
បុគ្គលិក និង ទ្រព្យសម្បត្តិរបស់ខ្លួន
(ត្រូវប្រតិភូកម្មដោយភ្នំពេញ)
ក្រុង
ក្រុមប្រឹក្សា
មានមុខងារ ហិរញ្ញវត្ថុ/ថវិកា
បុគ្គលិក និង ទ្រព្យសម្បត្តិរបស់ខ្លួន
(រដ្ឋបាលឯកភាព)
ស្រុក
ក្រុមប្រឹក្សា
មានមុខងារ ហិរញ្ញវត្ថុ/ថវិកា
បុគ្គលិក និង
ទ្រព្យសម្បត្តិរបស់ខ្លួន
(រដ្ឋបាលឯកភាព)
បោះឆ្នោតអសកល
បោះឆ្នោតអសកល
បោះឆ្នោតអសកល
បោះឆ្នោតអសកល
បោះឆ្នោតអសកល
បោះឆ្នោតអសកល
សង្កាត់
ក្រុមប្រឹក្សា
មិនមានមុខងារ ហិរញ្ញវត្ថុ/ថវិកា
បុគ្គលិក និង ទ្រព្យសម្បត្តិរបស់ខ្លួន
(ត្រូវប្រតិភូកម្មដោយភ្នំពេញ)
សង្កាត់
ក្រុមប្រឹក្សា
មិនមានមុខងារ ហិរញ្ញវត្ថុ/ថវិកា បុគ្គលិក
និង ទ្រព្យសម្បត្តិរបស់ខ្លួន
(ត្រូវប្រតិភូកម្មដោយក្រុមប្រឹក្សាក្រុង)
ឃុំ
ក្រុមប្រឹក្សា
មានមុខងារ ហិរញ្ញវត្ថុ/ថវិកា បុគ្គលិក
និង ទ្រព្យសម្បត្តិរបស់ខ្លួន តាមច្បាប់ឃុំ
និង ច្បាប់អង្គការ
សង្កាត់
ក្រុមប្រឹក្សា
មានមុខងារ ហិរញ្ញវត្ថុ/ថវិកា
បុគ្គលិក និង ទ្រព្យសម្បត្តិរបស់ខ្លួន
តាមច្បាប់ឃុំ
បោះឆ្នោតសកល
ប្រជាពលរដ្ឋ

## ទស្សនៈមួយទៀត៖ ដ្យាក្រាមមិនតាមឋានានុក្រមរបស់ក្រុមប្រឹក្សា

ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាឃុំ និងក្រុមប្រឹក្សាសង្កាត់ **មានអំណាចដោយ ខ្សែរបស់ខ្លួនផ្ទាល់ ដើម្បីធ្វើសេចក្តីសម្រេច** ដើម្បីអនុវត្តមុខងាររបស់ខ្លួន និងដើម្បីប្រើប្រាស់ធនធានរបស់ខ្លួនក្នុងការ បង្កើត ជំរុញ និងធ្វើឱ្យមានចីរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅក្នុងដែនដីរបស់ខ្លួន។

**ស្វ័យភាព ឱកាសធ្វើសេចក្តីសម្រេច និងឱកាសផ្នែកនយោបាយ និងឱកាសផ្នែកឆន្ទានុសិទ្ធិរបស់ក្រុមប្រឹក្សាទាំងអស់ ត្រូវតែទទួលបានការគោរព។ ដរាបណាក្រុមប្រឹក្សា** គោរពទៅតាមរដ្ឋធម្មនុញ្ញ ច្បាប់ និងលិខិតបទដ្ឋានជា ធរមាននានា គ្មានអ្នកណាម្នាក់អាចជ្រៀតជ្រែកទៅលើអាទិភាព ជម្រើស គោលនយោបាយ សេចក្តីសម្រេច ឬ ដីកា របស់ក្រុមប្រឹក្សាបានឡើយ (មាត្រា ១៧៤ នៃអនុក្រឹត្យស្តីលេខ២១៦ អ.ន.ក្រ.បក ស្តីពីតួនាទី ភារកិច្ច និងទំនាក់ ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាល ស្រុក)។

ដូច្នេះ ដ្យាក្រាមខាងក្រោម ផ្តល់**ទស្សនៈមិនតាមឋានានុក្រម**អំពីក្រុមប្រឹក្សានៅថ្នាក់ក្រោមជាតិ។



# ជនគ្រប់រូបនៅប្រទេសកម្ពុជា រស់នៅក្នុងដែនសមត្ថកិច្ចបួនប្រភេទខុសគ្នា

អ្នកដែលរស់នៅក្នុងតំបន់ជនបទនៃខេត្តមួយ គឺរស់នៅក្នុង

- ឃុំ
- ស្រុក
- ខេត្ត និង
- កម្ពុជា

អ្នកដែលរស់នៅក្នុងរាជធានីភ្នំពេញ គឺរស់នៅក្នុង

- សង្កាត់
- ខណ្ឌ
- ភ្នំពេញ និង
- កម្ពុជា

អ្នកដែលរស់នៅក្នុងតំបន់ប្រជុំជននៃខេត្តមួយ គឺរស់នៅក្នុង

- សង្កាត់
- ក្រុង
- ខេត្ត និង
- កម្ពុជា




ប្រជាពលរដ្ឋ

នៃឃុំគគីរ

ស្រុកកៀនស្វាយ

ខេត្តកណ្ដាល

ព្រះរាជាណាចក្រកម្ពុជា

## វគ្គទី ២:

## សង្ខេបមេរៀន

- កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ គឺជាយុទ្ធសាស្ត្រ ដើម្បីលើកកម្ពស់អភិបាលកិច្ចល្អ និងរួមចំណែកចំពោះកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាពសម្រាប់ប្រជាជនកម្ពុជា ។
- ៧០%នៃរដ្ឋទាំងអស់ មានរចនាសម្ព័ន្ធបែបវិមជ្ឈការ
- ឯកសារគោលនយោបាយភាគច្រើនរបស់កម្ពុជា មានលក្ខណៈស៊ីសង្វាក់គ្នា គឺអភិបាលកិច្ចល្អ/ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ គឺជាបុរេល័ក្ខខ័ណ្ឌយ៉ាងសំខាន់បំផុតសម្រាប់កំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព។ កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ គឺជាយុទ្ធសាស្ត្រមួយដើម្បីលើកកម្ពស់អភិបាលកិច្ចល្អ/ការអភិវឌ្ឍបែបប្រជាធិបតេយ្យ ។
- ទិដ្ឋភាពសំខាន់ៗ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ រួមមាន
    - ក្រុមប្រឹក្សាដែលត្រូវបោះឆ្នោតជ្រើសរើសឡើង
    - ការអភិវឌ្ឍបែបប្រជាធិបតេយ្យ
    - អភិបាលកិច្ចនៅជនបទ និងនៅទីប្រជុំជន
    - រដ្ឋបាលឯកភាព
    - អំណាចបញ្ញត្តិ និងអំណាចប្រតិបត្តិរបស់ក្រុមប្រឹក្សា
    - មុខងារតាមវិស័យ
    - វិមជ្ឈការហិរញ្ញវត្ថុ

## វគ្គទី ៣៖

## ឯកសារពិគ្រោះ

1. យុទ្ធសាស្ត្រចតុកោណសម្រាប់កំណើនការងារ សមធម៌ និងប្រសិទ្ធភាព ឆ្នាំ២០០៤
2. សុន្ទរកថារបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ស្តីពីយុទ្ធសាស្ត្រចតុកោណសម្រាប់កំណើនការងារ សមធម៌ និងប្រសិទ្ធភាពដំណាក់កាលទីពីរនៅក្នុងកិច្ចប្រជុំលើកទីមួយរបស់គណៈរដ្ឋមន្ត្រីសម្រាប់នីតិកាលទី៤ នៃ រដ្ឋសភា (ខែ កញ្ញា ឆ្នាំ ២០០៨)
3. ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ២០០៦-២០១០
4. ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្មឆ្នាំ២០០៩-២០១៣
5. ក្របខ័ណ្ឌយុទ្ធសាស្ត្រស្តីពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការឆ្នាំ២០០៥
6. ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
7. ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
8. ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានីភ្នំពេញ ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក និង ក្រុមប្រឹក្សាខណ្ឌ
9. ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ វិសោធនកម្មឆ្នាំ២០០៦
10. អភិបាលកិច្ចល្អសម្រាប់សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ ឆ្នាំ២០០៥។

## វគ្គទី ៤:

## ការងារជាក្រុម

**ការងារជាក្រុម ដូចមានពិពណ៌នាខាងក្រោម អាចមានលក្ខណៈមិនសមស្របសម្រាប់ការបណ្តុះបណ្តាលទាំងអស់ ។ សូមចាត់ទុកការងារជាក្រុមខាងក្រោមជាសំណូមពរតែប៉ុណ្ណោះ ។**

១. ចែកសិក្ខាកាមជាក្រុមដែលមានសមាជិកមិនលើសពី ៨ នាក់

២. ផ្តល់លំហាត់ខាងក្រោមអោយក្រុមនីមួយៗ ។

**លំហាត់ទីមួយ: ការអភិវឌ្ឍបែបប្រជាធិបតេយ្យ**

លទ្ធិប្រជាធិបតេយ្យ និង ការអភិវឌ្ឍ គឺជាតំលៃទាំងពីរដែលមានចែងនៅក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ។

**ពិភាក្សានៅក្នុងក្រុមតូចៗ :**

- តើ "លទ្ធិប្រជាធិបតេយ្យ" មានន័យដូចម្តេចសម្រាប់អ្នក ?
- តើ "ការអភិវឌ្ឍ" មានន័យដូចម្តេចសម្រាប់អ្នក?
- តើ "ការអភិវឌ្ឍបែបប្រជាធិបតេយ្យ" មានន័យដូចម្តេចសម្រាប់អ្នក ?

**លំហាត់ទីពីរ : ការឆ្លើយតប និង គណនេយ្យភាព**

ខ្យល់ព្យុះយ៉ាងខ្លាំងបានប៉ះទង្គិចមកលើស្រុក **មេភ្លៀង** ។ ខ្យល់ព្យុះនេះ បានធ្វើឱ្យស្ពានបាក់ ។ ស្ពាននេះមានសារៈសំខាន់ណាស់ចំពោះអាយុជីវិតសេដ្ឋកិច្ចរបស់ស្រុក ពីព្រោះវាភ្ជាប់ស្រុកទៅនឹងផ្សារដ៏ធំនៅខេត្ត។ ក្រៅពីនេះ ដំណាំស្រូវរបស់គ្រួសារជាច្រើនសម្រាប់ឆ្នាំនេះ ត្រូវបានបំផ្លាញទាំងស្រុង។ ខ្យល់ព្យុះ ក៏ធ្វើអោយខូចច្រាំងទន្លេផងដែរ ។ ការខូចនេះ ធ្វើឱ្យផ្ទះចំនួន ១៥០ ខ្នង ធ្លាក់ចូលទៅក្នុងទន្លេ ។ នៅពេលនេះ គ្រួសារខ្លះ

កំពុងរស់នៅជាមួយបងប្អូន និង មិត្តភ័ក្រ្ត ប៉ុន្តែគ្រួសារខ្លះទៀត មិនមានកន្លែងស្នាក់នៅឡើយ ។ ក្រុមប្រឹក្សាស្រុក **មេភ្លៀង** មិនមានមូលនិធិគ្រប់ គ្រាន់ ឬ មិនមានលទ្ធភាពទទួលបានមូលនិធិគ្រប់គ្រាន់ ដើម្បីជួសជុលស្ពាន ជួសជុលច្រាំងទន្លេ និង ដើម្បីជួយគ្រួសារ ដែលទទួលផលប៉ះពាល់ជាខ្លាំងពីខ្យល់ព្យុះ ។

រៀបចំការដើរតួមិនឱ្យលើសពី ១៥ នាទី ។ ការដើរតួពាក់ព័ន្ធនឹងការប្រជុំរបស់ក្រុមប្រឹក្សាស្រុក ។

តួអង្គ គួរមាន

- ប្រធានក្រុមប្រឹក្សាស្រុក ដែលយល់ថា ការជួសជុលស្ពាន គួរតែជាអាទិភាព
- សមាជិកក្រុមប្រឹក្សាស្រុកម្នាក់ដែលយល់ថា គ្រួសារដែលដំណាំស្រូវរបស់គាត់ ត្រូវបានបំផ្លាញ គួរទទួលបានការជួយជ្រោមជ្រែងជាអាទិភាព
- សមាជិកក្រុមប្រឹក្សាស្រុកម្នាក់ដែលយល់ថា គ្រួសារដែលគ្មានផ្ទះសម្បែង គួរទទួលបានការជួយជ្រោមជ្រែងជាមុន
- តំណាងគ្រួសារដែលដំណាំស្រូវរបស់គាត់ ត្រូវបានបំផ្លាញ
- តំណាងគ្រួសារដែលបាត់បង់ផ្ទះសំបែង ហើយគ្មានកន្លែងរស់នៅ
- តំណាងគ្រួសារដែលប្រើប្រាស់ស្ពាន ដើម្បីលក់ឥវ៉ាន់របស់ខ្លួននៅផ្សារក្នុងខេត្ត

ក្រុមប្រឹក្សា ត្រូវប្រជុំ ដើម្បីសំរេចអំពីរបៀបដែលខ្លួនចំណាយមូលនិធិដ៏មានកំរិតរបស់ខ្លួន ។ (សូមចាំថា ក្រុមប្រឹក្សាមិនមានមូលនិធិគ្រប់គ្រាន់ ដើម្បីដោះស្រាយបញ្ហាទាំងអស់ ឬ ដើម្បីជួយប្រជាជនទាំងអស់ឡើយ) ។ ប្រជាពលរដ្ឋ ត្រូវមានឱកាស ដើម្បីបញ្ជាក់តម្រូវការ និង ជំហររបស់ខ្លួននៅក្នុងអង្គប្រជុំ ។

**លំហាត់ទីបី: តម្លាភាព**

ពិភាក្សាសំណួរខាងក្រោមនៅក្នុងក្រុមរបស់អ្នក

- ហេតុអ្វីបានជាអ្នកគិតថា តម្លាភាព មានសារៈសំខាន់ចំពោះប្រជាពលរដ្ឋ?
- តើតម្លាភាព និង គណនេយ្យភាព មានទំនាក់ទំនងគ្នាដូចម្តេច?
- តើមធ្យោបាយដែលមានការច្នៃប្រឌិតមួយចំនួន ដើម្បីអោយក្រុមប្រឹក្សាខេត្ត ផ្សព្វផ្សាយព័ត៌មានដល់ប្រជាពលរដ្ឋរបស់ខ្លួន មានអ្វីខ្លះ? (ក្រៅពីការបិទផ្សាយព័ត៌មាននៅលើក្តារព័ត៌មាន)
- តើវិធីជាក់លាក់អ្វីខ្លះ ដើម្បីធានាឱ្យបានថា ព័ត៌មានពីក្រុមប្រឹក្សាស្រុក *ពិតជាត្រូវបានទទួល* ដោយស្ត្រី? យុវជន? ជនក្រីក្រ? ជនជាតិភាគតិច?

# មេរៀនសម្រាប់ការយល់ដឹង និង ការបណ្តុះបណ្តាលអំពី ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

## មេរៀនទី ២

## ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ

## វគ្គទី ១

១. សេចក្តីផ្តើម

២. និយមន័យ និងគោលការណ៍នៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ

៣. ការចូលរួម និងតម្លាភាពនៅក្នុងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

៤. គណនេយ្យភាព និងការឆ្លើយតបនៅក្នុងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

៥. សមធម៌នៅក្នុងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

## ផ្នែកទី ១: សេចក្ដីផ្ដើម

របៀបវារៈគោលនយោបាយរបស់រាជរដ្ឋាភិបាលសម្រាប់ឆ្នាំ២០០៩ ដល់ឆ្នាំ២០១៤ មានបញ្ជាក់នៅក្នុងយុទ្ធសាស្ត្រចតុកោណសម្រាប់កំណើនការងារ សមធម៌ និងប្រសិទ្ធភាព ដំណាក់កាលទីពីរ។ ស្នូលកណ្ដាលនៃយុទ្ធ-សាស្ត្រចតុកោណ គឺអភិបាលកិច្ចល្អ ឬក៏អាចហៅថាជាការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យដែលត្រូវបានទទួលស្គាល់ថាជាបុរេល័ក្ខខ័ណ្ឌសំខាន់បំផុតសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយចីរភាព សមធម៌ និងយុត្តិធម៌។ យុទ្ធ-សាស្ត្រចតុកោណចែងថា ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ **ពាក់ព័ន្ធនឹងការចូលរួមយ៉ាងទូលំទូលាយ លើកកម្ពស់ការចែករំលែកព័ត៌មាន តម្លាភាព សមភាព សាមគ្គីភាព នីតិរដ្ឋ** និង**គណនេយ្យភាព**។

ដើម្បីសម្រេចបានការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ យុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលផ្ដោតការយកចិត្តទុកដាក់ទៅលើកំណែទម្រង់នៅក្នុងវិស័យចំនួនបួនគឺ ការប្រយុទ្ធប្រឆាំងអំពើពុករលួយ កំណែទម្រង់ប្រព័ន្ធច្បាប់ និងតុលាការ កំណែទម្រង់រដ្ឋបាលសាធារណៈ និងកំណែទម្រង់កងកំលាំងប្រដាប់អាវុធ។ នៅក្នុងវិស័យកំណែទម្រង់រដ្ឋបាលសាធារណៈ រាជរដ្ឋាភិបាលទទួលស្គាល់វិមជ្ឈការថាមានសារៈសំខាន់ជាសារវ័ន្តចំពោះ**ការពង្រឹងលទ្ធិប្រជាធិបតេយ្យ** ហើយនៅក្នុងវិស័យមួយចំនួន **ចំពោះការកែលម្អគុណភាពនៃសេវាសាធារណៈ** និង**ការអភិវឌ្ឍមូលដ្ឋានដោយមានការចូលរួម**។

ច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌបានដាក់បញ្ចូលការអភិវឌ្ឍតាមបែបប្រជា-ធិបតេយ្យជាគោលការណ៍យ៉ាងសំខាន់មួយដែលជាមូលដ្ឋានគ្រឹះរបស់ច្បាប់។ សារៈសំខាន់នៃគោលការណ៍ជាគន្លឹះនេះត្រូវបានរំលេចនៅក្នុង**មាត្រាជាច្រើន** ដែលលើកឡើងពីការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ (មាត្រា ២, ១១, ១២, ២០, ៣៤, ៤២, ៩៦, ៩៧, ៩៩, ១០១, ១០៣, ១០៦, ១០៨, ១១០, ១១២, ២១៣, ២២៥, ២៤១, ២៥១ នៃច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ)។ សារៈសំខាន់នៃគោលការណ៍ជាគន្លឹះនេះ ក៏ត្រូវបានឆ្លុះបញ្ចាំងផងដែរ នៅក្នុងដំណើរការរបស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប)។ ក្រៅពីនេះ លិខិតបទដ្ឋាននានាដែលត្រូវបានដាក់ចេញក្រោមច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ បានបកស្រាយពីសារៈសំខាន់នៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ ហើយបានកំណត់យន្តការដើម្បីធានាថា ការអភិវឌ្ឍនេះសម្រេចទៅបាន។ ដូច្នេះជាការសំខាន់ណាស់ដែលត្រូវយល់ឱ្យច្បាស់អំពីការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ។

ប្រធានបទនៃមេរៀននេះ បញ្ជាក់អំពីរបៀបដែលច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដាក់បញ្ចូលគោលការណ៍នៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ។

## ផ្នែកទី ២: គោលការណ៍នៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ

**ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ**

**មាត្រា ២, ១១, ២០, ៤៧-៤៩**

✓ **ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ និងអភិបាលកិច្ចល្អ សំដៅលើស្ថាប័ននយោបាយដែលមានប្រសិទ្ធភាព និងការប្រើប្រាស់ដោយមានការទទួលខុសត្រូវលើអំណាចនយោបាយ និងការគ្រប់គ្រងធនធានសាធារណៈដោយរដ្ឋ** ដើម្បីជាប្រយោជន៍ដល់ប្រជាពលរដ្ឋ និងក្នុងនាមប្រជាពលរដ្ឋរបស់ខ្លួន។

✓ គោលបំណងរបស់ក្រុមប្រឹក្សា គឺដើម្បីបង្កើត ជំរុញ និងធ្វើឱ្យមានចីរភាពការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ (មាត្រា ២, ១១, ២០ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ)។

✓ ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ មានសមាសភាគខាងក្រោម:

> គ្រប់ក្រុមប្រឹក្សា គឺជាតំណាងសាធារណៈ ជាអ្នកការពារ និងជាអ្នកបម្រើផលប្រយោជន៍របស់ប្រជាពលរដ្ឋទាំងអស់នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន (មាត្រា ៦, ៦១, ១១៣នៃអនុក្រឹត្យលេខ២១៦ អ.ន.ក្រ.បក ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក)។

- **ភាពតំណាងជាសាធារណៈ** - ក្រុមប្រឹក្សាតំណាងឱ្យប្រជាពលរដ្ឋរបស់ខ្លួនហើយបំពេញការងារបម្រើឱ្យផលប្រយោជន៍ប្រជាពលរដ្ឋរបស់ខ្លួន។
- **ស្វ័យភាពរបស់មូលដ្ឋាន**-ក្រុមប្រឹក្សា មានសិទ្ធិអំណាចគ្រប់គ្រាន់ ដើម្បីឆ្លើយតបទៅនឹងតម្រូវការពិតប្រាកដរបស់ប្រជាពលរដ្ឋរបស់ខ្លួន។
- **ការពិគ្រោះយោបល់ និងការចូលរួម**- ប្រជាពលរដ្ឋទាំងអស់ មានឱកាសប្រកបដោយអត្ថន័យដើម្បីលើកឡើងពីតម្រូវការផលប្រយោជន៍ និងអាទិភាពរបស់ខ្លួន ហើយប្រជាពលរដ្ឋមានឱកាសប្រកបដោយអត្ថន័យដើម្បីចែករំលែកមតិយោបល់របស់ខ្លួនអំពីរបៀបដោះស្រាយតម្រូវការ ផលប្រយោជន៍ និងអាទិភាពទាំងនេះ។

- **ការឆ្លើយតប និងគណនេយ្យភាព**-ក្រុមប្រឹក្សា ឆ្លើយតបនឹងតម្រូវការ ផលប្រយោជន៍ និងអាទិភាពរបស់ប្រជាពលរដ្ឋរបស់ខ្លួន ក្រុមប្រឹក្សាឆ្លើយតបនឹងសេចក្ដីសម្រេចចិត្ត និងផលប៉ះពាល់នៃសេចក្ដីសម្រេចចិត្តរបស់ខ្លួន។
- **ការលើកកម្ពស់គុណភាពនៃជីវិតរស់នៅរបស់ប្រជាជននៅមូលដ្ឋាន** - ក្រុមប្រឹក្សា មានមុខងារជាក់លាក់ដែលខ្លួនអនុវត្ត ដើម្បីកែលំអជីវភាពប្រជាពលរដ្ឋរបស់ខ្លួន។
- **ការលើកស្ទួយសមធម៌** - ក្រុមប្រឹក្សាធានាឱ្យបានថា ប្រជាពលរដ្ឋទាំងអស់របស់ខ្លួន រួមមានបុរស ស្ត្រី យុវជន ជនក្រីក្រ ជនជាតិដើមភាគតិចមានឱកាសប្រកបដោយអត្ថន័យដើម្បី *ចូលរួមនៅក្នុងដំណើរការទាំងមូលនៃអភិបាលកិច្ចមូលដ្ឋាន និងទទួលបានផលប្រយោជន៍ស្មើគ្នាពី* អភិបាលកិច្ចមូលដ្ឋាន

> **ទាំងលទ្ធិប្រជាធិបតេយ្យ និង ការអភិវឌ្ឍ គឺជាតម្លៃដែលមានចែងនៅក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា**
>
> - **តើលទ្ធិប្រជាធិបតេយ្យមានន័យដូចម្ដេចចំពោះអ្នក?**
> - **តើការអភិវឌ្ឍមានន័យដូចម្ដេចចំពោះអ្នក?**
> - **ការអភិវឌ្ឍ *បែបប្រជាធិបតេយ្យ* មានន័យដូចម្ដេចចំពោះអ្នក?**

- **តម្លាភាព និងសុចរិតភាព** - ជាតំណាងរបស់ប្រជាពលរដ្ឋ ក្រុមប្រឹក្សាត្រូវមានតម្លាភាពនៅក្នុងសេចក្ដីសម្រេច និងកិច្ចការរបស់ខ្លួន ហើយក្រុមប្រឹក្សា ត្រូវបំពេញការងារដោយមានសុចរិតភាពខ្ពស់បំផុត។
- **វិធានការប្រឆាំងអំពើពុករលួយ និងការរំលោភអំណាច** - សមាជិកក្រុមប្រឹក្សា មិនត្រូវមានការពាក់ព័ន្ធនឹងអំពើពុករលួយ ឬការរំលោភអំណាចរបស់ខ្លួនឡើយ ហើយសមាជិកក្រុមប្រឹក្សា ត្រូវរាយការណ៍អំពីករណីនៃអំពើពុករលួយ ឬការរំលោភអំណាចនៅនៅក្នុងតំបន់របស់ខ្លួន។

# ការអភិវឌ្ឍតាមបែប ប្រជាធិបតេយ្យ



## ការពិនិត្យមើលឱ្យកាន់តែស៊ីជម្រៅលើគោលការណ៍មួយចំនួននៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ

### ការចូលរួមចំណែករបស់ប្រជាពលរដ្ឋ

✓ ទម្រង់នៃការចូលរួមចំណែករបស់ប្រជាពលរដ្ឋដោយផ្ទាល់ជាទូទៅបំផុតនៅក្នុងអភិបាលកិច្ចមូលដ្ឋានគឺ**ការបោះឆ្នោត**។ នៅពេលបោះឆ្នោតប្រជាពលរដ្ឋបោះឆ្នោតដោយផ្អែកទៅលើគោលការណ៍

**ឧទាហរណ៍**

**ការចូលរួមរបស់ប្រជាជននៅថ្នាក់ក្រោមជាតិ**

- ប្រជាពលរដ្ឋ ចូលរួមនៅក្នុងការប្រជុំរបស់ក្រុមប្រឹក្សា
- ប្រជាពលរដ្ឋ ជួបជុំគ្នា ដើម្បីធ្វើសំណើជូនក្រុមប្រឹក្សា
- សវនាការជាសាធារណៈ ឧទាហរណ៍លើផែនការប្រើប្រាស់ដីធ្លី ឬ ផែនការអភិវឌ្ឍន៍
- សិទ្ធិរបស់ប្រជាពលរដ្ឋក្នុងការជំទាស់ ឧទាហរណ៍ទាក់ទងនឹងផែនការសាងសង់
- ម៉ោងរបស់ប្រជាពលរដ្ឋជាមួយអភិបាល

ថាតើគាត់ពេញចិត្តនឹងគោលនយោបាយរបស់រដ្ឋបាលគាត់ឬទេ។ បន្ទាប់មក រដ្ឋបាលត្រូវទទួលយក គណនេយ្យភាពដោយទទួលយកលទ្ធផលនៃការបោះឆ្នោត។ ទោះបីជានៅក្នុងប្រទេសដែលមានប្រពៃណីប្រជា ធិបតេយ្យយូរអង្វែងក្តី ក៏បទពិសោធន៍បង្ហាញថា ប្រជាពលរដ្ឋត្រូវមានការរួមចំណែកនៅក្នុង**ការធ្វើសេចក្តី សម្រេចនៅចន្លោះពេលបោះឆ្នោត** ជាពិសេសនៅថ្នាក់ក្រោមជាតិ ដើម្បីឱ្យតម្រូវការរបស់គាត់ឆ្លើយតបបាន កាន់តែប្រសើរ។

### តម្លាភាព

✓ បន្ថែមពីលើសិទ្ធិបោះឆ្នោត បុរេល័ក្ខខ័ណ្ឌសម្រាប់ឱ្យប្រជាពលរដ្ឋ ទទួលបានផលប្រយោជន៍ពីសិទ្ធិតាមរបបប្រជាធិបតេយ្យរបស់ខ្លួនគឺសេរីភាពសារព័ត៌មាន សិទ្ធិបញ្ចេញមតិ សេរីភាពក្នុងការប្រមូលផ្តុំ សេរីភាពក្នុងការ បង្កើតគណបក្សនយោបាយ និង**សិទ្ធិរបស់ ប្រជាពលរដ្ឋ និងបណ្តាញផ្សព្វផ្សាយក្នុងការទទួលបានព័ត៌មាន**។ ប្រការនេះសំដៅលើសិទ្ធិទទួលបានព័ត៌មានអំពី ច្បាប់ និងបទបញ្ជា និងអំពីសេចក្តីសម្រេចចិត្តរបស់រដ្ឋបាល និង ក្រុមប្រឹក្សានៅថ្នាក់

**ឧទាហរណ៍-ការចូលរួមនៅថ្នាក់ក្រោមជាតិ**

មានយន្តការខុសៗគ្នាជាច្រើននៅលើពិភពលោក នៅក្នុងការចូលរួមរបស់ប្រជាជន ។ ឧទាហរណ៍ នៅប្រទេសស្វីស រដ្ឋធម្មនុញ្ញមិនអាចត្រូវធ្វើវិសោធនកម្មដោយរដ្ឋសភាតែឯងឡើយ។ មុនពេលរដ្ឋសភាអាចធ្វើវិសោធនកម្ម ត្រូវតែធ្វើប្រជាមតិជាមុនសិន។ ប្រជាមតិគឺជាការបោះឆ្នោតពិសេសរបស់ប្រជាជន។ រដ្ឋសភា អាចធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញដរាបណាមានការយល់ព្រមពីប្រជាជន។

ក្រោមជាតិ។ ប្រជាពលរដ្ឋ ក៏មានសិទ្ធិដឹងអំពីរបៀបចំណាយប្រាក់ពន្ធរបស់ខ្លួនផងដែរ ដូច្នេះ ត្រូវមានសិទ្ធិទទួលបានព័ត៌មានអំពីថវិការបស់រដ្ឋបាល។

## សមធម៌

✓ សមធម៌សំដៅលើភាពត្រឹមត្រូវនៃការប្រព្រឹត្តិទៅលើក្រុមផ្សេងៗ អនុលោមទៅតាមតម្រូវការ និងផលប្រយោជន៍រៀងៗខ្លួន។ ប្រការនេះ រួមមានការធានាឱ្យបានថា គ្រប់ក្រុមទាំងអស់ទទួលបានសិទ្ធិ ផលប្រយោជន៍ ឱកាស និងកាតព្វកិច្ចដូចគ្នា។ ឧទាហរណ៍ ប្រជាពលរដ្ឋទាំងអស់ត្រូវមានសិទ្ធិដូចគ្នាក្នុងការចូលរួមនៅក្នុងអភិបាលកិច្ចមូលដ្ឋាន។ សមធម៌ក៏អាចមានបញ្ចូលការធ្វើអន្តរាគមន៍ជាគោលដៅដើម្បីធានាថា សិទ្ធិទាំងនេះពិតជាត្រូវបានអនុវត្ត។

**ឧទាហរណ៍ - សមធម៌**

- កុមាររបស់ជនជាតិភាគតិច ត្រូវមានសិទ្ធិស្មើគ្នាក្នុងការទទួលបានការអប់រំ និងការសិក្សាដូចគ្នានឹងប្រជាជនទូទៅដែរ។
- តម្រូវការខុសគ្នារបស់ស្ត្រី និងបុរស ត្រូវតែលើកយកមកពិចារណានៅក្នុងផែនការអភិវឌ្ឍន៍ ឧទាហរណ៍ទាក់ទងនឹងការផ្តល់ការថែទាំសុខភាព។ ឧទាហរណ៍គឺស្ត្រី មិនមែនបុរសឡើយ ដែលទាមទារឱ្យមានការថែទាំសុខភាពមាតា។
- សំណើពីប្រជាពលរដ្ឋដល់ក្រុមប្រឹក្សា និងរដ្ឋបាលរបស់ក្រុមប្រឹក្សា ត្រូវតែដោះស្រាយដោយមិនគិតអំពីឋានៈនៅក្នុងសង្គមរបស់ប្រជាពលរដ្ឋ។
- ឱកាសចូលរួមនៅក្នុងអភិបាលកិច្ចមូលដ្ឋាន គួរកើតមានសម្រាប់ក្រុមទាំងអស់។ ឧទាហរណ៍ ការប្រជុំជាសាធារណៈ មិនគួរកើតមានឡើងនៅពេលបុរសជាប់រវល់ការងារស្រែចំការ ឬនៅពេលស្ត្រីជាប់រវល់ការងារផ្ទះសម្បែង។ ការប្រជុំជាសាធារណៈ ក៏គួរពិចារណាផងដែរអំពីការឈប់សម្រាករបស់ក្រុមជនជាតិដើមភាគតិច។

### ការឆ្លើយតប

- ✓ គណនេយ្យភាព និងការឆ្លើយតបគឺជាគោលការណ៍យ៉ាងសំខាន់នៅក្នុងការអភិវឌ្ឍបែបប្រជាធិបតេយ្យ និង អភិបាលកិច្ចល្អ។ ការឆ្លើយតបសំដៅលើការទទួលខុសត្រូវរបស់តំណាងជាប់ឆ្នោត**ក្នុងការឆ្លើយតបនឹងតម្រូវការពិតប្រាកដ**របស់ប្រជាពលរដ្ឋខ្លួន។ វាក៏សំដៅផងដែរលើការទទួលខុសត្រូវរបស់តំណាងជាប់ឆ្នោត**ក្នុងការស្តាប់សម្លេងរបស់ប្រជាពលរដ្ឋខ្លួន** ក្នុងការពិចារណាបញ្ហាដែលប្រជាពលរដ្ឋលើកឡើង និងតម្រូវការដែលប្រជាពលរដ្ឋទាមទារ ហើយបន្ទាប់មកឆ្លើយតបឱ្យបានប្រសើរបំផុតទៅតាមសិទ្ធិអំណាច និងធនធានរបស់ខ្លួន។
- ✓ ដើម្បីមានការឆ្លើយតប ក្រុមប្រឹក្សាត្រូវមានតួនាទី **មុខងារ** និង**ធនធាន**ចាំបាច់ ដើម្បីមានលទ្ធភាពឆ្លើយតបនឹងតម្រូវការ និងផលប្រយោជន៍របស់ប្រជាពលរដ្ឋ។ ក្រុមប្រឹក្សាក៏ត្រូវមានសិទ្ធិអំណាច និង**ឆន្ទានុសិទ្ធិ**គ្រប់គ្រាន់ផងដែរ ដើម្បីអនុវត្តមុខងារទាំងនោះ ហើយប្រើប្រាស់ធនធានរបស់ខ្លួនទៅតាមរបៀបដែលឆ្លើយតបនឹងតម្រូវការពិតប្រាកដនៅមូលដ្ឋាន (ឧទាហរណ៍ បច្ចុប្បន្នក្រុមប្រឹក្សាឃុំ សង្កាត់យល់ថា ខ្លួនមិនអាចឆ្លើយតបនឹងក្តីរំពឹងរបស់ប្រជាពលរដ្ឋឡើយ ដោយសារមុខងារ សិទ្ធិអំណាច និងធនធានដ៏មានកម្រិត)។

### គណនេយ្យភាព

- ✓ គណនេយ្យភាព មានសភាពខ្លាំងក្លាជាងការចូលរួម ខ្លាំងជាងតម្លាភាព និងខ្លាំងជាងការឆ្លើយតប។ គណនេយ្យភាព មានន័យថា **តួអង្គមួយក្រុមមានសិទ្ធិអំណាចលើតួអង្គមួយក្រុមទៀត**។ ឧទាហរណ៍ និយោជកមានសិទ្ធិអំណាចលើសកម្មភាពរបស់និយោជិតរបស់ខ្លួន។
- ✓ គណនេយ្យភាព ក៏គួរពាក់ព័ន្ធនឹងសិទ្ធិ**ដាក់ទណ្ឌកម្ម**ផងដែរ។ ឧទាហរណ៍ ប្រសិនបើចៅហ្វាយមិនមានសិទ្ធិអំណាចដាក់ទណ្ឌកម្មនិយោជិតរបស់ខ្លួនដែលមិនបានបំពេញការងារ និយោជិតនឹងមិនមានគណនេយ្យភាពចំពោះចៅហ្វាយរបស់ខ្លួនឡើយ។
- ✓ ប្រជាពលរដ្ឋដែលជាតួអង្គសំខាន់នៅក្នុងលទ្ធិប្រជាធិបតេយ្យ មានសិទ្ធិអំណាចលើមន្ត្រីជាប់ឆ្នោតរបស់ខ្លួន។ ប្រជាពលរដ្ឋមានសិទ្ធិអំណាចលើក្រុមប្រឹក្សារបស់ខ្លួន ពីព្រោះ**ប្រជាពលរដ្ឋបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា**។ ប្រការនេះសំដៅលើគណនេយ្យភាពតាមបែបប្រជាធិបតេយ្យដែលត្រូវពិភាក្សាខាងក្រោម។
- ✓ គណនេយ្យភាព មិនត្រឹមតែសំដៅលើគណនេយ្យភាពរបស់រដ្ឋបាលប៉ុណ្ណោះទេ។ គណនេយ្យភាពក៏សំដៅលើ**គណនេយ្យភាពនៅក្នុងចំណោមតួអង្គរបស់រដ្ឋបាលផងដែរ** (ដូចជាគណនេយ្យភាពរបស់គណៈអភិបាលចំពោះក្រុមប្រឹក្សា)។

**ឧទាហរណ៍អំពីគណនេយ្យភាព**

**គណនេយ្យភាពរបស់និយោជិតចំពោះនិយោជក**

- គណនេយ្យភាព អនុវត្តនៅក្នុងទំនាក់ទំនងយ៉ាងទូលំទូលាយ ។ ឧទាហរណ៍ និយោជិតមានគណនេយ្យភាពចំពោះនិយោជករបស់ខ្លួន ។
- ដោយហេតុថានិយោជិតមានគណនេយ្យភាព និយោជកមានសិទ្ធិពិនិត្យមើល និងវាយតម្លៃការងាររបស់និយោជិត និងពិភាក្សាការងារ និងតម្រូវការឱ្យមានការកែលំអជាមួយនិយោជិត ។
- ប្រសិនបើនិយោជក មិនសប្បាយចិត្តនឹងគុណភាព ឬបរិមាណការងារ និយោជក មានសិទ្ធិចាត់វិធានការអនុលោមទៅតាមកិច្ចសន្យាបម្រើការងារ និងច្បាប់ការងារជាធរមាន ។
- វិធានការដែលនិយោជកអាចប្រកាន់យក រួមមានការតម្រូវឱ្យនិយោជិតបំពេញភារកិច្ចតាមរបៀបផ្សេង ការតម្រូវឱ្យនិយោជិតបំពេញភារកិច្ចជាមួយគ្នា ការកំណត់តម្រូវការ ឬកាលបរិច្ឆេទទៅលើនិយោជិត និងបញ្ចុះឋានៈ ឬបញ្ឈប់ការងាររបស់និយោជិត ។

# ផ្នែកទី ៣៖ ការចូលរួម និងតម្លាភាពនៅក្នុងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

**ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ**

**មាត្រា ៣៦, ៣៨, ៣៩, ៤១, ៥០, ៥១, ៦៨, ៧៦, ៨៤, ១៣៦, ១៦៣, ១៦៤, ១៦៩, ១៧០**

ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ប្តេជ្ញាគាំទ្រការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ ដែលជាគោលការណ៍គ្រឹះយ៉ាងសំខាន់នៅក្នុងច្បាប់ស្តីពីនេះ។ គោលការណ៍នេះ ទាមទារឱ្យរាជធានីភ្នំពេញ ខេត្ត ក្រុង ស្រុក និងខណ្ឌ បំពេញការងារទៅតាមរបៀបដែលមានតម្លាភាព និងមានការចូលរួម ព្រមទាំងមានការពិគ្រោះយោបល់ដើម្បីជំរុញការចូលរួមចំណែករបស់ប្រជាពលរដ្ឋ។ ផ្នែកនេះ ផ្តល់ទិដ្ឋភាពទូទៅនៅក្នុងបទប្បញ្ញត្តិនៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌទាក់ទងនឹងតម្លាភាព និងការចូលរួមចំណែករបស់ប្រជាពលរដ្ឋ។

## ការទទួលខុសត្រូវរបស់ក្រុមប្រឹក្សា

> **គំរូបទបញ្ជាផ្ទៃក្នុង**
>
> គ.ជ.អ.ប បានដាក់ចេញគំរូបទបញ្ជាផ្ទៃក្នុង ដែលក្រុមប្រឹក្សាត្រូវធ្វើជាសំអាងនៅពេលក្រុមប្រឹក្សាអភិវឌ្ឍ និងអនុម័តបទបញ្ជាផ្ទៃក្នុងរបស់ខ្លួន។ គំរូបទបញ្ជាផ្ទៃក្នុង ចែងល័ក្ខខ័ណ្ឌជាអប្បបរមាដែលអាចត្រូវបន្ថែម និងអនុវត្តដោយក្រុមប្រឹក្សានីមួយៗ។

- ✓ ជាទូទៅ ការប្រជុំរបស់ក្រុមប្រឹក្សា ប្រព្រឹត្តិទៅជាសាធារណៈ និងបើកចំហចំពោះប្រជាពលរដ្ឋ។ ប្រជាពលរដ្ឋមិនចាំបាច់មានលិខិតអញ្ជើញ ដើម្បីចូលរួមកិច្ចប្រជុំរបស់ក្រុមប្រឹក្សាឡើយ (មាត្រា ៦៨ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងមាត្រា ២៥ នៃគំរូបទបញ្ជាផ្ទៃក្នុង)។
- ✓ ក្រុមប្រឹក្សា ត្រូវផ្សព្វផ្សាយជាសាធារណៈនូវប្រតិទិននៃកិច្ចប្រជុំសាមញ្ញរបស់ខ្លួនជារៀងរាល់ឆ្នាំ (មាត្រា ៧៥, ៧៦ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងមាត្រា ២.៦ នៃគំរូបទបញ្ជាផ្ទៃក្នុង)។
- ✓ រៀងរាល់កិច្ចប្រជុំរបស់ខ្លួន ក្រុមប្រឹក្សាត្រូវធ្វើសេចក្តីសម្រេច ឬដីកាតាមការចាំបាច់ទាក់ទងនឹងដំណើរការពិគ្រោះយោបល់ជាមួយសាធារណជននៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សា និងការផ្សព្វផ្សាយព័ត៌មាននានាជូនប្រជាពលរដ្ឋ (មាត្រា ៣៦ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ)។

✓ ក្រុមប្រឹក្សាទាំងអស់ត្រូវរៀបចំវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់ជារៀងរាល់ឆ្នាំ ដែលត្រូវចូលរួមដោយប្រជាពលរដ្ឋ ក៏ដូចជាក្រុមប្រឹក្សាផ្សេងទៀត ។ វេទិកាទាំងនេះ គឺជាយន្តការយ៉ាងសំខាន់សម្រាប់

- **តម្លាភាព**
- **ការចូលរួមចំណែករបស់ប្រជាពលរដ្ឋ:**
  - ការពិគ្រោះយោបល់
  - ការចូលរួម
  - សម្លេងរបស់ប្រជាពលរដ្ឋ
  - ការសន្ទនារវាងរដ្ឋបាល និងប្រជាពលរដ្ឋអំពីការអភិវឌ្ឍ ជម្រើស សិទ្ធិ និងសេវា
  - ការដាក់បញ្ចូលឱ្យបានពេញលេញ និងផ្តល់ឱកាសឱ្យប្រជាពលរដ្ឋដែលងាយរងគ្រោះបានចូលរួម
- **គណនេយ្យភាពតាមបែបប្រជាធិបតេយ្យ**

(មាត្រា ៩, ៦៥, ១២១ នៃអនុក្រឹត្យលេខ២១៦ អ.ន.ក្រ.បក ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក)

✓ គោលបំណងរបស់វេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់ គឺដើម្បី

- **ផ្តល់ព័ត៌មាន**អំពីសកម្មភាពរបស់ក្រុមប្រឹក្សា បន្ទាប់ពីវេទិកាចុងក្រោយ
- **ឆ្លើយតបនឹងសំណួមពរ**របស់អ្នកចូលរួម
- **ពិភាក្សា និងបំភ្លឺបញ្ហា**ដែលលើកឡើងដោយអ្នកចូលរួម
- **ប្រមូលមតិយោបល់**ពីអ្នកចូលរួម ដើម្បីកែលម្អការងាររបស់ក្រុមប្រឹក្សា និងការឆ្លើយតបរបស់ក្រុមប្រឹក្សាចំពោះប្រជាពលរដ្ឋ

(មាត្រា ៩, ៦៥, ១២១ នៃអនុក្រឹត្យលេខ២១៦)

✓ រដ្ឋបាលនៅថ្នាក់ក្រោមជាតិទាំងអស់ ត្រូវបើកទ្វារនៅក្នុងអំឡុងពេលនៃម៉ោងធ្វើការជាផ្លូវការ ។ នៅក្នុងអំឡុង ពេលនៃម៉ោងធ្វើការនេះ ប្រជាពលរដ្ឋគ្រប់រូបមានសិទ្ធិ :

**រដ្ឋបាលនៅថ្នាក់ក្រោមជាតិ**

រដ្ឋបាលនៅថ្នាក់ក្រោមជាតិ សំដៅលើក្រុមប្រឹក្សា និងគណៈអភិបាលរបស់ក្រុមប្រឹក្សា ។(មាត្រា២ នៃអនុក្រឹត្យលេខ២១៦ អ.ន.ក្រ.បក ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក)

- ទំនាក់ទំនង និងធ្វើការជាមួយក្រុមប្រឹក្សា និងគណៈអភិបាល
- ទទួលព័ត៌មានពីរដ្ឋបាលអំពីសំណូមពរ ឬកិច្ចការផ្សេងទៀត
- ផ្តល់មតិយោបល់ ឬសំណូមពរលើកិច្ចការណាមួយ។ (មាត្រា ៥០, ១០៧, ១៦៨ នៃអនុក្រឹត្យលេខ២១៦ អ.ន.ក្រ.បក ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក)

✓ ក្រុមប្រឹក្សា ត្រូវបង្កើតល័ក្ខខ័ណ្ឌសមស្របសម្រាប់ឱ្យសាធារណជនទទួលបានព័ត៌មានជាសាធារណៈអំពីរបាយការណ៍របស់ក្រុមប្រឹក្សា របៀបវារៈនៃកិច្ចប្រជុំ កំណត់ហេតុនៃកិច្ចប្រជុំ ដីកា ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ និងប្រកាសទាក់ទងនឹងក្រុមប្រឹក្សា និងឯកសារផ្សេងទៀតរបស់ក្រុមប្រឹក្សា (មាត្រា ៥១ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ)។

✓ រដ្ឋបាលត្រូវបង្កើតក្តារព័ត៌មានសាធារណៈដែលសាធារណជនអាចពិនិត្យបានដោយងាយ នៅពីមុខការិយាល័យរបស់រដ្ឋបាល។ ក្តារព័ត៌មានត្រូវដាក់បង្ហាញព័ត៌មានជាផ្លូវការរបស់ក្រុមប្រឹក្សានៅក្នុងរយៈពេលយ៉ាងតិច១០ថ្ងៃ។ ក្រៅពីនេះ ក្រុមប្រឹក្សាត្រូវបង្កើតក្តារព័ត៌មាននៅតាមទីសាធារណៈផ្សេងទៀត ដើម្បីផ្សព្វផ្សាយព័ត៌មានបន្ថែមដល់ប្រជាពលរដ្ឋ។ ក្រុមប្រឹក្សា ក៏ត្រូវស្វែងរកមធ្យោបាយផ្សេងៗ ដើម្បីផ្សព្វផ្សាយព័ត៌មានដល់ប្រជាពលរដ្ឋអំពីការងាររបស់រដ្ឋបាល (មាត្រា ៥៤, ១១១, ១៧២ នៃអនុក្រឹត្យលេខ២១៦ អ.ន.ក្រ.បក ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក)។

✓ ក្រុមប្រឹក្សា ត្រូវបិទផ្សាយជាសាធារណៈនូវព័ត៌មានអំពីសេចក្តីសម្រេច និងដីកាដែលខ្លួនបានអនុម័ត (មាត្រា ១៩ នៃគំរូបទបញ្ជាផ្ទៃក្នុង)។

✓ ក្រុមប្រឹក្សាត្រូវរៀបចំ និងផ្សព្វផ្សាយរបាយការណ៍ប្រចាំឆ្នាំ សេចក្តីសម្រេច សកម្មភាព និងការងាររបស់ខ្លួន (មាត្រា ៥០ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ)។

## ការទទួលខុសត្រូវរបស់គណៈអភិបាល

✓ គណៈអភិបាលត្រូវលើកសំណើទៅក្រុមប្រឹក្សា ដើម្បីកំណត់អំពីយុទ្ធសាស្ត្រ និងរបៀបនៃការពិគ្រោះយោបល់លើបញ្ហាចាំបាច់ផ្សេងៗជាមួយប្រជាពលរដ្ឋ ក្រសួង និងដៃគូពាក់ព័ន្ធដទៃទៀត (មាត្រា ១៦៤ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ)។

- ✓ គណៈអភិបាល ត្រូវធានាឱ្យមានក្ដារព័ត៌មាន និងមធ្យោបាយផ្សេងទៀតសម្រាប់ផ្សព្វផ្សាយព័ត៌មានដែលក្រុមប្រឹក្សាត្រូវការ។ រាល់ឯកសារទាំងអស់ដែលបានបោះពុម្ពផ្សាយ ត្រូវតែបិទផ្សាយនៅលើក្ដារព័ត៌មាន ឬត្រូវផ្សព្វផ្សាយតាមមធ្យោបាយផ្សេងៗទៀត (មាត្រា ១៦៩ នៃច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ)។

- ✓ គណៈអភិបាលត្រូវធានាឱ្យបានថា សាធារណជនមានលទ្ធភាពគ្រប់គ្រាន់ក្នុងការពិនិត្យមើលព័ត៌មាននានានៅលើក្ដារព័ត៌មាន ហើយត្រូវធានាថែរក្សាការពារសុវត្ថិភាពក្ដារព័ត៌មាន (មាត្រា ១៧០ នៃច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ)។

- ✓ គណៈអភិបាល មានការទទួលខុសត្រូវចំពោះការរៀបចំ ដើម្បីដាក់ជូនក្រុមប្រឹក្សាអនុម័តនូវរបាយការណ៍ប្រចាំឆ្នាំលើការបំពេញការងាររបស់ក្រុមប្រឹក្សាសម្រាប់ផ្សព្វផ្សាយជូនប្រជាពលរដ្ឋនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន (មាត្រា ១៦៣ នៃច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ)។

- ✓ ដោយហេតុថា គណៈអភិបាលមានគណនេយ្យភាពចំពោះក្រុមប្រឹក្សា គណៈអភិបាលត្រូវអនុវត្តការងាររបស់ខ្លួនទៅតាមរបៀបដែលមានតម្លាភាពចំពោះក្រុមប្រឹក្សា។ ឧទាហរណ៍ គណៈអភិបាលរាយការណ៍ជូនក្រុមប្រឹក្សានៅគ្រប់កិច្ចប្រជុំរបស់ក្រុមប្រឹក្សា។ ក្រៅពីនេះ កំណត់ហេតុត្រូវធ្វើឡើងនៅគ្រប់កិច្ចប្រជុំរបស់គណៈអភិបាល (មាត្រា ១៥៩, ១៦៥ នៃច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មាត្រា ៣១ នៃគំរូបទបញ្ជាផ្ទៃក្នុង មាត្រា ៣១, ៨៨, ១៤៩ នៃអនុក្រឹត្យលេខ២១៦ អ.ន.ក្រ.បក ស្ដីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក)។

## តម្លាភាព និងការចូលរួមចំណែករបស់ប្រជាពលរដ្ឋនៅក្នុងដំណើរការកសាងផែនការ

នៅក្នុងដំណើរការរៀបចំផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគរបស់ខ្លួន ក្រុមប្រឹក្សាត្រូវចែករំលែកព័ត៌មាន ប្រកបដោយមានតម្លាភាព។ ក្រុមប្រឹក្សា ត្រូវពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋទាំងអស់នៅក្នុងតំបន់របស់ខ្លួន និងធានាឱ្យមានឱកាសសម្រាប់ការចូលរួមចំណែករបស់ប្រជាពលរដ្ឋនៅក្នុងដំណើរការ (មាត្រា ៥, ១៣ នៃអនុក្រឹត្យស្ដីពីផែនការអភិវឌ្ឍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ)។

**គណៈអភិបាល** ត្រូវលើកសំណើជូនក្រុមប្រឹក្សាអំពីយុទ្ធសាស្ត្រសម្រាប់ពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋ។ ការពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋ អាចត្រូវធ្វើឡើងដោយក្រុមប្រឹក្សា ឬក្រុមប្រឹក្សាអាចសុំឱ្យគណៈអភិបាលធ្វើការពិគ្រោះយោបល់ក្នុងនាមក្រុមប្រឹក្សា។ គណៈអភិបាលក៏មានការទទួលខុសត្រូវផងដែរក្នុងការ ដឹកនាំ វេទិកាពិគ្រោះយោបល់នៅក្នុងអំឡុងពេលរៀបចំផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគផងដែរ (មាត្រា ៣៨, ១៦៤ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មាត្រា ៨ នៃអនុក្រឹត្យស្តីពីផែនការអភិវឌ្ឍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ) ។

> ចំពោះព័ត៌មានបន្ថែមស្តីពីតួនាទីគណៈកម្មាធិការសម្របសម្រួលបច្ចេកទេស សូមអានមេរៀនទី៧ ។

**គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស របស់ក្រុមប្រឹក្សា** មានការទទួលខុសត្រូវក្នុង ការសម្របសម្រួលការចូលរួមរបស់អ្នកពាក់ព័ន្ធនៅក្នុងដំណើរការកសាងផែនការ (មាត្រា ៤ នៃអនុក្រឹត្យលេខ ២១៨ ស្តីពីការបង្កើត ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសក្រុមប្រឹក្សាខេត្ត គណៈកម្មាធិការសម្របសម្រួលបច្ចេកទេសក្រុមប្រឹក្សាក្រុង និងគណៈកម្មាធិការសម្របសម្រួលបច្ចេកទេស ក្រុមប្រឹក្សាស្រុក)។

- ✓ ដើម្បីជំរុញគណនេយ្យភាពតាមបែបប្រជាធិប តេយ្យ ជាការសំខាន់ដែលសមាជិកក្រុមប្រឹក្សា ត្រូវដើរតួនាទីជាដុំកំភួននៅក្នុងដំណើរការកសាងផែនការនៅក្នុង ការពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋ។
- ✓ ក្រុមប្រឹក្សា ត្រូវធ្វើការផ្សព្វផ្សាយជាសាធារណៈ និងជាបន្ទាន់នូវផែនការអភិវឌ្ឍ បន្ទាប់ពីបានអនុម័តរួចហើយភ្លាម។ សាធារណជនអាចពិនិត្យឯកសារផែនការនេះនៅការិយាល័យរបស់ក្រុមប្រឹក្សាដោយឥតគិតថ្លៃ ឬអាចស្នើសុំជាវឯកសារផែនការនេះពីក្រុមប្រឹក្សាដោយគិតត្រឹមតម្លៃដើម (មាត្រា ៤១ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ)។

ផែនការអភិវឌ្ឍរបស់ក្រុមប្រឹក្សា ត្រូវមានបញ្ចូលយុទ្ធសាស្ត្រសម្រាប់អនុវត្តផែនការអភិវឌ្ឍន៍ទៅតាមរបៀបដែលមានតម្លាភាព មានគណនេយ្យភាព មានការចូលរួមរបស់ប្រជាពលរដ្ឋនៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សា និងមានប្រសិទ្ធិភាព (មាត្រា ៣៩ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មាត្រា ២២ នៃអនុក្រឹត្យស្តីពីផែនការអភិវឌ្ឍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ) ។

ក្រុមប្រឹក្សា ត្រូវចាត់ចែងពិនិត្យតាមដានការរីកចម្រើនការអនុវត្តផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគរបស់ខ្លួន។ ក្រុមប្រឹក្សាត្រូវអនុវត្តផងដែរនូវរបាយការណ៍ប្រចាំឆ្នាំដែលមានបញ្ជាក់ការរីកចម្រើនរបស់ខ្លួន និងផែនការរបស់ខ្លួន ក្នុងការអនុវត្តសម្រាប់ឆ្នាំក្រោយ (មាត្រា ២៦ នៃអនុក្រឹត្យស្តីពីផែនការអភិវឌ្ឍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ) ។

- ✓ ដើម្បីជំរុញគណនេយ្យភាពតាមបែបប្រជាធិបតេយ្យ ជាការសំខាន់ដែលប្រជាពលរដ្ឋត្រូវមានឱកាសក្នុងការពិនិត្យតាមដានមើលការងាររបស់ក្រុមប្រឹក្សានៅក្នុងការអនុវត្តផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគ ក៏ដូចជាភារកិច្ចផ្សេងទៀតរបស់ក្រុមប្រឹក្សាដូចជាការចុះអត្រានុកូលដ្ឋានជាដើម។

## ការគ្រប់គ្រងហិរញ្ញវត្ថុដោយមានតម្លាភាព

- ✓ ក្រុមប្រឹក្សាត្រូវធានាឱ្យបានថា ការគ្រប់គ្រងហិរញ្ញវត្ថុមានតម្លាភាព និងធានាថាក្រុមប្រឹក្សាមានគណនេយ្យភាពចំពោះប្រជាពលរដ្ឋអំពីរបៀបគ្រប់គ្រងហិរញ្ញវត្ថុរបស់ក្រុមប្រឹក្សា។ ក្រុមប្រឹក្សាត្រូវបិទផ្សាយថវិកាប្រចាំឆ្នាំរបស់ខ្លួន ហើយត្រូវធានាឱ្យបានថា សវនកម្មខាងក្នុង និងខាងក្រៅត្រូវបានធ្វើឡើង ហើយត្រូវធានាឱ្យមានដំណើរការលទ្ធកម្មសមស្រប (មាត្រា ៤៥ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ)។
- ✓ គណៈកម្មាធិការលទ្ធកម្មមានសិទ្ធិ និងភារកិច្ចធានាឱ្យសកម្មភាពលទ្ធកម្មទាំងអស់របស់រដ្ឋបាលថ្នាក់ក្រោមជាតិប្រព្រឹត្តធ្វើឡើងប្រកបដោយភាពស្មោះត្រង់ បើកចំហ មានតម្លាភាព និងមិនលំអៀង ដោយអនុលោមតាមច្បាប់ បទប្បញ្ញត្តិស្តីពីលទ្ធកម្មសាធារណៈ។ គណៈកម្មាធិការលទ្ធកម្ម ត្រូវការពារផលប្រយោជន៍របស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងប្រជាពលរដ្ឋរបស់ខ្លួន (មាត្រា ១៣៦ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ)។

## ផ្នែកទី ៤: គណនេយ្យភាព និងការឆ្លើយតបនៅក្នុងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

**ច្បាប់ស្តីពីការគ្រប់គ្រង រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ**

**មាត្រា ២៤-៣៤, ៣៩-៤៣, ៤៦, ៤៧, ៧៨, ៨៥, ៩៨, ១២១, ១៥១, ១៥២, ១៥៤, ១៥៧, ១៥៨, ១៦៥, ១៧៤, ១៧៧, ១៧៨, ១៨៤, ១៩០, ២២៥, ២២៦**

ការប្តេជ្ញាចិត្តចំពោះ**គណនេយ្យភាពតាមបែបប្រជាធិបតេយ្យ** គឺជាខ្លឹមសារដែលលើកឡើងជាច្រើនលើកនៅក្នុងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។ នៅក្នុងមាត្រាជាច្រើននៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ កំណត់ថា**ក្រុមប្រឹក្សា មានគណនេយ្យភាពចំពោះប្រជាពលរដ្ឋរបស់ខ្លួន**។ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងលិខិតបទដ្ឋាននានា មានភាពច្បាស់លាស់ថា **គណៈកម្មាធិការ គណៈអភិបាល និង បុគ្គលិករបស់ក្រុមប្រឹក្សា** មានគណនេយ្យភាពចំពោះក្រុមប្រឹក្សា។ **អភិបាល** មានគណនេយ្យភាពចំពោះក្រុមប្រឹក្សារបស់ខ្លួន។ ចំពោះកិច្ចការមួយចំនួន គណៈអភិបាលក៏មានគណនេយ្យភាពចំពោះរាជរដ្ឋាភិបាលផងដែរ។ ការងារមួយចំនួន ក្រុមប្រឹក្សាមានគណនេយ្យភាពចំពោះរាជរដ្ឋាភិបាល។

មិនដូចគណនេយ្យភាព **ការឆ្លើយតប**មិនត្រូវបានលើកឡើងជាញឹកញាប់នៅក្នុងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌឡើយ។ ទោះជាយ៉ាងណាក៏ដោយ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ចែងថាក្រុមប្រឹក្សាត្រូវទទួលបានសិទ្ធិអំណាច និង**ឆន្ទានុសិទ្ធិ**ជាអតិបរមា ដើម្បីមានលទ្ធភាព ឆ្លើយតបនឹងតម្រូវការពិតប្រាកដរបស់ប្រជាពលរដ្ឋខ្លួន។ ការងារនេះ ត្រូវសម្រេចទៅបានតាមរយៈការផ្ទេរ**មុខងារ**ដល់ក្រុមប្រឹក្សាដោយមានសិទ្ធិអំណាច និងឆន្ទានុសិទ្ធិពេញលេញ រួមជាមួយនឹង**ធនធាន**ឆន្ទានុសិទ្ធិ។ ដូច្នេះ ការឆ្លើយតបគឺជាសមាសធាតុដ៏សំខាន់នៅក្នុងកំណែទម្រង់។

### ការឆ្លើយតបរបស់ក្រុមប្រឹក្សាចំពោះប្រជាពលរដ្ឋ

- ✓ ក្រុមប្រឹក្សាត្រូវមានគណនេយ្យភាពដោយផ្ទាល់ចំពោះប្រជាពលរដ្ឋទាំងអស់ **អំពីជម្រើស**ដែលខ្លួនប្រកាន់យក អំពីសេចក្តីសម្រេចរបស់ខ្លួន និងអំពីការធានាឱ្យមានការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ (មាត្រា ៣៤ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ)។

- ✓ នៅពេលក្រុមប្រឹក្សាទទួលបានការផ្ទេរ**មុខងារតាមវិស័យ** ក្រុមប្រឹក្សាត្រូវទទួលបានសិទ្ធិអំណាច និងឆន្ទានុសិទ្ធិជាអតិបរមា ដើម្បីគ្រប់គ្រងមុខងារនោះ ដើម្បីឱ្យក្រុមប្រឹក្សាអាច**ឆ្លើយតបចំពោះតម្រូវការពិតប្រាកដរបស់ប្រជាពលរដ្ឋខ្លួន** ( មាត្រា ២២៥ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ) ។
- ✓ ផែនការអភិវឌ្ឍ និងកិច្ចការហិរញ្ញវត្ថុរបស់ក្រុមប្រឹក្សា ត្រូវ**ឆ្លើយតបចំពោះតម្រូវការរបស់ស្ត្រី បុរស យុវជន កុមារ និងក្រុមងាយរងគ្រោះ**រួមទាំងជនក្រីក្រ និងជនជាតិដើមភាគតិច ( មាត្រា ៣៩, ៤២ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ) ។
- ✓ ក្រុមប្រឹក្សាទាំងអស់ មានការទទួលខុសត្រូវចំពោះការគ្រប់គ្រង និងការប្រើប្រាស់យ៉ាងមានប្រសិទ្ធភាពនូវ**ទ្រព្យសម្បត្តិ**រដ្ឋដែលបានផ្ទេរមកអោយ ឬដែលបានទទួលដោយមធ្យោបាយផ្ទាល់ខ្លួន ( មាត្រា ៤៦ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ) ។
- ✓ ក្រុមប្រឹក្សាឃុំ ត្រូវមានការឆ្លើយតបចំពោះប្រជាពលរដ្ឋនៅក្នុងឃុំរបស់ខ្លួន ( មាត្រា ៦៦ និង ៨២ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់) ។

## គណនេយ្យភាពតាមបែបប្រជាធិបតេយ្យ

- ✓ ដើម្បីឱ្យកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការសម្រេចបានទិសដៅរបស់ខ្លួន ត្រូវមានគណនេយ្យភាព***តាមបែបប្រជាធិបតេយ្យ***របស់ក្រុមប្រឹក្សាចំពោះប្រជាពលរដ្ឋ ។

**គណនេយ្យភាពតាមបែបប្រជាធិបតេយ្យសំដៅលើ**

*តំណាងជាប់ឆ្នោត ដែលមានគណនេយ្យភាពតាមបែបប្រជាធិបតេយ្យត្រូវប្រកាន់យកជម្រើសដោយផ្អែកលើព័ត៌មានការបែងចែកធនធានដែលខ្លួនមាន និងអនុវត្តមុខងារ ភារកិច្ចរបស់ខ្លួនដើម្បីជាប្រយោជន៍សាធារណៈសំដៅឆ្លើយតបនឹងតម្រូវការជាអាទិភាពដែលបានលើកឡើងនៅមូលដ្ឋាន ។*

*គណនេយ្យភាពតាមបែបប្រជាធិបតេយ្យកើតមានឡើងនៅពេលប្រជាពលរដ្ឋ អាចកំណត់អំពីផលវិបាកនានាដែលខ្លួនជួបប្រទះទៅលើតំណាងជាប់ឆ្នោត ចំពោះជម្រើសដែលតំណាងជាប់ឆ្នោតប្រកាន់យក របៀបដែលតំណាងជាប់ឆ្នោតបែងចែកធនធានដ៏មានកម្រិត និងចំពោះការអនុវត្តមុខងារ និងភារកិច្ចរបស់ខ្លួន ។*

ដូច្នេះ គណនេយ្យភាពតាមបែបប្រជាធិបតេយ្យពាក់ព័ន្ធនឹង:

- ប្រជាពលរដ្ឋ មានឱកាសដើម្បីឱ្យសម្លេងរបស់គាត់ត្រូវបានស្តាប់ឮ ស្វែងយល់ និងពិចារណាដោយក្រុមប្រឹក្សា
- ប្រជាពលរដ្ឋ **វាយតម្លៃ**លើសកម្មភាពរបស់ក្រុមប្រឹក្សា និងការប្រើប្រាស់មូលនិធិសាធារណៈដោយក្រុមប្រឹក្សា**ផ្តល់មតិត្រឡប់មកវិញ** និង**ទាមទារ**ឱ្យចាត់វិធានការនៅពេលមិនពេញចិត្តនឹងការងាររបស់ក្រុមប្រឹក្សា ( រួមទាំងការងាររដ្ឋបាល)

- ការបែងចែកច្បាស់លាស់រវាង **ជម្រើសផ្នែកនយោបាយ** ដែលក្រុមប្រឹក្សាជាប់ឆ្នោត ត្រូវប្រកាន់យកក្នុងនាមប្រជាពលរដ្ឋរបស់ខ្លួន ពីការងារផ្នែកបច្ចេកទេសរបស់គណៈអភិបាល និងបុគ្គលិករបស់ក្រុមប្រឹក្សា
- ការបង្កើតបទបញ្ជា និងដំណើរការដើម្បីធានាថាក្រុមប្រឹក្សាប្រកាន់យក**ជម្រើសជាអាទិភាព និងធ្វើសេចក្តីសម្រេចដោយផ្អែកលើភស្តុតាង**
- **ការធានាឱ្យមានឱកាសផ្នែកនយោបាយ**សម្រាប់ក្រុមប្រឹក្សាពិភាក្សា និង**ជជែកវែកញែក**នៅពេលកំណត់អាទិភាពក្នុងនាមប្រជាពលរដ្ឋរបស់ខ្លួន
- ការផ្តល់ដល់ក្រុមប្រឹក្សានូវ**អាណត្តិច្បាស់លាស់** ដែលរួមមាន**សិទ្ធិអំណាច និងឆន្ទានុសិទ្ធិ** ដើម្បីដោះស្រាយតម្រូវការ និងកង្វល់ពិតប្រាកដរបស់ប្រជាពលរដ្ឋ
- ការផ្តល់ដល់ក្រុមប្រឹក្សានូវ**ធនធានតាមឆន្ទានុសិទ្ធិគ្រប់គ្រាន់** ដើម្បីដោះស្រាយតម្រូវការ និងកង្វល់ទាំងនោះ
- ការផ្តល់ដល់ប្រជាពលរដ្ឋនូវយន្តការ ដើម្បី**កំណត់ផលវិបាក**ទៅលើតំណាងជាប់ឆ្នោតរបស់ខ្លួន នៅពេលតំណាងជាប់ឆ្នោតទាំងនោះមិនឆ្លើយតបនឹងតម្រូវការរបស់ខ្លួន។

✓ សមាសធាតុសំខាន់ៗ នៃគណនេយ្យភាពតាមបែបប្រជាធិបតេយ្យដែលបានពិភាក្សាខាងលើ គឺតម្លាភាព ការចូលរួមចំណែករបស់ប្រជាពលរដ្ឋ និងការឆ្លើយតប។

✓ បទបញ្ញត្តិបន្ថែមទៅក្នុងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងលិខិតបទដ្ឋានដែលជម្រុញគណនេយ្យភាពតាមបែបប្រជាធិបតេយ្យរួមមាន

- គណៈអភិបាល ត្រូវចាត់ចែងឱ្យមានការសិក្សាស្រាវជ្រាវលើបញ្ហាជាគន្លឹះ ដើម្បីផ្តល់យោបល់ប្រកបដោយគុណភាពដល់ក្រុមប្រឹក្សា។ ប្រការនេះ នឹងផ្តល់លទ្ធភាពឱ្យក្រុមប្រឹក្សាធ្វើសេចក្តីសម្រេចដោយផ្អែកលើព័ត៌មាន និងកំណត់អាទិភាពផ្អែកលើភស្តុតាង (មាត្រា ២៩. ៨៦. ១៤៧ នៃអនុក្រឹត្យលេខ២១៦ អ.ន.ក្រ.បក ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក)

- ក្រុមប្រឹក្សាមាន កិច្ចប្រជុំប្រចាំខែ ដោយមានបទបញ្ជាផ្ទៃក្នុងដែលជាការផ្តល់ឱកាសផ្នែកនយោបាយដល់ក្រុមប្រឹក្សា ដើម្បីពិភាក្សា និងជជែកវែកញែក នៅពេលកំណត់អាទិភាព និងធ្វើសេចក្តីសម្រេចក្នុងនាមប្រជាពលរដ្ឋរបស់ខ្លួន (មាត្រា ២៥ នៃគំរូបទបញ្ជាផ្ទៃក្នុង)។

- ក្រុមប្រឹក្សាដែលជាប់ឆ្នោត មិនមែនគណៈអភិបាលឡើយដែលអនុម័តដីកា ផែនការអភិវឌ្ឍ ថវិកា កម្មវិធីវិនិយោគ របាយការណ៍ប្រចាំខែ ប្រចាំឆ្នាំ និងឯកសារសំខាន់ៗផ្សេងទៀត (មាត្រា ៣៧. ៤៤. ៥០. ៥៣ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ)។

- ក្រុមប្រឹក្សាទទួលបានមុខងារតាមវិស័យ និងធនធានសមស្រប ដើម្បីផ្តល់សេវា និងដោះស្រាយសិទ្ធិ និងតម្រូវការរបស់ប្រជាពលរដ្ឋ (មាត្រា ២១៥ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ)។
  - ក្រុមប្រឹក្សា គួរមានអាណត្តិច្បាស់លាស់ ដើម្បីអនុវត្តមុខងាររបស់ខ្លួន ដែលរួមមានសិទ្ធិអំណាច និងឆន្ទានុសិទ្ធិគ្រប់គ្រាន់ដើម្បីដោះស្រាយតម្រូវការ និងកង្វល់ពិតប្រាកដរបស់ប្រជាពលរដ្ឋ (មាត្រា ២២៥ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ)។
  - ក្រុមប្រឹក្សា គួរទទួលបានធនធានតាមឆន្ទានុសិទ្ធិគ្រប់គ្រាន់ ដើម្បីអនុវត្តមុខងាររបស់ខ្លួនក្នុងការដោះស្រាយតម្រូវការ និងកង្វល់ពិតប្រាកដរបស់ប្រជាពលរដ្ឋ។

> ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាឃុំ សង្កាត់ មានអំណាចដោយឡែករបស់ខ្លួន ដើម្បីធ្វើសេចក្តីសម្រេច អនុវត្តមុខងារ និងប្រើប្រាស់ធនធានរបស់ខ្លួន។ ប្រការនេះ គឺជាបុរេល័ក្ខខ័ណ្ឌសម្រាប់ឱ្យក្រុមប្រឹក្សាទាំងនេះ មានគណនេយ្យភាពតាមបែបប្រជាធិបតេយ្យចំពោះប្រជាពលរដ្ឋ។ ការមានអំណាចដោយឡែករបស់ខ្លួន មានន័យថា ក្រុមប្រឹក្សាអាចធ្វើសេចក្តីសម្រេចដែលឆ្លើយតបទៅនឹងតម្រូវការពិតប្រាកដរបស់ប្រជាពលរដ្ឋខ្លួន (មាត្រា ១៧៤ នៃអនុក្រឹត្យលេខ២១៦ អ.ន.ក្រ.បក ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក)។

- ច្បាប់ស្តីពីការបោះឆ្នោតធានាថា ប្រជាពលរដ្ឋអាចបោះឆ្នោតឱ្យបញ្ជីបេក្ខជននៃគណបក្សនយោបាយណាមួយដែលខ្លួនពេញចិត្តនៅពេលបោះឆ្នោតម្តងៗ។
- ក្រុមប្រឹក្សានីមួយៗ ត្រូវរៀបចំវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់ជារៀងរាល់ឆ្នាំ ហើយផ្តល់ឱកាសដល់ប្រជាពលរដ្ឋឱ្យលើកសំណូមពរ ស្នើឱ្យបំភ្លឺបញ្ហានានា និងផ្តល់មតិយោបល់ដល់ក្រុមប្រឹក្សា របស់ខ្លួន (មាត្រា ៩, ៦៥, ១២១ នៃអនុក្រឹត្យលេខ២១៦ អ.ន.ក្រ.បក ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនង ការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាល ស្រុក)

✓ សកម្មភាព ឬសេចក្តីសម្រេចមិនស្របច្បាប់របស់ក្រុមប្រឹក្សា (ឬគណៈអភិបាល ឬបុគ្គលិករបស់ក្រុមប្រឹក្សា) ដែលមានផលប៉ះពាល់ជាអវិជ្ជមានមកលើប្រជាពលរដ្ឋ ត្រូវទទួលបានសំណងទូទាត់ (មាត្រា ៨៥ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ)។

- ✓ ក្រុមប្រឹក្សាទាំងអស់ ត្រូវគ្រប់គ្រងធនធានហិរញ្ញវត្ថុរបស់ខ្លួនទៅតាមរបៀបដែលមានតម្លាភាព និងមានគណនេយ្យភាពចំពោះប្រជាពលរដ្ឋរបស់ខ្លួន ( មាត្រា ៤៣ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ) ។

## គណនេយ្យភាពរបស់ក្រុមប្រឹក្សាចំពោះរដ្ឋាភិបាល

- ✓ ក្រុមប្រឹក្សា មានគណនេយ្យភាពចំពោះរាជរដ្ឋាភិបាលលើការអនុវត្តតាមរដ្ឋធម្មនុញ្ញ ច្បាប់ និងលិខិតបទដ្ឋាននានា ( មាត្រា ២៤, ៣៥ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ) ។

- ✓ សកម្មភាព ឬសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាដែលស្ថិតនៅក្រៅវិសាលភាពនៃសិទ្ធិអំណាចរបស់ខ្លួន គឺជាសកម្មភាព ឬសេចក្តីសម្រេចមិនស្របច្បាប់ ( មាត្រា ៧៨ ដល់ ៨៥ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ) ។

- ✓ ក្នុងករណីដែលក្រុមប្រឹក្សា អនុវត្តសកម្មភាព ឬធ្វើសេចក្តីសម្រេចមិនស្របច្បាប់ ក្រសួងមហាផ្ទៃនឹងណែនាំក្រុមប្រឹក្សាឱ្យចាត់វិធានការចាំបាច់ដើម្បីកែលម្អសកម្មភាព ឬសេចក្តីសម្រេចនោះឱ្យមានភាពស្របច្បាប់ ។ ក្រុមប្រឹក្សាត្រូវធ្វើការកែតម្រូវនៅក្នុងរយៈពេលមួយខែ ។ ក្រុមប្រឹក្សាត្រូវផ្សព្វផ្សាយជាសាធារណៈជាបន្ទាន់នូវសេចក្តីណែនាំរបស់ក្រសួងមហាផ្ទៃនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ( មាត្រា ៨៤ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ) ។

ក្រុមប្រឹក្សាខេត្តបានទទួលប្រតិភូកម្មឱ្យធានាអនុលោមភាពតាមច្បាប់នៅក្នុងខេត្ត ។ ដូច្នេះ ក្រុមប្រឹក្សាត្រូវធានាឱ្យបានថា សេចក្តីសម្រេច និងសកម្មភាពរបស់ក្រុមប្រឹក្សាក្រុង និងស្រុកអនុលោមទៅតាមរដ្ឋធម្មនុញ្ញ ច្បាប់ និងលិខិតបទដ្ឋានផ្សេងទៀត ។ ក្រុមប្រឹក្សាខេត្តគាំទ្រក្រុមប្រឹក្សាក្រុង និងស្រុក ដើម្បីធានាឱ្យមានអនុលោមភាពតាមច្បាប់ដូចក្រុមប្រឹក្សាឃុំ សង្កាត់ដែរ ( មាត្រា ១៩៥ នៃអនុក្រឹត្យលេខ២១៦ អ.ន.ក្រ.បក ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក) ។

- ✓ ក្រុមប្រឹក្សាទាំងអស់មានកាតព្វកិច្ចរាយការណ៍អំពីអំពើពុករលួយ ឬការរំលោភអំណាចនៅក្នុងតំបន់របស់ខ្លួនទៅក្រសួងមហាផ្ទៃ ( មាត្រា ៨៧ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ) ។

- ✓ នៅពេលក្រសួងខ្សែបណ្តោយ ផ្ទេរវិសហមជ្ឈការមុខងារតាមវិស័យ តាមរយៈប្រតិភូកម្មទៅក្រុមប្រឹក្សា ក្រុមប្រឹក្សានេះ មានគណនេយ្យភាពចំពោះក្រសួងខ្សែបណ្តោយក្នុងការអនុវត្តទៅតាមល័ក្ខខ័ណ្ឌនៃប្រតិភូកម្ម ។

- ✓ ក្រុមប្រឹក្សាឃុំ សង្កាត់ មានគណនេយ្យភាពចំពោះរាជរដ្ឋាភិបាលក្នុងការអនុវត្តទៅតាមច្បាប់ និងលិខិតបទដ្ឋានផ្សេងទៀត (មាត្រា ៥៤, ៥៨ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់)។

## គណនេយ្យភាពរបស់ក្រុមប្រឹក្សាចំពោះសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់

- ✓ ក្រុមប្រឹក្សារាជធានីភ្នំពេញ ខេត្ត ក្រុង ស្រុក និងខណ្ឌ មិនត្រឹមតែមានគណនេយ្យភាពចំពោះប្រជាពលរដ្ឋប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងចំពោះអ្នកបោះឆ្នោតរបស់ខ្លួន គឺសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ផងដែរ ។
- ✓ ក្រុង ត្រូវពិគ្រោះយោបល់ជាប្រចាំជាមួយក្រុមប្រឹក្សាសង្កាត់នៅក្នុងក្រុង។ ស្រុក ត្រូវពិគ្រោះយោប់ជាប្រចាំជាមួយក្រុមប្រឹក្សាឃុំ សង្កាត់នៅក្នុងស្រុក (មាត្រា ៦៤, ៦៥, ៧០, ១១៦, ១១៨, ១២១, ១៨០, ១៨១ នៃអនុក្រឹត្យ លេខ២១៦ អ.ន.ក្រ.បក ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក)។
- ✓ មេឃុំ ចៅសង្កាត់ មានសិទ្ធិចូលរួមនៅក្នុងគ្រប់កិច្ចប្រជុំរបស់ក្រុមប្រឹក្សាស្រុក និងលើកបញ្ហាដើម្បីពិភាក្សា។ មេឃុំ ចៅសង្កាត់ អាចផ្តល់មតិយោបល់លើបញ្ហានានា និងអាចលើកសំណូមពរនានាក្នុងពេលប្រជុំនោះតែមិនមានសិទ្ធិអនុម័តបានឡើយ (មាត្រា ១១៩ នៃអនុក្រឹត្យលេខ២១៦ អ.ន.ក្រ.បក ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនង ការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក)។
- ✓ ក្រៅពីនេះ ក្រុមប្រឹក្សាស្រុកត្រូវបានចាត់តាំងតំណាងរបស់ខ្លួនឱ្យចូលរួមកិច្ចប្រជុំរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ នៅក្នុងស្រុកដើម្បីរាយការណ៍អំពីសកម្មភាព និងប្រមូលសំណូមពរ តម្រូវការ ព័ត៌មាន និងបញ្ហាប្រឈមនានារបស់ក្រុមប្រឹក្សា ឃុំ សង្កាត់ (មាត្រា ១២០ នៃអនុក្រឹត្យលេខ២១៦ អ.ន.ក្រ.បក ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក)។

## គណនេយ្យភាពរបស់គណៈអភិបាលចំពោះក្រុមប្រឹក្សា

- ✓ គណៈអភិបាល មានគណនេយ្យភាពចំពោះក្រុមប្រឹក្សារបស់ខ្លួនទាក់ទងនឹងការអនុវត្តសេចក្តីសម្រេច និងដីការបស់ក្រុមប្រឹក្សា។ គណៈអភិបាល មានគណនេយ្យភាពចំពោះរាជរដ្ឋាភិបាលទាក់ទងនឹងការអនុវត្តតួនាទីរបស់ខ្លួនអនុលោមទៅតាមរដ្ឋធម្មនុញ្ញ ច្បាប់ និងលិខិតបទដ្ឋានជាធរមានផ្សេងទៀត (មាត្រា ២៧, ៨៤, ១៤៥

នៃអនុក្រឹត្យលេខ២១៦ អ.ន.ក្រ.បក ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក)។

- ✓ គណៈអភិបាល មានគណនេយ្យភាពចំពោះក្រុមប្រឹក្សា និងរាជរដ្ឋាភិបាលលើការគ្រប់គ្រងការងារប្រចាំថ្ងៃ និងមានគណនេយ្យភាពលើការធានាចីរភាពការងារនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន (មាត្រា ៧ នៃប្រកាស ១២៤៩ ស្តីពីការប្រជុំចូលកាន់តំណែង)។

- ✓ **ក្រុមប្រឹក្សា ពិនិត្យតាមដាន និងវាយតំលៃគណៈអភិបាល** ដើម្បីធានាឱ្យបានថា គណៈអភិបាលបំពេញភារកិច្ចរបស់ខ្លួនអនុលោមទៅតាមការណែនាំ និងសេចក្តីសម្រេចរបស់ក្រុមប្រឹក្សា និងអនុលោមទៅតាមច្បាប់ និងលិខិតបទដ្ឋានជាធរមានផ្សេងទៀត (មាត្រា ១៥៧ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មាត្រា ១៧, ៧៣, ១៣៥ នៃអនុក្រឹត្យលេខ២១៦ អ.ន.ក្រ.បក ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក)។

- ✓ គណៈអភិបាល ត្រូវ**រាយការណ៍នៅក្នុងការប្រជុំទាំងអស់របស់ក្រុមប្រឹក្សា** (មាត្រា ១៦៥ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ)។

- ✓ ក្រុមប្រឹក្សា អាចតម្រូវឱ្យគណៈអភិបាល **បំភ្លឺបញ្ហាផ្សេងៗ នៅក្នុងកិច្ចប្រជុំរបស់ក្រុមប្រឹក្សា** (មាត្រា ១៥៧ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ)។

- ✓ ក្នុងករណីដែលគណៈអភិបាលធ្វើសេចក្តីសម្រេច ឬអនុវត្តសកម្មភាពដែលបានអនុញ្ញាតដោយក្រុមប្រឹក្សា **សេចក្តីសម្រេច ឬសកម្មភាពនោះមិនមានសុពលភាពឡើយ** (មាត្រា ១៥៨ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ)។

- ✓ ក្រុមប្រឹក្សា អាចស្នើសុំ**បញ្ឈប់ការងាររបស់អភិបាល ឬអភិបាលរង ដោយសារបំពេញការងារមិនល្អ ឬមានការរំលោភក្រមសីលធម៌** (មាត្រា ១៥១, ១៥២ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ)។

## គណនេយ្យភាពរបស់អភិបាល

✓ អភិបាល គឺជា**ប្រធានគណៈអភិបាល** ដូច្នេះគាត់ត្រូវបំរើការងារអោយក្រុមប្រឹក្សា និងមានគណនេយ្យភាពចំពោះក្រុមប្រឹក្សា។

✓ អភិបាល ក៏ជាតំណាងរបស់ក្រសួង និងស្ថាប័នរបស់រាជរដ្ឋាភិបាលនៅក្នុងការត្រួតពិនិត្យ សម្របសម្រួល និងតំរង់ទិសមន្ទីរ និងអង្គភាពខ្សែបណ្តោយទាំងអស់ដែលដំណើរការនៅក្នុងដែនដីរបស់ក្រុមប្រឹក្សា។ ដូច្នេះនៅក្នុងតួនាទីនេះ អភិបាលបំរើការងារជាតំណាងរាជរដ្ឋាភិបាល និងមានគណនេយ្យភាពចំពោះរាជរដ្ឋាភិបាល និងក្រសួង ស្ថាប័នដែលពាក់ព័ន្ធរបស់រាជរដ្ឋាភិបាល ( មាត្រា ១៥៤ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ) ។

ចំពោះព័ត៌មានបន្ថែមស្តីពីអភិបាល និង គណៈ-អភិបាល សូមអានមេរៀនទី ៦ ។

## គណនេយ្យភាពផ្សេងទៀត

✓ គណៈកម្មាធិការរបស់ក្រុមប្រឹក្សា មានគណនេយ្យភាពចំពោះក្រុមប្រឹក្សា។ គ្រប់ក្រុមប្រឹក្សា មានការទទួលខុសត្រូវចំពោះសេចក្តីសម្រេច និងសកម្មភាពទាំងអស់ដែលអនុវត្តដោយ**គណៈកម្មាធិការរបស់ក្រុមប្រឹក្សា** ( មាត្រា ១២១ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ) ។

✓ **បុគ្គលិករបស់ក្រុមប្រឹក្សា**រួមទាំងនាយករដ្ឋបាល និងប្រធានហិរញ្ញវត្ថុ ត្រូវមានគណនេយ្យភាពចំពោះគណៈ-អភិបាល និង**មានគណនេយ្យភាពជាចុងក្រោយចំពោះក្រុមប្រឹក្សារបស់ខ្លួន** ( មាត្រា ១៧៤, ១៧៧, ១៧៨, ១៨៤, ១៩០ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ) ។

ចំពោះព័ត៌មានបន្ថែមស្តីពីបុគ្គលិកក្រុមប្រឹក្សា សូមអានមេរៀនទី ៨ ។

✓ គ្រប់**ក្រុមប្រឹក្សាស្រុក ត្រូវមានគណនេយ្យភាពចំពោះក្រុមប្រឹក្សាឃុំ សង្កាត់** នៅក្នុងដែនដីរបស់ខ្លួនលើជំរើសសេចក្តីសម្រេច និង ការងាររបស់ក្រុមប្រឹក្សាស្រុក ( មាត្រា ៩៨ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ) ។

✓ ស្មៀនឃុំ សង្កាត់ មានគណនេយ្យភាពចំពោះក្រុមប្រឹក្សាឃុំ សង្កាត់របស់ខ្លួន ( មាត្រា ២៨ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ មាត្រា ៥ នៃប្រកាសស្តីពីតួនាទី ភារកិច្ច និងសិទ្ធិរបស់ស្មៀនឃុំ សង្កាត់) ។

### យន្តការគណនេយ្យភាព

✓ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ កំណត់ទំនាក់ទំនងថ្មីនៅក្នុងគណនេយ្យភាពរួមទាំងទំនាក់ទំនងនៃគណនេយ្យភាពតាមបែបប្រជាធិបតេយ្យដូចដែលបានពិភាក្សាខាងលើ។ ដោយសារច្បាប់រៀបចំអង្គការ និងលិខិតបទដ្ឋាននានាសម្រាប់អនុវត្តច្បាប់នេះបានកំណត់អំពីខ្សែគណនេយ្យភាពថ្មីៗជាច្រើនត្រូវបានទទួលយកដោយក្រុមប្រឹក្សា។ ហេតុនេះជាការចាំបាច់ណាស់ដែលត្រូវមានយន្តការគណនេយ្យភាពយ៉ាងរឹងមាំដើម្បីអនុវត្តបទបញ្ញត្តិអំពីគណនេយ្យភាពនៅក្នុងច្បាប់ និងលិខិតបទដ្ឋានអនុវត្តច្បាប់។

### គណនេយ្យភាពរបស់ក្រុមប្រឹក្សាស្រុកចំពោះក្រុមប្រឹក្សាឃុំ សង្កាត់ និងចំពោះប្រជាពលរដ្ឋ



## និន្នាការទូទៅនៃខ្សែគណនេយ្យភាព



## ផ្នែកទី ៥: សមធម៌នៅក្នុងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

**ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ**

**មាត្រា ១២. ៣៩. ១១៤.១១៨.១២៨. ១២៩. ១៧៦. ២១៥**

ការដោះស្រាយបញ្ហារបស់ប្រជាពលរដ្ឋបានត្រឹមត្រូវដោយមិនគិតអំពីឋានៈនៅក្នុងសង្គម គឺជាសមាសធាតុដ៏សំខាន់មួយទៀត នៅក្នុងការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ និងអភិបាលកិច្ចល្អ។ អ្នកមានទ្រព្យសម្បត្តិស្តុកស្តម្ភ និងអ្នកមានអំណាច មិនគួរទទួលបានសេវាសាធារណៈប្រសើរជាង ឬហ័សជាងជនក្រីក្រ ឬជនជាតិភាគតិចឡើយ។ ប្រជាពលរដ្ឋគ្រប់រូប មានសិទ្ធិដូចគ្នាក្នុងការទទួលបានសេវាសាធារណៈ។ ដូច្នេះ ក្រុមប្រឹក្សាមានការទទួលខុសត្រូវក្នុងការធានាឱ្យបានថា ប្រជាពលរដ្ឋទាំងអស់របស់ខ្លួនរួមមានស្ត្រី បុរស យុវជន ជនក្រីក្រ ជនជាតិដើមភាគតិច មានឱកាសប្រកបដោយអត្ថន័យដើម្បីចូលរួមនៅក្នុងដំណើរការអភិបាលកិច្ចមូលដ្ឋាន និងទទួលបានផលប្រយោជន៍ស្មើគ្នាពីអភិបាលកិច្ចមូលដ្ឋានរួមទាំងសេវាសាធារណៈនានាដែលផ្តល់ជូនពីដំណើរការនេះ។

ដូចមានបញ្ជាក់នៅក្នុងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ សមធម៌មានសារៈសំខាន់ចំពោះការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យដូចគ្នានឹងតម្លាភាព ការចូលរួម និងការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយដែរ (មាត្រា ១២ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ)។

✓ **ផែនការអភិវឌ្ឍ**របស់ក្រុមប្រឹក្សាទាំងអស់ ត្រូវពិចារណាអំពី**តម្រូវការខុសៗគ្នារបស់ស្ត្រី បុរស យុវជន កុមារ និងក្រុមងាយរងគ្រោះ** រួមមានជនក្រីក្រ និងជនជាតិដើមភាគតិច (មាត្រា ៣៩ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ)។

✓ ដើម្បីធានាឱ្យបានថា ក្រុមប្រឹក្សាពិចារណាអំពីតម្រូវការ ផលប្រយោជន៍ និងអាទិភាពរបស់ស្ត្រី និង កុមារ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ តម្រូវឱ្យក្រុមប្រឹក្សានីមួយៗ បង្កើត**គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ** (មាត្រា ១១៤ និង១២៨ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ)។

✓ សមាជិកពីររូបរបស់គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ មានសិទ្ធិ**ចូលរួមការប្រជុំទាំងអស់**របស់ក្រុមប្រឹក្សា គណៈអភិបាល និងគណៈកម្មាធិការផ្សេងទៀតរបស់ក្រុមប្រឹក្សា ដើម្បីផ្តល់អនុសាសន៍ក្នុងបំណងឱ្យ

សមភាពយេនឌ័រ និងបញ្ហារបស់ស្ត្រី និងកុមារត្រូវបានលើកយកមកពិចារណាជាប្រចាំ។ **គណៈកម្មាធិការ នេះ** ត្រូវលើកសំណូមពរជូនក្រុមប្រឹក្សា ដើម្បីលើកទឹកចិត្តឱ្យស្ត្រីចូលរួមយ៉ាងសកម្មនៅក្នុងអភិបាលកិច្ចល្អ (មាត្រា ១២៨, ១២៩ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ)។

✓ ក្រុមប្រឹក្សាក៏ត្រូវធានាឱ្យបានផងដែរថា ស្ត្រី**មានតំណាងនៅក្នុងគណៈកម្មាធិការទាំងអស់**របស់ក្រុមប្រឹក្សា ដែលមានជាប្រធាន ឬអនុប្រធាន (មាត្រា ១១៨ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ)។

✓ នៅក្នុងការជ្រើសរើស និងតែងតាំង**បុគ្គលិក** ក្រុមប្រឹក្សាត្រូវធានាឱ្យមានតំណាងសមស្របរបស់ស្ត្រីទាំងនៅក្នុងចំណោមប្រធាន និងអនុប្រធានអង្គភាពនានារបស់ក្រុមប្រឹក្សា (មាត្រា ១៧៦ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ)។

✓ គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប) នឹងពិនិត្យមើលឡើងវិញលើមុខងារតាមវិស័យរបស់រដ្ឋាភិបាល ដើម្បីធានាអោយមានការផ្ទេរមុខងារ និងធនធានសមស្របឱ្យក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឱ្យក្រុមប្រឹក្សាឃុំ សង្កាត់។ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មានរាយជាបញ្ជីអំពីវិស័យជាអាទិភាពដែលគណៈកម្មាធិការជាតិត្រូវផ្តោតការយកចិត្តទុកដាក់ជាបឋមរួមមាន សុខាភិបាល អាហារូបត្ថម្ភ និងសេវាសម្រាប់ប្រជាជនរួមទាំង**តម្រូវការផ្សេងទៀតរបស់ស្ត្រី បុរស យុវជន កុមារ ក្រុមជនងាយរងគ្រោះ និងជនជាតិដើមភាគតិច** (មាត្រា ២១៥ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ)។

### បញ្ហាដែលត្រូវដោះស្រាយ

ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ លើកឡើងជាញឹកញាប់អំពីគណនេយ្យភាព ប៉ុន្តែនៅមានសំណួរជាច្រើនដែលមិនទាន់មានចំលើយដូចជា:

- តើគណនេយ្យភាពតាមបែបប្រជាធិបតេយ្យពីក្រុមប្រឹក្សាចំពោះប្រជាពលរដ្ឋ អាចត្រូវអនុវត្តជាក់ស្តែងយ៉ាងដូចម្តេច?
- តើគណនេយ្យភាពនៅក្នុងចំណោមតួអង្គនានារបស់រដ្ឋបាលនៅថ្នាក់ក្រោមជាតិ អាចត្រូវអនុវត្តយ៉ាងដូចម្តេចនៅក្នុងស្ថានភាពជាក់ស្តែង (ដូចជារវាងក្រុមប្រឹក្សាជាមួយគណៈអភិបាល)?
- តើទំនាក់ទំនងរវាងក្រសួងមហាផ្ទៃ និងគណៈអភិបាលអាចត្រូវកំណត់យ៉ាងដូចម្តេច ដើម្បីជំរុញសិទ្ធិអំណាចរបស់ក្រុមប្រឹក្សាលើគណៈអភិបាល?
- តើក្រុមប្រឹក្សាអាចធ្វើដូចម្តេច ដើម្បីឱ្យអភិបាល និងគណៈអភិបាលមានគណនេយ្យភាព?
- តើគណនេយ្យភាព និងការឆ្លើយតបចំពោះក្រុមប្រឹក្សាឃុំ សង្កាត់ អាចត្រូវធានាយ៉ាងដូចម្តេច (ឧទាហរណ៍ ដើម្បីធានាឱ្យបានថាខេត្តពិចារណាតម្រូវការ និងការទាមទាររបស់ក្រុមប្រឹក្សាឃុំ សង្កាត់)?
- តើប្រព័ន្ធរាយការណ៍ប្រភេទណាដែលចាំបាច់ ដើម្បីផ្សារភ្ជាប់ស្រុកជាមួយក្រុមប្រឹក្សាឃុំ?
- តើក្រុមប្រឹក្សាឃុំអាចមានឥទ្ធិពលយ៉ាងដូចម្តេចទៅលើការកសាងផែនការរបស់ស្រុក និងធានាគណនេយ្យភាព និងការឆ្លើយតបចំពោះប្រជាពលរដ្ឋរបស់ខ្លួន ?
- តើសង្កាត់នៅរាជធានី និងក្រុងនឹងទទួលបានព័ត៌មានជាប្រចាំតាមវិធីណា ហើយតើសង្កាត់ទាំងនេះបញ្ជាក់ពីបំណងរបស់ខ្លួន និងធ្វើឱ្យមានឥទ្ធិពលលើសេចក្តីសម្រេចរបស់ក្រុមប្រឹក្សារាជធានី និងក្រុងតាមរបៀបណា?

# វគ្គទី ២

# មេរៀនសង្ខេប

- ✓ ច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ផ្ដល់ឱ្យក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ នូវយន្តការជាច្រើនដើម្បីបំពេញការងារអនុលោមទៅតាមគោលការណ៍អភិបាលកិច្ចល្អ ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ និងគណនេយ្យភាពតាមបែបប្រជាធិបតេយ្យ ។
- ✓ ក្រុមប្រឹក្សាទាំងអស់ គឺជាអ្នកតំណាងសាធារណៈ ជាអ្នកការពារ និងជាអ្នកបំរើផលប្រយោជន៍របស់ប្រជាពលរដ្ឋទាំងអស់នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ។
- ✓ ការឆ្លើយតបសំដៅលើការទទួលខុសត្រូវរបស់តំណាងជាប់ឆ្នោតក្នុងការស្ដាប់សម្លេងរបស់ប្រជាពលរដ្ឋខ្លួន ដើម្បីពិចារណាបញ្ហាដែលប្រជាពលរដ្ឋលើកឡើង ហើយបន្ទាប់មកឆ្លើយតបឱ្យបានប្រសើរបំផុតតាមដែលអាចធ្វើទៅបាននៅក្នុងរង្វង់សិទ្ធិអំណាច និងធនធានរបស់ខ្លួន ។
- ✓ គណនេយ្យភាពតាមបែបប្រជាធិបតេយ្យមានន័យថា តំណាងជាប់ឆ្នោតដែលមានគណនេយ្យភាពតាមបែបប្រជាធិបតេយ្យដោយប្រកាន់យកជម្រើសដោយផ្អែកលើព័ត៌មាន បែងចែកធនធានដែលខ្លួនមាន និងអនុវត្តមុខងារ និងភារកិច្ចរបស់ខ្លួនដើម្បីជាប្រយោជន៍សាធារណៈ និងដើម្បីឆ្លើយតបនឹងតម្រូវការដែលបានលើកឡើងនៅមូលដ្ឋាន។ គណនេយ្យភាពតាមបែបប្រជាធិបតេយ្យកើតមាននៅពេលប្រជាពលរដ្ឋអាចកំណត់ផលវិបាកទៅលើតំណាងជាប់ឆ្នោតចំពោះជម្រើសដែលតំណាងជាប់ឆ្នោតប្រកាន់យក របៀបដែលតំណាងជាប់ឆ្នោតបែងចែកធនធានដែលខ្លួនមាន និងចំពោះការអនុវត្តមុខងារ និងភារកិច្ចរបស់ខ្លួន ។
- ✓ ជាទូទៅ កិច្ចប្រជុំរបស់ក្រុមប្រឹក្សាត្រូវធ្វើឡើងជាសាធារណៈ និងបើកចំហចំពោះប្រជាពលរដ្ឋ។ ប្រជាពលរដ្ឋមិនចាំបាច់ត្រូវមានលិខិតអញ្ជើញដើម្បីចូលរួមក្នុងកិច្ចប្រជុំរបស់ក្រុមប្រឹក្សាឡើយ ។
- ✓ ក្រុមប្រឹក្សា ត្រូវរៀបចំវេទិកាផ្សព្វផ្សាយពិគ្រោះយោបល់ប្រចាំឆ្នាំ ដែលនៅក្នុងវេទិកានេះសម្លេងរបស់ប្រជាពលរដ្ឋអាចត្រូវស្ដាប់ ប្រជាពលរដ្ឋអាចលើកសំណូមពរ លើកបញ្ហា និងផ្ដល់មតិយោបល់ ។

- ✓ ក្រៅពីនេះ ក្រុមប្រឹក្សាអាចអភិវឌ្ឍយុទ្ធសាស្ត្រដើម្បីពិគ្រោះយោបល់ជាប្រចាំជាមួយប្រជាពលរដ្ឋរបស់ខ្លួន ដើម្បីឱ្យប្រជាពលរដ្ឋទទួលបានព័ត៌មាន និងចូលរួមចំណែក រួមទាំងទាក់ទងនឹងផែនការអភិវឌ្ឍន៍ផងដែរ។
- ✓ ក្រុមប្រឹក្សា ត្រូវផ្សព្វផ្សាយដល់សាធារណជនអំពីដីកា របាយការណ៍ របៀបវារៈ និងកំណត់ហេតុនៃកិច្ចប្រជុំរបស់ក្រុមប្រឹក្សា ផែនការអភិវឌ្ឍន៍ ថវិកា របាយការណ៍ប្រចាំឆ្នាំ និងឯកសារ និងសេចក្ដីសម្រេចសំខាន់ៗផ្សេងទៀតរបស់ក្រុមប្រឹក្សា។
- ✓ គណៈអភិបាល មានគណនេយ្យភាពចំពោះក្រុមប្រឹក្សា។ នៅទីបញ្ចប់ បុគ្គលិករបស់ក្រុមប្រឹក្សាមានគណនេយ្យចំពោះក្រុមប្រឹក្សា។
- ✓ ក្រុមប្រឹក្សា ត្រូវធានាឱ្យបានថា ប្រជាពលរដ្ឋទាំងអស់របស់ខ្លួនគឺស្ត្រី បុរស យុវជន កុមារ ក្រុមជនងាយរងគ្រោះ និង ក្រុមជនជាតិដើមភាគតិចមានឱកាសប្រកបដោយអត្ថន័យ ដើម្បីចូលរួម និងទទួលបានផលប្រយោជន៍ស្មើគ្នាពីអភិបាលកិច្ចមូលដ្ឋាន។

## វគ្គទី ៣:

## ការងារជាក្រុម

**ការងារជាក្រុម ដូចមានពិពណ៌នាខាងក្រោម អាចមានលក្ខណៈមិនសមស្របសម្រាប់ការបណ្តុះបណ្តាលទាំងអស់ ។ សូមចាត់ទុកការងារជាក្រុមខាងក្រោមជាសំណូមពរតែប៉ុណ្ណោះ ។**

១. ចែកសិក្ខាកាមជាក្រុមដែលមានសមាជិកមិនលើសពី ៨ នាក់

២. ផ្តល់លំហាត់ខាងក្រោមអោយក្រុមនីមួយៗ ។

**លំហាត់ទី ១: គណនេយ្យភាពតាមបែបប្រជាធិបតេយ្យ**

ពិភាក្សាសំណួរខាងក្រោមនៅក្នុងក្រុម:

- តើលោក អ្នកគិតថា គណនេយ្យភាពតាមបែបប្រជាធិបតេយ្យ អាចត្រូវបង្កើតឡើងថ្នាក់ក្រោមជាតិនៅប្រទេសកម្ពុជាឬទេ? ហេតុបានជាបង្កើតបាន ឬ ហេតុអ្វីបានជាបង្កើតមិនបាន?
- ជាសមាជិកក្រុមប្រឹក្សា តើលោក អ្នកអាចធ្វើអ្វី ដើម្បីបង្កើតគណនេយ្យភាពតាមបែបប្រជាធិបតេយ្យនៅក្នុងតំបន់របស់លោក អ្នក?

**លំហាត់ទី ២: គណនេយ្យភាព**

ពិភាក្សាសំណួរខាងក្រោមនៅក្នុងក្រុម:

- តើក្រុមប្រឹក្សាថ្មី អាចធ្វើដូចម្តេច ដើម្បីឱ្យគណៈអភិបាល មានគណនេយ្យភាព?
- តើក្រុមប្រឹក្សាឃុំ សង្កាត់ អាចធ្វើដូចម្តេច ដើម្បីឱ្យក្រុមប្រឹក្សាស្រុក និង ក្រុង និង ក្រុមប្រឹក្សារាជធានីភ្នំពេញ មានគណនេយ្យភាព?

### លំហាត់ទី ៣: តម្លាភាព

ពិភាក្សាសំណួរខាងក្រោមនៅក្នុងក្រុម:

- ហេតុអ្វីបានជាអ្នកគិតថា តម្លាភាពមានសារៈសំខាន់ចំពោះប្រជាពលរដ្ឋ?
- តើតម្លាភាព និង គណនេយ្យភាព មានទំនាក់ទំនងជាមួយគ្នាយ៉ាងដូចម្តេច?
- តើមធ្យោបាយដែលមានការច្នៃប្រឌិតមួយចំនួន ដើម្បីឱ្យក្រុមប្រឹក្សាខេត្ត ផ្សព្វផ្សាយព័ត៌មានដល់ប្រជាពលរដ្ឋរបស់ខ្លួន មានអ្វីខ្លះ? ( *ក្រៅពី*ការបិទផ្សាយព័ត៌មាននៅលើក្តារព័ត៌មាន)
- តើវិធីជាក់លាក់អ្វីខ្លះ ដើម្បីធានាឱ្យបានថា ព័ត៌មានពីក្រុមប្រឹក្សាស្រុក *ពិតជាត្រូវបានទទួល* ដោយស្ត្រី? យុវជន? ជនក្រីក្រ? ជនជាតិភាគតិច?

### លំហាត់ទី ៤: ការចូលរួមចំណែករបស់ប្រជាពលរដ្ឋ

ពិភាក្សាសំណួរខាងក្រោមនៅក្នុងក្រុម:

- តើក្រុមប្រឹក្សាអាចធ្វើដូចម្តេច ដើម្បីលើកទឹកចិត្តប្រជាពលរដ្ឋរបស់ខ្លួនឱ្យចូលរួមនៅក្នុងការប្រជុំរបស់ក្រុមប្រឹក្សា ?
- តើយុទ្ធសាស្ត្រមួយចំនួនដែលក្រុមប្រឹក្សា ត្រូវប្រើប្រាស់ ដើម្បីពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋរបស់ខ្លួន នៅក្នុងពេលរៀបចំផែនការអភិវឌ្ឍន៍រយៈពេល ៥ ឆ្នាំរបស់ក្រុមប្រឹក្សា មានអ្វីខ្លះ?

# មេរៀនសម្រាប់ការយល់ដឹង និង
# ការបណ្តុះបណ្តាលអំពី
# ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល រាជធានី
# ខេត្ត ក្រុង ស្រុក ខណ្ឌ

## មេរៀនទី ៣

## រចនាសម្ព័ន្ធរដ្ឋបាលថ្នាក់ក្រោមជាតិ

## វគ្គទី ១:

១. សេចក្តីផ្តើម

២. ក្រុមប្រឹក្សា និង សមាជិកក្រុមប្រឹក្សា

៣. អភិបាល និង គណៈអភិបាល

៤. គណៈកម្មាធិការរបស់ក្រុមប្រឹក្សា

៥. បុគ្គលិករបស់ក្រុមប្រឹក្សា

## ផ្នែកទី ១: សេចក្តីផ្តើម

✓ រាជធានី ខេត្ត ក្រុង ស្រុក និងខណ្ឌទាំងអស់ មានមូលដ្ឋានរចនាសម្ព័ន្ធស្មើរដូចគ្នាទាំងអស់ ដូចបង្ហាញនៅក្នុងដ្យាក្រាមខាងក្រោម ។



## រចនាសម្ព័ន្ធសាលាខេត្ត



## រចនាសម្ព័ន្ធសាលាក្រុង



## រចនាសម្ព័ន្ធសាលាស្រុក



**រចនាសម្ព័ន្ធសាលាខណ្ឌ**




✓ សមាសភាគនីមួយៗ នៃអង្គការចាត់តាំងនេះ ត្រូវបានពិភាក្សាខាងក្រោម ។ តួនាទី និង មុខងាររបស់សមាសភាគនីមួយៗ ត្រូវបានកំណត់នៅក្នុងមេរៀនដូចតទៅ:

- តួនាទី សិទ្ធិអំណាច និង មុខងាររបស់ក្រុមប្រឹក្សា : មេរៀនទី ៥
- តួនាទី និង មុខងាររបស់អភិបាល និង គណៈអភិបាល : មេរៀនទី ៦
- គណៈកម្មាធិការរបស់ក្រុមប្រឹក្សា : មេរៀនទី ៧
- បុគ្គលិករបស់ក្រុមប្រឹក្សា : មេរៀនទី ៨

## អត្ថន័យនៃពាក្យ "រដ្ឋបាល"

ពាក្យថា "រដ្ឋបាលខេត្ត" សំដៅលើក្រុមប្រឹក្សាខេត្ត និងគណៈអភិបាលខេត្ត។ ពាក្យថា "រដ្ឋបាលស្រុក" សំដៅលើក្រុមប្រឹក្សាស្រុក និងគណៈអភិបាលស្រុក។ ពាក្យថា "រដ្ឋបាលក្រុង" "រដ្ឋបាលរាជធានី" និង "រដ្ឋបាលខណ្ឌ" មានន័យដូចខាងលើដែរ។ (មាត្រា២ នៃអនុក្រឹត្យលេខ២១៦ អ.ន.ក្រ.បក ស្ដីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក)

## ផ្នែកទី ២: ក្រុមប្រឹក្សា និង សមាជិកក្រុមប្រឹក្សា

**ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ**

**មាត្រា ១០, ១៣, ១៧, ១៩, ៣០, ៣៤, ៣៦-៤៣, ៦៣, ៦៦-៧៧, ៦៨-៦៩, ៧១-៧៣, ១៥៨, ២២៥**

- ✓ ក្រុមប្រឹក្សារាជធានីភ្នំពេញ និងគ្រប់ក្រុមប្រឹក្សាខេត្ត ក្រុង ស្រុក និងខណ្ឌ មានសមាជិកក្រុមប្រឹក្សាដែល**ត្រូវបោះឆ្នោតជ្រើសរើសឡើងជាអសកលដោយសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់**។ ចំនួនសមាជិកក្រុមប្រឹក្សាសម្រាប់ក្រុមប្រឹក្សានីមួយៗ ត្រូវកំណត់ដោយអនុក្រឹត្យផ្អែកលើកត្តាប្រជាសាស្ត្រ និងភូមិសាស្ត្ររបស់តំបន់។ ទោះជាយ៉ាងណាក៏ដោយ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ បញ្ជាក់ចន្លោះនៃចំនួនសមាជិកក្រុមប្រឹក្សាសម្រាប់ក្រុមប្រឹក្សានីមួយៗ (មាត្រា ១៨ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ សូមអានមាត្រា ១២ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ផងដែរចំពោះក្រុមប្រឹក្សាឃុំ សង្កាត់)។

- ✓ ឧទាហរណ៍ ក្រុមប្រឹក្សារាជធានីភ្នំពេញ ក្រុមប្រឹក្សាខេត្តកំពង់ចាម ក្រុមប្រឹក្សាខេត្តកណ្តាល មានសមាជិកក្រុមប្រឹក្សាចំនួន២១នាក់សម្រាប់ខេត្តនីមួយៗ រីឯក្រុមប្រឹក្សាខេត្តមណ្ឌលគិរី ក្រុមប្រឹក្សាខេត្តប៉ៃលិន និងក្រុមប្រឹក្សាក្រុងកែប មានសមាជិកក្រុមចំនួន៩នាក់សម្រាប់ខេត្តនីមួយៗ (មាត្រា ១ នៃអនុក្រឹត្យស្តីពីចំនួនសមាជិកក្រុមប្រឹក្សា)។

| | | | |
|---|---|---|---|
| ក្រុមប្រឹក្សារាជធានីភ្នំពេញ<br>សមាជិកអតិ. ២១ រូប | | ក្រុមប្រឹក្សាខេត្ត<br>សមាជិកពី ៩ ទៅ ២១ រូប | |
| ក្រុមប្រឹក្សាខណ្ឌ<br>សមាជិកពី ៧ ទៅ ១៩ រូប | ក្រុមប្រឹក្សាក្រុង<br>សមាជិកពី ៧ ទៅ ១៥ រូប | ក្រុមប្រឹក្សាស្រុក<br>សមាជិកពី ៧ ទៅ ១៩ រូប | |
| ក្រុមប្រឹក្សាសង្កាត់<br>សមាជិកពី ៥ ទៅ ១១ រូប | ក្រុមប្រឹក្សាសង្កាត់<br>សមាជិកពី ៥ ទៅ ១១ រូប | ក្រុមប្រឹក្សាឃុំ<br>សមាជិកពី ៥ ទៅ ១១ រូប | ក្រុមប្រឹក្សាសង្កាត់<br>សមាជិកពី ៥ ទៅ ១១ រូប |

✓ សមាជិកក្រុមប្រឹក្សា **មានការទទួលខុសត្រូវក្នុងការធ្វើសេចក្ដីសំរេចទាំងអស់**សម្រាប់ក្រុមប្រឹក្សា។ សមាជិកក្រុមប្រឹក្សា ធ្វើសេចក្ដីសម្រេចក្នុងនាមប្រជាពលរដ្ឋរបស់ខ្លួន (មាត្រា ១៩, ៣០, ៣៦, ១៥៨ នៃច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងមាត្រា ៦, ៦១, ១១៣ នៃអនុក្រឹត្យលេខ ២១៦ អ.ន.ក្រ.បក ស្ដីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក)។

✓ **ក្រុមប្រឹក្សា មានគណនេយ្យភាពតាមបែបប្រជាធិបតេយ្យចំពោះប្រជាពលរដ្ឋរបស់ខ្លួន** (មាត្រា ៣៤, ៤៣, ២២៥ នៃច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ)។

> ចំពោះព័ត៌មានបន្ថែមស្ដីពីតួនាទី ការទទួលខុសត្រូវ និងមុខងាររបស់សមាជិកក្រុមប្រឹក្សា សូមអានមេរៀនទី៥។

✓ ក្រុមប្រឹក្សាទាំងអស់ មាន**ប្រធាន**មួយរូបដែលធ្វើជាអធិបតីនៃការប្រជុំទាំងអស់របស់ក្រុមប្រឹក្សា។ ប្រធាន គឺជាបេក្ខជនដែលមានឈ្មោះនៅលើគេបង្អស់នៃបញ្ជីបេក្ខជនដែលទទួលបានសំលេងឆ្នោត ច្រើនជាងគេបំផុតនៅក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា (មាត្រា ១៧, ៦៣ នៃច្បាប់ស្ដីពីការគ្រប់គ្រង រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងប្រការ ៣, ២០, ២១ នៃគំរូបទបញ្ជាផ្ទៃក្នុង)។

✓ សមាជិកក្រុមប្រឹក្សា ត្រូវចូលរួមនៅក្នុង**ការប្រជុំរបស់ក្រុមប្រឹក្សា**។ សមាជិកក្រុមប្រឹក្សាគ្រប់រូបមានសិទ្ធិបោះឆ្នោតមួយសំលេង ដើម្បីអនុម័តលើបញ្ហាទាំងអស់ដែលតម្រូវក្រុមប្រឹក្សាអនុម័តក្នុងកិច្ចប្រជុំក្រុមប្រឹក្សា។ ក្នុងករណីមានសំលេងឆ្នោតស្មើគ្នា ប្រធានមានឧត្តមានុភាព (មាត្រា ៦៦, ៦៧ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងប្រការ ១៦, ៣៨ នៃគំរូបទបញ្ជាផ្ទៃក្នុង)។

✓ ក្រុមប្រឹក្សាទាំងអស់ត្រូវអនុម័ត**បទបញ្ជាផ្ទៃក្នុង**របស់ខ្លួនផ្ទាល់ ដែលត្រូវគោរពតាមនៅពេលប្រជុំ (មាត្រា ៦៩, ៧១ និង៧២ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងប្រកា១១ នៃគំរូបទបញ្ជាផ្ទៃក្នុង)។

✓ សមាជិកក្រុមប្រឹក្សា មាន***សេរីភាពក្នុងការបង្ហាញមតិយោបល់របស់ខ្លួន***នៅក្នុងកិច្ចប្រជុំរបស់ក្រុមប្រឹក្សា។ សមាជិកក្រុមប្រឹក្សា មិនអាចទទួលរងទណ្ឌកម្មដោយសារមតិយោបល់ ឬការបោះឆ្នោតរបស់ខ្លួននៅក្នុងការប្រជុំរបស់ក្រុមប្រឹក្សាឡើយ (មាត្រា ៧៣ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងប្រការ ២២ នៃគំរូបបទបញ្ជាផ្ទៃក្នុង)។

**គំរូបទបញ្ជាផ្ទៃក្នុង**

គ.ជ.អ.ប បានដាក់ចេញបទបញ្ជាផ្ទៃក្នុងដែលក្រុមប្រឹក្សាអាចប្រើប្រាស់នៅពេលក្រុមប្រឹក្សាអភិវឌ្ឍ និងអនុម័តបទបញ្ជាផ្ទៃក្នុងរបស់ខ្លួនផ្ទាល់ ។ គំរូបទបញ្ជាផ្ទៃក្នុងចែង**លក្ខខណ្ឌអប្បបរមា**ដែលអាចត្រូវបន្ថែម និងអនុវត្តដោយក្រុមប្រឹក្សានីមួយៗ។

✓ ការប្រជុំរបស់ក្រុមប្រឹក្សា ត្រូវ**បើកចំហជាសាធារណៈ** ។ ប្រជាពលរដ្ឋមានសិទ្ធិចូលរួមកិច្ចប្រជុំរបស់ក្រុមប្រឹក្សាដោយមិនចាំបាច់មានលិខិតអញ្ជើញចូលរួមប្រជុំរបស់ក្រុមប្រឹក្សាឡើយ។ ការប្រជុំសំងាត់ អាចធ្វើឡើងតែនៅក្នុងកាលៈទេសៈពិសេសប៉ុណ្ណោះ (មាត្រា ៦៨ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងប្រការ ២៥ នៃគំរូបបទបញ្ជាផ្ទៃ ក្នុង)។

### គណនេយ្យភាពតាមបែបប្រជាធិបតេយ្យសំដៅលើ

*តំណាងជាប់ឆ្នោត ដែលមានគណនេយ្យភាពតាមបែបប្រជាធិបតេយ្យប្រកាន់យកជម្រើសដោយផ្អែកលើព័ត៌មាន បែងចែកធនធានដែលខ្លួនមាន និងអនុវត្តមុខងារ និងភារកិច្ចរបស់ខ្លួនដើម្បីជាប្រយោជន៍សាធារណៈ និងដើម្បីឆ្លើយតបនឹងតម្រូវការដែលបានលើកឡើងនៅមូលដ្ឋាន ។ គណនេយ្យភាពតាមបែបប្រជាធិបតេយ្យកើតមានឡើងនៅពេលប្រជាពលរដ្ឋអាចកំណត់ផលវិបាកទៅលើតំណាងជាប់ឆ្នោតចំពោះជម្រើសដែលតំណាងជាប់ឆ្នោតប្រកាន់យក របៀបដែលតំណាងជាប់ឆ្នោតបែងចែកធនធានដ៏មានកម្រិត និងចំពោះការអនុវត្តមុខងារ និងភារកិច្ចរបស់ខ្លួន ។*

ចំពោះព័ត៌មានបន្ថែមស្តីពីគណនេយ្យភាពតាមបែបប្រជាធិបតេយ្យ សូមអានមេរៀនទី ២ អំពីការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ ។

## ផ្នែកទី ៣: អភិបាល និង គណៈអភិបាល

**ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ**

**មាត្រា ១៣៨-១៧២**

✓ **រាជធានីភ្នំពេញ** និងគ្រប់**ខេត្ត ក្រុង ស្រុក** និង**ខណ្ឌ** មានគណៈអភិបាលមួយ ( មាត្រា ១៣៨ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ) ។ ក្រុមប្រឹក្សាឃុំ សង្កាត់មិនមានគណៈអភិបាលឡើយ ។

✓ គណៈអភិបាល មាន**អភិបាល** និង**អភិបាលរងមួយចំនួនដែលត្រូវតែងតាំងឡើង**។ អភិបាល គឺជាប្រធានរបស់គណៈអភិបាល ( មាត្រា ១៣៩ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ) ។

| **រាជធានីភ្នំពេញ និង ខេត្ត** | **ក្រុង ស្រុក និង ខណ្ឌ** |
|---|---|
| • គណៈអភិបាលមានសមាជិកពី ៣ ទៅ៧រូប | • គណៈអភិបាលមានសមាជិកពី ៣ ទៅ៥រូប |
| • អភិបាលត្រូវតែងតាំងដោយព្រះរាជក្រឹត្យ ( មានឋានន្តរសក្តិជាឧត្តមមន្ត្រី) | • អភិបាលត្រូវតែងតាំងដោយអនុក្រឹត្យ ( មានឋានន្តរសក្តិចាប់ពីអនុមន្ត្រី) |
| • អភិបាលរងត្រូវតែងតាំងដោយអនុក្រឹត្យ ( មានឋានន្តរសក្តិចាប់ពីវរមន្ត្រី) | • អភិបាលរងត្រូវតែងតាំងដោយប្រកាសរបស់ក្រសួងមហាផ្ទៃ ( មានឋានន្តរសក្តិចាប់ពីនាយក្រមការ) |

✓ អភិបាល គឺជា**ឧត្តមមន្ត្រី**។ អភិបាលរងគឺជាឧត្តមមន្ត្រី ឬវរមន្ត្រី។ អភិបាល និងអភិបាលរងនៃរដ្ឋបាលថ្នាក់ក្រោមជាតិតាមថ្នាក់ផ្សេងៗគ្នាត្រូវតែងតាំងដោយព្រះរាជក្រឹត្យ អនុក្រឹត្យ ឬប្រកាសក្រសួងមហាផ្ទៃ ( មាត្រា ១៤១ ដល់ ១៤៥ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ) ។

✓ **អាណត្តិ** របស់គណៈអភិបាលគឺ **៥ឆ្នាំ**។ អភិបាល ឬអភិបាលរងអាចត្រូវ**តែងតាំងឡើងវិញ** សម្រាប់អាណត្តិ ៥ ឆ្នាំបន្តទៀត ( មាត្រា ១៤៧ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ) ។

✓ គណៈអភិបាល **អនុវត្តសេចក្ដីសម្រេច និងដីការបស់ក្រុមប្រឹក្សា**។ គណៈអភិបាល **មានគណនេយ្យភាពចំពោះក្រុមប្រឹក្សា** (មាត្រា ១៥៥-១៥៨ នៃច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មាត្រា ២៧, ២៨, ៨៤, ៨៥, ១៤៥ នៃអនុក្រឹត្យលេខ ២១៦ អ.ន.ក្រ.បក ស្ដីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក និងប្រកាស ២៤, ៣១ នៃគំរូបទបញ្ជាផ្ទៃក្នុង)។

**តើវានឹងទៅជាយ៉ាងណាប្រសិនបើក្រុមប្រឹក្សា និងគណៈអភិបាលមិនឯកភាពគ្នា?**

គណៈអភិបាល ផ្ដល់អនុសាសន៍ឱ្យក្រុមប្រឹក្សា ប៉ុន្តែវាជាតួនាទី និងសិទ្ធិរបស់**ក្រុមប្រឹក្សាដែលជាប់ឆ្នោតក្នុងការធ្វើសេចក្ដីសម្រេចចុងក្រោយទាំងអស់ក្នុងនាមអ្នកបោះឆ្នោតឱ្យខ្លួន**។ ក្រុមប្រឹក្សាគឺជាអង្គធ្វើសេចក្ដីសំរេចសំរាប់ដែនដីរបស់ខ្លួន (មាត្រា ១០, ១៣, ១៥, ៣០, ៣៦, ១៥៨ នៃច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ)។

ក្នុងករណីដែលអភិបាល ឬគណៈអភិបាល ធ្វើសេចក្ដីសម្រេចដែលក្រុមប្រឹក្សាមិនបានអនុញ្ញាត **សេចក្ដីសំរេចរបស់អភិបាល ឬគណៈអភិបាលនោះ មិនមានសុពលភាពឡើយ** (មាត្រា ១៤៩, ១៥៨ នៃច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ)។

✓ អភិបាល និងអភិបាលរង អាចចូលរួម និងមានមតិនៅក្នុងការប្រជុំរបស់ក្រុមប្រឹក្សា ប៉ុន្តែគាត់**មិនមានសិទ្ធិបោះឆ្នោត**លើកិច្ចការអ្វីមួយឡើយ (មាត្រា ១៤៩ នៃច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ)។

ចំពោះព័ត៌មានបន្ថែមស្ដីពីអភិបាល និង គណៈអភិបាល សូមអានមេរៀនទី ៦ ។

**ការបញ្ឈប់ការងារ**

✓ អភិបាល ឬអភិបាលរង អាចត្រូវ**បញ្ឈប់ពីមុខតំណែងរបស់ខ្លួន** ដោយសារមូលហេតុជាក់លាក់មួយចំនួនរួមមាន ការបាត់បង់លក្ខណៈសម្បត្តិ ការងារមិនល្អ ការបាត់បង់សម្បទាវិជ្ជាជីវៈ ការរំលោភលើក្រមសីលធម៌ (មាត្រា ១៥១ នៃច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ)។

✓ ក្រុមប្រឹក្សា អាច**ស្នើសុំទៅក្រសួងមហាផ្ទៃ**អោយបញ្ឈប់ការងាររបស់អភិបាល ឬអភិបាលរងដោយផ្អែកលើមូលហេតុជាក់លាក់។ ក្រសួងមហាផ្ទៃ ត្រូវ**ធ្វើការស៊ើបអង្កេត**ជាបន្ទាន់ (មាត្រា ១៥២ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ)។

| ក្រុមប្រឹក្សា | គណៈអភិបាល |
|---|---|
| • បោះឆ្នោតដោយសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ | • តែងតាំងដោយរាជរដ្ឋាភិបាល |
| • មានអាណត្តិ ៥ឆ្នាំ | • មានអាណត្តិ ៤ឆ្នាំ |
| • ធ្វើសេចក្តីសំរេចសម្រាប់ដែនដីរបស់ខ្លួន | • ផ្តល់យោបល់បច្ចេកទេស និងអនុសាសន៍ដល់ក្រុមប្រឹក្សា |
| • ពិនិត្យមើលការងារគណៈអភិបាល | • អនុវត្តសេចក្តីសំរេច និងដីកាដែលក្រុមប្រឹក្សាធ្វើ |
| • មានគណនេយ្យភាពចំពោះប្រជាពលរដ្ឋ និងរាជរដ្ឋាភិបាល | • មានគណនេយ្យភាពចំពោះក្រុមប្រឹក្សា |
| | • រាយការណ៍ជូនក្រុមប្រឹក្សាជាប្រចាំ |
| • ពិនិត្យមើល ពិភាក្សា អនុម័តផែនការ និងថវិកាអភិវឌ្ឍ | • រៀបចំសេចក្តីព្រាងផែនការ និងថវិកាអភិវឌ្ឍ ដើម្បីឱ្យក្រុមប្រឹក្សាពិនិត្យ ពិភាក្សាអនុម័ត |
| • អាចស្នើសុំបញ្ឈប់ការងារអភិបាល/អភិបាលរង | |

## ផ្នែកទី ៤: គណៈកម្មាធិការរបស់ក្រុមប្រឹក្សា

**ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ**

**មាត្រា ១១៤-១៣៧**

### គោលបំណងនៃការបង្កើតគណៈកម្មាធិការរបស់ក្រុមប្រឹក្សា

- ✓ គណៈកម្មាធិការរបស់ក្រុមប្រឹក្សា គឺជាការប្រមូលផ្តុំនូវសមាសភាពនៃសមាជិកដែលមានទស្សនៈ និងជំនាញ-ឯកទេសផ្សេងៗគ្នា ដែលអាចផ្តោតទៅលើបញ្ហាសំខាន់ៗរបស់ក្រុមប្រឹក្សា។ គណៈកម្មាធិការទាំងនោះត្រូវរាយការណ៍ទៅក្រុមប្រឹក្សា។ តួនាទី ភារកិច្ចរបស់គណៈកម្មាធិការគឺត្រូវផ្តល់ព័ត៌មាន ឱ្យយោបល់ និងផ្តល់អនុសាសន៍ផ្សេងៗទៅឱ្យក្រុមប្រឹក្សា ធ្វើការសម្រេចចិត្ត។
- ✓ ព័ត៌មាន យោបល់ និងអនុសាសន៍ផ្សេងៗ ជួយឱ្យក្រុមប្រឹក្សាអាចធ្វើសេចក្តីសម្រេចចិត្តបានគ្រប់ជ្រុងជ្រោយ។ ដូចនេះ គណៈកម្មាធិការមានតួនាទី និងភារកិច្ចជួយធ្វើឱ្យប្រសើរឡើងដល់ការធ្វើសេចក្តីសម្រេចចិត្តរបស់ក្រុមប្រឹក្សា។
- ✓ គណៈកម្មាធិការ ក៏អាចជាយន្តការមួយសម្រាប់ធ្វើឱ្យមានការចូលរួមផងដែរ។ ក្រុមប្រឹក្សា អាចអនុញ្ញាតិឱ្យគណៈកម្មាធិការ អញ្ជើញតំណាងសហគមន៍ ឬប្រជាពលរដ្ឋណាមួយធ្វើជាទីប្រឹក្សារបស់គណៈកម្មាធិការនោះ។ (ច្បាប់គ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មាត្រា ១១៧)

### គណៈកម្មាធិការជាកាតព្វកិច្ច និងគណៈកម្មាធិការនានា

- ✓ ក្រុមប្រឹក្សានីមួយៗត្រូវបង្កើតគណៈកម្មាធិការជាកាតព្វកិច្ចចំនួនបី:
  - **គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស** ជាការប្រមូលផ្តុំនូវអ្នកពាក់ព័ន្ធសំខាន់ៗក្នុងរដ្ឋបាលឯកភាពដើម្បីធានាថា ការងារត្រូវបានសម្របសម្រួលក្នុងគោលបំណងទទួលបានលទ្ធផលប្រកបដោយប្រសិទ្ធិភាព។ គណៈកម្មាធិការនេះទទួលខុសត្រូវផ្តល់យោបល់ដល់ក្រុមប្រឹក្សា និងគណៈអភិបាលអំពីការសម្របសម្រួលការងាររបស់ក្រុមប្រឹក្សាជាមួយនឹងការងាររបស់របស់មន្ទីរ ការិយាល័យខ្សែបណ្តោយរបស់ក្រសួង និងធានាឱ្យបានថាផែនការ និងថវិការបស់ក្រសួង ស្ថាប័ន មន្ទីរ ការិយាល័យ និង អង្គភាពនានារបស់រាជរដ្ឋាភិបាលដែលផ្តល់សេវានៅក្នុងដែនដីរបស់ក្រុមប្រឹក្សា ត្រូវបានធ្វើសមាហរណកម្មទៅក្នុងផែនការអភិវឌ្ឍ និងថវិការបស់ក្រុមប្រឹក្សា។

- **គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ** ជាការប្រមូលផ្តុំនូវអ្នកពាក់ព័ន្ធសំខាន់ៗ ដើម្បីផ្តល់យោបល់ និងអនុសាសន៍ផ្សេងៗលើបញ្ហាសមភាពយេនឌ័រ និងបញ្ហាស្ត្រី និងកុមារ។ គណៈកម្មាធិការនេះទទួលខុសត្រូវផ្តល់អនុសាសន៍ដល់ក្រុមប្រឹក្សា គណៈអភិបាល និង គណៈកម្មាធិការនានារបស់ក្រុមប្រឹក្សាក្នុងការផ្តល់អាទិភាពលើបញ្ហារបស់ស្ត្រី និងកុមារ ដើម្បីពិចារណាដាក់បញ្ចូលទៅក្នុងគោលនយោបាយ សេចក្តីសម្រេច មុខងារ និងការចំណាយរបស់ក្រុមប្រឹក្សា។
- **គណៈកម្មាធិការលទ្ធកម្ម** ធានាឱ្យមានការការពារផលប្រយោជន៍ជូនដល់ប្រជាពលរដ្ឋ និងក្រុមប្រឹក្សាទាក់ទងនឹងការប្រើប្រាស់ថវិកា។ គណៈកម្មាធិការនេះមានការទទួលខុសត្រូវក្នុងការធានាឱ្យបានថា គ្រប់លទ្ធកម្ម សំភារៈ បរិក្ខារ និងសេវា ត្រូវធ្វើឡើងដោយភាពស្មោះត្រង់ តម្លាភាព មិនលំអៀង (មាត្រា ១១៤, ១២៣ ដល់ ១៣៧ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មាត្រា ២នៃអនុក្រឹត្យលេខ២១៨ ស្តីពីការបង្កើត ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសក្រុមប្រឹក្សាខេត្ត គណៈកម្មាធិការសម្របសម្រួលបច្ចេកទេសក្រុមប្រឹក្សាក្រុង និងគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសក្រុមប្រឹក្សាស្រុក)។

ចំពោះព័ត៌មានបន្ថែមស្តីពីគណៈកម្មាធិការរបស់ក្រុមប្រឹក្សា សូមអានមេរៀនទី ៧ ។

✓ ក្រុមប្រឹក្សា អាចបង្កើត**គណៈកម្មាធិការផ្សេងទៀត** ដើម្បីជួយការងាររបស់ក្រុមប្រឹក្សា។ ដើម្បីចៀសវាងការងារត្រួតគ្នា គណៈកម្មាធិការផ្សេងទាំងនេះមិនអាចមានភារកិច្ចដូចគណៈកម្មាធិការកាតព្វកិច្ចទាំងបី ឬដូចភារកិច្ចរបស់គណៈអភិបាលឡើយ (មាត្រា ១១៥ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ)។

✓ ក្រុមប្រឹក្សា ត្រូវធានាឱ្យមាន**តំណាងរបស់ស្ត្រី** នៅក្នុងគណៈកម្មាធិការទាំងអស់ (មាត្រា ១១៨ នៃ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ)។

✓ **ប្រជាពលរដ្ឋ** អាចធ្វើជា**ទីប្រឹក្សា**គណៈកម្មាធិការរបស់ក្រុមប្រឹក្សា (មាត្រា ១១៧ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ) ។

## ផ្នែកទី ៥: បុគ្គលិករបស់ក្រុមប្រឹក្សា

**ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ**
**មាត្រា ១៧៣-១៩១, ២៦២-២៧៣, ២៨១**

✓ ក្រុមប្រឹក្សានីមួយៗ ត្រូវមានបុគ្គលិកក្រុមប្រឹក្សារបស់ខ្លួន។ បុគ្គលិកទាំងនោះរួមមាន:

- ○ បុគ្គលិកដែលបានតែងតាំងដោយក្រុមប្រឹក្សា
- ○ បុគ្គលិកដែលត្រូវបានរៀបចំឡើងវិញទៅឱ្យក្រុមប្រឹក្សា
- ○ បុគ្គលិកដែលបានតែងតាំងឱ្យទៅបំពេញការងារជាមួយក្រុមប្រឹក្សា

(មាត្រា ១៧៣ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ)។

✓ **បុគ្គលិកដែលតែងតាំងដោយក្រុមប្រឹក្សា:**

- ក្រុមប្រឹក្សាអាចតែងតាំងបុគ្គលិកដែលក្រុមប្រឹក្សាត្រូវការដើម្បីធានាឱ្យបានថា ការងាររបស់ខ្លួនត្រូវបានអនុវត្តយ៉ាងមានប្រសិទ្ធិភាព (មាត្រា ១៧៣ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ)
- ក្រុមប្រឹក្សា តែងតាំង**ប្រធានហិរញ្ញវត្ថុ**របស់ខ្លួន ដែលមានការទទួលខុសត្រូវចំពោះការគ្រប់គ្រងហិរញ្ញវត្ថុ។ ការតែងតាំងប្រធានហិរញ្ញវត្ថុ ត្រូវអនុម័តដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុទៅតាមសំណើរបស់ក្រសួងមហាផ្ទៃ (មាត្រា ១៧៩ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ)។

✓ **បុគ្គលិកដែលបានរៀបចំឡើងវិញទៅឱ្យក្រុមប្រឹក្សា:**

- បន្ទាប់ពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក និងក្រុមប្រឹក្សាខណ្ឌ ក្រុមប្រឹក្សាថ្មីនេះត្រូវជំនួសរដ្ឋបាលខេត្ត ក្រុង ស្រុក ខណ្ឌពីមុនៗ។ ដូចនេះ បុគ្គលិកដែលបំពេញការងារនៅរដ្ឋបាលរាជធានី ខេត្ត ក្រុង

> **កែសំរួលរៀបចំឡើងវិញ** មានន័យថា ដូរក្របខ័ណ្ឌផ្សេង។
>
> **កែសំរួលរៀបចំឡើងវិញ** គឺត្រូវដូរបុគ្គលិកពីក្របខ័ណ្ឌនៅពេលសព្វថ្ងៃរបស់ខ្លួនជាបុគ្គលិករបស់ក្រសួង ទៅជាបុគ្គលិករបស់ក្រុមប្រឹក្សា។

ស្រុក ខណ្ឌ ត្រូវបានកែសំរួលរៀបចំឡើងវិញទៅឱ្យ ក្រុមប្រឹក្សាថ្មី (មាត្រា ២៧៧, ២៨១ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ)។

- នៅពេលមុខងារតាមវិស័យត្រូវផ្ទេរឱ្យក្រុមប្រឹក្សាណាមួយ បុគ្គលិកជំនាញដែលអនុវត្តមុខងារនោះត្រូវកែសំរួលរៀបចំឡើងវិញទៅឱ្យក្រុមប្រឹក្សា (មាត្រា ២៦២ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ)។
- បុគ្គលិកដែលត្រូវបានកែសំរួលរៀបចំឱ្យក្រុមប្រឹក្សា ក្លាយទៅជាបុគ្គលិករបស់ក្រុមប្រឹក្សា ហើយគាត់លែងជាបុគ្គលិករបស់ក្រសួងទៀតហើយ (មាត្រា ២៦២ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ)។

✓ **បុគ្គលិកដែលបានតែងតាំងឱ្យទៅបំពេញការងារជាមួយក្រុមប្រឹក្សា៖**

- ក្រុមប្រឹក្សាទាំងអស់មាននាយករដ្ឋបាលដែលជួយនៅក្នុងការត្រួតពិនិត្យ និងការបំពេញការងារប្រចាំថ្ងៃរបស់ក្រុមប្រឹក្សា និងគណៈអភិបាល។ នាយករដ្ឋបាល ត្រូវតែងតាំងដោយក្រសួងមហាផ្ទៃ។ គាត់មានគណនេយ្យភាពចំពោះក្រុមប្រឹក្សា និងគណៈអភិបាល (មាត្រា ១៨៣ ដល់ ១៨៧ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ)។

> ចំពោះព័ត៌មានបន្ថែមស្តីពីបុគ្គលិករបស់ក្រុមប្រឹក្សា សូមអានមេរៀនទី ៨ ។

✓ ក្រុមប្រឹក្សា ត្រូវបង្កើត**អង្គភាពបុគ្គលិក** ។ អង្គភាពនីមួយៗ មានប្រធានដែលមានគណនេយ្យភាពចំពោះក្រុមប្រឹក្សា តាមរយៈនាយករដ្ឋបាល និងគណៈអភិបាល (មាត្រា ១៨៩ ដល់១៩១ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ)។

> ចំពោះព័ត៌មានបន្ថែមស្តីពីតួនាទី និងរចនាសម្ព័ន្ធរបស់ក្រុមប្រឹក្សា សូមអានមេរៀនទី ១២ ផងដែរ ។

# វគ្គទី ២:

# មេរៀនសង្ខេប

- ក្រុមប្រឹក្សានីមួយៗ មាន :
    - សមាជិកក្រុមប្រឹក្សាដែលមានតួនាទីធ្វើសេចក្តីសំរេចសម្រាប់ក្រុមប្រឹក្សា
    - អភិបាលដែលធ្វើជាប្រធានគណៈអភិបាល តួនាទីសំខាន់របស់គណៈអភិបាល គឺត្រូវជួយក្រុមប្រឹក្សា និងអនុវត្តសេចក្តីសំរេចរបស់ក្រុមប្រឹក្សា
    - គណៈកម្មាធិការរបស់ក្រុមប្រឹក្សាដែលមានតួនាទី ផ្តល់យោបល់ដល់ក្រុមប្រឹក្សា និងជួយការងាររបស់របស់ក្រុមប្រឹក្សា
    - បុគ្គលិករបស់ក្រុមប្រឹក្សាដែលមានតួនាទីអនុវត្តសេចក្តីសំរេចរបស់ក្រុមប្រឹក្សា និងបំពេញការងាររបស់ក្រុមប្រឹក្សា ។

## ទិដ្ឋភាពទូទៅរបស់ក្រុមប្រឹក្សា គណៈអភិបាល និងគណៈកម្មាធិការរបស់ក្រុមប្រឹក្សា

| | សមាសភាព | របៀបបង្កើត | អាណត្តិ | មាត្រានៃច្បាប់ |
|---|---|---|---|---|
| **ក្រុមប្រឹក្សា** | ប្រធាន និងសមាជិកក្រុមប្រឹក្សា | សមាជិកក្រុមប្រឹក្សា ត្រូវបោះឆ្នោត ជ្រើសរើសឡើងជាអសកល ដោយសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ពីបញ្ជីឈ្មោះរបស់គណបក្ស | ៥ឆ្នាំ (ដោយការបោះឆ្នោតលើកទីមួយ បានធ្វើឡើងកាលពីខែឧសភា ឆ្នាំ២០០៩) | មាត្រា ១៤ ដល់ ១៨ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ<br>មាត្រា ២, ១៦, ២៧, ៥៣, ៨៩ នៃច្បាប់ បោះឆ្នោត |
| **គណៈអភិបាល** | អភិបាល និងអភិបាលរង (ជាឧត្តមមន្ត្រី វរមន្ត្រី អនុមន្ត្រី និងនាយក្រមការ) | តែងតាំងដោយព្រះរាជក្រឹត្យ អនុក្រឹត្យ និងប្រកាស | ៤ឆ្នាំ (អាចបន្ត ១ អាណត្តិទៀត) | មាត្រា ១៣៨ ដល់ ១៧២ នៃច្បាប់ ស្តីពីការគ្រប់គ្រងរដ្ឋបាល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ |
| **គណៈកម្មាធិការកិច្ចការស្ត្រី និងកុមារ** | សមាជិកក្រុមប្រឹក្សាជាស្ត្រី ឬស្ត្រី និង បុរសនៅក្នុងដែនដីរបស់ក្រុមប្រឹក្សា | ក្រុមប្រឹក្សា ត្រូវតែបង្កើតគណៈកម្មាធិការនេះជាដាច់ខាត | អាណត្តិ ៥ឆ្នាំ ដូចក្រុមប្រឹក្សាដែរ | មាត្រា ១២៧ ដល់ ១៣៥ នៃច្បាប់ ស្តីពីការគ្រប់គ្រងរដ្ឋបាល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ |

| | | | | |
|---|---|---|---|---|
| **គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស** | អភិបាលជាប្រធាន<br>ប្រធានអង្គភាព របស់ក្រុមប្រឹក្សា<br>ប្រធានហិរញ្ញវត្ថុ<br>ប្រធានមន្ទីរខ្សែបណ្តោយនៅក្នុងដែនដីរបស់ក្រុមប្រឹក្សា និង<br>តំណាង ផ្សេងទៀត | ក្រុមប្រឹក្សា ត្រូវតែបង្កើតគណៈកម្មាធិការនេះជាដាច់ខាត | អាណត្តិ ៥ឆ្នាំ ដូចក្រុមប្រឹក្សាដែរ | មាត្រា ១២៣ ដល់ ១២៦<br>នៃច្បាប់<br>ស្តីពីការគ្រប់គ្រងរដ្ឋបាល<br>រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ |
| **គណៈកម្មាធិការលទ្ធកម្ម** | ខ្លឹមសារពិស្តារ នឹងត្រូវកំណត់ដោយលិខិតបទដ្ឋាន | ក្រុមប្រឹក្សា ត្រូវតែបង្កើតគណៈកម្មាធិការនេះជាដាច់ខាត<br>ខ្លឹមសារពិស្តារ អាចត្រូវកំណត់ដោយលិខិតបទដ្ឋាន | អាណត្តិ ៥ឆ្នាំ ដូចក្រុមប្រឹក្សាដែរ | មាត្រា ១៣៦, ១៣៧<br>នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល<br>រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ |
| **គណៈកម្មាធិការផ្សេងទៀត** | សំរេចដោយក្រុមប្រឹក្សា<br>ត្រូវមានបញ្ចូលតំណាងរបស់ស្ត្រី<br>អាចមានបញ្ចូលប្រជាពលរដ្ឋជាទីប្រឹក្សា | សេចក្តីសម្រេចរបស់ក្រុមប្រឹក្សា | សម្រេចដោយក្រុមប្រឹក្សា | មាត្រា ១១៥ ដល់ ១២២<br>នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល<br>រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ |

# មេរៀនសម្រាប់ការយល់ដឹង និង ការបណ្តុះបណ្តាលអំពី ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

## មេរៀនទី ៤

## រដ្ឋបាលឯកភាព

## វគ្គទី ១

១. សេចក្តីផ្តើម

២. រចនាសម្ព័ន្ធរដ្ឋបាលនៅមុនពេលបោះឆ្នោត

៣. រដ្ឋបាលឯកភាពថ្មីនៅថ្នាក់ក្រោមជាតិក្រោយការបោះឆ្នោត

## ផ្នែកទី ១: សេចក្តីផ្តើម

បន្ទាប់ពីការបោះឆ្នោតនៅខែឧសភា ឆ្នាំ២០០៩ភ្លាម ក្រុមប្រឹក្សារាជធានីភ្នំពេញ ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក និងក្រុមប្រឹក្សាខណ្ឌថ្មីនឹងជំនួសរដ្ឋបាល "កាលពីមុន" ។ អភិបាលដែលបានកាន់តំណែងរួចហើយ នៅពេលអនុវត្តច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ នឹងត្រូវពិនិត្យវាយតម្លៃ តែងតាំងស្របតាមច្បាប់រៀបចំអង្គការ ។ ដូចគ្នានេះដែរ បុគ្គលិកដែលពីមុនមកធ្វើការនៅសាលារាជធានីភ្នំពេញ សាលាខេត្ត ក្រុង ស្រុក និងខណ្ឌ នៅបន្តមុខតំណែងរបស់ខ្លួនជាបុគ្គលិករបស់ក្រុមប្រឹក្សាថ្មីរហូតដល់ពេលមានការកែសំរួលរៀបចំឡើងវិញដល់ក្រុមប្រឹក្សាថ្មី (មាត្រា ២៧០, ២៧៧ និង ២៨១ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មាត្រា ២០៦ នៃអនុក្រឹត្យលេខ ២១៦) ។

ជំហានទាំងនេះ បាននាំទៅដល់ការចាប់ផ្តើមកំណែទម្រង់រដ្ឋបាលរបស់រាជរដ្ឋាភិបាល ។ គោលបំណងនៃកំណែទម្រង់រដ្ឋបាល គឺដើម្បីបង្កើតរដ្ឋបាលឯកភាពនៅថ្នាក់ក្រោមជាតិ ដើម្បីសម្របសម្រួលសកម្មភាពរដ្ឋបាលសាធារណៈទាំងអស់នៅក្នុងដែនដីរបស់ក្រុមប្រឹក្សា ។

ក្រសួងមហាផ្ទៃ ប៉ាន់ស្មានថា ដំណើរការនេះ នឹងចំណាយពេលប្រហែល ១០ ឆ្នាំ ជាក្របខ័ណ្ឌពេលវេលាមួយប្រកបដោយមហិច្ឆតា បើប្រៀបធៀបនឹងការបង្កើត និងការអភិវឌ្ឍសមត្ថភាពនៅក្រុមប្រឹក្សាឃុំ សង្កាត់ និងបើប្រៀបធៀបជាមួយកំណែទម្រង់ប្រហាក់ប្រហែលគ្នានេះនៅប្រទេសផ្សេងទៀត ។

## ផ្នែកទី ២៖ រចនាសម្ព័ន្ធរបស់រដ្ឋបាលដែលត្រូវតែងតាំងមុនមានការបោះឆ្នោត

- ✓ មុនពេលអនុវត្តច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ក្រសួងមហាផ្ទៃ ជ្រើសរើស អភិបាល និង អភិបាលរងនៅភ្នំពេញ និងនៅគ្រប់ខេត្ត ក្រុង ស្រុក ខណ្ឌ ។ អភិបាល និងអភិបាលរង គឺជាអ្នកដឹកនាំរដ្ឋបាល ដែលត្រូវតែងតាំង ហើយគាត់ត្រូវគោរពតាមសេចក្តីណែនាំរបស់ក្រសួងមហាផ្ទៃ ។
- ✓ ក្រៅពីនេះ មានមន្ទីរខ្សែបណ្តោយ (នៅតាមខេត្ត) និង អង្គភាពខ្សែបណ្តោយមួយចំនួន (នៅតាមស្រុក) របស់ក្រសួងនានា ។ មន្ទីរ និងអង្គភាពខ្សែបណ្តោយ គោរពតាមសេចក្តីណែនាំរបស់ក្រសួងរៀងខ្លួន ។
- ✓ ដោយលើកឧទាហរណ៍នៅថ្នាក់ខេត្តជួនកាលមានភាពត្រួតគ្នារវាងអ្វីដែលមន្ទីរនៅតាមខេត្តអនុវត្តជាមួយនឹងអ្វីដែលរដ្ឋបាលខេត្តបានធ្វើ ។ ជាញឹកញាប់ ការប្រាស្រ័យទាក់ទង និងការសម្របសម្រួលមិនសូវល្អឡើយរវាងមន្ទីរខ្សែបណ្តោយជាមួយអភិបាលខេត្ត និងរដ្ឋបាលដែលត្រូវតែងតាំង ។ ដូចគ្នានេះដែរ ការប្រាស្រ័យទាក់ទង និងការសម្របសម្រួលនៅក្នុងចំណោមមន្ទីរផ្សេងៗ នៅថ្នាក់ខេត្តមិនសូវមានការពិគ្រោះយោបល់គ្នា ឬមានការពិគ្រោះយោបល់ដែរ ប៉ុន្តែមិនមានប្រព័ន្ធនិងនីតិវិធីច្បាស់លាស់ ។ ដូច្នេះ សេចក្តីសម្រេចសំខាន់ៗសម្រាប់ខេត្ត អាចត្រូវធ្វើឡើងនៅក្នុងក្រសួង ដោយមិនមានការពិគ្រោះយោបល់ជាមួយអភិបាលខេត្ត ឬការពិគ្រោះយោបល់ជាមួយក្រសួងផ្សេងទៀត ឬមន្ទីររបស់ខ្លួន ។ ដោយសារតែមិនមានការប្រាស្រ័យទាក់ទង ការពិគ្រោះយោបល់ ការសម្របសម្រួល និងកិច្ចសហប្រតិបត្តិការ នឹងធ្វើឱ្យការងារជួបការលំបាក (ទំព័រ ៣ នៃក្របខ័ណ្ឌយុទ្ធសាស្រ្តស្តីពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ឆ្នាំ២០០៥) ។

**ឧទាហរណ៍ - ការខ្វះការប្រាស្រ័យទាក់ទង**

នៅលើផ្លូវមួយនៅទីក្រុងភ្នំពេញ មានការសាងសង់គំរោងបីផ្សេងគ្នាក្នុងរយៈពេលមួយឆ្នាំ ។ ការសាងសង់នីមួយៗ តម្រូវឱ្យមានការក្រាលកៅស៊ូឡើងវិញ ។ នៅក្នុងការសាងសង់លើកទីមួយ គេត្រូវកាលថ្នល់ ដោយសារមានគ្រលុកជ្រៅជាច្រើន ។ ប៉ុន្មានខែក្រោយមក កម្មករសំណង់ត្រូវមកទីនេះទៀត ។ គេត្រូវពង្រីកផ្លូវ ហើយត្រូវក្រាលកៅស៊ូលើកន្លែងថ្មើរជើង ។ បន្ទាប់ពីធ្វើការសាងសង់នេះរួចហើយ គេត្រូវចាក់ក្រាលកៅស៊ូលើចំណែកខ្លះនៃផ្លូវនេះម្តងទៀត ។ ប៉ុន្មានខែក្រោយមក ថ្នល់ និងកន្លែងដើរ ដែលទើបនឹងក្រាលកៅស៊ូហើយថ្មីៗ ត្រូវជីកកកាយឡើងវិញ ពីព្រោះគេត្រូវធ្វើប្រព័ន្ធលូទឹកស្អុយ ។ ថ្នល់ត្រូវក្រាលកៅស៊ូជាថ្មីម្តងទៀត គឺជាលើកទីបីនៅក្នុងឆ្នាំដដែលនេះ ។

ដ្យាក្រាមខាងក្រោម បង្ហាញពីរចនាសម្ព័ន្ធរដ្ឋបាលជារួមរបស់កម្ពុជា គឺរចនាសម្ព័ន្ធរដ្ឋបាលខេត្ត ក្រុង និង រចនា-សម្ព័ន្ធគណៈកម្មាធិការអភិវឌ្ឍន៍ជនបទខេត្តមុនការបោះឆ្នោតនៅថ្នាក់រដ្ឋបាលនេះ

**រចនាសម្ព័ន្ធរដ្ឋបាលពីមុនរបស់កម្ពុជា**

**ដោយមិនមានក្រុមប្រឹក្សាខេត្ត ក្រុង ស្រុក ខណ្ឌ**




រចនាសម្ព័ន្ធពីមុន
ខេត្ត និងក្រុង
អភិបាល
ក្រសួងខ្សែបណ្តោយ
ខុទ្ទកាល័យ
អគ្គលេខាធិការដ្ឋាន
ក្រុមហិរញ្ញវត្ថុ
ក្រុមអធិការកិច្ច
អង្គភាពរដ្ឋបាលមូលដ្ឋាន
មន្ទីរខ្សែបណ្តោយ
ពិធីការ
បុគ្គលិក
កណ្តាល
ទំនាក់ទំនងសាធារណៈ
ព័ត៌មាន
កិច្ចការទូទៅ
សង្គមកិច្ច
វិន្យាទាក់ទង
បំភាន់អក្សរ
នយោបាយ
សេដ្ឋកិច្ច
តុលាការ និងពន្ធនាគារ
អចលនទ្រព្យ
ចំណូល
ចំណាយ
គណនេយ្យ
រដ្ឋបាលពិនិត្យតាមដាន
ផែនការ ទិន្នន័យហិរញ្ញវត្ថុ
កសាងសមត្ថភាពព័ត៌មាន
មន្ទីរហិរញ្ញវត្ថុ
មន្ទីរផែនការ
មន្ទីរទេសចរណ៍
មន្ទីរសង្គមកិច្ច
មន្ទីរផ្សេងទៀត

## ផ្នែកទី ៣: រដ្ឋបាលឯកភាពថ្មីនៅថ្នាក់ក្រោមជាតិក្រោយការបោះឆ្នោត

**ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ**

**មាត្រា ២, ៨, ២៩-៣៤, ៣៦, ១១៤, ១២៣, ១២៤, ១៥៤-១៧០, ១៦៦, ១៧៣, ១៧៩, ១៨៣**

✓ រាជរដ្ឋាភិបាលមានបំណងបង្កើត**រដ្ឋ- បាលឯកភាពនៅថ្នាក់ក្រោមជាតិទាំង អស់**នៅរាជធានីភ្នំពេញ ខេត្ត ក្រុង ស្រុក ខណ្ឌ។

✓ ជំពូក ១ មាត្រា២ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ចែងថា: រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវគ្រប់គ្រងតាមគោលការណ៍នៃរដ្ឋបាលឯកភាព ដើម្បីបង្កើត ជំរុញ និង ធ្វើឱ្យមានចីរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យតាមរយៈនយោបាយវិមជ្ឈការ និង វិសហមជ្ឈការ ។

**រដ្ឋបាលឯកភាពនៅក្នុងប្រវត្តិសាស្ត្រនាពេលថ្មី ៗ**

កម្ពុជា បានព្យាយាមបង្កើតរដ្ឋបាលឯកភាពនៅពេលថ្មីៗ កន្លងមកនេះ។ នៅឆ្នាំ **១៩៧៩** បន្ទាប់ពីបានរំដោះប្រទេសកម្ពុជាពីរបបខ្មែរក្រហម កម្ពុជា បានបង្កើតរចនាសម្ព័ន្ធរដ្ឋបាលដែលមានសមត្ថកិច្ចយ៉ាងទូលំទូលាយសំរាប់ខេត្ត និងស្រុក។ ប៉ុន្តែ នៅពេលនោះមិនមានក្រុមប្រឹក្សាដែលត្រូវបោះឆ្នោតជ្រើសរើសឡើង ហើយរចនាសម្ព័ន្ធគណបក្សនៅមូលដ្ឋាន មានឥទ្ធិពលជាខ្លាំងទៅលើគោលនយោបាយរដ្ឋបាលខេត្ត និង ស្រុក ។

✓ ដូច្នេះ រដ្ឋបាលឯកភាព **ត្រូវរួមចំណែក ចំពោះការសម្រេចបានការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ** ។




✓ ការបង្កើតរដ្ឋបាលឯកភាពនៅថ្នាក់ក្រោមជាតិ គឺសំដៅដល់ការពង្រឹងអង្គឯកភាពរបស់រដ្ឋ ដើម្បី**សម្របសម្រួលសកម្មភាពរដ្ឋបាលសាធារណៈទាំងអស់** នៅក្នុងដែនដីរបស់ក្រុមប្រឹក្សា (មាត្រា ៨ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ) ។

✓ ដូច្នេះ ក្រុមប្រឹក្សា មិនគ្រាន់តែធ្វើសេចក្តីសម្រេចនៅក្នុងវិសាលភាពនៃមុខងារ និងភារកិច្ចរបស់ខ្លួនប៉ុណ្ណោះទេ ប៉ុន្តែថែមទាំង**ជាអ្នកសម្របសម្រួល និង ជាកាតាលីករ** ទាក់ទងនឹង**អភិបាលកិច្ច និងសកម្មភាពអភិវឌ្ឍន៍ទាំងអស់** នៅក្នុងដែនដីរបស់ខ្លួនផងដែរ ។ ក្រុមប្រឹក្សា ត្រូវធានាឱ្យបានថា មាន**ការសម្របសម្រួលសកម្មភាព**រវាងក្រុមប្រឹក្សា និងអង្គភាពខ្សែបណ្តោយនៅក្នុងតំបន់ និងនៅក្នុងចំណោមអង្គភាពខ្សែបណ្តោយនៅក្នុងដែនដីរបស់ខ្លួន ។

## សមាសធាតុនៃរដ្ឋបាលឯកភាព

✓ **ក្រុមប្រឹក្សាជាប់ឆ្នោត** ដឹកនាំ**រដ្ឋបាលឯកភាព**។ ក្រុមប្រឹក្សា មានមុខងាររបស់ខ្លួនផ្ទាល់ដែលខ្លួនអនុវត្ត និងមានធនធានរបស់ខ្លួនផ្ទាល់ ហើយក្រុមប្រឹក្សាមានសិទ្ធិធ្វើសេចក្តីសម្រេចសម្រាប់ដែនដីរបស់ខ្លួន ។ ក្រុមប្រឹក្សា គឺ

ជា**អាជ្ញាធរខ្ពស់បំផុត**នៅថ្នាក់ក្រោមជាតិ ។ (មាត្រា ២៩ ដល់ ៣៤ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ) ។

✓ **គណៈកម្មាធិការរបស់ក្រុមប្រឹក្សា** គឺជាផ្នែកមួយនៃរដ្ឋបាលឯកភាព។ គណៈកម្មាធិការទាំងនេះ រួមមានគណៈ-កម្មាធិការជាកាតព្វកិច្ចទាំងបី គឺគណៈកម្មាធិការសម្រប សម្រួលបច្ចេកទេស គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និង កុមារ និង គណៈកម្មាធិការលទ្ធកម្ម ។ ក្រុមប្រឹក្សា អាចបង្កើតគណៈកម្មាធិការបន្ថែមទៀតផងដែរ (មាត្រា ១១៤ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ) ។

> ចំពោះព័ត៌មានបន្ថែមអំពីគណៈកម្មាធិការរបស់ក្រុមប្រឹក្សា សូមអានមេរៀនទី ៧ ។

✓ **គណៈអភិបាល** ដែលត្រូវតែងតាំងឡើង មានអភិបាលដែលត្រូវតែងតាំងជាប្រធាន មានការទទួលខុសត្រូវក្នុងការជួយក្រុមប្រឹក្សាឱ្យដឹកនាំរដ្ឋបាលឯកភាព ។ គណៈ-អភិបាល ក៏ជួយក្រុមប្រឹក្សាផងដែរក្នុងការដាក់បញ្ចូលផែនការ និង ថវិការបស់ក្រសួង និង ស្ថាប័នរដ្ឋាភិបាលនៅក្នុងផែនការ និងថវិការបស់ខ្លួន។ ការដាក់បញ្ចូលផែនការ និងថវិកានៅក្នុងដែនដីរបស់ក្រុមប្រឹក្សាគឺជាទិដ្ឋភាពមួយយ៉ាងសំខាន់នៃរដ្ឋបាលឯកភាព (មាត្រា ១៥៥ ដល់ ១៧០ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ) ។

> ចំពោះព័ត៌មានបន្ថែមអំពីអភិបាល និង គណៈ-អភិបាល សូមអានមេរៀនទី ៦ ។

✓ បន្ថែមពីលើការទទួលខុសត្រូវធ្វើជាប្រធានគណៈអភិបាល **អភិបាល**ដែលត្រូវតែងតាំងមានសិទ្ធិអំណាចត្រួតពិនិត្យ សម្របសម្រួល និង ដឹកនាំក្រសួង និង ស្ថាប័នផ្សេងទៀតរបស់រដ្ឋាភិបាលនៅក្នុងដែនដីរបស់ក្រុមប្រឹក្សា។ នៅក្នុងតួនាទីនេះ អភិបាល ផ្តល់ការរួមចំណែកយ៉ាងសំខាន់ចំពោះការសម្របសម្រួលសកម្មភាពរដ្ឋបាលសាធារណៈទាំងអស់នៅក្នុងដែនដីរបស់ក្រុមប្រឹក្សា (មាត្រា ១៥៤ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ) ។

✓ ក្នុងតួនាទីជាតំណាងក្រសួង ស្ថាប័ននានារបស់រាជរដ្ឋាភិបាល អភិបាលមានភារកិច្ចៈ

- ណែនាំដល់មន្ទីរ អង្គភាព និងទីភ្នាក់ងារនានារបស់ក្រសួងស្ថាប័នឱ្យអនុវត្តតួនាទីភារកិច្ចរបស់ខ្លួនបានត្រឹមត្រូវស្របតាមច្បាប់ គោលនយោបាយជាតិ និងលិខិតបទដ្ឋានគតិយុត្តនានា

- សម្របសម្រួល តម្រង់ទិសដល់មន្ទីរ អង្គភាព និងទីភ្នាក់ងារនានារបស់ក្រសួងស្ថាប័ន ក្នុងការឆ្លើយតបតម្រូវការជាអាទិភាពនៅមូលដ្ឋាន
- តាមរយៈគណកម្មាធិការសម្របសម្រួលបច្ចេកទេស ក្រុមប្រឹក្សា និងគណៈអភិបាល សម្របសម្រួល និងតម្រង់ទិសដល់មន្ទីរ អង្គភាព និងទីភ្នាក់ងារនានារបស់ក្រសួងស្ថាប័ន ដើម្បីធ្វើសមាហរណកម្មផែនការ និងថវិការបស់អង្គភាពទាំងនោះ ទៅក្នុងផែនការ និងថវិការបស់ក្រុមប្រឹក្សា
- តាមដាន និងវាយតម្លៃការអនុវត្តការងាររបស់ប្រធានមន្ទីរ ការិយាល័យខ្សែបណ្តោយរបស់ក្រសួង
- ពិគ្រោះយោបល់ជាមួយក្រុមប្រឹក្សាក្នុងការផ្តល់យោបល់លើបេក្ខភាព ដែលស្នើតែងតាំងជាប្រធានមន្ទីរ ការិយាល័យខ្សែបណ្តោយរបស់ក្រសួង
- អភិបាលត្រូវណែនាំដល់ប្រធានមន្ទីរ ការិយាល័យ អង្គភាព និងអ្នកទទួលខុសត្រូវ ប្រសិនបើមានភាពមិនប្រក្រតីណាមួយកើតឡើង
- អភិបាលមានសិទ្ធិស្នើជាលាយល័ក្ខអក្សរទៅរដ្ឋមន្ត្រី ឬប្រធានស្ថាប័ន ដើម្បីដកហូតពីមុខតំណែងនូវប្រធានមន្ទីរ ការិយាល័យ អង្គភាពនានា ឬអ្នកទទួលខុសត្រូវណាមួយ ដែលប្រព្រឹត្តខុសឆ្គង
- ទទួល និងផ្តល់អនុសាសន៍ទៅលើរបាយការណ៍របស់មន្ទីរ ការិយាល័យខ្សែបណ្តោយរបស់ក្រសួង មុននឹងផ្ញើជូនទៅរដ្ឋមន្ត្រី ឬប្រធានស្ថាប័នសាមី ។ បើសិនជាឯកភាព អភិបាលខេត្ត ត្រូវចុះហត្ថលេខាលើរបាយការណ៍នេះជាមួយប្រធានមន្ទីរ ការិយាល័យ អង្គភាព និងអ្នកទទួលខុសត្រូវនៃទីភ្នាក់ងារនោះ ( មាត្រា ៣៥ ៩២ និង១៥៣ នៃអនុក្រឹត្យលេខ ២១៦ អ.ន.ក្រ.បក ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក ) ។

✓ **បុគ្គលិក**របស់ក្រុមប្រឹក្សា រួមមាន **នាយករដ្ឋបាល ប្រធានហិរញ្ញវត្ថុ** និងបុគ្គលដែលត្រូវរៀបចំឡើងវិញទាំងអស់ ដើម្បីជួយក្រុមប្រឹក្សាអនុវត្តការងាររបស់ខ្លួនក្នុងការដឹកនាំរដ្ឋបាលឯកភាព ( មាត្រា ១៧៩, ១៨២, ១៨៣ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ) ។

> ចំពោះព័ត៌មានបន្ថែមអំពីបុគ្គលិក និង អង្គភាពរបស់ក្រុមប្រឹក្សា សូមអានមេរៀនទី ៨ ។

✓ ទិដ្ឋភាពយ៉ាងសំខាន់នៃវដ្តបាលឯកភាព គឺសិទ្ធិអំណាចរបស់ក្រុមប្រឹក្សាក្នុងការ**សម្របសម្រួល**ផែនការ និង ថវិការបស់ខ្លួនជាមួយផែនការ និង ថវិការបស់ក្រសួង និង ស្ថាប័នផ្សេងទៀតរបស់រដ្ឋាភិបាលដែលផ្តល់សេវានៅក្នុងសមត្ថកិច្ចរបស់ក្រុមប្រឹក្សានីមួយៗ តាមរយៈ**គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស**របស់ក្រុមប្រឹក្សា។ គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស មានអភិបាលជាប្រធាន សមាជិកក្រុមប្រឹក្សា អភិបាលរង នាយករដ្ឋបាល ប្រធានអង្គភាពទាំងអស់របស់ក្រុមប្រឹក្សា ប្រធានហិរញ្ញវត្ថុរបស់ក្រុមប្រឹក្សា ប្រធានមន្ទីរ និងអង្គភាពខ្សែបណ្តោយរបស់ក្រសួង ស្ថាប័នរដ្ឋាភិបាលនៅក្នុងដែនដីរបស់ ក្រុមប្រឹក្សា តំណាងសមាគមក្រុមប្រឹក្សាឃុំ សង្កាត់ តំណាងគណៈកម្មាធិការពិគ្រោះយោបល់ កិច្ចការស្ត្រី និងកុមាររបស់ក្រុមប្រឹក្សា (មាត្រា ១២៣, ១២៤ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ) ។

> គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស ដើរតួនាទីយ៉ាងសំខាន់នៅក្នុងវដ្តបាលឯកភាព។
>
> គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស:
>
> - ជាយន្តការសម្រាប់ក្រុមប្រឹក្សា**ចរចារអំពីអាទិភាព សកម្មភាព និងថវិការបស់ក្រសួងខ្សែបណ្តោយ** នៅក្នុងដែនដី
> - ផ្តល់លទ្ធភាពដល់**ការធ្វើសមាហរណកម្ម (ដាក់បញ្ចូល) ផែនការ និងថវិកា** នៅក្នុងដែនដីរបស់ក្រុមប្រឹក្សា
> - ផ្តល់លទ្ធភាពឱ្យក្រុមប្រឹក្សា**សម្របសម្រួលការអភិវឌ្ឍអន្តរវិស័យ** នៅក្នុងដែនដីរបស់ខ្លួន (សមាហរណកម្មតាមវិស័យ)។

✓ ទិដ្ឋភាពយ៉ាងសំខាន់មួយទៀតនៃវដ្តបាលឯកភាព គឺលទ្ធភាពរបស់**ក្រុមប្រឹក្សាក្នុងការចរចារ**ជាមួយក្រសួង និងស្ថាប័នរបស់រដ្ឋាភិបាលដែលផ្តល់សេវានៅក្នុងដែនដីលើអាទិភាព សកម្មភាព និង ថវិកា ដើម្បីឆ្លើយតបនឹងតម្រូវការជាអាទិភាពរបស់ប្រជាពលរដ្ឋនៅមូលដ្ឋានឱ្យកាន់តែប្រសើរឡើង ។ វេទិកាមួយសម្រាប់ក្រុមប្រឹក្សាចរចារជាមួយក្រសួង និងអង្គភាពខ្សែបណ្តោយរបស់ខ្លួន គឺគណៈកម្មាធិការសម្របសម្រួលបច្ចេកទេស។

> ចំពោះព័ត៌មានបន្ថែមស្តីពីការកសាងផែនការ សូមអានមេរៀនទី ១៤ ។

✓ **ផែនការអភិវឌ្ឍ** និង**ថវិកា**របស់ក្រុមប្រឹក្សា មានបញ្ចូលសេវា និង សកម្មភាពរបស់ក្រុមប្រឹក្សា រួមជាមួយនឹងសេវា និងសកម្មភាពរបស់ក្រសួង និងស្ថាប័នរបស់រដ្ឋាភិបាលដែលកំពុងដំណើរការនៅក្នុងដែនដីរបស់ក្រុមប្រឹក្សា។ ដូច្នេះ ផែនការអភិវឌ្ឍ និង ថវិការបស់ក្រុមប្រឹក្សា មានបញ្ចូល**សេវា សកម្មភាព និងធនធានរបស់**

**រដ្ឋបាលឯកភាពទាំងមូល** ( មាត្រា ៣៦. ១២៣. ១២៤. ១៦៦ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ) ។

**បញ្ហាដែលត្រូវដោះស្រាយ**

ក្របខ័ណ្ឌច្បាប់សម្រាប់រដ្ឋបាលឯកភាព នឹងត្រូវបញ្ជាក់បន្ថែមទៀតតាមរយៈលិខិតបទដ្ឋាន។ ក្រៅពីនេះ គេអាចរំពឹងថា ការងារ និងទំនាក់ទំនងប្រចាំថ្ងៃពាក់ព័ន្ធនឹងរដ្ឋបាលឯកភាព នឹងមានការវិវិត្ត តាមរយៈការអនុវត្តជាក់ស្តែងនៅពេលខាងមុខ ។ កិច្ចការដែលត្រូវបញ្ជាក់បន្ថែមទៀតតាមរយៈលិខិតបទដ្ឋាន ឬ ការអនុវត្ត រួមមានៈ

- គណនេយ្យភាពតាមខ្សែបណ្តោយក្នុងចំណោមតួអង្គនៅក្នុងរដ្ឋបាលឯកភាព
- ទំនាក់ទំនងរវាងក្រុមប្រឹក្សា និង អង្គភាពខ្សែបណ្តោយ
- វិសាលភាពសម្រាប់ឱ្យអង្គភាពខ្សែបណ្តោយមានការឆ្លើយតបចំពោះសំណូមពររបស់ក្រុមប្រឹក្សា (តម្រូវការពីក្រោមរបស់ប្រជាពលរដ្ឋ)
- វិសាលភាពសម្រាប់ឱ្យអង្គភាពខ្សែបណ្តោយ សហប្រតិបត្តិការ និងសហការជាមួយអង្គភាពខ្សែបណ្តោយផ្សេងទៀត
- របៀបបំពេញការងាររបស់គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស និង ទំនាក់ទំនងរបស់គណៈកម្មាធិការនេះជាមួយក្រុមប្រឹក្សា
- របៀបរបប និងនីតិវិធីនៃដំណើរការកសាងផែនការសំដៅរួមចំណែកដល់ការពង្រឹងរដ្ឋបាលឯកភាព។

## វគ្គទី ២៖

## មេរៀនសង្ខេប

ការបង្កើតរដ្ឋបាលឯកភាពនៅថ្នាក់ក្រោមជាតិ មានបំណងពង្រឹងអង្គឯកភាពរបស់រដ្ឋ និងសម្របសម្រួលការអភិវឌ្ឍ តាមបែបប្រជាធិបតេយ្យ ។ តួអង្គសំខាន់នៅក្នុងរដ្ឋបាលឯកភាពថ្មីគឺ

- ក្រុមប្រឹក្សាជាប់ឆ្នោតដែលជាអាជ្ញាធរខ្ពស់បំផុត ហើយដឹកនាំរដ្ឋបាលឯកភាពនៅថ្នាក់ក្រោមជាតិ
- គណៈកម្មាធិការរបស់ក្រុមប្រឹក្សា រួមមានគណៈកម្មាធិការសម្របសម្រួលបច្ចេកទេស ដែលធ្វើជាអ្នកទំនាក់ទំនងរវាងក្រុមប្រឹក្សាជាមួយក្រសួង និង មន្ទីរខ្សែបណ្តោយ
- បុគ្គលិករបស់ក្រុមប្រឹក្សា
- គណៈអភិបាលដែលជួយក្រុមប្រឹក្សាឱ្យអនុវត្តការងាររបស់ខ្លួនក្នុងការដឹកនាំរដ្ឋបាលឯកភាព ។
- អភិបាលដែលមានតួនាទីបន្ថែមក្នុងការត្រួតពិនិត្យ សម្របសម្រួល និងដឹកនាំក្រសួង និងស្ថាប័នផ្សេងទៀតរបស់រដ្ឋាភិបាលនៅក្នុងដែនដីរបស់ក្រុមប្រឹក្សា។

# វគ្គទី ៣៖

# ការងារជាក្រុម

**ការងារជាក្រុម ដូចមានពិពណ៌នាខាងក្រោម អាចមានលក្ខណៈមិនសមស្របសម្រាប់ការបណ្តុះបណ្តាលទាំងអស់ ។ សូមចាត់ទុកការងារជាក្រុមខាងក្រោមជាសំណូមពរតែប៉ុណ្ណោះ ។**

១. ចែកសិក្ខាកាមជាក្រុមដែលមានសមាជិកមិនលើសពី ៨ នាក់

២. ផ្តល់លំហាត់ខាងក្រោមអោយក្រុមនីមួយៗ ។

**លំហាត់ទី ១ ៖ រដ្ឋបាលឯកភាព**

**ពិភាក្សានៅក្នុងក្រុមតូចៗ ៖**

- តើលោក អ្នកមានទស្សនៈដូចម្តេចចំពោះគុណសម្បត្តិនៃការមានរដ្ឋបាលឯកភាព ?
- តើលោក អ្នកគិតថា មានគុណវិបត្តិចំពោះការមានរដ្ឋបាលឯកភាពឬទេ ?

**លំហាត់ទី ២៖ ក្រុមប្រឹក្សា និង គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស**

**ពិភាក្សានៅក្នុងក្រុមតូចៗ ៖**

- តើភាពបត់បែនអ្វីខ្លះដែលលោក អ្នកគិតថា អង្គភាពខ្សែបណ្តោយ ត្រូវសម្របសម្រួលសកម្មភាពរបស់ខ្លួនជាមួយសកម្មភាពរបស់ក្រុមប្រឹក្សា? តើមានលទ្ធភាពអ្វីខ្លះ? តើមានបញ្ហាប្រឈមអ្វីខ្លះ?
- តើការកែប្រែអ្វីខ្លះដែលចាំបាច់ ដើម្បីឱ្យអង្គភាពខ្សែបណ្តោយ មានភាពបត់បែនក្នុងការសម្របសម្រួលសកម្មភាពរបស់ខ្លួនជាមួយសកម្មភាពរបស់ក្រុមប្រឹក្សា?

# មេរៀនសម្រាប់ការយល់ដឹង និង
# ការបណ្តុះបណ្តាលអំពី
# ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល រាជធានី
# ខេត្ត ក្រុង ស្រុក ខណ្ឌ

## មេរៀនទី ៥

## តួនាទី សិទ្ធិអំណាច និង មុខងាររបស់ក្រុមប្រឹក្សា

## វគ្គទី ១:

១. តួនាទី និង សិទ្ធិអំណាចរបស់ក្រុមប្រឹក្សា

២. មុខងារទូទៅរបស់ក្រុមប្រឹក្សា

៣. មុខងារជាក់លាក់របស់ក្រុមប្រឹក្សា

៤. មុខងាររបស់ក្រុមប្រឹក្សាឃុំ សង្កាត់

## ផ្នែកទី ១: តួនាទី និង សិទ្ធិអំណាចរបស់ក្រុមប្រឹក្សា

**ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ**

**មាត្រា ៩-១០, ២៩, ៣០-៣៣, ៥៣-៦១, ១៥៥, ១៨២, ២៤៤, ២៤៦**

### តួនាទីរបស់ក្រុមប្រឹក្សា

សូមអានមេរៀនទី៣ អំពីការបង្ហាញឱ្យស្គាល់ក្រុមប្រឹក្សា

✓ រាជធានីភ្នំពេញ និង ខេត្ត ក្រុង ស្រុក ខណ្ឌ គឺជា**នីតិបុគ្គល**នៃនីតិសាធារណៈរបស់កម្ពុជា។ នីតិបុគ្គលនីមួយៗ មាន**ក្រុមប្រឹក្សាមួយ** (មាត្រា ៩, ១០ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ)។

ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាឃុំ សង្កាត់ មាន**អំណាចដោយខ្លួនឯងរបស់ខ្លួន** ដើម្បីធ្វើសេចក្តីសម្រេច អនុវត្តមុខងារ និងប្រើប្រាស់ធនធានរបស់ខ្លួនក្នុងការបង្កើត ជំរុញ និងធ្វើឱ្យមានចីរភាពការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅក្នុងដែនដីរបស់ខ្លួន (មាត្រា ១៧៤ នៃអនុក្រឹត្យស្តីពីតួនាទី-ខេត្ត)។

✓ ក្រុមប្រឹក្សា មានតួនាទីពីរយ៉ាង។ ទីមួយ ក្រុមប្រឹក្សាត្រូវធ្វើអ្វីដែលចាំបាច់ ដើម្បីសម្រេចបានគោលបំណងរបស់ខ្លួនក្នុង**ការបង្កើត ជំរុញ និងធ្វើឱ្យមានចីរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ**នៅក្នុងដែនដីរបស់ខ្លួន។ ទីពីរ ក្រុមប្រឹក្សា មានតួនាទី**អនុវត្តមុខងារ** ដែលបានផ្ទេរឱ្យក្រុមប្រឹក្សាក្រោមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ (មាត្រា ២៩ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ)។

✓ **ក្នុងការបំពេញតួនាទីជាទូទៅរបស់ខ្លួន ក្រុមប្រឹក្សា មានសិទ្ធិអំណាចដូចខាងក្រោម:**

- អំណាចបញ្ញត្តិ
- អំណាចប្រតិបត្តិ
- អំណាចរកចំណូលរបស់ខ្លួនផ្ទាល់




✓ ក្នុងការបំពេញតួនាទី និង អនុវត្តសិទ្ធិអំណាចរបស់ខ្លួន ក្រុមប្រឹក្សា មាន**គណនេយ្យភាពតាមបែបប្រជាធិបតេយ្យ** ចំពោះប្រជាពលរដ្ឋលើគោលនយោបាយ សេចក្តីសម្រេច សកម្មភាព និង ការប្រើប្រាស់ធនធានសាធារណៈរបស់ខ្លួន។ ក្រុមប្រឹក្សា ក៏ត្រូវមានគណនេយ្យភាពចំពោះរាជរដ្ឋាភិបាលក្នុងការអនុវត្តតាមរដ្ឋធម្មនុញ្ញ ច្បាប់ និង លិខិតបទដ្ឋាននានា (មាត្រា ៣៤, ៤៣, ៤៦, ២២៥ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ)។

**គណនេយ្យភាពតាមបែបប្រជាធិបតេយ្យសំដៅលើ**

*តំណាងជាប់ឆ្នោត ដែលមានគណនេយ្យភាពតាមបែបប្រជាធិបតេយ្យ ប្រកាន់យកជម្រើសដោយផ្អែកលើព័ត៌មាន បែងចែកធនធានដែលខ្លួនមាន និងអនុវត្តមុខងារ និងភារកិច្ចរបស់ខ្លួន ដើម្បីជាប្រយោជន៍សាធារណៈ និងដើម្បីឆ្លើយតបនឹងតម្រូវការដែលបានលើកឡើងនៅមូលដ្ឋាន។ គណនេយ្យភាពតាមបែបប្រជាធិបតេយ្យកើតមានឡើងនៅពេលប្រជាពលរដ្ឋអាចកំណត់ផលវិបាកទៅលើតំណាងជាប់ឆ្នោតចំពោះជម្រើសដែលតំណាងជាប់ឆ្នោតប្រកាន់យករបៀបដែលតំណាងជាប់ឆ្នោតបែងចែកធនធានដែលខ្លួនមាន និងចំពោះការអនុវត្តមុខងារ និងភារកិច្ចរបស់ខ្លួន។*

ចំពោះព័ត៌មានបន្ថែមស្តីពីគណនេយ្យភាពតាមបែបប្រជាធិបតេយ្យ សូមអានមេរៀនទី ២ អំពីការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ។

## អំណាចរបស់ក្រុមប្រឹក្សាៈ អំណាចបញ្ញត្តិ

✓ ក្រុមប្រឹក្សា មានអំណាចបញ្ញត្តិ។ ក្រុមប្រឹក្សា អនុវត្តអំណាចបញ្ញត្តិរបស់ខ្លួន ដោយការធ្វើដីកា។ ដីកា គឺជាវិធានខាងផ្លូវច្បាប់ដែលបានអនុម័តដោយក្រុមប្រឹក្សា ហើយត្រូវប្រតិបត្តិ និង អនុវត្តនៅក្នុងដែនសមត្ថកិច្ចទាំងមូលរបស់ខ្លួន (មាត្រា ៣០, ៣២ និង ៥៣ ដល់ ៦១នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ)។

✓ ក្រុមប្រឹក្សា មានសិទ្ធិដាក់ចេញ**ដីកា**លើការងារណាដែលស្ថិតនៅក្នុងវិសាលភាពនៃតួនាទី ភារកិច្ច និងមុខងាររបស់ខ្លួន (មាត្រា ៥៤ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ)។

**ឧទាហរណ៍នៃដីកា**

- ការលែងគោឱ្យដើររហេតរហូត ត្រូវបានហាមឃាត់។ ការមិនគោរពតាមដីកា ត្រូវដាក់ទណ្ឌកម្មដោយផាកពិន័យ។
- តន្ត្រីដែលមានសំលេងឮខ្លាំង អាចលេងបាននៅចន្លោះពីម៉ោង៨.០០ ព្រឹក ដល់ម៉ោង៩.០០យប់។
- ការរំលោភសិទ្ធិកុមារ ត្រូវរាយការណ៍ជាបន្ទាន់ទៅក្រុមប្រឹក្សា និង នគរបាល
- រាល់ពិធីមង្គលការ ត្រូវមានសន្តិសុខការពារ

✓ ដីកា អាច**កំណត់ ហាមឃាត់ ឬ ត្រួតពិនិត្យសកម្មភាព ឬ កិច្ចការណាមួយ**។ ដីកា ក៏អាចកំណត់**ការពិន័យជាប្រាក់**ចំពោះការមិនគោរពតាមដីកាផងដែរ (មាត្រា ៥៤-៥៩ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ)។

✓ ដីកា គឺជាឧបករណ៍ប្រកបដោយអានុភាពខ្លាំងក្លាដែលក្រុមប្រឹក្សា អាចប្រើប្រាស់ដើម្បីជាប្រយោជន៍របស់ប្រជាពលរដ្ឋរបស់ខ្លួន។ ដូច្នេះ ក្រុមប្រឹក្សាគួរធានាថា ខ្លួនស្តាប់ និងពិចារណា**សម្លេងរបស់ប្រជាពលរដ្ឋ**មុនពេលសម្រេចដាក់ចេញដីកា។ ដីកា ក៏គួរពិចារណាផងដែរលើ**ព័ត៌មាន និងភស្តុតាង**ដែលនឹងផ្តល់លទ្ធភាពឱ្យក្រុមប្រឹក្សាពិភាក្សា **ជជែកវែកញែក** និង**សម្រេច**លើដីកាប្រកបដោយអត្ថន័យ។

✓ ដីកាមួយមាន**សុពលភាព**ដរាបណាដីកានេះ ត្រូវបានអនុម័តដោយសមាជិកក្រុមប្រឹក្សាមិនតិចជាងពាក់កណ្តាលនៃសមាជិកក្រុមប្រឹក្សាទាំងអស់។ ជាធម្មតា ការអនុម័តដីកា ត្រូវធ្វើឡើងដោយការលើកដៃ (ប្រការ ១៦, ១៧ នៃគំរូបទបញ្ជាផ្ទៃក្នុង)។

✓ **មន្ត្រីនគរបាលយុត្តិធម៌** ត្រូវជួយក្រុមប្រឹក្សា ដើម្បីពង្រឹងការអនុវត្តដីការបស់ក្រុមប្រឹក្សា ប្រសិនបើក្រុមប្រឹក្សាស្នើសុំជាលាយល័ក្ខអក្សរ (មាត្រា ៦១ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ) ។

✓ ប្រធានក្រុមប្រឹក្សា ត្រូវចាត់វិធានការ**បិទផ្សាយព័ត៌មានជាសាធារណៈ**អំពីដីកានៅក្នុងរយៈពេល ៥ ថ្ងៃធ្វើការ បន្ទាប់ពីការអនុម័តដីកា (មាត្រា ១៩ នៃគំរូបទបញ្ជាផ្ទៃក្នុង) ។

**គំរូបទបញ្ជាផ្ទៃក្នុង**

គ.ជ.អ.ប បានដាក់ចេញបទបញ្ជាផ្ទៃក្នុងដែលក្រុមប្រឹក្សាអាចប្រើប្រាស់នៅពេលក្រុមប្រឹក្សាអភិវឌ្ឍ និងអនុម័តបទបញ្ជាផ្ទៃក្នុងរបស់ខ្លួនផ្ទាល់។ គំរូបទបញ្ជាផ្ទៃក្នុងចែង**លក្ខខណ្ឌអប្បបរមា**ដែលអាចត្រូវបន្ថែម និងអនុវត្តដោយក្រុមប្រឹក្សានីមួយៗ។

✓ សមាជិកក្រុមប្រឹក្សាចំនួនមួយភាគបី អាចស្នើសុំឱ្យ**ធ្វើវិសោធនកម្ម**ដីកា (មាត្រា ១៨ នៃគំរូបទបញ្ជាផ្ទៃក្នុង) ។

## អំណាចរបស់ក្រុមប្រឹក្សា៖ អំណាចប្រតិបត្តិ

✓ ក្រុមប្រឹក្សា មានអំណាចប្រតិបត្តិ។ ក្រុមប្រឹក្សាអនុវត្តអំណាចប្រតិបត្តិរបស់ខ្លួន ដោយធ្វើ**សេចក្តីសម្រេចនៅក្នុងអង្គប្រជុំក្រុមប្រឹក្សារបស់ខ្លួន** និងដោយ**ធានាថា សេចក្តីសម្រេចរបស់ខ្លួនត្រូវបានអនុវត្ត**។ គណៈអភិបាល និង បុគ្គលិករបស់ក្រុមប្រឹក្សា មានការទទួលខុសត្រូវលើការអនុវត្តសេចក្តីសម្រេចរបស់ក្រុមប្រឹក្សា (មាត្រា ៣០, ៣១, ៣៣, ១៥៥, ១៨២ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ) ។

ក្រុមប្រឹក្សានីមួយៗ ត្រូវមានយុទ្ធសាស្ត្រដើម្បីធានាឱ្យបានថា សេចក្តីសំរេចរបស់ខ្លួនត្រូវអនុវត្តអនុលោមតាមទៅតាមឆន្ទៈរបស់ខ្លួន។ដូច្នេះ សមាជិកក្រុមប្រឹក្សា ឬគណៈកម្មាធិការរបស់សមាជិកក្រុមប្រឹក្សា អាចធ្វើការជ្រើសរើស ដើម្បីដើរតួនាទីយ៉ាងសកម្មនៅក្នុងការងារប្រចាំថ្ងៃរបស់ក្រុមប្រឹក្សា។

✓ ដូចគ្នានឹងដីកាដែរ ក្រុមប្រឹក្សាគួរធានាថា ខ្លួនស្តាប់ និងពិចារណា**សម្លេងរបស់ប្រជាពលរដ្ឋ**មុនពេលធ្វើសេចក្តីសម្រេច។ សេចក្តីសម្រេចរបស់ក្រុមប្រឹក្សា ក៏គួរពិចារណាផងដែរលើ**ព័ត៌មាន និងភស្តុតាង**ដែលនឹងផ្តល់លទ្ធភាពឱ្យក្រុមប្រឹក្សា ពិភាក្សា **ជជែកវែកញែក** និង **សម្រេច**ប្រកបដោយអត្ថន័យ មុនពេលឈានដល់សេចក្តីសម្រេចជាចុងក្រោយ។

- ✓ គណៈអភិបាល គួរធ្វើ**ការសិក្សាស្រាវជ្រាវ** ដើម្បីផ្ដល់មតិយោបល់ ព័ត៌មាន និងភស្តុតាងល្អៗ ដល់ក្រុមប្រឹក្សា។ លទ្ធផលនៃការសិក្សាគួរជួយក្រុមប្រឹក្សា ដើម្បីធ្វើសេចក្ដីសម្រេចដែលផ្អែកលើព័ត៌មានយ៉ាងប្រសើរ (មាត្រា ២៩. ៨៦. ១៤៧ នៃអនុក្រឹត្យលេខ ២១៦ អ.ន.ក្រ.បក ស្ដីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក)។

- ✓ ក្រៅពីនេះ ដើម្បី**មានមូលដ្ឋាននៅក្នុងសេចក្ដីសម្រេច**របស់ខ្លួន ក្រុមប្រឹក្សា អាចអញ្ជើញអភិបាល ឬ អភិបាលរង គណៈអភិបាល ឬអ្នកពាក់ព័ន្ធផ្សេងទៀត ដើម្បីពិភាក្សា:
    - ការចាំបាច់ ដើម្បីធ្វើការសិក្សាស្រាវជ្រាវ ឬការអង្កេតលើកិច្ចការដែលក្រុមប្រឹក្សាគិតថា មានសារៈសំខាន់ចំពោះប្រជាពលរដ្ឋរបស់ខ្លួន។
    - ការចាំបាច់ក្នុងការផ្សព្វផ្សាយលទ្ធផលនៃការសិក្សាស្រាវជ្រាវ ឬការអង្កេត
    - ដំណោះស្រាយចំពោះបញ្ហាបន្ទាន់ ឬបញ្ហាពិសេស (មាត្រា ១៥. ៧១. ១៣៣ នៃអនុក្រឹត្យលេខ ២១៦ អ.ន.ក្រ.បក ស្ដីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក)។

- ✓ ក្រុមប្រឹក្សា ត្រូវបែងចែកភារកិច្ចនៅក្នុងចំណោមសមាជិកក្រុមប្រឹក្សា ដើម្បីពិនិត្យតាមដានការអនុវត្តការងាររបស់ក្រុមប្រឹក្សា។ ក្រៅពីនេះ ដើម្បី**ធានាថា សេចក្ដីសម្រេចរបស់ខ្លួនត្រូវបានអនុវត្ត** ក្រុមប្រឹក្សា អាចអញ្ជើញអភិបាល ឬ អភិបាលរង គណៈអភិបាល ឬអ្នកពាក់ព័ន្ធផ្សេងទៀត ដើម្បីពិភាក្សា:
    - ការអនុវត្តសេចក្ដីសម្រេចរបស់ក្រុមប្រឹក្សា
    - ការណែនាំឱ្យគណៈអភិបាល ដោះស្រាយលទ្ធផលនៃការសិក្សាស្រាវជ្រាវ ឬការអង្កេត (មាត្រា ១៤. ១៥. ៧០. ៧១. ១៣២. ១៣៣ នៃអនុក្រឹត្យលេខ ២១៦ អ.ន.ក្រ.បក ស្ដីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក)។

- ✓ សេចក្ដីសម្រេចរបស់ក្រុមប្រឹក្សា **មានសុពលភាព** ដរាបណាសេចក្ដីសម្រេចនោះ ត្រូវបានអនុម័តដោយសមាជិកក្រុមប្រឹក្សាមិនតិចជាងពាក់កណ្ដាលនៅក្នុងចំណោមសមាជិកក្រុមប្រឹក្សាទាំងអស់។។ ជាធម្មតា ការអនុម័តសេចក្ដីសម្រេច ត្រូវធ្វើឡើងដោយការលើកដៃ (ប្រការ ១៦. ១៧ នៃគំរូបទបញ្ជាផ្ទៃក្នុង)។

- ✓ ប្រធានក្រុមប្រឹក្សា ត្រូវចាត់វិធានការ**បិទផ្សាយព័ត៌មានជាសាធារណៈ**អំពីសេចក្ដីសម្រេចរបស់ក្រុមប្រឹក្សានៅក្នុងរយៈពេល ៥ ថ្ងៃធ្វើការ បន្ទាប់ពីក្រុមប្រឹក្សាអនុម័តសេចក្ដីសម្រេច (ប្រកាស ១៩ នៃគំរូបទបញ្ជាផ្ទៃក្នុង) ។

- ✓ សមាជិកក្រុមប្រឹក្សាចំនួនមួយភាគបី អាចស្នើសុំឱ្យ**ធ្វើវិសោធនកម្ម**សេចក្ដីសម្រេច (ប្រកាស ១៨ នៃគំរូបទបញ្ជាផ្ទៃក្នុង) ។

- ✓ ក្រុមប្រឹក្សា ត្រូវធានាថាសេចក្ដីសម្រេចរបស់ខ្លួន ត្រូវបានអនុវត្តដោយទទួល**របាយការណ៍ជាប្រចាំពីគណៈអភិបាល** (មាត្រា ១៥៩, ១៦៥ នៃច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងប្រកាស ៣១ នៃគំរូបទបញ្ជាផ្ទៃក្នុង) ។

**អំណាចរបស់ក្រុមប្រឹក្សា:** ការរកចំណូលរបស់ខ្លួនផ្ទាល់

- ✓ ក្រុមប្រឹក្សា មាន**សិទ្ធិអំណាចទទួលបានពន្ធ ឈ្នួល និងកម្រៃនៅមូលដ្ឋាន** និងប្រមូលចំណូលមិនមែនពន្ធផ្សេងទៀត។ ពន្ធ ឈ្នួល និង កំរៃ និងចំណូលមិនមែនពន្ធដែលរក្សាទុកសម្រាប់ក្រុមប្រឹក្សា ត្រូវកំណត់នៅក្នុងច្បាប់ដោយឡែក (មាត្រា ២៤៤, ២៤៦ នៃច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ) ។

> ចំពោះព័ត៌មានបន្ថែមអំពីចំណូលផ្ទាល់ខ្លួន សូមអានមេរៀនទី ១៥

## ផ្នែកទី ២: មុខងារទូទៅរបស់ក្រុមប្រឹក្សា

**មុខងារទូទៅរបស់ក្រុមប្រឹក្សា រួមមាន:**

- ពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋនិង ផ្សព្វផ្សាយព័ត៌មានដល់ប្រជាពលរដ្ឋ
- រៀបចំផែនការសម្រាប់ដែនដីរបស់ខ្លួន
- រៀបចំថវិកា និង គ្រប់គ្រងធនធានរបស់ក្រុមប្រឹក្សា

### ការពិគ្រោះយោបល់ និងការផ្សព្វផ្សាយព័ត៌មាន

**ច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ**

**មាត្រា ១២, ៣៤, ៣៨, ៤១, ៥០-៥១, ៦៨, ១១៧**

✓ ការពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋ និងការផ្សព្វផ្សាយព័ត៌មានដល់ប្រជាពលរដ្ឋ គឺជា**ការទទួលខុសត្រូវយ៉ាងសំខាន់ និងជាប្រចាំរបស់ក្រុមប្រឹក្សា។**

✓ **ការពិគ្រោះយោបល់ គឺជាការជួបប្រជុំរបស់ក្រុមប្រឹក្សាជាមួយប្រជាពលរដ្ឋរបស់ខ្លួន** ដើម្បីទទួលបានព័ត៌មានអំពីតម្រូវការរបស់ប្រជាពលរដ្ឋ និងមតិយោបល់របស់ប្រជាពលរដ្ឋអំពីគោលនយោបាយ សេចក្ដីសម្រេច សកម្មភាព និងផែនការរបស់ក្រុមប្រឹក្សា។ ការពិគ្រោះយោបល់មានន័យថា ក្រុមប្រឹក្សា មិនត្រូវរង់ចាំឱ្យប្រជាពលរដ្ឋមករកក្រុមប្រឹក្សាឡើយ ផ្ទុយទៅវិញ ក្រុមប្រឹក្សាត្រូវប្រកាន់យកការផ្ដួចផ្ដើម ហើយស្វែងរកបញ្ហាប្រជាពលរដ្ឋរបស់ខ្លួនយ៉ាងសកម្ម។ ការពិគ្រោះយោបល់ ធ្វើឱ្យក្រុមប្រឹក្សាទទួលបានការយល់ដឹងសំដៅឆ្លើយតបទៅនឹងតម្រូវការ ផលប្រយោជន៍ និងអាទិភាពពិតប្រាកដរបស់ប្រជាពលរដ្ឋ ពោលគឺធ្វើឱ្យក្រុមប្រឹក្សាមានលទ្ធភាព**ស្ដាប់ឮសម្លេងប្រជាពលរដ្ឋរបស់ខ្លួន**។ ក្រុមប្រឹក្សាដែលយល់ពីតម្រូវការ ផលប្រយោជន៍ និងអាទិភាពពិតប្រាកដរបស់ប្រជាពលរដ្ឋ អាចធ្វើ**សេចក្ដីសម្រេចដែលផ្អែកលើព័ត៌មាន** ដើម្បីឆ្លើយតបនឹងតម្រូវការ ផលប្រយោជន៍ និង

អាទិភាពទាំងនោះ។ ការពិគ្រោះយោបល់ គឺជា**សមាសភាគដ៏សំខាន់នៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ** (មាត្រា ១២ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ)។

✓ **ការផ្សព្វផ្សាយព័ត៌មាន** គឺជាការងារអំពី**តម្លាភាព**។ តម្លាភាព សំដៅលើការផ្តល់ព័ត៌មានដោយក្រុមប្រឹក្សាដល់ប្រជាពលរដ្ឋអំពីសេចក្តីសម្រេច ដីកា សកម្មភាព ឯកសារ និងរបាយការណ៍ ផែនការ និងថវិកា ប្រក្រតិទិនសម្រាប់ការប្រជុំរបស់ក្រុមប្រឹក្សា និងព័ត៌មានផ្សេងទៀតដែលក្រុមប្រឹក្សាមាន។ ដោយសារក្រុមប្រឹក្សា គឺជាតំណាងជាប់ឆ្នោតរបស់ប្រជាពលរដ្ឋ កិច្ចការទាំងអស់របស់ក្រុមប្រឹក្សា គួរមានតម្លាភាពចំពោះប្រជាពលរដ្ឋ។ តម្លាភាព ក៏ជា**សមាសភាគដ៏សំខាន់នៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ**ផងដែរ (មាត្រា ១២ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ)។

## វេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់

✓ ក្រុមប្រឹក្សាទាំងអស់ ត្រូវរៀបចំវេទិកាពិគ្រោះយោបល់ជារៀងរាល់ឆ្នាំ ដែលត្រូវចូលរួមដោយប្រជាពលរដ្ឋ ក៏ដូចជាក្រុមប្រឹក្សាផ្សេងទៀត។ វេទិកាទាំងនេះ គឺជាយន្តការយ៉ាងសំខាន់សម្រាប់:

- **តម្លាភាព**
- **ការចូលរួមចំណែករបស់ប្រជាពលរដ្ឋ**
  - ការពិគ្រោះយោបល់
  - ការចូលរួម
  - សម្លេងរបស់ប្រជាពលរដ្ឋ
  - ការពិគ្រោះយោបល់រវាងរដ្ឋបាល និងប្រជាពលរដ្ឋអំពីការអភិវឌ្ឍ ជម្រើស សិទ្ធិ និងសេវា
  - សាមគ្គីភាព ដែលមានការពាក់ព័ន្ធនឹងប្រជាពលរដ្ឋដែលងាយរងគ្រោះ។
- **គណនេយ្យភាពតាមបែបប្រជាធិបតេយ្យ** (មាត្រា ៩, ៦៥, ១២១ នៃអនុក្រឹត្យលេខ ២១៦ អ.ន.ក្រ.បក ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក)

✓ គោលបំណងរបស់វេទិកាពិគ្រោះយោបល់ គឺដើម្បីឱ្យក្រុមប្រឹក្សាៈ

- **ផ្តល់ព័ត៌មាន**អំពីសកម្មភាពរបស់ក្រុមប្រឹក្សា បន្ទាប់ពីវេទិកាចុងក្រោយ
- **ឆ្លើយតបនឹងសំណួមពរ**របស់អ្នកចូលរួម

- **ពិភាក្សា និងបំភ្លឺបញ្ហា**ដែលលើកឡើងដោយអ្នកចូលរួម
- **ប្រមូលមតិយោបល់** ពីអ្នកចូលរួម ដើម្បីកែលម្អការងាររបស់ក្រុមប្រឹក្សា និងការឆ្លើយតបរបស់ក្រុមប្រឹក្សាចំពោះតម្រូវការនៅមូលដ្ឋាន

(មាត្រា ៩, ៦៥, ១២១ នៃអនុក្រឹត្យលេខ ២១៦ អ.ន.ក្រ.បក ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក)

## បទបញ្ញត្តិផ្សេងទៀតទាក់ទងនឹងការពិគ្រោះយោបល់

✓ មានបទបញ្ញត្តិមួយចំនួនទៀតនៅក្នុងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដែលតម្រូវ ឬលើកទឹកចិត្តឱ្យក្រុមប្រឹក្សាធ្វើការពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋរបស់ខ្លួន។

> **រដ្ឋបាលនៅថ្នាក់ក្រោមជាតិ**
>
> រដ្ឋបាលនៅថ្នាក់ក្រោមជាតិ សំដៅលើក្រុមប្រឹក្សា និងគណៈអភិបាលរបស់ក្រុមប្រឹក្សា។ (មាត្រា ២ នៃអនុក្រឹត្យលេខ ២១៦ អ.ន.ក្រ.បក ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក)

- រដ្ឋបាលនៅថ្នាក់ក្រោមជាតិទាំងអស់ត្រូវបើកទ្វារនៅក្នុងអំឡុងពេលនៃ**ម៉ោងធ្វើការជាផ្លូវការ**។ នៅក្នុងអំឡុងពេលនៃម៉ោងធ្វើការនេះ ប្រជាពលរដ្ឋគ្រប់រូបមានសិទ្ធិ:
  - ○ ទំនាក់ទំនង និងធ្វើការជាមួយក្រុមប្រឹក្សា និងគណៈអភិបាល
  - ○ ទទួលព័ត៌មានពីរដ្ឋបាលអំពីសំណូមពរ ឬកិច្ចការផ្សេងទៀត
  - ○ ផ្តល់មតិយោបល់ ឬសំណូមពរលើកិច្ចការណាមួយ។

(មាត្រា ៥០, ១០៧, ១៦៨ នៃអនុក្រឹត្យលេខ ២១៦ អ.ន.ក្រ.បក ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក)

- ក្រុមប្រឹក្សាទាំងអស់ ត្រូវធ្វើការពិចារណានៅគ្រប់កិច្ចប្រជុំទាំងអស់**អំពីរបៀបពិគ្រោះយោបល់**ជាមួយប្រជាពលរដ្ឋរបស់ខ្លួន (មាត្រា ១៤, ៧០, ១៣២ នៃអនុក្រឹត្យលេខ ២១៦ អ.ន.ក្រ.បក ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក)។
- ក្រុមប្រឹក្សា ត្រូវបែងចែកភារកិច្ចនៅក្នុងចំណោមសមាជិករបស់ខ្លួន ដើម្បីពិគ្រោះយោបល់ជាមួយប្រជា-ពលរដ្ឋនៅក្នុងដែនដី (មាត្រា ១៤, ៧០, ១៣២ នៃអនុក្រឹត្យលេខ ២១៦ អ.ន.ក្រ.បក ស្តីពីតួនាទី

ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក) ។

- ក្រុមប្រឹក្សា ត្រូវពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋរបស់ខ្លួននៅពេលរៀបចំ និងអនុវត្ត**ផែនការអភិវឌ្ឍ**របស់ខ្លួន ( មាត្រា ៣៨ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មាត្រា ១៣ នៃអនុក្រឹត្យស្តីពី ផែនការអភិវឌ្ឍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ) ។
- ក្រុមប្រឹក្សា អាច**ធ្វើការស្ទាបស្ទង់** ដើម្បីឱ្យដឹងពីទស្សនៈរបស់ប្រជាពលរដ្ឋ ( មាត្រា ៣៤ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ) ។
- ក្រុមប្រឹក្សា អាចជំរុញឱ្យប្រជាពលរដ្ឋចូលរួមនៅក្នុង**កិច្ចប្រជុំរបស់ក្រុមប្រឹក្សា** ដែលក្រុមប្រឹក្សាអាចពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋ តាមរយៈការពិភាក្សា ( មាត្រា៦៨ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ) ។
- ប្រជាពលរដ្ឋ អាចធ្វើជាទីប្រឹក្សាឱ្យ**គណៈកម្មាធិការរបស់ក្រុមប្រឹក្សា** ( មាត្រា ១១៧ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ) ។

**បទបញ្ញត្តិផ្សេងទៀតទាក់ទងនឹងការផ្សព្វផ្សាយព័ត៌មាន**

✓ ក៏មានបទបញ្ញត្តិជាច្រើនទៀតផងដែរនៅក្នុងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដែលតម្រូវឱ្យក្រុមប្រឹក្សាផ្សព្វផ្សាយព័ត៌មានដល់ប្រជាពលរដ្ឋរបស់ខ្លួន។

- ជាទូទៅ **កិច្ចប្រជុំរបស់ក្រុមប្រឹក្សា** ត្រូវបើកចំហដល់សាធារណជន ហើយប្រជាពលរដ្ឋមិនចាំបាច់មានលិខិតអញ្ជើញ ដើម្បីចូលរួមឡើយ ( មាត្រា ៦៨ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ប្រការ ២៥ នៃគំរូបទបញ្ជាផ្ទៃក្នុង) ។
- ក្រុមប្រឹក្សាទាំងអស់ ត្រូវធ្វើការពិចារណានៅគ្រប់កិច្ចប្រជុំទាំងអស់**អំពីរបៀបផ្សព្វផ្សាយព័ត៌មាន** ដល់ប្រជាពលរដ្ឋរបស់ខ្លួន ( មាត្រា ១៤, ៧០, ១៣២ នៃអនុក្រឹត្យលេខ ២១៦ អ.ន.ក្រ.បក ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក) ។
- ក្រុមប្រឹក្សា ត្រូវធ្វើអ្វីៗ ដែលអាចធ្វើទៅបាន ដើម្បីធានាឱ្យបានថា **សាធារណជន មានលទ្ធភាពទទួលបានព័ត៌មាន**ដូចជា របៀបវារៈរបស់ក្រុមប្រឹក្សា កំណត់ហេតុនៃកិច្ចប្រជុំរបស់ក្រុមប្រឹក្សា ដីការបស់ក្រុមប្រឹក្សា ផែនការអភិវឌ្ឍរបស់ក្រុមប្រឹក្សា និងឯកសារសំខាន់ៗផ្សេងទៀត ( មាត្រា ៤១, ៥១ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងប្រការ ២, ៦ នៃគំរូបទបញ្ជាផ្ទៃក្នុង) ។

- រដ្ឋបាលត្រូវបង្កើត**ក្ដារព័ត៌មាន**សាធារណៈ ដែលសាធារណៈជនអាចពិនិត្យមើលបានដោយងាយស្រួលនៅពីមុខការិយាល័យរបស់រដ្ឋបាល។ ក្ដារព័ត៌មានត្រូវដាក់បង្ហាញព័ត៌មានជាផ្លូវការរបស់ក្រុមប្រឹក្សានៅក្នុងរយៈពេលយ៉ាងតិច១០ថ្ងៃ។ ក្រៅពីនេះ ក្រុមប្រឹក្សាត្រូវបង្កើតក្ដារព័ត៌មាននៅតាមទីសាធារណៈផ្សេងទៀត ដើម្បីផ្សព្វផ្សាយព័ត៌មានបន្ថែមដល់ប្រជាពលរដ្ឋ។ ក្រុមប្រឹក្សាក៏ត្រូវស្វែងរកមធ្យោបាយផ្សេងៗ ដើម្បីផ្សព្វផ្សាយព័ត៌មានដល់ប្រជាពលរដ្ឋអំពីការងាររដ្ឋបាលខ្លួន (មាត្រា ៥៤, ១១១, ១៧២ នៃអនុក្រឹត្យលេខ ២១៦ អ.ន.ក្រ.បក ស្ដីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក)។
- ប្រធានក្រុមប្រឹក្សា ត្រូវចាត់វិធានការបិទផ្សាយព័ត៌មានជាសាធារណៈអំពី**សេចក្ដីសម្រេច** ឬ**ដីកា**របស់ក្រុមប្រឹក្សានៅក្នុងរយៈពេល៥ថ្ងៃធ្វើការ បន្ទាប់ពីក្រុមប្រឹក្សាអនុម័តសេចក្ដីសម្រេច ឬដីកា (ប្រការ ១៩ នៃគំរូបទបញ្ជាផ្ទៃក្នុង)។
- ក្រុមប្រឹក្សា ត្រូវរៀបចំ និង ផ្សព្វផ្សាយ**របាយការណ៍ប្រចាំឆ្នាំ**របស់ខ្លួន ដែលលើកឡើងអំពីសកម្មភាព និងការងាររបស់ខ្លួន (មាត្រា ៥០ នៃច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ)។

**បញ្ហាដែលត្រូវដោះស្រាយ**

គួរមានឱកាសបន្ថែមទៀត សំរាប់ឱ្យប្រជាពលរដ្ឋចូលរួមនៅក្នុងការធ្វើសេចក្ដីសម្រេចនៅពេលដាក់ចេញលិខិតបទដ្ឋានបន្ថែម ក្រោមច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

ឧទាហរណ៍ គេរំពឹងថា លិខិតបទដ្ឋានទាក់ទងនឹងកិច្ចការខាងក្រោម នឹងដោះស្រាយការចូលរួម និង ការពិគ្រោះយោបល់របស់ប្រជាពលរដ្ឋៈ

- ការកសាងផែនការអភិវឌ្ឍន៍
- ការរៀបចំថវិកា
- ការគ្រប់គ្រងកិច្ចការហិរញ្ញវត្ថុ
- ដីការបស់ក្រុមប្រឹក្សា
- នីតិវិធីសំរាប់ការបំពេញការងាររបស់គណៈកម្មាធិការក្រុមប្រឹក្សា។

**ច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ**

**មាត្រា ៣៧ ដល់ ៤១, ១២៤, ១៦៦**

✓ ក្រុមប្រឹក្សា ត្រូវចូលរួមនៅក្នុងការរៀបចំ ហើយត្រូវអនុម័ត និងពិនិត្យមើលការអនុវត្ត**ផែនការអភិវឌ្ឍរយៈពេល ៥ ឆ្នាំ** និង **កម្មវិធីវិនិយោគ ៣ ឆ្នាំរំកិល ថវិកា** និងក្របខ័ណ្ឌចំណាយរយៈពេលមធ្យម។ ផែនការអភិវឌ្ឍ និងកម្មវិធីវិនិយោគ ត្រូវពិនិត្យតាមដាន វាយតម្លៃ និងធ្វើបច្ចុប្បន្នភាពជារៀងរាល់ឆ្នាំ (មាត្រា ៣៧, ៤០ នៃច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មាត្រា ៤ នៃអនុក្រឹត្យស្ដីពីការកសាងផែនការ)។

✓ នៅក្នុងការរៀបចំផែនការអភិវឌ្ឍរបស់ខ្លួន ក្រុមប្រឹក្សា ត្រូវកំណត់តម្រូវការរបស់**ស្ត្រី** និង**បុរស យុវជន កុមារ** និង**ក្រុមជនងាយរងគ្រោះ** (រួមទាំង**ជនក្រីក្រ** និង**ជនជាតិដើមភាគតិច**) (មាត្រា ៣៩ នៃច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មាត្រា ៥ នៃអនុក្រឹត្យស្ដីពីការកសាងផែនការ )។

✓ នៅក្នុងការរៀបចំ និងការអនុវត្តផែនការអភិវឌ្ឍ ក្រុមប្រឹក្សាត្រូវមាន**តម្លាភាព** តាមរយៈការផ្សព្វផ្សាយការចែក**រំលែកព័ត៌មាន**ហើយក្រុមប្រឹក្សា ត្រូវ **ពិគ្រោះយោបល់ឱ្យបានទូលំទូលាយ** រួមមានជាមួយប្រជាពលរដ្ឋទាំងអស់នៅក្នុងដែនដីរបស់ខ្លួន ក្រុមប្រឹក្សាផ្សេងទៀត ក្រសួងពាក់ព័ន្ធ និងអ្នកពាក់ព័ន្ធផ្សេងទៀត (មាត្រា ៣៨ នៃច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មាត្រា ៥ នៃអនុក្រឹត្យស្ដីពីការកសាងផែនការ)។ អ្នកពាក់ព័ន្ធផ្សេងទៀត គួរមានបញ្ចូលអង្គការ**សង្គមស៊ីវិលផ្អែកលើសហគមន៍** ដែលមានទីតាំងនៅក្នុងតំបន់របស់ក្រុមប្រឹក្សា ឬកំពុងបំពេញការងារនៅក្នុងតំបន់របស់ក្រុមប្រឹក្សារួមទាំងអង្គការនានានៅសហគមន៍។

ចំពោះព័ត៌មានបន្ថែមអំពីការកសាងផែនការ សូមអានមេរៀនទី ១៤

✓ ផែនការអភិវឌ្ឍរបស់ក្រុមប្រឹក្សា ត្រូវឆ្លុះបញ្ចាំងសកម្មភាពមកពីវិស័យផ្សេងៗទាំងអស់ នៅក្នុងដែនដីរបស់ក្រុមប្រឹក្សា។ ដូច្នេះ ផែនការអភិវឌ្ឍ ត្រូវ**ដាក់បញ្ចូលសកម្មភាពអភិវឌ្ឍទាំងអស់** នៅក្នុងដែនដីរបស់ក្រុមប្រឹក្សា ទោះបីជាសកម្មភាពនោះមិនស្ថិតនៅក្រោមការគ្រប់គ្រង ឬការត្រួតពិនិត្យរបស់ក្រុមប្រឹក្សាក្តី (មាត្រា ១២៤ និង ១៦៦ នៃច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ)។

**ឧទាហរណ៍** មន្ទីរកសិកម្មខេត្តមួយផ្តល់សេវានៅក្នុងស្រុកមួយ ។ ផែនការអភិវឌ្ឍ និងថវិការបស់ស្រុកនោះ ត្រូវដាក់បញ្ចូលសេវាដែលផ្តល់នៅក្នុងស្រុកដោយមន្ទីរកសិកម្មខេត្ត ។

✓ ក្រុមប្រឹក្សា ណែនាំគណៈអភិបាលអំពីការចាត់ចែងអនុវត្តផែនការអភិវឌ្ឍ និងកម្មវិធីវិនិយោគ រួមទាំងរបៀបអនុវត្តផែនការ និងកម្មវិធីនេះប្រកបដោយ**តម្លាភាព គណនេយ្យភាព ការចូលរួម** និង**ប្រសិទ្ធិភាព** ( មាត្រា ២២ នៃអនុក្រឹត្យស្តីពីការកសាងផែនការ ) ។

✓ **ក្រុមប្រឹក្សា ចាត់ចែង**ឱ្យមាន**ការពិនិត្យតាមដាន**ការអនុវត្តផែនការអភិវឌ្ឍ និងកម្មវិធីវិនិយោគ ( មាត្រា ២៥ នៃអនុក្រឹត្យស្តីពីការកសាងផែនការ) ។

## ការគ្រប់គ្រងហិរញ្ញវត្ថុ និងការរៀបចំថវិកា

**ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ**

**មាត្រា ៤២ ដល់ ៤៥, ២៤១ ដល់ ២៤៥, ២៥៣**

✓ ក្រុមប្រឹក្សា ត្រូវគ្រប់គ្រងកិច្ចការហិរញ្ញវត្ថុរបស់ខ្លួន ទៅតាមរបៀបដែល**បើកចំហ និងមានតម្លាភាព**ចំពោះប្រជាពលរដ្ឋរបស់ខ្លួន។ ក្រុមប្រឹក្សា **មានគណនេយ្យភាព**ចំពោះប្រជាពលរដ្ឋរបស់ខ្លួនលើទិដ្ឋភាពទាំងអស់នៃការគ្រប់គ្រងហិរញ្ញវត្ថុ ( មាត្រា ៤៣ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ) ។

✓ រាជធានីភ្នំពេញ ខេត្ត ក្រុង និងស្រុក មាន**ថវិការបស់ខ្លួនផ្ទាល់ ។** សង្កាត់ និងខណ្ឌនៅភ្នំពេញ និងសង្កាត់នៅក្រុងទទួលថវិការបស់ខ្លួនពីក្រុមប្រឹក្សារាជធានីភ្នំពេញ ឬពីក្រុមប្រឹក្សាក្រុង ( មាត្រា ៤៤ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ) ។ ឃុំ និងសង្កាត់នៅក្នុងស្រុក នៅបន្តទទួលបានថវិការបស់ខ្លួនក្រោមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ( មាត្រា ៧៣ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ )

✓ ក្រុមប្រឹក្សា ត្រូវរៀបចំ**ថវិកាប្រចាំឆ្នាំ** និង**ផែនការចំណាយរយៈពេលមធ្យម ។** ថវិកា ត្រូវរក្សាតុល្យភាពរវាងចំណូល និងចំណាយរបស់ក្រុមប្រឹក្សា ( មាត្រា ៤៤ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ) ។

✓ ក្រុមប្រឹក្សា ត្រូវចាត់ចែងកិច្ចការហិរញ្ញវត្ថុរបស់ខ្លួន ដោយផ្តោតទៅលើ**ការផ្តល់សេវាជាមូលដ្ឋានដល់ប្រជាពលរដ្ឋរបស់ខ្លួន** ដើម្បីកាត់បន្ថយភាពក្រីក្រ និងឆ្លើយតបនឹងតម្រូវការរបស់ស្ត្រី និងបុរស យុវជន កុមារ និង**ក្រុមជនងាយរងគ្រោះ** (រួមទាំងជនក្រីក្រ និង ជនជាតិដើមភាគតិច) (មាត្រា ៤២ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ) ។

> ចំពោះព័ត៌មានបន្ថែមអំពីការគ្រប់គ្រងហិរញ្ញវត្ថុ សូមអានមេរៀនទី ១៥

✓ *ច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ* និងលិខិតបទដ្ឋានផ្សេងទៀត នឹងត្រូវអនុម័ត ដើម្បីដោះស្រាយការគ្រប់គ្រងហិរញ្ញវត្ថុ ថវិកា និងការគ្រប់គ្រងទ្រព្យសម្បត្តិនៅថ្នាក់ក្រោមជាតិ( មាត្រា ៤៤-៤៦,២៤៤, ២៤៥, ២៤៨, ២៥៣, ២៥៥នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ) ។

## ផ្នែកទី ៣: មុខងារជាក់លាក់របស់ក្រុមប្រឹក្សា

### មុខងាររដ្ឋបាល

**ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ**

**មាត្រា ២៧៧, ២៧៨, ២៨១**

✓ បន្ទាប់ពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាលើកទីមួយ ក្រុមប្រឹក្សាថ្មី បានជំនួសរដ្ឋបាលដែលត្រូវតែងតាំងពីមុនមកនៅក្នុងដែនដីរបស់ខ្លួន។ ឧទាហរណ៍ ក្រុមប្រឹក្សារាជធានីភ្នំពេញ បានជំនួសរដ្ឋបាលសាលាក្រុងភ្នំពេញដែលត្រូវបានតែងតាំងពីមុន (មាត្រា ២៧៧ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មាត្រា ៧ នៃប្រកាស ១២៤៩ ស្តីពីការប្រជុំចូលកាន់តំណែង)។

✓ អភិបាលដែលមានស្រាប់ បានកាន់តំណែងរបស់ខ្លួនរហូតដល់ពេលក្រុមប្រឹក្សា និងគណៈអភិបាលថ្មីមកជំនួស។ ក្រៅពីនេះ **បុគ្គលិកដែលកំពុងបំពេញការងារនៅក្នុងអង្គភាព**របស់រដ្ឋបាលពីមុន ត្រូវបាន**កែសម្រួលរៀបចំឡើងវិញ** ឱ្យក្រុមប្រឹក្សាជាប់ឆ្នោតថ្មីនៅរាជធានីភ្នំពេញ ខេត្ត ក្រុង ស្រុក និង ខណ្ឌ (មាត្រា ២៧៨, ២៨១ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ)។

### មុខងារតាមវិស័យ

**ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ**

**មាត្រា ១០៨, ១១២, ២០០, ២១៣ ដល់ ២៤០**

✓ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មានចែងតួនាទី និងភារកិច្ចទូទៅរបស់ក្រុមប្រឹក្សា។ ក្រៅពីនេះ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ គូសបញ្ជាក់ដំណើរការ និងលក្ខណៈវិនិច្ឆ័យសម្រាប់**ការពិនិត្យមើលឡើងវិញលើមុខងារតាមវិស័យ** ដើម្បីកំណត់ថាតើមុខងារតាមវិស័យមួយណា**គួរផ្ទេរឱ្យក្រុមប្រឹក្សាណាមួយ** រួមទាំង ក្រុមប្រឹក្សា ឃុំ (មាត្រា ២០០, ២១៣ ដល់២៤០ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុកខណ្ឌ មាត្រា ២០៦ នៃអនុក្រឹត្យលេខ ២១៦)។

✓ ការផ្ទេរមុខងារតាមវិស័យជាក់លាក់ដល់ក្រុមប្រឹក្សា គឺជា**ការផ្លាស់ប្តូរជាដុំកំភួន បើធៀបការគ្រប់គ្រងនៅមុនមានការបោះឆ្នោតនៅថ្នាក់ក្រោមជាតិ**។ ការផ្តល់ឱ្យក្រុមប្រឹក្សា នូវមុខងារតាមវិស័យជាក់លាក់ គួរដោះស្រាយបាន**ការលំបាកនាពេលបច្ចុប្បន្ននៅថ្នាក់ឃុំ។** បច្ចុប្បន្ននេះ ក្រុមប្រឹក្សាឃុំជាច្រើន មានភាពស្រពិចស្រពិលលើមុខងារដែលគាត់គួរ ឬមិនគួរអនុវត្ត។ ជាលទ្ធផល ក្រុមប្រឹក្សាឃុំហាក់ដូចជាមិន អនុវត្តមុខងារតាមវិស័យជាក់លាក់ណាមួយនៅឡើយ។ ហេតុនេះ នៅពេលក្រុមប្រឹក្សា ទទួលបានការផ្ទេរមុខងារតាមវិស័យជាក់លាក់ មិនគួរឱ្យមានភាពស្រពិចស្រពិលនេះមានទៀតឡើយ។

**មុខងារ**

ឧទាហរណ៍លើមុខងារដែលអាចមាន:

- ការផ្តល់សេវាផ្សព្វផ្សាយកសិកម្ម
- គ្រប់គ្រងសាលាបឋមសិក្សា
- ប្រមូល និងគ្រប់គ្រងសំរាម
- ត្រួតពិនិត្យកន្លែងសត្តឃាដ ។ល។

ជាប្រការមិនអាចធ្វើបានឡើយដែលសមាជិកក្រុមប្រឹក្សា អនុវត្តមុខងារទាំងអស់របស់ក្រុមប្រឹក្សា *ដោយខ្លួនឯងផ្ទាល់*។ ជាពិសេស មុខងារដែលពាក់ព័ន្ធនឹងជំនាញបច្ចេកទេស ដូចជា ការផ្តល់យោបល់លើរបៀបបង្កើនទិន្នផលស្រូវ។ ដូច្នេះ ក្រុមប្រឹក្សា នឹងមាន**បុគ្គលិកជំនាញរបស់ខ្លួនផ្ទាល់** ដែលមានតួនាទី **អនុវត្តមុខងាររបស់ក្រុមប្រឹក្សា។**

✓ ដំណើការ និងលក្ខណៈវិនិច្ឆ័យដែលមានចែងនៅក្នុងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ នឹងត្រូវប្រើប្រាស់ដើម្បីកំណត់មុខងារដែលត្រូវផ្ទេរឱ្យក្រុមប្រឹក្សារាជធានីភ្នំពេញ ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង និងក្រុមប្រឹក្សាស្រុក ក៏ដូចជាក្រុមប្រឹក្សាឃុំ (មាត្រា ២២០ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ)។

✓ ដោយសារខណ្ឌ និងសង្កាត់ស្ថិតនៅទីប្រជុំជន ក្រុមប្រឹក្សាខណ្ឌ និងក្រុមប្រឹក្សាសង្កាត់ក្នុងរាជធានីភ្នំពេញ និងសង្កាត់ក្នុងក្រុង ទទួលបានតែមុខងារដែលត្រូវធ្វើប្រតិភូកម្មដោយក្រុមប្រឹក្សារាជធានីភ្នំពេញ និងក្រុមប្រឹក្សាក្រុងប៉ុណ្ណោះ (មាត្រា ១០៨, ១១២ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ)។

✓ សង្កាត់នៅក្នុងស្រុក នឹងត្រូវចាត់ទុកដូចជាឃុំក្រោមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។ ដូច្នេះ សង្កាត់នៅក្នុងស្រុក បន្តមានមុខងារក្រោមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ហើយអាចទទួលបានមុខងារដោយផ្ទាល់ពីថ្នាក់ជាតិ ក្រោមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ (មាត្រា ៤៣ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់)។

✓ នៅពេលខាងមុខ គេអាចរំពឹងថា ក្រុមប្រឹក្សានៅតាមថ្នាក់ផ្សេងៗ នឹងមាន**មុខងារជាក់លាក់ ដើម្បីអនុវត្តនៅក្នុងវិស័យមួយចំនួន** ដូចជាអប់រំ សុខាភិបាល ការគ្រប់គ្រងធនធានធម្មជាតិ ការគ្រប់គ្រងដីធ្លី កសិកម្ម ។ល។ (មាត្រា ២១៥ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ)។ គេអាចរំពឹងថា ក្រុមប្រឹក្សា នឹងមានការយកចិត្តទុកដាក់ជាច្រើនទៅលើការធ្វើសេចក្តីសម្រេចអំពីរបៀបអនុវត្តមុខងារតាមវិស័យរបស់ខ្លួន និងការធានាឱ្យបានថា មុខងារទាំងនេះត្រូវបានអនុវត្តយ៉ាងសមស្របនៅពេលបន្ទាប់។

ចំពោះព័ត៌មានបន្ថែមអំពីការការផ្ទេរមុខងារតាមវិស័យ សូមអានមេរៀនទី ១៣

**ការដោះស្រាយវិវាទ**

**ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ**

**មាត្រា ៨៩ ដល់ ៩៥**

✓ ក្រុមប្រឹក្សាឃុំ សង្កាត់ និង រដ្ឋបាលស្រុក កំពុងសំរុះសំរួលវិវាទមួយចំនួននៅមូលដ្ឋាន។ នៅពេលខាងមុខ **ក្រុមប្រឹក្សាទាំងអស់** នឹងមានមុខងារ ដើម្បីសម្រុះសម្រួលវិវាទនៅមូលដ្ឋាន។

✓ ក្រុមប្រឹក្សា ត្រូវចាត់វិធានការដើម្បីសម្រុះសម្រួល**វិវាទនៅមូលដ្ឋាន**នៅក្នុងដែនដីរបស់ខ្លួន។ វិវាទនៅមូលដ្ឋានគឺជា**វិវាទមានលក្ខណៈឯកជន**រវាងប្រជាពលរដ្ឋ (មាត្រា ៨៩, ៩០ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ)។

✓ ក្នុងករណីដែលបុគ្គលមានវិវាទមិនទទួលយកដំណោះស្រាយដែលស្នើឡើងដោយក្រុមប្រឹក្សា បុគ្គលរូបនោះអាចប្តឹងទៅតុលាការ ដើម្បីដោះស្រាយបាន (មាត្រា ៩២ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ)។

✓ មានវិវាទប្រភេទខ្លះដែលក្រុមប្រឹក្សាមិនអាចសម្រុះសម្រួលបាន ឧទាហរណ៍ វិវាទពាក់ព័ន្ធនឹងការលែងលះ និងបទឧក្រិដ្ឋមួយចំនួន (មាត្រា ៩៤ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ)។

✓ នៅក្នុងពេលនៃកិច្ចប្រជុំរបស់ក្រុមប្រឹក្សា ក្រុមប្រឹក្សា អាចសម្រេចពិនិត្យ និងចាត់វិធានការដោះស្រាយវិវាទនៅមូលដ្ឋានស្របទៅតាមច្បាប់ និងនីតិវិធីជាធរមាន (មាត្រា ១៥, ៧១, ១៣៣ នៃអនុក្រឹត្យលេខ ២១៦ អ.ន.ក្រ.បក ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក)។

✓ នៅក្នុងពេលនៃកិច្ចប្រជុំរបស់ក្រុមប្រឹក្សា ក្រុមប្រឹក្សាក៏អាចសម្រេចផងដែរ អំពីវិធានការដែលត្រូវប្រកាន់យកដើម្បីដោះស្រាយសំណូមពរ ឬបណ្តឹងរបស់ប្រជាពលរដ្ឋ (មាត្រា ១៥, ៧១, ១៣៣ នៃអនុក្រឹត្យលេខ ២១៦ អ.ន.ក្រ.បក ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក)។

**បញ្ហាដែលត្រូវដោះស្រាយ**

ជាការសំខាន់ណាស់ដែលនីតិវិធីសំរាប់សម្រុះសម្រួលធានាឱ្យមានកម្រិតជាអតិបរមានៃភាពត្រឹមត្រូវ និងយុត្តិធម៌នៅក្នុងដំណើរការ។ ប្រការនេះនឹងកសាងបាននូវជំនឿទុកចិត្តរបស់សាធារណជនទៅលើក្រុមប្រឹក្សាថ្មី។

## ការគាំទ្ររបស់ខេត្តដល់ក្រុមប្រឹក្សាផ្សេងទៀត

✓ រាជរដ្ឋាភិបាល បាន**ធ្វើប្រតិភូកម្ម**ដល់ក្រុមប្រឹក្សាខេត្តនូវ**មុខងារដើម្បីគាំទ្រ**ក្រុមប្រឹក្សាផ្សេងទៀតនៅក្នុងខេត្ត និង**ធ្វើការពិនិត្យនីត្យានុកូលភាព**ផងដែរលើសេចក្តីសម្រេច និងសកម្មភាពរបស់ក្រុមប្រឹក្សាក្រុង និងស្រុក។ ប្រតិភូកម្មនេះរួមមានៈ

- ការអភិវឌ្ឍយុទ្ធសាស្ត្រ ដើម្បីគាំទ្រការអភិវឌ្ឍសមត្ថភាពរបស់ក្រុមប្រឹក្សា និងបុគ្គលិករបស់ក្រុមប្រឹក្សា ក្រុង ស្រុក ឃុំ សង្កាត់

- ការណែនាំ ការសម្របសម្រួល និងការគាំទ្រក្រុមប្រឹក្សាទាំងនេះនៅក្នុងការអនុវត្តមុខងារ និងភារកិច្ចរបស់ខ្លួន និងនៅក្នុងការប្រើប្រាស់ធនធានរបស់ខ្លួន
- ការធានាឱ្យបានថា ក្រុង និងស្រុក ផ្តល់ការគាំទ្រសមស្របដល់សង្កាត់នៅក្នុងក្រុង និងឃុំ សង្កាត់នៅក្នុងស្រុក ។

(មាត្រា ១៩៦ នៃអនុក្រឹត្យលេខ ២១៦ អ.ន.ក្រ.បក ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក) ។

- ការទទួលខុសត្រូវទាំងនេះ ត្រូវអនុវត្តដោយ**គណៈអភិបាល** និង **បុគ្គលិករបស់ក្រុមប្រឹក្សា**។ គណៈអភិបាលត្រូវរាយការណ៍អំពីការងារនេះដល់ក្រុមប្រឹក្សានៅរាល់កិច្ចប្រជុំរបស់ក្រុមប្រឹក្សា (មាត្រា ១៩៦ នៃអនុក្រឹត្យលេខ ២១៦ អ.ន.ក្រ.បក ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក) ។

## ការគាំទ្ររបស់ស្រុកដល់ឃុំ សង្កាត់នៅក្នុងស្រុក

**ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ**

**មាត្រា ៩៦ ដល់ ១០៥**

✓ គ្រប់ក្រុមប្រឹក្សាស្រុក មាន**មុខងារពិសេស ដើម្បីជួយក្រុមប្រឹក្សាឃុំ សង្កាត់** នៅក្នុងស្រុក ដើម្បីឱ្យក្រុមប្រឹក្សាឃុំ សង្កាត់ អាចសម្រេចបានលទ្ធផលល្អប្រសើរក្នុងការបង្កើត ជំរុញ និងធ្វើឱ្យមានចីរភាពសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅក្នុងដែនដីរបស់ខ្លួន (មាត្រា ៩៧ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ) ។

✓ ក្រុមប្រឹក្សា ត្រូវចាត់ចែង**ឱ្យមានការអភិវឌ្ឍសមត្ថភាព** ដល់ក្រុមប្រឹក្សាឃុំ សង្កាត់ ដើម្បីឱ្យក្រុមប្រឹក្សាឃុំ សង្កាត់ អាច**ទទួលមុខងារ និងធនធាន** ហើយអាចអនុវត្តមុខងារ និងប្រើប្រាស់ធនធានទៅតាមរបៀបដែលបង្កើត ជម្រុញ និងធ្វើឱ្យមានចីរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ ។

- ក្រុមប្រឹក្សាស្រុក ត្រូវ**វាយតម្លៃ**សមត្ថភាពរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ យ៉ាងតិចម្តងជារៀងរាល់ឆ្នាំ ។
- បន្ទាប់មក ក្រុមប្រឹក្សាស្រុក អាចចាត់ចែង**ការបណ្តុះបណ្តាល**កសាងសមត្ថភាពដល់ក្រុមប្រឹក្សាឃុំ សង្កាត់ និងបុគ្គលិករបស់ឃុំ សង្កាត់ ផ្អែកលើលទ្ធផលនៃការវាយតម្លៃ ។

(មាត្រា ៩៩, ១០១ ដល់ ១០៤ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មាត្រា ១២២ នៃអនុក្រឹត្យលេខ ២១៦ អ.ន.ក្រ.បក ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក)។

- ✓ ក្រុមប្រឹក្សាស្រុក និង ក្រុមប្រឹក្សាឃុំ សង្កាត់នៅក្នុងស្រុក ត្រូវធ្វើការជាមួយគ្នា ដើម្បីធានាឱ្យបានថា **ប្រជាពលរដ្ឋ** មានឱកាសប្រកបដោយអត្ថន័យ ដើម្បី**ចូលរួមនៅក្នុងអភិបាលកិច្ច** (ការចូលរួមចំណែករបស់ប្រជាពលរដ្ឋ) និងថា **តម្រូវការរបស់ប្រជាពលរដ្ឋ** នៅក្នុងស្រុក **ត្រូវបានឆ្លើយតប** (មាត្រា ៩៧ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ)។

- ✓ គ្រប់ក្រុមប្រឹក្សាស្រុក មានការិយាល័យគាំទ្រក្រុមប្រឹក្សាឃុំ សង្កាត់នៅក្នុងស្រុក គឺ **ការិយាល័យផែនការ និងគាំទ្រក្រុមប្រឹក្សាឃុំ សង្កាត់** (មាត្រា ៨១ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ប្រការ ២៦ នៃប្រកាសស្តីពីការបង្កើតការិយាល័យចំណុះទីចាត់ការសាលាខេត្ត ការិយាល័យសាលាក្រុង និងការិយាល័យសាលាស្រុក)។

> ទំនាក់ទំនងរវាងក្រុមប្រឹក្សាស្រុក ត្រូវរៀបចំឡើងដើម្បីពង្រឹង និងផ្តល់អំណាចដល់ក្រុមប្រឹក្សាឃុំ សង្កាត់ និងដើម្បីធានាឱ្យបានថាតម្រូវការនៅមូលដ្ឋាន ត្រូវបានឆ្លើយតប។ ដូច្នេះ ក្រុមប្រឹក្សា និងគណៈអភិបាលស្រុក ត្រូវ**គោរពស្វ័យភាពរបស់ក្រុមប្រឹក្សាឃុំ សង្កាត់** (មាត្រា ១៧៤ នៃអនុក្រឹត្យលេខ ២១៦)។ និយាយបានម្យ៉ាងទៀតថា តួនាទីរបស់ស្រុក គឺត្រូវ**ផ្តល់ឱកាសធ្វើសេចក្តីសម្រេច**ដល់ក្រុមប្រឹក្សាឃុំ សង្កាត់ឱ្យបានជាអតិបរមា គឺមិនត្រូវជ្រៀតជ្រែកការងារឡើយ។

- ✓ ក្រុមប្រឹក្សាស្រុក ក៏មានការទទួលខុសត្រូវផងដែរក្នុងការពិនិត្យមើលថា **ដីកា និង សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់** អនុលោមទៅតាមរដ្ឋធម្មនុញ្ញ ច្បាប់ និងលិខិតបទដ្ឋានជាធរមាន។ គណៈអភិបាលស្រុក បំពេញ ភារកិច្ចនេះក្នុងនាមក្រុមប្រឹក្សាស្រុក ( មាត្រា ៧៤-១៩៦ អនក្រ ២១៦ អ.ន.ក្រ.បក ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និង ក្រុមប្រឹក្សា គណៈអភិបាលស្រុក ប្រកាសលេខ៤២៧៤ស្តីពីការបង្កើត ការិយាល័យចំណុះទីចាត់ការសាលាខេត្ត ការិយាល័យសាលាក្រុង និងការិយាល័យសាលាស្រុក ប្រការ ៤ )។

> ចំពោះព័ត៌មានបន្ថែមអំពីការគាំទ្ររបស់ក្រុមប្រឹក្សាស្រុក ដល់ក្រុមប្រឹក្សាឃុំ សង្កាត់ សូមអានមេរៀនទី ១១

✓ តួនាទីគាំទ្រនិងតួនាទីពិនិត្យមើលនីត្យានុកូលភាព ដែលក្រុមប្រឹក្សាស្រុកប្រកាន់យក មិនមែនមានន័យថា ក្រុមប្រឹក្សាឃុំ សង្កាត់ មានគណនេយ្យភាពចំពោះក្រុមប្រឹក្សាស្រុកឡើយ។ ផ្ទុយទៅវិញ **គឺក្រុមប្រឹក្សាស្រុក ទេដែលមានគណនេយ្យភាពចំពោះក្រុមប្រឹក្សាឃុំ សង្កាត់**នៅក្នុងស្រុក (មាត្រា ៩៧, ៩៨ នៃច្បាប់ស្តីពី ការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ)។

✓ ក្រុមប្រឹក្សាស្រុក **មានគណនេយ្យភាព**ចំពោះ ក្រុមប្រឹក្សាឃុំ សង្កាត់នៅក្នុងស្រុក ពីព្រោះសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ គឺជាអ្នកបោះឆ្នោតជ្រើសរើស សមាជិកក្រុមប្រឹក្សាស្រុក។ ក្រុមប្រឹក្សាស្រុក ត្រូវមានគណនេយ្យភាពចំពោះអ្នកបោះឆ្នោតរបស់ខ្លួន។

✓ ឧទាហរណ៍ ក្រុមប្រឹក្សាស្រុក ត្រូវបានតម្រូវឱ្យធ្វើការពិគ្រោះយោបល់ជាប្រចាំជាមួយក្រុមប្រឹក្សាឃុំ សង្កាត់នៅក្នុងស្រុក ហើយឆ្លើយតបទៅនឹងសំណូមពររបស់ក្រុមប្រឹក្សាឃុំ សង្កាត់។ វិធីមួយក្នុងចំណោមវិធីនានាដែលក្រុមប្រឹក្សាស្រុក ពិគ្រោះយោបល់ជាមួយក្រុមប្រឹក្សាឃុំ សង្កាត់ គឺតាមរយៈ**វេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់**ដែលបានពិភាក្សាខាងលើរួចហើយ (មាត្រា ៩៧, ៩៨ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មាត្រា ១១៦, ១៣២ នៃអនុក្រឹត្យលេខ ២១៦ អ.ន.ក្រ.បក ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក)។

✓ ក្រៅពីនេះ មេឃុំ ចៅសង្កាត់ មាន**សិទ្ធិចូលរួមនៅក្នុងកិច្ចប្រជុំទាំងអស់របស់ក្រុមប្រឹក្សាស្រុក** ដើម្បីពិភាក្សាផ្តល់យោបល់ និងលើកសំណូមពរ (មាត្រា ១១៩ នៃអនុក្រឹត្យលេខ ២១៦ អ.ន.ក្រ.បក ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក)។

✓ វិធីមួយទៀត ដើម្បីជម្រុញ**គណនេយ្យភាពរបស់ក្រុមប្រឹក្សាស្រុក** ចំពោះក្រុមប្រឹក្សាឃុំ សង្កាត់ គឺគ្រប់ក្រុមប្រឹក្សាស្រុក ត្រូវចាត់តាំងតំណាងជាសមាជិកក្រុមប្រឹក្សាម្នាក់ ដើម្បីចូលរួមនៅក្នុងកិច្ចប្រជុំរបស់ក្រុមប្រឹក្សាឃុំ សង្កាត់នៅ ក្នុងស្រុក។ **សមាជិកក្រុមប្រឹក្សាស្រុក ត្រូវរាយការណ៍**ដល់ក្រុមប្រឹក្សាឃុំ សង្កាត់អំពីសកម្មភាព និងសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាស្រុក។ សមាជិកក្រុមប្រឹក្សាស្រុក ត្រូវបំភ្លឺបញ្ហានានាដែលបានលើកឡើង

- ហើយត្រូវប្រមូលសំណូមពរ និងសិក្សាបញ្ហាប្រឈមដែលក្រុមប្រឹក្សាឃុំ សង្កាត់ មិនអាចដោះស្រាយដោយខ្លួនឯង ( មាត្រា ១២០អនក្រ ២១៦ អ.ន.ក្រ.បក ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក )។

## ការគាំទ្ររបស់ក្រុងដល់សង្កាត់នៅក្នុងក្រុង

✓ ដូចគ្នានឹងក្រុមប្រឹក្សាស្រុកដែលគាំទ្រក្រុមប្រឹក្សាឃុំ សង្កាត់នៅក្នុងស្រុក ក្រុមប្រឹក្សាក្រុង ត្រូវគាំទ្រក្រុមប្រឹក្សាសង្កាត់នៅក្នុងក្រុង។

✓ នៅរាល់កិច្ចប្រជុំរបស់ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សា ត្រូវពិចារណាអំពីរបៀប**ពិគ្រោះយោបល់ជាមួយក្រុមប្រឹក្សាសង្កាត់**។ នៅក្នុងកិច្ចប្រជុំរបស់ខ្លួន ក្រុមប្រឹក្សាក្រុង ក៏អាចធ្វើសេចក្តីសម្រេចផងដែរទាក់ទងនឹងការគាំទ្រដល់ក្រុមប្រឹក្សាសង្កាត់ និងការធ្វើ**ប្រតិភូកម្មមុខងារ**ដល់ក្រុមប្រឹក្សាសង្កាត់ ( មាត្រា ៧០, ៧១ នៃអនុក្រឹត្យលេខ ២១៦ អ.ន.ក្រ.បក ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក)។

✓ ក្រុមប្រឹក្សាក្រុង ត្រូវផ្តល់**ការគាំទ្រកសាងសមត្ថភាព**យ៉ាងសកម្មដល់ក្រុមប្រឹក្សាសង្កាត់ ដើម្បីឱ្យក្រុមប្រឹក្សាសង្កាត់មានសមត្ថភាពទទួលមុខងារដែលបានធ្វើប្រតិភូកម្មពីក្រុមប្រឹក្សាក្រុង ( មាត្រា ១៨០ នៃអនុក្រឹត្យលេខ ២១៦ អ.ន.ក្រ.បក ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក)។

✓ គ្រប់ក្រុមប្រឹក្សាក្រុង មានការិយាល័យគាំទ្រក្រុមប្រឹក្សាសង្កាត់នៅក្នុងក្រុង គឺ **ការិយាល័យផែនការ និងគាំទ្រក្រុមប្រឹក្សាសង្កាត់** ( ប្រការ ១៧ នៃប្រកាសស្តីពីការបង្កើតការិយាល័យចំណុះទីចាត់ការ សាលាខេត្ត ការិយាល័យសាលាក្រុង និងការិយាល័យសាលាស្រុក )។

> ចំពោះព័ត៌មានបន្ថែមអំពីការគាំទ្ររបស់ក្រុមប្រឹក្សាស្រុកដល់ក្រុមប្រឹក្សាឃុំ សង្កាត់ សូមអានមេរៀនទី ១១

✓ ក្រុមប្រឹក្សាក្រុង ត្រូវ**ពិគ្រោះយោបល់ សម្របសម្រួល និងសហប្រតិបត្តិការយ៉ាងជិតស្និទ្ធ**ជាមួយក្រុមប្រឹក្សាសង្កាត់ដើម្បីកំណត់ និងដោះស្រាយតម្រូវការនៅមូលដ្ឋាន។ វិធីមួយក្នុងចំណោមវិធីនានាដែលក្រុមប្រឹក្សាក្រុងពិគ្រោះយោបល់ជាមួយក្រុមប្រឹក្សាសង្កាត់ គឺតាមរយៈ**វេទិកាផ្សព្វផ្សាយនិងពិគ្រោះយោបល**ដែលបានពិភាក្សាខាងលើរួចហើយ ( មាត្រា ៦៤, ១៨០ នៃអនុក្រឹត្យលេខ ២១៦ អ.ន.ក្រ.បក ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនង

ការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក) ។

- ✓ ក្រៅពីនេះ ក្រុមប្រឹក្សាក្រុង ត្រូវ**ផ្តល់ធនធាន** (ហិរញ្ញវត្ថុ និងបុគ្គលិក) និងការអភិវឌ្ឍសមត្ថភាពចាំបាច់ ដើម្បីឱ្យក្រុមប្រឹក្សាសង្កាត់ និងបុគ្គលិករបស់សង្កាត់**អនុវត្តមុខងារដែលបានធ្វើប្រតិភូកម្ម**យ៉ាងមានប្រសិទ្ធិភាព (មាត្រា ១៨២, ១៨៣ នៃអនុក្រឹត្យលេខ ២១៦ អ.ន.ក្រ.បក ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក) ។

- ✓ ក្រៅពីនេះ ក្រុមប្រឹក្សាក្រុង មានការទទួលខុសត្រូវចំពោះការពិនិត្យមើលថា **ដីកា និងសេចក្តីសម្រេច**របស់**ក្រុមប្រឹក្សាសង្កាត់** អនុលោមទៅតាមរដ្ឋធម្មនុញ្ញ ច្បាប់ និងលិខិតបទដ្ឋានជាធរមាន។ គណៈអភិបាលក្រុង បំពេញ ភារកិច្ចនេះក្នុងនាមក្រុមប្រឹក្សា (មាត្រា ៧៤ នៃអនុក្រឹត្យលេខ ២១៦ អ.ន.ក្រ.បក ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក) ។

## តិដ្ឋភាពទូទៅ

## សិទ្ធិអំណាចរបស់ក្រុមប្រឹក្សា មុខងារទូទៅ និង មុខងារជាក់លាក់



## ផ្នែកទី ៤: មុខងាររបស់ក្រុមប្រឹក្សាឃុំ សង្កាត់

### មុខងារក្រោមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់

✓ ក្រុមប្រឹក្សាឃុំ សង្កាត់ បន្តមានមុខងារ អនុលោមតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ( មាត្រា ២៨៣ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ) ។

✓ ក្រោមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ក្រុមប្រឹក្សាឃុំ សង្កាត់ មានមុខងារពីរប្រភេទ។
ទីមួយ ក្រុមប្រឹក្សាឃុំ សង្កាត់ មានមុខងារ**បែបវិមជ្ឈការផ្ទាល់ខ្លួន** ដើម្បី :

- ធានារក្សាសន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ
- ចាត់ចែងសេវាសាធារណៈចាំបាច់
- លើកកំពស់សុខុមាលភាពរបស់ប្រជាពលរដ្ឋ
- លើកកំពស់ការអភិវឌ្ឍសេដ្ឋកិច្ច សង្គម និង កែលម្អកំរិតជីវភាពរបស់នៅរបស់ប្រជាពលរដ្ឋ
- ការពារ និងអភិរក្សបរិស្ថាន ធនធានធម្មជាតិ និងវប្បធម៌ ព្រមទាំងបេតិកភ័ណ្ឌជាតិ
- សម្រុះសម្រួលទស្សនៈរបស់ប្រជាពលរដ្ឋ ដើម្បីឱ្យមានការយោគយល់ និងការសណ្តោសន្តាទៅវិញទៅមក
- អនុវត្តការងារទូទៅ ដើម្បីឆ្លើយតបនឹងតម្រូវការរបស់ប្រជាពលរដ្ឋ ( មាត្រា ៤២, ៤៣ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់)

✓ ទីពីរ ក្រុមប្រឹក្សាឃុំ សង្កាត់ អាចទទួលបានមុខងារ ដើម្បីអនុវត្ត**ជាភ្នាក់ងាររបស់រដ្ឋ។** មុខងារទាំងនេះ ត្រូវបាន**ធ្វើវិសហមជ្ឈការតាមរយៈការធ្វើប្រតិភូកម្ម** ( មាត្រា ៤២, ៤៤ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់) ។ ឧទាហរណ៍ ក្រសួងមហាផ្ទៃ បានធ្វើប្រតិភូកម្មឱ្យក្រុមប្រឹក្សាឃុំ សង្កាត់នូវមុខងារចុះអត្រានុកូលដ្ឋានឱ្យប្រជា-ពលរដ្ឋ និងមុខងារចុះឈ្មោះអ្នកបោះឆ្នោត ។

### មុខងារក្រោមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

**ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ**
**មាត្រា ៤៤, ១០៨, ១១២, ២១៧**

✓ ក្រៅពីមុខងារក្រោមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ឃុំ និងសង្កាត់នៅក្នុងស្រុក នឹងមានមុខងារក្រោមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

✓ ក្រុមប្រឹក្សាឃុំ នឹងទទួលបានមុខងារតាមវិស័យដោយផ្ទាល់ពីថ្នាក់ជាតិដើម្បីអនុវត្ត។ ក្រុមប្រឹក្សាឃុំ នឹងទទួលបានថវិការបស់ខ្លួនផ្ទាល់ ដើម្បីអនុវត្តមុខងារទាំងនេះ (មាត្រា ២១៧ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ)។

✓ ក្រុមប្រឹក្សាសង្កាត់នៅរាជធានីភ្នំពេញ និងនៅតាមក្រុង នឹងទទួលបានមុខងារតាមវិស័យ ដែលត្រូវបានធ្វើប្រតិភូកម្មដល់ក្រុមប្រឹក្សាសង្កាត់ ដោយក្រុមប្រឹក្សារាជធានីភ្នំពេញ ឬក្រុមប្រឹក្សាក្រុង (មាត្រា ១០៨, ១១២ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ)។ ក្រុមប្រឹក្សាសង្កាត់ នឹងទទួលបានថវិកាដើម្បីអនុវត្តមុខងារដែលបានធ្វើប្រតិភូកម្មទាំងនេះពីក្រុមប្រឹក្សារាជធានីភ្នំពេញ ឬក្រុមប្រឹក្សាក្រុង (មាត្រា ៤៤ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ)។

✓ សង្កាត់នៅក្នុងស្រុក អាចទទួលបានមុខងារក្រោមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ (មាត្រា ២១៧ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ)។

### ជួរក្រោមមិនតាមឋានានុក្រមរបស់ក្រុមប្រឹក្សា

✓ ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាឃុំ និងក្រុមប្រឹក្សាសង្កាត់ **មានអំណាចដោយឡែករបស់ខ្លួនផ្ទាល់ ដើម្បីធ្វើសេចក្តីសម្រេច** ដើម្បីអនុវត្តមុខងាររបស់ខ្លួន និងដើម្បីប្រើប្រាស់ធនធានរបស់ខ្លួនក្នុងការបង្កើត ជំរុញ និងធ្វើឱ្យមានចីរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅក្នុងដែនដីរបស់ខ្លួន។

✓ **ស្វ័យភាព ឱកាសធ្វើសេចក្តីសម្រេច និងឱកាសផ្នែកនយោបាយ និងឱកាសផ្នែកឆន្ទានុសិទ្ធិរបស់ក្រុមប្រឹក្សាទាំងអស់ ត្រូវតែទទួលបានការគោរព។** ដរាបណាក្រុមប្រឹក្សាគោរពទៅតាមរដ្ឋធម្មនុញ្ញ ច្បាប់ និងលិខិតបទដ្ឋានជាធរមានផ្សេងទៀត គ្មានអ្នកណាម្នាក់អាចជ្រៀតជ្រែកទៅលើអាទិភាព ជម្រើស គោលនយោបាយ សេចក្តីសម្រេច ឬដីការបស់ក្រុមប្រឹក្សាបានឡើយ (មាត្រា ១៧៤ នៃអនុក្រឹត្យលេខ ២១៦)។

✓ ដូច្នេះ ដ្យាក្រាមខាងក្រោម ផ្តល់**ទស្សនៈមិនតាមឋានានុក្រម**អំពីក្រុមប្រឹក្សានៅថ្នាក់ក្រោមជាតិ ។



## វគ្គទី ២:

## មេរៀនសង្ខេប

- តួនាទីជាទូទៅរបស់ក្រុមប្រឹក្សានីមួយៗ គឺត្រូវធ្វើអ្វីដែលចាំបាច់ ដើម្បីសម្រេចបានគោលបំណងរបស់ខ្លួនក្នុងការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ និងអនុវត្តមុខងារដែលក្រុមប្រឹក្សាទទួលបាន ក្រោមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

- ក្រុមប្រឹក្សា មានសិទ្ធិអំណាចជាក់លាក់ក្រោមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌគឺ:
  - អំណាចប្រតិបត្តិ
  - អំណាចបញ្ញត្តិ
  - អំណាចរកចំណូលផ្ទាល់ខ្លួន

- ក្រុមប្រឹក្សា មានមុខងារទូទៅគឺ:
  - ការពិគ្រោះយោបល់ និងការផ្សព្វផ្សាយព័ត៌មាន
  - ការកសាងផែនការ
  - ការគ្រប់គ្រងហិរញ្ញវត្ថុ និងការរៀបចំថវិកា

- ក្រុមប្រឹក្សា ក៏មានមុខងារជាក់លាក់ផងដែរគឺ:
  - មុខងាររដ្ឋបាល ដោយត្រូវទទួលយកពីរដ្ឋបាលដែលបានតែងតាំងពីមុននៅក្នុងដែនដីរបស់ក្រុមប្រឹក្សា
  - មុខងារតាមវិស័យដែលត្រូវផ្ទេរឱ្យក្រុមប្រឹក្សា ( មិនទាន់បានកំណត់នៅឡើយ)
  - សម្រុះសម្រួលវិវាទបុគ្គលមួយចំនួននៅមូលដ្ឋាន
  - ក្រុមប្រឹក្សាខេត្ត ត្រូវគាំទ្រក្រុមប្រឹក្សាផ្សេងទៀតនៅក្នុងខេត្ត
  - ក្រុមប្រឹក្សាស្រុក ត្រូវជួយ និងគាំទ្រក្រុមប្រឹក្សាឃុំ សង្កាត់នៅក្នុងស្រុក។
  - ក្រុមប្រឹក្សាក្រុង ត្រូវជួយ និងគាំទ្រក្រុមប្រឹក្សាសង្កាត់នៅក្នុងក្រុង។

- ក្រុមប្រឹក្សាឃុំ សង្កាត់បន្តមានមុខងារក្រោមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់។ ឃុំ និង សង្កាត់នៅក្នុងស្រុកក៏នឹងទទួលបានមុខងារដោយផ្ទាល់ពីថ្នាក់ជាតិផងដែរ ក្រោមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

# វគ្គទី ៣៖

# ការងារជាក្រុម

**ការងារជាក្រុម ដូចមានពិពណ៌នាខាងក្រោម អាចមានលក្ខណៈមិនសមស្របសម្រាប់ការបណ្តុះបណ្តាលទាំងអស់។ សូមចាត់ទុកការងារជាក្រុមខាងក្រោមជាសំណូមពរតែប៉ុណ្ណោះ។**

១. ចែកសិក្ខាកាមជាក្រុមដែលមានសមាជិកមិនលើសពី ៨ នាក់

២. ផ្តល់លម្ហាត់ខាងក្រោមអោយក្រុមនីមួយៗ។

**លំហាត់ទីមួយ៖ មុខងារតាមវិស័យ**

អ្នកជាក្រុមប្រឹក្សាស្រុក។ អ្នកមានឱកាស ដើម្បីពិភាក្សាជាមួយក្រសួងអប់រំ ដើម្បីទទួលបានមុខងារទាក់ទងនឹងការអប់រំ ដើម្បីអនុវត្ត។

អភិវឌ្ឍអំណះអំណាងរបស់អ្នកថាហេតុអ្វីបានជាក្រុមប្រឹក្សាស្រុក គួរទទួលបានការផ្ទេរមុខងារខាងក្រោម។ (សូមចាំថា ក្រុមប្រឹក្សាស្រុក នឹងទទួលបានដោយស្វ័យប្រវត្តិនូវការអភិវឌ្ឍសមត្ថភាព ហិរញ្ញវត្ថុ បុគ្គលិក និង ទ្រព្យសម្បត្តិចាំបាច់)។

- អគារ ការជួសជុល និង ការថែទាំសាលារៀន
- ការជួល និង ការត្រួតពិនិត្យគ្រូបង្រៀន
- ការរៀបចំគណៈកម្មាធិការមាតា បិតា-គ្រូបង្រៀន

**លម្ហាត់ទីពីរ៖** ការគាំទ្ររបស់ស្រុកដល់ក្រុមប្រឹក្សាឃុំ សង្កាត់

អ្នកជាក្រុមប្រឹក្សាស្រុក។ អ្នកកំពុងប្រជុំ ដើម្បីអភិវឌ្ឍផែនការអំពីរបៀបដែលអ្នកនឹងគាំទ្រក្រុមប្រឹក្សាឃុំ សង្កាត់នៅក្នុងតំបន់របស់ខ្លួន។

- តើវិធានការជាក់ស្តែងអ្វីខ្លះ ដែលក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាឃុំ សង្កាត់ អាចប្រកាន់យក ដើម្បីធានាឱ្យបានថា មានការចូលរួមរបស់សាធារណជនប្រកបដោយអត្ថន័យនៅក្នុងអភិបាលកិច្ចមូលដ្ឋាន (ក្រៅពីការប្រជុំទ្រង់ទ្រាយធំនៅក្នុងភូមិ)?

- តើមធ្យោបាយប្រកបដោយការច្នៃប្រឌិតមួយចំនួន (ក្រៅពីការបណ្តុះបណ្តាល) ដែលក្រុមប្រឹក្សាស្រុក អាចប្រើប្រាស់ ដើម្បីអភិវឌ្ឍសមត្ថភាពនៅក្នុងក្រុមប្រឹក្សាឃុំ សង្កាត់នៅក្នុងដែនដីរបស់ខ្លួន ?
- តើក្រុមប្រឹក្សាស្រុក ត្រូវប្រកាន់យកវិធានការអ្វីខ្លះ ដើម្បីធានាឱ្យបានថា ក្រុមប្រឹក្សាឃុំ សង្កាត់ មិនមានអារម្មណ៍ថា ត្រូវគ្របសង្កត់ដោយក្រុមប្រឹក្សាស្រុក ?

**លំហាត់ទី ៣:** ការដោះស្រាយវិវាទ

លោក សំឡេន ឃួន នៅផ្ទះជាប់បងប្អូនជីដូនមួយរបស់គាត់ គឺលោក សំឡេន ទូច។ លោក ឃួន ចូលចិត្តស្តាប់ចំរៀងខារ៉ាអូខេនៅពេលល្ងាច ហើយគាត់មានទំលាប់ចាក់ចំរៀងខារ៉ាអូខេឮខ្លាំង។ បងប្អូនជីដូនមួយរបស់គាត់គឺលោក ទូច មិនពេញចិត្តនឹងសំលេងភ្លេងលាន់ឮខ្លាំងពីផ្ទះលោក ឃួន រៀងរាល់ល្ងាចឡើយ។ បងប្អូនជីដូនមួយទាំងពីរនាក់នេះ មានការមិនចុះសំរុងគ្នាជាច្រើនអំពីបញ្ហានេះ។ ជាចុងក្រោយ អ្នកទាំងពីរ ព្រមព្រៀងគ្នានឹងយកវិវាទនេះទៅក្រុមប្រឹក្សាស្រុក។

អ្នកជាក្រុមប្រឹក្សាស្រុក។

- តើអ្នកនឹងធ្វើដូចម្តេច ដើម្បីសំរុះសំរួលវិវាទរវាងលោកឃួន និង លោកទូច ដោយត្រឹមត្រូវ និង យុត្តិធម៌?
- តើវិធានការអ្វីខ្លះដែលអ្នកនឹងប្រកាន់យក ?
- តើត្រូវធ្វើយ៉ាងណាប្រសិនបើលោក ឃួន និង លោក ទូច មិនឯកភាពជាមួយអនុសាសន៍របស់អ្នកអំពីរបៀបដោះស្រាយវិវាទនេះ ?

**លំហាត់ទី ៤:** ដីកា

អ្នកជាក្រុមប្រឹក្សាខេត្ត។ នៅក្នុងខេត្តរបស់អ្នក មានឧប្បត្តិហេតុជាច្រើនទាក់ទងនឹងរឿងគោគ្មានអ្នកឃ្វៀល ដើរបំផ្លាញដំណាំគេ។ បញ្ហានេះ មានការកើនឡើង ហើយបង្កឱ្យមានអំពើអមិត្រនៅក្នុងសហគមន៍។

រៀបចំសេចក្តីព្រាងដីកា ដើម្បីដោះស្រាយបញ្ហានេះ (ពិនិត្យមើលមាត្រា ៥៣ ដល់ ៦១ នៃច្បាប់រៀបចំអង្គការ)

**លំហាត់ទី ៥:** ថវិការបស់ខណ្ឌ និង សង្កាត់

សង្កាត់ និង ខណ្ឌ ទទួលថវិការបស់ខ្លួនពីក្រុមប្រឹក្សារាជធានីភ្នំពេញ ឬ ក្រុមប្រឹក្សាក្រុង។

**ពិភាក្សាសំណួរខាងក្រោម:**

- តើអ្នកគិតថា នឹងមានផលវិបាកដូចម្តេចខ្លះសម្រាប់សង្កាត់ និង ខណ្ឌក្នុងការទទួលថវិការបស់ខ្លួនពីក្រុមប្រឹក្សារាជធានីភ្នំពេញ ឬ ក្រុមប្រឹក្សាក្រុង?
- តើខណ្ឌ និង សង្កាត់ អាចចរចារដូចម្តេច ដើម្បីទទួលបានថវិកាសមស្រប ?

# មេរៀនសម្រាប់ការយល់ដឹង និង ការបណ្តុះបណ្តាលអំពី ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

## មេរៀនទី ៦

## អភិបាល និងគណៈអភិបាល

## វគ្គទី ១៖

១.	តួនាទី និងមុខងាររបស់គណៈអភិបាល

២.	តួនាទី និងមុខងាររបស់អភិបាល

## ផ្នែកទី ១: តួនាទី និង មុខងាររបស់គណៈអភិបាល

**ច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ**

**មាត្រា ១៣៨ ដល់ ១៧២**

**គណៈអភិបាល មានតួនាទីបីប្រភេទគឺ តួនាទីផ្ដល់យោបល់ តួនាទីគ្រប់គ្រង និងតួនាទីរាយការណ៍**

### តួនាទីផ្ដល់យោបល់

- ✓ គណៈអភិបាល មានតួនាទីផ្ដល់សេចក្ដីអធិប្បាយ និងយោបល់ដល់ក្រុមប្រឹក្សាអំពីការអនុវត្តការងាររបស់ក្រុមប្រឹក្សា ដើម្បីក្រុមប្រឹក្សាពិចារណាពិភាក្សា និងអនុម័តអំពីជំរើសដែលល្អបំផុតក្នុងការអនុវត្តការងាររបស់ខ្លួន (មាត្រា ១៥៥ នៃច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ)។
- ✓ គណៈអភិបាល ត្រូវធ្វើ**ការសិក្សាស្រាវជ្រាវ ដើម្បីផ្ដល់យោបល់ប្រកបដោយគុណភាព និងផ្អែកលើភស្ដុតាង**ដល់ក្រុមប្រឹក្សាដែលអាចជួយក្រុមប្រឹក្សាឱ្យធ្វើសេចក្ដីសម្រេចដោយផ្អែកលើព័ត៌មាន (មាត្រា ២៩, ៨៦, ១៤៧ នៃអនុក្រឹត្យលេខ ២១៦ អ.ន.ក្រ.បក ស្ដីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក)។
  - **គណៈអភិបាលក្រុង** ត្រូវធ្វើការសិក្សាស្រាវជ្រាវទាក់ទងនឹងរបៀបដោះស្រាយសំណូមពរ និងបញ្ហាប្រឈមរបស់ក្រុមប្រឹក្សាសង្កាត់ និងទាក់ទងនឹងមុខងារដែលគួរធ្វើប្រតិភូកម្មទៅក្រុមប្រឹក្សាសង្កាត់ (មាត្រា ៨៦ នៃអនុក្រឹត្យលេខ ២១៦ អ.ន.ក្រ.បក ស្ដីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក)។
  - ដូចគ្នានេះដែរ **គណៈអភិបាលស្រុក** ត្រូវធ្វើការសិក្សាស្រាវជ្រាវ ទាក់ទងនឹងរបៀបសហប្រតិបត្តិការ និងគាំទ្រក្រុមប្រឹក្សាឃុំ សង្កាត់នៅក្នុងស្រុក និងទាក់ទងនឹងរបៀបដោះស្រាយសំណើ សំណូមពរ និងបញ្ហាប្រឈមរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ (មាត្រា ១៤៧ នៃអនុក្រឹត្យលេខ ២១៦ អ.ន.ក្រ.បក ស្ដីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក)។
  - គណៈអភិបាលផ្ដល់សេចក្ដីអធិប្បាយ និងមតិយោបល់អំពីយុទ្ធសាស្ត្រសម្រាប់ក្រុមប្រឹក្សាទទួលយក**មុខងារ និងធនធានថ្មី** (មាត្រា ១៦០ នៃច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ)។

- ✓ គណៈអភិបាល លើកសំណើអំពីយុទ្ធសាស្ត្រសម្រាប់ការពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋ ក្រុមប្រឹក្សាផ្សេងទៀត ក្រសួងពាក់ព័ន្ធ និងមន្ទីរអង្គភាពរបស់ក្រសួង ស្ថាប័ននៅថ្នាក់ក្រោមជាតិ និងអ្នកពាក់ព័ន្ធផ្សេងទៀតនៅក្នុងដែនដីរបស់ខ្លួន (មាត្រា ១៦៤ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ) ។
- ✓ គណៈអភិបាល ផ្តល់អនុសាសន៍ដល់ក្រុមប្រឹក្សាអំពីរចនាសម្ព័ន្ធបុគ្គលិក ប្រព័ន្ធ និង នីតិវិធី និង អំពីយុទ្ធសាស្ត្រអភិវឌ្ឍន៍សមត្ថភាពសម្រាប់បុគ្គលិករបស់ក្រុមប្រឹក្សា (មាត្រា ១៦២ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ) ។
- ✓ គណៈអភិបាល ផ្តល់អនុសាសន៍ដល់ក្រុមប្រឹក្សាអំពី**ការបង្កើតគណៈកម្មាធិការបន្ថែមទៀត** (មាត្រា១៦៨ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ) ។

**តួនាទីគ្រប់គ្រង**

- ✓ គណៈអភិបាល មានតួនាទី **គាំទ្រក្រុមប្រឹក្សានៅក្នុងការបំពេញមុខងារ** សិទ្ធិអំណាច និង ភារកិច្ចរបស់ខ្លួន (មាត្រា ១៥៥ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ) ។
- ✓ គណៈអភិបាល **អនុវត្តសេចក្តីសម្រេច និងដីការបស់ក្រុមប្រឹក្សា** និង ធានាឱ្យបានថា មន្ត្រី បុគ្គលិក និង អង្គភាពរបស់ក្រុមប្រឹក្សា អនុវត្តសេចក្តីសម្រេច ដីកា និង សកម្មភាពរបស់ក្រុមប្រឹក្សាយ៉ាងមានប្រសិទ្ធិភាព។ **ក្រុមប្រឹក្សាត្រូវពិនិត្យតាមដាន និងវាយតម្លៃ**ការងាររបស់គណៈអភិបាលនៅក្នុងការអនុវត្តតួនាទីនេះ ហើយត្រូវធានាឱ្យបានថា គណៈអភិបាល អនុវត្តទៅតាមការណែនាំរបស់ក្រុមប្រឹក្សា (មាត្រា ១៥៧, ១៦១ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មាត្រា ១៧, ៧៣, ១៣៥ នៃអនុក្រឹត្យលេខ ២១៦ អ.ន.ក្រ.បក ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក) ។
- ✓ ក្រុមប្រឹក្សា អាចស្នើសុំឱ្យគណៈអភិបាល ធ្វើការ**ពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋ** និង អ្នកផ្សេងទៀតក្នុងនាមក្រុមប្រឹក្សា (មាត្រា ១៦៤ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ) ។
- ✓ គណៈអភិបាល **ត្រូវពិគ្រោះយោបល់ជាមួយគណៈកម្មាធិការសម្របសម្រួលបច្ចេកទេស** ដើម្បីធានាឱ្យបានថា ផែនការ និង ថវិការបស់ក្រសួង ស្ថាប័ន មន្ទីរ និង អង្គភាពរបស់រាជរដ្ឋាភិបាល ត្រូវបានដាក់បញ្ចូលយ៉ាងល្អទៅក្នុងផែនការអភិវឌ្ឍន៍រយៈពេល ៥ ឆ្នាំ និង កម្មវិធីវិនិយោគ និង ថវិការយៈពេល ៣ ឆ្នាំរំកិលរបស់ក្រុមប្រឹក្សា (មាត្រា ១៦៦ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ) ។
- ✓ គណៈអភិបាលត្រូវធានាឱ្យបានថា **ព័ត៌មាន**អំពីសេចក្តីសម្រេច និងសកម្មភាពរបស់ក្រុមប្រឹក្សាត្រូវបាន**ផ្សព្វផ្សាយជូនសាធារណជន** (មាត្រា ១៦៩, ១៧០ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ) ។
- ✓ គណៈអភិបាលត្រូវ**រៀបចំសេចក្តីព្រាង** និង ដាក់ជូនទៅក្រុមប្រឹក្សាសម្រាប់ពិចារណានូវៈ

- **ផែនការអភិវឌ្ឍន៍**រយៈពេល ៥ ឆ្នាំ និង **ក្របខណ្ឌចំណាយ**រយៈពេលមធ្យមរបស់ក្រុមប្រឹក្សា
- **កម្មវិធីវិនិយោគ**៣ ឆ្នាំរំកិលរបស់ក្រុមប្រឹក្សា
- **របាយការណ៍ប្រចាំឆ្នាំរបស់ក្រុមប្រឹក្សា** ( មាត្រា ១៦៣ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ) ។

**គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ**

សមាជិកពីររូបរបស់គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និង កុមារ អាចចូលរួមនៅក្នុងកិច្ចប្រជុំរបស់គណៈអភិបាល ដើម្បីផ្តល់អនុសាសន៍ក្នុងការពិចារណាលើបញ្ហារបស់ស្ត្រី និង កុមារ ( មាត្រា ១២៩ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ប្រកាសស្តីពីគ.ក.ន.ក មាត្រា ១៤ នៃគំរូបទបញ្ជាផ្ទៃក្នុង) ។

✓ គណៈអភិបាល ត្រូវគាំទ្រក្រុមប្រឹក្សា និងបុគ្គលិករបស់ខ្លួន ដើម្បី **រាយការណ៍**អំពី**អំពើពុករលួយ ឬ ការរំលោភអំណាច**នៅក្នុងដែនដីរបស់ក្រុមប្រឹក្សា ( មាត្រា ១៦៧ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ) ។

✓ គណៈអភិបាល ត្រូវគាំទ្រក្រុមប្រឹក្សា ដើម្បី**ពិនិត្យ តាមដាន** មុខងារ ភារកិច្ច និងធនធានទាំងអស់ ( មាត្រា ១៥៦ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ) ។

## តួនាទីរាយការណ៍

✓ គណៈអភិបាល **ត្រូវរាយការណ៍ជាប្រចាំជូនក្រុមប្រឹក្សា**អំពីការអនុវត្តសេចក្តីសម្រេច និងសកម្មភាពរបស់ក្រុមប្រឹក្សាអំពីកិច្ចការហិរញ្ញវត្ថុ និងអំពីការងារផ្សេងទៀតរបស់ក្រុមប្រឹក្សា ( មាត្រា ១៥៥.១៥៩. ១៦០. ១៦៥. នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មាត្រា ១៧. ៧៣. ១៣៥ នៃអនុក្រឹត្យលេខ ២១៦ អ.ន.ក្រ.បក ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក មាត្រា ២៤ នៃប្រកាស ១២៤៩ ស្តីពីការប្រជុំចូលកាន់តំណែង ប្រការ៣១ នៃគំរូបទបញ្ជាផ្ទៃក្នុង) ។

✓ គណៈអភិបាល អាចចូលរួម និង**មានមតិនៅក្នុងកិច្ចប្រជុំរបស់ក្រុមប្រឹក្សា**។ ទោះជាយ៉ាងណាក៏ដោយ គណៈអភិបាល មិនមានសិទ្ធិបោះឆ្នោតអនុម័តលើកិច្ចការណាមួយក្នុងកិច្ចប្រជុំក្រុមប្រឹក្សាបានឡើយ ( មាត្រា ១៤៩នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ) ។

✓ គណៈអភិបាល អាចស្នើសុំឱ្យ**មានការដាក់បញ្ចូលទៅក្នុងរបៀបវារៈ**នៃកិច្ចប្រជុំរបស់ក្រុមប្រឹក្សា ( ប្រការ ៥. ៣០ នៃគំរូបទបញ្ជាផ្ទៃក្នុង ) ។

✓ ក្រុមប្រឹក្សា អាចអញ្ជើញគណៈអភិបាល ឬអភិបាលចូលរួមនៅក្នុងកិច្ចប្រជុំរបស់ក្រុមប្រឹក្សា ដើម្បី**បំភ្លឺបញ្ហា**។ នៅក្នុងកិច្ចប្រជុំ សមាជិកក្រុមប្រឹក្សា អាចសាកសួរអភិបាលលើការរីកចំរើននៃការអនុវត្តសេចក្តីសម្រេច និងដីការបស់ក្រុមប្រឹក្សា (មាត្រា ១៩៧ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ប្រការ២៤នៃគំរូបទបញ្ជាផ្ទៃក្នុង)។

**គំរូបទបញ្ជាផ្ទៃក្នុង**

គ.ជ.អ.ប បានដាក់ចេញគំរូបទបញ្ជាផ្ទៃក្នុងដែលក្រុមប្រឹក្សាអាចប្រើប្រាស់នៅពេលក្រុមប្រឹក្សាអភិវឌ្ឍ និងអនុម័តបទបញ្ជាផ្ទៃក្នុងរបស់ខ្លួនផ្ទាល់ ។ គំរូបទបញ្ជាផ្ទៃក្នុងចែង**លក្ខខណ្ឌអប្បបរមា**ដែលអាចត្រូវបន្ថែម និងអនុវត្តដោយក្រុមប្រឹក្សានីមួយៗ។

## គណនេយ្យភាពចំពោះក្រុមប្រឹក្សា

✓ ក្រុមប្រឹក្សាគឺជា**អង្គការធ្វើសេចក្តីសម្រេច**នៅក្នុងដែនដីរបស់ខ្លួន។ គណៈអភិបាលមានតួនាទីជួយ និងគាំទ្រក្រុមប្រឹក្សា និងអនុវត្តសេចក្តីសម្រេចនិងដីការបស់ក្រុមប្រឹក្សា។ ដូច្នេះ នៅក្នុងតួនាទីនេះ**គណៈអភិបាលមានគណនេយ្យភាពចំពោះក្រុមប្រឹក្សា** (ប្រការ៧នៃប្រកាស១២៤៩ ស្តីពីការប្រជុំចូលកាន់តំណែង)។ គណៈអភិបាល មាន**គណនេយ្យភាពចំពោះរាជរដ្ឋាភិបាល** លើការអនុវត្តតួនាទីនេះអនុលោមទៅតាមរដ្ឋធម្មនុញ្ញ ច្បាប់ និងលិខិតបទដ្ឋានជាធរមានផ្សេងទៀត (មាត្រា ២៧, ៨៤, ១៤៥ នៃអនុក្រឹត្យលេខ ២១៦ អ.ន.ក្រ.បក ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក)។

✓ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មានបញ្ចូល**យន្តការមួយចំនួន** ដើម្បីជួយក្រុមប្រឹក្សា ធ្វើឱ្យ**គណៈអភិបាលរបស់ខ្លួនមានគណនេយ្យភាព**៖

**គណនេយ្យភាព**

ទាំងសមាជិកក្រុមប្រឹក្សាដែលជាប់ឆ្នោត និងគណៈអភិបាល អាចត្រូវសាកសួរអំពី គោលនយោបាយសេចក្តីសម្រេចសកម្មភាព និងការប្រើប្រាស់ធនធានសាធារណៈរបស់ខ្លួន ។

នៅពេលនិយាយថាគណៈអភិបាល មាន គណនេយ្យភាពចំពោះក្រុមប្រឹក្សាប្រការនេះមានន័យថា ក្រុមប្រឹក្សាមានសិទ្ធិអំណាចលើគណៈអភិបាល រួមមាន

- សិទ្ធិពិនិត្យតាមដាន និងវាយតម្លៃការងាររបស់គណៈអភិបាល
- សិទ្ធិទាមទារព័ត៌មានពីគណៈអភិបាល
- សិទ្ធិធានា និងវាយតម្លៃថាតើគណៈអភិបាល បានអនុវត្តទៅតាមសេចក្តី សម្រេចនិងការណែនាំរបស់ក្រុមប្រឹក្សាឬទេ
- សិទ្ធិធ្វើអសុពលភាពលើសេចក្តីសម្រេច ឬ សកម្មភាពរបស់គណៈអភិបាល ក្នុងករណីដែលសេចក្តីសម្រេចឬសកម្មភាពមិនស្របទៅតាម សេចក្តីសម្រេច ឬ ការណែនាំរបស់ ក្រុមប្រឹក្សា
- សិទ្ធិស្វែងរកការបញ្ឈប់ការងាររបស់អភិបាល ឬនិងអភិបាលរង ឬនិង គណៈអភិបាល។

- ក្រុមប្រឹក្សា មានភារកិច្ចតាមផ្លូវច្បាប់ក្នុងការ **ពិនិត្យតាមដានសកម្មភាព** និង **ការងារ**របស់ អភិបាល និង គណៈអភិបាល ( មាត្រា ១៥៧ នៃ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ) ។
- ក្រុមប្រឹក្សា មានសិទ្ធិអញ្ជើញអភិបាល ឬ គណៈអភិបាលឱ្យ**បំភ្លឺបញ្ហានានានៅក្នុងកិច្ចប្រជុំរបស់ក្រុមប្រឹក្សា** ( មាត្រា ១៥៧ នៃច្បាប់ស្តីពីការ គ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ប្រការ ២៤ នៃគំរូបទបញ្ជាផ្ទៃក្នុង) ។
- អភិបាល និង គណៈអភិបាល អាចធ្វើសេចក្តីសម្រេច ឬ អនុវត្តសកម្មភាព ដរាបណា **សេចក្តីសម្រេច** ឬ **សកម្មភាពនេះ** ត្រូវបាន**អនុញ្ញាតដោយក្រុមប្រឹក្សា** ។ សេចក្តីសម្រេច ឬ សកម្មភាពដែលមិនត្រូវបាន អនុញ្ញាតដោយក្រុមប្រឹក្សា មិនមានសុពលភាពឡើយ ( មាត្រា ១៥៨ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ) ។
- ក្រុមប្រឹក្សា អាចស្នើសុំទៅក្រសួងមហាផ្ទៃឱ្យ**បញ្ឈប់ការងារអភិបាល ឬ អភិបាលរង** ដោយផ្អែកលើមូល ហេតុជាក់លាក់ ។ ក្រសួងមហាផ្ទៃ ត្រូវធ្វើការអង្កេតជាបន្ទាន់ ( មាត្រា ១៥២ នៃច្បាប់ស្តីពីការគ្រប់គ្រង រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ) ។

### នីតិវិធីបំពេញការងាររបស់គណៈអភិបាល

✓ គណៈអភិបាល **ត្រូវជួបប្រជុំយ៉ាងតិចពីរដងជារៀងរាល់ខែ**។ កំណត់ហេតុ ត្រូវធ្វើឡើងនៅគ្រប់កិច្ចប្រជុំរបស់ ក្រុមប្រឹក្សា។ **សាធារណជន គួរទទួលបានព័ត៌មានអំពីកំណត់ហេតុទាំងនេះ** ( មាត្រា ៣១, ៨៨, ១៤៩ នៃ អនុក្រឹត្យលេខ ២១៦ អ.ន.ក្រ.បក ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈ អភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក មាត្រា ៥១ នៃច្បាប់ស្តីពី ការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ) ។

✓ គណៈអភិបាល **ត្រូវបែងចែកភារកិច្ចនៅក្នុងចំណោមអភិបាល និងអភិបាលរង** ហើយបន្ទាប់មកស្នើសុំឱ្យក្រុម ប្រឹក្សា ពិនិត្យ និងអនុម័តការបែងចែក។ ក្រសួងមហាផ្ទៃ នឹងដាក់ចេញគោលការណ៍ណែនាំស្តីពីការបែងចែក ភារកិច្ចនៅក្នុងចំណោមអភិបាល និងអភិបាលរង ( មាត្រា ៣៣, ៩០, ១៥១ នៃអនុក្រឹត្យលេខ ២១៦ អ.ន.ក្រ.បក ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក ) ។

**ទំនាក់ទំនងរបស់គណៈអភិបាលជាមួយរដ្ឋបាល**

✓ សាលារាជធានី សាលាខេត្ត សាលាស្រុក សាលាក្រុង សាលាខណ្ឌ គឺជា**កន្លែងបំពេញការងាររបស់ក្រុមប្រឹក្សា និងគណៈអភិបាល**។ សាលារាជធានី សាលាខេត្ត សាលាស្រុក សាលាក្រុង សាលាខណ្ឌ ត្រូវបើកទ្វារនៅក្នុងអំឡុងពេលនៃ**ម៉ោងធ្វើការជាផ្លូវការ** ។ នៅក្នុងអំឡុងពេលនៃម៉ោងធ្វើការនេះ ប្រជាពលរដ្ឋគ្រប់រូបមានសិទ្ធិ

- ទំនាក់ទំនង និងធ្វើការជាមួយក្រុមប្រឹក្សា និងគណៈអភិបាល
- ទទួលព័ត៌មានពីរដ្ឋបាលខេត្តអំពីសំណូមពរ ឬកិច្ចការផ្សេងទៀត
- ផ្តល់មតិយោបល់ ឬសំណូមពរលើកិច្ចការណាមួយ ។

( ប្រការ ១, ១៦, ២៥ នៃប្រកាស ១២៤៩ ស្តីពីការប្រជុំចូលកាន់តំណែង )

✓ អង្គភាពរបស់រដ្ឋបាលនៅថ្នាក់ក្រោមជាតិទាំងអស់ ស្ថិតនៅក្រោមការទទួលខុសត្រូវ ការត្រួតពិនិត្យ និងការគ្រប់គ្រងផ្ទាល់របស់ប្រធានអង្គភាព។ **ប្រធានអង្គភាពនីមួយៗ** មានការទទួលខុសត្រូវ និងមានគណនេយ្យភាពចំពោះនាយករដ្ឋបាល។ **នាយករដ្ឋបាល** មានការទទួលខុសត្រូវ និង**មានគណនេយ្យភាពចំពោះគណៈអភិបាល និងក្រុមប្រឹក្សា** ( ប្រការ ១០, ២១, ៣០ នៃប្រកាស ១២៤៩ ស្តីពីការប្រជុំចូលកាន់ តំណែង ) ។

✓ គណៈអភិបាល ដឹកនាំ និងណែនាំនាយករដ្ឋបាលនៅក្នុងការ**ប្រគល់ភារកិច្ចដល់អង្គភាព**របស់រដ្ឋបាល ( ប្រការ ១៣, ២៣, ៣២ នៃប្រកាស ១២៤៩ ស្តីពីការប្រជុំចូលកាន់ តំណែង ) ។

✓ អង្គភាពរបស់រដ្ឋបាលខេត្ត ក្រុង និងស្រុក មានការទទួលខុសត្រូវក្នុងការជួយគណៈអភិបាលនៅក្នុងការអនុវត្តការទទួលខុសត្រូវរបស់ខ្លួន។ ឧទាហរណ៍ **ទីចាត់ការផែនការ និងវិនិយោគ**ផ្តល់អនុសាសន៍ជូនអភិបាលអំពីនីត្យានុកូលភាពនៃផែនការអភិវឌ្ឍរបស់ក្រុង ស្រុក ឃុំ សង្កាត់ ( ប្រការ ៤ នៃប្រកាស ១២៤៩ ស្តីពីការប្រជុំចូលកាន់តំណែង ) ។

✓ គណៈអភិបាល ដឹកនាំ និងណែនាំនាយករដ្ឋបាលនៅក្នុងការរៀបចំ**កម្មវិធីបណ្តុះបណ្តាល និងអភិវឌ្ឍសមត្ថភាព**សម្រាប់បុគ្គលិកក្រុមប្រឹក្សាខេត្ត ដោយមានជំនួយពីការិយាល័យគ្រប់គ្រងបុគ្គលិក ( ប្រការ ១៥ នៃប្រកាសលេខ ៤២៧៤ ប្រក. ស្តីពី ការបង្កើតការិយាល័យចំណុះទីចាត់ការនៃសាលាខេត្ត ការបង្កើតការិយាល័យនៃសាលាក្រុង ការបង្កើតការិយាល័យនៃសាលាស្រុក និងការកំណត់តួនាទីភារកិច្ច របៀបរបបការងារនៃការិយាល័យទាំងនោះ) ។

| ក្រុមប្រឹក្សា | គណៈអភិបាល |
|---|---|
| • បោះឆ្នោតដោយសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ | • តែងតាំងដោយរាជរដ្ឋាភិបាល |
| • មានអាណត្តិ ៥ ឆ្នាំ | • មានអាណត្តិ ៤ ឆ្នាំ |
| • ធ្វើសេចក្តីសម្រេចសម្រាប់ដែនដីរបស់ខ្លួន | • អនុវត្តសេចក្តីសម្រេចរបស់ក្រុមប្រឹក្សា |
| • មានគណនេយ្យភាពចំពោះប្រជាពលរដ្ឋ និង រាជរដ្ឋាភិបាល | • មានគណនេយ្យភាពចំពោះក្រុមប្រឹក្សា |
| • ពិនិត្យមើលការងារគណៈអភិបាល | • រាយការណ៍ជូនក្រុមប្រឹក្សាជាប្រចាំ |
| • អនុម័តផែនការអភិវឌ្ឍ និង ថវិកា | • រៀបចំសេចក្តីព្រាងផែនការអភិវឌ្ឍ និង ថវិកាដើម្បីដាក់ជូនក្រុមប្រឹក្សាពិនិត្យពិភាក្សា និងអនុម័ត |
| • អាចស្នើសុំបញ្ឈប់ការងារអភិបាល អភិបាលរង | |

## ផ្នែកទី ២: តួនាទី និងមុខងាររបស់អភិបាល

**ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ**
**មាត្រា ១២៣ ដល់ ១២៦, ១៣៨ ដល់ ១៧២**

### តួនាទីបីយ៉ាងរបស់អភិបាល

✓ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ប្រគល់តួនាទីបីយ៉ាងដល់អភិបាល ។

១. ទីមួយ អភិបាល គឺជា**ប្រធានគណៈអភិបាល**។ ក្នុងតួនាទីនេះ អភិបាល បំរើ និងមានគណនេយ្យភាពចំពោះក្រុមប្រឹក្សា ។ តួនាទីរបស់គណៈអភិបាល ត្រូវបានពិភាក្សានៅក្នុងផ្នែកមុន (មាត្រា ១៣៩ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ប្រការ ៧ នៃប្រកាស ១២៤៩ ស្តីពីការប្រជុំចូលកាន់តំណែង) ។

២. ទីពីរ អភិបាល តំណាងឱ្យក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាលដើម្បី**ត្រួតពិនិត្យ សម្របសម្រួល និង ដឹកនាំមន្ទីរ និង អង្គភាពខ្សែបណ្តោយទាំងអស់** ដែលដំណើរការនៅក្នុងដែនដីរបស់ក្រុមប្រឹក្សា ។ ដូច្នេះ នៅក្នុងតួនាទីនេះ អភិបាលបំរើ និងមានគណនេយ្យភាពចំពោះរាជរដ្ឋាភិបាល និង ចំពោះក្រសួង ស្ថាប័នដែលពាក់ព័ន្ធរបស់រាជរដ្ឋាភិបាល ។ នៅក្នុងតួនាទីនេះ អភិបាលមានលទ្ធភាពធ្វើជាខ្សែទំនាក់ទំនងរវាងក្រុមប្រឹក្សាជាមួយក្រសួងខ្សែបណ្តោយនៅថ្នាក់ជាតិ (មាត្រា ១៥៤ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មាត្រា ៣៥, ៩២, ១៥៣ នៃអនុក្រឹត្យលេខ ២១៦) ។ ទោះយ៉ាងណាអភិបាលត្រូវ រាយការណ៍ជូនក្រុមប្រឹក្សាអំពីតួនាទីនេះ ។

៣. ទីបី អភិបាលតំណាងឱ្យរាជរដ្ឋាភិបាល ក្រសួង និងស្ថាប័នរបស់រាជរដ្ឋាភិបាលលើការងារទាក់ទងនឹង**សន្តិសុខ សណ្តាប់ធ្នាប់សង្គម និង សណ្តាប់ធ្នាប់សាធារណៈ ច្បាប់ និង សិទ្ធិមនុស្ស**នៅក្នុងដែនដី។ អភិបាលគឺជាប្រធានគណៈបញ្ជាការឯកភាពនៅក្នុងដែនដីរបស់ខ្លួន។ នៅក្នុងតួនាទីនេះ អភិបាល បំរើ និងមានគណនេយ្យភាពចំពោះរាជរដ្ឋាភិបាល និង ក្រសួងមហាផ្ទៃ (មាត្រា ១៥៤ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មាត្រា ៣៦, ៩៣, ១៥៤ នៃអនុក្រឹត្យលេខ ២១៦ អ.ន.ក្រ.បក ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក ) ។ ទោះបីយ៉ាងណាត្រូវ រាយការណ៍អោយក្រុមប្រឹក្សា។

### មួកទាំងបីរបស់អភិបាល




**មួកទីមួយរបស់អភិបាលៈ ប្រធានគណៈអភិបាល**

តួនាទីនេះ ត្រូវបានពិភាក្សានៅក្នុងផ្នែកមុននៃមេរៀននេះ ។

**មួកទីពីររបស់អភិបាលៈ តំណាងរបស់រាជរដ្ឋាភិបាលទាក់ទងនឹងអង្គភាពខ្សែបណ្តោយ**

នៅក្នុងសមត្ថភាពរបស់ខ្លួនជា**តំណាងរបស់រាជរដ្ឋាភិបាល និងក្រសួង ស្ថាប័ននានា** ក្នុងការត្រួតពិនិត្យ សម្របសម្រួល និង ដឹកនាំមន្ទីរ ឬការិយាល័យខ្សែបណ្តោយ អភិបាលមានភារកិច្ចខាងក្រោមដើម្បី :

- **សម្របសម្រួល និងដឹកនាំ** មន្ទីរ ឬការិយាល័យខ្សែបណ្តោយនៅក្នុងដែនដីក្នុងការឆ្លើយតបទៅនឹង**តម្រូវការជាអាទិភាពនៅមូលដ្ឋាន**
- តាមរយៈគណៈកម្មាធិការសម្របសម្រួលបច្ចេកទេស ក្រុមប្រឹក្សា និងអភិបាល ត្រូវសម្របសម្រួល និង ដឹកនាំមន្ទីរ ឬការិយាល័យខ្សែបណ្តោយនៅក្នុងដែនដី **ដើម្បីធ្វើសមាហរណកម្មផែនការ និងថវិការបស់ខ្លួន ទៅក្នុងផែនការ និងថវិការបស់ក្រុមប្រឹក្សា**
- **ដឹកនាំ**មន្ទីរ ឬការិយាល័យខ្សែបណ្តោយនៅក្នុងដែនដី ដើម្បីអនុវត្តតួនាទីរបស់ខ្លួន អនុលោមទៅតាមច្បាប់ គោលនយោបាយជាតិ និងលិខិតបទដ្ឋានជាធរមាន ។
- **ពិនិត្យតាមដាន** និងវាយតំលៃប្រធានមន្ទីរ ឬ ការិយាល័យខ្សែបណ្តោយ

> តើលោក អ្នកគិតថា មន្ទីរ/ការិយាល័យ មានឆន្ទានុសិទ្ធិគ្រប់គ្រាន់ដើម្បីមានលទ្ធភាព ឆ្លើយតបនឹងតម្រូវការនៅមូលដ្ឋានឬទេ?

- ពិគ្រោះយោបល់ជាមួយក្រុមប្រឹក្សា ហើយបន្ទាប់មកលើកសំណើសុំ**តែងតាំងប្រធាន**មន្ទីរ ឬការិយាល័យខ្សែបណ្ដោយ
- អភិបាលខេត្ត ត្រូវណែនាំប្រធានមន្ទីរខ្សែបណ្ដោយឱ្យ**កែតម្រូវភាពមិនប្រក្រតី** ឬអំពើខុសឆ្គងដែលបានរកឃើញ។ ប្រសិនបើមិនមានការកែតម្រូវ ហើយភាពមិនប្រក្រតី ឬអំពើខុសឆ្គងមានសភាពធ្ងន់ធ្ងរ អភិបាលត្រូវរាយការណ៍បញ្ហានេះជូនទៅក្រសួងពាក់ព័ន្ធផ្ទាល់
  - ○ អភិបាលក្រុង ឬ ស្រុក ត្រូវរាយការណ៍អំពីភាពមិនប្រក្រតី ឬអំពើខុសឆ្គងជូនអភិបាលខេត្តរបស់ខ្លួន។ អភិបាលខេត្ត ត្រូវណែនាំប្រធានការិយាល័យខ្សែបណ្ដោយឱ្យកែតម្រូវភាពមិនប្រក្រតី ឬអំពើខុសឆ្គងដែលបានរកឃើញ។ ប្រសិនបើមិនមានការកែតម្រូវ ហើយភាពមិនប្រក្រតី ឬអំពើខុសឆ្គង មានសភាពធ្ងន់ធ្ងរ អភិបាលខេត្ត ត្រូវរាយការណ៍បញ្ហានេះជូនទៅក្រសួងពាក់ព័ន្ធ។
- អភិបាលខេត្ត អាចស្នើសុំជាលាយល័ក្ខអក្សរទៅក្រសួង ដើម្បីដកហូតពីមុខតំណែងនូវប្រធានមន្ទីរ ការិយាល័យ អង្គភាពនានា ឬអ្នកទទួលខុសត្រូវពីភ្នាក់ងារណាមួយ ដែលប្រព្រឹត្តខុសឆ្គង ។
  - ○ អភិបាលក្រុង ឬស្រុក ត្រូវស្នើសុំទៅអភិបាលខេត្ត ដើម្បីដាក់សំណើបែបនេះទៅក្រសួងពាក់ព័ន្ធ ទាក់ទងនឹងប្រធានការិយាល័យ
- ទទួល និងផ្ដល់មតិជាមុន ហើយចុះហត្ថលេខា**លើរបាយការណ៍**របស់មន្ទីរ ឬការិយាល័យខ្សែបណ្ដោយផ្ញើជូនក្រសួងរបស់ខ្លួន។

(មាត្រា ៣៥, ៩២, ១៩៣ នៃអនុក្រឹត្យលេខ ២១៦ អ.ន.ក្រ.បក ស្ដីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក)។

✓ **អភិបាលត្រូវរាយការណ៍ជាប្រចាំជូនទៅក្រុមប្រឹក្សា**អំពីសកម្មភាព និងលទ្ធផលរបស់អភិបាលនៅក្នុងការអនុវត្តការងាររបស់ខ្លួនជាតំណាងរបស់រាជរដ្ឋាភិបាល។ ក្រុមប្រឹក្សា អាចស្នើសុំឱ្យអភិបាលរាយការណ៍នៅក្នុងកិច្ចប្រជុំរបស់ក្រុមប្រឹក្សា ក្នុងករណីដែលមានបញ្ហាទាក់ទងនឹងការងាររបស់អភិបាល ក្នុងនាមជាតំណាងរបស់រាជរដ្ឋាភិបាលដែល **មានផលប៉ះពាល់មកលើផលប្រយោជន៍ស្របច្បាប់របស់ប្រជាពលរដ្ឋ ឬប្រជាពលរដ្ឋបានដាក់ពាក្យបណ្ដឹង** (មាត្រា ៣៩, ៩៦, ១៩៧ នៃអនុក្រឹត្យលេខ ២១៦ អ.ន.ក្រ.បក ស្ដីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងារ របស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក)។

✓ អភិបាលក៏ជា**ប្រធានគណៈកម្មាធិការសម្របសម្រួលបច្ចេកទេស**របស់ក្រុមប្រឹក្សាផងដែរ។ គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស គឺជាអ្នកទំនាក់ទំនង

| |
|---|
| ចំពោះព័ត៌មានបន្ថែមអំពីគណៈកម្មាធិការសំរបសំរួលបច្ចេកទេស សូមអានមេរៀនទី ៧ ។ |

យ៉ាងសំខាន់របស់ក្រុមប្រឹក្សាជាមួយក្រសួង ស្ថាប័ន មន្ទីរ និង អង្គភាពរបស់រាជរដ្ឋាភិបាលដែលកំពុងដំណើរការនៅក្នុងដែនដីរបស់ក្រុមប្រឹក្សា ។ គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស គឺជាវេទិកាយ៉ាងសំខាន់សម្រាប់ក្រុមប្រឹក្សា និងអង្គភាពខ្សែបណ្ដោយ**សម្របសម្រួលការងាររបស់ខ្លួន**។ ជាប្រធាន អភិបាល អាចប្រើប្រាស់មួកទីពីររបស់គាត់ដើម្បីសម្របសម្រួល និង ដឹកនាំមន្ទីរ និង អង្គភាពខ្សែបណ្ដោយដែលជាសមាជិករបស់គណៈកម្មាធិការសម្រប សម្រួលបច្ចេកទេស ។

- ✓ នៅក្នុងតួនាទីនេះ អភិបាល មានគណនេយ្យភាពចំពោះរាជរដ្ឋាភិបាល និងក្រសួង ( មាត្រា ៣៨, ៩៥, ១៥៦ នៃអនុក្រឹត្យលេខ ២១៦ អ.ន.ក្រ.បក ស្ដីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក ) ។

**មួកទីបីរបស់អភិបាលៈ តំណាងរបស់រាជរដ្ឋាភិបាលលើការងារសន្តិសុខ និងសណ្ដាប់ធ្នាប់សាធារណៈ**

- ✓ នៅក្នុងសមត្ថភាពរបស់គាត់ជាតំណាងលើ**ការងារសន្តិសុខ សណ្ដាប់ធ្នាប់សាធារណៈ ច្បាប់ និងសិទ្ធិមនុស្ស** អភិបាលជំរុញការយល់ដឹងអំពីច្បាប់ ធានាឱ្យបានថា ច្បាប់ត្រូវបានអនុវត្ត និងថា សិទ្ធិមនុស្សត្រូវបានគោរព ( មាត្រា ៣៦, ៩៣, ១៥៤ នៃអនុក្រឹត្យលេខ ២១៦ អ.ន.ក្រ.បក ស្ដីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក ) ។
- ✓ អភិបាល គឺជា**ប្រធានគណៈបញ្ជាការឯកភាព**នៅក្នុងដែនដីរបស់គាត់។ នៅក្នុងសមត្ថភាពនេះ អភិបាលដឹកនាំ និងសម្របសម្រួលអង្គភាពខ្សែបណ្ដោយ និងរដ្ឋបាលដែលពាក់ព័ន្ធឱ្យរក្សាសន្តិសុខ និងសណ្ដាប់ធ្នាប់ ( មាត្រា ៣៦, ៩៣, ១៥៤ នៃអនុក្រឹត្យលេខ ២១៦ អ.ន.ក្រ.បក ស្ដីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក ) ។
- ✓ ច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ចែងថា បុគ្គលិករបស់ក្រុមប្រឹក្សា **មិនរាប់បញ្ចូល** មន្ត្រីរបស់ក្រសួង ស្ថាប័ន មន្ទីរ និងអង្គភាពរបស់រាជរដ្ឋាភិបាលដែលបំពេញភារកិច្ចទាក់ទងនឹងសន្តិសុខ សណ្ដាប់ធ្នាប់សាធារណៈ និងសណ្ដាប់ធ្នាប់សង្គម ច្បាប់ និងសិទ្ធិមនុស្សក្នុងនាមរាជរដ្ឋាភិបាល ( មាត្រា ១៥៧ នៃច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ) ។
- ✓ ទោះជាយ៉ាងណាក៏ដោយ ប្រកាសស្ដីពីការបង្កើតការិយាល័យចំណុះទីចាត់ការសាលាខេត្ត ការិយាល័យសាលាក្រុង និងការិយាល័យសាលាស្រុកបានចែងថា ផ្នែកអន្តរវិស័យរបស់រដ្ឋបាលខេត្ត គាំទ្រអភិបាលក្នុងឋានៈជាតំណាងរបស់រាជរដ្ឋាភិបាលលើការងារសន្តិសុខ និងសណ្ដាប់ធ្នាប់ ច្បាប់ និងសិទ្ធិមនុស្ស។ ផ្នែកអន្តរវិស័យ ចូលរួមនៅក្នុងកិច្ចប្រជុំរបស់គណៈបញ្ជាការឯកភាព ហើយត្រូវពិនិត្យតាមដានការអនុវត្តសេចក្ដីសម្រេចដែលបានធ្វើឡើងនៅក្នុងកិច្ចប្រជុំ (ប្រកាសស្ដីពីការបង្កើតការិយាល័យចំណុះទីចាត់ការសាលាខេត្ត ការិយាល័យសាលាក្រុង និងការិយាល័យសាលាស្រុក) ។

✓ នៅក្នុងតួនាទីនេះ អភិបាល មានគណនេយ្យភាពចំពោះរាជរដ្ឋាភិបាល ( មាត្រា ៣៨, ៩៥, ១៥៦ នៃអនុក្រឹត្យលេខ ២១៦ អ.ន.ក្រ.បក ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក ) ។

## អភិបាលរង

✓ អភិបាល អាចបែងចែកភារកិច្ចរបស់គាត់នៅក្នុងចំណោមអភិបាលរង ដើម្បីឱ្យអភិបាលរង អាចជួយអភិបាល។ ប្រការនេះ មានន័យថា អភិបាលរង ដូចគ្នានឹងអភិបាលដែរ អាចពាក់មួកច្រើនជាងមួយ( មាត្រា ៣៧, ៩៤, ១៥៥ នៃអនុក្រឹត្យលេខ ២១៦ ) ។

### រចនាសម្ព័ន្ធរបស់ក្រុមប្រឹក្សាថ្មី



**បញ្ហាដែលត្រូវដោះស្រាយ**

អភិបាល គឺជាតួអង្គយ៉ាងសំខាន់នៅក្នុងរដ្ឋបាលឯកភាព ។ រំលឹកឡើងវិញថា រដ្ឋបាលឯកភាពមានគោលបំណងសម្រេចឱ្យបាននូវការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ ។ ដូច្នេះ តួនាទី និង សិទ្ធិអំណាចរបស់អភិបាល ត្រូវគាំទ្រដល់សមាសភាគនានានៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ ដូចជា តម្លាភាព និង គណនេយ្យភាពចំពោះប្រជាពលរដ្ឋ និង ការកែលំអគុណភាពនៃជីវភាពរស់នៅ របស់ប្រជាពលរដ្ឋ ។

ជាតំណាងរបស់ក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាលកម្ពុជា អភិបាលមានគណនេយ្យភាពចំពោះរាជរដ្ឋាភិបាល ។ គណនេយ្យភាពនេះ អាចជួបការលំបាកនៅក្នុងករណីដែលក្រសួងពីរ ឬ មន្ទីរខ្សែបណ្ដោយរបស់ក្រសួងទាំងពីរ មានផលប្រយោជន៍ដែលមានលក្ខណៈប្រកួតប្រជែងគ្នានៅក្នុងខេត្ត (ឧទាហរណ៍ ដីមួយកន្លែងត្រូវបានស្នើសុំដោយមន្ទីរសុខាភិបាល ដើម្បីសង់មន្ទីរពេទ្យ និងដោយមន្ទីរអប់រំដើម្បីសង់សាលារៀន) ។ គ.ជ.អ.ប ដែលមានតួនាទី ធានាឱ្យមានសមាហរណកម្មសកម្មភាពរបស់ក្រសួងនៅថ្នាក់ក្រោមជាតិ អាចមានតួនាទីដែលត្រូវប្រកាន់យកនៅក្នុងករណីបែបនេះ ។

បញ្ហាប្រឈមធំបំផុត ប្រហែលជាការបង្កើតឆន្ទានុសិទ្ធិ និងភាពបត់បែននៅក្នុងអង្គភាពខ្សែបណ្ដោយដើម្បីផ្ដល់លទ្ធភាពឱ្យអង្គភាពទាំងនេះ ឆ្លើយតបនឹងសំណើពីក្រោមឡើងលើរបស់ប្រជាពលរដ្ឋដែលក្រុមប្រឹក្សាលើកឡើងក្នុងនាមប្រជាពលរដ្ឋទាំងនោះ។ បញ្ហាចោទស្ថិតនៅត្រង់ថាតើ ក្រសួងនឹងផ្ដល់ដល់អង្គភាពខ្សែបណ្ដោយរបស់ខ្លួននូវវិសាលភាព ដើម្បីឆ្លើយតបនឹងការណែនាំរបស់អភិបាល និងតម្រូវការនៅមូលដ្ឋានដែរឬទេ។ បញ្ហាចោទក៏ស្ថិតនៅផងដែរថាតើ អង្គភាពខ្សែបណ្ដោយ នឹងមានឆន្ទានុសិទ្ធិ និងភាពបត់បែនគ្រប់គ្រាន់ ដើម្បីសម្របសម្រួលសកម្មភាពរបស់ខ្លួនជាមួយសកម្មភាពរបស់ក្រុមប្រឹក្សា និងសកម្មភាពរបស់អង្គភាពខ្សែបណ្ដោយផ្សេងទៀត។

## វគ្គទី ២:

## មេរៀនសង្ខេប

- រាជធានីភ្នំពេញ និងខេត្ត ក្រុង ស្រុក និងខណ្ឌ នីងមានគណៈអភិបាល ។ គណៈអភិបាលមានអភិបាលមួយរូប និងអភិបាលរងមួយចំនួន ។
- គណៈអភិបាល មានតួនាទីសំខាន់បីយ៉ាង:
  - តួនាទីផ្តល់យោបល់: ផ្តល់សេចក្តីអធិប្បាយ និងយោបល់ដល់ក្រុមប្រឹក្សា
  - តួនាទីគ្រប់គ្រង ដែលរួមមានការគាំទ្រក្រុមប្រឹក្សានៅក្នុងការអនុវត្តសិទ្ធិអំណាច មុខងារ និងភារកិច្ច និងធានាថាសេចក្តីសម្រេចរបស់ក្រុមប្រឹក្សា ត្រូវបានអនុវត្ត។
  - តួនាទីរាយការណ៍ ដើម្បីឱ្យក្រុមប្រឹក្សាដឹងបានពេញលេញអំពីការងាររបស់ក្រុមប្រឹក្សា ។
- ក្រុមប្រឹក្សា គឺជាអង្គការធ្វើសេចក្តីសម្រេចនៅក្នុងដែនដីរបស់ខ្លួន ។ គណៈអភិបាលមានតួនាទីជួយ និងគាំទ្រក្រុមប្រឹក្សា និងអនុវត្តសេចក្តីសម្រេចរបស់ក្រុមប្រឹក្សា ។ ដូច្នេះគណៈអភិបាលមានគណនេយ្យភាពចំពោះក្រុមប្រឹក្សា ។
- ប្រធានអង្គភាពនីមួយៗរបស់រដ្ឋបាលមានការទទួលខុសត្រូវ និងមានគណនេយ្យភាពចំពោះនាយករដ្ឋបាល ។ នាយករដ្ឋបាលមានការទទួលខុសត្រូវ និងមានគណនេយ្យភាពចំពោះគណៈអភិបាល និងក្រុមប្រឹក្សា។
- អភិបាលមានតួនាទីចំនួនបីគឺ :
  - ជាប្រធានគណៈអភិបាល
  - ជាតំណាងរបស់ក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាល ដោយមានការទទួលខុសត្រូវក្នុងការត្រួតពិនិត្យ សម្របសម្រួល និងដឹកនាំមន្ទីរ និងអង្គភាពខ្សែបណ្តោយទាំងអស់ដែលដំណើរការនៅក្នុងដែនដីរបស់ក្រុមប្រឹក្សា
  - ជាតំណាងរបស់ក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាលលើការងារទាក់ទងនឹងសន្តិសុខ សណ្តាប់ធ្នាប់សង្គម និងសណ្តាប់ធ្នាប់សាធារណៈ ច្បាប់ និងសិទ្ធិមនុស្សនៅក្នុងដែនដីរបស់ខ្លួន ។
- ការមានតួនាទីទាំងបីនេះ អភិបាលអាចធ្វើជាអ្នកទំនាក់ទំនងយ៉ាងសំខាន់រវាងក្រុមប្រឹក្សា និងក្រសួងខ្សែបណ្តោយនៅថ្នាក់ជាតិ ។

# វគ្គទី ៣:

# ការងារជាក្រុម

ការងារជាក្រុមដូចមានពិពណ៌នាខាងក្រោមអាចមានលក្ខណៈមិនសមស្របសម្រាប់ការបណ្តុះបណ្តាលទាំងអស់ ។ សូមចាត់ទុកការងារជាក្រុមខាងក្រោមជាសំណូមពរតែប៉ុណ្ណោះ ។

១. ចែកសិក្ខាកាមជាក្រុមដែលមានសមាជិកមិនលើសពី៨នាក់ ។

**លំហាត់ទី ១: ទំនាក់ទំនងរវាងក្រុមប្រឹក្សាជាមួយគណៈអភិបាល**

**ពិភាក្សាសំណួរខាងក្រោម:**

- នៅក្នុងការអនុវត្តជាក់ស្តែង តើអ្នកគិតដូចម្តេចអំពីការបំពេញការងារជាមួយគ្នារវាងក្រុមប្រឹក្សា និងគណៈអភិបាល ?
- ហេតុអ្វីបានជាគណៈអភិបាល មានគណនេយ្យភាពចំពោះក្រុមប្រឹក្សា ជាការសំខាន់ ?

**លំហាត់ទី ២: ទំនាក់ទំនងរវាងក្រុមប្រឹក្សាជាមួយគណៈអភិបាល**

**ពិភាក្សាសំណួរខាងក្រោម:**

- តើអ្នកគិតថា អង្គភាពខ្សែបណ្តោយ មានវិសាលភាពអនុវត្តទៅតាមការណែនាំរបស់អភិបាលសម្រាប់ឱ្យអង្គភាពខ្សែបណ្តោយឆ្លើយតបនឹងតម្រូវការនៅមូលដ្ឋានឬទេ?
- ប្រសិនបើមិនមានទេ តើអ្នកគិតថាត្រូវកែប្រែអ្វី ដើម្បីឱ្យអង្គភាពខ្សែបណ្តោយ មានលទ្ធភាពអនុវត្តទៅតាមការណែនាំរបស់អភិបាលក្នុងការឆ្លើយតបនឹងតម្រូវការនៅមូលដ្ឋាន?

# មេរៀនសម្រាប់ការយល់ដឹង និង
# ការបណ្តុះបណ្តាលអំពី
# ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល រាជធានី
# ខេត្ត ក្រុង ស្រុក ខណ្ឌ

មេរៀនទី ៧៖

គណៈកម្មាធិការរបស់ក្រុមប្រឹក្សា

# វគ្គទី ១

១. ការណែនាំបង្ហាញគណៈកម្មាធិការរបស់ក្រុមប្រឹក្សា

២. គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ

៣. គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស

៤. គណៈកម្មាធិការលទ្ធកម្ម

## ផ្នែកទី ១: ការណែនាំបង្ហាញគណៈកម្មាធិការរបស់ក្រុមប្រឹក្សា

**ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ**

**មាត្រា ១១៤ ដល់ ១២២**

### គោលបំណងនៃការបង្កើតគណៈកម្មាធិការរបស់ក្រុមប្រឹក្សា

- ✓ គណៈកម្មាធិការរបស់ក្រុមប្រឹក្សា គឺជាការប្រមូលផ្តុំនូវសមាសភាពនៃសមាជិក ដែលមានទស្សនៈ និងជំនាញ-ឯកទេសផ្សេងៗគ្នា ដែលអាចផ្តោតទៅលើបញ្ហាសំខាន់ៗរបស់ក្រុមប្រឹក្សា ។ គណៈកម្មាធិការទាំងនោះត្រូវរាយការណ៍ទៅក្រុមប្រឹក្សា។ តួនាទី ភារកិច្ចរបស់គណៈកម្មាធិការ គឺត្រូវផ្តល់ព័ត៌មានឱ្យយោបល់ និងផ្តល់អនុសាសន៍ផ្សេងៗទៅឱ្យក្រុមប្រឹក្សាធ្វើការសម្រេចចិត្ត ។
- ✓ ព័ត៌មាន យោបល់ និងអនុសាសន៍ផ្សេងៗជួយឱ្យក្រុមប្រឹក្សា អាចធ្វើសេចក្តីសម្រេចចិត្តបានគ្រប់ជ្រុងជ្រោយ។ ដូចនេះគណៈកម្មាធិការ មានតួនាទី ភារកិច្ច ជួយធ្វើឱ្យប្រសើរឡើងដល់ការធ្វើសេចក្តីសម្រេចចិត្តរបស់ក្រុមប្រឹក្សា ។
- ✓ គណៈកម្មាធិការ ក៏អាចជាយន្តការមួយសម្រាប់ធ្វើឱ្យមានការចូលរួមផងដែរ ។ ក្រុមប្រឹក្សា អាចអនុញ្ញាតឱ្យគណៈកម្មាធិការ អញ្ជើញតំណាងសហគមន៍ ឬ ប្រជាពលរដ្ឋណាមួយធ្វើជាទីប្រឹក្សារបស់គណៈកម្មាធិការនោះ។ (ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មាត្រា ១១៧)

### គណៈកម្មាធិការជាកាតព្វកិច្ច និងគណៈកម្មាធិការនានា

- ✓ គ្រប់ក្រុមប្រឹក្សា ត្រូវបានតម្រូវឱ្យបង្កើតគណៈកម្មាធិការពិសេសចំនួនបីដែលក្រុមប្រឹក្សាមានកាតព្វកិច្ចត្រូវបង្កើតដោយខានមិនបានគឺ: **គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ** និង **គណៈកម្មាធិការលទ្ធកម្ម** (មាត្រា ១១៤ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ) ។
- ✓ ក្រុមប្រឹក្សា អាចបង្កើត**គណៈកម្មាធិការបន្ថែម** ដើម្បីជួយការងាររបស់ក្រុមប្រឹក្សា (មាត្រា ១១៥ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ) ។ ក្រុមប្រឹក្សា ក៏អាចបង្កើតអនុគណៈកម្មាធិការ ឬ ក្រុមការងារ ដោយផ្អែកលើសំណើរបស់គណៈកម្មាធិការ ឬ សំណើរបស់គណៈអភិបាល (មាត្រា ១៥, ៧៦,

១៣៧ នៃអនុក្រឹត្យលេខ ២១៦ អ.ន.ក្រ.បក ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក ) ។

✓ ក្រុមប្រឹក្សា អាចតែងតាំងគណៈកម្មាធិការឱ្យរៀបចំសេចក្តីព្រាងដីកាដែលក្រុមប្រឹក្សាបានសម្រេចថា ជាការចាំបាច់ ( មាត្រា ១២, ៦៨, ១៣០ នៃអនុក្រឹត្យលេខ ២១៦ អ.ន.ក្រ.បក ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក ) ។

✓ ក្រុមប្រឹក្សា អាចតែងតាំងសមាជិកក្រុមប្រឹក្សា អភិបាល អភិបាលរង មន្ត្រីរបស់ក្រុមប្រឹក្សា និងតំណាងរបស់ក្រុមប្រឹក្សាផ្សេងទៀតនៅក្នុងដែនដីជាសមាជិករបស់គណៈកម្មាធិការ អនុគណៈកម្មាធិការ ឬ ក្រុមការងារបន្ថែមទៀត ។ ក្រុមប្រឹក្សា ក៏អាចតែងតាំង**តំណាងសហគមន៍ ប្រជាពលរដ្ឋសាមញ្ញ** ឬបុគ្គលផ្សេងទៀត**ឱ្យធ្វើជាទីប្រឹក្សារបស់**គណៈកម្មាធិការ អនុគណៈកម្មាធិការ ឬ ក្រុមការងារផងដែរ ( មាត្រា ១១៥, ១១៧ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មាត្រា ២០, ៧៧, ១៣៨ នៃអនុក្រឹត្យលេខ ២១៦ អ.ន.ក្រ.បក ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក ) ។

✓ ក្រុមប្រឹក្សា សម្រេចលើចំនួនសមាជិក ប្រធាន និង អនុប្រធាននៅក្នុងគណៈកម្មាធិការ អនុគណៈកម្មាធិការ និងក្រុមការងាររបស់ខ្លួន និងការរៀបចំ និងការប្រព្រឹត្តិទៅរបស់គណៈកម្មាធិការ អនុគណៈកម្មាធិការ និងក្រុមការងារ ។ ក្រុមប្រឹក្សា ត្រូវ**ធានាឱ្យមានតំណាងស្ត្រី**នៅក្នុងគណៈកម្មាធិការ អនុគណៈកម្មាធិការ និង ក្រុមការងារ និង នៅក្នុងចំណោមប្រធាន និង អនុប្រធានរបស់គណៈកម្មាធិការ អនុគណៈកម្មាធិការ និងក្រុមការងារ ។ ក្រុមប្រឹក្សា ក៏អាចបញ្ឈប់ការងារសមាជិករបស់គណៈកម្មាធិការផងដែរ ( មាត្រា ១១៦, ១១៨, ១២០ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មាត្រា ២០, ៧៧, ១៣៨ នៃអនុក្រឹត្យលេខ ២១៦ អ.ន.ក្រ.បក ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក ) ។

✓ ការទទួលខុសត្រូវរបស់គណៈកម្មាធិការមួយ **មិនអាចត្រួតគ្នា**ជាមួយនឹងការទទួលខុសត្រូវរបស់គណៈកម្មាធិការចាំបាច់ទាំងបី ឬ ការទទួលខុសត្រូវរបស់គណៈអភិបាលឡើយ ( មាត្រា ១១៥ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ) ។

✓ គណៈអភិបាល អាចស្នើសុំឱ្យគណៈកម្មាធិការ អនុគណៈកម្មាធិការ និង ក្រុមការងារ**ធ្វើការសិក្សា និងផ្តល់មតិយោបល់**លើបញ្ហាណាមួយ មាត្រា ២១, ៧៨, ១៣៩ នៃអនុក្រឹត្យលេខ ២១៦ អ.ន.ក្រ.បក ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក) ។ លទ្ធផលនៃការសិក្សា និង មតិយោបល់របស់គណៈកម្មាធិការ អនុគណៈកម្មាធិការ និង ក្រុមការងារ អាច**ផ្តល់ជាព័ត៌មានដល់ការធ្វើសេចក្តីសម្រេចរបស់ក្រុមប្រឹក្សា** ដើម្បីឱ្យក្រុមប្រឹក្សាអាចធ្វើសេចក្តីសម្រេចកាន់តែប្រសើរ ។

**ប្រជាពលរដ្ឋជាទីប្រឹក្សារបស់គណៈកម្មាធិការ**

ការអញ្ជើញប្រជាពលរដ្ឋឱ្យចូលរួមនៅក្នុងក្រុមប្រឹក្សារបស់គណៈកម្មាធិការ ផ្តល់ផលប្រយោជន៍ដល់ក្រុមប្រឹក្សា និងដល់ប្រជាពលរដ្ឋ ។ ការមានប្រជាពលរដ្ឋ ឬតំណាងសហគមន៍ជាសមាជិកនៅក្នុងគណៈកម្មាធិការរបស់ក្រុមប្រឹក្សា គឺជាឧទាហរណ៍នៃ**ការចូលរួមចំណែករបស់ប្រជាពលរដ្ឋ** ។

ស្រមៃមើលក្រុមប្រឹក្សា បង្កើតគណៈកម្មាធិការសុខាភិបាល ។ ការអញ្ជើញវេជ្ជបណ្ឌិត និងគិលានុបដ្ឋាយិកាឱ្យធ្វើជាសមាជិករបស់គណៈកម្មាធិការនោះ នឹងប្រើប្រាស់ជំនាញនៅក្នុងដែនដីរបស់ក្រុមប្រឹក្សា ។

ការដាក់បញ្ចូលប្រជាពលរដ្ឋនៅក្នុងគណៈកម្មាធិការ ក៏ជាវិធីកែលម្អតម្លាភាពរបស់ក្រុមប្រឹក្សា ដើម្បីកែលម្អការចូលរួមរបស់ប្រជាពលរដ្ឋ នៅក្នុងអភិបាលកិច្ច និងដើម្បីលើកកំពស់គណនេយ្យភាពរបស់ក្រុមប្រឹក្សា ផងដែរ ។

ក្រៅពីនេះ គណៈកម្មាធិការ អាចធ្វើជាច្រកចូលសម្រាប់ប្រជាពលរដ្ឋដែលជាធម្មតា មិនមានឱកាសចូលរួមចំណែកនៅក្នុងអាជ្ញាធរមូលដ្ឋាន និងបញ្ចេញសំលេងរបស់ខ្លួន ។ ប្រការនេះ អាចមានបញ្ចូលស្ត្រី យុវជន ជនជាតិដើមភាគតិច និងជនក្រីក្រ ។

✓ ក្រុមប្រឹក្សាត្រូវណែនាំឱ្យគណៈអភិបាល ផ្តល់ការគាំទ្រកិច្ចការផ្នែកលេខាធិការដ្ឋាន ការគាំទ្រផ្នែកច្បាប់ និងបច្ចេកទេសព្រមទាំងការគាំទ្រដទៃទៀតដល់គណៈកម្មាធិ ការ ទាំងបី ឬ អនុគណៈកម្មាធិការ ឬ ក្រុមការងារនានា (មាត្រា ២៣, ៨០, ១៤១ នៃអនុក្រឹត្យលេខ ២១៦ អ.ន.ក្រ.បក ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក) ។

- **លេខាធិការដ្ឋានរបស់ក្រុមប្រឹក្សា** នៅក្នុងផ្នែករដ្ឋបាលរបស់**រដ្ឋបាលខេត្ត** មានការទទួលខុសត្រូវចំពោះការគាំទ្រដល់គណៈកម្មាធិការរបស់ក្រុម ប្រឹក្សា។ លេខាធិការដ្ឋានរបស់ក្រុម ប្រឹក្សា គាំទ្រគណៈកម្មាធិការដោយរៀបចំរបៀបវារៈ និងឯកសារ សម្រាប់ការប្រជុំ រៀបចំលិខិត អញ្ជើញប្រជុំ រៀបចំកន្លែងប្រជុំ ធ្វើកំណត់ហេតុនៃកិច្ចប្រជុំ និងសហការជាមួយផ្នែកផ្សេងទៀតរបស់រដ្ឋបាល និងជាមួយបណ្តាញសារព័ត៌មានដើម្បីផ្សព្វផ្សាយព័ត៌មានដល់សាធារណជនអំពីលទ្ធផល និងសេចក្តីសម្រេច របស់គណៈកម្មាធិការរបស់ក្រុមប្រឹក្សា (មាត្រា ៣ នៃប្រកាសលេខ៤២៧៤ ប្រក. ស្តីពីការបង្កើតការិយាល័យចំណុះទីចាត់ការសាលាខេត្ត

ការបង្កើតការិយាល័យនៃសាលាក្រុង ការបង្កើតការិយាល័យការិយាល័យសាលាស្រុក និងការកំណត់តួនាទីភារកិច្ច របៀបរបបការងារនៃការិយាល័យទាំងនោះ) ។

- **ការិយាល័យគ្រប់គ្រងបុគ្គលិក**នៅក្នុងផ្នែកគ្រប់គ្រងធនធានមនុស្សរបស់**រដ្ឋបាលខេត្ត** ត្រូវផ្តល់យោបល់ទាក់ទងនឹងសមាសភាពរបស់គណៈកម្មាធិការ អនុគណៈកម្មាធិការ និង ក្រុមការងាររបស់ក្រុមប្រឹក្សា ( មាត្រា ៦ នៃប្រកាសចូលកាន់តំណែងខេត្ត) ។
- នៅក្នុង**ក្រុង និង ស្រុក ការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុ**របស់រដ្ឋបាល មានការទទួលខុសត្រូវចំពោះការរៀបចំសេចក្តីព្រាងរបៀបវារៈ រួមទាំងមាតិកានៃរបៀបវារៈ រៀបចំឯកសារប្រជុំ រៀបចំ និងចែកលិខិតអញ្ជើញ រៀបចំកន្លែងប្រជុំ និងធ្វើកំណត់ហេតុនៃកិច្ចប្រជុំ ( មាត្រា ១៧, ២៦ នៃប្រកាសចូលកាន់តំណែង-ខេត្ត) ។

✓ គ្រប់គណៈកម្មាធិការ ត្រូវ**រាយការណ៍ជាប្រចាំអំពីសកម្មភាពរបស់ខ្លួន** ជូនទៅក្រុមប្រឹក្សា និង គណៈអភិបាល ( មាត្រា ១១៩ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មាត្រា ២៤, ៨១, ១៤២ នៃអនុក្រឹត្យស្តីពីតួនាទី-ខេត្ត ) ។

✓ គណៈកម្មាធិការ **មានគណនេយ្យភាពចំពោះក្រុមប្រឹក្សា** ។ ក្រុមប្រឹក្សាខ្លួនឯង មានការទទួលខុសត្រូវ និង មានគណនេយ្យភាពចំពោះប្រជាពលរដ្ឋលើសេចក្តីសម្រេច និង សកម្មភាពរបស់គណៈកម្មាធិការក្រុមប្រឹក្សា ( មាត្រា ១២១ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ) ។

# គណៈកម្មាធិការរបស់ក្រុមប្រឹក្សា (ពណ៌ទឹកក្រូច)



## ផ្នែកទី ២: គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និង កុមារ

**ច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ**

**មាត្រា ១២៧ ដល់ ១៣៥**

**ប្រកាសស្ដីពីការបង្កើតគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និង កុមារ**

### តួនាទីរបស់គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ

✓ គ្រប់ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មានកាតព្វកិច្ចបង្កើតគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ (មាត្រា ១១៤ នៃច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ) ។

✓ គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និង កុមារ មានការទទួលខុសត្រូវក្នុងការផ្ដល់**មតិយោបល់ និង អនុសាសន៍**ដល់:

- ក្រុមប្រឹក្សា
- គណៈអភិបាល
- គណៈកម្មាធិការផ្សេងទៀតរបស់ក្រុមប្រឹក្សា

> វានឹងមានការលំបាក ក្នុងការគិតអំពីកិច្ចការមួយ ដែលមានផលប៉ះពាល់មកលើបុរសតែប៉ុណ្ណោះ ដោយមិនប៉ះពាល់ស្ត្រី។ វាក៏មានការលំបាកដូចគ្នាដែរក្នុងការគិតអំពីបញ្ហាអ្វីមួយ ដែលមិនមានផលប៉ះពាល់មកលើកុមារ។ ដូច្នេះការទទួលខុសត្រូវរបស់គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ មានវិសាលភាពធំទូលាយណាស់ ។

✓ គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និង កុមារ មានសិទ្ធិអំណាចផ្ដល់**មតិយោបល់ និង អនុសាសន៍**ដល់ក្រុមប្រឹក្សា គណៈអភិបាល និង គណៈកម្មាធិការផ្សេងទៀតរបស់ក្រុមប្រឹក្សា ដើម្បីលើកកំពស់សមភាពយេនឌ័រដល់ បញ្ហានានាពាក់ព័ន្ធស្ត្រី និងកុមារដែលត្រូវលើកមកពិចារណា ជាប្រចាំ (មាត្រា ១២៨, ១២៩ នៃច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មាត្រា ២ នៃ ប្រកាសស្ដីពីការបង្កើតគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និង កុមារ) ។

**ឧទាហរណ៍**

ក្រុមប្រឹក្សាគ្រោងបង្កើតសាលាបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ ដែលផ្តល់ផលប្រយោជន៍ដល់បុរស ស្ត្រី យុវវ័យ កុមារ រួមទាំងជនក្រីក្រ និងក្រុមជនងាយរងគ្រោះ ។ បន្ទាប់ពីមានការពិគ្រោះយោបល់ជាមួយអ្នកទាំងនោះ ក្រុមប្រឹក្សាសម្រេចផ្តល់វគ្គបណ្តុះបណ្តាលដូចខាងក្រោមៈ

- ជំនាញកុំព្យូទ័រ ភាគច្រើនត្រូវស្នើឡើងដោយក្រុមយុវវ័យ
- ជំនាញកាត់ដេរ ភាគច្រើនត្រូវបានស្នើឡើងដោយយុវតី
- ជំនាញជួសជុលម៉ូតូ ភាគច្រើនត្រូវស្នើឡើងដោយយុវជន
- ជំនាញចុងភៅ ភាគច្រើនត្រូវស្នើឡើងដោយស្ត្រីវ័យចំណាស់
- ជំនាញជាងឈើ ភាគច្រើនត្រូវស្នើឡើងដោយបុរសវ័យចំណាស់

ពេលវេលាសម្រាប់វគ្គបណ្តុះបណ្តាលខាងលើ ត្រូវរៀបចំឡើងឱ្យសមស្របសម្រាប់សិស្ស ។ ដូចជាវគ្គជំនាញចុងភៅដែលភាគច្រើនស្នើដោយស្ត្រីវ័យចំណាស់ គួររៀបចំឡើងនៅពេលរសៀល ដែលពេលនោះកូនរបស់ពួកគាត់នៅសាលារៀន ហើយកិច្ចការផ្ទះរបស់ពួកគាត់ក៏ប្រហែលជាត្រូវបានរៀបចំរួចរាល់ហើយដែរ ។

## សមាសភាពគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ

✓ សមាសភាពរបស់គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារសម្រាប់រាជធានី និងខេត្ត ត្រូវបានបង្ហាញនៅក្នុងតារាងខាងក្រោម ( មាត្រា ៣ នៃប្រកាសស្តីពីការបង្កើតគណៈកម្មាធិការពិគ្រោះយោបល់ កិច្ចការស្ត្រី និងកុមារ) ។

- សមាជិកក្រុមប្រឹក្សាជាស្ត្រី ដែលជ្រើសរើសដោយក្រុមប្រឹក្សា ប្រធាន
- សមាជិកក្រុមប្រឹក្សា ដែលជ្រើសរើសដោយក្រុមប្រឹក្សា អនុប្រធាន
- អភិបាលរងជាស្ត្រី ០១រូប អនុប្រធាន
- ប្រធាន ឬអនុប្រធានមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា អនុប្រធាន
- ប្រធាន ឬអនុប្រធានមន្ទីរកិច្ចការនារី អនុប្រធានអចិន្ត្រៃយ៍
- នាយករងរដ្ឋបាល ០១រូប សមាជិក
- ប្រធាន ឬអនុប្រធានមន្ទីរផែនការ សមាជិក
- ប្រធាន ឬអនុប្រធានមន្ទីរសុខាភិបាល សមាជិក
- ប្រធាន ឬអនុប្រធានមន្ទីរអភិវឌ្ឍន៍ជនបទ សមាជិក
- ប្រធាន ឬអនុប្រធានមន្ទីរអប់រំ យុវជន និងកីឡា សមាជិក
- ប្រធាន ឬអនុប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សមាជិក
- ប្រធាន ឬអនុប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សមាជិក
- ស្នងការ ឬតំណាងស្នងការដ្ឋាននគរបាល សមាជិក
- នាយក ឬនាយករងទីចាត់ការអន្តរវិស័យ សមាជិក
- ប្រធាន ឬអនុប្រធានសមាគមក្រុមប្រឹក្សាឃុំ សង្កាត់នៃរាជធានី សមាជិក
- តំណាងពីស្ថាប័ន ឬអង្គភាពផ្សេងៗទៀត តាមការចាំបាច់ សមាជិក

✓ គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារនៅតាម**ក្រុង ស្រុក និងខណ្ឌ** មានសមាសភាពប្រហាក់ប្រហែលគ្នា ប៉ុន្តែសមាជិកត្រូវយកចេញពីការិយាល័យខ្សែបណ្តោយ មិនមែនយកចេញពីមន្ទីរឡើយ។ គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារនៅតាមក្រុង ស្រុក ខណ្ឌ ក៏មាន**ជនបង្គោលទទួលបន្ទុក កិច្ចការស្ត្រី និងកុមារឃុំ សង្កាត់**នៅក្នុងដែនដីរបស់ខ្លួនជាសមាជិកផងដែរ (មាត្រា ៣ នៃប្រកាសស្តីពីការបង្កើត គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ)។

✓ គ្រប់ក្រុមប្រឹក្សាត្រូវប្រឹងប្រែងដើម្បីដាក់បញ្ចូល**ចំនួនស្ត្រីឱ្យបានសមស្រប**នៅក្នុងគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ (មាត្រា ៤ នៃប្រកាសស្តីពីការបង្កើតគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ)។

✓ សមាជិកគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ មានចំនួនរហូតដល់០២រូប អាច**ចូលរួមនៅក្នុងការប្រជុំរបស់**ក្រុមប្រឹក្សា គណៈកម្មាធិការរបស់ក្រុមប្រឹក្សា និងគណៈអភិបាល លើកលែងតែការប្រជុំជាសម្ងាត់។ សមាជិកគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ មានសិទ្ធិទទួលបាន**របៀបវារៈ និងឯកសារសម្រាប់ប្រជុំ**។ សមាជិកដែលចូលរួមប្រជុំ **មានសិទ្ធិពេញលេញក្នុងការចូលរួមបញ្ចេញមតិយោបល់របស់ខ្លួន**នៅក្នុងពេលប្រជុំ (មាត្រា ១៣០, ១៣១ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មាត្រា ៨ នៃប្រកាសស្តីពីការបង្កើតគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ)។

✓ សមាជិកគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារដែលជាសមាជិកក្រុមប្រឹក្សា មានសិទ្ធិបោះឆ្នោតនៅក្នុងកិច្ចប្រជុំរបស់ក្រុមប្រឹក្សា។ សមាជិកក្រុមប្រឹក្សាដែលជាសមាជិកគណៈកម្មាធិការ មិនមានសិទ្ធិបោះឆ្នោតនៅក្នុងកិច្ចប្រជុំរបស់គណៈអភិបាលឡើយ (មាត្រា១៣២ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ)។

✓ ក្រុមប្រឹក្សា គណៈកម្មាធិការ និងគណៈអភិបាល **ត្រូវពិចារណាលើអនុសាសន៍** ដែលទទួលបានពី**គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និង កុមារ** និងសមាជិករបស់ខ្លួន ហើយត្រូវធ្វើការពិចារណាឱ្យបានត្រឹមត្រូវថាតើអនុសាសន៍នោះអាចអនុវត្តបាន ឬយ៉ាងណា (មាត្រា៨នៃប្រកាសស្តីពីការបង្កើតគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ)។

ក្រុមប្រឹក្សា និង គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និង កុមាររបស់ក្រុមប្រឹក្សា ត្រូវបំពេញការងារជាមួយគ្នា ដើម្បីសំរេចបានលទ្ធផលល្អសម្រាប់ស្ត្រី និង កុមារនៅក្នុងដែនដីរបស់ខ្លួន។

សមាជិករបស់គណៈកម្មាធិការ ត្រូវមានលទ្ធភាពចូលរួមពេញលេញនៅក្នុងការពិភាក្សានៅពេលប្រជុំរបស់ក្រុមប្រឹក្សា គណៈកម្មាធិការនានា និង គណៈអភិបាល។ នៅក្នុងពេលពិភាក្សា សមាជិករបស់គណៈកម្មាធិការ អាចចែករំលែក**ទស្សនៈ និង តម្រូវការពិសេសរបស់ស្ត្រី និង កុមារ** ហើយគាត់អាចលើកឡើងពីយុទ្ធសាស្ត្រ**សម្រាប់ដោះស្រាយបញ្ហាទាំងអស់នៅមូលដ្ឋាន** ដោយមានការពិចារណាអំពីស្ត្រី និង កុមារ។

ដើម្បីអនុវត្តការទទួលខុសត្រូវរបស់ខ្លួន គណៈកម្មាធិការមិនអាចគិតឱ្យធ្វើតែការងាររដ្ឋបាល ឬប្រើប្រាស់ដោយឡែកសម្រាប់តែការងារណាមួយ ដូចជាការប្រមូលទិន្នន័យឡើយ។ គណៈកម្មាធិការត្រូវមាន**វិសាលភាពចូលរួមចំណែកលើបញ្ហាពិតប្រាកដ ដែលក្រុមប្រឹក្សាកំពុងជួបប្រទះ**។

## ភារកិច្ចសំខាន់ៗ របស់គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ

✓ គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និង កុមារមាន**ភារកិច្ចជាក់លាក់សំខាន់ៗ មួយចំនួន** ដែលរួមមាន

- ចូលរួមនៅក្នុងការរៀបចំ**ចក្ខុវិស័យយុទ្ធសាស្ត្រសម្រាប់ការអភិវឌ្ឍរបស់ក្រុមប្រឹក្សា** រួមទាំងចក្ខុវិស័យសម្រាប់សមភាពយេនឌ័រ និងការផ្តល់សេវាសមស្របដល់ស្ត្រី យុវជន និងកុមារ។

- ផ្ដល់**អនុសាសន៍**អំពីរបៀបលើកកំពស់ការប្រាស្រ័យទាក់ទង ការសហការ និងការសម្របសម្រួលនៅក្នុងចំណោមក្រុមប្រឹក្សា មន្ទីរ ឬការិយាល័យខ្សែបណ្ដោយ អង្គការមិនមែនរដ្ឋាភិបាល និងសហគមន៍ ដើម្បី**អនុវត្តសកម្មភាពដែលផ្ដល់ផលប្រយោជន៍ដល់ស្ត្រី យុវជន និងកុមារ ។**
- ផ្ដល់**អនុសាសន៍**អំពីវិធានការដែលត្រូវប្រកាន់យកដោយអាជ្ញាធរ ដើម្បីដោះស្រាយបញ្ហាទាក់ទងនឹង ស្ត្រី យុវវ័យ កុមារហើយ**បង្ការគ្រោះថ្នាក់ចំពោះស្ត្រី យុវជន និងកុមារ ។**
- **ប្រមូល និងវិភាគព័ត៌មាន**ទាក់ទងនឹងយេនឌ័រ និងតម្រូវការរបស់ស្ត្រី យុវជន និងកុមារ និងដាក់បញ្ចូលព័ត៌មាននោះទៅក្នុងផែនការអភិវឌ្ឍ និងកម្មវិធីវិនិយោគរបស់ក្រុមប្រឹក្សា ។
- ផ្ដល់អនុសាសន៍លើបញ្ហាទាក់ទងនឹងសមភាពយេនឌ័រ និងស្ត្រី យុវជន និងកុមារ ។
- **ស្វែងរកការគាំទ្រ**សម្រាប់ឱ្យស្ត្រីចូលរួមនៅក្នុងការធ្វើសេចក្ដីសម្រេចទាក់ទងនឹងការអភិវឌ្ឍ ។
- ចូលរួមនៅក្នុង**ការពិនិត្យតាមដាន និងវាយតំលៃ**ផែនការ និងថវិកាប្រចាំឆ្នាំរបស់ក្រុមប្រឹក្សា ដើម្បីលើកកម្ពស់សមភាពយេនឌ័រ និងដោះស្រាយបញ្ហាទាក់ទងនឹងស្ត្រី យុវជន និងកុមារ ។
- ពិនិត្យតាមដានការអនុវត្តគោលនយោបាយស្ដីពីសមភាពយេនឌ័រ និងស្ថានភាពរបស់ស្ត្រី យុវជន និងកុមារ ។
- **រាយការណ៍**ជាប្រចាំ**ដល់ក្រុមប្រឹក្សា**អំពីសមភាពយេនឌ័រ ការផ្ដល់អំណាចដល់ស្ត្រី និងបញ្ហាដែលពាក់ព័ន្ធនឹងយុវជន និងកុមារ ។

  (មាត្រា ៨ នៃប្រកាសស្ដីពីការបង្កើតគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ) ។

✓ គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារនៅថ្នាក់ខេត្ត មានការទទួលខុសត្រូវបន្ថែម ។ គណៈកម្មាធិការនេះត្រូវ**គាំទ្រក្រុង ស្រុក និងក្រុមប្រឹក្សាឃុំ សង្កាត់**នៅក្នុងការដោះស្រាយបញ្ហាទាក់ទងនឹងស្ត្រី យុវជន និងកុមារ ។ គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារនៅរាជធានី ត្រូវផ្ដល់ការគាំទ្រដូចគ្នានេះដល់ក្រុមប្រឹក្សាខណ្ឌ និងសង្កាត់នៅក្នុងរាជធានី (មាត្រា ២១ នៃប្រកាសស្ដីពីការបង្កើតគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ) ។

## ការប្រជុំ និងការរាយការណ៍របស់គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ

✓ គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និង កុមារ ត្រូវរៀបចំ**កិច្ចប្រជុំសាមញ្ញ**របស់ខ្លួន ។ ដើម្បីឱ្យកិច្ចប្រជុំដំណើរការទៅបាន ត្រូវមានវត្តមានរបស់សមាជិកគណៈកម្មាធិការច្រើនជាងពាក់កណ្ដាល ។ សេចក្ដីសម្រេច មាន

សុពលភាពជរាបណាសេចក្ដីសម្រេចនោះ ត្រូវធ្វើឡើងដោយសមាជិករបស់គណៈកម្មាធិការច្រើនជាងពាក់កណ្ដាល (មាត្រា ១៧, ១៨ នៃប្រកាសស្ដីពីការបង្កើតគណៈកម្មាធិការពិគ្រោះយោបល់ កិច្ចការស្ត្រី និងកុមារ)។

✓ កិច្ចប្រជុំរបស់គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ **ត្រូវធ្វើឡើងជាសាធារណៈ** លើកលែងតែករណីពិសេសដែលតម្រូវឱ្យធ្វើជាសម្ងាត់ (ដូចជាករណីពាក់ព័ន្ធនឹងការរំលោភផ្លូវភេទ) (មាត្រា ១៧, ១៨ នៃប្រកាសស្ដីពីការបង្កើតគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ)។

✓ តាមរយៈក្រុមប្រឹក្សារបស់ខ្លួន គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ អាចអញ្ជើញប្រធាន ឬតំណាងរបស់ក្រុមប្រឹក្សាផ្សេងទៀត គណៈកម្មាធិការរបស់ក្រុមប្រឹក្សា មន្ទីរ ឬការិយាល័យខ្សែបណ្ដោយ ឬបុគ្គលផ្សេងទៀតឱ្យ**ចូលរួមនៅក្នុងកិច្ចប្រជុំរបស់ គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ** និង**ផ្ដល់ព័ត៌-មានពាក់ព័ន្ធ**គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ (មាត្រា ៦ នៃប្រកាសស្ដីពីការបង្កើតគណៈ-កម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ)។

✓ គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ **រាយការណ៍ដល់ក្រុមប្រឹក្សារបស់ខ្លួន**ប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំ។ **របាយការណ៍ប្រចាំឆ្នាំ**របស់គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ ត្រូវពណ៌នាអំពីស្ថានភាពរបស់ស្ត្រី និងកុមារនៅក្នុងដែនដី និងអនុសាសន៍ផ្សេងទៀតសម្រាប់កែលម្អ។ របាយការណ៍ត្រូវដាក់បញ្ចូលទៅក្នុងរបាយការណ៍ប្រចាំឆ្នាំរបស់ក្រុមប្រឹក្សា (មាត្រា ១៣៣ និង១៣៤ នៃច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មាត្រា ១១ នៃប្រកាសស្ដីពីការបង្កើតគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ)។

## ផ្នែកទី ៣: គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស

**ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ**

**មាត្រា ១២៣ ដល់ ១២៦, ១៦៦**

**អនុក្រឹត្យស្តីពីការបង្កើតគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសខេត្ត**

**អនុក្រឹត្យស្តីពីការបង្កើតគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសរាជធានី**

### តួនាទីរបស់គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស

✓ គ្រប់ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មានកាតព្វកិច្ចបង្កើតគណៈកម្មាធិការសម្របសម្រួលបច្ចេកទេស (មាត្រា ១១៤ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ) ។

✓ ទោះជាយ៉ាងណាក៏ដោយ ក្រុមប្រឹក្សាពីរ ឬ ច្រើនអាចប្រើប្រាស់គណៈកម្មាធិការសម្របសម្រួលបច្ចេកទេសមួយជាមួយគ្នា (មាត្រា ១២៥ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ) ។

✓ តួនាទីរបស់គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស គឺដើម្បី**ផ្តល់យោបល់**ដល់ក្រុមប្រឹក្សា និងគណៈអភិបាល**អំពីការសម្របសម្រួលការងាររបស់ក្រុមប្រឹក្សាជាមួយការងាររបស់មន្ទីរ ឬការិយាល័យខ្សែបណ្តោយ** (មាត្រា ១២៤ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មាត្រា ២ នៃអនុក្រឹត្យលេខ២១៨ អនក្រ.បក ស្តីពីការបង្កើត ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសក្រុមប្រឹក្សាខេត្ត គណៈកម្មាធិការសម្របសម្រួលបច្ចេកទេសក្រុមប្រឹក្សាក្រុង និងគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសក្រុមប្រឹក្សាស្រុក មាត្រា ២ នៃអនុក្រឹត្យលេខ២១៧

> គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស ធ្វើជា**អ្នកទំនាក់ទំនងយ៉ាងសំខាន់រវាងក្រសួងខ្សែបណ្តោយនៅថ្នាក់ជាតិ** និងក្រុមប្រឹក្សានៅថ្នាក់ក្រោមជាតិ ។
>
> គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស:
>
> - ផ្តល់យន្តការសម្រាប់ឱ្យក្រុមប្រឹក្សា**ចរចារឱ្យមានសកម្មភាព និងថវិការបស់ក្រសួងខ្សែបណ្តោយ**នៅក្នុងដែនដី ។
> - ធ្វើឱ្យមាន**ផែនការ និងថវិកាដែលបានធ្វើសមាហរណកម្ម**នៅក្នុងដែនដីរបស់ក្រុមប្រឹក្សា
> - ធ្វើឱ្យក្រុមប្រឹក្សាមានលទ្ធភាព**សម្របសម្រួលការអភិវឌ្ឍនៅក្នុងចំណោមវិស័យនានា**នៅក្នុងដែនដីរបស់ខ្លួន (សមាហរណកម្មតាមវិស័យ)

អនក្រ.បក ស្តីពីការបង្កើត ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសរាជធានី និងគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសខណ្ឌ នៃរាជធានីភ្នំពេញ) ។

✓ ជាផ្នែកមួយនៃតួនាទីរបស់ខ្លួននៅក្នុងការសម្របសម្រួល គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស ត្រូវ**ដាក់បញ្ចូល**ទៅក្នុងផែនការអភិវឌ្ឍ កម្មវិធីវិនិយោគបីឆ្នាំរំកិល ក្របខ័ណ្ឌចំណាយ និងថវិការបស់ក្រុមប្រឹក្សានូវ**ផែនការ និងថវិការបស់ក្រសួង** ស្ថាប័ន មន្ទីរ និងអង្គភាពរបស់រាជរដ្ឋាភិបាលដែលផ្តល់សេវានៅក្នុងដែនដីរបស់ក្រុមប្រឹក្សា ( មាត្រា ១២៤ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ) ។

✓ ដូច្នេះ នឹងមានផែនការអភិវឌ្ឍ និងថវិការួមមួយនៅក្នុងដែនដីរបស់ក្រុមប្រឹក្សា។ ហេតុនេះ គណៈកម្មាធិការសម្របសម្រួលបច្ចេកទេសរបស់ក្រុមប្រឹក្សា ត្រូវ**សម្របសម្រួលសកម្មភាពរដ្ឋបាលសាធារណៈទាំងអស់**នៅក្នុងដែនដីរបស់ក្រុមប្រឹក្សា ( មាត្រា ៨. ១២៤ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក) ។

## សមាសភាពគណៈកម្មាធិការសម្របសម្រួលបច្ចេកទេស

✓ **សមាសភាព**របស់គណៈកម្មាធិការសម្របសម្រួលបច្ចេកទេសសម្រាប់ក្រុមប្រឹក្សានីមួយៗ មានលក្ខណៈប្រហាក់ប្រហែលគ្នា។ ខាងក្រោមនេះ គឺជាសមាសភាពរបស់គណៈកម្មាធិការសម្របសម្រួលបច្ចេកទេសនៅថ្នាក់ខេត្ត ( មាត្រា ១២៣ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក មាត្រា ៣ នៃអនុក្រឹត្យស្តីពីការបង្កើតគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសខេត្ត ) ។

- អភិបាលខេត្ត ជាប្រធាន
- អភិបាលរងខេត្ត០១រូប ជាអនុប្រធាន
- នាយករដ្ឋបាលសាលាខេត្ត ជាសមាជិកអចិន្ត្រៃយ៍
- សមាជិកក្រុមប្រឹក្សាខេត្តយ៉ាងតិច០២រូប ជាសមាជិក
- ប្រធានមន្ទីរ អង្គភាពដែលប្រចាំនៅខេត្ត ជាសមាជិក
- នាយកទីចាត់ការទាំងអស់របស់សាលាខេត្ត ជាសមាជិក
- អភិបាលក្រុង អភិបាលស្រុកទាំងអស់នៅក្នុងខេត្ត ជាសមាជិក
- តំណាងសមាគមក្រុមប្រឹក្សាឃុំ សង្កាត់ប្រចាំខេត្ត០២រូប ជាសមាជិក
- តំណាងគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ០១រូប ជាសមាជិក

- ✓ បន្ថែមពីលើតំណាងមួយរូបរបស់គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារដែលមានចែងនៅក្នុងអនុក្រឹត្យ សមាជិកមួយរូបទៀតរបស់គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ មានសិទ្ធិចូលរួមនៅក្នុងកិច្ចប្រជុំរបស់គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស (មាត្រា ១៣១ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក មាត្រា ៩ នៃប្រកាសស្តីពីការបង្កើតគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ)។

- ✓ សមាសភាពរបស់គណៈកម្មាធិការសម្របសម្រួលបច្ចេកទេសសម្រាប់ក្រុមប្រឹក្សាផ្សេងទៀត មានលក្ខណៈប្រហាក់ប្រហែលគ្នា។ សមាសភាពរបស់គណៈកម្មាធិការសម្របសម្រួលបច្ចេកទេសផ្សេងទៀត អាចឃើញមាននៅក្នុងអនុក្រឹត្យស្តីពីការបង្កើតគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសខេត្ត និងអនុក្រឹត្យស្តីពីការបង្កើតគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសរាជធានី។

  - គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស**នៅថ្នាក់ស្រុក** គឺមេឃុំ ចៅសង្កាត់ទាំងអស់នៅក្នុងស្រុក ជាសមាជិករបស់គណៈកម្មាធិការសម្របសម្រួលបច្ចេកទេសស្រុក (មាត្រា ២១ នៃអនុក្រឹត្យលេខ២១៨ អនក្រ.បក ស្តីពីការបង្កើត ការរៀបចំ និងការប្រព្រឹត្តទៅនៃ គណៈកម្មាធិការសម្របសម្រួលបច្ចេកទេសក្រុមប្រឹក្សាខេត្ត គណៈកម្មាធិការសម្របសម្រួលបច្ចេកទេសក្រុមប្រឹក្សាក្រុង និងគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសក្រុមប្រឹក្សាស្រុក)។

  - គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស**នៅថ្នាក់ក្រុង** គឺចៅសង្កាត់ទាំងអស់នៅក្នុងក្រុងជាសមាជិករបស់គណៈកម្មាធិការសម្របសម្រួលបច្ចេកទេសក្រុង (មាត្រា ១២ នៃអនុក្រឹត្យលេខ២១៨ អនក្រ.បក ស្តីពីការបង្កើត ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសក្រុមប្រឹក្សាខេត្ត គណៈកម្មាធិការសម្របសម្រួលបច្ចេកទេសក្រុមប្រឹក្សាក្រុង និងគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសក្រុមប្រឹក្សាស្រុក)។

  - គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស**នៅថ្នាក់រាជធានី** សមាសភាពរបស់គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស**នៅថ្នាក់រាជធានី** មានលក្ខណៈដូចគ្នានឹងសមាសភាពរបស់គណៈកម្មាធិការសម្របសម្រួលបច្ចេកទេសនៅថ្នាក់ខេត្ត (មាត្រា ៣ នៃអនុក្រឹត្យលេខ២១៧ អនក្រ.បក ស្តីពីការបង្កើត ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសក្រុមប្រឹក្សារាជធានី និងគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសក្រុមប្រឹក្សាខណ្ឌ នៃរាជធានីភ្នំពេញ)។

- គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស**នៅថ្នាក់ខណ្ឌ** គឺចៅសង្កាត់ទាំងអស់នៅក្នុងខណ្ឌ គឺជាសមាជិករបស់គណៈកម្មាធិការសម្របសម្រួលបច្ចេកទេសខណ្ឌ ( មាត្រា ១២ នៃអនុក្រឹត្យលេខ ២១៧ អនក្រ.បក ស្តីពីការបង្កើត ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសក្រុមប្រឹក្សារាជធានី និងគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសក្រុមប្រឹក្សាខណ្ឌនៃរាជធានីភ្នំពេញ ) ។

✓ ក្នុងឋានៈជាប្រធានគណៈកម្មាធិការសម្របសម្រួលបច្ចេកទេស **អភិបាល** ដែលពាក់មួកជាតំណាងរបស់រាជរដ្ឋាភិបាល និងក្រសួង អាចសម្របសម្រួល និង**ដឹកនាំប្រធានមន្ទីរ និងអង្គភាពខ្សែបណ្តោយរបស់ក្រសួង** ដែលជាសមាជិករបស់គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស (មាត្រា ១៥៤ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ) ។

✓ **គណៈអភិបាល** ពិគ្រោះយោបល់ជាមួយគណៈកម្មាធិការសម្របសម្រួលបច្ចេកទេស ដើម្បីធានាឱ្យបានថា ផែនការ និង ថវិកា ត្រូវបានដាក់បញ្ចូលយ៉ាងល្អ ( មាត្រា ១៦៦ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ) ។

## ភារកិច្ចសំខាន់ៗ របស់គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស

✓ ភារកិច្ចចំបងរបស់គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស គឺត្រូវ**ផ្តល់មតិយោបល់ដល់ក្រុមប្រឹក្សា និងអភិបាល**លើវិស័យសំខាន់ៗដូចខាងក្រោម:

**ផែនការអភិវឌ្ឍ កម្មវិធីវិនិយោគ ក្របខ័ណ្ឌចំណាយ និងថវិកា**

- ដាក់បញ្ចូលផែនការ និងថវិការបស់មន្ទីរ ឬការិយាល័យខ្សែបណ្តោយដែលមានសកម្មភាពនៅក្នុងដែនដីទៅក្នុងផែនការអភិវឌ្ឍន៍ កម្មវិធីវិនិយោគ ក្របខ័ណ្ឌចំណាយ និងថវិកាប្រចាំឆ្នាំរបស់*ក្រុមប្រឹក្សា*
- រៀបចំសេចក្តីព្រាង និងធ្វើបច្ចុប្បន្នភាពផែនការអភិវឌ្ឍន៍រយៈពេល ៥ ឆ្នាំ កម្មវិធីវិនិយោគពាន្ឆាំរំកិល ផែនការ និងថវិកាប្រចាំឆ្នាំ ក្របខ័ណ្ឌចំណាយរយៈពេលមធ្យម
- កៀរគរធនធាន ដើម្បីគាំទ្រគម្រោងវិនិយោគ
- លើកសំណើបែងចែកមូលនិធិវិនិយោគ ដើម្បីគាំទ្រកម្មវិធីនៅក្នុងដែនដី
- រៀបចំរបាយការណ៍រីកចំរើន

**ការសម្របសម្រួលរវាងក្រុមប្រឹក្សាជាមួយមន្ទីរ ឬការិយាល័យខ្សែបណ្តោយ**

- សហប្រតិបត្តិការ ពិគ្រោះយោបល់ និងសម្របសម្រួលការងាររបស់ក្រុមប្រឹក្សាជាមួយការងាររបស់មន្ទីរ ឬការិយាល័យខ្សែបណ្តោយ
- សម្របសម្រួលការផ្តល់សេវា និងសកម្មភាពអភិវឌ្ឍរបស់មន្ទីរ ឬការិយាល័យខ្សែបណ្តោយដើម្បីឱ្យមន្ទីរ ឬការិយាល័យឆ្លើយតបនឹងតម្រូវការនៅមូលដ្ឋាន

> រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ នឹងមាន**ផែនការអភិវឌ្ឍ កម្មវិធីវិនិយោគ ក្របខ័ណ្ឌចំណាយ និងថវិកាប្រចាំឆ្នាំដែលបានធ្វើសមាហរកម្ម** ដែលនឹងបង្ហាញពី**សកម្មភាព និងធនធានទាំងអស់របស់រដ្ឋបាល**នៅក្នុងដែនដី។

- សម្របសម្រួលដំណោះស្រាយវិវាទរវាងការងាររបស់ក្រុមប្រឹក្សាជាមួយការងាររបស់មន្ទីរ ឬការិយាល័យខ្សែបណ្តោយ
- ផ្តល់អនុសាសន៍ដល់ក្រសួងអំពីការកែលម្អការផ្តល់សេវា និងសកម្មភាពអភិវឌ្ឍ ដើម្បីឱ្យមានការឆ្លើយតបកាន់តែប្រសើរចំពោះតម្រូវការនៅមូលដ្ឋាន

**កិច្ចសហប្រតិបត្តិការ និងការសម្របសម្រួលនៅក្នុងរដ្ឋបាលឯកភាព**

- រៀបចំបង្កើតយន្តការដែលមានលក្ខណៈពិគ្រោះយោបល់ និងការចូលរួមសម្រាប់រដ្ឋបាលឯកភាព
- អភិវឌ្ឍប្រព័ន្ធ នីតិវិធី និងយន្តការទំនាក់ទំនងសម្រាប់រដ្ឋបាលឯកភាព
- ដោះស្រាយវិវាទនៅក្នុងរដ្ឋបាលឯកភាព

**កិច្ចសហប្រតិបត្តិការ និងការសម្របសម្រួលនៅក្នុងចំណោមក្រុមប្រឹក្សា**

| **នៅក្នុងខេត្ត** | **នៅក្នុងរាជធានី** |
|---|---|
| • អភិវឌ្ឍយន្តការពិគ្រោះយោបល់នៅក្នុងចំណោមក្រុមប្រឹក្សាខេត្ត ក្រុង ស្រុក និងឃុំ សង្កាត់ | • អភិវឌ្ឍយន្តការពិគ្រោះយោបល់នៅក្នុងចំណោមក្រុមប្រឹក្សារាជធានី ខណ្ឌនិងសង្កាត់ |
| • ឆ្លើយតបនឹងអនុសាសន៍ និងសំណូមពររបស់ក្រុមប្រឹក្សាក្រុង ស្រុក និងឃុំ សង្កាត់ នៅពេលក្រុមប្រឹក្សាទាំងនេះមិនអាចឆ្លើយតបនឹងតម្រូវការនៅមូលដ្ឋាននៅក្នុងដែនដីរបស់ខ្លួន | • ឆ្លើយតបនឹងអនុសាសន៍ និងសំណូមពររបស់ក្រុមប្រឹក្សាខណ្ឌ និង សង្កាត់ នៅពេលក្រុមប្រឹក្សាទាំងនេះមិនអាចឆ្លើយតបនឹងតម្រូវការនៅមូលដ្ឋាននៅក្នុងដែនដីរបស់ខ្លួន |
| • ដោះស្រាយវិវាទនៅក្នុងចំណោមក្រុមប្រឹក្សាខេត្ត ក្រុង ស្រុក និងឃុំ សង្កាត់ | • ដោះស្រាយវិវាទនៅក្នុងចំណោមក្រុមប្រឹក្សារាជធានី ខណ្ឌ និងសង្កាត់ |
| (មាត្រា ៤ នៃអនុក្រឹត្យស្តីពីការបង្កើតគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសខេត្ត) | (មាត្រា ៤ នៃអនុក្រឹត្យស្តីពីការបង្កើតគណៈកម្មាធិ-ការសម្របសម្រួលបច្ចេកទេសរាជធានី) |

**កិច្ចសហប្រតិបត្តិការ និងការសម្របសម្រួលជាមួយក្រុមប្រឹក្សាដែលពាក់ព័ន្ធ**

- រៀបចំបង្កើតយន្តការពិគ្រោះយោបល់នៅក្នុងចំណោមក្រុមប្រឹក្សាដែលមានព្រំប្រទល់ជាប់គ្នា និង ក្រុមប្រឹក្សាដែលមានការពាក់ព័ន្ធផ្សេងទៀត
- សម្របសម្រួលដំណោះស្រាយចំពោះវិវាទនៅក្នុងចំណោមក្រុមប្រឹក្សាដែលមានព្រំប្រទល់ជាប់គ្នា និង ក្រុមប្រឹក្សាដែលមានការពាក់ព័ន្ធផ្សេងទៀត

**ភារកិច្ចទាក់ទងនឹងមុខងារ ធនធាន**

- ចាត់វិធានការលើកកម្ពស់ប្រសិទ្ធភាពនៅក្នុងការអនុវត្តមុខងារ និងការប្រើប្រាស់ធនធាន
- រៀបចំឱ្យក្រុមប្រឹក្សាត្រៀមទទួលយក និង អនុវត្តមុខងារ ធនធានថ្មី
- ផ្តួចផ្តើមមុខងារ និងធនធានដើម្បីធ្វើការផ្ទេរដល់ក្រុមប្រឹក្សា

> គណៈកម្មាធិការសម្របសម្រួលបច្ចេកទេសរបស់**ក្រុមប្រឹក្សារាជធានី** ក៏ត្រូវពិចារណាផងដែរអំពីមុខងាររួមជាមួយធនធានដែលគួរធ្វើប្រតិភូកម្មដោយក្រុមប្រឹក្សារាជធានីដល់ក្រុមប្រឹក្សាខណ្ឌ ឬ ក្រុមប្រឹក្សាសង្កាត់។
>
> ដូចគ្នានេះដែរ គណៈកម្មាធិការសម្របសម្រួលបច្ចេកទេសរបស់**ក្រុមប្រឹក្សារាជធានី** ត្រូវពិចារណាអំពីមុខងារ រួមជាមួយធនធាន ដែលគួរធ្វើប្រតិភូកម្មដល់ក្រុមប្រឹក្សាសង្កាត់នៅក្នុងក្រុង។

- វាយតំលៃការងារនៅក្នុងការអនុវត្តមុខងារ និងការប្រើប្រាស់ធនធានរបស់ក្រុមប្រឹក្សា (មាត្រា ៤, ១៣, ២២ នៃអនុក្រឹត្យស្តីពីការបង្កើតគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសខេត្ត មាត្រា ៤, ១៣ នៃអនុក្រឹត្យស្តីពីការបង្កើតគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសរាជធានី)។

គណៈកម្មាធិការសម្របសម្រួលបច្ចេកទេសរបស់ក្រុមប្រឹក្សាក្រុង និងគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសរបស់ក្រុមប្រឹក្សាស្រុក មានភារកិច្ចប្រហាក់ប្រហែលគ្នា (មាត្រា ១៣, ២២ នៃអនុក្រឹត្យស្តីពីការបង្កើតគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសខេត្ត)។

> **ឧទាហរណ៍**
>
> គណៈកម្មាធិការសម្របសម្រួលបច្ចេកទេសខេត្ត "ក" មានកិច្ចប្រជុំមួយ ហើយប្រធានមន្ទីរសាធារណការ និងដឹកជញ្ជូនបានចូលរួមក្នុងកិច្ចប្រជុំនោះដែរ។ មន្ទីរសាធារណការ និងដឹកជញ្ជូន មានផែនការជួសជុលផ្លូវមួយខ្សែក្នុងក្រុង "ក"។ ក្រុមប្រឹក្សាក៏មានគម្រោងជួសជុលផ្លូវមួយខ្សែនោះដែរ។
>
> តាមរយៈការពិភាក្សានៅក្នុងកិច្ចប្រជុំរបស់គណៈកម្មាធិការសម្របសម្រួលបច្ចេកទេសខេត្ត "ក" ទាំងមន្ទីរនិងក្រុមប្រឹក្សាអាចបញ្ជៀសការជួសជុលផ្លូវស្ទួនគ្នាបាន។

## គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស និងដំណើរការកសាងផែនការ

- ✓ អនុក្រឹត្យស្ដីពីការកសាងផែនការចែងថា គណៈកម្មាធិការសម្របសម្រួលបច្ចេកទេសមានការទទួលខុសត្រូវចំពោះ:
  - ការសម្របសម្រួល**ការចូលរួមរបស់អ្នកពាក់ព័ន្ធ**នៅក្នុងដំណើរការកសាងផែនការ
  - ផ្ដល់**មតិយោបល់**ដល់ក្រុមប្រឹក្សាមុនពេលអនុម័តផែនការអភិវឌ្ឍ និងកម្មវិធីវិនិយោគ ៣ ឆ្នាំរំកិលរបស់ក្រុមប្រឹក្សា។
  - ផ្ដល់មតិយោបល់ដល់ក្រុមប្រឹក្សាអំពី**ការអនុវត្ត**ផែនការអភិវឌ្ឍ និងកម្មវិធីវិនិយោគ ៣ ឆ្នាំរំកិល។

(មាត្រា ៧ នៃអនុក្រឹត្យស្ដីពីផែនការអភិវឌ្ឍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ)។

ជាមួយនឹងការយល់ព្រមរបស់ក្រុមប្រឹក្សា និងដោយមានការគាំទ្រពីគណៈកម្មាធិការសម្របសម្រួលបច្ចេកទេស គណៈអភិបាល បង្កើត**ក្រុមការងារ**ដែលមានការទទួលខុសត្រូវចំពោះការរៀបចំសេចក្ដីព្រាងផែនការអភិវឌ្ឍ និងសេចក្ដីព្រាងកម្មវិធីវិនិយោគ។ ប្រធាន ឬតំណាងផ្សេងទៀតរបស់មន្ទីរ ឬអង្គភាពខ្សែបណ្ដោយ គឺជាសមាជិករបស់ក្រុមការងារ។ សមាសភាពរបស់ក្រុមការងារ មានលក្ខណៈប្រហាក់ប្រហែលគ្នានឹងសមាសភាពរបស់គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស (មាត្រា ៧.១០ នៃអនុក្រឹត្យស្ដីពី ផែនការអភិវឌ្ឍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ)។

## នីតិវិធីបំពេញការងាររបស់គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស

- ✓ គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស ត្រូវរៀបចំ**កិច្ចប្រជុំយ៉ាងតិចម្ដងរៀងរាល់ពីរខែ**។ ដើម្បីឱ្យកិច្ចប្រជុំដំណើរការទៅបាន ត្រូវមានវត្តមានរបស់សមាជិកគណៈកម្មាធិការច្រើនជាងពាក់កណ្ដាល ។ សេចក្ដីសម្រេច មានសុពលភាពជាវាបណាសេចក្ដីសម្រេចនោះ ត្រូវធ្វើឡើងដោយសមាជិករបស់គណៈកម្មាធិការសម្របសម្រួលបច្ចេកទេសច្រើនជាងពាក់កណ្ដាល (មាត្រា ៥, ១៤, ២៣ នៃអនុក្រឹត្យស្ដីពីការបង្កើតគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសខេត្ត មាត្រា ៥, ១៤ នៃអនុក្រឹត្យស្ដីពីការបង្កើតគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសរាជធានី)។

- ✓ គណៈកម្មាធិការសម្របសម្រួលបច្ចេកទេសអាចបង្កើត**បទបញ្ជាផ្ទៃក្នុង និងនីតិវិធីបំពេញការងាររបស់ខ្លួនផ្ទាល់**។ ដូច្នេះ អភិបាលអាចស្នើសុំឱ្យអភិបាលរង មន្ត្រី ទីប្រឹក្សាបច្ចេកទេស ឬបុគ្គលផ្សេងទៀតឱ្យចូលរួមកិច្ចប្រជុំរបស់

គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស។ បុគ្គលនោះអាចផ្តល់មតិយោបល់ ប៉ុន្តែមិនមានសិទ្ធិអនុម័តលើកិច្ចការអ្វីឡើយ (មាត្រា ៧, ១៦, ២៥ នៃអនុក្រឹត្យស្តីពីការបង្កើតគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសខេត្ត មាត្រា ៧, ១៦ នៃអនុក្រឹត្យស្តីពីការបង្កើតគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសរាជធានី)។

✓ គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស អាចស្នើសុំឱ្យក្រុមប្រឹក្សាបង្កើត**ក្រុមការងាររបស់គណៈកម្មាធិការសម្របសម្រួលបច្ចេកទេសមួយ ឬច្រើន** (មាត្រា ១១, ២០, ២៩ នៃអនុក្រឹត្យស្តីពីការបង្កើតគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសខេត្ត មាត្រា ១១, ២០ នៃអនុក្រឹត្យស្តីពីការបង្កើតគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសរាជធានី)។

✓ **របៀបវារៈ**នៃកិច្ចប្រជុំរបស់គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស គួរផ្អែកទៅលើ

- តម្រូវការរបស់ក្រុមប្រឹក្សា
- តម្រូវការរបស់គណៈអភិបាល
- តម្រូវការរបស់គណៈកម្មាធិការរបស់ក្រុមប្រឹក្សា
- សំណូមពរយ៉ាងតិចមួយភាគបីនៃសមាជិកទាំងអស់របស់គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស
- តម្រូវការស្របច្បាប់ផ្សេងទៀត។

(មាត្រា ៨, ១៧, ២៦ នៃអនុក្រឹត្យស្តីពីការបង្កើតគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសខេត្ត មាត្រា ៨, ១៧ នៃអនុក្រឹត្យស្តីពីការបង្កើតគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសរាជធានី)។

✓ ដោយមានជំនួយពីនាយករដ្ឋបាល អភិបាល ត្រូវរៀបចំ**របាយការណ៍ជូនក្រុមប្រឹក្សា**អំពីលទ្ធផលនៃកិច្ចប្រជុំរបស់គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស (មាត្រា ១០, ១៩, ២៨ នៃអនុក្រឹត្យស្តីពីការបង្កើតគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសខេត្ត មាត្រា ១០, ១៩ នៃអនុក្រឹត្យស្តីពីការបង្កើតគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសរាជធានី)។

## គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស



**បញ្ហាដែលត្រូវដោះស្រាយ**

នៅមិនទាន់មានភាពច្បាស់លាស់នៅឡើយថាតើ "**ការដាក់បញ្ចូល**" ផែនការ និង ថវិកា មានន័យដូចម្តេចនៅក្នុងការអនុវត្តជាក់ស្តែង ។ ឧទាហរណ៍

- តើក្រុមប្រឹក្សា ជាពិសេសក្រុមប្រឹក្សាឃុំ សង្កាត់ អាចពិភាក្សាអំពីផែនការ និង ថវិការបស់ក្រសួង បានក្នុងកំរិតណា?
- តើគណៈកម្មាធិការសម្របសម្រួលបច្ចេកទេស ជម្រុញការកសាងផែនការពីក្រោមឡើងលើ ហើយ បង្កើនគណនេយ្យភាពរបស់ក្រសួងចំពោះប្រជាពលរដ្ឋយ៉ាងដូចម្តេច? ប្រសិនបើដូច្នេះមែន តើត្រូវធ្វើតាមរបៀបណា?
- តើត្រូវធ្វើយ៉ាងណា ប្រសិនបើផែនការកំណត់អាទិភាព ឬ គំរោងផ្ទុយគ្នា (ឧទាហរណ៍ ក្រុមប្រឹក្សាមានជំនឿថា ការបង្កើនលទ្ធភាពទទួលបានការអប់រំ តម្រូវឱ្យមានរថយន្តសម្រាប់ដឹកជញ្ជូនសិស្ស ។ ទោះជាយ៉ាងណាក៏ដោយ មន្ទីរអប់រំ គ្រោងសាងសង់សាលារៀនថែមទៀត ដើម្បីដោះស្រាយបញ្ហាដដែលនេះ)
- តើផែនការរបស់ក្រុមប្រឹក្សាផ្សេងទៀត និង ផែនការរបស់អង្គការសង្គមស៊ីវិល គួរត្រូវដាក់បញ្ចូលគ្នាឬទេ ? តាមរបៀបណា?

វាក៏អាចជាបញ្ហាផងដែរថាតើមន្ទីរ ឬការិយាល័យខ្សែបណ្តោយមានការចូលរួមកំរិតណានៅក្នុងការផ្តល់យោបល់ទាក់ទងកិច្ចការផ្ទៃក្នុងរបស់ក្រុមប្រឹក្សាដូចមានចែងនៅក្នុងអនុក្រឹត្យដូចជាៈ

- ការអភិវឌ្ឍប្រព័ន្ធ និងនីតិវិធីបំពេញការងារសម្រាប់អង្គភាពរបស់រដ្ឋបាលមួយ
- ការដោះស្រាយវិវាទទាក់ទងនឹងការបំពេញការងាររបស់អង្គភាពនៃរដ្ឋបាលមួយ
- ការអភិវឌ្ឍយន្តការពិគ្រោះយោបល់នៅក្នុងចំណោមក្រុមប្រឹក្សាជាប់ឆ្នោត
- ការសម្របសម្រួលដំណោះស្រាយចំពោះវិវាទនៅក្នុងចំណោមក្រុមប្រឹក្សាជាប់ឆ្នោត ។

## ផ្នែកទី ៤: គណៈកម្មាធិការលទ្ធកម្ម

**ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ**
**មាត្រា ១៣៦, ១៣៧**

- ✓ គ្រប់ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មានកាតព្វកិច្ចបង្កើតគណៈកម្មាធិការលទ្ធកម្ម (មាត្រា ១១៤ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ) ។
- ✓ គណៈកម្មាធិការលទ្ធកម្ម មានការទទួលខុសត្រូវ ដើម្បី**ធានាឱ្យបានថា សកម្មភាពលទ្ធកម្មទាំងអស់ ត្រូវប្រព្រឹត្តធ្វើឡើងប្រកបដោយភាពស្មោះត្រង់ តម្លាភាព និងមិនលំអៀង** និង អនុលោមតាមច្បាប់ស្តីពីលទ្ធកម្មសាធារណៈ (មាត្រា ១៣៦ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ) ។
- ✓ គោលបំណងរបស់គណៈកម្មាធិការលទ្ធកម្ម គឺត្រូវ **ការពារផលប្រយោជន៍របស់ក្រុមប្រឹក្សា និង ប្រជាពលរដ្ឋ** (មាត្រា ១៣៦ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ) ។
- ✓ នឹងមានលិខិតបទដ្ឋានដើម្បីកំណត់អំពីការបង្កើត ការរៀបចំ និង ការប្រព្រឹត្តិទៅរបស់គណៈកម្មាធិការលទ្ធកម្ម ។

**គណនេយ្យភាពរបស់ក្រុមប្រឹក្សាចំពោះលទ្ធកម្ម**

ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដែលមានលក្ខណៈច្បាស់លាស់ថា ក្រុមប្រឹក្សាមានគណនេយ្យភាពចំពោះប្រជាពលរដ្ឋអំពីរបៀបគ្រប់គ្រងកិច្ចការហិរញ្ញវត្ថុរបស់ខ្លួន រួមទាំងលទ្ធកម្ម (មាត្រា ៤៣, ១៣៦ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ) ។

ដូច្នេះជាការសំខាន់ណាស់ដែលគណៈកម្មាធិការលទ្ធកម្មត្រូវមានតម្លាភាព និង មានគណនេយ្យភាពចំពោះក្រុមប្រឹក្សា ។ បើមិនដូច្នេះទេ គណនេយ្យភាពរបស់ក្រុមប្រឹក្សាចំពោះប្រជាពលរដ្ឋ នឹងមិនអាចកើតមានឡើយ ។

# វគ្គទី ២៖

# មេរៀនសង្ខេប

- ក្រុមប្រឹក្សា តម្រូវឱ្យបង្កើតគណៈកម្មាធិការពិសេសចំនួនបីគឺ គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស និងគណៈកម្មាធិការលទ្ធកម្ម ។ ក្រុមប្រឹក្សាអាចបង្កើតគណៈកម្មាធិការបន្ថែមទៀតបានតាមតម្រូវការរបស់ក្រុមប្រឹក្សាដើម្បីជួយការងាររបស់ខ្លួន ។

- ក្រុមប្រឹក្សា អាចតែងតាំងសមាជិកក្រុមប្រឹក្សា អភិបាល អភិបាលរង ឬមន្ត្រីរបស់ក្រុមប្រឹក្សាជាសមាជិករបស់គណៈកម្មាធិការបន្ថែម។ ក្រុមប្រឹក្សា អាចតែងតាំងប្រជាពលរដ្ឋ ឬតំណាងរបស់សហគមន៍ឱ្យធ្វើជាទីប្រឹក្សារបស់គណៈកម្មាធិការ។ ត្រូវមានតំណាងរបស់ស្ត្រីនៅក្នុងគណៈកម្មាធិការរួមមានជាប្រធាន ឬអនុប្រធានរបស់គណៈកម្មាធិការ ។

- គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារមានការទទួលខុសត្រូវក្នុងការផ្តល់អនុសាសន៍ដល់ក្រុមប្រឹក្សា គណៈអភិបាល អភិបាល និងគណៈកម្មាធិការផ្សេងទៀតរបស់ក្រុមប្រឹក្សាដើម្បីធានាឱ្យបានថាបញ្ហារបស់ស្ត្រី និងកុមារ ត្រូវបានលើកយកមកពិចារណាជាប្រចាំ ។

- គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស ត្រូវដាក់បញ្ចូលទៅក្នុងផែនការអភិវឌ្ឍន៍ កម្មវិធីវិនិយោគបីឆ្នាំរំកិលក្របខ័ណ្ឌ ចំណាយ និងថវិការបស់ក្រុមប្រឹក្សានូវផែនការ និងថវិការបស់ក្រសួង ស្ថាប័ន មន្ទីរ និងអង្គភាពរបស់រដ្ឋាភិបាលដែលផ្តល់សេវានៅក្នុងដែនដីរបស់ក្រុមប្រឹក្សា។

- សមាជិករបស់គណៈកម្មាធិការសម្របសម្រួលបច្ចេកទេសមាន អភិបាល ប្រធានអង្គភាពរបស់ក្រុមប្រឹក្សា ប្រធានហិរញ្ញវត្ថុ ប្រធានមន្ទីរ និងអង្គភាពខ្សែបណ្តោយរបស់ក្រសួង និងស្ថាប័នរបស់រដ្ឋាភិបាលដែលផ្តល់សេវានៅក្នុងដែនដីរបស់ក្រុមប្រឹក្សា។

- គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស ជាអ្នកទំនាក់ទំនងយ៉ាងសំខាន់រវាងក្រសួងខ្សែបណ្តោយនៅថ្នាក់ជាតិ និងក្រុមប្រឹក្សានៅថ្នាក់ក្រោមជាតិ ។ គណៈកម្មាធិការសម្របសម្រួលបច្ចេកទេសត្រូវៈ
    - ធ្វើឱ្យក្រុមប្រឹក្សាមានលទ្ធភាពសម្របសម្រួលការអភិវឌ្ឍនៅក្នុងចំណោមវិស័យនានានៅក្នុងដែនដីរបស់ខ្លួន(សមាហរណកម្មតាមវិស័យ)
    - ផ្តល់យន្តការសម្រាប់ឱ្យក្រុមប្រឹក្សាពិភាក្សាជាមួយក្រសួងខ្សែបណ្តោយលើអាទិភាព សកម្មភាព និងថវិកានៅក្នុងតំបន់។

- គណៈកម្មាធិការលទ្ធកម្មមានការទទួលខុសត្រូវក្នុងការធានាអោយបានថា សកម្មភាពលទ្ធកម្មទាំងអស់ត្រូវប្រព្រឹត្តិទៅដោយមានភាពស្មោះត្រង់ មានតម្លាភាព និងមិនលំអៀង និងអនុលោមទៅតាមច្បាប់ស្តីពីលទ្ធកម្មសាធារណៈ ។

# វគ្គទី ៣:

# ការងារជាក្រុម

**ការងារជាក្រុម ដូចមានពិពណ៌នាខាងក្រោម អាចមានលក្ខណៈមិនសមស្របសម្រាប់ការបណ្តុះបណ្តាលទាំងអស់ ។ សូមចាត់ទុកការងារជាក្រុមខាងក្រោមជាសំណូមពរតែប៉ុណ្ណោះ ។**

១. ចែកសិក្ខាកាមជាក្រុមដែលមានសមាជិកមិនលើសពី៨ នាក់ ។

២. ផ្តល់លំហាត់ខាងក្រោមដល់ក្រុមនីមួយៗ ។

**លំហាត់ទី ១:** គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និង កុមារ

ក្រុមប្រឹក្សាស្រុកសុខាពីប កំពុងរៀបចំផែនការអំពីរបៀបគាំទ្រគ្លីនិកសុខភាពស្រុក ។

អោយសមាជិករបស់ក្រុម ដើរតួដូចក្រោម:

- សមាជិកក្រុមប្រឹក្សាចំនួន ៤ រូប
- អភិបាលស្រុក ១ រូប
- សមាជិកគណៈកម្មាធិការសុខភាពរបស់ក្រុមប្រឹក្សា ១ រូប ដែលជាឆ្មប
- សមាជិកគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារពីររូប ។

សមាជិកក្រុមប្រឹក្សាស្រុកចំនួន ៤ រូបមានផែនការប្រគល់ថវិកាសុខភាពជាច្រើនរបស់ខ្លួនទៅលើសេវាបង្ការ និងព្យាបាលជំងឺអេដស៍។ អភិបាលស្រុកក៏បានផ្តល់សំណូមពរផងដែរថាអាចចំណាយមូលនិធិទៅលើយុទ្ធនាការផ្សព្វផ្សាយសាធារណៈអំពីជំងឺរបេង និងការព្យាបាលជំងឺរបេង។ សមាជិកក្រុមប្រឹក្សា និងអភិបាលស្រុក ជឿថាការងារនេះ គឺជាបញ្ហាសុខភាពយ៉ាងសំខាន់នៅក្នុងស្រុក ។

ឆ្មប និងសមាជិកពីរនាក់របស់គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារមិនឯកភាព។ ពួកគាត់មានអារម្មណ៍ថា មានតម្រូវការជាខ្លាំងក្នុងការដាក់ឱ្យអនុវត្តកម្មវិធីចាក់ថ្នាំបង្ការកុមារ ។ គាត់គិតថា ការផ្តល់ការ

ចាក់ថ្នាំបង្ការ និងការពារកុមារមិនឱ្យមានជំងឺជាច្រើនប្រភេទនៅពេលខាងមុខ។ ឆ្មប និងសមាជិករបស់គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារក៏មានជំនឿងផងដែរថា មានតម្រូវការខ្លាំងក្នុងការឱ្យមានឆ្មបច្រើនថែមទៀត។ ស្ត្រីមួយចំនួននៅក្នុងស្រុកបានទទួលមរណភាពនៅពេលថ្មីៗនេះនៅពេលសំរាលកូនដោយសារឆ្មប ដែលមានការបណ្តុះបណ្តាលមិនមានគ្រប់ចំនួន។

ឱ្យធ្វើការដើរតួនៅក្នុងកិច្ចប្រជុំរបស់ក្រុមប្រឹក្សាស្រុក ដោយប្រធានបទសម្រាប់ការពិភាក្សា គឺតើថវិកាសុខាភិបាលរបស់ក្រុមប្រឹក្សាគួរផ្តល់អាទិភាពទៅលើអ្វី?

ការដើរតួមានបំណងឆ្លុះបញ្ចាំងអំពីសារៈសំខាន់របស់គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ។

**លំហាត់ទី ២: គណៈកម្មាធិការលទ្ធកម្ម**

រៀបកៅអី ៥ ជារង្វង់តូចមួយ។ ឱ្យអ្នកស្ម័គ្រចិត្ត ៤នាក់មកអង្គុយលើកៅអី ៤។ ទុកកៅអី១ឱ្យនៅទំនេរ។

អ្នកស្ម័គ្រចិត្តទាំង ៤ នឹងពិភាក្សាសំណួរមួយ ឬច្រើនជាង ១ ដូចមានខាងក្រោម។

ប្រសិនបើអ្នកស្ម័គ្រចិត្ត មានបំណងចាកចេញពីការពិភាក្សា គាត់ត្រូវអញ្ជើញអ្នកជំនួសឱ្យមកចូលរួមនៅក្នុងការពិភាក្សា ។

កៅអីទំនេត្រូវទុកឱ្យអ្នកដែលចង់ចូលរួមនៅក្នុងការពិភាក្សា (ទោះបីជាមិនត្រូវបានអញ្ជើញក្តី)។

បទបញ្ជា: ត្រូវមានមនុស្សអង្គុយនៅលើកៅអីយ៉ាងហោចណាស់ ៤ នៅគ្រប់ពេលទាំងអស់ (កៅអីទំនេរមិនត្រូវលើសពី ១)

**សំណួរពិភាក្សា:**

- តើអ្នកគិតថា អ្នកណាខ្លះគួរជាសមាជិករបស់គណៈកម្មាធិការលទ្ធកម្ម ហេតុអ្វី?
- តើក្រុមប្រឹក្សា អាចធានាឱ្យមានការត្រួតពិនិត្យលើគណៈកម្មាធិការលទ្ធកម្មតាមវិធីណា?

# មេរៀនសម្រាប់ការយល់ដឹង និង
# ការបណ្តុះបណ្តាលអំពី
# ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល រាជធានី
# ខេត្ត ក្រុង ស្រុក ខណ្ឌ

## មេរៀនទី ៨:
## បុគ្គលិករបស់ក្រុមប្រឹក្សា

## វគ្គទី ១:

១. សេចក្តីផ្តើម

២. បុគ្គលិករបស់ក្រុមប្រឹក្សា

៣. អង្គភាពរបស់ក្រុមប្រឹក្សា

៤. គណនេយ្យភាពរបស់បុគ្គលិក និងអង្គភាពបុគ្គលិក

៥. ការកែសម្រួលរៀបចំបុគ្គលិកឡើងវិញ

## ផ្នែកទី ១: សេចក្តីផ្តើម

✓ បន្ទាប់ពីការបោះឆ្នោតនៅខែឧសភា ឆ្នាំ២០០៩ ក្រុមប្រឹក្សាថ្មីនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបង្កើតឡើងនៅរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ (មាត្រា ២៧៧ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ)។ ជំហានដំបូងនៅក្នុងកាបង្កើតរដ្ឋបាលថ្មី គឺ**កាផ្ទេរដល់ក្រុមប្រឹក្សាថ្មីនូវអង្គភាព បុគ្គលិក និងមុខងាររដ្ឋបាល**របស់រដ្ឋបាលពីមុននៅរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ (មាត្រា ២៨១ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មាត្រា ៧ នៃប្រកាស ១២៤៩ ស្តីពីកិច្ចប្រជុំចូលកាន់តំណែង)។

**រដ្ឋបាលនៅថ្នាក់ក្រោមជាតិ**

រដ្ឋបាលនៅថ្នាក់ក្រោមជាតិ សំដៅលើក្រុមប្រឹក្សា និងគណៈអភិបាលរបស់ក្រុមប្រឹក្សា។

(មាត្រា ២ នៃអនុក្រឹត្យស្តីពីតួនាទីខេត្ត)

✓ តាមរយៈការផ្ទេរអង្គភាព បុគ្គលិក និងមុខងាររដ្ឋបាលដែលមានស្រាប់ដល់ក្រុមប្រឹក្សាថ្មី និរន្តរភាពការងារដោយមានភាពរលូន គួរមាននៅក្នុងវិស័យទាំងអស់ **ដោយចៀសវាងការផ្អាកមិនសមស្រប**នៅក្នុងសេវារបស់រដ្ឋបាល និងសកម្មភាពរបស់ដៃគូអភិវឌ្ឍ (ជំពូក ២ ក្របខ័ណ្ឌអនុវត្តបឋមគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ)។

**ឧទាហរណ៍ - បរិស្ថាន**

ក្រុង ទទួលបានការទទួលខុសត្រូវលើការគ្រប់គ្រងកាកសំណល់នៅក្នុងមូលដ្ឋានរបស់ខ្លួន ។ ដើម្បីសំរេចបានការទទួលខុសត្រូវនេះ ក្រុងត្រូវមានៈ

- *ហិរញ្ញវត្ថុ* ដើម្បីផ្តល់សេវា រួមមាន ការចំណាយរដ្ឋបាល (ដូចជាប្រាក់បៀវត្ស) ចំណាយប្រតិបត្តិការសម្រាប់ការផ្តល់សេវា ការចំណាយទុនការថែទាំជាប្រចាំ និង ការចំណាយផ្សេងៗ ។
- ***បុគ្គលិក* សម្រាប់រដ្ឋបាល**។ បុគ្គលិកទាំងនេះ អាចយកមកពីមន្ទីរ ដែលពីមុនមកមានការទទួលខុសត្រូវលើការងារនេះ ។ ចុះលើវិនិយោគក្រុង នឹងទទួលបានប្រាក់បៀវត្សសម្រាប់បើកឱ្យអ្នកប្រមូលសំរាម អ្នកបើកបរ កម្មករនៅកន្លែងចាក់សំរាម ។
- ***ទ្រព្យសម្បត្តិ*** ឧទាហរណ៍ ដីសម្រាប់ចាក់សំរាម និងរថយន្តដឹកសំរាម ។

✓ នៅឆ្នាំខាងមុខ គ្រប់ក្រុមប្រឹក្សានឹងទទួលបានបុគ្គលិកបន្ថែម នៅពេលក្រុមប្រឹក្សាទទួលមុខងារថ្មីពីថ្នាក់ជាតិ។ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ចែងថា

ការផ្ទេរមុខងារថ្មីត្រូវប្រព្រឹត្តិទៅជាមួយនឹង**ការផ្ទេរធនធាន** រួមទាំងចំណូល ហិរញ្ញវត្ថុ **បុគ្គលិក** ទ្រព្យសម្បត្តិ និងសមត្ថភាពសម្រាប់គ្រប់គ្រង និងអនុវត្តមុខងារនីមួយៗ (មាត្រា ២០០ នៃច្បាប់ស្តីពីការ គ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ) ។

## ផ្នែកទី ២: បុគ្គលិករបស់ក្រុមប្រឹក្សា

**ច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ**

**មាត្រា ១៦២, ១៧៣-១៨៨, ២៦២**

> ចំពោះព័ត៌មានបន្ថែមស្ដីពីរដ្ឋបាលឯកភាព សូមអានមេរៀនទី ៤

- ✓ ច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ចែងថា ថ្នាក់ក្រោមជាតិទាំងអស់ ត្រូវគ្រប់គ្រងអនុលោមទៅតាមគោលការណ៍នៃ**រដ្ឋបាលឯកភាព** ( មាត្រា ២ នៃច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ) ។
- ✓ គោលការណ៍មួយនៃរដ្ឋបាលឯកភាព គឺថាក្រុមប្រឹក្សានីមួយៗ មាន**បុគ្គលិករបស់ខ្លួនផ្ទាល់** ដែលមានសមត្ថភាព ដើម្បី
  - ○ អនុវត្ត**សេចក្ដីសម្រេច និងដីកា**របស់ក្រុមប្រឹក្សា
  - ○ អនុវត្ត ឬសម្របសម្រួល**សកម្មភាពរបស់ក្រុមប្រឹក្សា**
  - ○ ជួយក្រុមប្រឹក្សាឱ្យដឹកនាំ**រដ្ឋបាលឯកភាព**នៅក្នុងដែនដីរបស់ខ្លួន ។
- ✓ ក្រុមប្រឹក្សា ក៏មានការទទួលខុសត្រូវផងដែរក្នុងការធានាថា ក្រុមប្រឹក្សា មាន**ព័ត៌មាន និងភស្តុតាងប្រកបដោយគុណភាពដែលក្រុមប្រឹក្សាអាចធ្វើជាបង្អែកចំពោះសេចក្ដីសម្រេចរបស់ខ្លួន**។ ដូច្នេះ អង្គភាពរដ្ឋបាលមានការទទួលខុសត្រូវចំពោះការរៀបចំការសិក្សា និងការស្រាវជ្រាវ និងចំពោះការផ្ដល់មតិយោបល់ដល់អភិបាលដែលបន្ទាប់មកផ្ដល់ព័ត៌មានជាបន្តដល់ក្រុមប្រឹក្សា ( មាត្រា ១៣, ២៣, ៣២ នៃប្រកាសស្ដីពីការបង្កើតការិយាល័យខេត្ត) ។

### ប្រភពបុគ្គលិក

- ✓ ក្រុមប្រឹក្សាទាំងអស់ មាន**បុគ្គលិករបស់ខ្លួនផ្ទាល់**។ បុគ្គលិករបស់ក្រុមប្រឹក្សា អនុវត្តមុខងារ និងការងារប្រចាំថ្ងៃរបស់ក្រុមប្រឹក្សា ( មាត្រា ១៧៣, ១៨២ នៃច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ) ។
- ✓ បុគ្គលិកមួយចំនួនរបស់ក្រុមប្រឹក្សា **ត្រូវតែងតាំងដោយក្រុមប្រឹក្សា**។ ក្រុមប្រឹក្សា មានសិទ្ធិជ្រើសរើសបុគ្គលិកទៅតាមការចាំបាច់ ( មាត្រា ១៧៣, ១៧៦, ១៧៧ នៃច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ) ។

✓ បុគ្គលិកមួយចំនួន **ត្រូវតែងតាំងឱ្យបំពេញការងារជាមួយក្រុមប្រឹក្សា** ។ ក្រសួងមហាផ្ទៃ ចាត់តាំង**នាយករដ្ឋបាល**ឱ្យបំពេញការងារជាមួយក្រុមប្រឹក្សានីមួយៗ (មាត្រា ១៧៣, ១៨៣ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ) ។

✓ បុគ្គលិកមួយចំនួន **ត្រូវកែសម្រួលរៀបចំឡើងវិញ**ពីក្រសួង និងស្ថាប័នផ្សេងទៀតរបស់រដ្ឋាភិបាល ។ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ចែងថា នៅពេលមុខងារជំនាញ ត្រូវផ្ទេរឱ្យក្រុមប្រឹក្សា **បុគ្គលិកជំនាញ**ដែលបានបំពេញមុខងារនោះរួចហើយ ត្រូវផ្ទេរ (កែសម្រួលរៀបចំឡើងវិញ) ដើម្បីឱ្យក្លាយទៅជាបុគ្គលិករបស់ក្រុមប្រឹក្សា ។

✓ បុគ្គលិកដែលត្រូវកែសម្រួលរៀបចំឡើងវិញឱ្យក្រុមប្រឹក្សា ត្រូវផ្ទេរក្របខ័ណ្ឌ ចេញពីក្របខ័ណ្ឌបច្ចុប្បន្នរបស់ខ្លួនទៅជាបុគ្គលិករបស់ក្រុមប្រឹក្សា (មាត្រា២៦២ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ) ។

✓ បុគ្គលិកក្រសួងមហាផ្ទៃដែលបានបំពេញការងារនៅក្នុងរដ្ឋបាលថ្នាក់ក្រោមជាតិពីមុនមក គឺជា**ឧទាហរណ៍នៃបុគ្គលិកដែលត្រូវរៀបចំកែសម្រួលឡើងវិញ** ។ បុគ្គលិកទាំងនោះ ត្រូវបានផ្ទេរឱ្យរដ្ឋបាលថ្មីនៅថ្នាក់ក្រោមជាតិ ។

### ប្រភពទាំងបីនៃបុគ្គលិករបស់ក្រុមប្រឹក្សា



**បុគ្គលិកបំពេញការងារសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងសណ្តាប់ធ្នាប់សង្គម**

បុគ្គលិកដែលមានការទទួលខុសត្រូវលើការងារសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងរបៀបរៀបរយសង្គម ច្បាប់ និងសិទ្ធិមនុស្សនៅតែជាបុគ្គលិករបស់ក្រសួងពាក់ព័ន្ធ។

ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ បញ្ជាក់ថា បុគ្គលិករបស់ក្រុមប្រឹក្សា មិនរាប់បញ្ចូលមន្ត្រីរបស់ក្រសួង ស្ថាប័ន មន្ទីរ និងអង្គភាពរបស់រាជរដ្ឋាភិបាល ឬមន្ត្រីផ្សេងទៀតដែលមានភារកិច្ចពាក់ព័ន្ធនឹងសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងសណ្តាប់ធ្នាប់សង្គម ច្បាប់ និងសិទ្ធិមនុស្សក្នុងនាមរាជរដ្ឋាភិបាល (មាត្រា ១៧៥ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ)។

## ការគ្រប់គ្រងបុគ្គលិក

- ✓ ក្រុមប្រឹក្សា មាន**សិទ្ធិអំណាចទូលំទូលាយនៅក្នុងការគ្រប់គ្រងបុគ្គលិករបស់ខ្លួន** (មាត្រា ៣៦, ១៧៤, ១៧៧, ១៧៨, ១៨២, ១៨៤ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ)។
- ✓ ក្រុមប្រឹក្សា ធ្វើសេចក្តីសំរេចលើ**ការតែងតាំង ការបញ្ឈប់ការងារ ការកំណត់កាំប្រាក់បៀវត្ស** និង **ផលប្រយោជន៍**ផ្សេងទៀតសម្រាប់មុខតំណែងរបស់បុគ្គលិក។ សេចក្តីសំរេច ត្រូវធ្វើឡើងអនុលោមទៅតាមលក្ខន្តិកៈសម្រាប់បុគ្គលិកនៅថ្នាក់ក្រោមជាតិ។ លក្ខន្តិកៈសម្រាប់បុគ្គលិកនៅថ្នាក់ក្រោមជាតិ មិនទាន់បានរៀបចំនៅឡើយ (មាត្រា ១៧៦, ១៧៧, ២៦៤ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ)។
- ✓ **គណៈអភិបាល ត្រូវផ្តល់យោបល់ដល់ក្រុមប្រឹក្សា**អំពី
  - **ការតែងតាំង ការតំឡើងឋានៈ និងការបញ្ឈប់ការងារ**បុគ្គលិករបស់ក្រុមប្រឹក្សា
  - ការកំណត់ការទទួលខុសត្រូវ និងការរៀបចំ**ល័ក្ខខ័ណ្ឌការងារ**របស់បុគ្គលិក
  - ការរៀបចំយុទ្ធសាស្ត្រ**ការអភិវឌ្ឍសមត្ថភាព**សម្រាប់បុគ្គលិករបស់ក្រុមប្រឹក្សា

(មាត្រា ១៦២ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ)។

✓ **ការជ្រើសរើស** និង ការតែងតាំងបុគ្គលិកដោយក្រុមប្រឹក្សា ត្រូវដំណើរការតាមការប្រកួតប្រជែងដែលមានតម្លាភាព ( មាត្រា ១៧៦ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ) ។

✓ ការជ្រើសរើស និង ការតែងតាំងបុគ្គលិករបស់ក្រុមប្រឹក្សា ត្រូវធានាឱ្យមាន**ចំនួនស្ត្រី**សមស្របនៅក្នុងមុខតំណែងជាប្រធាន ឬ អនុប្រធានអង្គភាព និង បុគ្គលិករបស់ក្រុមប្រឹក្សា ( មាត្រា ១៧៦ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ) ។

✓ រដ្ឋបាលខេត្ត មានផ្នែកគ្រប់គ្រងធនធានមនុស្ស ។ ផ្នែកនេះ មានការទទួលខុសត្រូវចំពោះការងារបុគ្គលិករបស់ក្រុមប្រឹក្សាខេត្ត និងចំពោះការគាំទ្រក្រុង និងស្រុកក្នុងការគ្រប់គ្រងបុគ្គលិករបស់ខ្លួន ( មាត្រា ៦ នៃប្រកាសស្តីពីការបង្កើតការិយាល័យ-ខេត្ត) ។

**នាយករដ្ឋបាល**

✓ ក្រុមក្រុមប្រឹក្សា មាននាយករដ្ឋបាលមួយរូប និងនាយករងរដ្ឋបាលយ៉ាងច្រើនពីររូប ដែលត្រូវតែងតាំងដោយក្រសួងមហាផ្ទៃឱ្យបំពេញការងារជាមួយក្រុមប្រឹក្សា។ នាយករដ្ឋបាល និងនាយករងរដ្ឋបាលពីររូប**ត្រូវបានតែងតាំងដោយក្រសួងមហាផ្ទៃ** តាមសំណើរបស់អភិបាល និងមានការឯកភាពីក្រុមប្រឹក្សា ( មាត្រា ១៨៣ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មាត្រា ៤២. ៩៩. ១៦០ នៃអនុក្រឹត្យលេខ ២១៦ អនក្រ. បក ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក) ។

✓ នាយករដ្ឋបាល មានតួនាទីជា**ជំនួយការក្នុងការចាត់ចែងកិច្ចការរដ្ឋបាល និង បុគ្គលិករបស់ក្រុមប្រឹក្សា**។ នាយករដ្ឋបាល ក៏ត្រូវធានានិរន្តរភាពកិច្ចការរដ្ឋបាលប្រចាំថ្ងៃរបស់ក្រុមប្រឹក្សា និងគណៈអភិបាលផងដែរ ។ ( មាត្រា ១៨៤ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មាត្រា ៤៧. ១០៤. ១៦៤ នៃអនុក្រឹត្យលេខ២១៦ អនក្រ. បក ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក) ។

- ✓ នាយករដ្ឋបាល ផ្តល់**យោបល់បច្ចេកទេស**ដល់ក្រុមប្រឹក្សា និងគណៈអភិបាលក្នុងទម្រង់ជាសេចក្តីអធិប្បាយ។ ឧទាហរណ៍ នាយករដ្ឋបាល អាចផ្តល់សេចក្តីអធិប្បាយថា ចំពោះមិនស្របទៅនឹងលិខិតបទដ្ឋានជាធរមាន (មាត្រា ១៨៥ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មាត្រា ៤៧, ១០៤, ១៦៤ នៃអនុក្រឹត្យលេខ២១៦ អនក្រ.បក ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក)។

- ✓ គណៈអភិបាល ដឹកនាំ និងណែនាំនាយករដ្ឋបាលក្នុងការ**ប្រគល់ភារកិច្ចដល់អង្គភាព**របស់រដ្ឋបាល (ប្រការ ១៣, ២៣, ៣២ នៃប្រកាសលេខ៤២៧៤ ប្រក. ស្តីពីការបង្កើតការិយាល័យចំណុះទីចាត់ការនៃសាលាខេត្ត ការបង្កើតការិយាល័យនៃសាលាក្រុង ការបង្កើតការិយាល័យនៃសាលាស្រុក និងការកំណត់តួនាទី ភារកិច្ច របៀបរបបការងារនៃការិយាល័យទាំងនោះ)។

- ✓ **ប្រធានអង្គភាព**របស់រដ្ឋបាលថ្នាក់ក្រោមជាតិ រាយការណ៍ និងមានគណនេយ្យភាពដោយផ្ទាល់ចំពោះនាយករដ្ឋបាល (មាត្រា ១៧៨ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មាត្រា ៥៦, ១១២, ១៧៣ នៃអនុក្រឹត្យលេខ២១៦ អនក្រ.បក ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក)។

- ✓ នាយករដ្ឋបាល ត្រូវមាន**គណនេយ្យភាពចំពោះក្រុមប្រឹក្សា និង គណៈអភិបាល** (មាត្រា ១៨៤ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ)។

- ✓ នាយករដ្ឋបាល មានភារកិច្ចជាក់លាក់ដូចខាងក្រោម:
    - **រៀបចំការងារប្រចាំថ្ងៃ**អនុលោមទៅតាមច្បាប់ និងលិខិតបទដ្ឋានជាធរមានសម្រាប់ការពិនិត្យមើលដាក់ជូនគណៈអភិបាល ដើម្បីពិនិត្យ និងសម្រេច
    - ផ្តល់សេចក្តីអធិប្បាយក្រុមប្រឹក្សា គណៈកម្មាធិការរបស់ក្រុមប្រឹក្សា និងគណៈអភិបាល ដើម្បីគ្រប់គ្រង **ការងារប្រចាំថ្ងៃ** របស់ក្រុមប្រឹក្សា និងគណៈអភិបាល
    - ជួយគណៈអភិបាល ដើម្បី**រាយការណ៍ជូនក្រុមប្រឹក្សា**
    - រៀបចំវិធាន និងគោលការណ៍សម្រាប់**អនុវត្តដីកា និងសេចក្តីសម្រេច**របស់ក្រុមប្រឹក្សា

- ផ្តល់**ការគាំទ្រ**ផ្នែកច្បាប់ បច្ចេកទេស និងការគាំទ្រចាំបាច់ផ្សេងទៀតសម្រាប់រៀបចំ**សេចក្តីព្រាងដីកា និងសេចក្តីសម្រេច**
- ធានាថា បុគ្គលិករបស់ក្រុមប្រឹក្សា**អនុវត្តសេចក្តីសម្រេច និងដីកា**របស់ក្រុមប្រឹក្សា
- ធានាថា **ប្រធានហិរញ្ញវត្ថុ**បំពេញការងាររបស់ខ្លួនបានត្រឹមត្រូវ
- ធ្វើជា**លេខាធិការរបស់អភិបាល និងប្រធានក្រុមប្រឹក្សា** រួមមានការរៀបចំសេចក្តីព្រាងរបៀបវារៈ និងឯកសារសម្រាប់ការប្រជុំរបស់ក្រុមប្រឹក្សាដែលត្រូវឯកភាពដោយគណៈអភិបាល ហើយបន្ទាប់មកដោយក្រុមប្រឹក្សា
- ធ្វើជាលេខាធិការរបស់ក្រុមប្រឹក្សាសម្រាប់រៀបចំ និងចែកចាយលិខិតអញ្ជើញចូលរួមប្រជុំ កន្លែងប្រជុំ និងធ្វើកំណត់ហេតុប្រជុំ
- ធ្វើការរៀបចំចាំបាច់សម្រាប់ការប្រជុំរបស់គណៈអភិបាល
- ធានាថា លិខិត និងឯកសារត្រូវបានបែងចែកសមស្របដល់សមាជិកក្រុមប្រឹក្សា អភិបាល និងអភិបាលរង ក៏ដូចជាក្រសួង មន្ទីរ អង្គភាព និងអ្នកពាក់ព័ន្ធផ្សេងទៀត
- ធានាថែរក្សាឯកសារ និងលិខិតបទដ្ឋានទាំងអស់ឱ្យបានត្រឹមត្រូវ
- បំពេញភារកិច្ចផ្សេងទៀតដែលបានប្រគល់ដោយក្រុមប្រឹក្សា គណៈអភិបាល ឬដោយច្បាប់ ឬលិខិតបទដ្ឋាន។

(មាត្រា ១៨៥-១៨៧ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មាត្រា ១២, ៤៥, ៦៨, ៩៦, ១០២, ១០៥, ១៣០, ១៥៧, ១៦៣ នៃអនុក្រឹត្យលេខ២១៦ អនក្រ.បក ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក)។

✓ **គណៈអភិបាល អាចធ្វើប្រតិភូកម្មការងារទៅនាយករដ្ឋបាល**។ អភិបាល ដោយពាក់មុខជាតំណាងរបស់រាជរដ្ឋាភិបាល ក៏អាចធ្វើប្រតិភូកម្មភារកិច្ចទៅនាយករដ្ឋបាលផងដែរ។

- ✓ ទោះជាយ៉ាងណាក៏ដោយ នាយករដ្ឋបាល មិនគ្រាន់តែអនុវត្តសេចក្តីសំរេចរបស់ក្រុមប្រឹក្សា និង គណៈអភិបាល ប៉ុណ្ណោះទេ គាត់ថែមទាំងដើរតួនាទីយ៉ាងសកម្មនៅក្នុងរដ្ឋបាលថ្មីផងដែរ ។ ( មាត្រា ១៨៦ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មាត្រា ៤៩, ១០៦, ១៦៧ នៃអនុក្រឹត្យលេខ២១៦ អនក្រ. បក ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក) ។

- ✓ នាយករដ្ឋបាល **មានសិទ្ធិចូលរួម និង មានយោបល់នៅក្នុងកិច្ចប្រជុំ**របស់ក្រុមប្រឹក្សា កិច្ចប្រជុំគណៈកម្មាធិការ និង អនុកម្មាធិការរបស់ក្រុមប្រឹក្សា និងកិច្ចប្រជុំរបស់គណៈអភិបាល ។ ទោះជាយ៉ាងណាក៏ដោយ នាយករដ្ឋបាល មិនបោះឆ្នោតនៅក្នុងកិច្ចប្រជុំទាំងនោះឡើយ លើកលែងតែពេលនាយករដ្ឋបាល ត្រូវបានតែងតាំងជាសមាជិកគណៈ-កម្មាធិការ ឬអនុគណៈកម្មាធិការរបស់ក្រុមប្រឹក្សា ( មាត្រា ៤៦, ១០៣, ១៦៣ នៃអនុក្រឹត្យលេខ២១៦ អនក្រ.បក ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក) ។

**ប្រធានហិរញ្ញវត្ថុ**

- ✓ រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ ត្រូវមានប្រធានហិរញ្ញវត្ថុមួយរូប ។ ប្រធានហិរញ្ញវត្ថុនេះ ត្រូវបានតែងតាំងដោយក្រុមប្រឹក្សា បន្ទាប់ពីមានការយល់ព្រមពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ( មាត្រា ១៧៩ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ) ។

- ✓ ប្រធានហិរញ្ញវត្ថុ មានការទទួលខុសត្រូវក្នុងការគ្រប់គ្រងហិរញ្ញវត្ថុ និងការងារលទ្ធកម្មរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ។ ប្រធានហិរញ្ញវត្ថុ ធានាដល់ការធ្វើសវនកម្មឱ្យបានត្រឹមត្រូវស្របតាមច្បាប់នេះ និងលិខិតបទដ្ឋានជាធរមានផ្សេងទៀត ( មាត្រា ១៨០ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ) ។

## ផ្នែកទី ៣: អង្គភាពបុគ្គលិករបស់ក្រុមប្រឹក្សា

**ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ខណ្ឌ**

**មាត្រា ១៨៩, ២៧៧**

✓ ក្រុមប្រឹក្សានីមួយៗ មានអង្គភាពបុគ្គលិក។ ក្រុមប្រឹក្សានីមួយៗ បង្កើត**អង្គភាពបុគ្គលិករបស់ខ្លួនផ្ទាល់**ទៅតាមការចាំបាច់ ( មាត្រា ១៨៩ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ) ។ អង្គភាពបុគ្គលិកសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ ត្រូវបានពិភាក្សានៅក្នុងមេរៀនទី ១១។

✓ អង្គភាពបុគ្គលិកមួយចំនួន គឺអង្គភាពដែលត្រូវអនុវត្តមុខងាររដ្ឋបាលស្នូល នឹងត្រូវបង្កើតឡើងភ្លាមបន្ទាប់ពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាថ្មី។ ឧទាហរណ៍ អង្គភាពហិរញ្ញវត្ថុ និងអង្គភាពសង្គមកិច្ចដែលមានរួចហើយក្រោមរដ្ឋបាលពីមុន ត្រូវបានធ្វើសមាហរណកម្មទៅក្នុងរចនាសម្ព័ន្ធថ្មីនៃរដ្ឋបាលនៅថ្នាក់ក្រោមជាតិថ្មី។ ដូច្នេះអង្គភាពហិរញ្ញវត្ថុរបស់រដ្ឋបាលពីមុននៅស្រុកបាត់ដំបង ត្រូវបានធ្វើសមាហរណកម្មទៅការិយាល័យក្នុងរដ្ឋបាល និងការិយាល័យហិរញ្ញវត្ថុថ្មីរបស់ក្រុងបាត់ដំបង ( មាត្រា ២៧៧ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ) ។

✓ អង្គភាពរបស់រដ្ឋបាលខេត្ត ក្រុង និងស្រុក មានការទទួលខុសត្រូវក្នុងការជួយគណៈអភិបាលដើម្បីអនុវត្តការទទួលខុសត្រូវរបស់ខ្លួន។ ឧទាហរណ៍ **ទីចាត់ចារផែនការ និងវិនិយោគ**ខេត្តត្រូវទទួលខុសត្រូវក្នុងដំណើរការរៀបចំផែនការអភិវឌ្ឍ និងកម្មវិធីវិនិយោគខេត្តសាម៉ី និងទទួលខុសត្រូវក្នុងការអនុវត្តស្របតាមនិតិវិធី ផ្តល់អនុសាសន៍ដល់អភិបាលអំពី**និត្យានុកូលភាព ត្រូវពិនិត្យនីតិវិធីកសាងផែនការអភិវឌ្ឍ**របស់ក្រុង ស្រុក ឃុំ និងសង្កាត់ (ប្រការ ៤ នៃប្រកាសលេខ៤២៧៤ ប្រក. ស្តីពីការបង្កើតការិយាល័យចំណុះទីចាត់ការនៃសាលខេត្ត ការបង្កើតការិយាល័យនៃសាសាក្រុង ការបង្កើតការិយាល័យនៃសាលាស្រុក និងការកំណត់តួនាទី ភារកិច្ច របៀបរបបការងារនៃការិយាល័យទាំងនោះ ) ។

✓ ជាងនេះទៀត អង្គភាពបុគ្គលិកដែលបានបង្កើតឡើង។ ក៏អាចមានការពាក់ព័ន្ធនឹងមុខងារតាមវិស័យ ដែលត្រូវផ្ទេរដល់ក្រុមប្រឹក្សាថ្មី។ ឧទាហរណ៍ ប្រសិនបើមុខងារសុខាភិបាលត្រូវផ្ទេរឱ្យស្រុកក្រុមប្រឹក្សាស្រុកអាចចាត់អោយមានការពិភាក្សាដើម្បីបង្កើតអោយមានអង្គភាពថ្មីមួយទទួលការងារនេះ ឬដាក់បញ្ចូលការងារនេះនៅក្នុងអង្គភាពណាមួយដែលសមស្រប។ អង្គភាព និងបុគ្គលិកមានការងារដើម្បីជួយគណៈអភិបាលក្នុងការពិភាក្សាលើបញ្ហានេះ។

## ផ្នែកទី ៤: គណនេយ្យភាពរបស់បុគ្គលិក និងអង្គភាពបុគ្គលិក

**ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ខណ្ឌ**

**មាត្រា ១៧៤, ១៧៨, ១៨២, ១៩០, ១៩១**

✓ **បុគ្គលិកទាំងអស់របស់ក្រុមប្រឹក្សា មានគណនេយ្យភាពចំពោះក្រុមប្រឹក្សា** (មាត្រា ១៧៤, ១៩០ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ)។

- បុគ្គលិកទាំងអស់របស់ក្រុមប្រឹក្សាមានការទទួលខុសត្រូវ និងមានគណនេយ្យភាពដោយផ្ទាល់ចំពោះប្រធានគ្រប់គ្រងផ្ទាល់របស់ខ្លួន និងត្រូវមានការទទួលខុសត្រូវ និងគណនេយ្យភាពដោយប្រយោលចំពោះនាយករដ្ឋបាល អភិបាល គណៈអភិបាល និងក្រុមប្រឹក្សា**តាមឋានានុក្រម** (មាត្រា ១៧៤, ១៧៨, ១៩០ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ប្រការ ១០, ២១, ៣០ នៃប្រកាសលេខ៤២៧៤ ប្រក. ស្តីពីការបង្កើតការិយាល័យចំណុះទីចាត់ការនៃសាលខេត្ត ការបង្កើតការិយាល័យនៃសាលាក្រុង ការបង្កើតការិយាល័យនៃសាលាស្រុក និងការកំណត់តួនាទី ភារកិច្ច របៀបរបបការងារនៃការិយាល័យទាំងនោះ)
- បុគ្គលិក និងអង្គភាពបុគ្គលិក ត្រូវស្ថិតនៅក្រោមការទទួលខុសត្រូវ ការត្រួតពិនិត្យ និងការគ្រប់គ្រងផ្ទាល់របស់**គណៈអភិបាលក្នុងនាមក្រុមប្រឹក្សា** (មាត្រា ១៧៤, ១៩០ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ)។

✓ ក្រៅពីនេះ បុគ្គលិករបស់ក្រុមប្រឹក្សា បំពេញការងារប្រចាំថ្ងៃរបស់ខ្លួនដើម្បីអនុវត្តសេចក្តីសម្រេចរបស់ក្រុមប្រឹក្សា និងគណៈអភិបាល ក្រោមការណែនាំរបស់ប្រធានអង្គភាពរបស់ខ្លួន (មាត្រា ១៨២, ១៩១ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ)

✓ នាយករដ្ឋបាល ក្រោមការដឹកនាំរបស់គណៈអភិបាល ត្រូវធានាឱ្យបានថា បុគ្គលិករបស់ក្រុមប្រឹក្សា បំពេញការងារអនុលោមទៅតាមច្បាប់ និងលិខិតបទដ្ឋាន ក៏ដូចជាសេចក្តីសម្រេចរបស់ក្រុមប្រឹក្សា និងគណៈអភិបាល (មាត្រា ៤៨, ១០៥, ១៦៦ នៃអនុក្រឹត្យលេខ២១៦ អនក្រ.បក ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក)។



ក្រុមប្រឹក្សាជាប់ឆ្នោត
គណៈកម្មាធិការ ផ្សេងទៀត
គណៈកម្មាធិការ ពិគ្រោះយោបល់ កិច្ចការស្ត្រី និង កុមារ
គណៈកម្មាធិការ លទ្ធកម្ម
គណៈកម្មាធិការ សម្របសម្រួលបច្ចេកទេស
គណៈអភិបាល (អភិបាល និងអភិបាលរង)
នាយករដ្ឋបាល
ទីចាត់ការ រដ្ឋបាល
ទីចាត់ការផែនការ និង វិនិយោគ
ទីចាត់ការ ហិរញ្ញវត្ថុ
ទីចាត់ការគ្រប់គ្រង ធនធានមនុស្ស
ទីចាត់ការ អន្តរវិស័យ

## ផ្នែកទី ៥: ការកែសម្រួលរៀបចំបុគ្គលិកឡើងវិញ

**ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ខណ្ឌ**

**មាត្រា ១៧៦,២៦២-២៦៤,២៦៨-២៧០, ២៧២, ២៧៧, ២៨១**

- ✓ ដំណើរការផ្ទេរមុខងារ និងធនធាន (រួមទាំងការរៀបចំកែសម្រួលបុគ្គលិកឡើងវិញ) ប្រហែលជាភារកិច្ចលំបាកបំផុតដែលត្រូវប្រឈមជាមួយក្រសួង ស្ថាប័ននានាជាមួយបុគ្គលិកផ្ទាល់ក៏ដូចជាដំណើរការរបស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប) និងក្រុមប្រឹក្សា។ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ចែងពីគោលការណ៍ទូទៅសម្រាប់អនុវត្តដំណើរការនេះ។ ទោះជាយ៉ាងណាក៏ដោយ របៀបអនុវត្តជាក់ស្តែងនៅមិនទាន់បានកំណត់នៅឡើយ។
- ✓ មានការរៀបចំកែសម្រួលបុគ្គលិកឡើងវិញជាបឋមនៅក្នុងដំណាក់កាលអន្តរកាល បន្ទាប់ពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាថ្មីភ្លាម។ បុគ្គលិករបស់ក្រសួងមហាផ្ទៃដែលបានបំពេញការងារនៅក្រោមរដ្ឋបាលដែលបានតែងតាំងពីមុនត្រូវបានរៀបចំកែសម្រួលឡើងវិញ ហើយនៅពេលនេះ គឺជាបុគ្គលិករបស់ក្រុមប្រឹក្សាជាប់ឆ្នោតថ្មីនៅតាមថ្នាក់នីមួយៗ។
- ✓ ក្រៅពីនេះ នឹងមានដំណើរការរយៈពេលវែងក្នុងការរៀបចំកែសម្រួលបុគ្គលិកឡើងវិញដល់ក្រុមប្រឹក្សា។ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ តម្រូវឱ្យក្រសួងតាមវិស័យ ពិនិត្យមើលឡើងវិញលើមុខងាររបស់ខ្លួន ហើយកំណត់មុខងារដែលត្រូវផ្ទេរឱ្យក្រុមប្រឹក្សា។ នៅពេលមុខងារតាមវិស័យត្រូវផ្ទេរឱ្យក្រុមប្រឹក្សា បុគ្គលិកជំនាញដែលកំពុងអនុវត្តមុខងារនោះ ក៏ត្រូវផ្ទេរ (រៀបចំកែសម្រួលឡើងវិញ) ឱ្យក្រុមប្រឹក្សាផងដែរ។

### ការកែសម្រួលរៀបចំឡើងវិញនៅក្នុងដំណាក់កាលអន្តរកាល

- ✓ បន្ទាប់ពីការបោះឆ្នោតនៅខែ ឧសភា ឆ្នាំ ២០០៩ ក្រុមប្រឹក្សាថ្មីបានជំនួសរដ្ឋបាលដែលបានតែងតាំងពីមុនមកនៅរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។ ឧទាហរណ៍ ក្រុមប្រឹក្សាថ្មីនៅខេត្តស្វាយរៀង ជំនួសរដ្ឋបាលដែលបានតែងតាំងពីមុនមកនៅខេត្តស្វាយរៀង (មាត្រា ២៧៧ នៃច្បាប់ស្តីពី ការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ប្រការ ៧ នៃប្រកាសលេខ ១២៤៩ ប្រក. ស្តីពីការប្រកាសចូលកាន់តំណែង កិច្ចប្រជុំសាមញ្ញលើកទី១ កិច្ចប្រជុំសាមញ្ញលើកទី២របស់ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ការប្រកាសចូលកាន់តំណែងនៃ

គណៈអភិបាលសម្រាប់ក្រុមប្រឹក្សាអាណត្តិទី១ និងការទទួលខុសត្រូវបន្ទុវសិទ្ធិ និងការទទួលខុសត្រូវពីរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌបច្ចុប្បន្ន ទៅក្រុមប្រឹក្សា និងគណៈអភិបាលអាណត្តិទី១) ។

- ✓ ក្រសួងមហាផ្ទៃ ត្រូវធានាថា **រដ្ឋបាលថ្មី ធ្វើសមាហរណកម្មបុគ្គលិកដែលមានស្រាប់**នៅក្នុងក្របខ័ណ្ឌមន្ត្រីរាជការរបស់ក្រសួងមហាផ្ទៃ។ បុគ្គលិកទាំងនេះ ភាគច្រើនជាបុគ្គលិករដ្ឋបាល។ នៅពេលបច្ចុប្បន្ន បុគ្គលិកដែលបានធ្វើសមាហរណកម្ម និងបុគ្គលិកកិច្ចសន្យា **ត្រូវបានត្រួតពិនិត្យ និងគ្រប់គ្រងដោយក្រុមប្រឹក្សា និងគណៈអភិបាល**។ ឧទាហរណ៍ បុគ្គលិកពីមុនរបស់រដ្ឋបាលខេត្តស្វាយរៀង នៅពេលនេះ គឺជាបុគ្គលិករបស់រដ្ឋបាលថ្មីនៅខេត្តស្វាយរៀង (មាត្រា ២៨១ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មាត្រា ២០៦ នៃអនុក្រឹត្យលេខ២១៦ អនក្រ.បក ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក) ។
- ✓ ក្នុងករណីដែលបុគ្គលិកដែលត្រូវបានរៀបចំកែសម្រួលឡើងវិញទាំងនេះ មិនអាចឆ្លើយតបទៅនឹងតម្រូវការរបស់ក្រុមប្រឹក្សា ក្រុមប្រឹក្សា និងគណៈអភិបាល អាចជ្រើសរើសបុគ្គលិកនៅក្នុងក្របខ័ណ្ឌមន្ត្រីរាជការរបស់ក្រសួងផ្សេងទៀត (មាត្រា ២០៦ នៃអនុក្រឹត្យលេខ២១៦ អនក្រ. បក ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក) ។
- ✓ នៅពេលមិនទាន់មានលក្ខន្តិកៈសម្រាប់បុគ្គលិកនៅថ្នាក់ក្រោមជាតិ ក្រុមប្រឹក្សា ត្រូវអនុម័តលើការ**តែងតាំង**បុគ្គលិក **តំឡើងឋានៈ** កែប្រែលើ**ប្រាក់បៀវត្ស** ឬផលប្រយោជន៍ផ្សេងទៀត ហើយក្រុមប្រឹក្សា ត្រូវអនុម័តការជ្រើសរើសបុគ្គលិកកិច្ចសន្យា និងបុគ្គលិកផ្សេងទៀត រួមទាំងទីប្រឹក្សាបច្ចេកទេស ។ នៅពេលមានការឯកភាពពីក្រុមប្រឹក្សា អភិបាលត្រូវស្នើសុំទៅក្រសួងមហាផ្ទៃឱ្យចាត់វិធានការចាំបាច់ ដើម្បីអនុវត្តសេចក្តីសម្រេចរបស់ក្រុមប្រឹក្សា (មាត្រា ២០៦ នៃអនុក្រឹត្យលេខ២១៦ អនក្រ.បក ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក ) ។

## ការកែសម្រួលរៀបចំឡើងវិញលើបុគ្គលិកដែលអនុវត្តមុខងារតាមវិស័យ

> ចំពោះព័ត៌មានបន្ថែមស្តីពីការផ្ទេរមុខងារដល់ក្រុមប្រឹក្សា សូមអានមេរៀនទី១៣

- ✓ ទិដ្ឋភាពសំខាន់នៅក្នុងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ គឺតម្រូវការឱ្យផ្ទេរមុខងារតាមវិស័យឱ្យក្រុមប្រឹក្សា ដើម្បីឱ្យក្រុមប្រឹក្សាអនុវត្តជំនួសក្រសួង។ ក្រុមប្រឹក្សានឹងមានលទ្ធភាពអនុវត្តមុខងារតាមវិស័យយ៉ាងមានប្រសិទ្ធិភាពប្រសិនបើបុគ្គលិកជំនាញដែលកំពុងអនុវត្តមុខងារនោះ ត្រូវបានផ្ទេរឱ្យក្រុមប្រឹក្សា ហើយធនធានហិរញ្ញវត្ថុផងសមស្របសម្រាប់មុខងារនោះដែលបានផ្ទេរអោយដែរ (មាត្រា ២០០, ២១៧ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ)។

- ✓ ដូច្នេះ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ចែងថា **ការផ្ទេរមុខងារ ត្រូវដំណើរការស្របពេលជាមួយគ្នា**នឹងការផ្ទេរធនធានចាំបាច់ ដូចជា ចំណូល ហិរញ្ញវត្ថុ **បុគ្គលិក** ទ្រព្យសម្បត្តិ និងសមត្ថភាព (មាត្រា ២០០, ២១៧, ២៦២ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ)។

- ✓ បុគ្គលិករបស់ក្រសួងដែលបានរៀបចំកែសម្រួលឡើងវិញដល់ក្រុមប្រឹក្សា ក្លាយទៅជាបុគ្គលិករបស់ក្រុមប្រឹក្សា ហើយ**លែងជាបុគ្គលិករបស់ក្រសួងទៀតហើយ** (មាត្រា ១៧៣ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ)។

- ✓ គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប) ត្រូវអភិវឌ្ឍ**គោលនយោបាយ និងយុទ្ធសាស្ត្រ** ដើម្បីធានាថា ការពិនិត្យមើល និងការរៀបចំកែសម្រួលបុគ្គលិកឡើងវិញ ត្រូវបានអនុវត្តត្រឹមត្រូវ (មាត្រា ២៦៣ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ)។

- ✓ បច្ចុប្បន្ននេះ មន្ត្រីរាជការ ស្ថិតនៅក្នុងក្របខ័ណ្ឌនៅថ្នាក់ជាតិ ហើយត្រូវគ្រប់គ្រងដោយសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល។ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ តម្រូវឱ្យរៀបចំលក្ខន្តិកៈថ្មី ដើម្បីគ្រប់គ្រងបុគ្គលិករបស់ក្រុមប្រឹក្សា។ បុគ្គលិករបស់ក្រុមប្រឹក្សា គឺជាបុគ្គលិកនៅថ្នាក់ក្រោមជាតិ (មាត្រា ១៧៦, ២៦៤ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ)។

- ✓ គ.ជ.អ.ប ត្រូវធានាថា កំណែទម្រង់មិននាំឱ្យមានការបង្កើន**ចំនួនបុគ្គលិកមុខងារសាធារណៈ**ឡើយ (មាត្រា ២៦៤ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ)។

✓ ការពិនិត្យ និងការកែសម្រួលឡើងវិញនូវការរៀបចំបុគ្គលិកឱ្យក្រុមប្រឹក្សា ត្រូវធ្វើឡើងផ្អែកលើគោលការណ៍ខាងក្រោម:

- ស្របជាមួយនឹងការពិនិត្យមើលឡើងវិញលើមុខងារ
- ទៅតាមរបៀបដែល**មានការពិគ្រោះយោបល់ មានផែនការកម្មវិធី មានសនិទានភាព មានតម្លាភាព** និងអនុលោមតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- ទៅតាមរបៀបដែលគិតគូរអំពីផលប្រយោជន៍របស់ក្រុមប្រឹក្សា និងរបស់បុគ្គលិកដែលពាក់ព័ន្ធ ( មាត្រា ២៦៥ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ) ។

✓ ក្នុងករណីដែលមុខងារមួយត្រូវបានផ្ទេរឱ្យក្រុមប្រឹក្សា ប៉ុន្តែបុគ្គលិកចាំបាច់មានចំនួនមិនគ្រប់គ្រាន់ ឬគ្មានតែម្តង ដើម្បីអនុវត្តមុខងារនោះ ក្រុមប្រឹក្សាត្រូវបានទទួលធនធានហិរញ្ញវត្ថុ ដើម្បីជ្រើសរើសបុគ្គលិកមកបំរើការងារតាមការចាំបាច់ ( មាត្រា ២៦៨ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ) ។

✓ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ត្រូវផ្ទេរដល់ក្រុមប្រឹក្សានូវ**ប្រាក់បៀវត្ស ប្រាក់ឧបត្ថម្ភ និងអត្ថប្រយោជន៍ផ្សេងៗទៀតរបស់បុគ្គលិក**ដែលបានផ្ទេរឱ្យក្រុមប្រឹក្សា ( មាត្រា ២៧១ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ) ។

**ឧទាហរណ៍ - បុគ្គលិកដែលត្រូវកែសម្រួលរៀបចំឡើងវិញ**

ឧបមាថា មុខងារផ្តល់សេវាផ្សព្វផ្សាយកសិកម្ម ត្រូវបានធ្វើប្រតិភូកម្ម ឬ ផ្ទេរឱ្យក្រុមប្រឹក្សាស្រុក ។ សមាជិកក្រុមប្រឹក្សាស្រុក មិនអាចអនុវត្តមុខងារនេះដោយខ្លួនឯងឡើយ ។ សមាជិកក្រុមប្រឹក្សា ត្រូវមានបុគ្គលិកដើម្បីផ្តល់សេវាផ្សព្វផ្សាយកសិកម្ម ។ ដោយសារហេតុផលនេះ នៅពេលមុខងារត្រូវផ្ទេរទៅក្រុមប្រឹក្សាស្រុក មន្ត្រីរាជការដែលកំពុងផ្តល់សេវាផ្សព្វផ្សាយនៅពេលសព្វថ្ងៃ ត្រូវកែសម្រួលរៀបចំឡើងវិញឱ្យក្រុមប្រឹក្សា ។ មន្ត្រីរាជការទាំងនេះ ក្លាយទៅជាបុគ្គលិករបស់ក្រុមប្រឹក្សា ហើយលែងស្ថិតនៅក្នុងក្របខ័ណ្ឌក្រសួងខ្សែបណ្តោយទៀតហើយ ។ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ត្រូវផ្ទេរប្រាក់បៀវត្ស ប្រាក់ឧបត្ថម្ភ និង ផលប្រយោជន៍ផ្សេងទៀតទៅក្រុមប្រឹក្សាស្រុក ។

✓ ការរៀបចំបុគ្គលិកឡើងវិញ ចូលជាធរមាននៅពេលគ.ជ.អ.ប និងក្រសួង ស្ថាប័នដែលពាក់ព័ន្ធរបស់រាជរដ្ឋាភិបាលដាក់ចេញសេចក្តីសម្រេចដែលកំណត់អំពី:

- មន្ត្រីរាជការដែលត្រូវកែសម្រួលរៀបចំឡើងវិញ

- ប្រភេទក្រុមប្រឹក្សាដែលបុគ្គលិកនោះត្រូវទៅបំពេញការងារ
- កាលបរិច្ឆេទដែលបុគ្គលិកនោះត្រូវចូលបំរើការងារ

(មាត្រា ២៧០ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ)។

✓ ក្រុមប្រឹក្សាត្រូវរាយការណ៍ជាបន្ទាន់ដល់គ.ជ.អ.ប ក្នុងករណីដែលបុគ្គលិកណាម្នាក់ ត្រូវបានផ្ទេរឱ្យក្រុមប្រឹក្សារួចហើយ តែបុគ្គលិកនោះខកខានមិនបានចូលបម្រើការងារតាមការកំណត់នៅក្នុងសេចក្តីសម្រេច (មាត្រា ២៧២ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ)។

**បញ្ហាដែលត្រូវដោះស្រាយ**

ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ បានចែងយ៉ាងច្បាស់ថា គ្រប់ក្រុមប្រឹក្សា ត្រូវមានបុគ្គលិករបស់ខ្លួនផ្ទាល់ ដែលរួមមាននាយករដ្ឋបាល ប្រធានហិរញ្ញវត្ថុ និងបុគ្គលិកដែលត្រូវរៀបចំកែសម្រួលឡើងវិញ។ ទោះជាយ៉ាងណាក្តី សេចក្តីលំអិតជាច្រើនអំពីបុគ្គលិករបស់ក្រុមប្រឹក្សា នៅមិនទាន់បានកំណត់នៅឡើយ ។ បញ្ហាមួយចំនួនដែលតម្រូវឱ្យមានការបញ្ជាក់បន្ថែមទៀតរួមមាន៖

- មិនទាន់មានភាពច្បាស់លាស់ថាតើលក្ខន្តិកៈដោយឡែកមន្ត្រីរាជការស៊ីវិលនៅថ្នាក់ក្រោមជាតិគ្រប់គ្រងទាំងបុគ្គលិកដែលត្រូវរៀបចំកែសម្រួលឡើងវិញឱ្យក្រុមប្រឹក្សា និងបុគ្គលិកដែលត្រូវតែងតាំងដោយក្រុមប្រឹក្សា ឬទេ។
- ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មិនបានបញ្ជាក់អំពីកំរិតនៃសេរីភាពដែលក្រុមប្រឹក្សាមាននៅក្នុងការតែងតាំងបុគ្គលិកបន្ថែម ឧទាហរណ៍ តើក្រុមប្រឹក្សាខ្លួនឯងផ្ទាល់ អាចធ្វើសេចក្តីសម្រេចលើប្រាក់បៀវត្ស និង ផលប្រយោជន៍ផ្សេងទៀតឬទេ ? ឬតើលក្ខន្តិកៈដោយឡែកមន្ត្រីរាជការស៊ីវិលនៅថ្នាក់ក្រោមជាតិចែងអំពីការងារទាំងនេះយ៉ាងណា?
- តើក្រុមប្រឹក្សា អាចផ្ទេរបុគ្គលិកដែលបានកែសម្រួលឡើងវិញ ឬ ស្នើសុំឱ្យមានការផ្ទេរបុគ្គលិកនេះ ឬទេ ?
  គួរមិនត្រូវបានចែងទេ ការសុំយោបល់នេះក្រសួងទាំងពីរជានាអោយច្បាស់ សមត្ថភាព អត្តចរិក អកប្បកិរិយា គួរ-មានការកំណត់ក្នុងករណីមានវិវាទរវាងក្រុមប្រឹក្សា និងប្រធានហិរញ្ញវត្ថុ។ គួរកំណត់អ្នកដែលធ្វើសេចក្តីសម្រេចលើការបញ្ឈប់ប្រធានហិរញ្ញវត្ថុ។ តើក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងមហាផ្ទៃ ឬក្រុមប្រឹក្សា ?

– **ជម្រើសរបស់មន្ត្រីរាជការ**

✓ ការកែសំរួលរៀបចំមន្ត្រីរាជការឡើងវិញ មិនដែលប្រព្រឹត្តទៅដោយគ្មានការលំបាកឡើយ។ ការងារនេះកាន់តែមានភាពស្មុគស្មាញសំរាប់ការផ្ទេរដែលតម្រូវឱ្យមានការផ្លាស់ប្តូរលំនៅដ្ឋានដើម្បីទទួលយកមុខតំណែងថ្មី។ ក្នុងកាលៈទេសៈពិសេសបែបនេះ មន្ត្រីរាជការដែលត្រូវផ្លាស់ប្តូរលំនៅដ្ឋានរបស់ខ្លួន ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ផ្តល់ជំរើសឱ្យមន្ត្រីរាជការ**បដិសេធការរៀបចំកែសម្រួលឡើងវិញ**។

✓ ប្រសិនបើមន្ត្រីរាជការនៅសព្វថ្ងៃត្រូវបានស្នើសុំឱ្យរៀបចំកែសម្រួលដល់ក្រុមប្រឹក្សា ហើយការកែសម្រួលឡើងវិញតម្រូវឱ្យបុគ្គលិកប្តូរទីលំនៅរបស់ខ្លួន បុគ្គលិកនោះអាចមិនយល់ព្រមតាមការរៀបចំនេះ ដោយផ្តល់**សេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរ**នៅក្នុងរយៈពេលមួយខែ បន្ទាប់ពីទទួលបានសេចក្តីសម្រេចអំពីការកែសម្រួលឡើងវិញ ( មាត្រា ២៦៩ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ) ។

✓ មន្ត្រីរាជការនៅពេលសព្វថ្ងៃ ដែលបានបដិសេធចំពោះការរៀបចំកែសម្រួលឡើងវិញដល់ក្រុមប្រឹក្សា អាចនៅជាមន្ត្រីរាជការរបស់ក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាលជាបន្តទៀត ប៉ុន្តែអាចត្រូវប្រគល់មុខងារផ្សេង។ មន្ត្រីរាជការនោះ មិនអាចបន្តអនុវត្តមុខងារចាស់របស់ខ្លួនទៀតឡើយ ពីព្រោះមុខងារនោះ ត្រូវបានផ្ទេរឱ្យក្រុមប្រឹក្សា ហើយដូច្នេះ មុខងារនោះលែងអនុវត្តដោយក្រសួង ឬស្ថាប័នសាមីរបស់បុគ្គលិកនោះទៀតឡើយ ( មាត្រា ២៦៩ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ) ។

## វគ្គទី ២៖

## មេរៀនសង្ខេប

- ✓ រាជធានី ខេត្ត ក្រុង ស្រុក និង ខណ្ឌ ត្រូវគ្រប់គ្រងអនុលោមទៅតាមគោលការណ៍នៃរដ្ឋបាលឯកភាព ។
- ✓ គ្រប់ក្រុមប្រឹក្សា មានបុគ្គលិករបស់ខ្លួនផ្ទាល់ ។
- ✓ បុគ្គលិករបស់ក្រុមប្រឹក្សាត្រូវ មានប្រភេទបីយ៉ាងៈ បុគ្គលិកដែលត្រូវតែងតាំងដោយក្រុមប្រឹក្សា បុគ្គលិកដែលត្រូវតែងតាំងឱ្យបំពេញការងារជាមួយក្រុមប្រឹក្សា និងបុគ្គលិកដែលត្រូវកែសម្រួលរៀបចំឡើងវិញឱ្យក្រុមប្រឹក្សា ។
- ✓ ក្រុមប្រឹក្សា ត្រូវបង្កើតអង្គភាពបុគ្គលិករបស់ខ្លួនផ្ទាល់ទៅតាមការចាំបាច់ ។
- ✓ ក្រុមប្រឹក្សានីមួយៗ មាននាយករដ្ឋបាល ដែលត្រូវតែងតាំងដោយក្រសួងមហាផ្ទៃ ។
- ✓ ក្រុមប្រឹក្សានីមួយៗ មានប្រធានហិរញ្ញវត្ថុដែលត្រូវតែងតាំងដោយក្រុមប្រឹក្សា បន្ទាប់ពីមានការឯកភាពរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។
- ✓ បុគ្គលិក អង្គភាព ប្រធានអង្គភាព ប្រធានហិរញ្ញវត្ថុ នាយករដ្ឋបាលត្រូវមានគណនេយ្យភាពចំពោះក្រុមប្រឹក្សា និងគណៈអភិបាល ។

# វគ្គទី ៣៖

# ការងារជាក្រុម

**ការងារជាក្រុម ដូចមានពិពណ៌នាខាងក្រោម អាចមានលក្ខណៈមិនសមស្របសម្រាប់ការបណ្តុះបណ្តាលទាំងអស់ ។ សូមចាត់ទុកការងារជាក្រុមខាងក្រោមជាសំណូមពរតែប៉ុណ្ណោះ ។**

១. ចែកសិក្ខាកាមជាក្រុមដែលមានសមាជិកមិនលើសពី ៨ នាក់ ។

២. ផ្តល់លំហាត់ខាងក្រោមដល់ក្រុមនីមួយៗ ។

**លំហាត់ទី ១ : ការកែសម្រួលរៀបចំបុគ្គលិកឡើងវិញ**

**ការពិភាក្សានៅក្នុងក្រុមតូចៗ :**

- តើអ្នកគិតថា នឹងមានបញ្ហាអ្វីខ្លះ អាចកើតមានឡើងនៅពេលបុគ្គលិករបស់ក្រសួង ត្រូវបានកែសម្រួលរៀបចំឡើងវិញឱ្យក្រុប្រឹក្សានៅថ្នាក់ក្រោមជាតិ?
- តើអ្នកគិតថា ក្រុមប្រឹក្សា អាចធ្វើអ្វីបាន ដើម្បីធានាថា បុគ្គលិកដែលត្រូវរៀបចំកែសម្រួលឡើងវិញ ត្រូវបានដាក់បញ្ចូលយ៉ាងល្អទៅក្នុងក្រុមប្រឹក្សា និងរដ្ឋបាលរបស់ក្រុមប្រឹក្សា ?

**លំហាត់ទី ២៖ បុគ្គលិករបស់ក្រុមប្រឹក្សា**

**ការពិភាក្សានៅក្នុងក្រុមតូចៗ :**

- តើក្រុមប្រឹក្សាអាចធ្វើដូចម្តេច ដើម្បីធានាឱ្យបានថា ដំណើរការជ្រើសរើស មានលក្ខណៈមិនលំអៀង និងមានតម្លាភាព ?
- តើត្រូវធ្វើដូចម្តេចខ្លះ ដើម្បីធានាឱ្យស្ត្រី ទទួលបានមុខងតំណែងនៅក្នុងថ្នាក់ដឹកនាំនៅក្នុងរដ្ឋបាលរបស់ក្រុមប្រឹក្សា ( ឧទាហរណ៍ ប្រធាន ឬ អនុប្រធានរបស់អង្គភាព) ?

# មេរៀនសំរាប់ការយល់ដឹង និង ការបណ្តុះបណ្តាលអំពី ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

## មេរៀនទី ៩

## កិច្ចប្រជុំរបស់ក្រុមប្រឹក្សា និងបទបញ្ជាផ្ទៃក្នុង

វគ្គទី ១:

១. សេចក្តីណែនាំបន្ទាញកិច្ចប្រជុំរបស់ក្រុមប្រឹក្សា

២. បទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សា

៣. កិច្ចប្រជុំសាមញ្ញ និងវិសាមញ្ញ

៤. តួនាទីរបស់ប្រធាន សមាជិកក្រុមប្រឹក្សា គណៈអភិបាល

៥. សេចក្តីសម្រេច និងដីការបស់ក្រុមប្រឹក្សា

៦. របៀបវារៈ កូរ៉ុម និងកំណត់ហេតុប្រជុំ

៧. អវត្តមាន និងវិន័យ

## ផ្នែកទី ១: សេចក្តីណែនាំបច្ចាញកិច្ចប្រជុំរបស់ក្រុមប្រឹក្សា

✓ កិច្ចប្រជុំរបស់ក្រុមប្រឹក្សា មានសារៈសំខាន់ជាសារវ័ន្តសម្រាប់**គណនេយ្យភាពតាមបែបប្រជាធិបតេយ្យ**។ ដើម្បីប្រកាន់យកជម្រើស និងធ្វើសេចក្តីសម្រេចផ្នែកនយោបាយក្នុងនាមប្រជាពលរដ្ឋរបស់ខ្លួន សមាជិកក្រុមប្រឹក្សាត្រូវមាន**ឱកាសពិចារណា ដើម្បីធ្វើសេចក្តីសម្រេចទៅតាមឆន្ទៈរបស់ខ្លួន**។

✓ **ជម្រើសផ្នែកនយោបាយ ត្រូវចែកឱ្យដាច់ពីការងារបច្ចេកទេស**។ ប្រការនេះមានន័យថា ជម្រើសផ្នែកនយោបាយរបស់ក្រុមប្រឹក្សាដែលជាប់ឆ្នោត ត្រូវចែកឱ្យដាច់ស្រលះពីការងារបច្ចេកទេសរបស់គណៈអភិបាល និងបុគ្គលិករបស់ក្រុមប្រឹក្សា។ ក្នុងន័យនេះមានតែសមាជិកក្រុមប្រឹក្សាប៉ុណ្ណោះ ដែលអាចបោះឆ្នោត នៅក្នុងកិច្ចប្រជុំរបស់ក្រុមប្រឹក្សា។

> **គណនេយ្យភាពតាមបែបប្រជាធិបតេយ្យសំដៅលើ**
>
> *តំណាងជាប់ឆ្នោតដែលមានគណនេយ្យភាពតាមបែបប្រជាធិបតេយ្យ ប្រកាន់យកជម្រើសដោយផ្អែកលើព័ត៌មាន បែងចែកធនធានដ៏មានកំរិត និងអនុវត្តមុខងារ និងភារកិច្ចរបស់ខ្លួនដើម្បីជាប្រយោជន៍សាធារណៈ និងដើម្បីឆ្លើយតបនឹងតម្រូវការដែលបានលើកឡើងនៅមូលដ្ឋាន។*
>
> *គណនេយ្យភាពតាមបែបប្រជាធិបតេយ្យកើតមានឡើងនៅពេលប្រជាពលរដ្ឋ អាចកំណត់ផលវិបាកទៅលើតំណាងជាប់ឆ្នោតចំពោះជម្រើសដែលតំណាងជាប់ឆ្នោតប្រកាន់យករបៀបដែលតំណាងជាប់ឆ្នោតបែងចែកធនធានដ៏មានកម្រិត និងចំពោះការអនុវត្តមុខងារ និងភារកិច្ចរបស់ខ្លួន។*

✓ ឱកាសពិចារណា ក៏មានការពាក់ព័ន្ធនឹងការធានាឱ្យបានថា ក្រុមប្រឹក្សាប្រកាន់យក**ជម្រើសដែលផ្អែកលើភស្តុតាង** (ដូចជា ទិន្នន័យ ការសិក្សាព័ត៌មានអំពីជោគជ័យ និងបរាជ័យកន្លងមក)។ គណៈអភិបាល និងបុគ្គលិករបស់ក្រុមប្រឹក្សាមានការទទួលខុសត្រូវក្នុងការផ្តល់ព័ត៌មាន និងភស្តុតាងដល់ក្រុមប្រឹក្សា។

✓ កិច្ចប្រជុំរបស់ក្រុមប្រឹក្សា គួរជាវេទិកាសម្រាប់ឱ្យសមាជិកក្រុមប្រឹក្សាដែលជាប់ឆ្នោត វាយតម្លៃស្នាដៃលើការងារផ្សេងៗ ពិភាក្សាបញ្ហា និង**ជជែកវែកញែក**បញ្ហា។ ការប្រជុំដែលផ្តល់លទ្ធភាពដល់ការពិភាក្សាល្អិតល្អន់បែបនេះគួរនាំឱ្យទៅដល់**ការធ្វើសេចក្តីសម្រេច**ដែលជា**ប្រយោជន៍ដ៏ប្រសើរបំផុតរបស់ប្រជាពលរដ្ឋ**។

✓ **កិច្ចប្រជុំរបស់ក្រុមប្រឹក្សា គឺជាវេទិកាយ៉ាងសំខាន់**សម្រាប់សមាជិកក្រុមប្រឹក្សា:

- លើកឡើង ពិភាក្សា ជជែកវែកញែកបញ្ហាដែលមានសារៈសំខាន់ចំពោះប្រជាពលរដ្ឋនៅមូលដ្ឋាន
- តាក់តែងគោលនយោបាយ ធ្វើសេចក្តីសម្រេច និងអនុម័តដីកាដែលចាំបាច់

- ពិនិត្យមើលហិរញ្ញវត្ថុរបស់ក្រុមប្រឹក្សា
- ពិនិត្យមើល និងដោះស្រាយសំណូមពរ ឬបណ្តឹងពីប្រជាពលរដ្ឋ
- ចាត់វិធានការ ដើម្បីដោះស្រាយវិវាទនៅមូលដ្ឋាន
- ទទួលបច្ចុប្បន្នភាពពីគណៈអភិបាលអំពីការរីកចំរើនលើការអនុវត្តសេចក្តីសម្រេច ដីកា និងសកម្មភាពរបស់ក្រុមប្រឹក្សា
- សួរសំណួរ និងស្វែងរកការបំភ្លឺពីគណៈអភិបាល
- បំពេញការទទួលខុសត្រូវរបស់ក្រុមប្រឹក្សា ដើម្បីធានាថា គណៈអភិបាល និងបុគ្គលិក មានគណនេយ្យភាពចំពោះក្រុមប្រឹក្សា។

✓ រាល់ការប្រជុំរបស់ក្រុមប្រឹក្សា ត្រូវ**ធ្វើឡើងជាសាធារណៈ** លើកលែងតែករណីចាំបាច់ដែលមានចែងនៅក្នុងច្បាប់។ ការប្រជុំជាសាធារណៈ ត្រូវមានកន្លែងអង្គុយសម្រាប់សាធារណជន (មាត្រា ៦៨ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មាត្រា ២, ១៣, ២៥ នៃគំរូបទបញ្ជាផ្ទៃក្នុង)។

## ផ្នែកទី ២: បទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សា

- ✓ ក្រុមប្រឹក្សាទាំងអស់ ត្រូវអនុម័តបទបញ្ជាផ្ទៃក្នុងរបស់ខ្លួនក្នុងទម្រង់ជាដីកា ( មាត្រា ៦៩, ៧១ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មាត្រា ២ នៃគំរូបទបញ្ជាផ្ទៃក្នុង) ។

- ✓ គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប) បានដាក់ចេញ**គំរូបទបញ្ជាផ្ទៃក្នុង**។ គំរូបទបញ្ជាផ្ទៃក្នុង គឺជាគំរូ និងជាការណែនាំសម្រាប់ឱ្យក្រុមប្រឹក្សាអនុវត្តតាមនៅពេលអភិវឌ្ឍបទបញ្ជាផ្ទៃក្នុងរបស់ខ្លួនផ្ទាល់ ។

- ✓ គំរូបទបញ្ជាផ្ទៃក្នុង បានចែងអំពី**តម្រូវការជាអប្បបរមា**ដែលក្រុមប្រឹក្សា ត្រូវអនុវត្តតាមនៅពេលដំណើរការកិច្ចប្រជុំរបស់ខ្លួន។ ដូច្នេះ តម្រូវការជាអប្បបរមានេះ ត្រូវមាននៅក្នុងបទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សាទាំងអស់ ។ ទោះជាយ៉ាងក៏ដោយ ក្រុមប្រឹក្សា **អាចប្រើប្រាស់គំរូបទបញ្ជាផ្ទៃក្នុង**ដែលបានដាក់ចេញដោយ គ.ជ.អ.ប ឬ អាចកែសម្រួលគំរូបទបញ្ជាផ្ទៃក្នុង ដរាបណាតម្រូវការជាអប្បបរមាត្រូវបានរក្សាទុក ( មាត្រា ១ នៃគំរូបទបញ្ជាផ្ទៃក្នុង) ។

> **ឧទាហរណ៍**
>
> ក្រុមប្រឹក្សា គួរមានសិទ្ធិបន្ថែមទៅក្នុងបទបញ្ជាផ្ទៃក្នុងរបស់ខ្លួននូវបទបញ្ញត្តិសម្រាប់ឱ្យប្រជាពលរដ្ឋ និយាយ និងសួរសំណួរនៅពេលចាប់ផ្តើម ឬ នៅពេលបញ្ចប់នៃកិច្ចប្រជុំរបស់ខ្លួន។

- ✓ នៅពេលក្រុមប្រឹក្សាកែសម្រួលគំរូបទបញ្ជាផ្ទៃក្នុងដែលបានដាក់ចេញដោយ គ.ជ.អ.ប ក្រសួងមហាផ្ទៃ ត្រូវពិនិត្យមើលការកែសម្រួលនោះ។ ក្នុងករណីដែលការកែសម្រួលផ្ទុយទៅគោលការណ៍ច្បាប់ និងលិខិតបទដ្ឋាន ក្រសួងមហាផ្ទៃត្រូវណែនាំក្រុមប្រឹក្សាអំពីរបៀបកែតម្រូវបទបញ្ជាផ្ទៃក្នុងរបស់ខ្លួន ហើយក្រុមប្រឹក្សា ត្រូវធ្វើការកែតម្រូវនៅក្នុងកិច្ចប្រជុំលើកក្រោយរបស់ខ្លួន ( មាត្រា ២ នៃគំរូបទបញ្ជាផ្ទៃក្នុង) ។

- ✓ នៅពេលក្រុមប្រឹក្សា អនុម័តដីកាស្តីពីបទបញ្ជាផ្ទៃក្នុងរបស់ខ្លួន ក្រុមប្រឹក្សាត្រូវផ្តល់ច្បាប់ចម្លងនៃបទបញ្ជាផ្ទៃក្នុងនោះដល់សមាជិកក្រុមប្រឹក្សាគ្រប់រូប គណៈអភិបាល និងដល់ក្រសួងមហាផ្ទៃ។ ក្រៅពីនេះ ច្បាប់ចម្លងនៃ**បទបញ្ជាផ្ទៃក្នុង** ត្រូវរក្សាទុកជាឯកសារនៅការិយាល័យរបស់ក្រុមប្រឹក្សា និង**អាចទទួលបានជាសាធារណៈ** ( មាត្រា ៥១ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មាត្រា២ នៃគំរូបទបញ្ជាផ្ទៃក្នុង) ។

✓ កិច្ចប្រជុំទាំងអស់របស់ក្រុមប្រឹក្សា ត្រូវធ្វើឡើងអនុលោមទៅតាមបទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សា។ សេចក្តីសម្រេចដែលមិនបានធ្វើឡើងអនុលោមទៅតាមបទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សា គឺជាសេចក្តីសម្រេចដែលមិនមានសុពលភាព (មាត្រា ៦៩ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មាត្រា ២.៦ នៃគំរូបទបញ្ជាផ្ទៃក្នុង)។

## ផ្នែកទី ៣: កិច្ចប្រជុំសាមញ្ញ និងវិសាមញ្ញ

✓ កិច្ចប្រជុំរបស់ក្រុមប្រឹក្សា មានពីរប្រភេទ: **កិច្ចប្រជុំសាមញ្ញ** និង**កិច្ចប្រជុំវិសាមញ្ញ** (មាត្រា ៧៤, ៧៧ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ប្រការ ១ នៃគំរូបបទបញ្ជាផ្ទៃក្នុង) ។

✓ គ្រប់ក្រុមប្រឹក្សា មាន**កិច្ចប្រជុំសាមញ្ញយ៉ាងតិច ១២ ដងក្នុងមួយឆ្នាំ** ។ កិច្ចប្រជុំសាមញ្ញនេះ ត្រូវប្រារព្ធឡើងមិនឱ្យមុនម្ភៃប្រាំថ្ងៃ ឬលើសពីសាមសិបប្រាំថ្ងៃ បន្ទាប់ពីការប្រជុំសាមញ្ញលើកមុន (មាត្រា ៧៤ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ប្រការ ២ នៃគំរូបបទបញ្ជាផ្ទៃក្នុង) ។

✓ ក្រុមប្រឹក្សាទាំងអស់ត្រូវអនុម័ត ហើយបន្ទាប់មកត្រូវ**ផ្សព្វផ្សាយជាសាធារណៈនូវប្រតិទិនសម្រាប់ការប្រជុំសាមញ្ញរបស់ក្រុមប្រឹក្សា**នៅក្នុងរយៈពេលមួយឆ្នាំជាមុន។ ប្រតិទិន ត្រូវបញ្ជាក់កាលបរិច្ឆេទ និងទីកន្លែងសម្រាប់កិច្ចប្រជុំនីមួយៗ ។ ក្រៅពីនេះ កាលបរិច្ឆេទ និងទីកន្លែងសម្រាប់កិច្ចប្រជុំនីមួយៗ ត្រូវដាក់បង្ហាញនៅលើក្តារព័ត៌មានរបស់ក្រុមប្រឹក្សា ហើយត្រូវផ្សព្វផ្សាយជាសាធារណៈដោយមធ្យោបាយផ្សេងទៀត (មាត្រា ៥១, ៧៥ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ប្រការ ២, ៦ នៃគំរូបបទបញ្ជាផ្ទៃក្នុង) ។

✓ ក្រៅពីនេះក្រុមប្រឹក្សា **អាចប្រជុំវិសាមញ្ញ** ដើម្បីដោះស្រាយបញ្ហាបន្ទាន់ ឬពិសេស (មាត្រា ៧៧ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ប្រការ ៤ នៃគំរូបបទបញ្ជាផ្ទៃក្នុង) ។

✓ កិច្ចប្រជុំវិសាមញ្ញ អាចត្រូវ**កោះអញ្ជើញដោយប្រធាន ឬដោយសមាជិកក្រុមប្រឹក្សាយ៉ាងតិចមួយភាគបីនៃសមាជិកក្រុមប្រឹក្សាទាំងអស់** (ប្រការ ៤ នៃគំរូបបទបញ្ជាផ្ទៃក្នុង) ។

✓ លិខិតអញ្ជើញ និងរបៀបវារៈសម្រាប់កិច្ចប្រជុំវិសាមញ្ញត្រូវចែកជូនសមាជិកក្រុមប្រឹក្សាគ្រប់រូបយ៉ាងតិចពីរថ្ងៃធ្វើការមុនពេលប្រជុំ (ប្រការ ៤ នៃគំរូបបទបញ្ជាផ្ទៃក្នុង) ។

✓ **នៅគ្រប់កិច្ចប្រជុំ** ក្រុមប្រឹក្សា ធ្វើសេចក្តីសម្រេច ឬដីកាចាំបាច់លើបញ្ហាទាក់ទងនឹង:

- ការត្រៀមខ្លួនសម្រាប់ទទួលយក**មុខងារ** ភារកិច្ច និងធនធាន**ថ្មី**
- ការអនុវត្តមុខងារជាកាតព្វកិច្ច និងជាជម្រើសរបស់ក្រុមប្រឹក្សា
- **ផែនការអភិវឌ្ឍ** កម្មវិធីវិនិយោគ និងថវិការបស់ក្រុមប្រឹក្សា
- បញ្ហាហិរញ្ញវត្ថុ

- ការបង្កើតរចនាសម្ព័ន្ធ ប្រព័ន្ធ និងធនធានសម្រាប់**គណៈកម្មាធិការរបស់ក្រុមប្រឹក្សា** អង្គភាព និង**បុគ្គលិក**របស់ក្រុមប្រឹក្សា
- ការបែងចែកភារកិច្ចនៅក្នុងចំណោមសមាជិកក្រុមប្រឹក្សា ដើម្បី**ប្រាស្រ័យទាក់ទងជាមួយប្រជាពលរដ្ឋ** និងពិនិត្យតាមដានការអនុវត្តការងាររបស់ក្រុមប្រឹក្សា
- ការគ្រប់គ្រង និងការប្រើប្រាស់**ទ្រព្យសម្បត្តិ**
- ការពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋ និងការផ្សព្វផ្សាយព័ត៌មានដល់**ប្រជាពលរដ្ឋ**
- សមិទ្ធផល និង**បញ្ហាប្រឈម**នៅក្នុងការងាររបស់ក្រុមប្រឹក្សា។

(មាត្រា ៣៦ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មាត្រា ១៤ នៃអនុក្រឹត្យលេខ២១៦ ប្រការ ១៥ នៃគំរូបទបញ្ជាផ្ទៃក្នុង)។

✓ ក្រៅពីនេះ ក្រុមប្រឹក្សាអាចធ្វើសេចក្តីសម្រេចទាក់ទងនឹង:

- ការអញ្ជើញអភិបាល ឬអភិបាលរង ឬគណៈអភិបាល ឬបុគ្គលផ្សេងទៀត ដើម្បីពិភាក្សាការអនុវត្តសេចក្តីសម្រេចរបស់ក្រុមប្រឹក្សា ឬ**បញ្ហាបន្ទាន់ ឬបញ្ហាពិសេសណាមួយ ឬមួយចំនួន**
- **ការសិក្សាស្រាវជ្រាវ** ឬការអង្កេតលើករណីណាមួយដែលក្រុមប្រឹក្សាគិតថា មានសារៈសំខាន់ចំពោះប្រជាពលរដ្ឋ
- ការណែនាំគណៈអភិបាលឱ្យចាត់វិធានការផ្អែកលើលទ្ធផលនៃការសិក្សាស្រាវជ្រាវ ឬការអង្កេត
- ការពិនិត្យមើល ការស្រាវជ្រាវ និងការរាយការណ៍ជូនក្រសួងមហាផ្ទៃករណីមានការ**រំលោភអំណាច**
- ការពិនិត្យមើល និងការដោះស្រាយ**សកម្មភាពខុសច្បាប់**អនុវត្តដោយក្រុមប្រឹក្សា សមាជិកក្រុមប្រឹក្សា គណៈអភិបាល ឬបុគ្គលិករបស់ក្រុមប្រឹក្សា
- ការពិនិត្យមើល និងការចាត់វិធានការ ដើម្បីដោះស្រាយ**វិវាទនៅមូលដ្ឋាន**
- ការពិនិត្យមើល និងការដោះស្រាយសំណូមពរ ឬ**ពាក្យបណ្តឹងរបស់ប្រជាពលរដ្ឋ**
- ការពិនិត្យមើល និងការអនុម័តរបាយការណ៍ការរៀបចំដោយគណៈអភិបាល។

(មាត្រា ១៥ នៃអនុក្រឹត្យលេខ២១៦)

## ផ្នែកទី ៤: តួនាទីរបស់ប្រធាន សមាជិកក្រុមប្រឹក្សា គណៈអភិបាល

### តួនាទីអង្គប្រជុំក្រុមប្រឹក្សា

✓ **ប្រធានក្រុមប្រឹក្សា** គឺជាប្រធានអង្គប្រជុំទាំងអស់របស់ក្រុមប្រឹក្សា (មាត្រា ៦៣ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ប្រការ ២០ នៃគំរូបទបញ្ជាផ្ទៃក្នុង) ។

✓ ក្នុងករណីដែល**ប្រធានអវត្តមាន** សមាជិកក្រុមប្រឹក្សាដែលមានឈ្មោះបន្ទាប់ នៅលើបញ្ជីបេក្ខជនឈរឈ្មោះឆ្នោតជាមួយគ្នា ត្រូវធ្វើជាប្រធាន។ ប្រសិនបើសមាជិកក្រុមប្រឹក្សានោះ ក៏អវត្តមានដែរ ប្រធានអង្គប្រជុំគឺជាសមាជិកក្រុមប្រឹក្សាដែលមានឈ្មោះនៅលើគេបង្អស់របស់បញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោត ដែលទទួលបានសម្លេងឆ្នោតលំដាប់ទីពីរ។ ប្រសិនបើបុគ្គលនេះ ក៏អវត្តមានដែរ សមាជិកក្រុមប្រឹក្សាដែលធ្វើជាប្រធាន គឺជាសមាជិកក្រុមប្រឹក្សាដែលមានឈ្មោះបន្ទាប់ នៅលើបញ្ជីបេក្ខជនឈរឈ្មោះឆ្នោតដែលទទួលបានសម្លេងឆ្នោតលំដាប់ទីពីរ (មាត្រា ៦៥ នៃច្បាប់ស្តីពីការគ្រប់គ្រង រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ប្រការ ២០ នៃគំរូបទបញ្ជាផ្ទៃក្នុង) ។

✓ ប្រធានក្រុមប្រឹក្សា មានការទទួលខុសត្រូវក្នុងការអញ្ជើញសមាជិកក្រុមប្រឹក្សាឱ្យចូលរួមនៅក្នុងអង្គប្រជុំទាំងអស់របស់ក្រុមប្រឹក្សា។ សម្រាប់ការប្រជុំសាមញ្ញទាំងអស់ **លិខិតអញ្ជើញ** ត្រូវចែកជូនសមាជិកក្រុមប្រឹក្សាគ្រប់រូបយ៉ាងតិចបីថ្ងៃធ្វើការ មុនពេលប្រជុំ។ **របៀបវារៈ** ត្រូវមានភ្ជាប់ជាមួយលិខិតអញ្ជើញ រួមជាមួយ**ឯកសារពាក់ព័ន្ធផ្សេងទៀត** (ប្រការ ៣ នៃគំរូបទបញ្ជាផ្ទៃក្នុង) ។

✓ នៅក្នុងអំឡុងពេលប្រជុំ ប្រធានត្រូវ:

- ធានាថា កិច្ចប្រជុំ ប្រព្រឹត្តិទៅប្រកបដោយលក្ខណៈប្រជាធិបតេយ្យ ដោយមានអព្យាក្រឹត្យភាព មានសណ្តាប់ធ្នាប់ និង ដោយគ្មានការរំខាន
- ផ្តល់លទ្ធភាពឱ្យសមាជិកក្រុមប្រឹក្សាទាំងអស់សំដែងមតិយោបល់របស់ខ្លួន
- អនុវត្តបទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សា
- (មាត្រា ៦៤ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ប្រការ ២១ នៃគំរូបទបញ្ជាផ្ទៃក្នុង) ។

- ✓ ប្រធាន អាច**អញ្ជើញបុគ្គលដែលពាក់ព័ន្ធ**ឱ្យមកចូលរួមនៅក្នុងកិច្ចប្រជុំរបស់ក្រុមប្រឹក្សាដូចជា មន្ត្រីរបស់ស្ថាប័នផ្សេងទៀតរបស់រាជរដ្ឋាភិបាល ឬបុគ្គលពាក់ព័ន្ធផ្សេងទៀត។ បុគ្គលដែលត្រូវបានអញ្ជើញឱ្យចូលរួមនៅក្នុងកិច្ចប្រជុំរបស់ក្រុមប្រឹក្សា មានសិទ្ធិបញ្ចេញមតិយោបល់របស់ខ្លួន ប៉ុន្តែមិនអាចបោះឆ្នោតឡើយ ( ប្រការ ២៣ នៃគំរូបទបញ្ជាផ្ទៃក្នុង) ។

## តួនាទីរបស់សមាជិកក្រុមប្រឹក្សា

- ✓ **សមាជិកក្រុមប្រឹក្សាគ្រប់រូប មានសិទ្ធិបញ្ចេញមតិយោបល់របស់ខ្លួន**។ គ្មានសមាជិកក្រុមប្រឹក្សាណាម្នាក់ អាចត្រូវចាប់ខ្លួន ឃុំខ្លួន ឬជាកម្មវត្ថុនៃអំពើ ឬវិធានការមួយដោយឈរលើមូលដ្ឋានដែលសមាជិកក្រុមប្រឹក្សារូបនោះបានសំដែងមតិយោបល់ ឬបានបោះឆ្នោតទៅតាមរបៀបណាមួយនៅក្នុងអំឡុងពេលនៃកិច្ចប្រជុំរបស់ក្រុមប្រឹក្សា (មាត្រា ៧៣ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ប្រការ ២២ នៃគំរូបទបញ្ជាផ្ទៃក្នុង) ។
- ✓ សមាជិកក្រុមប្រឹក្សា មានសិទ្ធិ**សាកសួរអភិបាល**អំពីការរីកចំរើននៅក្នុងការអនុវត្តសេចក្តីសម្រេច និងដីការបស់ក្រុមប្រឹក្សា និងសកម្មភាពផ្សេងទៀតដែលអនុវត្តដោយគណៈអភិបាល (មាត្រា ១៥៧, ១៥៩ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ប្រការ ២៤ នៃគំរូបទបញ្ជាផ្ទៃក្នុង) ។
- ✓ ដើម្បីសំដែងមតិយោបល់របស់ខ្លួន សមាជិកក្រុមប្រឹក្សា ត្រូវ**លើកដៃ** ដើម្បីទទួលបានការយល់ព្រមពីប្រធានមុននឹងចាប់ផ្តើមសំដែងមតិយោបល់។ សមាជិកក្រុមប្រឹក្សា អាចនិយាយរយៈពេល **១៥ នាទី** ទាក់ទងនឹងបញ្ហាដែលកំពុងពិភាក្សា។ ប្រធាន អាចអនុញ្ញាតឱ្យសមាជិកក្រុមប្រឹក្សា និយាយ ៥ នាទីបន្ថែមទៀត និង៥នាទីបន្ថែមទៀតជាលើកទីពីរ (ប្រការ ១២ នៃគំរូបទបញ្ជាផ្ទៃក្នុង) ។
- ✓ សមាជិកក្រុមប្រឹក្សាម្នាក់ មិនមានសិទ្ធិសំដែងមតិយោបល់ក្នុងនាមក្រុមប្រឹក្សាទាំងមូលបានឡើយ លើកលែងតែពេលដែលសមាជិកក្រុមប្រឹក្សានោះ បានទទួលការអនុញ្ញាតពីក្រុមប្រឹក្សាឱ្យធ្វើដូច្នេះ (ប្រការ ២២ នៃគំរូបទបញ្ជាផ្ទៃក្នុង) ។

## តួនាទីរបស់គណៈអភិបាល

- ✓ អភិបាល ឬគណៈអភិបាល អាចស្នើសុំឱ្យប្រធានដាក់បញ្ចូលកិច្ចការណាមួយទៅក្នុង**របៀបវារៈ**នៃកិច្ចប្រជុំរបស់ក្រុមប្រឹក្សា។ អភិបាល ឬគណៈអភិបាល ក៏អាចស្នើសុំផងដែរឱ្យប្រធានកោះហៅ**កិច្ចប្រជុំវិសាមញ្ញរបស់ក្រុមប្រឹក្សា** (ប្រការ ៣០ នៃគំរូបទបញ្ជាផ្ទៃក្នុង) ។

✓ នៅគ្រប់កិច្ចប្រជុំទាំងអស់ គណៈអភិបាល ត្រូវ**រាយការណ៍ទៅក្រុមប្រឹក្សា** អំពីលទ្ធផល និងការរីកចំរើននៅក្នុងការអនុវត្តសេចក្តីសម្រេច ដីកា និងសកម្មភាពនានារបស់ក្រុមប្រឹក្សា បន្ទាប់ពីកិច្ចប្រជុំលើកមុន។ សេចក្តីរាយការណ៍ ត្រូវដាក់បញ្ចូលលទ្ធផល និងការរីកចំរើន ដែលសម្រេចបានដោយគណៈអភិបាល (តាមរយៈបុគ្គលិករបស់ក្រុមប្រឹក្សា) និងដោយគណៈកម្មាធិការរបស់ក្រុមប្រឹក្សា (មាត្រា១៥៩ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ប្រការ៣១ នៃគំរូបទបញ្ជាផ្ទៃក្នុង)។

គណៈអភិបាល ត្រូវ**ធ្វើការសិក្សាស្រាវជ្រាវ** ដើម្បី**ផ្តល់យោបល់ល្អៗ**ដល់ក្រុមប្រឹក្សាដែលអាចជួយក្រុមប្រឹក្សាឱ្យធ្វើសេចក្តីសម្រេចដែលផ្អែកលើព័ត៌មាន (មាត្រា ២៩. ៨៦. ១៤៧ នៃអនុក្រឹត្យលេខ២១៦)។

**ឧទាហរណ៍** គណៈអភិបាល អាចចាត់ចែងការសិក្សា ដើម្បីដឹងថាហេតុអ្វីបានជាកុមារមកចាក់ថ្នាំបង្ការមានចំនួនកាន់តែតិច។

✓ គណៈអភិបាល អាចត្រូវសាកសួរឱ្យ**បំភ្លឺអំពីកិច្ចការណាមួយ**នៅក្នុងកិច្ចប្រជុំរបស់ក្រុមប្រឹក្សា ហើយអាចតម្រូវឱ្យ**ឆ្លើយសំណួរអំពីការរីកចំរើន**នៅក្នុងការអនុវត្តសេចក្តីសម្រេច និងដីកា និងសកម្មភាពផ្សេងទៀតរបស់ក្រុមប្រឹក្សាដែលអនុវត្តដោយគណៈអភិបាល (មាត្រា ១៥៧ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ប្រការ ២៤ នៃគំរូបទបញ្ជាផ្ទៃក្នុង)។

**ឧទាហរណ៍**

ឧបមាថា ក្រុមប្រឹក្សា បានសម្រេចអោយចែកអង្ករនៅក្នុងអំឡុងពេលខ្វះស្បៀងអាហារបន្ទាប់ពីទឹកជំនន់ដ៏អាក្រក់មួយ។

សមាជិកក្រុមប្រឹក្សាម្នាក់ត្រូវបានទាក់ទងដោយប្រជាពលរដ្ឋមួយចំនួននៅក្នុងភូមិរបស់គាត់។ ប្រជាពលរដ្ឋបានត្អូញត្អែរថា ពួកគាត់មិនទាន់បានទទួលអង្ករនៅឡើយ។ នៅក្នុងអំឡុងពេលនៃកិច្ចប្រជុំប្រចាំខែរបស់ក្រុមប្រឹក្សា សមាជិកក្រុមប្រឹក្សានោះអាចសាកសួរ គណៈអភិបាលអំពីករណីនេះ។ ក្នុងចំណោមសំណួរជាច្រើន សមាជិកក្រុមប្រឹក្សានេះអាចស្នើរឱ្យអភិបាលបញ្ជាក់អំពីរបៀបដែលគណៈអភិបាល ជ្រើសរើសប្រជាពលរដ្ឋត្រូវទទួលអង្ករ ហើយអំពីពេលវេលានៃការចែកអង្ករ។ ល។

ផ្សេងៗ

- ✓ **ប្រធានគណៈកម្មាធិការនានារបស់ក្រុមប្រឹក្សា** មានសិទ្ធិចូលរួមនៅក្នុងកិច្ចប្រជុំរបស់ក្រុមប្រឹក្សា (ប្រការ ១៤ នៃគំរូបទបញ្ជាផ្ទៃក្នុង)។

> ចំពោះបញ្ហាទាំងអស់ ត្រូវបំរុងពេលទុកដោយឡែកសម្រាប់ឱ្យតំណាងរបស់គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារទស្សនៈ សំណូមពរ និងអនុសាសន៍របស់ខ្លួន។

- ✓ សមាជិកពីររូបរបស់**គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ** មានសិទ្ធិចូលរួម និងផ្តល់ សំណូមពរ និងអនុសាសន៍នៅក្នុងកិច្ចប្រជុំទាំងអស់របស់ក្រុមប្រឹក្សា។ សមាជិករបស់គណៈកម្មាធិការនេះ មានសិទ្ធិដូចសមាជិកក្រុមប្រឹក្សាដែរក្នុងការទទួលបានរបៀបវារៈ និងឯកសារពាក់ព័ន្ធផ្សេងទៀតសម្រាប់កិច្ចប្រជុំរបស់ក្រុមប្រឹក្សា (មាត្រា ១២៨-១៣២ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ប្រការ ១៤ នៃគំរូបទបញ្ជាផ្ទៃក្នុង)។

- ✓ **គណៈកម្មាធិការមួយ ឬច្រើនជាងមួយរបស់ក្រុមប្រឹក្សា** អាចត្រូវបានស្នើសុំឱ្យ**ធ្វើការស្រាវជ្រាវ** និងផ្តល់ព័ត៌មានដល់ក្រុមប្រឹក្សា ដើម្បីដោះស្រាយប្រធានបទថ្មី។ គណៈអភិបាល និងនាយករដ្ឋបាល ត្រូវផ្តល់ការគាំទ្រផ្នែកច្បាប់ និងផ្នែកបច្ចេកទេសដល់គណៈកម្មាធិការ (មាត្រា ១២២ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ប្រការ ២៨, ២៩ នៃគំរូបទបញ្ជាផ្ទៃក្នុង)។

- ✓ **នាយករដ្ឋបាលត្រូវ**ធ្វើជាលេខាធិការរបស់ក្រុមប្រឹក្សា និងប្រធានក្រុមប្រឹក្សានៅក្នុងការរៀបចំសេចក្តីព្រាងរបៀបវារៈ លិខិតអញ្ជើញ កំណត់ហេតុនៃកិច្ចប្រជុំ និងឯកសារពាក់ព័ន្ធផ្សេងទៀតរបស់កិច្ចប្រជុំ (ប្រការ ៣២ នៃគំរូបទបញ្ជាផ្ទៃក្នុង មាត្រា ៤៥, ១០២, ១៦៣ នៃអនុក្រឹត្យលេខ២១៦)។

- ✓ **នាយករដ្ឋបាល** មានការទទួលខុសត្រូវក្នុងការទុកដាក់ និងរក្សាសុវត្ថិភាពឯកសារប្រជុំ រួមទាំងរបៀបវារៈ និងកំណត់ហេតុ ហើយអាច**ផ្តល់ឯកសារទាំងនោះដល់សាធារណជនក្នុងករណីមានសំណូមពរពីសាធារណជន** (ប្រការ ៣៣ នៃគំរូបទបញ្ជាផ្ទៃក្នុង)។

- ✓ នាយករដ្ឋបាល អាចចូលរួម និងរួមចំណែកមតិយោបល់នៅក្នុងអំឡុងពេលនៃកិច្ចប្រជុំរបស់ក្រុមប្រឹក្សា។ នាយករដ្ឋបាល ត្រូវផ្តល់មតិយោបល់បច្ចេកទេសដល់ក្រុមប្រឹក្សា ដើម្បីឱ្យក្រុមប្រឹក្សាមានលទ្ធភាពធ្វើសេចក្តីសម្រេចកាន់តែប្រសើរ។ ទោះជាយ៉ាងណាក៏ដោយ នាយករដ្ឋបាលមិនមានសិទ្ធិបោះឆ្នោតឡើយ (មាត្រា ៤៧, ១០៤, ១៦៤ នៃអនុក្រឹត្យលេខ២១៦)។

## ផ្នែកទី ៥: សេចក្តីសម្រេច និងដីការបស់ក្រុមប្រឹក្សា

- ✓ នៅគ្រប់កិច្ចប្រជុំក្រុមប្រឹក្សាអាចដាក់ចេញធ្វើសេចក្តីសម្រេច និងដាក់ចេញដីកាតាមការចាំបាច់ (មាត្រា ៣៦ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មាត្រា ១៤ នៃអនុក្រឹត្យលេខ២១៦ ប្រការ ១៥ នៃគំរូបទបញ្ជាផ្ទៃក្នុង) ។

- ✓ ក្រុមប្រឹក្សាអាចបង្កើតគណៈកម្មាធិការដើម្បីរៀបចំសេចក្តីព្រាងដីកាសម្រាប់ដាក់ជូនក្រុមប្រឹក្សាធ្វើការពិចារណាអនុម័ត។ គណៈអភិបាលត្រូវណែនាំនាយករដ្ឋបាល និងអង្គភាពរដ្ឋបាលដែលពាក់ព័ន្ធដល់ការគាំទ្រផ្នែកច្បាប់ និងបច្ចេកទេសដល់គណៈកម្មាធិការនោះ ( មាត្រា ១២, ៦៨, ១៣០ នៃអនុក្រឹត្យលេខ២១៦ ) ។

- ✓ សេចក្តីសម្រេច ឬដីការបស់ក្រុមប្រឹក្សាមានសុពលភាពប្រសិនបើសេចក្តីសម្រេច ឬដីកានោះ **ត្រូវបានអនុម័តដោយសមាជិកក្រុមប្រឹក្សាច្រើនជាងពាក់កណ្តាលនៃសមាជិកក្រុមប្រឹក្សាទាំងអស់**។ ក្នុងករណីមានសម្លេងឆ្នោតស្មើគ្នា សម្លេងឆ្នោតរបស់ប្រធាន គឺជាសម្លេងឆ្នោតសម្រេច ( មាត្រា ៦៦, ៦៧ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ប្រការ ១៦ នៃគំរូបទបញ្ជាផ្ទៃក្នុង) ។

- ✓ ការបោះឆ្នោតលើសេចក្តីសម្រេច ឬដីកា ត្រូវធ្វើឡើងដោយ**ការលើកដៃ**។ សមាជិកក្រុមប្រឹក្សា អាច "យល់ព្រម" "មិនយល់ព្រម" "អព្យាក្រឹត្យ"។ ទោះជាយ៉ាងក៏ដោយ នៅក្នុងកាលៈទេសៈជាក់លាក់មួយចំនួន ការបោះឆ្នោតត្រូវធ្វើឡើងជាសម្ងាត់ (មាត្រា ៦៦, ៦៧ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ប្រការ ១៧, ៥០ នៃគំរូបទបញ្ជាផ្ទៃក្នុង) ។

- ✓ ដើម្បី**កែតម្រូវសេចក្តីសម្រេច ឬដីការបស់ក្រុមប្រឹក្សា** សមាជិកក្រុមប្រឹក្សាចំនួនមួយភាគបីនៃសមាជិកក្រុមប្រឹក្សាទាំងអស់ ត្រូវស្នើសុំជាលាយលក្ខអក្សរ។ សំណើ ត្រូវគូសបញ្ជាក់អំពីមូលហេតុនៃការស្នើសុំកែតម្រូវ។ ក្រុមប្រឹក្សាត្រូវសិក្សាសំណើ ហើយត្រូវដាក់បញ្ចូលសំណើនៅក្នុងរបៀបវារៈនៃកិច្ចប្រជុំលើកក្រោយ (ប្រការ ១៨ នៃគំរូបទបញ្ជាផ្ទៃក្នុង) ។

- ✓ ដើម្បីកែតម្រូវបទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សា ត្រូវមានការយល់ព្រមពីសមាជិកក្រុមប្រឹក្សាច្រើនជាងពាក់កណ្តាលនៃសមាជិកក្រុមប្រឹក្សាទាំងអស់ ( ប្រការ ៥១ នៃគំរូបទបញ្ជាផ្ទៃក្នុង) ។

- ✓ ប្រធាន និងគណៈអភិបាល ត្រូវធានាថាព័ត៌មានអំពីសេចក្តីសម្រេច ឬដីការបស់ក្រុមប្រឹក្សា **ត្រូវបានផ្សព្វផ្សាយជាសាធារណៈ** ( មាត្រា ៥១ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ប្រការ ១៩ នៃគំរូបទបញ្ជាផ្ទៃក្នុង) ។

## ផ្នែកទី ៦: របៀបវារៈ កូរ៉ុម និងកំណត់ហេតុនៃកិច្ចប្រជុំ

### របៀបវារៈ

- ✓ **ប្រធាន** ដោយមានការពិគ្រោះយោបល់ជាមួយអភិបាល រៀបចំសេចក្តីព្រាងរបៀបវារៈសម្រាប់ការប្រជុំនីមួយៗ (ប្រការ ៥ នៃគំរូបទបញ្ជាផ្ទៃក្នុង) ។
- ✓ សេចក្តីព្រាងរបៀបវារៈ ត្រូវតែដាក់ជូនក្រុមប្រឹក្សាឱ្យ**អនុម័ត**នៅក្នុងអំឡុងពេលនៃកិច្ចប្រជុំនីមួយៗ (ប្រការ ៥ នៃគំរូបទបញ្ជាផ្ទៃក្នុង) ។
- ✓ **បុគ្គលខាងក្រោម អាចស្នើសុំឱ្យដាក់បញ្ចូលកិច្ចការមួយទៅក្នុងរបៀបវារៈនៃកិច្ចប្រជុំ:**
  - ប្រធានក្រុមប្រឹក្សា
  - សមាជិកមួយភាគបីនៃសមាជិកក្រុមប្រឹក្សាទាំងអស់
  - ប្រធានគណៈកម្មាធិការរបស់ក្រុមប្រឹក្សា
  - អភិបាល
  - គណៈអភិបាល

  (ប្រការ ៥ នៃគំរូបទបញ្ជាផ្ទៃក្នុង) ។

### កូរ៉ុម

- ✓ កិច្ចប្រជុំរបស់ក្រុមប្រឹក្សាមានសុពលភាពដរាបណាមានវត្តមានរបស់**សមាជិកក្រុមប្រឹក្សាមិនតិចជាងពាក់កណ្តាលនៃសមាជិកទាំងអស់ចូលរួមប្រជុំ** (មាត្រា ៦៦ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងប្រការ៨ នៃគំរូបទបញ្ជាផ្ទៃក្នុង) ។
- ✓ ប្រសិនបើសមាជិកក្រុមប្រឹក្សាម្នាក់ ឬច្រើននាក់ដើរចេញនៅក្នុងអំឡុងពេលនៃកិច្ចប្រជុំដែលធ្វើឱ្យកិច្ចប្រជុំនោះលែងមានកូរ៉ុម ប្រធានត្រូវបញ្ឈប់ និងពន្យាពេលនៃកិច្ចប្រជុំ (ប្រការ ១១ នៃគំរូបទបញ្ជាផ្ទៃក្នុង) ។

## កំណត់ហេតុនៃកិច្ចប្រជុំ

✓ កំណត់ហេតុនៃកិច្ច ត្រូវកត់ត្រា:

- ឈ្មោះអ្នកដែលចូលរួមនៅក្នុងកិច្ចប្រជុំ
- បញ្ជីឈ្មោះសមាជិកក្រុមប្រឹក្សាដែលអវត្តមាន
- សេចក្ដីសម្រេចដែលអនុម័តដោយក្រុមប្រឹក្សា
- មតិយោបល់សំខាន់ៗដែលធ្វើឡើងនៅក្នុងអំឡុងពេលនៃកិច្ចប្រជុំ និង
- កិច្ចការផ្សេងទៀតដែលមានបញ្ជាក់នៅក្នុងបទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សា
- (ប្រការ ៣៤, ៣៥ នៃគំរូបទបញ្ជាផ្ទៃក្នុង) ។

✓ កំណត់ហេតុត្រូវចែកជូនសមាជិកក្រុមប្រឹក្សាផ្សេងទៀតនៅក្នុងរយៈពេលយ៉ាងតិច៥ថ្ងៃមុនកិច្ចប្រជុំលើកក្រោយ ។ សេចក្ដីព្រាងកំណត់ហេតុត្រូវតែអនុម័តនៅក្នុងកិច្ចប្រជុំបន្ទាប់ (ប្រការ ៣៤-៣៧ នៃគំរូបទបញ្ជាផ្ទៃក្នុង) ។

## ផ្នែកទី ៧: អវត្តមាន និងវិន័យ

### អវត្តមាន

- ✓ សមាជិកក្រុមប្រឹក្សា ត្រូវបានតម្រូវឱ្យចូលរួមនៅក្នុងកិច្ចប្រជុំទាំងអស់របស់ក្រុមប្រឹក្សា។ ទោះជាយ៉ាងណាក៏ដោយ ក្នុងករណីដែលសមាជិកក្រុមប្រឹក្សាមិនអាចចូលរួមនៅក្នុងកិច្ចប្រជុំរបស់ក្រុមប្រឹក្សា សមាជិកក្រុមប្រឹក្សានោះត្រូវដាក់សំណើសុំអវត្តមានពីកិច្ចប្រជុំជូនទៅប្រធាន។ សំណើត្រូវដាក់ជូននៅក្នុងរយៈពេលយ៉ាងតិច**មួយថ្ងៃមុនកិច្ចប្រជុំ** (ប្រការ ៣៨ នៃគំរូបទបញ្ជាផ្ទៃក្នុង)។
- ✓ ប្រសិនបើសមាជិកក្រុមប្រឹក្សាណាម្នាក់ចាកចេញពីកិច្ចប្រជុំរបស់ក្រុមប្រឹក្សាមុនពេលបញ្ចប់នៃកិច្ចប្រជុំ សមាជិកក្រុមប្រឹក្សានេះត្រូវបានចាត់ទុកថាអវត្តមានដោយគ្មានការអនុញ្ញាត (ប្រការ ៣៨ នៃគំរូបទបញ្ជាផ្ទៃក្នុង)។
- ✓ សមាជិកក្រុមប្រឹក្សាត្រូវបាត់បង់សមាជិកភាពពីសមាជិកក្រុមប្រឹក្សាក្នុងករណីសាមីខ្លួនមិនបានចូលរួមកិច្ចប្រជុំសាមញ្ញរបស់ក្រុមប្រឹក្សាជាប់ៗគ្នាចាប់ពី២ដងឡើងទៅដោយគ្មានច្បាប់អនុញ្ញាត (មាត្រា ២២ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ប្រការ ៤០ នៃគំរូបទបញ្ជាផ្ទៃក្នុង)។
- ✓ សមាជិកក្រុមប្រឹក្សាដែលអវត្តមានពីកិច្ចប្រជុំរបស់ក្រុមប្រឹក្សាដោយគ្មានការអនុញ្ញាត នឹងត្រូវ**វិន័យ** (ប្រការ ៤២ នៃគំរូបទបញ្ជាផ្ទៃក្នុង)។

### វិន័យ

- ✓ សមាជិកក្រុមប្រឹក្សា **អាចត្រូវដាក់ទណ្ឌកម្ម**ដោយសារ**អវត្តមានពីកិច្ចប្រជុំដោយគ្មានការអនុញ្ញាត** ឬដោយសារ**ប្រកាន់ឥរិយាបថមិនសមរម្យ**នៅក្នុងអំឡុងពេលនៃកិច្ចប្រជុំរបស់ក្រុមប្រឹក្សា (មាត្រា ៤៣ នៃគំរូបទបញ្ជាផ្ទៃក្នុង)។
- ✓ ទណ្ឌកម្មអាចរួមមាន:
    - សេចក្តីរំលឹកដាស់តឿន ឬការព្រមានដែលអាច ឬ មិនអាចកត់ត្រានៅក្នុងកំណត់ហេតុនៃកិច្ចប្រជុំ
    - ការកាត់ចំណែកខ្លះនៃប្រាក់ឧបត្ថម្ភរបស់សមាជិកក្រុមប្រឹក្សា
    - ការបាត់បង់សមាជិកភាពនៅក្នុងក្រុមប្រឹក្សា
    - (ប្រការ ៤៤, ៤៦ នៃគំរូបទបញ្ជាផ្ទៃក្នុង)។
- ✓ ក្រៅពីនេះ ប្រធានអាចបណ្តេញចេញពីក្នុងកិច្ចប្រជុំចំពោះ**សមាជិកគណៈអភិបាល** ឬបុគ្គលដែលបានអញ្ជើញផ្សេងទៀត ប្រសិនបើបុគ្គលនោះបន្តការរំខានបន្ទាប់ពីបានទទួលការព្រមានម្តងរួចហើយ (ប្រការ ២៦, ៤៧, ៤៨ នៃគំរូបទបញ្ជាផ្ទៃក្នុង)។

## វគ្គទី ២:

## មេរៀនសង្ខេប

- ✓ កិច្ចប្រជុំរបស់ក្រុមប្រឹក្សា មានសារៈសំខាន់ជាសារវន្តសម្រាប់**គណនេយ្យភាពតាមបែបប្រជាធិបតេយ្យ**។ ដើម្បីប្រកាន់យកជម្រើស និងធ្វើសេចក្ដីសម្រេចផ្នែកនយោបាយក្នុងនាមប្រជាពលរដ្ឋរបស់ខ្លួន សមាជិកក្រុមប្រឹក្សាត្រូវមាន**ឱកាសពិចារណា** ដែលកិច្ចប្រជុំរបស់ក្រុមប្រឹក្សាផ្ដល់ឱ្យ។
- ✓ ក្រុមប្រឹក្សាទាំងអស់ ត្រូវអនុម័តបទបញ្ជាផ្ទៃក្នុងរបស់ខ្លួនក្នុងទម្រង់ជាដីកា។ កិច្ចប្រជុំទាំងអស់របស់ក្រុមប្រឹក្សាត្រូវធ្វើឡើងអនុលោមទៅតាមបទបញ្ជាផ្ទៃក្នុងរបស់ខ្លួន។
- ✓ ក្រុមប្រឹក្សាមានកិច្ចប្រជុំពីរប្រភេទ គឺកិច្ចប្រជុំសាមញ្ញ និងកិច្ចប្រជុំវិសាមញ្ញ។ គ្រប់ក្រុមប្រឹក្សាមានកិច្ចប្រជុំសាមញ្ញយ៉ាងតិច ១២ ដងក្នុងមួយឆ្នាំ ។
- ✓ ក្រុមប្រឹក្សាទាំងអស់ត្រូវអនុម័ត ហើយបន្ទាប់មកផ្សព្វផ្សាយជាសាធារណៈនូវប្រតិទិនសម្រាប់កិច្ចប្រជុំសាមញ្ញរបស់ក្រុមប្រឹក្សាក្នុងរយៈពេលមួយឆ្នាំជាមុន។
- ✓ ប្រធានក្រុមប្រឹក្សា គឺជាប្រធានកិច្ចប្រជុំទាំងអស់របស់ក្រុមប្រឹក្សា។
- ✓ សមាជិកក្រុមប្រឹក្សាគ្រប់រូបមានសិទ្ធិសំដែងមតិយោបល់របស់ខ្លួន។ គ្មានសមាជិកក្រុមប្រឹក្សាណាម្នាក់អាចត្រូវចាប់ខ្លួន ឃុំខ្លួន ឬជាកម្មវត្ថុនៃអំពើ ឬវិធានការណាមួយដោយឈរលើមូលដ្ឋានដែលសមាជិកក្រុមប្រឹក្សានោះបានសំដែងមតិយោបល់ ឬបានបោះឆ្នោតទៅតាមរបៀបណាមួយនៅក្នុងអំឡុងពេលនៃកិច្ចប្រជុំរបស់ក្រុមប្រឹក្សា។
- ✓ នៅគ្រប់កិច្ចប្រជុំរបស់ក្រុមប្រឹក្សា គណៈអភិបាលត្រូវរាយការណ៍ជូនក្រុមប្រឹក្សាអំពីលទ្ធផល និងការរីកចំរើននៅក្នុងការអនុវត្តសេចក្ដីសម្រេច ដីកា និងសកម្មភាពរបស់ក្រុមប្រឹក្សាបន្ទាប់ពីកិច្ចប្រជុំលើកមុនរបស់ក្រុមប្រឹក្សា។ សមាជិកក្រុមប្រឹក្សាមានសិទ្ធិសាកសួរអភិបាល។
- ✓ ប្រធានគណៈកម្មាធិការទាំងអស់របស់ក្រុមប្រឹក្សា មានសិទ្ធិចូលរួមនៅក្នុងកិច្ចប្រជុំរបស់ក្រុមប្រឹក្សា។ សមាជិកពីររូបរបស់គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ ក៏មានសិទ្ធិចូលរួម និងផ្ដល់សំណូមពរ និងអនុសាសន៍ផងដែរ។
- ✓ សមាជិកក្រុមប្រឹក្សា អាចត្រូវដាក់ទណ្ឌកម្មដោយសារអវត្តមានពីរកិច្ចប្រជុំដោយគ្មានការអនុញ្ញាត ឬដោយសារប្រកាន់កិរិយាបទមិនសមរម្យនៅក្នុងអំឡុងពេលនៃកិច្ចប្រជុំ។

## វគ្គទីបី ៖

## ការងារជាក្រុម

**ការងារជាក្រុម ដូចមានពិពណ៌នាខាងក្រោម អាចមានលក្ខណៈមិនសមស្របសម្រាប់ការបណ្តុះបណ្តាលទាំងអស់ ។ សូមចាត់ទុកការងារជាក្រុមខាងក្រោមជាសំណូមពរតែប៉ុណ្ណោះ ។**

១. ចែកសិក្ខាកាមជាក្រុមដែលមានសមាជិកមិនលើសពី ៨ នាក់

២. ផ្តល់លំហាត់ខាងក្រោមអោយក្រុមនីមួយៗ ។

**លំហាត់៖ អ្វីដែលមិនត្រូវធ្វើនៅពេលប្រជុំក្រុមប្រឹក្សា**

សមាជិកក្រុមប្រឹក្សានៅខេត្ត ក បានជួបជុំគ្នានៅក្នុងកិច្ចប្រជុំសាមញ្ញប្រចាំខែ។

ប្រគល់តួនាទីខាងក្រោមដល់សមាជិកនៅក្នុងក្រុមរបស់អ្នក៖

- ✓ ប្រធានក្រុមប្រឹក្សាម្នាក់
- ✓ សមាជិកក្រុមប្រឹក្សាម្នាក់
- ✓ សមាជិកម្នាក់របស់គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ
- ✓ អភិបាលម្នាក់
- ✓ ប្រជាពលរដ្ឋម្នាក់
- ✓ តំណាងអង្គការនៅសហគមន៍ម្នាក់
- ✓ ប្រធានមន្ទីរកសិកម្មដែលត្រូវបានអញ្ជើញឱ្យចូលរួម

ធ្វើការដើរតួរយៈពេល ៥ នាទី ដោយបង្ហាញអ្វីដែលមិនត្រូវធ្វើនៅពេលប្រជុំក្រុមប្រឹក្សា ។ ដាក់បញ្ចូលការបំពានយ៉ាងតិច ៥ លើគំរូបទបញ្ជាផ្ទៃក្នុងរបស់ក្រសួងមហាផ្ទៃ។

អ្នកចូលរួមផ្សេងទៀត មានតួនាទីកត់ត្រាទុកការបំពានដែលខ្លួនសង្កេតឃើញ។ បន្ទាប់ពីការដើរតួ ត្រូវបញ្ចប់ អ្នកចូលរួម ត្រូវបានស្នើសុំឱ្យចែករំលែកការបំពានដែលខ្លួនបានសង្កេតឃើញ។ បន្ទាប់មក ការដើរតួរបស់ក្រុមដែលពន្យល់ពីរបៀបកែតម្រូវការបំពានដែលបានបង្ហាញនៅក្នុងការដើរតួ ។

# មេរៀនសម្រាប់ការយល់ដឹង និង ការបណ្តុះបណ្តាលអំពី ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

## មេរៀនទី ១០:

## ទំនាក់ទំនងអន្តររដ្ឋបាល

## រាជរដ្ឋាភិបាល និងក្រុមប្រឹក្សានៅថ្នាក់ក្រោមជាតិ

វគ្គទី ១៖

១. សេចក្តីផ្តើម

២. គ.ជ.អ.ប និងក្រសួងកំណែទម្រង់សំខាន់ៗ

៣. ការផ្ទេរមុខងារតាមវិស័យដល់ក្រុមប្រឹក្សា

៤. ក្រសួង ~ ក្រុមប្រឹក្សា៖ ទំនាក់ទំនង វិវាទ

៥. ការតែងតាំងនៅថ្នាក់ជាតិ

៦. អភិបាល៖ តំណាងរបស់រាជរដ្ឋាភិបាល

៧. គណៈកម្មាធិការរបស់ក្រុមប្រឹក្សា

៨. រដ្ឋបាលនៅថ្នាក់ក្រោមជាតិ

# ផ្នែកទី ១: សេចក្តីផ្តើម

មុនពេលអនុម័តច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ទំនាក់ទំនងរវាងរាជរដ្ឋាភិបាល និង រដ្ឋបាលថ្នាក់ក្រោមជាតិដែលត្រូវបានតែងតាំងមានលក្ខណៈជាខ្សែបណ្តោយ ដោយមានរដ្ឋបាលដែលត្រូវតែងតាំងនៅថ្នាក់ខេត្ត ក្រុង ស្រុក ខណ្ឌ ស្ថិតនៅក្រោមការចង្អុលណែនាំ និងការត្រួតពិនិត្យរបស់រាជរដ្ឋាភិបាល។ រដ្ឋបាលថ្នាក់ក្រោមជាតិ មានគណនេយ្យភាពដោយត្រង់ទៅថ្នាក់ជាតិ។ ក្រសួងមហាផ្ទៃជាអ្នកស្នើឈ្មោះតែងតាំងអភិបាលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលត្រូវតែងតាំង ហើយបុគ្គលិករបស់រដ្ឋបាលដែលត្រូវតែងតាំង គឺជាបុគ្គលិករបស់ក្រសួងមហាផ្ទៃ។ ក្រៅពីនេះក្រសួងខ្សែ បណ្តោយជាច្រើន មានមន្ទីរ និងអង្គភាពខ្សែបណ្តោយ និងមានបុគ្គលិករបស់ខ្លួនដែលត្រូវរាយការណ៍ទៅក្រសួង ស្ថាប័នសាមីរៀងៗខ្លួន។

ឃុំ សង្កាត់ ដោយមានក្រុមប្រឹក្សាដែលត្រូវបានបោះឆ្នោតជ្រើសរើសឡើងចាប់ពីឆ្នាំ២០០២ មានស្វ័យភាពខ្ពស់ជាងថ្នាក់ក្រោមជាតិផ្សេងទៀត។ ក្រុមប្រឹក្សាឃុំ សង្កាត់មានការទទួលខុសត្រូវ និងមានមុខងារដែលទោះបីជាមានលក្ខណៈបង្គួរក្តី ក៏ខ្លួនអាចអនុវត្ត និងប្រើប្រាស់ទៅតាម។ អ្វីដែលសំខាន់នោះ ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវបោះឆ្នោតជ្រើសរើសឡើងរៀងរាល់៥ឆ្នាំ ដូច្នេះ ក្រុមប្រឹក្សាឃុំ សង្កាត់ មានគណនេយ្យភាពតាមបែបប្រជាធិបតេយ្យចំពោះប្រជាពលរដ្ឋរបស់ខ្លួន។ ផ្តើមពីនេះ ក្រុមប្រឹក្សាឃុំ សង្កាត់ ក៏មានគណនេយ្យភាពចំពោះរាជរដ្ឋាភិបាលផងដែរ។

បច្ចុប្បន្នក្រោមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មានតួអង្គអភិបាលកិច្ចថ្មីនៅលើឆាក ដោយចាប់ផ្តើមជាមួយនឹងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សានៅរាជធានី ខេត្ត ក្រុង ស្រុក និងខណ្ឌ។ ក្រុមប្រឹក្សាថ្មី ដូចគ្នា នឹងក្រុមប្រឹក្សាឃុំ សង្កាត់ដែរ មានការទទួលខុសត្រូវចំពោះអភិបាលកិច្ច និងការអភិវឌ្ឍនៅក្នុងដែនដីរបស់ខ្លួន។ ក្រុមប្រឹក្សាថ្មី ដូចគ្នានឹងក្រុមប្រឹក្សាឃុំ សង្កាត់ដែរគឺក្រុមប្រឹក្សាទាំងនោះត្រូវមានមុខងារ និងធនធានរបស់ខ្លួនផ្ទាល់ជាមួយស្វ័យភាពកាន់តែ ធំហើយមានគណនេយ្យភាព តាមបែបប្រជាធិបតេយ្យចំពោះប្រជាពលរដ្ឋរបស់ខ្លួនក៏ដូចជាចំពោះរាជរដ្ឋាភិបាល។

នៅពេលនេះ ជាមួយនឹងក្រុមប្រឹក្សាដែលជាប់ឆ្នោតថ្មីនៅគ្រប់ថ្នាក់ក្រោមជាតិ ទំនាក់ទំនងរវាងរាជរដ្ឋាភិបាល និងថ្នាក់ក្រោមជាតិនឹងបានកំពុង ឧទាហរណ៍: ស្រុកពីមុនជារដ្ឋបាលចំណុះសាលាខេត្តឥឡូវនេះបានក្លាយជារដ្ឋបាលមួយ ដែលមានស្វ័យភាព និងមានធនធានផ្ទាល់ខ្លួនអាចចាត់ចែងអភិវឌ្ឍមូលដ្ឋានរបស់ខ្លួនឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋមូលដ្ឋានមានការប្រែប្រួល ។ ការបង្កើតឱ្យមានក្រុមប្រឹក្សាថ្មី ក៏នឹងធ្វើឱ្យមានការកែប្រែជាខ្លាំងផងដែរលើទំនាក់ទំនងនៅក្នុងចំណោមថ្នាក់ក្រោមជាតិនីមួយៗ ជាពិសេសក្រុមប្រឹក្សាត្រូវអភិវឌ្ឍទំនាក់ទំនងយ៉ាងរឹងមាំជាមួយមន្ទីរ ឬអង្គភាពខ្សែបណ្ដោយនៅក្នុងដែនដីរបស់ខ្លួន ។

ទំនាក់ទំនងក៏នឹងមានការកែប្រែផងដែរនៅក្នុងចំណោមថ្នាក់ក្រោមជាតិ ។ ឧទាហរណ៍ ស្រុកលែងស្ថិតនៅក្រោមចំណុះ របស់ខេត្ត ហើយក្រុមប្រឹក្សាឃុំ សង្កាត់ នឹងមានទំនាក់ទំនងថ្មីជាមួយរាជធានី ខេត្ត ក្រុង ស្រុក និង ខណ្ឌ។

**នៅក្នុងមេរៀននេះ មានការបង្ហាញអំពីទិដ្ឋភាពទូទៅអំពីទំនាក់ទំនងអន្តររដ្ឋបាលរវាងរាជរដ្ឋាភិបាល និងក្រុមប្រឹក្សានៅ ថ្នាក់ក្រោមជាតិ និងរដ្ឋបាលរបស់ខ្លួន**។ មេរៀនបន្ទាប់ (មេរៀនទី ១១) ពិភាក្សាទំនាក់ទំនងអន្តររដ្ឋបាលនៅក្នុងចំណោមក្រុម ប្រឹក្សានៅថ្នាក់ក្រោមជាតិ។

## ផ្នែកទី ២: គ.ជ.អ.ប និង ក្របខណ្ឌកំណែទម្រង់សំខាន់ៗ

### គណៈកម្មាធិការជាតិសំរាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប) និង ក្រុមប្រឹក្សា

**ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ**

**មាត្រា ១៩២-២៧៣**

✓ គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប) មាន**ការទទួលខុសត្រូវ រួមលើការអនុវត្តច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ** (មាត្រា ២០២ នៃច្បាប់ស្តីពីការគ្រប់ គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មាត្រា ១, ៥ នៃព្រះរាជក្រឹត្យស្តីពីការបង្កើត គ.ជ.អ.ប) ។

✓ គ.ជ.អ.ប មាន**សមាជិក**ដូចខាងក្រោម

- រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ (ប្រធាន)
- រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (អនុប្រធាន)
- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី (អនុប្រធាន)
- រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ (សមាជិក)
- រដ្ឋមន្ត្រីក្រសួងផែនការ (សមាជិក)
- រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍជនបទ (សមាជិក)

> រាជរដ្ឋាភិបាលកម្ពុជា មានកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដែលរៀបរាប់លម្អិតអំពីក្របខណ្ឌច្បាប់ ដែលមានចែងក្នុងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ សម្រាប់ធ្វើជាមូលដ្ឋានក្នុងការអនុវត្តការងាររបស់ខ្លួន ។
>
> រាជរដ្ឋាភិបាលកម្ពុជា ក៏បានអនុម័តផែនការអនុវត្តរយៈពេល៣ឆ្នាំដំបូង (ផ.អ.៣) នៃកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដែលបញ្ជាក់លម្អិតអំពីកម្មវិធីកំណែទម្រង់រយៈពេល៣ឆ្នាំដំបូង ។

- រដ្ឋមន្ត្រីក្រសួងកិច្ចការនារី (សមាជិក)
- រដ្ឋមន្ត្រីក្រសួងសុខាភិបាល (សមាជិក)
- រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (សមាជិក)
- រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា (សមាជិក)
- រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល (សមាជិក)
- រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ (សមាជិក)
- រដ្ឋលេខាធិការមួយរូបមកពីក្រសួងមហាផ្ទៃ (សមាជិក)
- រដ្ឋលេខាធិការមួយរូបមកពីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ (សមាជិក)
- តំណាងមួយរូបមកពីក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (សមាជិក)
- ប្រធានលេខាធិការដ្ឋាន គ.ជ.អ.ប (សមាជិកអចិន្ត្រៃយ៍)
- សមាជិកមួយចំនួនទៀតទៅតាមការចាំបាច់។

(មាត្រា ២ នៃព្រះរាជក្រឹត្យស្តីពីការបង្កើត គ.ជ.អ.ប)

✓ គ.ជ.អ.ប មានអនុគណៈកម្មាធិការចំនួនបួនគឺ

- **អនុគណៈកម្មាធិការមុខងារ និងធនធានៈ** ជួយ និងផ្តល់យោបល់ដល់ គ.ជ.អ.ប អំពីការងារទាក់ទងនឹងការកំណត់ និងការផ្ទេរមុខងារ និងធនធានដល់រដ្ឋបាលថ្នាក់ក្រោមជាតិ
- **អនុគណៈកម្មាធិការកិច្ចការសារពើពន្ធ និងហិរញ្ញវត្ថុៈ** ជួយ និងផ្តល់យោបល់ដល់ គ.ជ.អ.ប អំពីការងារទាក់ទងនឹងកិច្ចការសារពើពន្ធ និង

គ្រប់អនុគណៈកម្មាធិការ គ.ជ.អ.ប ត្រូវមានតំណាងក្រុមប្រឹក្សានៅគ្រប់ថ្នាក់ជាសមាជិក។ ប្រការនេះ មានន័យថាអនុគណៈកម្មាធិការនីមួយៗរបស់ គ.ជ.អ.ប រួមទាំងអនុគណៈ-កម្មាធិការមុខងារ និងធនធានដែលពាក់ព័ន្ធ នឹងការពិនិត្យមើលមុខងារឡើងវិញមានមនុស្សខាងក្រោមជាសមាជិកៈ

- តំណាងមួយរូបរបស់រាជធានី
- តំណាងមួយរូបរបស់ខេត្តទាំងអស់
- តំណាងមួយរូបរបស់ក្រុងទាំងអស់
- តំណាងមួយរូបរបស់ស្រុកទាំងអស់
- តំណាងមួយរូបរបស់ខណ្ឌទាំងអស់
- តំណាងមួយរូបរបស់ឃុំទាំងអស់
- តំណាងមួយរូបរបស់សង្កាត់ទាំងអស់

(មាត្រា ៣ នៃអនុក្រឹត្យស្តីពីការបង្កើតអនុគណៈកម្មាធិការ គ.ជ.អ.ប)។

ក្រៅពីនេះក្រុមប្រឹក្សាខេត្តនីមួយៗ ទំនាក់ទំនងជាមួយ គ.ជ.អ.ប និងក្រសួងអំពីការពិនិត្យមុខងារឡើងវិញនៅ ក្នុងខេត្ត។

ហិរញ្ញវត្ថុរបស់រដ្ឋបាលថ្នាក់ក្រោម ជាតិ

- **អនុគណៈកម្មាធិការបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ:** ជួយ និងផ្តល់ យោបល់ដល់ គ.ជ.អ.ប អំពីការងារ ទាក់ទងនឹងការរៀបចំកែសម្រួលបុគ្គលិកឡើងវិញ និងក្របខ័ណ្ឌបុគ្គលិកសម្រាប់ក្រុមប្រឹក្សាថ្នាក់ ក្រោមជាតិ និងទាក់ទងនឹងការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្សសម្រាប់ក្រុមប្រឹក្សា ថ្នាក់ ក្រោមជាតិ ។
- **អនុគណៈកម្មាធិការផែនការអភិវឌ្ឍន៍ថ្នាក់ក្រោមជាតិ:** ជួយ និងផ្តល់យោបល់ដល់ គ.ជ.អ.ប អំពីការងារទាក់ទង នឹងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគរបស់ក្រុមប្រឹក្សាថ្នាក់ក្រោមជាតិ ។

(មាត្រា ២, ៩, ១២ នៃអនុក្រឹត្យស្តីពីការបង្កើតអនុគណៈកម្មាធិការ គ.ជ.អ.ប) ។

**កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (២០១០-២០១៩)**

✓ កម្មវិធីជាតិ១០ឆ្នាំសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិរបស់រាជរដ្ឋាភិបាលកម្ពុជា ត្រូវបានអនុម័តនៅថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១០ ដើម្បីចង្អុលបង្ហាញការអនុវត្តកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ។ កម្មវិធី ជាតិ១០ឆ្នាំងនេះគឺផ្អែកទៅលើក្របខណ្ឌ គោលនយោបាយ និងលិខិតបទដ្ឋាន គតិយុត្តិ ដែលមានចែងនៅក្នុងក្របខណ្ឌយុទ្ធ សាស្ត្រស្តីពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ និង ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ។

✓ គ.ជ.អ.ប តាមរយៈលេខាធិការដ្ឋានរបស់ខ្លួន ទទួលខុសត្រូវក្នុងការអនុវត្តកម្មវិធីជាតិនេះ ។

✓ កម្មវិធីជាតិនេះ មានគោលបំណងសម្រេចឱ្យបាននូវលទ្ធផលចម្បង៧ចំនួន៣:

- ការរៀបចំតាក់តែងគោលនយោបាយ ក្របខណ្ឌច្បាប់ និងលិខិតបទដ្ឋានគតិយុត្តិក្រោមច្បាប់ស្តីពី ការគ្រប់គ្រង រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ សម្រាប់ការធ្វើវិមជ្ឈការសារពើពន្ធ និង វិមជ្ឈការតាមវិស័យ
- ការអភិវឌ្ឍស្ថាប័ន និងសមត្ថភាពរដ្ឋបាលថ្នាក់ក្រោមជាតិ
- ការផ្ទេរធនធានទៅរដ្ឋបាលថ្នាក់ក្រោមជាតិ សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាន ការគ្រប់គ្រង ធនធានធម្មជាតិ និងការវិនិយោគហេដ្ឋារចនាសម្ព័ន្ធ ។

✓ កម្មវិធីជាតិបានកំណត់នូវសមាសធាតុកម្មវិធីចំនួន៥ ដែលគាំទ្រដល់ការសម្រេចឱ្យបាននូវគោលបំណងនៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ និងលទ្ធផលចម្បង១ទាំង៣ខាងលើ។ សមាសធាតុទាំង៥នោះរួមមាន:

- សមាសធាតុកម្មវិធីទី១: ការរៀបចំស្ថាប័នរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីធានាថារដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបានបង្កើត និងមានប្រតិបត្តិការបាន
- សមាសធាតុកម្មវិធីទី២: ប្រព័ន្ធគ្រប់គ្រង និងអភិវឌ្ឍធនធានមនុស្សដើម្បីធានាឱ្យមានប្រព័ន្ធគ្រប់គ្រងមន្ត្រីរាជការ ស៊ីវិលនៅថ្នាក់ក្រោមជាតិដ៏រឹងមាំមួយ
- សមាសធាតុកម្មវិធីទី៣: ការផ្ទេរមុខងារ ដើម្បីធានាឱ្យបានថា មុខងារ និងធនធានសម្រាប់អនុវត្តមុខងារត្រូវបានផ្ទេរដោយត្រឹមត្រូវដល់ក្រុមប្រឹក្សា
- សមាសធាតុកម្មវិធីទី៤: ប្រព័ន្ធគ្រប់គ្រងថវិកា ហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិនានា ដើម្បីធានាឱ្យមានក្របខណ្ឌច្បាប់ យន្តការក្នុងការគ្រប់គ្រងទ្រព្យសម្បត្តិ និងហិរញ្ញវត្ថុរបស់ក្រុមប្រឹក្សា
- សមាសធាតុទី៥: ស្ថាប័នគាំទ្រកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ គឺដើម្បីធានាឱ្យមានការរៀបចំស្ថាប័នដែលចាំបាច់ ដើម្បីជំរុញកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ព្រមទាំងបង្កលទ្ធភាពឱ្យរដ្ឋបាលថ្នាក់ក្រោម ជាតិអាចគ្រប់គ្រង និងចាត់ចែងការងារប្រកបដោយប្រសិទ្ធិភាព និងនិរន្តភាព។

✓ មានប្រធានបទបី ដែលមានលក្ខណៈអន្តរវិស័យ គឺការបញ្ជ្រាបយេនឌ័រ ការប្រែប្រួលអាកាសធាតុ និងគណនេយ្យភាព ត្រូវបានដាក់បញ្ចូលទៅក្នុងសមាសធាតុទាំង៥។

✓ ជាបឋមកម្មវិធីជាតិផ្តោតទៅលើស្រុក ក្រុង ឃុំ និងសង្កាត់

**ផែនការអនុវត្តរយៈពេល៣ឆ្នាំ (២០១១-២០១៣) របស់កម្មវិធីជាតិ**

✓ ដើម្បីមាននូវការណែនាំច្បាស់លាស់មួយសម្រាប់រយៈពេលបីឆ្នាំដំបូង រាជរដ្ឋាភិបាលបានរៀបចំតាក់តែងនូវផែនការអនុវត្ត រយៈពេល៣ឆ្នាំ ដោយផ្អែកទៅលើកម្មវិធីជាតិ។

✓ គ.ជ.អ.ប តាមរយៈលេខាធិការដ្ឋានរបស់ខ្លួន ទទួលខុសត្រូវក្នុងកាអនុវត្ត ផែនការការអនុវត្តរយៈពេលបីឆ្នាំ (ផ.អ.៣)។

✓ ស្ថាប័នខាងក្រោមនេះ ទទួលខុសត្រូវក្នុងការអនុវត្តផ្នែកនានា ដែលមានក្នុង ផ.អ.៣ ។

- លេខាធិការដ្ឋាន គ.ជ.អ.ប
- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងផែនការ
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- សម្ព័ន្ធភាពជាតិឃុំ សង្កាត់

✓ គោលដៅនៃផអ៣ គឺផ្តល់លទ្ធភាពឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការលើកកម្ពស់សុខុមាលភាព (ជីវភាពរស់នៅ សិទ្ធិ សេវា) ការលើកកម្ពស់សមភាពរវាងប្រជាពលរដ្ឋ និងសហគមន៍នានា និងការធានាបាននូវភាពគ្មានលំអៀងនៅក្នុងការទទួលបាននូវសេវានានា (ផ.អ.៣ ទំព័រ៣៩) ។

✓ ផ.អ.៣ ផ្តោតជាសំខាន់លើស្រុក និងក្រុង ។ ផ.អ.៣ក៏ផ្តោតការគាំទ្រទៅលើទំនាក់ទំនងរវាងស្រុក និងឃុំ ព្រមទាំងទំនាក់ទំនងរវាងក្រុង និងសង្កាត់ ។

> ផ.អ.៣ សង្កត់ធ្ងន់ទៅលើសារៈសំខាន់នៃក្រុមប្រឹក្សា ដែលជា ស្ថាប័នតំណាងខាងផ្នែកនយោបាយ ។
>
> ក្នុងនាមជាតួអង្គរៀបចំគោលនយោបាយ ក្រុមប្រឹក្សាត្រូវមានសិទ្ធិអំណាច ធនធានឆន្ទានុសិទ្ធិ និងការត្រួតពិនិត្យលើរចនាសម្ព័ន្ធរដ្ឋបាល និងប្រតិបត្តិដែលត្រូវមានគណនេយ្យភាពចំពោះក្រុមប្រឹក្សា និងអាចអនុវត្តគោលនយោបាយនានារបស់ក្រុមប្រឹក្សា។ ប៉ុន្តែបញ្ហាសំខាន់ គឺក្រុមប្រឹក្សាត្រូវមាននីតិវិធីប្រតិបត្តិការនានា ដែលអាចជួយសម្រួលឱ្យមានការចូលរួមរបស់ប្រជាពលរដ្ឋ សង្គមស៊ីវិល និងការពិភាក្សា ដែលមានមូលដ្ឋានច្បាស់លាស់។ ជាមួយគ្នានេះដែរក្រុមប្រឹក្សាទាំងអស់ត្រូវបំពេញមុខងារជារចនាសម្ព័ន្ធមួយដែលមានភាពជាតំណាងផ្នែកនយោបាយប្រកបដោយប្រសិទ្ធភាព។

✓ ផ.អ.៣ រួមមានអនុកម្មវិធីចំនួន៦ ដែលអនុកម្មវិធីនីមួយៗ អនុវត្តដោយស្ថាប័នដែលបានរៀបរាប់ខាងលើ ។ អនុកម្មវិធីទាំងនោះរួមមានៈ

- អនុកម្មវិធីទី១ គឺជាការរៀបចំតាក់តែងនូវគោលនយោបាយ ការសម្របសម្រួលកម្មវិធី ការរៀបចំឱ្យមានឱកាសពិគ្រោះយោបល់ដល់ក្រុមប្រឹក្សា និងសមត្ថភាពក្នុងការធ្វើសេចក្តីសម្រេចចិត្តផ្នែកនយោបាយ ដែលត្រូវបានអនុវត្តដោយលេខា ធិការដ្ឋាន គ.ជ.អ.ប ។ អនុកម្មវិធីនេះផ្តោតទៅលើៈ
    - ការរៀបចំលិខិតបទដ្ឋានគតិយុត្តស្តីពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ
    - ការជំរុញកំណែទម្រង់វិមជ្ឈការ វិសហមជ្ឈការតាមវិស័យ និងការផ្ទេរមុខងារ

- ការពង្រឹងសមត្ថភាពក្នុងការសម្របសម្រួល ការគ្រប់គ្រង និងការតាមដាន
- ការរៀបចំប្រព័ន្ធប្រឹក្សាយោបល់សម្រាប់ក្រុមប្រឹក្សា និងការផ្តល់ប្រព័ន្ធគាំទ្រ និងការហ្វឹកហ្វឺនដល់ក្រុមប្រឹក្សា

- អនុកម្មវិធីទី២ គឺការរៀបចំអភិវឌ្ឍធនធានមនុស្ស និងស្ថាប័ន ដែលត្រូវអនុវត្តដោយក្រសួងមហាផ្ទៃ ។ អនុកម្មវិធីនេះរួមមាន:
  - ការរៀបចំបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ
  - ការអភិវឌ្ឍសមត្ថភាពស្ថាប័ន និងបុគ្គលិកនៅរដ្ឋបាលថ្នាក់ក្រោមជាតិ
  - ការត្រួតពិនិត្យមើល និងការត្រួតពិនិត្យនីត្យានុកូលភាព
  - ការលើកកម្ពស់ល័ក្ខខ័ណ្ឌប្រតិបត្តិការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- អនុកម្មវិធីទី៣ គឺការគ្រប់គ្រងធនធានមនុស្សនៅថ្នាក់ក្រោមជាតិ ដែលអនុវត្តដោយរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ។ អនុកម្មវិធីនេះ ធ្វើសមាហរណកម្ម និងដំណើរការនៃការរៀបចំនូវបុគ្គលិកឡើងវិញនៅពេលមាន ការផ្ទេរមុខងារដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ព្រមទាំងការរៀបចំតាក់តែងក្របខណ្ឌច្បាប់សម្រាប់គ្រប់គ្រងបុគ្គលិក ថ្នាក់ក្រោមជាតិ ។
- អនុកម្មវិធីទី៤ គឺការរៀបចំឱ្យមានធនធានហិរញ្ញវត្ថុសម្រាប់ថ្នាក់ក្រោមជាតិ ដែលអនុវត្តដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ អនុកម្មវិធីនេះរួមមាន:
  - គោលនយោបាយ និងក្របខ័ណ្ឌច្បាប់សម្រាប់យន្តការផ្តល់ហិរញ្ញប្បទាននៃរដ្ឋបាលថ្នាក់ក្រោមជាតិ
  - ប្រព័ន្ធ និងនីតិវិធីនានានៃការគ្រប់គ្រងហិរញ្ញវត្ថុ និងគណនេយ្យភាពផ្នែកហិរញ្ញវត្ថុរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
  - សមត្ថភាពរដ្ឋបាលថ្នាក់ក្រោមជាតិសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុ និងគណនេយ្យភាពហិរញ្ញវត្ថុ
  - ការពង្រឹងស្ថាប័នថ្នាក់ជាតិសម្រាប់ការគាំទ្រ និងការត្រួតពិនិត្យ
- អនុកម្មវិធីទី៥ គឺប្រព័ន្ធកសាងផែនការ និងកម្មវិធីវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលអនុវត្តដោយក្រសួងផែនការ ។
- អនុម្មវិធីទី៦ គឺការអភិវឌ្ឍសមត្ថភាពសមាគមក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលអនុវត្តដោយសម្ព័ន្ធភាពជាតិក្រុមប្រឹក្សាឃុំ សង្កាត់ ។ អនុកម្មវិធីនេះ គឺការរៀបចំអភិវឌ្ឍឱ្យមានសមាគមមួយឬច្រើនសម្រាប់ក្រុមប្រឹក្សា ថ្មី ដើម្បីធ្វើឱ្យក្រុមប្រឹក្សាថ្មីនេះមានសម្លេងរឹងមាំរួមមួយ ។

✓ បន្ថែមលើអនុកម្មវិធីទាំង៦នេះ ផែនការអនុវត្តរយៈពេល៣ឆ្នាំរួមបញ្ចូលៈ

- យុទ្ធសាស្ត្រតាមដានត្រួតពិនិត្យ និងវាយតម្លៃ
- យុទ្ធសាស្ត្របញ្ច្រាបយេនឌ័រ
- ក្របខណ្ឌអភិវឌ្ឍសមត្ថភាពថ្នាក់ជាតិ

**តួនាទី ភារកិច្ចជាក់លាក់របស់ គ.ជ.អ.ប**

> ចំពោះព័ត៌មានបន្ថែមស្តីពីការផ្ទេរមុខងារ សូម អានមេរៀនទី ១៣

✓ គ.ជ.អ.ប **បំពេញការងារជាមួយក្រសួង ដើម្បីកំណត់មុខងារ និង ធនធានណាដែលនឹងត្រូវផ្ទេរ**ឱ្យក្រុមប្រឹក្សានីមួយៗនៅថ្នាក់ក្រោមជាតិ តាមរយៈអនុគណៈកម្មាធិការមុខងារ និងធនធាន។ គ.ជ.អ.ប មានការទទួលខុសត្រូវក្នុងការធានាឱ្យបានថា នៅពេលមុខងារមួយត្រូវផ្ទេរឱ្យក្រុមប្រឹក្សាត្រូវទទួលបានធនធានចាំបាច់ (រួមមានប្រាក់ចំណូល ហិរញ្ញវត្ថុ បុគ្គលិក ទ្រព្យសម្បត្តិ និងសមត្ថភាព) ដើម្បីអនុវត្តមុខងារនោះ (មាត្រា ២០០ និង ២១៧ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មាត្រា ៣(៤) នៃព្រះរាជក្រឹត្យស្តីពីការបង្កើត គ.ជ.អ.ប)។

✓ **ក្រុមប្រឹក្សាខេត្ត** ត្រូវទំនាក់ទំនង និងសហប្រតិបត្តិការជាមួយ គ.ជ.អ.ប និងក្រសួងក្នុងការបែងចែក និងផ្ទេរមុខងារ និងធនធាន (ប្រាក់ចំណូល ហិរញ្ញវត្ថុ បុគ្គលិក) ពីថ្នាក់ជាតិទៅក្រុមប្រឹក្សាថ្នាក់ក្រោមជាតិ។ នៅក្នុងការអនុវត្តតួនាទីនេះ ក្រុមប្រឹក្សាខេត្ត**ត្រូវពិគ្រោះយោបល់ជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិទាំងអស់**នៅក្នុងខេត្ត (មាត្រា ១៩៥ នៃអនុក្រឹត្យ លេខ២១៦)។

✓ នៅពេលសេចក្តីសម្រេច ត្រូវបានធ្វើឡើងដោយ គ.ជ.អ.ប និងក្រសួងនានា ក្រុមប្រឹក្សាខេត្តត្រូវសម្របសម្រួលជាមួយ រដ្ឋបាលនៅថ្នាក់ក្រោមជាតិ ដោយសារក្រុមប្រឹក្សាទទួលបានមុខងារ និងធនធានថ្មី (មាត្រា ១៩៥ នៃអនុក្រឹត្យស្តីពីតួនាទីខេត្ត)។

> ចំពោះព័ត៌មានបន្ថែមស្តីពីការធ្វើសមាហរណកម្មផែនការ និងថវិការបស់ក្រសួង សូមអាន មេរៀនទី ៧

✓ **រដ្ឋបាលរាជធានី** ក៏ត្រូវសម្របសម្រួល និងសហប្រតិបត្តិការផងដែរ នៅពេល**ពិនិត្យមើលឡើងវិញលើមុខងារ និងធនធាន** ដែលត្រូវផ្ទេរឱ្យក្រុមប្រឹក្សា

> ក្រុមប្រឹក្សា មានអារម្មណ៍ថានៅពេលក្រុមប្រឹក្សាទទួលបានការផ្ទេរមុខងារថ្មីឱ្យជួសជុលសាលារៀននៅក្នុងដែនដីរបស់ខ្លួន ហើយធនធានដែលត្រូវផ្ទេរឱ្យអនុវត្តមុខងារនោះ មានចំនួនមិនគ្រប់គ្រាន់។ ប្រសិនបើក្រសួង និងក្រុមប្រឹក្សាពាក់ព័ន្ធ មិនអាចដោះស្រាយបញ្ហានេះដោយខ្លួនឯងបានទេ គ.ជ.អ.ប ត្រូវសម្របសម្រួលរកដំណោះស្រាយចំពោះបញ្ហាមិនចុះសម្រុងគ្នានេះ។

រាជធានី និង ខណ្ឌ ( មាត្រា ៥៨ នៃ អនុក្រឹត្យលេខ២១៦) ។

✓ ចំពោះមុខងារដែលត្រូវរក្សាទុកដោយក្រសួង គ.ជ.អ.ប ត្រូវធានាឱ្យបានថា ក្រសួងទាំងនោះ**ធ្វើសមាហរណកម្មផែនការ និងថវិការបស់ខ្លួន**ទៅក្នុងផែនការអភិវឌ្ឍ និងថវិការបស់ក្រុមប្រឹក្សា។ ការដាក់បញ្ចូលនេះសម្រេចទៅបានតាមរយៈ **គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស**របស់ក្រុមប្រឹក្សានីមួយៗ (មាត្រា ២០១ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មាត្រា ៣,៥ នៃព្រះរាជក្រឹត្យស្តីពីការបង្កើតគ.ជ.អ.ប មាត្រា ២០៤ នៃអនុក្រឹត្យលេខ ២១៦ មាត្រា ១៤២ នៃអនុក្រឹត្យលេខ២១៦ មាត្រា ៤,១៣ នៃអនុក្រឹត្យលេខ២១៨ មាត្រា ៤,១៣ នៃអនុក្រឹត្យលេខ ២១៧ )

✓ គ.ជ.អ.ប ត្រូវធ្វើការស្រាវជ្រាវអំពីរបៀបដាក់បញ្ចូល**គណៈកម្មាធិការប្រតិបត្តិ នៃគណៈកម្មាធិការអភិវឌ្ឍន៍ជនបទខេត្ត** ទៅក្នុងរដ្ឋបាលខេត្ត និងពីរបៀបដាក់បញ្ចូល**គណៈកម្មាធិការអភិវឌ្ឍ រាជធានី** ទៅក្នុងរដ្ឋបាលរាជធានី។ នៅក្នុងដំណើរការស្រាវជ្រាវ ការងារនេះ គ.ជ.អ.ប ត្រូវពិគ្រោះយោបល់ និងសម្របសម្រួលជាមួយក្រសួងដៃគូអភិវឌ្ឍ និងអ្នកពាក់ព័ន្ធផ្សេងទៀត ( មាត្រា ២១០ នៃអនុក្រឹត្យលេខ២១៦ មាត្រា ១៤៧ នៃអនុក្រឹត្យ លេខ២១៥) ។

✓ គ.ជ.អ.ប មានការទទួលខុសត្រូវក្នុងការដាក់ចេញសេចក្តីណែនាំ ក៏ដូចជាផ្តល់ការគាំទ្រផងដែរនៅពេលក្រុមប្រឹក្សាអភិវឌ្ឍ**ប្រព័ន្ធពិនិត្យតាមដាន និងវាយតំលៃរបស់ខ្លួន**។ ជាការសំខាន់ណាស់ដែលក្រុមប្រឹក្សាវាយតំលៃការងាររបស់ខ្លួន និងលទ្ធផលការងាររបស់ខ្លួន ហើយធ្វើការកែលម្អទៅតាមការចាំបាច់ ដើម្បីធានាឱ្យបានថា ក្រុមប្រឹក្សាមាន**ការឆ្លើយតប**ចំពោះ ប្រជាពលរដ្ឋកាន់តែប្រសើរឡើង ( មាត្រា ១៧, ៧៣, ១៣៥ នៃអនុក្រឹត្យលេខ២១៦ មាត្រា ១៧, ៧៤ នៃអនុក្រឹត្យលេខ២១៥) ។

✓ ប្រសិនបើក្រុមប្រឹក្សា មាន**ភាពមិនច្បាស់លាស់អំពីការអនុវត្តក្របខ័ណ្ឌច្បាប់** ឬប្រសិនបើក្រុមប្រឹក្សា មានជំនឿថាក្របខ័ណ្ឌច្បាប់ **មិនឆ្លុះបញ្ចាំងស្ថានភាពនៅមូលដ្ឋាន** ក្រុមប្រឹក្សាត្រូវស្នើសុំមតិយោបល់ពីក្រសួងមហាផ្ទៃ។ តាមរយៈគ.ជ.អ.ប ក្រសួងមហាផ្ទៃ ត្រូវសម្របសម្រួលជាមួយក្រសួងពាក់ព័ន្ធ ដើម្បីផ្តល់ការបំភ្លឺ ( មាត្រា ១៦, ៧២, ១៣៤ នៃអនុក្រឹត្យលេខ ២១៦ មាត្រា ១៦ នៃអនុក្រឹត្យលេខ២១៥) ។

✓ គ.ជ.អ.ប **សម្របសម្រួលជំលោះស្រាយភាពមិនចុះសម្រុងគ្នា** ដែលកើតឡើងរវាងក្រសួង និងក្រុមប្រឹក្សា។ ប្រសិនបើ ភាពមិនចុះសម្រុងគ្នា មិនអាចដោះស្រាយបាន គ.ជ.អ.ប ត្រូវរាយការណ៍ជូនប្រមុខរាជរដ្ឋាភិបាល (មាត្រា ២០០ នៃ អនុក្រឹត្យលេខ២១៦ មាត្រា ១៣៧ នៃអនុក្រឹត្យលេខ២១៥)។

✓ គ.ជ.អ.ប **ត្រូវធានាឱ្យបានថា ក្រសួង និងក្រុមប្រឹក្សា អនុវត្ត**តាមសេចក្តីសម្រេចរបស់ គ.ជ.អ.ប។ ក្នុងករណីដែលក្រុមប្រឹក្សា មិនអនុវត្តតាមសេចក្តីសម្រេចរបស់ គ.ជ.អ.ប អាចស្នើឱ្យក្រសួងមហាផ្ទៃអនុវត្តនីតិវិធីដែលកំណត់ដោយច្បាប់ ដើម្បីឱ្យក្រុមប្រឹក្សាអនុវត្តតាម (មាត្រា ២០២, ២០៦, ២០៨ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ)។

## តួនាទី ភារកិច្ចជាក់លាក់របស់ក្រសួងមហាផ្ទៃ៖ ជាអ្នកត្រួតពិនិត្យ និងជាទីប្រឹក្សារបស់ក្រុមប្រឹក្សា

**ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ**

**មាត្រា ៨១-៨៨**

### តួនាទីត្រួតពិនិត្យ

✓ ក្រសួងមហាផ្ទៃ មាន**ភារកិច្ចត្រួតពិនិត្យ**លើក្រុមប្រឹក្សាថ្នាក់ទាំងអស់ ក៏ដូចជាក្រុមប្រឹក្សាឃុំ សង្កាត់។ ក្រសួងមហាផ្ទៃ ធានា ឱ្យបានថា ក្រុមប្រឹក្សាអនុវត្តតាមរដ្ឋធម្មនុញ្ញ ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស និងលិខិតបទដ្ឋានផ្សេងទៀត រួមទាំង បទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សាផ្ទាល់ (មាត្រា ២៤, ៣៥, ៨១, ៨៨ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មាត្រា ៥៣-៥៨ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ មាត្រា ១១, ៦៧, ១២៥ នៃអនុក្រឹត្យលេខ២១៦ មាត្រា ១១, ៦៩ នៃអនុក្រឹត្យលេខ២១៥)។

✓ ប្រការនេះ មិនខុសគ្នាពីថ្នាក់ជាតិឡើយ ពោលគឺរាជរដ្ឋាភិបាល និងក្រសួងរបស់រាជរដ្ឋាភិបាល ត្រូវអនុវត្តតាមរដ្ឋធម្មនុញ្ញ ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស និងលិខិតបទដ្ឋានផ្សេងទៀត ដែលស្ថិតនៅជាធរមាន។

**ឧទាហរណ៍**

ប្រសិនបើអភិបាល ប្រើប្រាស់ថវិកាដោយគ្មានការអនុម័តពីក្រុមប្រឹក្សា សកម្មភាពនោះ គឺមិនមានសុពលភាព ឡើយ។ ការអនុម័តថវិកា គឺជាតួនាទីរបស់ក្រុមប្រឹក្សា ។

- ច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ចែងពីដំណើរការសម្រាប់ដោះស្រាយ **សកម្មភាព ឬសេចក្ដីសម្រេចមិនស្របច្បាប់របស់ក្រុមប្រឹក្សា គណៈកម្មាធិការរបស់ក្រុមប្រឹក្សា អភិបាល គណៈអភិបាល ឬបុគ្គលិករបស់ក្រុមប្រឹក្សា**។ សកម្មភាព ឬ សេចក្ដីសម្រេចមិនស្របច្បាប់ គឺជាសកម្មភាព ឬសេចក្ដីសម្រេចដែលហួសពីសិទ្ធិអំណាចរបស់មុខតំណែងមួយ និង/ឬ រំលោភរដ្ឋធម្មនុញ្ញ ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស និងលិខិតបទដ្ឋានផ្សេងទៀតដែលស្ថិតនៅជាធរមាន (មាត្រា ៧៨, ៧៩ នៃច្បាប់ ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ)។
- ក្រសួងមហាផ្ទៃត្រូវដោះស្រាយ**សកម្មភាព ឬ សេចក្ដីសម្រេចមិនស្របច្បាប់របស់ក្រុមប្រឹក្សា គណៈ-កម្មាធិការរបស់ ក្រុមប្រឹក្សា អភិបាល គណៈអភិបាល ឬបុគ្គលិករបស់ក្រុមប្រឹក្សា** (មាត្រា ៨១, ៨៨ នៃច្បាប់ស្ដីពីការគ្រប់គ្រង រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ)។
- ជាដំបូង ក្រសួងមហាផ្ទៃ ត្រូវ**ជូនដំណឹងជាលាយលក្ខអក្សរ**ដល់ក្រុមប្រឹក្សា និងអភិបាលថា មានសកម្មភាព ឬសេចក្ដី សម្រេចខុសច្បាប់។ ក្រុមប្រឹក្សា ឬគណៈអភិបាល មានរយៈពេលមួយខែដើម្បីផ្ដល់ការបំភ្លឺទៅក្រសួងមហាផ្ទៃ។ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវឆ្លើយតបនៅក្នុងរយៈពេលមួយខែក្នុងករណីដែលក្រសួងនៅតែចាត់ទុកថាសកម្មភាព ឬ សេចក្ដីសម្រេចនោះមិនស្របច្បាប់ (មាត្រា ៨១ នៃច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ)។
- ក្រសួងមហាផ្ទៃ មានភារកិច្ចផ្ដល់ព័ត៌មានដល់ក្រុមប្រឹក្សា និងគណៈអភិបាលអំពី**វិធានការចាំបាច់ដើម្បីកែតម្រូវ**សកម្ម ភាព ឬសេចក្ដីសម្រេចខុសច្បាប់ (មាត្រា ៨៣, ៨៤ នៃច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ)។
- នៅក្នុងកិច្ចការទាំងនេះ ក្រុមប្រឹក្សា មាន**គណនេយ្យភាពចំពោះក្រសួងមហាផ្ទៃ**។

✓ នៅក្នុងខេត្ត **ក្រុមប្រឹក្សាខេត្ត ត្រូវបានធ្វើប្រតិភូកម្មភារកិច្ចឱ្យធានាអនុលោមភាពតាមច្បាប់**។ ដូច្នេះ ក្រុមប្រឹក្សាខេត្តត្រូវ ធានាឱ្យបានថា សេចក្ដីសម្រេច និងសកម្មភាពរបស់ក្រុមប្រឹក្សាក្រុង និងស្រុក អនុលោមទៅតាមរដ្ឋធម្មនុញ្ញ ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស និងលិខិតបទដ្ឋានផ្សេងទៀត ដែលស្ថិតនៅជាធរមាន។ ក្រុមប្រឹក្សាខេត្ត គាំទ្រក្រុមប្រឹក្សា ក្រុង និងស្រុក ដើម្បីធានាអនុលោមភាពតាមច្បាប់ដោយក្រុមប្រឹក្សាឃុំ សង្កាត់។ នៅក្នុងរាជធានី ភារកិច្ចធានាអនុលោម ភាពតាមច្បាប់ដោយខណ្ឌ

និងសង្កាត់ ត្រូវ**បានធ្វើប្រតិភូកម្មដល់ក្រុមប្រឹក្សារាជធានី** ( មាត្រា ១៩៥, ១៩៦ នៃអនុក្រឹត្យ លេខ២១៦ មាត្រា ៥៨, ៧៥, ១២២ នៃអនុក្រឹត្យលេខ២១៥) ។

✓ ក្រុមប្រឹក្សា មានតួនាទីយ៉ាងសំខាន់ក្នុងការពិនិត្យមើលឡើងវិញ អង្កេត និងរាយការណ៍ទៅក្រសួងមហាផ្ទៃ អំពីករណីនៃការ **រំលោភអំណាច**ដែលកើតមាននៅក្នុងដែនដីរបស់ខ្លួន។ គណៈអភិបាលត្រូវជួយក្រុមប្រឹក្សា អំពីការងារនេះ ( មាត្រា ១៥, ៣០, ៧១, ៨៧, ១៣៣, ១៤៨ នៃអនុក្រឹត្យលេខ២១៦ មាត្រា ១៥, ៣០, ៧៣ នៃអនុក្រឹត្យលេខ២១៥) ។

✓ ក្រុមប្រឹក្សាដែលមានបំណង**បង្កើត រំសាយ ឬរៀបចំឡើងវិញលើទីចាត់ការ ឬការិយាល័យ**នៅក្នុងរដ្ឋបាល របស់ខ្លួន ត្រូវស្នើ សុំទៅក្រសួងមហាផ្ទៃតាមរយៈគណៈអភិបាល ( មាត្រា ៦០ នៃអនុក្រឹត្យ លេខ២១៦ មាត្រា ៩, ២០, ២៩ នៃប្រកាស៤២៧៤ មាត្រា ៦០ នៃអនុក្រឹត្យលេខ២១៥ មាត្រា ១២, ២២ នៃប្រកាស លេខ៤២៧៣) ។

✓ នៅពេលមិនទាន់មានលក្ខន្តិកៈស្តីពីបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ ក្រុមប្រឹក្សាខេត្តអនុម័ត**សំណើតែងតាំងមន្ត្រីសម្រាប់ តំណែងជានាយក ឬនាយករងទីចាត់ការ និងប្រធាន ឬអនុប្រធាន**នៅក្នុងរដ្ឋបាលខេត្ត។ ក្រុមប្រឹក្សាក្រុង ឬស្រុក អនុម័ត សំណើតែងតាំងមន្ត្រីសម្រាប់មុខតំណែងជាប្រធាន ឬអនុប្រធាន ការិយាល័យក្រុង ឬស្រុក។ អភិបាលខេត្តស្នើសុំឱ្យក្រសួង មហាផ្ទៃអនុម័តលើសំណើរបស់ក្រុមប្រឹក្សាខេត្ត ឬក្រុមប្រឹក្សាក្រុង ឬ កុមប្រឹក្សាស្រុក។ សម្រាប់ក្រុមប្រឹក្សារាជធានី និង ខណ្ឌ មានការចាត់ចែង ប្រហាក់ប្រហែលគ្នានេះ ( មាត្រា ៣៩ នៃប្រកាសលេខ៤២៧៤ មាត្រា ២៨ នៃប្រកាស លេខ៤២៧៣ ) ។

✓ ក្នុងករណីមាន**ការមិនចុះសម្រុងគ្នារវាងរដ្ឋបាល**នៅក្នុងខេត្ត ឬ នៅក្នុងរាជធានី ក្រសួងមហាផ្ទៃត្រូវដោះស្រាយ ភាពមិនចុះ សម្រុងគ្នាអនុលោមទៅតាមក្របខ័ណ្ឌច្បាប់ ( មាត្រា ១៩៩ នៃអនុក្រឹត្យលេខ២១៦ មាត្រា ១៣៥ នៃអនុក្រឹត្យលេខ ២១៥) ។

## តួនាទីផ្តល់យោបល់

✓ ក្រសួងមហាផ្ទៃក៏ដើរតួនាទី**ផ្តល់យោបល់**ផងដែរ។ មុនពេល ដាក់ចេញ**ដីកា**របស់ក្រុមប្រឹក្សា **សេចក្តីសម្រេច**របស់ក្រុមប្រឹក្សា ឬ**កិច្ចសន្យា**របស់ក្រុមប្រឹក្សា ក្រុមប្រឹក្សា ឬគណៈអភិបាលអាចធ្វើសំណើជាលាយលក្ខអក្សរជូនទៅក្រសួង

> **ឧទាហរណ៍**
>
> ក្រុមប្រឹក្សាស្រុក ព្យាយាមដោះស្រាយបញ្ហាល្បែង ស៊ីសងនៅក្នុងដែនដីរបស់ខ្លួន។ ក្រុមប្រឹក្សាចង់ដាក់ចេញ ដីកាដែលហាមឃាត់រោងល្បែងស៊ីសងកំពុងដំណើរការនៅក្នុងស្រុក។ ក្រុមប្រឹក្សាមានក្តីមន្ទិល ថាតើដីកាបែបនេះ ស្ថិតនៅក្នុងសិទ្ធិអំណាចរបស់ខ្លួនដើម្បីដាក់ចេញឬទេ។
>
> ក្រុមប្រឹក្សា អាចធ្វើសេចក្តីព្រាងដីការបស់ខ្លួនទៅក្រសួងមហាផ្ទៃដើម្បីផ្តល់យោបល់។

មហាផ្ទៃដើម្បីផ្តល់មតិលើដីកា ឬសេចក្តីសម្រេច។ ក្រសួង មហាផ្ទៃត្រូវឆ្លើយតបនៅក្នុងរយៈពេលមួយខែ បន្ទាប់ពីបាន ទទួលសំណើ ( មាត្រា ៨២ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ) ។

✓ ដោយមានទស្សនៈ**គាំទ្រគណៈកម្មាធិការសម្របសម្រួលបច្ចេកទេស** ក្រសួងមហាផ្ទៃត្រូវផ្តល់**ការកសាងសមត្ថភាពដល់** សមាជិកក្រុមប្រឹក្សា គណៈអភិបាល នាយករដ្ឋបាល គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស និងបុគ្គលិករបស់រដ្ឋបាល ក្រុមប្រឹក្សា ក៏ដូចជាបុគ្គលផ្សេងទៀត ( មាត្រា ៣១ នៃអនុក្រឹត្យលេខ២១៨ មាត្រា ២២ នៃអនុក្រឹត្យលេខ២១៧ ) ។

> ចំពោះព័ត៌មានបន្ថែមស្តីពីគណៈកម្មាធិការសម្របសម្រួលបច្ចេកទេស
> សូមអានមេរៀនទី៧

✓ ប្រសិនបើ**មិនមានក្របខ័ណ្ឌច្បាប់**សម្រាប់ឱ្យក្រុមប្រឹក្សា **ចាត់វិធានការឆ្លើយតបនឹងតម្រូវការនៅមូលដ្ឋាន** អភិបាល ត្រូវស្រាវជ្រាវរកជម្រើសអំពីវិធានការដែលអាចអនុវត្ត។ ជម្រើស ត្រូវអនុលោមទៅតាមគោលការណ៍តម្លាភាព គណនេយ្យភាព និងប្រសិទ្ធិភាព។ ក្រុមប្រឹក្សា អាចពិចារណា និងសម្រេចលើវិធានការដែលខ្លួនមានបំណងចង់អនុវត្ត។ ក្រុមប្រឹក្សា ត្រូវដាក់សំណើរបស់ខ្លួនជូនទៅក្រសួងមហាផ្ទៃ ឬក្រសួងពាក់ព័ន្ធផ្សេងទៀត ដើម្បីផ្តល់មតិយោបល់ ( មាត្រា ១៦, ៣២, ១៣៤ នៃអនុក្រឹត្យលេខ២១៦ មាត្រា ១៦ នៃអនុក្រឹត្យលេខ២១៥ ) ។

## តួនាទី ភារកិច្ចជាក់លាក់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រុមប្រឹក្សា

**ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ**

**មាត្រា ៤៤-៤៦, ២៤២-២៦១**

✓ ក្រុមប្រឹក្សា ត្រូវគ្រប់គ្រងហិរញ្ញវត្ថុរបស់ខ្លួនប្រកបដោយប្រសិទ្ធភាព និង**មានតម្លាភាព**។ នៅក្នុងការគ្រប់គ្រងហិរញ្ញវត្ថុរបស់ខ្លួន ក្រុមប្រឹក្សាត្រូវមាន**គណនេយ្យភាពតាមបែបប្រជាធិបតេយ្យ**ចំពោះប្រជាពលរដ្ឋរបស់ខ្លួន។ ក្រុមប្រឹក្សា ក៏ត្រូវមានគណនេយ្យភាពចំពោះរាជរដ្ឋាភិបាលក្នុងការអនុវត្តទៅតាមលិខិតបទដ្ឋានជាធរមានផងដែរ ( មាត្រា ២៤៣ នៃច្បាប់ ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ) ។

> ចំពោះព័ត៌មានបន្ថែមស្តីពីវិមជ្ឈការសារពើពន្ធ និងការគ្រប់គ្រងហិរញ្ញវត្ថុ
> សូមអានមេរៀនទី ១៥

✓ ចំពោះបែបបទ និងនីតិវិធីសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុ និងថវិកា នឹងត្រូវកំណត់ដោយច្បាប់ដោយឡែកគឺ ***ច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ*** (មាត្រា ៤៤-៤៦, ១៣៧, ២៤៤, ២៤៥, ២៤៨, ២៥៣, ២៥៥ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ) ។

✓ ក្រុមប្រឹក្សាថ្មី មាន**សិទ្ធិទទួលបានប្រាក់ចំណូល**ពីប្រភពចំណូលនៅមូលដ្ឋាននៅថ្នាក់ជាតិ និងពីប្រភពផ្សេងទៀត (មាត្រា ២៤៤ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ) ។

✓ ក្រុមប្រឹក្សា អាចទទួលបាន**ទ្រព្យសម្បត្តិរដ្ឋ**។ ក្រុមប្រឹក្សា មានកាតព្វកិច្ចថែរក្សា និង ការពារទ្រព្យសម្បត្តិដែលរដ្ឋប្រគល់ឱ្យ អោយបានគង់វង្ស។ ក្រុមប្រឹក្សាគ្មានសិទ្ធិលក់ដូរ ឬផ្ទេរកម្មសិទ្ធិ ឬផ្ទេរការប្រើប្រាស់ដោយគ្មានការយល់ព្រមពីក្រសួងមហាផ្ទៃ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុឡើយ (មាត្រា ២៥៥ នៃច្បាប់ស្តីពីការគ្រប់គ្រង រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ) ។

✓ នៅពេលមន្ត្រីរាជការ ត្រូវបានរៀបចំកែសម្រួលឡើងវិញឱ្យក្រុមប្រឹក្សា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុត្រូវផ្ទេរដល់ក្រុម ប្រឹក្សានូវ**ប្រាក់បៀវត្ស** ប្រាក់ឧបត្ថម្ភ និងអត្ថប្រយោជន៍ផ្សេងៗទៀតរបស់បុគ្គលិកដែលបានផ្ទេរឱ្យក្រុមប្រឹក្សា (មាត្រា ២៧១ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ) ។

## តួនាទី ភារកិច្ច ជាក់លាក់របស់ក្រសួងផែនការ

✓ ក្រសួងមហាផ្ទៃ និងក្រសួងផែនការ មានការទទួលខុសត្រូវចំពោះការដាក់ចេញ**សេចក្តីណែនាំ**សម្រាប់ការរៀបចំ និងការអនុវត្តផែនការអភិវឌ្ឍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល (មាត្រា ២៨ នៃប្រកាសស្តីពីការកសាងផែនការ) ។

ចំពោះព័ត៌មានបន្ថែមស្តីពីការកសាងផែនការ សូមអានមេរៀនទី ១៤

## ផ្នែកទី ៣: ការផ្ទេរមុខងារដល់ក្រុមប្រឹក្សា

✓ ក្រសួងនីមួយៗ ត្រូវបង្កើត**ក្រុមការងារវិមជ្ឈការ និងវិសហមជ្ឈការ** (D&D)។ ក្រុមការងារវិមជ្ឈការ និងវិសហមជ្ឈការ មានការទទួលខុសត្រូវចំពោះការរៀបចំគោលនយោបាយ យុទ្ធសាស្ត្រ និងផែនការការងារសម្រាប់ក្រសួងរបស់ខ្លួន ដើម្បី អនុវត្តច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ (មាត្រា១៧ នៃព្រះរាជក្រឹត្យស្តីពីការបង្កើតគ.ជ.អ.ប មាត្រា ៨ នៃអនុក្រឹត្យស្តីពីការបង្កើតអនុគណៈកម្មាធិការ គ.ជ.អ.ប)។

✓ ក្រសួងនីមួយៗ ត្រូវកំណត់ និង**ផ្ទេរ (ប្រគល់ ឬធ្វើប្រតិភូកម្ម) មុខងារសមស្របរបស់ក្រសួង**ដល់ក្រុមប្រឹក្សា។ ទន្ទឹមគ្នានឹងការផ្ទេរមុខងារ ក្រសួងត្រូវផ្ទេរធនធានហិរញ្ញវត្ថុ បុគ្គលិក ហើយត្រូវធានាថា ក្រុមប្រឹក្សា និងក្រុមប្រឹក្សានៅថ្នាក់ក្រោមជាតិមានសមត្ថភាពចាំបាច់ (មាត្រា ២០០, ២១៧ នៃច្បាប់ស្តីពីការ គ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មាត្រា ១៨៩ នៃអនុក្រឹត្យលេខ២១៦ មាត្រា ១២៨, ១២៩ នៃ អនុក្រឹត្យលេខ២១៥)។

ចំពោះព័ត៌មានបន្ថែមស្តីពីការផ្ទេរមុខងារ សូម អានមេរៀនទី ១៣

✓ ក្រសួងក៏ត្រូវ**ពិនិត្យមើលឡើងវិញ**ផងដែរលើ**ច្បាប់ លិខិតបទដ្ឋាន និងកម្មវិធី**របស់ខ្លួន ដើម្បីធ្វើវិសោធនកម្មក្នុងករណី ចាំបាច់លើដើម្បីឱ្យស្របទៅនឹងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងអោយស្របតាមបច្ចុប្បន្ន នៅថ្នាក់ក្រោមជាតិ**មានការពិចារណា**ថានៅពេលនេះ មាន**ក្រុមប្រឹក្សាថ្មី** (មាត្រា ២០៣ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មាត្រា ១៩០ នៃអនុក្រឹត្យលេខ២១៦ មាត្រា ១២៩ នៃអនុក្រឹត្យលេខ២១៥)

✓ ក្រៅពីនេះក្រសួងត្រូវអភិវឌ្ឍ**គោលនយោបាយ ក្របខ័ណ្ឌច្បាប់ និងបទដ្ឋានតាមវិស័យដើម្បីគាំទ្រដល់ក្រុមប្រឹក្សាថ្មី**នៅក្នុងការអនុវត្តមុខងារដែលក្រសួងផ្ទេរឱ្យក្រុមប្រឹក្សា។ បទដ្ឋានអាចមានបញ្ចូលការកំណត់**បទដ្ឋានជាតិសម្រាប់សុវត្ថិភាព និងគុណភាព** ( មាត្រា ១៩១ នៃអនុក្រឹត្យលេខ២១៦ មាត្រា ១៣០ នៃអនុក្រឹត្យលេខ២១៥)។

**ឧទាហរណ៍**

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ នឹងមានបទដ្ឋានជាតិទាក់ទងនឹងសុវត្ថិភាពសម្រាប់ការសាងសង់សំណង់អគារ ។ បទដ្ឋានទាំងនេះ នឹងអនុវត្តនៅទូទាំងប្រទេស ពីព្រោះសុវត្ថិភាពនៃសំណង់អគារ មិនផ្អែកលើ កាលៈទេសៈនៅមូលដ្ឋានឡើយ ។

ឧទាហរណ៍មួយទៀត ក្រសួងសុខាភិបាល អាចមានបទដ្ឋានជាតិទាក់ទងនឹងរបៀបស្តុកទុកវ៉ាក់សាំង ។ ស្តង់ដារនេះ ក៏នឹងត្រូវអនុវត្តនៅទូទាំងប្រទេសផងដែរ ពីព្រោះការស្តុកទុកវ៉ាក់សាំងត្រឹមត្រូវ មិនផ្អែកលើកាលៈទេសៈនៅមូលដ្ឋានឡើយ ។

## ផ្នែកទី ៤: ក្រសួង និងក្រុមប្រឹក្សា - ទំនាក់ទំនង និងវិវាទ

### ទំនាក់ទំនងរវាងក្រសួងតាមវិស័យ និងក្រុមប្រឹក្សា

✓ **ក្រសួង អាចទំនាក់ទំនងដោយផ្ទាល់ និងសហប្រតិបត្តិការជាមួយរដ្ឋបាលនៅថ្នាក់ក្រោមជាតិ** ទៅតាមការចាំបាច់។ ទោះជាយ៉ាងណាក៏ដោយ ក្រសួងត្រូវផ្តល់ព័តិមានដល់រដ្ឋបាលខេត្ត ឬរដ្ឋបាលរាជធានីនៅពេលទំនាក់ទំនងជាមួយក្រុមប្រឹក្សានៅ ក្នុងខេត្ត ឬនៅក្នុងរាជធានី ( មាត្រា ១៩៨ នៃអនុក្រឹត្យលេខ២១៦ មាត្រា ១៣៤ និង ១៣៦ នៃអនុក្រឹត្យលេខ២១៥) ។

✓ ក្រុមប្រឹក្សារាជធានី ត្រូវទំនាក់ទំនងជាមួយក្រសួង ដើម្បីពិគ្រោះយោបល់ និងសហប្រតិបត្តិការក្នុងការ**ដោះស្រាយតម្រូវ ការរបស់ប្រជាពលរដ្ឋ**ដែលក្រុមប្រឹក្សារាជធានី ខណ្ឌ និង សង្កាត់ មិនអាចឆ្លើយតបបាន ( មាត្រា ១៣៦ នៃអនុក្រឹត្យលេខ២១៥) ។

### ដំណោះស្រាយវិវាទរវាងក្រសួងតាមវិស័យ និងក្រុមប្រឹក្សា

✓ ប្រសិនបើមាន**ភាពមិនចុះសម្រុងគ្នារវាងក្រសួង និងក្រុមប្រឹក្សា** គ.ជ.អ.ប ត្រូវសម្របសម្រួលដោះស្រាយភាពមិនចុះ សម្រុងគ្នាអនុលោមទៅតាមលិខិតបទដ្ឋានជាធរមាន។ ប្រសិនបើ គ.ជ.អ.ប មិនអាចដោះស្រាយភាពមិនចុះសម្រុងគ្នា គ.ជ.អ.ប ត្រូវរាយការណ៍ទៅរាជរដ្ឋាភិបាល ( មាត្រា២០០ នៃអនុក្រឹត្យលេខ២១៦ មាត្រា ១៣៧ នៃអនុក្រឹត្យលេខ ២១៥) ។

## ផ្នែកទី ៥: ថ្នាក់ជាតិ: ការតែងតាំងគណៈអភិបាល និងនាយករដ្ឋបាល

### គណៈអភិបាល

✓ រាជរដ្ឋាភិបាល តែងតាំងគណៈអភិបាលសម្រាប់ក្រុមប្រឹក្សាថ្មីនីមួយៗ ដែលមានអភិបាលមួយរូប និងអភិបាលរងមួយចំនួន។ គណៈអភិបាលមាន**តួនាទីផ្តល់យោបល់ គ្រប់គ្រង និងរាយការណ៍ជូនក្រុមប្រឹក្សា**។ គណៈអភិបាល**មានគណនេយ្យភាព ចំពោះក្រុមប្រឹក្សា** (មាត្រា ១៥៥ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មាត្រា ៧ នៃប្រកាស ១២៤៩ ស្តីពីកិច្ចប្រជុំចូលកាន់តំណែង)។

✓ បន្ថែមពីលើតួនាទីរបស់អភិបាលជាប្រធានគណៈអភិបាល **អភិបាលមានការទទួលខុសត្រូវក្នុងការធ្វើជាតំណាងរបស់រាជរដ្ឋាភិបាល និងក្រសួងស្ថាប័ននានា**នៅក្នុងដែនដីរបស់ខ្លួន។ តួនាទីជាតំណាងរបស់ក្រសួងនៅក្នុងដែនដី រួមមានការត្រួតពិនិត្យ ការសម្របសម្រួល និងការដឹកនាំមន្ទីរ ការិយាល័យខ្សែបណ្តោយ ទាំងអស់របស់ក្រសួងដែលដំណើរការនៅក្នុងដែនដីរបស់ក្រុមប្រឹក្សា។ នៅក្នុងតួនាទីអភិបាល **មានគណនេយ្យភាពចំពោះរាជរដ្ឋាភិបាល និងក្រសួងស្ថាប័ននានា** (មាត្រា ១៥៤ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ)។

ចំពោះព័ត៌មានបន្ថែមស្តីពីអភិបាល និងគណៈអភិបាល សូមអានមេរៀនទី ៦

### នាយករដ្ឋបាល

✓ ក្រសួងមហាផ្ទៃ តែងតាំង**នាយករដ្ឋបាល**នៅក្នុងក្រុមប្រឹក្សានីមួយៗ ផ្អែកលើសំណើរបស់អភិបាល និងការឯកភាពរបស់ក្រុមប្រឹក្សា ។ នាយករដ្ឋបាល មាន**គណនេយ្យភាពចំពោះគណៈអភិបាល និងក្រុមប្រឹក្សា**។ ក្រសួងមហាផ្ទៃ ក៏តែងតាំង នាយករងរដ្ឋបាលនៅក្នុងក្រុមប្រឹក្សានីមួយៗផងដែរ (មាត្រា ១៨៣, ១៨៤ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មាត្រា ៤២, ៤៤, ៩៩, ១០១, ១៦០ នៃអនុក្រឹត្យលេខ២១៦ មាត្រា ៤២, ១០១ នៃអនុក្រឹត្យ លេខ២១៥)។

✓ **នាយករដ្ឋបាល គឺជាជំនួយការក្រុមប្រឹក្សា គណៈអភិបាល និងអភិបាល** ។ នាយករដ្ឋបាលធានាថា បុគ្គលិករបស់ក្រុមប្រឹក្សា បំពេញការងារអនុលោមទៅតាមច្បាប់លិខិតបទដ្ឋានជាធរមាន នីតិវិធីរបស់ក្រុមប្រឹក្សា និងសេចក្តីសម្រេច របស់ក្រុមប្រឹក្សា និងគណៈអភិបាល (មាត្រា ១៨៤ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មាត្រា ៤៤, ៤៨, ១០១, ១០៥, ១៦២, ១៦៦ នៃអនុក្រឹត្យលេខ២១៦ មាត្រា ៤៤, ៤៨, ១០៣, ១០៧ នៃអនុក្រឹត្យ លេខ២១៥)។

## ផ្នែកទី ៦: អភិបាល: តំណាងរបស់រាជរដ្ឋាភិបាល

✓ អភិបាល មានតួនាទីបីយ៉ាងខុសគ្នា ( មួកបី) គឺ

> ចំពោះព័ត៌មានបន្ថែមស្តីពីអភិបាល និង គណៈអភិបាល សូមអានមេរៀនទី ៦

- **ប្រធានគណៈអភិបាល**
- **តំណាងរបស់រាជរដ្ឋាភិបាល និងក្រសួង** ដើម្បីត្រួតពិនិត្យ សម្របសម្រួល និងដឹកនាំមន្ទីរ ឬការិយាល័យខ្សែបណ្តោយ
- **តំណាងរបស់រាជរដ្ឋាភិបាល** លើការងារសន្តិសុខ និង សណ្តាប់ធ្នាប់សាធារណៈ ច្បាប់ និងសិទ្ធិមនុស្ស ( មាត្រា ១៣៩, ១៥៤ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មាត្រា) ។

**មួកនាំងបីរបស់អភិបាល**




✓ នៅក្នុងសមត្ថភាពរបស់ខ្លួនជា**តំណាងរបស់រាជរដ្ឋាភិបាល និងក្រសួង** ក្នុងការត្រួតពិនិត្យ សម្របសម្រួល និងដឹកនាំមន្ទីរ ឬ ការិយាល័យខ្សែបណ្តោយ ( មួកទី ២) អភិបាលមានភារកិច្ចខាងក្រោមដើម្បី :

- **សម្របសម្រួល និងដឹកនាំ** មន្ទីរ ឬការិយាល័យខ្សែបណ្តោយនៅក្នុងដែនដីក្នុងការឆ្លើយតបនឹង **តម្រូវការជា អាទិភាពនៅមូលដ្ឋាន**

- តាមរយៈគណៈកម្មាធិការសម្របសម្រួលបច្ចេកទេស ក្រុមប្រឹក្សា និងអភិបាល ត្រូវសម្របសម្រួល និងដឹកនាំ មន្ទីរ ឬការិយាល័យខ្សែបណ្តោយនៅក្នុងដែនដី **ដើម្បីធ្វើសមាហរណកម្មផែនការ និងថវិការបស់ខ្លួនទៅ ក្នុងផែនការ និងថវិការបស់ក្រុមប្រឹក្សា**

> តើលោកអ្នកគិតថា មន្ទីរ ការិយាល័យ មានឆន្ទានុសិទ្ធិ គ្រប់គ្រាន់ដើម្បីមានលទ្ធភាពឆ្លើយតបនឹងតម្រូវការនៅមូលដ្ឋានឬទេ?

- **ដឹកនាំ**មន្ទីរ ឬការិយាល័យខ្សែបណ្តោយនៅក្នុងដែនដី ដើម្បីអនុវត្តតួនាទីរបស់ខ្លួន អនុលោមទៅតាមច្បាប់ គោលនយោបាយជាតិ និងលិខិតបទដ្ឋានជាធរមាន។
- **ពិនិត្យតាមដាន** និងវាយតំលៃប្រធានមន្ទីរ ឬការិយាល័យខ្សែបណ្តោយ
- ពិគ្រោះយោបល់ជាមួយក្រុមប្រឹក្សា ហើយលើកសំណើសុំ**តែងតាំងប្រធាន**មន្ទីរ ឬការិយាល័យខ្សែបណ្តោយ
- អភិបាលខេត្ត ត្រូវណែនាំប្រធានមន្ទីរខ្សែបណ្តោយឱ្យ**កែតម្រូវភាពមិនប្រក្រតី** ឬអំពើខុសឆ្គងដែលបានរកឃើញ។ ប្រសិនបើមិនមានការកែតម្រូវ ហើយភាពមិនប្រក្រតី ឬអំពើខុសឆ្គង មានសភាពធ្ងន់ធ្ងរ អភិបាល ត្រូវរាយ ការណ៍បញ្ហានេះជូនទៅក្រសួងពាក់ព័ន្ធផ្ទាល់៖
    - អភិបាលក្រុង ស្រុក ឬខណ្ឌ ត្រូវរាយការណ៍អំពីភាពមិនប្រក្រតី ឬ អំពើខុសឆ្គងជូនអភិបាលខេត្ត ឬរាជធានី របស់ខ្លួន។ អភិបាលខេត្ត ឬរាជធានី ត្រូវណែនាំប្រធានការិយាល័យខ្សែបណ្តោយឱ្យកែតម្រូវភាពមិនប្រក្រតី ឬ អំពើខុសឆ្គងដែលបានរកឃើញ។ ប្រសិនបើមិនមានការកែតម្រូវ ហើយភាពមិនប្រក្រតី ឬអំពើខុសឆ្គង មានសភាពធ្ងន់ធ្ងរ អភិបាលខេត្ត ឬរាជធានី ត្រូវរាយការណ៍បញ្ហានេះជូនទៅក្រសួងពាក់ព័ន្ធ។
- អភិបាលខេត្ត និងរាជធានី អាចស្នើសុំជាលាយលក្ខអក្សរទៅក្រសួង ដើម្បី**បញ្ចុះឋានៈ**របស់ប្រធានមន្ទីរខ្សែ បណ្តោយ **ប្រសិនបើភាពមិនប្រក្រតី ឬអំពើខុសឆ្គង** មិនអាចកែតម្រូវបាន៖
    - អភិបាលក្រុង ស្រុក ឬខណ្ឌ ត្រូវស្នើសុំទៅអភិបាលខេត្ត ឬរាជធានី ដើម្បីដាក់សំណើបែបនេះទៅក្រសួង ពាក់ព័ន្ធទាក់ទងនឹងប្រធានការិយាល័យ
- ទទួល និងផ្តល់មតិជាមុន ហើយចុះហត្ថលេខា**លើរបាយការណ៍**របស់មន្ទីរ ឬការិយាល័យខ្សែបណ្តោយផ្ញើជូន ក្រសួងរបស់ខ្លួន។

(មាត្រា ៣៥, ៩២, ១៥៣ នៃអនុក្រឹត្យលេខ២១៦ មាត្រា ៣៥, ៩៤ នៃអនុក្រឹត្យលេខ២១៥)។

- ✓ **អភិបាល ត្រូវរាយការណ៍ជាប្រចាំជូនទៅក្រុមប្រឹក្សា**អំពីសកម្មភាព និងលទ្ធផលការងារក្នុងការរបស់ខ្លួនជាតំណាងរបស់រាជរដ្ឋាភិបាល។ ក្រុមប្រឹក្សា អាចតម្រូវឱ្យអភិបាលរាយការណ៍នៅក្នុងកិច្ចប្រជុំរបស់ក្រុមប្រឹក្សាក្នុងករណីដែលមានបញ្ហាទាក់ទងនឹងការងាររបស់អភិបាលក្នុងនាមតំណាងរបស់រាជរដ្ឋាភិបាល ដែល**មានផលប៉ះពាល់មកលើផលប្រយោជន៍ ស្របច្បាប់របស់ប្រជាពលរដ្ឋ ឬប្រជាពលរដ្ឋបានដាក់ពាក្យបណ្ដឹង** (មាត្រា ៣៩, ៩៦, ១៥៧ នៃអនុក្រឹត្យលេខ២១៦)។
- ✓ ក្រុមប្រឹក្សា មានសិទ្ធិផ្ដល់អនុសាសន៍ និងការណែនាំដល់អភិបាលនៅក្នុងតួនាទីរបស់គាត់ជាតំណាងរបស់រាជរដ្ឋាភិបាល ដើម្បីដោះស្រាយតម្រូវការជាអាទិភាព និងបញ្ហាប្រឈមនៅមូលដ្ឋាន។ **អភិបាល ត្រូវទទួលយកអនុសាសន៍ និងការណែនាំរបស់ក្រុមប្រឹក្សា** ហើយអនុវត្តនៅពេលសម្របសម្រួល និងដឹកនាំអង្គភាពខ្សែបណ្ដោយ ហើយបន្ទាប់មកអភិបាល ត្រូវរាយការណ៍ជូនក្រុមប្រឹក្សាវិញ (មាត្រា ៣៩, ៩៦, ១៥៧ នៃអនុក្រឹត្យលេខ២១៦)។
- ✓ អភិបាលក៏ជា**ប្រធានគណៈកម្មការសម្របសម្រួលបច្ចេកទេស**របស់ក្រុមប្រឹក្សាផងដែរ។ គណៈកម្មការសម្របសម្រួលបច្ចេកទេស គឺជាអ្នកទំនាក់ទំនងយ៉ាងសំខាន់សម្រាប់ក្រុមប្រឹក្សា និងមន្ទីរ ឬការិយាល័យខ្សែបណ្ដោយ និងជាវេទិកាយ៉ាងសំខាន់សម្រាប់ក្រុមប្រឹក្សា និងមន្ទីរ ឬការិយាល័យខ្សែបណ្ដោយ**សម្របសម្រួលការងាររបស់ខ្លួន**។
- ✓ នៅក្នុងសមត្ថភាពរបស់ខ្លួនជាតំណាងលើ**ការងារសន្តិសុខ សណ្ដាប់ធ្នាប់សាធារណៈ ច្បាប់ និងសិទ្ធិមនុស្ស** (ពាក់មួកទី ៣) អភិបាលជម្រុញការយល់ដឹងអំពីច្បាប់ ធានាឱ្យបានថា ច្បាប់ត្រូវបានអនុវត្ត និងថាសិទ្ធិមនុស្សត្រូវបានគោរព (មាត្រា ៣៦, ៩៣, ១៥៤ នៃអនុក្រឹត្យលេខ២១៦ មាត្រា ៣៦, ៩៥ នៃអនុក្រឹត្យលេខ២១៥)។
- ✓ អភិបាល គឺជា**ប្រធានគណៈបញ្ជាការឯកភាព**នៅក្នុងដែនដីរបស់ខ្លួន។ នៅក្នុងសមត្ថភាពនោះ អភិបាលដឹកនាំ និងសម្របសម្រួលមន្ទីរ ឬអង្គភាពខ្សែបណ្ដោយ និងរដ្ឋបាលដែលពាក់ព័ន្ធឱ្យរក្សាសន្តិសុខ និងសណ្ដាប់ធ្នាប់សាធារណៈ (មាត្រា ៣៦, ៩៣, ១៥៤ នៃអនុក្រឹត្យលេខ២១៦ មាត្រា ៣៦, ៩៥ នៃអនុក្រឹត្យលេខ២១៥)។
- ✓ អភិបាលអាចបែងចែកភារកិច្ចនេះនៅក្នុងចំណោម**អភិបាលរងនៅក្នុងគណៈអភិបាលរបស់ខ្លួន** (មាត្រា ៣៧, ៩៤, ១៥៥ នៃអនុក្រឹត្យលេខ២១៦ មាត្រា ៣៧, ៩៦ នៃអនុក្រឹត្យលេខ២១៥)។

## ផ្នែកទី ៧: គណៈកម្មាធិការរបស់ក្រុមប្រឹក្សា

### គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស

✓ គ្រប់ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មានកាតព្វកិច្ចបង្កើតគណៈកម្មាធិការសម្របសម្រួលបច្ចេកទេស។ ទោះជាយ៉ាងណាក៏ដោយ ក្រុមប្រឹក្សាពីរ ឬច្រើនអាចប្រើប្រាស់គណៈកម្មាធិការសម្របសម្រួលបច្ចេកទេសមួយជាមួយគ្នា (មាត្រា ១១៤, ១២៥ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ)។

✓ តួនាទីរបស់គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស គឺដើម្បី**សិក្សា និង ផ្តល់យោបល់**ដល់ក្រុមប្រឹក្សា និងគណៈអភិបាល **អំពីការសម្របសម្រួលការងាររបស់ក្រុមប្រឹក្សាជាមួយការងាររបស់មន្ទីរ ឬការិយាល័យខ្សែបណ្តោយ** (មាត្រា ១២៤ នៃ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មាត្រា ២ នៃអនុក្រឹត្យស្តីពីការបង្កើតគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសខេត្ត មាត្រា ២ នៃអនុក្រឹត្យស្តីពីការបង្កើតគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសរាជធានី)។

✓ **សមាសភាព**របស់គណៈកម្មាធិការសម្របសម្រួលបច្ចេកទេសសម្រាប់ក្រុមប្រឹក្សានីមួយៗ មានលក្ខណៈប្រហាក់ប្រហែលគ្នា។ ខាងក្រោមនេះ គឺជាសមាសភាពរបស់**គណៈកម្មាធិការសម្របសម្រួលបច្ចេកទេសនៅថ្នាក់ខេត្ត** (មាត្រា ៣ នៃ អនុក្រឹត្យស្តីពីការបង្កើតគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសខេត្ត)។

- អភិបាលខេត្ត ជាប្រធាន
- អភិបាលរងខេត្ត០១រូប ជាអនុប្រធាន
- នាយករដ្ឋបាលសាលាខេត្ត ជាសមាជិកអចិន្ត្រៃយ៍
- សមាជិកក្រុមប្រឹក្សាខេត្តយ៉ាងតិច០២រូប ជាសមាជិក
- ប្រធានមន្ទីរ អង្គភាពដែលប្រចាំនៅខេត្ត ជាសមាជិក
- នាយកទីចាត់ការទាំងអស់របស់សាលាខេត្ត ជាសមាជិក
- អភិបាលក្រុង អភិបាលស្រុកទាំងអស់នៅក្នុងខេត្ត ជាសមាជិក
- តំណាងសមាគមក្រុមប្រឹក្សាឃុំ សង្កាត់ប្រចាំខេត្ត០២រូប ជាសមាជិក
- តំណាងគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ០១រូប ជាសមាជិក

✓ សមាសភាពរបស់គណៈកម្មាធិការសម្របសម្រួលបច្ចេកទេសសម្រាប់ក្រុមប្រឹក្សាផ្សេងទៀត មានលក្ខណៈប្រហាក់ប្រហែលគ្នា។ សមាសភាពរបស់គណៈកម្មាធិការសម្របសម្រួលបច្ចេកទេសផ្សេងទៀត អាចឃើញមាននៅក្នុងនៃអនុក្រឹត្យស្តីពីការបង្កើតគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសខេត្ត និងអនុក្រឹត្យស្តីពីការបង្កើតគណៈកម្មាធិការសម្របសម្រួលបច្ចេក ទេសរាជធានី។

✓ ដូច្នេះ **ក្រសួងដែលមានសកម្មភាពនៅក្នុងដែនដីរបស់ក្រុមប្រឹក្សា** មានតំណាងនៅក្នុងគណៈកម្មាធិការសម្របសម្រួលបច្ចេក ទេសរបស់ក្រុមប្រឹក្សា។

✓ ភារកិច្ចចំបងរបស់គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស គឺត្រូវ**ផ្តល់មតិយោបល់ដល់ក្រុមប្រឹក្សា និងគណៈអភិបាល** លើវិស័យសំខាន់ៗ ដូចខាងក្រោម

- រៀបចំ**ផែនការអភិវឌ្ឍ** កម្មវិធីវិនិយោគ ក្របខ័ណ្ឌចំណាយ និង**ថវិការបស់ក្រុមប្រឹក្សា**
- **ដាក់បញ្ចូលផែនការ និង ថវិការបស់មន្ទីរ ការិយាល័យខ្សែបណ្តោយ** ទៅក្នុងផែនការអភិវឌ្ឍ កម្មវិធីវិនិយោគ ក្របខ័ណ្ឌចំណាយ និងថវិការបស់ក្រុមប្រឹក្សា
- **សម្របសម្រួល** រវាងការងាររបស់ក្រុមប្រឹក្សាជាមួយការងាររបស់មន្ទីរ ឬការិយាល័យខ្សែបណ្តោយ

> គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស ធ្វើជា**ច្រកទំនាក់ទំនង** យ៉ាងសំខាន់រវាង**ក្រសួងខ្សែបណ្តោយនៅថ្នាក់ជាតិ និង ក្រុមប្រឹក្សានៅថ្នាក់ ក្រោមជាតិ។**
>
> គណៈកម្មាធិការសម្របសម្រួលបច្ចេកទេសៈ
>
> - ផ្តល់យន្តការសម្រាប់ឱ្យក្រុមប្រឹក្សា**ចរចារឱ្យមានសកម្មភាព និង ថវិកា របស់ក្រសួងខ្សែបណ្តោយ**នៅក្នុងដែនដី។
> - ធ្វើឱ្យមាន**ផែនការ និង ថវិកាដែលបានធ្វើសមាហរណកម្ម** នៅក្នុងដែនដី របស់ក្រុមប្រឹក្សា
> - ធ្វើឱ្យក្រុមប្រឹក្សាមានលទ្ធភាព**សម្របសម្រួលការអភិវឌ្ឍនៅក្នុងចំណោមវិស័យនានា**នៅក្នុងដែនដីរបស់ខ្លួន (សមាហរណកម្មតាមវិស័យ)

- អភិវឌ្ឍយន្តការ ប្រព័ន្ធ និងនីតិវិធី ដែលមានការចូលរួមនៅក្នុង**រដ្ឋបាលឯកភាព**
- **កិច្ចសហប្រតិបត្តិការ និងការសម្របសម្រួលនៅក្នុងចំណោមក្រុមប្រឹក្សា** រួមទាំងការពិគ្រោះយោបល់ យន្តការ ការឆ្លើយតបចំពោះសំណូមពររបស់ក្រុមប្រឹក្សាផ្សេងទៀត ដើម្បីដោះស្រាយតម្រូវការនៅមូលដ្ឋាន និងយន្តការ ដោះស្រាយភាពមិនចុះសម្រុងគ្នានៅក្នុងចំណោមក្រុមប្រឹក្សា

- ផ្តល់យោបល់ដល់ក្រុមប្រឹក្សាក្នុងការត្រៀមខ្លួនទទួល**មុខងារ និងធនធានថ្មី** វាយតំលៃ និងជំរុញប្រសិទ្ធិភាព នៅក្នុងការអនុវត្តមុខងាររបស់ក្រុមប្រឹក្សា និងការប្រើប្រាស់ធនធាន
- (មាត្រា ៤. ១៣. ២២ នៃអនុក្រឹត្យលេខ២១៨ មាត្រា ៤. ១៣ នៃអនុក្រឹត្យលេខ២១៧)។

> ចំពោះព័ត៌មានបន្ថែមស្តីពីគណៈកម្មាធិការសម្របសម្រួលបច្ចេកទេស សូមអានមេរៀនទី ៧

## គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ

✓ គ្រប់ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មានកាតព្វកិច្ចបង្កើតគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ (មាត្រា ១១៤ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ)។

✓ គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ មានតួនាទីផ្តល់**មតិយោបល់ និងអនុសាសន៍** ដល់ក្រុមប្រឹក្សា គណៈកម្មាធិការរបស់ក្រុមប្រឹក្សា គណៈអភិបាល និងអភិបាល អំពីបញ្ហាទាក់ទងនឹងសមភាពយេនឌ័រ ស្ត្រី យុវជន និងកុមារ។

> ចំពោះព័ត៌មានបន្ថែមស្តីពីគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ សូមអានមេរៀនទី ៧

គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ ជួយក្រុមប្រឹក្សា គណៈកម្មាធិការរបស់ក្រុមប្រឹក្សា គណៈអភិបាល និង អភិបាលឱ្យធ្វើសេចក្តីសម្រេចដែលមានលក្ខណៈ**ពេញលេញ**សម្រាប់ប្រជាពលរដ្ឋទាំងអស់ (មាត្រា ២ នៃប្រកាសស្តីពី ការបង្កើតគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ)។

✓ ក្រុមប្រឹក្សា **សហប្រតិបត្តិការជាមួយមន្ទីរ ឬការិយាល័យខ្សែបណ្តោយមួយចំនួន** តាមរយៈគណៈកម្មាធិការពិគ្រោះយោបល់ កិច្ចការស្ត្រី និងកុមាររបស់ខ្លួន។

✓ **សមាសភាព**របស់គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារសម្រាប់ខេត្ត និងរាជធានី ត្រូវបានបង្ហាញនៅក្នុងតារាងខាងក្រោម (មាត្រា ៣ នៃប្រកាសស្តីពីការបង្កើតគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការ ស្ត្រី និងកុមារ)។

- សមាជិកក្រុមប្រឹក្សាជាស្ត្រី ដែលជ្រើសរើសដោយក្រុមប្រឹក្សា ប្រធាន
- សមាជិកក្រុមប្រឹក្សា ដែលជ្រើសរើសដោយក្រុមប្រឹក្សា អនុប្រធាន
- អភិបាលរងជាស្ត្រី ០១រូប អនុប្រធាន
- ប្រធាន ឬអនុប្រធានមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា អនុប្រធាន
- ប្រធាន ឬអនុប្រធានមន្ទីរកិច្ចការនារី អនុប្រធានអចិន្ត្រៃយ៍
- នាយករងរដ្ឋបាល ០១រូប សមាជិក
- ប្រធាន ឬអនុប្រធានមន្ទីរផែនការ សមាជិក
- ប្រធាន ឬអនុប្រធានមន្ទីរសុខាភិបាល សមាជិក
- ប្រធាន ឬអនុប្រធានមន្ទីរអភិវឌ្ឍន៍ជនបទ សមាជិក
- ប្រធាន ឬអនុប្រធានមន្ទីរអប់រំ យុវជន និងកីឡា សមាជិក
- ប្រធាន ឬអនុប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សមាជិក
- ប្រធាន ឬអនុប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សមាជិក
- ស្នងការ ឬតំណាងស្នងការដ្ឋាននគរបាល សមាជិក
- នាយក ឬនាយករងទីចាត់ការអន្តរវិស័យ សមាជិក
- ប្រធាន ឬអនុប្រធានសមាគមក្រុមប្រឹក្សាឃុំ សង្កាត់នៃរាជធានី សមាជិក
- តំណាងពីស្ថាប័ន ឬអង្គភាពផ្សេងៗទៀត តាមការចាំបាច់ សមាជិក

✓ គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារនៅតាម**ក្រុង ស្រុក និងខណ្ឌ** មានសមាសភាពប្រហាក់ប្រហែលគ្នា ប៉ុន្តែសមាជិកត្រូវយកចេញពីការិយាល័យខ្សែបណ្តោយ មិនមែនយកចេញពីមន្ទីរឡើយ។ គណៈកម្មាធិការពិគ្រោះយោបល់ កិច្ចការស្ត្រី និងកុមារនៅតាមក្រុង ស្រុក និងខណ្ឌ ក៏មាន**ជនបង្គោលទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់**នៅក្នុង ដែនដីរបស់ខ្លួនជាសមាជិកផងដែរ (មាត្រា ៣ នៃប្រកាសស្តីពីការបង្កើតគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និង កុមារ)។

✓ សមាជិកគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ ចំនួន ២រូប អាច**ចូលរួមនៅក្នុងការប្រជុំរបស់**ក្រុមប្រឹក្សា គណៈកម្មាធិការរបស់ក្រុមប្រឹក្សា និងគណៈអភិបាល លើកលែងតែការប្រជុំជាសំងាត់។ សមាជិកគណៈកម្មាធិការពិគ្រោះ យោបល់កិច្ចការស្ត្រី និងកុមារទាំងពីររូបមានសិទ្ធិ**ពេញលេញក្នុងការរួមចំណែកមតិយោបល់របស់ខ្លួន**នៅក្នុងអំឡុងពេល ប្រជុំ (មាត្រា ១២៨-១៣២ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មាត្រា ៩ នៃប្រកាសស្តីពីការ បង្កើតគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ)។

✓ ក្រុមប្រឹក្សា គណៈកម្មាធិការ និងគណៈអភិបាល **ត្រូវពិចារណាអនុសាសន៍** ដែលទទួលបានពីគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ និងសមាជិករបស់ខ្លួន ហើយត្រូវផ្តល់ការពិចារណាឱ្យបានត្រឹមត្រូវថាតើអនុសាសន៍នោះ អាចអនុវត្តបាន (មាត្រា ៨ នៃប្រកាសស្តីពីការបង្កើតគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ)។

## ផ្នែកទី ៨: រដ្ឋបាលថ្នាក់ក្រោមជាតិ

✓ នៅពេលអនុវត្តមុខងាររបស់ក្រុមប្រឹក្សារដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវ**ប្រាស្រ័យទាក់ទង និងសហប្រតិបត្តិការជាមួយមន្ទីរ ការិយាល័យខ្សែបណ្តោយ**នៅក្នុងដែនដីរបស់ខ្លួន។ នៅក្នុងវិស័យអប់រំ ឱ្យក្រុមប្រឹក្សាឃុំ មុខងារមួយចំនួនឱ្យក្រុមប្រឹក្សាស្រុក ទាំងមានមុខងារមួយចំនួនទៀតត្រូវផ្ទេរឱ្យក្រុមប្រឹក្សាខេត្ត។ ទោះជាយ៉ាងណាក៏ដោយ មុខងារមួយចំនួននឹងត្រូវរក្សាទុកដោយក្រសួងអប់រំយុវជន និងកីឡា។ ក្នុងនោះ អាចមានមុខងារមួយចំនួនក្រសួងទំនងជាធ្វើប្រតិភូកម្មដល់មន្ទីរអប់រំ និងការិយាល័យអប់រំ នូវមុខងារមួយចំនួនដែលខ្លួន រក្សាទុក ។

**ឧទាហរណ៍**

**ក្រសួងអប់រំ** មានមុខងារកំណត់បទដ្ឋានជាតិសម្រាប់ការអប់រំនៅបឋមសិក្សា ដូចជា ចំនួនម៉ោងសម្រាប់រៀន និងប្រធានបទ ជាកាតព្វកិច្ចដែលត្រូវបង្រៀន និងមុខងារពិនិត្យតាមដានថា បទដ្ឋានជាតិទាំងនេះត្រូវបានឆ្លើយតប។ ក្រសួងអប់រំធ្វើប្រតិភូ កម្មដល់ការិយាល័យអប់រំស្រុករបស់ខ្លួននូវមុខងារពិនិត្យតាមដានថា បទដ្ឋានជាតិសម្រាប់ការអប់រំត្រូវបានឆ្លើយតប។

**ក្រុមប្រឹក្សាខេត្ត** មានមុខងារ ជួលគ្រូបង្រៀនសាលាបឋមសិក្សា និងមុខងារផ្តល់ការអប់រំជាប្រចាំដល់គ្រូបង្រៀនទាំងនោះ ដើម្បីកែលម្អជំនាញ និងចំណេះដឹងរបស់គាត់។

**ក្រុមប្រឹក្សាស្រុក** មានមុខងារផ្តល់ការអប់រំនៅបឋមសិក្សា រួមមាន ការគ្រប់គ្រងសាលារៀន ការសាងសង់សាលារៀន និង ការធ្វើលទ្ធកម្មសំភារៈឧបទេស។

**ក្រុមប្រឹក្សាឃុំ សង្កាត់** មានមុខងារប្រមូលទិន្នន័យ ដើម្បីវាយតំលៃតម្រូវការរបស់សាលារៀន ដើម្បីជំរុញការចូលរៀន ដើម្បីផ្តល់មតិដល់ស្រុកអំពីកន្លែងដែលត្រូវសាងសង់សាលារៀន ការថែទាំសាលារៀន និងជូនដំណឹងទៅស្រុកអំពីអវត្តមាន នៅសាលារៀនរយៈពេលយូរ។

**ដើម្បីផ្តល់ការអប់រំនៅបឋមសិក្សាដល់កុមារយ៉ាងមានប្រសិទ្ធិភាព ក្រសួងអប់រំ ក្រុមប្រឹក្សា និងការិយាល័យអប់រំទាំងអស់ ត្រូវធ្វើការប្រាស្រ័យទាក់ទងគ្នា ត្រូវសហប្រតិបត្តិការ និងសហការគ្នា** ។ តួអង្គរបស់រដ្ឋបាលនីមួយៗនេះមានតួនាទីរបស់ខ្លួន ផ្ទាល់ដើម្បីសម្រេចបានគោលដៅនៃការផ្តល់ការអប់រំនៅបឋមសិក្សា។

ត្រូវធ្វើដូចគ្នានេះ ដើម្បីសម្រេចបានគោលដៅនៅក្នុងវិស័យផ្សេងទៀត ដូចជា សុខាភិបាល ធនធានធម្មជាតិ និងការគ្រប់គ្រង កសិកម្ម និងវិស័យផ្សេងៗ។

- ✓ **ទីចាត់ការផែនការ និង វិនិយោគ**របស់ក្រុមប្រឹក្សារាជធានី និងក្រុមប្រឹក្សាខេត្ត ត្រូវ
  - ទំនាក់ទំនង និងសហប្រតិបត្តិការជាមួយមន្ទីរ ឬការិយាល័យខ្សែបណ្ដោយទាក់ទងនឹងតម្រូវការជាអាទិភាពរបស់ រាជធានី ឬខេត្ត និងតម្រូវការជាអាទិភាពរបស់ក្រុង ស្រុក ឃុំ សង្កាត់
  - សហប្រតិបត្តិការជាមួយមន្ទីរ ឬការិយាល័យខ្សែបណ្ដោយនៅក្នុងការពិនិត្យមើល និងការផ្ដល់មតិយោបល់ ដើម្បីលើកទឹកចិត្តការវិនិយោគនៅក្នុងរាជធានី ឬខេត្ត
  - សហប្រតិបត្តិការជាមួយមន្ទីរ ឬការិយាល័យខ្សែបណ្ដោយនៅក្នុងការពិនិត្យតាមដាន និងការអនុវត្តយន្តការដើម្បី លើកទឹកចិត្តការវិនិយោគនៅក្នុងរាជធានី ឬខេត្ត ( ប្រការ ៤ នៃប្រកាសលេខ៤២៧៤ មាត្រា ៤ នៃប្រកាសលេខ ៤២៧៣)
- ✓ **ទីចាត់ការអន្តរវិស័យ**របស់ក្រុមប្រឹក្សាខេត្ត និងក្រុមប្រឹក្សារាជធានីត្រូវ
  - សហប្រតិបត្តិការ និងសម្របសម្រួល ដើម្បីជំរុញការផ្ដល់សេវាទាក់ទងនឹងអប់រំ សុខាភិបាល និងអនាម័យនៅ ក្នុងខេត្ត
  - សហប្រតិបត្តិការនៅក្នុងការអប់រំ និងផ្សព្វផ្សាយព័ត៌មានទាក់ទងនឹងការបង្ការជំងឺ និងសេវាសុខភាពសាធារណៈ
  - សហប្រតិបត្តិការ និងសម្របសម្រួល ដើម្បីដោះស្រាយបញ្ហាទាក់ទងនឹងការងារផ្ដល់ជំនួយសង្គ្រោះសម្រាប់ជនក្រីក្រ និវត្តន៍ជន ជនពិការ ក្មេងកំព្រា និងជនងាយរងគ្រោះផ្សេងទៀត
  - សម្របសម្រួលសកម្មភាពអន្តរវិស័យដើម្បីជម្រុញបរិយាកាសដែលអនុគ្រោះដល់សកម្មសេដ្ឋកិច្ចនៅមូលដ្ឋាន ការ វិនិយោគ និងការអភិវឌ្ឍវិស័យឯកជន។ ( មាត្រា ៧ នៃប្រកាសលេខ៤២៧៤ មាត្រា ៨ នៃប្រកាសលេខ ៤២៧៣)
- ✓ **ការិយាល័យអភិវឌ្ឍក្រុង**របស់ក្រុមប្រឹក្សាក្រុង ត្រូវសហប្រតិបត្តិការជាមួយការិយាល័យពាក់ព័ន្ធក្នុងការសិក្សាស្រាវជ្រាវ និងផ្ដល់សេចក្ដីអធិប្បាយលើការអភិវឌ្ឍនៅក្នុងក្រុង (មាត្រា ១៧ នៃប្រកាសលេខ៤២៧៤)។
- ✓ ការិយាល័យផែនការ និងគាំទ្រឃុំ សង្កាត់របស់**ក្រុមប្រឹក្សាស្រុក** ត្រូវទំនាក់ទំនង និងសហប្រតិបត្តិការជាមួយស្ថាប័ន និង អង្គភាពនានាទាក់ទងនឹងតម្រូវការជាអាទិភាពរបស់ស្រុក និងឃុំ សង្កាត់នៅក្នុងស្រុក ( មាត្រា ២៦ នៃប្រកាស លេខ៤២៧៤)
- ✓ ទាំងនេះគឺគ្រាន់តែជាឧទាហរណ៍ខ្លះអំពីរបៀបរៀបរយរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបំពេញការងារជាមួយ មន្ទីរ ឬការិយាល័យ ខ្សែបណ្ដោយនៅក្នុងដែនដីរបស់ខ្លួន។

# វគ្គទី ២៖

# មេរៀនសង្ខេប

- ✓ ទំនាក់ទំនងរបស់រដ្ឋបាលនៅគ្រប់ថ្នាក់ និងនៅក្នុងរដ្ឋបាលនៅតាមថ្នាក់នីមួយៗ នឹងមានការកែប្រែដោយសារច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

- ✓ គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប) មានការទទួលខុសត្រូវ រួមនៅក្នុងការអនុវត្តច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។ គ.ជ.អ.ប បំពេញការងារជាមួយ ក្រសួងនានា ដើម្បីកំណត់មុខងារ និងធនធានដែលនឹងត្រូវផ្ទេរឱ្យក្រុមប្រឹក្សាថ្នាក់ក្រោមជាតិនីមួយៗ។

- ✓ ក្រសួងមហាផ្ទៃ មានភារកិច្ចត្រួតពិនិត្យក្រុមប្រឹក្សាថ្មីទាំងអស់ ក៏ដូចជាក្រុមប្រឹក្សាឃុំ សង្កាត់។ ក្រសួងមហាផ្ទៃក៏មាន តួនាទីក្នុងការផ្តល់យោបល់ផងដែរ។

- ✓ ក្រសួងនីមួយៗត្រូវកំណត់ និង ផ្ទេរ (ប្រគល់ ឬធ្វើប្រតិភូកម្ម) នូវមុខងារសមស្របរបស់ក្រសួងដល់ក្រុមប្រឹក្សា រួមជាមួយ ធនធានហិរញ្ញវត្ថុ បុគ្គលិក និង សមត្ថភាព។

- ✓ អភិបាលមានតួនាទីបីយ៉ាង គឺ ១. ជាប្រធានគណៈអភិបាល ២. ជាតំណាងរបស់រាជរដ្ឋាភិបាល និងក្រសួងដើម្បីត្រួតពិនិត្យ សម្របសម្រួល និងដឹកនាំមន្ទីរ ឬការិយាល័យខ្សែបណ្តោយ និង ៣. តំណាងរបស់រាជរដ្ឋាភិបាលលើការងារសន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ ច្បាប់ និងសិទ្ធិមនុស្ស។

- ✓ គ្រប់ក្រុមប្រឹក្សា មានកាតព្វកិច្ចបង្កើតគណៈកម្មាធិការសម្របសម្រួលបច្ចេកទេស ដើម្បីសិក្សា និងផ្តល់យោបល់ដល់ក្រុមប្រឹក្សា និងគណៈអភិបាលអំពីការសម្របសម្រួលការងាររបស់ក្រុមប្រឹក្សាជាមួយមន្ទីរ ឬការិយាល័យខ្សែបណ្តោយ។

- ✓ ក្រសួងដែលមានសកម្មភាពនៅក្នុងដែនដីរបស់ក្រុមប្រឹក្សា មានតំណាងនៅក្នុងគណៈកម្មាធិការសម្របសម្រួលបច្ចេកទេស របស់ក្រុមប្រឹក្សា។

- ✓ គ្រប់ក្រុមប្រឹក្សា មានកាតព្វកិច្ចបង្កើតគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ ដើម្បីផ្តល់មតិយោបល់ និង អនុសាសន៍ដល់ក្រុមប្រឹក្សា គណៈកម្មាធិការរបស់ក្រុមប្រឹក្សា គណៈអភិបាល និង អភិបាលអំពីបញ្ហាទាក់ទងនឹងសមភាព យេនឌ័រ ស្ត្រី យុវជន និងកុមារ ។

- ✓ ប្រធាន ឬអនុប្រធានមន្ទីរ ឬការិយាល័យខ្សែបណ្តោយមួយចំនួនជាសមាជិកគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និង កុមារនៅក្នុងដែនដីរបស់ខ្លួន ។

- ✓ នៅពេលអនុវត្តមុខងាររបស់ក្រុមប្រឹក្សា រដ្ឋបាលថ្នាក់ក្រោមជាតិទាំងអស់ ត្រូវទំនាក់ទំនង និងសហប្រតិបត្តិការជាមួយ មន្ទីរ ឬការិយាល័យខ្សែបណ្តោយ ។

## វគ្គទី ៣:

## ការងារជាក្រុម

**ការងារជាក្រុម ដូចមានពិពណ៌នាខាងក្រោម អាចមានលក្ខណៈមិនសមស្របសំរាប់ការបណ្តុះបណ្តាលទាំងអស់។ សូមចាត់ទុកការងារជាក្រុមខាងក្រោមជាសំណូមពរតែប៉ុណ្ណោះ។**

១. ចែកសិក្ខាកាមជាក្រុមដែលមានសមាជិកមិនលើសពី ៨ នាក់

២. ផ្តល់លំហាត់ខាងក្រោមអោយក្រុមនីមួយៗ។

### លំហាត់ទី ១: គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស

### ពិភាក្សានៅក្នុងក្រុមតូច

- តើគណៈកម្មាធិការសម្របសម្រួលបច្ចេកទេស អាចកែប្រែទំនាក់ទំនងពីមុនមករវាងរដ្ឋបាល និងមន្ទីរ ឬការិយាល័យ ខ្សែ បណ្តោយយ៉ាងដូចម្តេច?
- តើលោកអ្នកគិតថាបញ្ហាប្រឈមរបស់គណៈកម្មាធិការសម្របសម្រួលបច្ចេកទេសមានអ្វីខ្លះ?

### លំហាត់ទី ២: គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ

ក្រុមប្រឹក្សាស្រុក កូមា នៅខេត្តកំពង់ស្ពឺ កំពុងជួបប្រជុំ ដើម្បីពិភាក្សាអំពីរបៀបចំណាយអំណោយសប្បុរសជនដែល ទើបតែបានទទួល ដើម្បីសាងសង់ និងដំណើរការកីឡាដ្ឋាន។

ស្រម៉ៃមើលថា លោកអ្នក គឺជាសមាជិកគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមាររបស់ស្រុក កូមា។ កំណត់បញ្ហាអ្វីដែលលោកអ្នក នឹងលើកឡើងនៅក្នុងអំឡុងពេលនៃកិច្ចប្រជុំរបស់ក្រុមប្រឹក្សា ដើម្បីឱ្យក្រុមប្រឹក្សាពិចារណា តម្រូវការរបស់ស្ត្រី យុវជន និងកុមារនៅពេលធ្វើសេចក្តីសម្រេចរបស់ខ្លួនអំពីកីឡាដ្ឋាន។

[illegible]

[illegible]

[illegible]

[illegible]

[illegible]

[illegible]

[illegible]

[illegible]

[illegible]

[illegible]

[illegible]

[illegible]

[illegible]

# មេរៀនសម្រាប់ការយល់ដឹង និង ការបណ្ដុះបណ្ដាលអំពី ច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

## មេរៀនទី ១១:

## ទំនាក់ទំនងអន្តររដ្ឋបាល

## ខេត្ត ក្រុង ស្រុក

## ក្រុមប្រឹក្សាឃុំ សង្កាត់

## វគ្គទី ១៖

១. សេចក្ដីផ្ដើម

២. តួនាទីយ៉ាងសំខាន់របស់ក្រុមប្រឹក្សាឃុំ សង្កាត់

៣. ទំនាក់ទំនងក្រុមប្រឹក្សាខេត្ត

៤. ទំនាក់ទំនងក្រុមប្រឹក្សាស្រុក

៥. ទំនាក់ទំនងក្រុមប្រឹក្សាក្រុង

## ផ្នែកទី ១: សេចក្តីផ្តើម

ទំនាក់ទំនងរដ្ឋបាលពីមុនមក ត្រូវបានកំណត់ឡើងវិញយ៉ាងច្រើនដោយច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។ នៅក្នុងយុគសម័យថ្មីនៃអភិបាលកិច្ចនៅថ្នាក់ក្រោមជាតិនេះ ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក និងឃុំ មានស្វ័យភាពនៅក្នុងដែនដីរៀងខ្លួន។ ក្រុមប្រឹក្សាមួយមិនមានសិទ្ធិជ្រៀតជ្រែតនៅក្នុងឱកាសគិតពិចារណា ឬឱកាសជាឆន្ទានុសិទ្ធិរបស់ក្រុមប្រឹក្សាមួយទៀតបានឡើយ។ ដូច្នេះ ក្រុមប្រឹក្សាមួយមិនមានសិទ្ធិជ្រៀតជ្រែតលើជម្រើសផ្នែកនយោបាយ គោលនយោបាយ សេចក្តីសម្រេច ឬដីការបស់ក្រុមប្រឹក្សា មួយទៀតទេ ដរាបណាជម្រើសគោល នយោបាយ សេចក្តីសម្រេច និងដីកានោះ ស្របទៅតាមរដ្ឋធម្មនុញ្ញ ច្បាប់ និងលិខិតបទដ្ឋានផ្សេងទៀត។

> ក្រុមប្រឹក្សាខេត្ត ក្រុង ស្រុក និងក្រុមប្រឹក្សាឃុំ សង្កាត់ មាន**អំណាចដោយឡែករបស់ខ្លួន** ដើម្បីធ្វើសេចក្តីសម្រេច អនុវត្តមុខងារ និងប្រើប្រាស់ធនធាន (មាត្រា ១៧៤ នៃ អនុក្រឹត្យលេខ២១៦)។

ប៉ុន្តែទោះបីក្រុមប្រឹក្សាទាំងនេះ មានស្វ័យភាពនៅក្នុងដែនដីរបស់ខ្លួនក្តី ក៏ក្រុមប្រឹក្សាទាំងនេះមានទំនាក់ទំនងកិច្ចសហប្រតិបត្តិការយ៉ាងរឹងមាំជាមួយក្រុមប្រឹក្សាផ្សេងទៀត។ ក្រុមប្រឹក្សាត្រូវមានការពិគ្រោះយោបល់ កិច្ចសហប្រតិបត្តិការ និងការសហការគ្នា។ ក្រុមប្រឹក្សាខ្លះ ដូចជាក្រុមប្រឹក្សាខេត្ត អនុវត្តតួនាទីគាំទ្រដល់ក្រុមប្រឹក្សាផ្សេងទៀត។ ឧទាហរណ៍ ក្រុមប្រឹក្សាស្រុកផ្តល់ការអភិវឌ្ឍសមត្ថភាព និងការគាំទ្រប្រភេទផ្សេងទៀតដល់ក្រុមប្រឹក្សាឃុំ សង្កាត់នៅក្នុងស្រុក។

ចាត់ទុកថា រដ្ឋបាលថ្នាក់ក្រោមជាតិជាម៉ាស៊ីនដែលមានគ្រឿងចក្រផ្សេងគ្នា ហើយត្រូវបំពេញការងារជាមួយ គ្នាដើម្បីទទួលបានលទ្ធផលប្រសើរបំផុត។ ដើម្បីឱ្យម៉ាស៊ីនដំណើរការល្អ គ្រឿងចក្រនីមួយៗ នៃម៉ាស៊ីននេះត្រូវមានភាពរឹងមាំ ហើយទាមទារអោយមានការថែទាំឱ្យបានល្អ។ គ្រឿងចក្រមួយត្រូវដំណើរការដោយសហការជាមួយគ្រឿងចក្រផ្សេងទៀត។ ដូចគ្នានេះដែរដើម្បីឱ្យអភិបាលកិច្ចនៅថ្នាក់ក្រោមជាតិនៅកម្ពុជាទទួលបានជោគជ័យ ទាមទារឱ្យក្រុមប្រឹក្សានៅថ្នាក់ផ្សេងគ្នាបំពេញការងារជាលក្ខណៈផលិតភាពជាមួយគ្នាដោយគោរពស្វ័យភាពរបស់ ថ្នាក់ផ្សេងទៀត ។ ប្រការនេះមានន័យថាក្រុមប្រឹក្សានីមួយៗមានគណនេយ្យភាពតាមបែបប្រជាធិបតេយ្យចំពោះប្រជាពលរដ្ឋរបស់ខ្លួន ហើយដូច្នេះ ក្រុមប្រឹក្សានីមួយៗត្រូវមានឱកាសដើម្បីប្រកាន់យកជម្រើសផ្នែកនយោបាយក្នុងនាមប្រជាពលរដ្ឋរបស់ខ្លួន។ ដោយបំពេញការងារជាលក្ខណៈសហប្រតិបត្តិការជាមួយគ្នា និងគោរពគ្នាបញ្ហា អភិបាលកិច្ចនៅថ្នាក់ក្រោមជាតិទំនងជាត្រូវដោះស្រាយដោយសមស្របហើយគោលដៅតាមវិស័យដូចជា គោលដៅអភិវឌ្ឍន៍សហស្សវត្ស ទំនងជាត្រូវដោះស្រាយបានប្រកបដោយជោគជ័យ។ ការងាររបស់ក្រុមប្រឹក្សានីមួយៗ ទំនងជាត្រូវពង្រឹងដោយទំនាក់ទំនងរបស់ក្រុមប្រឹក្សាមួយជាមួយក្រុមប្រឹក្សាផ្សេងទៀត។

**មេរៀននេះ ពិនិត្យមើលទំនាក់ទំនងនៅក្នុងចំណោមក្រុមប្រឹក្សានៅថ្នាក់ក្រោមជាតិនៅក្នុងខេត្ត។**

**តើអ្នកណាខ្លះជាតួអង្គដែលមានការពាក់ព័ន្ធនៅក្នុង "ទំនាក់ទំនងអន្តររដ្ឋបាល"?**

**ទំនាក់ទំនងអន្តររដ្ឋបាល សំដៅលើទំនាក់ទំនង:**

- នៅក្នុងចំណោមក្រសួង និងរវាងក្រសួងជាមួយ គ.ជ.អ.ប
- នៅក្នុងចំណោមក្រុមប្រឹក្សា (នៅថ្នាក់ដូចគ្នា និង នៅថ្នាក់ផ្សេងគ្នា)
- នៅក្នុងចំណោមរដ្ឋបាលរបស់ក្រុមប្រឹក្សាផ្សេងគ្នា
- រវាងអង្គភាពខ្សែបណ្តោយរបស់ក្រសួង និងក្រុមប្រឹក្សា
- រវាងអភិបាលជាតំណាងរបស់រាជរដ្ឋាភិបាល និងអង្គភាពរបស់ក្រសួងខ្សែបណ្តោយ
- រវាងអភិបាលជាតំណាងរបស់រាជរដ្ឋាភិបាល និងក្រុមប្រឹក្សា។

**ទំនាក់ទំនងអន្តររដ្ឋបាល មិនសំដៅលើទំនាក់ទំនងផ្ទៃក្នុងនៅក្នុងក្រុមប្រឹក្សា និងរដ្ឋបាលរបស់ខ្លួនឡើយ។** ឧទាហរណ៍ ទំនាក់ទំនងអន្តររដ្ឋបាលមិនរាប់បញ្ចូលទំនាក់ទំនង:

- រវាងក្រុមប្រឹក្សា និងអភិបាលក្នុងឋានៈជាប្រធានគណៈអភិបាល
- រវាងក្រុមប្រឹក្សា និងគណៈអភិបាល
- រវាងគណៈអភិបាល និងនាយករដ្ឋបាល
- រវាងនាយករដ្ឋបាល និងបុគ្គលិករបស់ក្រុមប្រឹក្សា។

- **តើ "ទំនាក់ទំនង" នៅក្នុងទំនាក់ទំនងអន្តររដ្ឋបាល មានអ្វីខ្លះ?**

ឧទាហរណ៍ចំពោះអ្វីដែលអាចពាក់ព័ន្ធនឹងទំនាក់ទំនងអន្តររដ្ឋបាល រួមមាន:

- ការចែករំលែកព័ត៌មាន និងការប្រាស្រ័យទាក់ទង
- ការសម្របសម្រួល
- កិច្ចសហប្រតិបត្តិការ
- ការសហការ
- ការគាំទ្រ
- ជំនួយផ្នែកបច្ចេកទេស
- ការពិនិត្យនីត្យានុកូលភាព
- ការពិនិត្យតាមដាន និងវាយតំលៃ។

## ផ្នែកទី ២: តួនាទីយ៉ាងសំខាន់របស់ក្រុមប្រឹក្សាឃុំ សង្កាត់

✓ ក្រុមប្រឹក្សាឃុំ សង្កាត់ មាន**ទំនាក់ទំនងជាមួយក្រុមប្រឹក្សានៅថ្នាក់ផ្សេងទៀតទាំងអស់**នៅក្នុងខេត្ត។ ដូច្នេះ ក្រុមប្រឹក្សាឃុំ សង្កាត់ មានទំនាក់ទំនងជាមួយក្រុមប្រឹក្សាស្រុករបស់ខ្លួន ជាមួយក្រុមប្រឹក្សាខេត្តរបស់ខ្លួន និងជាមួយក្រុមប្រឹក្សាឃុំ និងក្រុមប្រឹក្សាស្រុកដែលនៅជាប់គ្នា ហើយប្រហែលជាមួយក្រុមប្រឹក្សាក្រុង និងក្រុមប្រឹក្សាសង្កាត់ដែលនៅជិតខាងផងដែរ។ ដូចគ្នានេះ ក្រុមប្រឹក្សាសង្កាត់ នឹងមានទំនាក់ទំនងជាមួយក្រុមប្រឹក្សាក្រុង ឬក្រុមប្រឹក្សាស្រុករបស់ខ្លួនជាមួយក្រុមប្រឹក្សាខេត្តរបស់ខ្លួន និងជាមួយក្រុមប្រឹក្សានៅជិតខាងផ្សេងទៀតផងដែរ។

✓ សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ដើរតួនាទីយ៉ាងសំខាន់នៅក្នុងអភិបាលកិច្ចនៅថ្នាក់ក្រោមជាតិ។ ក្រុមប្រឹក្សានៅថ្នាក់ក្រោមជាតិទាំងអស់នៅក្នុងខេត្ត មាន**គណនេយ្យភាពចំពោះក្រុមប្រឹក្សាឃុំ សង្កាត់**ពីព្រោះសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ជាអ្នកបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាទាំងនោះ។

> នៅពេលគិតអំពីសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ និង ក្រុមប្រឹក្សាស្រុក **គណនេយ្យភាព** សំដៅលើក្រុមប្រឹក្សាឃុំ សង្កាត់ដែលមានសិទ្ធិអំណាចមួយចំនួនលើក្រុមប្រឹក្សាស្រុក។ ប្រការនេះមានន័យថា
>
> - សិទ្ធិស្នើសុំ និង **ទទួលព័ត៌មាន**ពីក្រុមប្រឹក្សាស្រុក
> - សិទ្ធិធ្វើឱ្យសម្លេងរបស់ខ្លួន ទទួលបានការស្តាប់ឮ យល់ និងពិចារណា
> - សិទ្ធិ**វាយតម្លៃសកម្មភាព**របស់ក្រុមប្រឹក្សាស្រុក និង ទាមទារឱ្យចាត់វិធានការនៅពេលការងាររបស់ក្រុមប្រឹក្សា មិនទទួលបានការពេញចិត្ត

✓ ក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវ:

- ផ្តល់សេចក្តីអធិប្បាយ និងពិនិត្យតាមដានក្រុមប្រឹក្សាស្រុក ក្រុង និងក្រុមប្រឹក្សាខេត្តរបស់ខ្លួន ដើម្បីធានាឱ្យបានថាក្រុមប្រឹក្សាទាំងនោះ**មានការឆ្លើយតបចំពោះតម្រូវការពិតប្រាកដ**របស់ប្រជាជននៅមូលដ្ឋាន។
- ផ្តល់អនុសាសន៍ដល់ក្រុមប្រឹក្សាផ្សេងទៀតអំពី**តម្រូវការនៅមូលដ្ឋាន**ដែលក្រុមប្រឹក្សាឃុំ សង្កាត់ **មិនអាចដោះស្រាយដោយខ្លួនឯង**
- សហប្រតិបត្តិការជាមួយក្រុមប្រឹក្សាផ្សេងទៀតនៅក្នុងការជំរុញ និងការសម្របសម្រួល**ការផ្តល់សេវា** និងការអភិវឌ្ឍនៅមូលដ្ឋាន (មាត្រា ១៨៥ នៃអនុក្រឹត្យលេខ២១៦)។

✓ ទោះបីជាក្រុមប្រឹក្សាឃុំ សង្កាត់ គឺជាក្រុមប្រឹក្សានៅថ្នាក់ "ទាបបំផុតក្តី" ក៏ក្រុមប្រឹក្សាឃុំ សង្កាត់ មាន**តួនាទីជាក់លាក់**ក្នុងការធ្វើឱ្យក្រុមប្រឹក្សា "នៅថ្នាក់ខ្ពស់ជាង" មានគណនេយ្យភាព និងធានាឱ្យបានថា **តម្រូវការរបស់**

**ប្រជាពលរដ្ឋរបស់ខ្លួនត្រូវបានឆ្លើយតប**។ នេះគឺជាតួនាទីយ៉ាងពិសេសរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ពីព្រោះក្រុមប្រឹក្សាឃុំ សង្កាត់ **ស្ថិតនៅកៀកនឹងប្រជាពលរដ្ឋ** ដែលអាចមើលឃើញយ៉ាងច្បាស់អំពីតម្រូវការ និងអាទិភាពនៅមូលដ្ឋាន។ នេះគឺជាតួនាទីយ៉ាងពិសេសរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ដោយហេតុថាក្រុមប្រឹក្សាឃុំសង្កាត់ត្រូវបានបោះឆ្នោតជ្រើសរើសឡើងដោយផ្ទាល់ពីសំណាក់ប្រជាពលរដ្ឋមាន**ចំណងគណនេយ្យតាមបែបប្រជាធិបតេយ្យយ៉ាងរឹងមាំ**រវាងក្រុមប្រឹក្សាឃុំ សង្កាត់ និងប្រជាពលរដ្ឋរបស់ខ្លួន។

## ផ្នែកទី ៣៖ ទំនាក់ទំនងក្រុមប្រឹក្សាខេត្ត

✓ ដូចក្រុមប្រឹក្សាទាំងអស់ដែរ ក្រុមប្រឹក្សាខេត្ត មានគោលបំណងបង្កើត ជំរុញ និងធ្វើឱ្យមានចីរភាពដល់ភាព**ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ**នៅក្នុងដែនដីរបស់ខ្លួន។ ក្រុមប្រឹក្សាខេត្ត**មានគណនេយ្យភាពតាមបែបប្រជាធិបតេយ្យ** ចំពោះប្រជាពលរដ្ឋ និងចំពោះសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ដែលបោះឆ្នោតជ្រើសរើសគាត់។ ក្រុមប្រឹក្សាខេត្ត ក៏មានគណនេយ្យភាពចំពោះរាជរដ្ឋាភិបាលផងដែរចំពោះការអនុវត្តតាម រដ្ឋធម្មនុញ្ញ ច្បាប់ និងលិខិតបទដ្ឋានជាធរមានផ្សេងទៀត។

✓ ក្រៅពីការអនុវត្តការងាររបស់ខ្លួនផ្ទាល់ ក្រុមប្រឹក្សាខេត្ត មាន**ភារកិច្ចគាំទ្រ និងផ្តល់អំណាចដល់ក្រុមប្រឹក្សាផ្សេងទៀតទាំងអស់**នៅក្នុងខេត្ត។ ផ្នែកនេះ នឹងពិនិត្យមើលទំនាក់ទំនងរបស់ក្រុមប្រឹក្សាខេត្តជាមួយក្រុមប្រឹក្សាទាំងអស់ផ្សេងទៀតនៅក្នុងខេត្ត គឺក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាក្រុង និងក្រុមប្រឹក្សាឃុំ សង្កាត់។

### ការគាំទ្រដល់ក្រុមប្រឹក្សាផ្សេងទៀត

✓ ក្រុមប្រឹក្សាខេត្ត មានការទទួលខុសត្រូវចំពោះការផ្តល់**ការគាំទ្រដល់ក្រុមប្រឹក្សាទាំងអស់**នៅក្នុងខេត្ត។ ការគាំទ្រនេះត្រូវផ្តល់ដោយរដ្ឋបាលខេត្ត (មាត្រា ៥៨ នៃអនុក្រឹត្យលេខ២១៦ ប្រការ ៣-៧ នៃប្រកាសលេខ៤២៧៤)។

✓ ទីចាត់ការផែនការ និងវិនិយោគរបស់រដ្ឋបាលខេត្ត ៖

- សហប្រតិបត្តិការជាមួយ និងគាំទ្រក្រុមប្រឹក្សាទាំងអស់នៅក្នុងការរៀបចំ និងការអនុវត្ត**ផែនការអភិវឌ្ឍ និងកម្មវិធីវិនិយោគ**
- ផ្តល់ការគាំទ្រផ្នែកបច្ចេកទេសសម្រាប់**ការសិក្សាលើលទ្ធភាពអនុវត្ត** ការប៉ាន់ស្មានលើការចំណាយ និង**សំណើគម្រោង**
- **ពិនិត្យតាមដាន វាយតំលៃ និងគាំទ្រ**សមត្ថភាព និងការបំពេញការងាររបស់ក្រុមប្រឹក្សាផ្សេងទៀត (មាត្រា ៥៨ នៃប្រកាសលេខ៤២៧៤ ប្រការ ៤ នៃប្រកាសលេខ៤២៧៣)។

✓ ទីចាត់ការហិរញ្ញវត្ថុរបស់ក្រុមប្រឹក្សាខេត្ត គាំទ្រក្រុមប្រឹក្សាក្រុង និងស្រុក ដើម្បី**រៀបចំ និងអនុវត្តថវិការ**បស់ខ្លួន។ ទីចាត់ការហិរញ្ញវត្ថុ ក៏គាំទ្រផងដែរដល់ក្រុមប្រឹក្សាក្រុង និងស្រុក ដើម្បីជួយក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងការរៀបចំថវិការបស់ឃុំ សង្កាត់ (មាត្រា ៥៨ នៃអនុក្រឹត្យលេខ២១៦ ប្រការ ៤ នៃប្រកាសលេខ៤២៧៤ )។

✓ និយាយកាន់តែទូទៅ ក្រុមប្រឹក្សាខេត្តត្រូវបំពេញការងារជាមួយក្រុមប្រឹក្សាក្រុង និងស្រុក ដើម្បី**ឆ្លើយតបនឹងតម្រូវការរបស់ក្រុមប្រឹក្សាឃុំ សង្កាត់** (មាត្រា ១៨៥ នៃអនុក្រឹត្យលេខ២១៦)។

**ឧទាហរណ៍**

ក្រុមប្រឹក្សាឃុំ សង្កាត់នៅក្នុងស្រុក អាចជួបនឹងបញ្ហាអំពើហិង្សារបស់យុវជន។ ក្រុមប្រឹក្សាទាំងនេះ បានព្យាយាមប្រើប្រាស់យុទ្ធសាស្ត្រផ្សេងៗ ដើម្បីដោះស្រាយបញ្ហា ប៉ុន្តែមិនទទួលបានជោគជ័យ។ ខាងក្រោមនេះ គឺជាឧទាហរណ៍នៃការគាំទ្រដែលក្រុមប្រឹក្សាឃុំ សង្កាត់ អាចស្វែងរកពីក្រុមប្រឹក្សាស្រុក និងក្រុមប្រឹក្សាខេត្តរបស់ខ្លួន។

- ស្នើសុំការគាំទ្រក្នុងការលើកបញ្ហានៅក្នុងសហគមន៍របស់ខ្លួន ដើម្បីស្តាប់សម្លេងរបស់ប្រជាពលរដ្ឋអំពីវិធីដោះស្រាយបញ្ហា (ការចូលរួមចំណែករបស់ប្រជាពលរដ្ឋ)
- ស្នើសុំឱ្យមានការរៀបចំវេទិកាថ្នាក់ខេត្ត ដើម្បីចែករំលែកបទពិសោធន៍អំពីរបៀបដោះស្រាយអំពើហិង្សាយុវជន
- ស្នើសុំការគាំទ្រពីក្រុមប្រឹក្សាស្រុក និង ខេត្ត ដើម្បីឱ្យក្រុមប្រឹក្សាឃុំ សង្កាត់ អាចបើកមជ្ឈមណ្ឌលកំសាន្តដែលផ្តល់កម្មវិធីដល់យុវជនមានបញ្ហា
- ស្នើសុំឱ្យស្រុកបើកមជ្ឈមណ្ឌលកំសាន្តនៅក្នុងស្រុកដែលផ្តល់កម្មវិធីដល់យុវជនមានបញ្ហា។

ក្របខ័ណ្ឌច្បាប់ តម្រូវថា ក្រុមប្រឹក្សាស្រុក និងក្រុមប្រឹក្សាខេត្ត អាចបំពេញការងារជាមួយគ្នា ដើម្បីឆ្លើយតបនឹងតម្រូវការរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងការដោះស្រាយបញ្ហាអំពើហិង្សាយុវជន (មាត្រា ១៨៥ នៃអនុក្រឹត្យលេខ២១៦)។

✓ សមាជិកក្រុមប្រឹក្សាខេត្ត មិនផ្តល់ការគាំទ្រដល់ក្រុមប្រឹក្សាផ្សេងទៀត*ដោយខ្លួនឯង*ឡើយ។ ក្រុមប្រឹក្សាខេត្ត អាចធ្វើប្រតិភូកម្មភារកិច្ចទាំងនេះដល់**គណៈអភិបាលខេត្ត** (មាត្រា ១៩៦ នៃអនុក្រឹត្យលេខ២១៦)។

✓ ក្នុងការផ្តល់ការគាំទ្រ ក្រុមប្រឹក្សាខេត្ត និងគណៈអភិបាលខេត្ត ត្រូវ**គោរពស្វ័យភាពរបស់ក្រុមប្រឹក្សាទាំងអស់** (មាត្រា ១៧៤ នៃអនុក្រឹត្យលេខ២១៦)។ និយាយម៉្យាងទៀតថា ក្រុមប្រឹក្សាខេត្ត និងគណៈអភិបាលខេត្តមិនអាចណែនាំក្រុមប្រឹក្សាផ្សេងទៀតអំពីអ្វីដែលត្រូវធ្វើ និងរបៀបដែលត្រូវធ្វើឡើយ។

ចំពោះព័ត៌មានបន្ថែមអំពីការផ្ទេរមុខងារ សូមអាន មេរៀនទី ១៣។

✓ ក្រុមប្រឹក្សាខេត្ត មានការទទួលខុសត្រូវបន្ថែមក្នុងការប្រាស្រ័យទាក់ទង និងសហប្រតិបត្តិការជាមួយ គ.ជ.អ.ប និងក្រសួងនានាទាក់ទងនឹង**ការបែងចែក និងការផ្ទេរមុខងារ និងធនធាន** (ហិរញ្ញវត្ថុ ទ្រព្យសម្បត្តិ និងបុគ្គលិក)ពីថ្នាក់ជាតិដល់ក្រុមប្រឹក្សានៅថ្នាក់ក្រោមជាតិ។ នៅក្នុងការអនុវត្តតួនាទីនេះ ក្រុមប្រឹក្សាខេត្តត្រូវ**ពិគ្រោះយោបល់ជាមួយនឹងរដ្ឋបាលផ្សេងទៀតនៅថ្នាក់ក្រោមជាតិ**នៅក្នុងខេត្តរបស់ខ្លួន។ ដូច្នេះ ក្រុមប្រឹក្សាខេត្តត្រូវប្រមូលមតិយោបល់របស់ក្រុមប្រឹក្សានានានៅក្នុងខេត្តអំពីមុខងារ និងធនធានដែលគួរ (និងមិនគួរ) ផ្ទេរ

មកឱ្យខ្លួន។ ក្រុមប្រឹក្សាខេត្ត ត្រូវបង្ហាញមតិយោបល់ទាំងនេះនៅថ្នាក់ជាតិ (មាត្រា ៥៨, ១៩៥ នៃអនុក្រឹត្យលេខ២១៦ មាត្រា ៧ នៃប្រកាសលេខ៤២៧៤)។

✓ នៅពេលសេចក្ដីសម្រេចត្រូវបានធ្វើដោយ គ.ជ.អ.ប និងក្រសួង ក្រុមប្រឹក្សាខេត្តត្រូវធានាឱ្យបានថា ការផ្ទេរមុខងារ និងធនធានដល់ក្រុមប្រឹក្សានៅក្នុងខេត្តមាន**ការសម្របសម្រួលគ្នាយ៉ាងល្អ** (មាត្រា ១៩៥ នៃអនុក្រឹត្យលេខ២១៦)។

## ការពិនិត្យនីត្យានុកូលភាព

✓ ក្រុមប្រឹក្សាខេត្ត បានទទួលការធ្វើប្រតិភូកម្មមុខងារដើម្បីធានាឱ្យបានថា ក្រុមប្រឹក្សាផ្សេងទៀតអនុវត្តទៅតាម**រដ្ឋធម្មនុញ្ញ ច្បាប់ ក្របខ័ណ្ឌច្បាប់ និងគោលនយោបាយជាតិ** (មាត្រា ១៩៥, ១៩៦ នៃអនុក្រឹត្យលេខ២១៦)។

✓ ក្រុមប្រឹក្សាខេត្ត មានការទទួលខុសត្រូវក្នុងការពិនិត្យនីត្យានុកូលភាពនៃដីកា និង សេចក្ដីសម្រេចរបស់**ក្រុមប្រឹក្សាក្រុង និង ស្រុក** (មាត្រា ៤ នៃអនុក្រឹត្យលេខ២១៦)។

**ឧទាហរណ៍**

ក្រុមប្រឹក្សាស្រុក ដាក់ចេញដីកាដែលហាមឃាត់ប្រជាពលរដ្ឋមិនឱ្យធ្វើចំណាកស្រុក។ ដីកាបែបនេះ រំលោភមាត្រា ៤០ នៃរដ្ឋធម្មនុញ្ញ ដែលចែងថា

- ប្រជាពលរដ្ឋខ្មែរ មានសិទ្ធិធ្វើដំណើរ និងតាំងទីលំនៅនៅបរទេស ហើយវិលត្រឡប់មកកាន់ប្រទេសវិញ។

✓ ក្រុមប្រឹក្សាខេត្តខ្លួនឯងមិនពិនិត្យនីត្យានុកូលភាពលើដីកា និងសេចក្ដីសម្រេចរបស់**ក្រុមប្រឹក្សាឃុំ សង្កាត់** ឡើយ។ ជាជំនួស ក្រុមប្រឹក្សាខេត្ត គាំទ្រក្រុមប្រឹក្សាក្រុង និងក្រុមប្រឹក្សាស្រុកក្នុងការពិនិត្យនីត្យានុកូលភាពលើ ដីកា និងសេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ (មាត្រា ៧៤, ១៩៦ នៃអនុក្រឹត្យលេខ២១៦ ប្រការ ៤ នៃប្រកាសលេខ៤២៧៤)។

ត្រូវមានការចងចាំថា ក្រុមប្រឹក្សាខេត្ត និងគណៈអភិបាលខេត្ត ត្រូវ**គោរពស្វ័យភាព ឱកាសគិតពិចារណា និងឱកាសផ្នែកនយោបាយ និងឆន្ទានុសិទ្ធិរបស់ក្រុមប្រឹក្សាទាំងអស់**។

ការពិនិត្យនីត្យានុកូលភាព គឺជាការធានាឱ្យបានថា ដីកា និងសេចក្ដីសម្រេច មានអនុលោមភាពផ្នែកបច្ចេកទេស និងច្បាប់តាមរដ្ឋធម្មនុញ្ញ ច្បាប់ លិខិតបទដ្ឋាន និងគោលនយោបាយជាតិ។

ដរាបណាក្រុមប្រឹក្សា មានអនុលោមភាពរួចហើយ ក្រុមប្រឹក្សាខេត្ត និងគណៈអភិបាលខេត្ត មិនមាន**សិទ្ធិណែនាំក្រុមប្រឹក្សា**អំពីអ្វីដែលត្រូវធ្វើ ឬរបៀបដែលត្រូវធ្វើឡើយ (មាត្រា ១៧៤ នៃអនុក្រឹត្យលេខ២១៦)។

✓ ជាផ្នែកមួយនៃភារកិច្ចរបស់ខ្លួនក្នុងការធានាថា ក្រុមប្រឹក្សាទាំងអស់អនុវត្តតាមរដ្ឋធម្មនុញ្ញ ច្បាប់ លិខិតបទដ្ឋាន និង គោលនយោបាយជាតិ ក្រុមប្រឹក្សាខេត្ត ត្រូវ

- អភិវឌ្ឍយុទ្ធសាស្ត្រ ដើម្បី**កសាងសមត្ថភាព**របស់ក្រុមប្រឹក្សានៅថ្នាក់ក្រោមជាតិនៅក្នុងខេត្ត និងបុគ្គលិករបស់ក្រុមប្រឹក្សា ដើម្បីឱ្យក្រុមប្រឹក្សា និងបុគ្គលិករបស់ខ្លួនយល់អំពីរបៀបបំពេញការងារអនុលោមទៅតាមរដ្ឋធម្មនុញ្ញ ច្បាប់ លិខិតបទដ្ឋាន និងគោលនយោបាយជាតិ

- **ដឹកនាំ សម្របសម្រួល និងគាំទ្រ**ក្រុមប្រឹក្សានៅថ្នាក់ក្រោមជាតិនៅក្នុងខេត្ត ដើម្បីអនុវត្តមុខងាររបស់ខ្លួន និងប្រើប្រាស់ធនធានរបស់ខ្លួន អនុលោមទៅតាមរដ្ឋធម្មនុញ្ញ ច្បាប់ លិខិតបទដ្ឋាន និងគោលនយោបាយជាតិ

- ធានាឱ្យបានថា ក្រុមប្រឹក្សាឃុំ សង្កាត់ ទទួលបាន**ការគាំទ្រសមស្របពីក្រុមប្រឹក្សាក្រុង និងស្រុក** ដើម្បីបំពេញការងារអនុលោមទៅតាមរដ្ឋធម្មនុញ្ញ ច្បាប់ លិខិតបទដ្ឋាន និងគោលនយោបាយជាតិ (មាត្រា ១៩៦ នៃអនុក្រឹត្យលេខ២១៦) ។

## វេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់

✓ នៅត្រីមាសទី ៤ ជារៀងរាល់ឆ្នាំ ក្រុមប្រឹក្សាខេត្ត ត្រូវរៀបចំវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់នៅគ្រប់ក្រុង និងស្រុកនៅក្នុងខេត្ត ។ វេទិកាទាំងនេះអាចជាយន្តការយ៉ាងសំខាន់សម្រាប់:

- **តម្លាភាព**
- **ការចូលរួមចំណែករបស់ប្រជាពលរដ្ឋ**
  - **ការពិគ្រោះយោបល់**
  - **ការចូលរួម**
  - **សម្លេងរបស់ប្រជាពលរដ្ឋ**
  - **ការពិគ្រោះយោបល់រវាងរដ្ឋបាល និងប្រជាពលរដ្ឋអំពីការអភិវឌ្ឍ ជម្រើស សិទ្ធិ និងសេវា**
- **សាមគ្គីភាព ដែលមានការពាក់ព័ន្ធនឹងប្រជាពលរដ្ឋដែលគេមិនរាប់អាន**
- **គណនេយ្យភាពតាមបែបប្រជាធិបតេយ្យ**

(មាត្រា ៩ នៃអនុក្រឹត្យលេខ២១៦ អ.ន.ក្រ.បក ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក)

✓ វេទិកា ត្រូវចូលរួមដោយសមាជិកក្រុមប្រឹក្សាខេត្ត និង ដោយគណៈអភិបាលខេត្ត ហើយ

- នៅពេលវេទិកា ត្រូវរៀបចំនៅក្នុងក្រុង សមាជិកក្រុមប្រឹក្សាក្រុង និងគណៈអភិបាលក្រុង ក៏ត្រូវចូលរួមដែរ
- នៅពេលវេទិកាត្រូវរៀបចំនៅក្នុងស្រុក សមាជិកក្រុមប្រឹក្សាស្រុក និងគណៈអភិបាលស្រុក ក៏ត្រូវចូលរួមដែរ (មាត្រា ៩ នៃអនុក្រឹត្យលេខ២១៦) ។

✓ ក្រៅពីនេះ នៅគ្រប់វេទិកា **សមាជិកក្រុមប្រឹក្សាឃុំ និងសង្កាត់**នៅក្នុងដែនដី ត្រូវចូលរួមក៏ដូចជាជាតំណាងរបស់ **សហគមន៍ប្រជាជន** និងអ្នកពាក់ព័ន្ធផ្សេងទៀតផងដែរ (មាត្រា ៩ នៃអនុក្រឹត្យលេខ២១៦) ។

✓ គោលបំណងរបស់វេទិកា គឺដើម្បីឱ្យក្រុមប្រឹក្សាខេត្ត:

- **រាយការណ៍**អំពីសកម្មភាពរបស់ក្រុមប្រឹក្សាខេត្ត នៅឆ្នាំកន្លងមក

- **ឆ្លើយតបនឹងសំណួមពរ និងសំណើ**របស់អ្នកចូលរួម គឺក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាសង្កាត់ តំណាងរបស់សហគមន៍ ប្រជាជន និងអ្នកពាក់ព័ន្ធផ្សេងទៀត

**ឧទាហរណ៍**

អ្នកចូលរួមនៅក្នុងវេទិកាអាចៈ

- ស្នើសុំឱ្យក្រុមប្រឹក្សាសាងសង់មន្ទីរពេទ្យឯកទេសកុមារនៅក្នុងខេត្ត
- ស្វែងរកការបំភ្លឺថាហេតុអ្វីបានជាក្រុមប្រឹក្សាមិនបានចំណាយថវិកាទាំងអស់ដែលក្រុមប្រឹក្សាបានផ្ដល់សម្រាប់សន្តិសុខសង្គម។

- **ពិភាក្សា និងបំភ្លឺបញ្ហា**ដែលលើកឡើងដោយអ្នកចូលរួម
- **ប្រមូលមតិយោបល់**ពីអ្នកចូលរួម ដើម្បីកែលម្អការងាររបស់ក្រុមប្រឹក្សាខេត្ត និងការ ឆ្លើយតបរបស់ក្រុមប្រឹក្សាចំពោះតម្រូវការ នៅមូលដ្ឋាន (មាត្រា ៩ នៃអនុក្រឹត្យ លេខ២១៦)។

✓ គណៈអភិបាលខេត្ត ក្នុងនាមក្រុមប្រឹក្សា ចងក្រង និងវាយតំលៃលទ្ធផលនៃវេទិកានៅក្នុងរយៈពេល១៥ថ្ងៃ។ **របាយការណ៍**របស់គណៈអភិបាល ត្រូវមានបញ្ចូលរបៀបដែលក្រុមប្រឹក្សា អាចឆ្លើយតបនឹងតម្រូវការដែលបានលើកឡើងនៅក្នុងអំឡុងពេលនៃវេទិកា (មាត្រា ៩ នៃអនុក្រឹត្យលេខ២១៦)។

✓ នៅពេលបញ្ហាដែលបានលើកឡើង **ស្ថិតនៅក្រៅវិសាលភាពភារកិច្ចរបស់ក្រុមប្រឹក្សាខេត្តៈ**

- រដ្ឋបាលខេត្ត ត្រូវពិគ្រោះយោបល់ជាមួយក្រុមប្រឹក្សាដែលមានការទទួលខុសត្រូវ ដើម្បីឱ្យក្រុមប្រឹក្សានេះអាចដោះស្រាយបញ្ហា
- ឬរដ្ឋបាលខេត្តត្រូវរាយការណ៍ជូនក្រសួងមហាផ្ទៃ ប្រសិនបើបញ្ហានោះទាក់ទងនឹងការទទួលខុសត្រូវរបស់ថ្នាក់ជាតិ។

(មាត្រា នៃអនុក្រឹត្យលេខ២១៦ អ.ន.ក្រ.បក ស្ដីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក)។

✓ ដូចគ្នានឹងរបាយការណ៍របស់ក្រុមប្រឹក្សាផ្សេងទៀតដែរ របាយការណ៍អំពីវេទិកា**ត្រូវផ្ដល់ជូនសាធារណជន** (មាត្រា ៥១ នៃច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ)។

## ទំនាក់ទំនងជាមួយមន្ទីរខេត្តបណ្ដោយ

✓ ក្រុមប្រឹក្សាថ្មីទាំងអស់ នឹងមានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយមន្ទីរ ឬការិយាល័យខ្សែបណ្ដោយនៅក្នុងដែនដីរបស់ខ្លួន។ ទំនាក់ទំនងនេះ គឺជាចំណុចដ៏សំខាន់នៃទស្សនាទានអំពី**រដ្ឋបាលឯកភាព**។

✓ ក្រុមប្រឹក្សា និងមន្ទីរ ឬការិយាល័យខ្សែបណ្ដោយ ត្រូវ**ទំនាក់ទំនងសហប្រតិបត្តិការ និងសហការ** ដើម្បីកែលម្អអភិបាលកិច្ច និងកែលម្អលទ្ធផលអភិវឌ្ឍនៅក្នុងដែនដីរបស់ខ្លួន។

| |
|---|
| ចំពោះព័ត៌មានបន្ថែមអំពីរដ្ឋបាលឯកភាព សូមអានមេរៀនទី ៤។ |

✓ ដូចគ្នានឹងក្រុមប្រឹក្សាថ្មីទាំងអស់ដែរ ក្រុមប្រឹក្សាខេត្តមាន**គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស**។ គណៈកម្មាធិការសម្របសម្រួលបច្ចេកទេសមានសមាជិកដូចតទៅ៖ អភិបាល (ប្រធាន) សមាជិកក្រុមប្រឹក្សា បុគ្គលិករបស់ក្រុមប្រឹក្សាក៏ដូចជាប្រធានមន្ទីរខ្សែបណ្ដោយដែលកំពុងផ្ដល់សេវានៅក្នុងដែនដីរបស់ក្រុមប្រឹក្សា។ ឧទាហរណ៍ ប្រធានមន្ទីរ សុខាភិបាល គឺជាសមាជិកគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសរបស់ក្រុមប្រឹក្សាខេត្ត (មាត្រា ៣ នៃអនុក្រឹត្យលេខ២១៨)។

| |
|---|
| ចំពោះព័ត៌មានបន្ថែមអំពីគណៈកម្មាធិការសម្របសម្រួលបច្ចេកទេស និងអំពីគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារសូមអានមេរៀនទី៧ |

✓ តួនាទីទូទៅរបស់គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស គឺត្រូវផ្ដល់យោបល់ដល់ក្រុមប្រឹក្សាខេត្ត និងគណៈអភិបាលខេត្តអំពី**ការសម្របសម្រួល**ការងាររបស់ក្រុមប្រឹក្សាខេត្តជាមួយការងាររបស់មន្ទីរខ្សែបណ្ដោយ (មាត្រា ២ នៃអនុក្រឹត្យលេខ២១៨)។

✓ ដូច្នេះ ក្រុមប្រឹក្សាខេត្តប្រាស្រ័យទាក់ទងជាមួយមន្ទីរខ្សែបណ្ដោយ តាមរយៈគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសរបស់ក្រុមប្រឹក្សា។

✓ ដូចគ្នានឹងក្រុមប្រឹក្សាថ្មីទាំងអស់ដែរ ក្រុមប្រឹក្សាខេត្ត មាន**គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ**។ តួនាទីរបស់គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ គឺត្រូវធានាឱ្យបានថា ក្រុមប្រឹក្សាលើកកំពស់សមភាពយេនឌ័រ ហើយគិតពិចារណាអំពីតម្រូវការរបស់**ស្ត្រី យុវជន និងកុមារ** នៅពេលរៀបចំគោលនយោបាយ និងសេចក្ដីសម្រេចនៅក្នុងការដាក់ចេញដីកា និងនៅក្នុងសកម្មភាពរបស់ខ្លួន។ គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមាររបស់ក្រុមប្រឹក្សាខេត្តមានសមាសភាពដូចតទៅ៖ សមាជិកក្រុមប្រឹក្សា អភិបាលរង បុគ្គលិកក្រុមប្រឹក្សាក៏ដូចជា**ប្រធាន ឬអនុប្រធានមន្ទីរខ្សែបណ្ដោយ**មួយចំនួន (មាត្រា ១២៨

នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មាត្រា ៧ នៃប្រកាសស្តីពីការបង្កើតគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ)។

- ✓ ដូច្នេះ វិធីមួយទៀតដែលក្រុមប្រឹក្សាខេត្តប្រាស្រ័យទាក់ទងជាមួយមន្ទីរខ្សែបណ្តោយ គឺតាមរយៈគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមាររបស់ក្រុមប្រឹក្សា។

**គណៈកម្មាធិការរបស់ក្រុមប្រឹក្សាខេត្ត**

- ✓ ក្រុមប្រឹក្សាខេត្ត អាចតែងតាំង**តំណាងរបស់ក្រុមប្រឹក្សាផ្សេងទៀត** (ក៏ដូចជាប្រជាពលរដ្ឋ ឬសមាជិកសហគមន៍) ឱ្យធ្វើជាសមាជិកគណៈកម្មាធិការ អនុគណៈកម្មាធិការ ឬក្រុមការងាររបស់ក្រុមប្រឹក្សាខេត្ត (មាត្រា ២០ នៃអនុក្រឹត្យលេខ២១៦)។

- ✓ ដូចបានពិភាក្សាពីខាងលើ ទាំងគណៈកម្មាធិការសម្របសម្រួលបច្ចេកទេស និងគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារមានបញ្ចូលសមាជិកដែលជា**ប្រធាន ឬអនុប្រធានមន្ទីរ ឬការិយាល័យខ្សែបណ្តោយ**។

> ចំពោះព័ត៌មានបន្ថែមអំពីគណៈកម្មាធិការរបស់ក្រុមប្រឹក្សា សូមអានមេរៀនទី ៧។

- ✓ ក្រៅពីនេះ ទាំងគណៈកម្មាធិការសម្របសម្រួលបច្ចេកទេស និងគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារមានតំណាងរបស់**សមាគមក្រុមប្រឹក្សាឃុំ សង្កាត់នៅតាមខេត្ត**ជាសមាជិក (មាត្រា ៣ នៃអនុក្រឹត្យលេខ ២១៨ ប្រការ ៣ នៃប្រកាសលេខ៤២៧៥)។

- ✓ ដូច្នេះ គណៈកម្មាធិការរបស់ក្រុមប្រឹក្សាផ្តល់ឱកាសសម្រាប់ឱ្យក្រុមប្រឹក្សាប្រាស្រ័យទាក់ទងជាមួយប្រជាពលរដ្ឋ ក្រុមប្រឹក្សាផ្សេងទៀត និងមន្ទីរ ឬការិយាល័យខ្សែបណ្តោយ។

## ការកសាងផែនការអភិវឌ្ឍ

> ចំពោះព័ត៌មានបន្ថែមអំពីការកសាងផែនការសូមអានមេរៀនទី ១៤ ។

- ✓ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ចែងថាគ្រប់ក្រុមប្រឹក្សាត្រូវ**ពិគ្រោះយោបល់**ជាមួយក្រុមប្រឹក្សាទាំងអស់ផ្សេងទៀតនៅក្នុងដែនដីរបស់ខ្លួននៅក្នុងការរៀបចំ និងការអនុវត្ត**ផែនការអភិវឌ្ឍ**របស់ខ្លួន។ ដូច្នេះក្រុមប្រឹក្សាខេត្តត្រូវពិគ្រោះយោបល់ជាមួយក្រុមប្រឹក្សាក្រុង ស្រុក និងឃុំ សង្កាត់ទាំងអស់នៅក្នុងខេត្តទាក់ទងនឹងផែនការអភិវឌ្ឍន៍ខេត្ត (មាត្រា ៣៨ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ខណ្ឌ មាត្រា ១៣ នៃអនុក្រឹត្យស្តីពីការកសាងផែនការ) ។

- ✓ ក្រុមប្រឹក្សាខេត្តត្រូវរៀបចំ**កិច្ចប្រជុំពិគ្រោះយោបល់ពិសេស**នៅពេលរៀបចំផែនការអភិវឌ្ឍ និងកម្មវិធីវិនិយោគរបស់ខ្លួន។ កិច្ចប្រជុំពិគ្រោះយោបល់ពិសេសនេះត្រូវចូលរួមដោយប្រធានក្រុមប្រឹក្សាក្រុង និងស្រុក និងប្រធានគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមាររបស់ក្រុង និងស្រុក (មាត្រា ១៤, ១៥ នៃអនុក្រឹត្យស្តីពីការកសាងផែនការ) ។

- ✓ **ក្រុមប្រឹក្សាឃុំ សង្កាត់** មិនចូលរួមនៅក្នុងកិច្ចប្រជុំពិគ្រោះយោបល់ពិសេសឡើយ។ ដូច្នេះ ក្រុមប្រឹក្សាខេត្ត ត្រូវអភិវឌ្ឍយន្តការដើម្បីពិគ្រោះយោបល់ជាមួយក្រុមប្រឹក្សាឃុំ សង្កាត់អំពីការកសាងផែនការអភិវឌ្ឍ។

- ✓ ដូចបានពិភាក្សាខាងលើ ក្រុមប្រឹក្សាខេត្តក៏ត្រូវគាំទ្រក្រុមប្រឹក្សា**ក្រុង ស្រុក និង ឃុំ សង្កាត់** នៅក្នុងការរៀបចំ និងការអនុវត្តផែនការអភិវឌ្ឍ និងថវិការបស់ខ្លួន (មាត្រា ៥៨ នៃ អនុក្រឹត្យលេខ២១៦) ។

> ចំពោះព័ត៌មានបន្ថែមអំពីគណៈកម្មាធិការសម្របសម្រួល បច្ចេកទេស និងការកសាងផែនការ សូមអានមេរៀនទី ១០

- ✓ **គណៈកម្មាធិការសម្របសម្រួលបច្ចេកទេសរបស់ក្រុមប្រឹក្សាខេត្ត** មានការពាក់ព័ន្ធជាខ្លាំងនៅក្នុងដំណើរការកសាងផែនការអភិវឌ្ឍ រួមទាំងសមាជិកដែលជាប្រធានមន្ទីរខ្សែបណ្តោយ (មាត្រា ៧, ៩, ១១ នៃអនុក្រឹត្យស្តីពីការកសាងផែនការ) ។

**ទំនាក់ទំនង**

✓ ក្នុងពេលមិនទាន់មានប្រព័ន្ធទំនាក់ទំនង អភិបាលខេត្តតំណាងឱ្យរាជរដ្ឋាភិបាលក្នុងការផ្សារភ្ជាប់ទំនាក់ទំនងរវាងថ្នាក់ជាតិជាមួយក្រុមប្រឹក្សាក្រុង និងស្រុក ( មាត្រា ១៤ នៃប្រកាស ១២៤៩ ស្តីពីកិច្ចប្រជុំចូលកាន់តំណែង) ។

✓ ក្រសួងអាចទំនាក់ទំនងដោយផ្ទាល់ និងសហប្រតិបត្តិការជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិទៅតាមការចាំបាច់ ។ ទោះជាយ៉ាងណាក៏ដោយ ក្រសួង**ត្រូវផ្តល់ព័ត៌មានជូនរដ្ឋបាលខេត្ត**នៅពេលទំនាក់ទំនងជាមួយក្រុមប្រឹក្សានៅក្នុងខេត្ត ( មាត្រា ១៩៨ នៃអនុក្រឹត្យលេខ២១៦) ។

**គណៈអភិបាល**

✓ គណៈអភិបាលរបស់ក្រុមប្រឹក្សាទាំងអស់ និងមេឃុំ ចៅសង្កាត់ ត្រូវរក្សាទំនាក់ទំនងល្អនៅក្នុងការងារប្រចាំថ្ងៃរបស់ខ្លួន ( មាត្រា ១៨៦ នៃអនុក្រឹត្យលេខ២១៦) ។

## ផ្នែកទី ៤: ទំនាក់ទំនងក្រុមប្រឹក្សាស្រុក

- ✓ មាន**ទំនាក់ទំនងយ៉ាងជិតស្និទ្ធរវាងក្រុមប្រឹក្សាស្រុក និងក្រុមប្រឹក្សាឃុំ សង្កាត់**នៅក្នុងស្រុក។

- ✓ ក្រុមប្រឹក្សាឃុំ សង្កាត់ខ្លះមានទំហំតូចជាខ្លាំង ហើយទំនងជាជួបការលំបាកក្នុងការឆ្លើយតបយ៉ាងមានប្រសិទ្ធិភាពចំពោះតម្រូវការមួយចំនួនរបស់ប្រជាពលរដ្ឋខ្លួន។ ដូច្នេះ ក្រុមប្រឹក្សាស្រុកមានតួនាទី**បំពេញការងារ**ជាមួយក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងការឆ្លើយតបនឹងតម្រូវការទាំងនោះ។ ដូច្នេះ នៅគ្រប់កិច្ចប្រជុំ ក្រុមប្រឹក្សាស្រុកត្រូវធ្វើសេចក្ដីសម្រេចអំពីរបៀប**ពិគ្រោះយោបល់**ជាមួយក្រុមប្រឹក្សាឃុំ សង្កាត់នៅក្នុងស្រុក (មាត្រា ៩៧-១០៤ នៃច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មាត្រា ១៣២, ១៨៤ នៃអនុក្រឹត្យលេខ២១៦)។

- ✓ ទំនាក់ទំនងជាមួយក្រុមប្រឹក្សាស្រុក ត្រូវរៀបចំឡើងដើម្បី**ពង្រឹង និងផ្ដល់អំណាចដល់ក្រុមប្រឹក្សាឃុំ សង្កាត់** និងដើម្បីធានាឱ្យបានថា តម្រូវការនៅមូលដ្ឋានត្រូវបានឆ្លើយតប។ ដូច្នេះ ក្រុមប្រឹក្សាស្រុក និងគណៈអភិបាលស្រុកត្រូវ**គោរពស្វ័យភាពរបស់ក្រុមប្រឹក្សាឃុំ សង្កាត់** (មាត្រា ១៧៤ នៃអនុក្រឹត្យលេខ២១៦)។ និយាយម៉្យាងទៀតថា តួនាទីរបស់ស្រុក គឺត្រូវផ្ដល់**ឱកាសគិតពិចារណា**ជាអតិបរមាដល់ក្រុមប្រឹក្សាឃុំ សង្កាត់ មិនមែនជ្រៀតជ្រែតលើការងាររបស់ឃុំ សង្កាត់ឡើយ។

- ✓ ក្រុមប្រឹក្សាស្រុក ដូចគ្នានឹងក្រុមប្រឹក្សាថ្មីទាំងអស់ដែរមានគណនេយ្យភាពមិនចំពោះតែប្រជាពលរដ្ឋប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងចំពោះសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ដែលបោះឆ្នោតជ្រើសរើសគាត់ផងដែរ។ ដូច្នេះជាការសំខាន់ដែលក្រុមប្រឹក្សាស្រុក យល់ និងឆ្លើយតបចំពោះតម្រូវការ និងអាទិភាពរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ (មាត្រា ៩៨ នៃច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ)។

- ✓ ដោយសារហេតុផលនេះ ក្រុមប្រឹក្សាស្រុកត្រូវបង្កើតយន្តការសម្រាប់ការពិគ្រោះយោបល់ និងការពិភាក្សាជាមួយក្រុមប្រឹក្សាឃុំ សង្កាត់ ដើម្បីធានាឱ្យបានថា សេចក្ដីសម្រេច និងដីការបស់ក្រុមប្រឹក្សាស្រុកមានការឆ្លើយតបទៅនឹងតម្រូវការជាអាទិភាពរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ និងប្រជាពលរដ្ឋនៅក្នុងស្រុក (មាត្រា ១១៦ នៃអនុក្រឹត្យលេខ២១៦)។ បន្ទាប់មក ស្រុកមានការទទួលខុសត្រូវក្នុងការលើកឡើងពីតម្រូវការ និងអាទិភាពរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ជាមួយក្រុមប្រឹក្សាខេត្ត។

## ការគាំទ្រចំពោះក្រុមប្រឹក្សាឃុំ សង្កាត់

✓ ក្រុមប្រឹក្សាស្រុក មានការទទួលខុសត្រូវក្នុងការជួយក្រុមប្រឹក្សាឃុំ សង្កាត់ ដើម្បីបង្កើត ជំរុញ និងធ្វើឱ្យមានចីរភាព**ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ** (មាត្រា ៩៧ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មាត្រា ១១៥ នៃអនុក្រឹត្យលេខ២១៦)។

✓ ក្រុមប្រឹក្សាស្រុក ត្រូវ**អភិវឌ្ឍសមត្ថភាព**របស់ក្រុមប្រឹក្សាឃុំ សង្កាត់ ដើម្បី**ទទួលមុខងារ និងធនធាន** និងអនុវត្តមុខងារ និងប្រើប្រាស់ធនធានទៅតាមរបៀបដែលបង្កើត ជំរុញ និងធ្វើឱ្យមានចីរភាពការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ។ ប្រការនេះ មានន័យថា ក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវមានសមត្ថភាពដើម្បីប្រកាន់យក**ជម្រើសផ្នែកនយោបាយ**ឱ្យបានល្អនៅពេលអនុវត្តមុខងាររបស់ខ្លួន និងប្រើប្រាស់ធនធានរបស់ខ្លួនដើម្បីឱ្យសេចក្តីសម្រេច**ឆ្លើយតប**នឹងតម្រូវការពិតប្រាកដនៅមូលដ្ឋាន ។

- ក្រុមប្រឹក្សាស្រុកត្រូវ**វាយតំលៃ**សមត្ថភាពរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ យ៉ាងតិចម្តងក្នុងមួយឆ្នាំ។
- បន្ទាប់មក ក្រុមប្រឹក្សាស្រុកត្រូវចាត់ចែង**ការបណ្តុះបណ្តាល**កសាងសមត្ថភាពសម្រាប់ក្រុមប្រឹក្សាឃុំ សង្កាត់ និងបុគ្គលិករបស់ឃុំ សង្កាត់ ដោយផ្អែកលើលទ្ធផលនៃការវាយតំលៃ (មាត្រា ៩៩ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មាត្រា ១២២ នៃអនុក្រឹត្យលេខ២១៦)។

> **ឧទាហរណ៍**
>
> ក្រុមប្រឹក្សាឃុំ សង្កាត់ អាចមានមុខងារជួលគ្រូសាលាមត្តេយ្យរបស់រដ្ឋ។ ទោះជាយ៉ាងណាក៏ បុគ្គលិករបស់ក្រុមប្រឹក្សាឃុំ សង្កាត់ មិនមានបទពិសោធន៍នៅក្នុងការសម្ភាសន៍គ្រូបង្រៀន។ ជាលទ្ធផល គ្រូបង្រៀនជាច្រើនដែលបានជួល បំពេញការងារមិនបានល្អ។
>
> ក្រុមប្រឹក្សាស្រុក អាចសម្រេចចាត់ចែងឱ្យបុគ្គលិករបស់ក្រុមប្រឹក្សាឃុំ សង្កាត់ទទួលបានការបណ្តុះបណ្តាលអំពីជំនាញសម្ភាសន៍។

- គ្រប់ក្រុមប្រឹក្សាស្រុកមានការិយាល័យគាំទ្រក្រុមប្រឹក្សាឃុំ សង្កាត់នៅក្នុងស្រុក គឺ**ការិយាល័យផែនការ និងគាំទ្រក្រុមប្រឹក្សាឃុំ សង្កាត់** (មាត្រា ១៨១ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ប្រការ ២៦ នៃប្រកាសលេខ៤២៧៤ )។

✓ ការទទួលខុសត្រូវរបស់ការិយាល័យផែនការ និង គាំទ្រក្រុមប្រឹក្សាឃុំ សង្កាត់ រួមមានៈ

- គាំទ្រក្រុមប្រឹក្សាឃុំ សង្កាត់ក្នុង**ការវិភាគ និងវាយតំលៃការអភិវឌ្ឍ**នៅក្នុងដែនដីរបស់ខ្លួន
- គាំទ្រក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងការរៀបចំ និងអនុវត្ត**ផែនការអភិវឌ្ឍ និងថវិការបស់ខ្លួន**
- ទំនាក់ទំនង និងសហប្រតិបត្តិការជាមួយ**ស្ថាប័ន និងការិយាល័យខ្សែបណ្តោយ**ដែលពាក់ព័ន្ធនឹងតម្រូវការជាអាទិភាពរបស់ឃុំ សង្កាត់
- **កៀរគរធនធាន**សម្រាប់ការអភិវឌ្ឍស្រុក និងឃុំ សង្កាត់
- **ពិនិត្យតាមដាន និងវាយតម្លៃ**ការប្រើប្រាស់មូលនិធិវិនិយោគឃុំ សង្កាត់ ( ប្រការ ២៦ នៃប្រកាសលេខ៤២៧៤ ) ។

> នៅក្នុងការពិនិត្យតាមដាន និងវាយតំលៃការប្រើប្រាស់មូលនិធិវិនិយោគឃុំ សង្កាត់ ក្រុមប្រឹក្សាស្រុក និង គណៈអភិបាលស្រុក ត្រូវ**គោរពស្វ័យភាពរបស់ក្រុមប្រឹក្សាឃុំ សង្កាត់** (មាត្រា ១៧៤ នៃអនុក្រឹត្យស្តីពីតួនាទី-ខេត្ត) ។

✓ ក្រុមប្រឹក្សាស្រុក ក៏ត្រូវកំណត់ និង**ឆ្លើយតបចំពោះសំណើរបស់ក្រុមប្រឹក្សាឃុំ សង្កាត់**នៅក្នុងស្រុកផងដែរ ។ ក្រុមប្រឹក្សាស្រុក និងក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវដាក់បញ្ចូលទៅក្នុងផែនការអភិវឌ្ឍ កម្មវិធីវិនិយោគ និងថវិការបស់ខ្លួននូវយុទ្ធសាស្ត្រ និងសកម្មភាពជាក់លាក់ដែលឆ្លើយតបនឹងតម្រូវការ និងសំណូមពររបស់ក្រុមប្រឹក្សាឃុំ សង្កាត់ (មាត្រា ៩៧, ១០០ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មាត្រា ១១៥ នៃអនុក្រឹត្យលេខ២១៦ ) ។

✓ ក្រុមប្រឹក្សាស្រុក ត្រូវគាំទ្រ សហប្រតិបត្តិការ និងសម្របសម្រួលជាមួយក្រុមប្រឹក្សាឃុំ សង្កាត់នៅក្នុងស្រុកដើម្បី**លើកកម្ពស់គុណភាពនៃការផ្តល់សេវា និងការអភិវឌ្ឍ** ។ ក្រុមប្រឹក្សាស្រុក ក៏ត្រូវលើកកម្ពស់**កិច្ចសហប្រតិបត្តិការអន្តរឃុំផងដែរ** (មាត្រា ១១៧, ១៧៣ នៃអនុក្រឹត្យលេខ២១៦) ។

> គណៈអភិបាលស្រុក ត្រូវធ្វើ**ការសិក្សា**ដើម្បីផ្តល់ព័ត៌មានដល់ក្រុមប្រឹក្សាស្រុកអំពីរបៀបដែលក្រុមប្រឹក្សាអាចសហប្រតិបត្តិការជាមួយ និងគាំទ្រក្រុមប្រឹក្សាឃុំ សង្កាត់ និងអំពីរបៀបក្រុមប្រឹក្សាស្រុកអាចឆ្លើយតបនឹងសំណើ សំណូមពរ និងបញ្ហាប្រឈមរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ( មាត្រា ១៧៤ នៃអនុក្រឹត្យលេខ២១៦) ។

✓ ក្រុមប្រឹក្សាស្រុក ក៏ត្រូវបំពេញការងារជាមួយក្រុមប្រឹក្សាឃុំ សង្កាត់ផងដែរ ដើម្បីជំរុញ**ការចូលរួមចំណែករបស់ប្រជាពលរដ្ឋ** (ការចូលរួមរបស់សាធារណជន) នៅក្នុងស្រុក (មាត្រា ៩៧ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មាត្រា ១១៥, ១២២ នៃអនុក្រឹត្យលេខ២១៦) ។

✓ ប្រសិនបើសមត្ថភាព ឬធនធានផ្នែករដ្ឋបាលរបស់ឃុំ សង្កាត់ មានបរិមាណមិនគ្រប់គ្រាន់ ក្រុមប្រឹក្សាស្រុកអាចសម្របសម្រួលនៅក្នុងចំណោមក្រុមប្រឹក្សាឃុំ សង្កាត់ពីរ ឬច្រើនដើម្បីប្រើប្រាស់រួមគ្នានូវ**បុគ្គលិក ឬទ្រព្យសម្បត្តិ** (មាត្រា ១២៤ នៃអនុក្រឹត្យលេខ២១៦)។

✓ ក្រុមប្រឹក្សាស្រុកក៏អាចឱ្យចាត់ចែងផងដែរឱ្យក្រុមប្រឹក្សាឃុំ សង្កាត់ **ប្រើប្រាស់បុគ្គលិករបស់ស្រុក** ដើម្បីជំរុញសមត្ថភាព ឬធនធានផ្នែករដ្ឋបាលរបស់រដ្ឋបាលឃុំ សង្កាត់នោះ។ ក្នុងករណីនេះ បុគ្គលិកស្រុកដែលមានការពាក់ព័ន្ធត្រូវមានគណនេយ្យភាពចំពោះក្រុមប្រឹក្សាឃុំ សង្កាត់លើសកម្មភាពរបស់ខ្លួន។ បុគ្គលិកស្រុកក៏ត្រូវមានគណនេយ្យភាពផងដែរចំពោះក្រុមប្រឹក្សាស្រុកក្នុងការអនុវត្តទៅតាមច្បាប់ និងលិខិតបទដ្ឋានផ្សេងទៀតដែលស្ថិតនៅជាធរមាន (មាត្រា ១២៤ នៃអនុក្រឹត្យលេខ២១៦)។

✓ នៅក្នុងការផ្តល់ការគាំទ្រ ក្រុមប្រឹក្សាស្រុកត្រូវ**គោរពស្វ័យភាពរបស់ក្រុមប្រឹក្សាឃុំ សង្កាត់**។ ក្រុមប្រឹក្សាស្រុកមិនត្រូវធ្វើការងារជំនួសក្រុមប្រឹក្សាឃុំ សង្កាត់ឡើយ (មាត្រា ១២៥ នៃអនុក្រឹត្យលេខ២១៦)។

✓ ក្នុងករណីដែលក្រុមប្រឹក្សាឃុំ សង្កាត់ ទាមទារការគាំទ្រដើម្បីអនុវត្តភារកិច្ច និងមុខងារសំខាន់របស់ខ្លួនច្រើនជាងការគាំទ្រដែលក្រុមប្រឹក្សាស្រុកអាចផ្តល់ ក្រុមប្រឹក្សាស្រុក និងក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវរាយការណ៍ជាលាយលក្ខអក្សរទៅក្រសួងមហាផ្ទៃ (មាត្រា ១២៦, ១២៧ នៃអនុក្រឹត្យលេខ២១៦)។

## ការពិនិត្យនីត្យានុកូលភាព

✓ ក្រុមប្រឹក្សាខេត្តពិនិត្យនីត្យានុកូលភាពលើ**ដីកា និងសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាស្រុក** (មាត្រា ១៩៦ នៃអនុក្រឹត្យលេខ២១៦ ប្រការ ៤ នៃប្រកាសលេខ៤២៧៤)។

✓ ក្រុមប្រឹក្សាស្រុកធ្វើការពិនិត្យនីត្យានុកូលភាពលើ**ដីកា និងសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់** (មាត្រា ៧៤, ១៩៦ នៃអនុក្រឹត្យលេខ២១៦ ប្រការ ៤ នៃប្រកាសស្តីលេខ៤២៧៤)។

## សិទ្ធិរបស់ក្រុមប្រឹក្សាឃុំ សង្កាត់

- ✓ មេឃុំ ចៅសង្កាត់មាន**សិទ្ធិចូលរួម និងមានមតិនៅក្នុងកិច្ចប្រជុំរបស់ក្រុមប្រឹក្សាស្រុក**។ មេឃុំ ចៅសង្កាត់អាចពិភាក្សា ផ្តល់យោបល់ និងលើកសំណូមពរទាក់ទងនឹងឃុំ សង្កាត់របស់គាត់សម្រាប់ឱ្យក្រុមប្រឹក្សាស្រុកពិចារណា។
    - មេឃុំ ចៅសង្កាត់ដែលចូលរួមនៅក្នុងកិច្ចប្រជុំរបស់ក្រុមប្រឹក្សាស្រុក ត្រូវគោរពបទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សាស្រុក ហើយមេឃុំ ចៅសង្កាត់ មិនមានសិទ្ធិបោះឆ្នោតលើកិច្ចការណាមួយឡើយ។
    - បន្ទាប់ពីកិច្ចប្រជុំ មេឃុំ ចៅសង្កាត់ត្រូវ**រាយការណ៍ត្រឡប់**ទៅក្រុមប្រឹក្សាឃុំ សង្កាត់របស់ខ្លួនវិញ ហើយរាយការណ៍ព័ត៌មានអំពីកិច្ចប្រជុំរបស់ក្រុមប្រឹក្សាស្រុកជូនប្រជាពលរដ្ឋ (មាត្រា ១១៩ នៃអនុក្រឹត្យលេខ ២១៦)។
- ✓ ក្រៅពីនេះ **សមាជិកក្រុមប្រឹក្សាស្រុកម្នាក់ ឬច្រើននាក់** ត្រូវបានចាត់**ឱ្យចូលរួមនៅក្នុងកិច្ចប្រជុំរបស់ក្រុមប្រឹក្សាឃុំ សង្កាត់**។ ក្រុមប្រឹក្សាស្រុកត្រូវ:
    - **រាយការណ៍**ជូនក្រុមប្រឹក្សាឃុំ សង្កាត់អំពីសកម្មភាព និងសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាស្រុក
    - **បំភ្លឺបញ្ហា**ដែលលើកឡើងដោយសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់
    - ប្រមូល**សំណើ** និង**សំណូមពរ**របស់ក្រុមប្រឹក្សាឃុំ សង្កាត់ និង**បញ្ហាប្រឈម**ដែលក្រុមប្រឹក្សាឃុំ សង្កាត់ មិនអាចដោះស្រាយដោយខ្លួនឯង (មាត្រា ១២០ នៃអនុក្រឹត្យលេខ២១៦)។
- ✓ សមាជិកក្រុមប្រឹក្សាស្រុកដែលចូលរួមនៅក្នុងកិច្ចប្រជុំរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវគោរពបទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សាឃុំ សង្កាត់។ សមាជិកក្រុមប្រឹក្សាស្រុក **មិនមានសិទ្ធិបោះឆ្នោតលើ**កិច្ចការណាមួយឡើយ (មាត្រា ១២០ នៃអនុក្រឹត្យលេខ២១៦)។
- ✓ សមាជិកក្រុមប្រឹក្សាស្រុកដែលចូលរួមនៅក្នុងកិច្ចប្រជុំរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវរៀបចំ**របាយការណ៍ជាលាយលក្ខអក្សរ** ហើយដាក់ជូនគណៈអភិបាលស្រុក។ គណៈអភិបាលស្រុកត្រូវ**ដោះស្រាយជាបន្ទាន់**ចំពោះសំណើ សំណូមពរ និងបញ្ហាប្រឈមដែលស្ថិតនៅក្នុងសិទ្ធិអំណាចរបស់គណៈអភិបាល (មាត្រា ១២០ នៃអនុក្រឹត្យលេខ២១៦)

✓ ចំពោះសំណើ សំណូមពរ និងបញ្ហាប្រឈមដែលស្ថិតនៅក្នុងសិទ្ធិអំណាចរបស់ក្រុមប្រឹក្សាស្រុក គណៈអភិបាលស្រុកត្រូវធ្វើការ**សិក្សា** និង**ពិគ្រោះយោបល់**ដើម្បីដាក់អោយជូនក្រុមប្រឹក្សាស្រុកធ្វើការពិចារណា និងធ្វើសេចក្តីសម្រេច ( មាត្រា ១២០ នៃអនុក្រឹត្យលេខ២១៦) ។

**វេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់**

✓ នៅខែមិថុនាជារៀងរាល់ឆ្នាំ ក្រុមប្រឹក្សាស្រុកត្រូវរៀបចំវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់នៅគ្រប់ឃុំ សង្កាត់នៅក្នុងស្រុក ។ វេទិកាទាំងនេះគឺជាយន្តការយ៉ាងសំខាន់សម្រាប់:

- **តម្លាភាព**
- **ការចូលរួមចំណែករបស់ប្រជាពលរដ្ឋ**
  - **ការពិគ្រោះយោបល់**
  - **ការចូលរួម**
  - **សម្លេងរបស់ប្រជាពលរដ្ឋ**
  - **ការពិគ្រោះយោបល់រវាងរដ្ឋបាល និងប្រជាពលរដ្ឋអំពីការអភិវឌ្ឍ ជម្រើស សិទ្ធិ និងសេវា**
- **សាមគ្គីភាពដែលមានការពាក់ព័ន្ធនឹងប្រជាពលរដ្ឋដែលគេមិនរាប់អាន**
- **គណនេយ្យភាពតាមបែបប្រជាធិបតេយ្យ**

( មាត្រា ១២១ នៃអនុក្រឹត្យលេខ២១៦ អ.ន.ក្រ.បក ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក)

✓ វេទិកាត្រូវចូលរួមដោយសមាជិកក្រុមប្រឹក្សាស្រុក និងដោយគណៈអភិបាលស្រុក និង

- **សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់នៅក្នុងស្រុក**
- តំណាងរបស់ប្រជាជននៅក្នុងសហគមន៍
- អ្នកពាក់ព័ន្ធផ្សេងទៀតទៅតាមការសម្រេចរបស់ក្រុមប្រឹក្សាស្រុក ( មាត្រា ១២១ នៃអនុក្រឹត្យលេខ២១៦) ។

✓ គោលបំណងរបស់វេទិកា គឺដើម្បីឱ្យក្រុមប្រឹក្សាស្រុកៈ

- **រាយការណ៍**អំពីសកម្មភាពរបស់ក្រុមប្រឹក្សាស្រុកនៅឆ្នាំកន្លងមក
- **ឆ្លើយតបនឹងសំណូមពរ និងសំណើ**របស់អ្នកចូលរួម ក្រុមប្រឹក្សាឃុំ សង្កាត់ តំណាងរបស់សហគមន៍ប្រជាជន និងអ្នកពាក់ព័ន្ធផ្សេងទៀត
- **ពិភាក្សា និងបំភ្លឺបញ្ហា**ដែលលើកឡើងដោយអ្នកចូលរួម
- **ប្រមូលមតិយោបល់**ពីអ្នកចូលរួម ដើម្បីកែលម្អការងាររបស់ក្រុមប្រឹក្សាស្រុក និងការឆ្លើយតបរបស់ក្រុមប្រឹក្សាចំពោះតម្រូវការនៅមូលដ្ឋាន (មាត្រា ១២១ នៃអនុក្រឹត្យលេខ២១៦ អ.ន.ក្រ.បក ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក)។

✓ គណៈអភិបាលស្រុកក្នុងនាមក្រុមប្រឹក្សាចងក្រង និងវាយតម្លៃលទ្ធផលនៃវេទិកានៅក្នុងរយៈពេល១៥ថ្ងៃ។ **របាយការណ៍**របស់គណៈអភិបាល ត្រូវមានបញ្ចូលរបៀបដែលក្រុមប្រឹក្សាអាចឆ្លើយតបនឹងតម្រូវការដែលបានលើកឡើងនៅក្នុងវេទិកា។ របាយការណ៍មួយច្បាប់ត្រូវផ្តល់ជូនរដ្ឋបាលខេត្តដើម្បីចាត់វិធានការទៅតាមការចាំបាច់ (មាត្រា ១២១ នៃអនុក្រឹត្យលេខ២១៦ អ.ន.ក្រ.បក ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក)។

✓ ប្រសិនបើបញ្ហាដែលបានលើកឡើង**ស្ថិតនៅក្រៅវិសាលភាពនៃភារកិច្ចរបស់ក្រុមប្រឹក្សាស្រុក** រដ្ឋបាលស្រុកត្រូវពិគ្រោះយោបល់ជាមួយក្រុមប្រឹក្សាដែលមានការទទួលខុសត្រូវ ដើម្បីឱ្យក្រុមប្រឹក្សានោះអាចដោះស្រាយបញ្ហា។ ប្រសិនបើបញ្ហាដែលបានលើកឡើងទាក់ទងនឹងការទទួលខុសត្រូវនៅថ្នាក់ជាតិ គណៈអភិបាលខេត្តត្រូវរាយការណ៍ទៅក្រសួងមហាផ្ទៃ។

✓ ដូចគ្នានឹងរបាយការណ៍ផ្សេងទៀតរបស់ក្រុមប្រឹក្សាដែរ របាយការណ៍ស្តីពីវេទិកា **ត្រូវផ្តល់ជូនសាធារណជន** (មាត្រា ៥១ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ)។

## ទំនាក់ទំនងក្រុមប្រឹក្សាស្រុកជាមួយការិយាល័យខ្សែបណ្តោយ

✓ ក្រុមប្រឹក្សាស្រុកនឹងមានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយការិយាល័យខ្សែបណ្តោយនៅក្នុងស្រុក។ ទំនាក់ទំនងយ៉ាងជិតស្និទ្ធនេះ គឺជាចំណុចយ៉ាងសំខាន់នៅក្នុងទស្សនៈនៃ**រដ្ឋបាលឯកភាព**។

✓ ក្រុមប្រឹក្សា និងការិយាល័យខ្សែបណ្ដោយត្រូវ **ទំនាក់ទំនង សហប្រតិបត្តិការ និងសហការគ្នា** ដើម្បីកែលម្អអភិបាលកិច្ច និងកែលម្អសមិទ្ធផលអភិវឌ្ឍនៅក្នុងស្រុក។

| |
|---|
| ចំពោះព័ត៌មានបន្ថែមអំពីរដ្ឋបាលឯកភាព សូមអាន មេរៀនទី ៧។ |

✓ គណៈកម្មាធិការសម្របសម្រួលបច្ចេកទេសរបស់ក្រុមប្រឹក្សាស្រុកមានសមាជិកដូចតទៅ៖ អភិបាល (ប្រធាន) សមាជិកក្រុមប្រឹក្សា បុគ្គលិករបស់ក្រុមប្រឹក្សា ក៏ដូចជាប្រធានការិយាល័យខ្សែបណ្ដោយដែលផ្ដល់សេវានៅក្នុងដែនដីរបស់ក្រុមប្រឹក្សា។ មេឃុំ ចៅសង្កាត់ទាំងអស់នៅក្នុងស្រុក ក៏ជាសមាជិកគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសរបស់ស្រុកដែរ (មាត្រា ២១ នៃអនុក្រឹត្យលេខ២១៨ ស្ដីពីការបង្កើត ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសក្រុមប្រឹក្សាខេត្ត គណៈកម្មាធិការសម្របសម្រួលបច្ចេកទេសក្រុមប្រឹក្សាក្រុង និងគណៈកម្មាធិការសម្របសម្រួលបច្ចេកទេស ក្រុមប្រឹក្សាស្រុក)។

✓ តួនាទីរួមរបស់គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស គឺត្រូវផ្ដល់យោបល់ដល់ក្រុមប្រឹក្សាស្រុក និងគណៈ-អភិបាលស្រុកអំពី**ការសម្របសម្រួល**ការងាររបស់ក្រុមប្រឹក្សាជាមួយការងាររបស់ការិយាល័យខ្សែបណ្ដោយ (មាត្រា ២ នៃអនុក្រឹត្យលេខ២១៨ ស្ដីពីការបង្កើត ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសក្រុមប្រឹក្សាខេត្ត គណៈកម្មាធិការសម្របសម្រួលបច្ចេកទេសក្រុមប្រឹក្សាក្រុង និងគណៈកម្មាធិការសម្របសម្រួលបច្ចេកទេស ក្រុមប្រឹក្សាស្រុក)។

✓ **គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ**មានតួនាទីធានាឱ្យបានថា ក្រុមប្រឹក្សាលើកកម្ពស់សមភាពយេនឌ័រ និងពិចារណាតម្រូវការរបស់**ស្ត្រី យុវជន និងកុមារ**នៅពេលគាត់តែងគោលនយោបាយ និងធ្វើសេចក្ដីសម្រេចនៅពេលដាក់ចេញដីកា និងនៅក្នុងសកម្មភាពរបស់ខ្លួន។ គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមាររបស់ក្រុមប្រឹក្សាស្រុកមានសមាជិកដូចតទៅ៖ សមាជិកក្រុមប្រឹក្សា អភិបាលរង បុគ្គលិករបស់ក្រុមប្រឹក្សា ក៏ដូចជាប្រធាន ឬអនុប្រធានការិយាល័យខ្សែបណ្ដោយ (មាត្រា ១២៨ នៃច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មាត្រា ៣, ៧ នៃប្រកាសស្ដីពីការបង្កើតគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និង កុមារ)។

| |
|---|
| ចំពោះព័ត៌មានបន្ថែមស្ដីពីការបង្កើតគណៈកម្មាធិការសម្របសម្រួលបច្ចេកទេស និងគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និង កុមារ សូមអានមេរៀនទី ៧ |

✓ ដូច្នេះ វិធីដែលក្រុមប្រឹក្សាស្រុកទំនាក់ទំនងជាមួយការិយាល័យខ្សែបណ្ដោយ គឺតាមរយៈគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមាររបស់ក្រុមប្រឹក្សា។

## គណៈកម្មាធិការរបស់ក្រុមប្រឹក្សាស្រុក

- ✓ ក្រុមប្រឹក្សាស្រុក អាចតែងតាំង**តំណាងរបស់ក្រុមប្រឹក្សាឃុំ សង្កាត់**នៅក្នុងគណៈកម្មាធិការ អនុគណៈកម្មាធិការ និងក្រុមការងាររបស់ក្រុមប្រឹក្សាស្រុក (ដែលមានបុគ្គលិករបស់ស្រុក ប្រជាពលរដ្ឋ តំណាងរបស់សហគមន៍ប្រជាជន និងអ្នកពាក់ព័ន្ធផ្សេងទៀតផងដែរ) (មាត្រា ១៣៨ នៃអនុក្រឹត្យលេខ២១៦ អ.ន.ក្រ.បក ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក)។

> ចំពោះព័ត៌មានបន្ថែមស្តីពីការបង្កើតគណៈកម្មាធិការរបស់ក្រុមប្រឹក្សា សូមអានមេរៀនទី ៧

- ✓ ដូចដែលបានពិភាក្សាខាងលើ គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស និងគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមាររបស់ក្រុមប្រឹក្សាស្រុកមាន**ប្រធាន ឬអនុប្រធានការិយាល័យខ្សែបណ្តាញ**ជាសមាជិក។
- ✓ ក្រៅពីនេះ **មេឃុំ ចៅសង្កាត់ទាំងអស់**នៅក្នុងស្រុក គឺជាសមាជិកគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសរបស់ក្រុមប្រឹក្សាស្រុក ។ **ជនបង្គោលទទួលបន្ទុកកិច្ចការស្ត្រី និង កុមារឃុំ សង្កាត់** ជាសមាជិកគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមាររបស់ក្រុមប្រឹក្សាស្រុក។
- ✓ ដូច្នេះ គណៈកម្មាធិការរបស់ក្រុមប្រឹក្សាផ្តល់ឱកាសសម្រាប់ឱ្យក្រុមប្រឹក្សា ធ្វើការប្រាស្រ័យទាក់ទងជាមួយប្រជាពលរដ្ឋ ក្រុមប្រឹក្សាផ្សេងទៀត និងការិយាល័យខ្សែបណ្តាញ។

## ការកសាងផែនការអភិវឌ្ឍ

- ✓ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ចែងថាគ្រប់ក្រុមប្រឹក្សាត្រូវ**ពិគ្រោះយោបល់**ជាមួយក្រុមប្រឹក្សាផ្សេងទៀតទាំងអស់នៅក្នុងដែនដីរបស់ខ្លួនអំពីការរៀបចំ និងការអនុវត្ត**ផែនការអភិវឌ្ឍ**របស់ខ្លួន។ ដូច្នេះ ក្រុមប្រឹក្សាស្រុកត្រូវពិគ្រោះយោបល់ជាមួយក្រុមប្រឹក្សាឃុំ សង្កាត់ទាំងអស់នៅក្នុងស្រុកទាក់ទងនឹងផែនការអភិវឌ្ឍស្រុក (មាត្រា ៣៨ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មាត្រា ១៣ នៃអនុក្រឹត្យស្តីពីការកសាងផែនការ)។

> ចំពោះព័ត៌មានបន្ថែមអំពីការកសាងផែនការ សូមអានមេរៀនទី ១៤។

- ✓ ក្រុមប្រឹក្សាស្រុកត្រូវរៀបចំ**កិច្ចប្រជុំពិគ្រោះយោបល់ពិសេស** នៅពេលរៀបចំផែនការអភិវឌ្ឍ និងកម្មវិធីវិនិយោគរបស់ខ្លួន។ កិច្ចប្រជុំពិគ្រោះយោបល់ពិសេស ត្រូវចូលរួមដោយមេឃុំ ចៅសង្កាត់ និងជនបង្គោលទទួលបន្ទុកកិច្ចការស្ត្រី និងកុមារទាំងអស់នៅក្នុងស្រុក។

- ✓ ក្រុមប្រឹក្សាស្រុកត្រូវពិគ្រោះយោបល់ និងពិភាក្សាជាមួយក្រុមប្រឹក្សាឃុំ សង្កាត់អំពី**យុទ្ធសាស្ត្រ កម្មវិធី និងសកម្មភាព**ដែលត្រូវដាក់បញ្ចូលនៅក្នុងផែនការអភិវឌ្ឍ និងកម្មវិធីវិនិយោគរបស់ស្រុក ដើម្បីឆ្លើយតបទៅនឹងតម្រូវការ និងសំណូមពររបស់ក្រុមប្រឹក្សាស្រុក។ ក្រុមប្រឹក្សាស្រុក និងក្រុមប្រឹក្សាឃុំ សង្កាត់ ក៏ត្រូវពិភាក្សាអំពី**ថវិកា** និងក្របខ័ណ្ឌចំណាយរបស់ស្រុក និងឃុំ សង្កាត់ផងដែរ។
- ✓ **ក្រុមប្រឹក្សាខេត្ត ត្រូវគាំទ្រ**ក្រុមប្រឹក្សាស្រុកនៅក្នុងការរៀបចំ និងអនុវត្តផែនការអភិវឌ្ឍ និងថវិការបស់ស្រុក។
- ✓ ក្រៅពីនេះ ដូចដែលបានពិភាក្សាខាងលើ ក្រុមប្រឹក្សាស្រុកចូលរួមនៅក្នុងដំណើរការកសាងផែនការអភិវឌ្ឍរបស់ក្រុមប្រឹក្សាខេត្ត។

**ការបែងចែកចំណូល**

- ✓ ក្រុមប្រឹក្សាស្រុកត្រូវ**បែងចែកចំណូល**មួយចំនួនជាមួយឃុំ សង្កាត់នៅក្នុងស្រុក។ ក្រុមប្រឹក្សាស្រុកបែងចែកចំណូលដែលខ្លួនទទួលបានពីការចេញអាជ្ញាប័ណ្ណ កំរៃ និងឈ្នួលសេវា និងចំណូលមិនមែនពន្ធ។ ការបែងចែកចំណូលនេះ នឹងត្រូវកំណត់ដោយ*ច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ* (មាត្រា ២៤៨ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ)។

> ចំពោះព័ត៌មានបន្ថែមអំពីការបែងចែកចំណូល និងវិមជ្ឈការសារពើពន្ធ សូមអានមេរៀនទី ១៥។

**ទំនាក់ទំនង**

- ✓ ក្នុងពេលមិនទាន់មានប្រព័ន្ធទំនាក់ទំនង អភិបាលខេត្តតំណាងឱ្យរាជរដ្ឋាភិបាលក្នុង**ការផ្សារភ្ជាប់ទំនាក់ទំនងរវាងថ្នាក់ជាតិ**ជាមួយក្រុមប្រឹក្សាស្រុក (មាត្រា ១៤ នៃប្រកាសលេខ ១២៤៩ ស្តីពីកិច្ចប្រជុំចូលកាន់តំណែង)។

**គណៈអភិបាល**

- ✓ គណៈអភិបាលស្រុក និងមេឃុំ ចៅសង្កាត់ ត្រូវ**រក្សាទំនាក់ទំនងល្អ**ដើម្បីអនុវត្តការងារប្រចាំថ្ងៃរបស់ខ្លួនឱ្យមានប្រសិទ្ធិភាព និងប្រសិទ្ធិផល (មាត្រា ១៨៦ នៃអនុក្រឹត្យលេខ២១៦)។

## ផ្នែកទី ៥: ទំនាក់ទំនងក្រុមប្រឹក្សាក្រុង

✓ ដូចគ្នានឹងឃុំ សង្កាត់ និងស្រុកដែរ ក្រុមប្រឹក្សាក្រុងត្រូវមាន**ទំនាក់ទំនងយ៉ាងជិតស្និទ្ធ**រវាងក្រុមប្រឹក្សាសង្កាត់នៅក្នុងក្រុង។ ទោះបីយ៉ាងណាក៏ដោយ មិនដូចឃុំ សង្កាត់នៅក្នុងស្រុក **ក្រុមប្រឹក្សាសង្កាត់ស្ថិតនៅក្រោមការត្រួតពិនិត្យ និងការគ្រប់គ្រងរបស់ក្រុមប្រឹក្សាក្រុង**។

**ហេតុអ្វីបានជាសង្កាត់នៅក្នុងក្រុង មានលក្ខណៈខុសប្លែកពីគេ?**

**តំបន់ប្រជុំជន** គឺជា**អង្គភាពភូមិសាស្ត្រ សង្គម និងសេដ្ឋកិច្ច**ដែលមានដង់ស៊ីតេប្រជាជនខ្ពស់ និងមានការប្រាស្រ័យទាក់ទង និងការពឹងផ្អែកគ្នាទៅវិញទៅមកក្នុងកំរិតខ្ពស់។ ជាលក្ខណៈសេដ្ឋកិច្ច តំបន់ប្រជុំជនពឹងផ្អែកលើសកម្មភាពដែលមិនមែនជាកសិកម្មដែលអាចរួមមានផលិតកម្ម ឧស្សាហកម្ម និងសេវាកម្ម។ តំបន់ជនបទមានលក្ខណៈខុសពីនេះដោយមានការប្រាស្រ័យទាក់ទងនៅក្នុងសង្គមពាក់ព័ន្ធច្រើនជាមួយនឹងភូមិ ហើយមានសេដ្ឋកិច្ចពឹងផ្អែកច្រើនទៅលើវិស័យកសិកម្ម។

ដោយហេតុថា តំបន់ប្រជុំជនគឺជាអង្គភាពភូមិសាស្ត្រ សង្គម និងសេដ្ឋកិច្ចតែមួយមានតម្រូវការឱ្យមាន**អភិបាលកិច្ច និងការអភិវឌ្ឍទីប្រជុំជនដែលមានលក្ខណៈស៊ីសង្វាក់គ្នា និងមានការឯកភាពគ្នា**។ ដើម្បីធានាឱ្យបានថាមានអភិបាលកិច្ច និងការអភិវឌ្ឍទីប្រជុំជនដែលមានលក្ខណៈស៊ីសង្វាក់គ្នា និងមានការឯកភាពគ្នា ក្រុមប្រឹក្សាសង្កាត់ត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យ និងការគ្រប់គ្រងរបស់ក្រុមប្រឹក្សាក្រុង។

## និដ្ឋភាពទូទៅអំពីទំនាក់ទំនងរវាងក្រុមប្រឹក្សាក្រុង និងក្រុមប្រឹក្សាសង្កាត់

✓ ក្រុមប្រឹក្សាក្រុង មាន**គណនេយ្យភាពតាមបែបប្រជាធិបតេយ្យ**ចំពោះប្រជាពលរដ្ឋ និងមានគណនេយ្យភាពផងដែរចំពោះសមាជិកក្រុមប្រឹក្សាសង្កាត់នៅក្នុងក្រុង។

✓ ទោះបីជាមានការចាត់ចែងផ្ទេគណនេយ្យភាពនេះក្តី សង្កាត់នៅក្នុងក្រុង ស្ថិតនៅក្រោម**ការត្រួតពិនិត្យ និងការគ្រប់គ្រងរបស់ក្រុមប្រឹក្សាក្រុង** (មាត្រា ១១១ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ)។

- ក្រុមប្រឹក្សាសង្កាត់ (ក៏ដូចជា ក្រុមប្រឹក្សាខណ្ឌដែរ) មិនទទួលបានមុខងារផ្ទាល់ពីថ្នាក់ជាតិដូចក្រុមប្រឹក្សាផ្សេងទៀតឡើយ។ ជាជំនួស ក្រុមប្រឹក្សាក្រុង**ធ្វើប្រតិភូកម្មមុខងារ**មួយចំនួនរបស់ខ្លួនដល់ក្រុមប្រឹក្សាសង្កាត់។ ក្រុមប្រឹក្សាក្រុងធ្វើប្រតិភូកម្មមុខងារ ដោយមានគោលបំណងបង្កើត ជំរុញ និងធ្វើឱ្យមានចីរភាពការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅក្នុងដែនដីរបស់ខ្លួន (មាត្រា ១១២ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ)។
- ក្រុមប្រឹក្សាសង្កាត់នៅក្នុងក្រុងមាន**ថវិកា**ដើម្បីអនុវត្តមុខងារ និងភារកិច្ចតាមផ្លូវច្បាប់របស់ខ្លួន។ ថវិការបស់ក្រុមប្រឹក្សាសង្កាត់ត្រូវបានដាក់បញ្ចូលទៅក្នុងថវិការបស់ក្រុមប្រឹក្សាក្រុង មិនដូចក្រុមប្រឹក្សាផ្សេងទៀតដែលមានថវិកាដោយឡែករបស់ខ្លួនផ្ទាល់ (មាត្រា ២២៤ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ)។

✓ អ្វីដែលសំខាន់នោះ នៅក្នុងកិច្ចប្រជុំទាំងអស់របស់ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សា ត្រូវពិចារណាអំពីរបៀប**ពិគ្រោះយោបល់ជាមួយក្រុមប្រឹក្សាសង្កាត់**។

✓ ក៏ជាការសំខាន់ផងដែរ ដែលក្រុមប្រឹក្សាក្រុង**ពិគ្រោះយោបល់ សម្របសម្រួល និងសហប្រតិបត្តិការយ៉ាងជិតស្និទ្ធ**ជាមួយក្រុមប្រឹក្សាសង្កាត់ ដើម្បីកំណត់ និងដោះស្រាយតម្រូវការនៅមូលដ្ឋាន។ រដ្ឋបាលក្រុងមានការិយាល័យដែលមានការទទួលខុសត្រូវចំពោះទំនាក់ទំនងជាមួយក្រុមប្រឹក្សាសង្កាត់ (មាត្រា ៦៤, ១១២, ១៨០ នៃអនុក្រឹត្យលេខ២១៦ អ.ន.ក្រ.បក ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក)។

## ការធ្វើប្រតិភូកម្មមុខងារដល់ក្រុមប្រឹក្សាសង្កាត់

✓ ដូចដែលបានលើកឡើងពីខាងលើ ក្រុមប្រឹក្សាសង្កាត់មិនទទួលបានមុខងារផ្ទាល់ពីថ្នាក់ជាតិ ដូចក្រុមប្រឹក្សាផ្សេងទៀតឡើយ។ ជាជំនួស ក្រុមប្រឹក្សាក្រុង **ធ្វើប្រតិភូកម្មមុខងារ** មួយចំនួនរបស់ខ្លួនដល់ក្រុមប្រឹក្សាសង្កាត់។ (មាត្រា ១១២ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ)។

✓ **តាមរយៈការពិគ្រោះយោបល់ជាមួយក្រុមប្រឹក្សាសង្កាត់** នៅក្នុងក្រុង ក្រុមប្រឹក្សាក្រុង សម្រេចលើមុខងារដែលត្រូវធ្វើប្រតិភូកម្មដល់ក្រុមប្រឹក្សាសង្កាត់។ ការពិគ្រោះយោបល់រួមមាន ការពិភាក្សាអំពីក្រុមប្រឹក្សាណា ដែលអាចអនុវត្តមុខងារយ៉ាងសមស្រប និងយ៉ាងមានប្រសិទ្ធិភាព មុខងារណាដែលគួររក្សាទុកដោយក្រុមប្រឹក្សាក្រុង និងមុខងារណាដែលគួរធ្វើប្រតិភូកម្មដល់ក្រុមប្រឹក្សាសង្កាត់ (មាត្រា ១៨១ នៃអនុក្រឹត្យលេខ ២១៦)។

**ក្របខ័ណ្ឌយុទ្ធសាស្ត្រស្តីពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ–គោលការណ៍សាប់ស៊ីឌីយ៉ារីធី**

ក្របខ័ណ្ឌយុទ្ធសាស្រ្តស្តីពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការរបស់រាជរដ្ឋាភិបាល អនុម័តគោលការណ៍សាប់ស៊ីឌីយ៉ារីធី (ទំព័រ ១២) ដូចគ្នានឹងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិដែរ (ទំព័រ ៣៧)។ ជាលក្ខណៈអន្តរជាតិ គោលការណ៍សាប់ស៊ីឌីយ៉ារីធី គឺថា:

- **មុខងារមួយ គួរផ្ទេរទៅឱ្យថ្នាក់ទាបបំផុត** (ក្រុមប្រឹក្សាដែលស្ថិតនៅកៀកនឹងប្រជាជន) **ដែលអាចអនុវត្តមុខងារនោះយ៉ាងមានប្រសិទ្ធិភាព និងប្រសិទ្ធិផល**

ដូច្នេះ គេអាចរំពឹងថា នៅប៉ុន្មានឆ្នាំខាងមុខនេះ មុខងារសំខាន់ៗមួយចំនួន នឹងត្រូវផ្ទេរឱ្យក្រុមប្រឹក្សានៅថ្នាក់ក្រោមជាតិ។

ចំពោះព័ត៌មានបន្ថែមអំពីការផ្ទេរមុខងារ សូមអានមេរៀនទី ១៣។

## ការគាំទ្រដល់ក្រុមប្រឹក្សាសង្កាត់

✓ ក្រុមប្រឹក្សាក្រុង ត្រូវផ្តល់ការគាំទ្រអភិវឌ្ឍសមត្ថភាពរបស់ក្រុមប្រឹក្សាសង្កាត់យ៉ាងសកម្មដើម្បីឱ្យក្រុមប្រឹក្សាសង្កាត់មាន**សមត្ថភាពទទួលមុខងារដែលបានធ្វើប្រតិភូកម្មថ្មី**ពីក្រុមប្រឹក្សាក្រុង (មាត្រា ១៨០ នៃអនុក្រឹត្យលេខ ២១៦)។

✓ ក្រៅពីនេះ ក្រុមប្រឹក្សាក្រុងត្រូវ**ផ្តល់ធនធាន** (ហិរញ្ញវត្ថុ និងបុគ្គលិក) និងការអភិវឌ្ឍសមត្ថភាពចាំបាច់សម្រាប់ឱ្យក្រុមប្រឹក្សាសង្កាត់ និងបុគ្គលិករបស់សង្កាត់អនុវត្តមុខងារដែលបានធ្វើប្រតិភូកម្មយ៉ាងមានប្រសិទ្ធិភាព និងអនុលោមទៅតាមរដ្ឋធម្មនុញ្ញ ច្បាប់ លិខិតបទដ្ឋាន និងគោលនយោបាយជាតិ (មាត្រា ១៨២, ១៨៣ នៃអនុក្រឹត្យលេខ២១៦)។

**ឧទាហរណ៍**

ក្រុមប្រឹក្សាក្រុង បានទទួលការផ្ទេរមុខងារឱ្យគ្រប់គ្រងសំរាមនៅក្នុងក្រុង។ ក្រុមប្រឹក្សាក្រុងអាចធ្វើប្រតិភូកម្មដល់សង្កាត់នៅក្នុងក្រុងនូវមុខងារដើម្បី:

- ពិនិត្យតាមដានគុណភាពនៃការប្រមូលសំរាមនៅតាមផ្ទះនៅក្នុងសង្កាត់
- ដាក់ធុងសំរាមនៅតាមទីសាធារណៈនៅក្នុងសង្កាត់ និងចាត់ចែងយកសំរាមដែលមាននៅក្នុងធុងចេញ
- ផ្តល់អនុសាសន៍អំពីទីកន្លែងដែលត្រូវដាក់ធុងសំរាមធំនៅក្នុងសង្កាត់សម្រាប់ប្រើប្រាស់

នៅពេលក្រុមប្រឹក្សាក្រុង ធ្វើប្រតិភូកម្មដល់ក្រុមប្រឹក្សាសង្កាត់ ក្រុមប្រឹក្សាក្រុងក៏ត្រូវផ្ទេរហិរញ្ញវត្ថុ និងបុគ្គលិកចាំបាច់ក៏ដូចជាការអភិវឌ្ឍសមត្ថភាពចាំបាច់ដល់សង្កាត់ដើម្បីអនុវត្តមុខងារ។

ឧទាហរណ៍ ដើម្បីដាក់ធុងសំរាមទទេនៅតាមទីសាធារណៈ ក្រុមប្រឹក្សាសង្កាត់នឹងត្រូវការធនធានហិរញ្ញវត្ថុដើម្បីជួលបុគ្គលិកឱ្យអនុវត្តមុខងារ ឬទាក់ទងជាមួយផ្នែកឯកជនដើម្បីអនុវត្តមុខងារ។

ដើម្បីមានលទ្ធភាពផ្តល់អនុសាសន៍អំពីទីតាំងដាក់ធុងសំរាមធំ សង្កាត់អាចត្រូវការការបណ្តុះបណ្តាលដើម្បីដឹងអំពីលក្ខណៈវិនិច្ឆ័យផ្នែកបច្ចេកទេសដែលសង្កាត់អាចប្រើប្រាស់នៅពេលអភិវឌ្ឍន៍អនុសាសន៍របស់ខ្លួន។

✓ គ្រប់ក្រុមប្រឹក្សាក្រុង មានការិយាល័យគាំទ្រក្រុមប្រឹក្សាសង្កាត់នៅក្នុងក្រុង គឺ**ការិយាល័យផែនការ និងគាំទ្រក្រុមប្រឹក្សាសង្កាត់**។

✓ ការទទួលខុសត្រូវរបស់ការិយាល័យផែនការ និងគាំទ្រក្រុមប្រឹក្សាសង្កាត់រួមមាន:

- សម្របសម្រួលការអភិវឌ្ឍ**កិច្ចសហប្រតិបត្តិការ និងការផ្តល់សេវានៅក្នុងចំណោមសង្កាត់**
- វាយតម្លៃ និងផ្តល់មតិយោបល់អំពី**តម្រូវការសមត្ថភាព**របស់សមាជិកក្រុមប្រឹក្សាសង្កាត់
- ឆ្លើយតបទៅនឹង**សំណើ សំណូមពរ និងបញ្ហាប្រឈម**របស់ក្រុមប្រឹក្សាសង្កាត់
- គាំទ្រក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងការរៀបចំ និង

គណៈអភិបាលក្រុង ត្រូវធ្វើ**ការសិក្សា** ដើម្បីផ្តល់ព័ត៌មានដល់ក្រុមប្រឹក្សាក្រុងអំពី:

- របៀបដោះស្រាយសំណូមពរ និង បញ្ហាប្រឈមរបស់សង្កាត់
- របៀបគាំទ្រក្រុមប្រឹក្សាសង្កាត់
- ការធ្វើប្រតិភូកម្មមុខងារដល់ក្រុមប្រឹក្សាសង្កាត់

អនុវត្តផែនការអភិវឌ្ឍ និងថវិការបស់ខ្លួន

- ទំនាក់ទំនង និងសហប្រតិបត្តិការជាមួយ**ស្ថាប័ន និងការិយាល័យខ្សែបណ្តោយ**ដែលពាក់ព័ន្ធ នឹងតម្រូវការជាអាទិភាពរបស់សង្កាត់
- **កៀរគរធនធាន**សម្រាប់ការអភិវឌ្ឍស្រុក និង ឃុំ សង្កាត់
- ពិនិត្យមើលល័ក្ខខ័ណ្ឌសម្រាប់សង្កាត់ក្នុងការទទួល**ធនធាន និងមុខងារ**
- ពិនិត្យតាមដាន និងវាយតម្លៃការប្រើប្រាស់**មូលនិធិវិនិយោគ**របស់សង្កាត់

✓ ក្រុមប្រឹក្សាក្រុងក៏ត្រូវរៀបចំការពិគ្រោះយោបល់ជាមួយក្រុមប្រឹក្សាសង្កាត់ដើម្បី**សម្របសម្រួលកិច្ចសហប្រតិបត្តិការនៅក្នុងចំណោមក្រុមប្រឹក្សាសង្កាត់**ក្នុងការឆ្លើយតបនឹងតម្រូវការនៅមូលដ្ឋាន

## ការពិនិត្យនីត្យានុកូលភាព

✓ ក្រុមប្រឹក្សាក្រុងមានការទទួលខុសត្រូវចំពោះការពិនិត្យនីត្យានុកូលភាពលើ**ដីកា និងសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសង្កាត់**ក្នុងការអនុវត្តទៅតាមរដ្ឋធម្មនុញ្ញ ច្បាប់ និង លិខិតបទដ្ឋានជាធរមាន ។ គណៈអភិបាលក្រុងបំពេញភារកិច្ចនេះក្នុងនាមក្រុមប្រឹក្សា ។

✓ ក្នុងករណីដែលក្រុមប្រឹក្សាសង្កាត់ មិនអនុវត្តតាម ឬធ្វើសកម្មភាពហួសពីវិសាលភាពនៃសិទ្ធិអំណាចដែលបានធ្វើប្រតិភូកម្មឱ្យក្រុមប្រឹក្សាសង្កាត់ដោយក្រុមប្រឹក្សាក្រុង គណៈអភិបាលក្រុងនឹងណែនាំក្រុមប្រឹក្សាសង្កាត់ជាលាយលក្ខអក្សរ ដើម្បីកែតម្រូវការងារនេះ។ ប្រសិនបើក្រុមប្រឹក្សាសង្កាត់ មិនកែតម្រូវការងារនេះនៅក្នុងរយៈពេល ១៥ថ្ងៃ ក្រុមប្រឹក្សាក្រុងត្រូវ**រាយការណ៍ការងារនេះទៅក្រុមប្រឹក្សាខេត្ត** ។

✓ ក្រុមប្រឹក្សាខេត្ត ធ្វើការពិនិត្យនីត្យានុកូលភាពលើ**ដីកា និងសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាក្រុង** ។

✓ **ក្រុមប្រឹក្សាខេត្ត**ក៏គាំទ្រក្រុមប្រឹក្សាក្រុងផងដែរក្នុងការពិនិត្យនីត្យានុកូលភាពលើដីកា និងសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសង្កាត់ ។

## សិទ្ធិ និងភារកិច្ចរបស់ក្រុមប្រឹក្សាសង្កាត់

> **តើយន្តការអ្វីដែលលោក អ្នកគិតថា នឹងមានប្រសិទ្ធិភាពដើម្បីធានាឱ្យបានថាក្រុមប្រឹក្សាសង្កាត់មានឱកាសប្រកបដោយអត្ថន័យក្នុងការផ្តល់យោបល់ និង ពិគ្រោះយោបល់ជាមួយក្រុមប្រឹក្សាក្រុង និង ធានាថា ក្រុមប្រឹក្សាក្រុង មានគណនេយ្យភាព?**

✓ ក្រុមប្រឹក្សាសង្កាត់ មានការទទួលខុសត្រូវចំពោះ

- ការផ្តល់យោបល់ និងការពិគ្រោះយោបល់ជាមួយក្រុមប្រឹក្សាក្រុងដើម្បីធានាថា ក្រុមប្រឹក្សាក្រុងមាន **គណនេយ្យភាព និងមានការឆ្លើយតបចំពោះតម្រូវការពិតប្រាកដ**របស់ប្រជាជននៅមូលដ្ឋាន និងក្រុមប្រឹក្សាសង្កាត់
- ការផ្តល់អនុសាសន៍ដល់ក្រុមប្រឹក្សាក្រុងអំពី**តម្រូវការនៅមូលដ្ឋាន** ដែលក្រុមប្រឹក្សាសង្កាត់**មិនអាចដោះស្រាយដោយខ្លួនឯង**
- ការអនុវត្តមុខងារដែលក្រុមប្រឹក្សាក្រុងបានធ្វើប្រតិភូកម្មដល់ក្រុមប្រឹក្សាសង្កាត់ ។

✓ នៅក្នុងវិសាលភាពនៃសិទ្ធិអំណាចរបស់ខ្លួន ក្រុមប្រឹក្សាសង្កាត់មានអំណាចធ្វើសេចក្តីសម្រេចរបស់ខ្លួនផ្ទាល់ ។

✓ មិនមានបទបញ្ញត្តិដែលផ្តល់សិទ្ធិឱ្យចៅសង្កាត់**ចូលរួមនៅក្នុងកិច្ចប្រជុំរបស់ក្រុមប្រឹក្សាក្រុង**ឡើយ (សូមចាំថា មេឃុំ ចៅសង្កាត់នៅក្នុងស្រុកពិតជាមានសិទ្ធិចូលរួមនៅក្នុងកិច្ចប្រជុំរបស់ក្រុមប្រឹក្សាស្រុក) ។ ទោះជាយ៉ាងណាក៏ដោយ កិច្ចប្រជុំរបស់ក្រុមប្រឹក្សាក្រុងត្រូវធ្វើឡើងជាសាធារណៈ ដូច្នេះ សមាជិកក្រុមប្រឹក្សាសង្កាត់គួរមានសិទ្ធិចូលរួម ។

## វេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់

✓ នៅខែ មិថុនាជារៀងរាល់ឆ្នាំ ក្រុមប្រឹក្សាក្រុងត្រូវរៀបចំវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់នៅគ្រប់សង្កាត់នៅក្នុងក្រុង ។ វេទិកាទាំងនេះ គឺជាយន្តការយ៉ាងសំខាន់សម្រាប់:

- **តម្លាភាព**
- **ការចូលរួមចំណែករបស់ប្រជាពលរដ្ឋ**
    - **ការពិគ្រោះយោបល់**
    - **ការចូលរួម**

- **សម្លេងរបស់ប្រជាពលរដ្ឋ**
- **ការពិគ្រោះយោបល់រវាងរដ្ឋបាល និងប្រជាពលរដ្ឋអំពីការអភិវឌ្ឍ ជម្រើស សិទ្ធិ និងសេវា**

- **សាមគ្គីភាព ដែលមានការពាក់ព័ន្ធនឹងប្រជាពលរដ្ឋដែលគេមិនរាប់អាន**
- **គណនេយ្យភាពតាមបែបប្រជាធិបតេយ្យ**

✓ វេទិកា ត្រូវចូលរួមដោយសមាជិកក្រុមប្រឹក្សាក្រុង គណៈអភិបាលក្រុង សមាជិកក្រុមប្រឹក្សាសង្កាត់នៅក្នុងក្រុង ក៏ដូចជាតំណាងរបស់ប្រជាជននៅក្នុងសហគមន៍ និងអ្នកពាក់ព័ន្ធផ្សេងទៀត។

✓ គោលបំណងរបស់វេទិកា គឺដើម្បីឱ្យក្រុមប្រឹក្សាក្រុងៈ

- **ផ្តល់ព័ត៌មាន**អំពីសកម្មភាពរបស់ក្រុមប្រឹក្សាក្រុង បន្ទាប់ពីវេទិកាកន្លងមក
- **ឆ្លើយតបនឹងសំណូមពរ**របស់អ្នកចូលរួមគឺ ក្រុមប្រឹក្សាសង្កាត់ តំណាងរបស់សហគមន៍ប្រជាជន និងអ្នកពាក់ព័ន្ធផ្សេងទៀត
- **ពិភាក្សា និងបំភ្លឺបញ្ហា**ដែលលើកឡើងដោយអ្នកចូលរួម
- **ប្រមូលមតិយោបល់**ពីអ្នកចូលរួមដើម្បីកែលម្អការងាររបស់ក្រុមប្រឹក្សាក្រុង និងការឆ្លើយតបរបស់ក្រុមប្រឹក្សាចំពោះតម្រូវការនៅមូលដ្ឋាន។

✓ គណៈអភិបាលក្រុង ក្នុងនាមក្រុមប្រឹក្សា ចងក្រង និងវាយតម្លៃលទ្ធផលនៃវេទិកានៅក្នុងរយៈពេល ១៥ ថ្ងៃ។ **របាយការណ៍**របស់គណៈអភិបាលត្រូវមានបញ្ចូលរបៀបដែលក្រុមប្រឹក្សា អាចឆ្លើយតបនឹងតម្រូវការដែលបានលើកឡើងនៅក្នុងវេទិកា ។

✓ ប្រសិនបើបញ្ហាដែលបានលើកឡើង **ស្ថិតនៅក្រៅវិសាលភាពនៃភារកិច្ចរបស់ក្រុមប្រឹក្សាក្រុង** រដ្ឋបាលក្រុងត្រូវពិគ្រោះយោបល់ជាមួយក្រុមប្រឹក្សាដែលមានការទទួលខុសត្រូវ ដើម្បីឱ្យក្រុមប្រឹក្សានោះអាចដោះស្រាយបញ្ហា។ ប្រសិនបើបញ្ហាដែលបានលើកឡើងទាក់ទងនឹងការទទួលខុសត្រូវនៅថ្នាក់ជាតិ គណៈអភិបាលខេត្ត ត្រូវរាយការណ៍ទៅក្រសួងមហាផ្ទៃ។

✓ ដូចគ្នានឹងរបាយការណ៍ផ្សេងទៀតរបស់ក្រុមប្រឹក្សាដែរ របាយការណ៍ស្តីពីវេទិកា **ត្រូវផ្តល់ជូនសាធារណជន** (មាត្រា ៥១ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ) ។

**ទំនាក់ទំនងក្រុមប្រឹក្សាក្រុងជាមួយការិយាល័យខ្សែបណ្ដោយ** –

✓ ក្រុមប្រឹក្សាក្រុង នឹងមានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយការិយាល័យខ្សែបណ្ដោយនៅក្នុងក្រុង។ ទំនាក់ទំនងយ៉ាងជិតស្និទ្ធនេះ គឺជាចំណុចយ៉ាងសំខាន់នៅក្នុងទស្សនៈនៃ**រដ្ឋបាលឯកភាព**។

✓ ក្រុមប្រឹក្សាក្រុង និងការិយាល័យខ្សែបណ្ដោយ មិនអាចបំពេញការងារដោយឯកកោពីគ្នាបានឡើយ។ ក្រុមប្រឹក្សា និងការិយាល័យខ្សែបណ្ដោយត្រូវ**ទំនាក់ទំនង សហប្រតិបត្តិការ និងសហការគ្នា** ដើម្បីកែលម្អអភិបាលកិច្ច និងកែលម្អសមិទ្ធផលអភិវឌ្ឍន៍នៅក្នុងក្រុង។

> ចំពោះព័ត៌មានបន្ថែមអំពីរដ្ឋបាលឯកភាព សូមអានមេរៀនទី ៤។

✓ **គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស**របស់ក្រុមប្រឹក្សាក្រុង មានសមាជិកដូចតទៅៈ អភិបាល (ប្រធាន) សមាជិកក្រុមប្រឹក្សា បុគ្គលិករបស់ក្រុមប្រឹក្សា ក៏ដូចជាប្រធានការិយាល័យខ្សែបណ្ដោយដែលផ្ដល់សេវានៅក្នុងដែនដីរបស់ក្រុមប្រឹក្សា។ ចៅសង្កាត់ទាំងអស់នៅក្នុងក្រុង ក៏ជាសមាជិកគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសរបស់ក្រុងផងដែរ។

✓ តួនាទីរួមរបស់គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស គឺត្រូវផ្ដល់យោបល់ដល់ក្រុមប្រឹក្សាក្រុង និងគណៈអភិបាលក្រុងអំពី**ការសម្របសម្រួល**ការងាររបស់ក្រុមប្រឹក្សាជាមួយការងាររបស់ការិយាល័យខ្សែបណ្ដោយ។

✓ **គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ** របស់ក្រុមប្រឹក្សាក្រុងមានតួនាទីធានាឱ្យបានថា ក្រុមប្រឹក្សាលើកកំពស់សមភាពយេនឌ័រ និងពិចារណាតម្រូវការរបស់**ស្ត្រី យុវជន និងកុមារ**នៅពេលតាក់តែងគោលនយោបាយ និងធ្វើសេចក្ដីសម្រេចនៅពេលដាក់ចេញដីកា និងនៅក្នុងសកម្មភាពរបស់ខ្លួន។ គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមាររបស់ក្រុមប្រឹក្សាក្រុងមានសមាជិកដូចតទៅៈ សមាជិកក្រុមប្រឹក្សា អភិបាលរង បុគ្គលិករបស់ក្រុមប្រឹក្សាក៏ដូចជាប្រធាន ឬអនុប្រធានការិយាល័យខ្សែបណ្ដោយ (មាត្រា ១២៨ នៃច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ប្រការ ៣, ៧ នៃប្រកាស លេខ៤២៧៥)។

> ចំពោះព័ត៌មានបន្ថែមស្ដីពីការបង្កើតគណៈកម្មាធិការសម្របសម្រួលបច្ចេកទេស និង គណៈកម្មា-ធិការពិគ្រោះយោបល់កិច្ចការស្ត្រី និង កុមារ សូមអានមេរៀនទី ៧

✓ ដូច្នេះ វិធីមួយទៀតដែលក្រុមប្រឹក្សាក្រុង ទំនាក់ទំនងជាមួយការិយាល័យខ្សែបណ្ដោយ គឺតាមរយៈគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមាររបស់ក្រុមប្រឹក្សា។

## គណៈកម្មាធិការរបស់ក្រុមប្រឹក្សាក្រុង

- ✓ ក្រុមប្រឹក្សាស្រុក អាចតែងតាំង**តំណាងរបស់ក្រុមប្រឹក្សាសង្កាត់**នៅក្នុងគណៈកម្មាធិការ អនុគណៈកម្មាធិការ ឬក្រុមការងាររបស់ក្រុមប្រឹក្សាក្រុង។

> ចំពោះព័ត៌មានបន្ថែមស្តីពីការបង្កើតគណៈកម្មាធិការរបស់ក្រុមប្រឹក្សា សូមអានមេរៀនទី ៧

- ✓ ដូចដែលបានពិភាក្សាខាងលើ គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស និងគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមាររបស់ក្រុមប្រឹក្សាស្រុកមាន **ប្រធាន ឬអនុប្រធានការិយាល័យខ្មែរបណ្តាយ** ជាសមាជិក។
- ✓ ក្រៅពីនេះ **ចៅសង្កាត់ទាំងអស់**នៅក្នុងក្រុង គឺជាសមាជិកគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសរបស់ក្រុមប្រឹក្សាស្រុក។ **ជនបង្គោលទទួលបន្ទុកកិច្ចការស្ត្រី និងកុមារសង្កាត់**ជាសមាជិកគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមាររបស់ក្រុមប្រឹក្សាក្រុង។
- ✓ ដូច្នេះ គណៈកម្មាធិការរបស់ក្រុមប្រឹក្សាផ្តល់ឱកាសសម្រាប់ឱ្យក្រុមប្រឹក្សាធ្វើការប្រាស្រ័យទាក់ទងជាមួយប្រជាពលរដ្ឋ ក្រុមប្រឹក្សាផ្សេងទៀត និងការិយាល័យខ្មែរបណ្តាយ។

## ការកសាងផែនការអភិវឌ្ឍន៍

- ✓ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ចែងថា គ្រប់ក្រុមប្រឹក្សាត្រូវ**ពិគ្រោះយោបល់**ជាមួយក្រុមប្រឹក្សាផ្សេងទៀតទាំងអស់នៅក្នុងដែនដីរបស់ខ្លួនអំពីការរៀបចំ និងការអនុវត្ត**ផែនការអភិវឌ្ឍន៍**របស់ខ្លួន។ ដូច្នេះ ក្រុមប្រឹក្សាក្រុងត្រូវពិគ្រោះយោបល់ជាមួយក្រុមប្រឹក្សាឃុំ សង្កាត់ទាំងអស់នៅក្នុងក្រុងទាក់ទងនឹងផែនការអភិវឌ្ឍន៍ក្រុង (មាត្រា ៣៨ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

> ចំពោះព័ត៌មានបន្ថែមអំពីការកសាងផែនការ សូមអានមេរៀនទី ១៤ ។

- ✓ ក្រុមប្រឹក្សាក្រុងត្រូវរៀបចំ**កិច្ចប្រជុំពិគ្រោះយោបល់ពិសេស** នៅពេលរៀបចំផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគរបស់ខ្លួន។ កិច្ចប្រជុំពិគ្រោះយោបល់ពិសេសត្រូវចូលរួមដោយចៅសង្កាត់ និងជនបង្គោលទទួលបន្ទុកកិច្ចការស្ត្រី និងកុមារទាំងអស់នៅក្នុងក្រុង។
- ✓ **ក្រុមប្រឹក្សាខេត្តត្រូវគាំទ្រ**ក្រុមប្រឹក្សាក្រុងនៅក្នុងការរៀបចំ និងអនុវត្តផែនការអភិវឌ្ឍន៍ និងថវិការបស់ខ្លួន។

✓ ក្រៅពីនេះ ដូចដែលបានពិភាក្សាខាងលើ ក្រុមប្រឹក្សាស្រុកចូលរួមនៅក្នុង**ដំណើការកសាងផែនការអភិវឌ្ឍន៍របស់ក្រុមប្រឹក្សាខេត្ត**។

**ទំនាក់ទំនង**

✓ ក្នុងពេលមិនទាន់មានប្រព័ន្ធទំនាក់ទំនង អភិបាលខេត្ត តំណាងឱ្យរាជរដ្ឋាភិបាលក្នុង**ការផ្សារភ្ជាប់ទំនាក់ទំនងរវាងថ្នាក់ជាតិ**ជាមួយក្រុមប្រឹក្សាស្រុក ( ប្រការ ១៤ នៃប្រកាស ១២៤៩ ស្តីពីកិច្ចប្រជុំចូលកាន់តំណែង) ។

**គណៈអភិបាលក្រុង**

✓ គណៈអភិបាលក្រុង និងចៅសង្កាត់ត្រូវ**រក្សាទំនាក់ទំនងល្អ**ដើម្បីអនុវត្តការងារប្រចាំថ្ងៃរបស់ខ្លួនឱ្យមានប្រសិទ្ធិភាព និងប្រសិទ្ធិផល ។

| |
|---|
| ចំពោះព័ត៌មានបន្ថែមអំពីគណៈអភិបាល សូមអានមេរៀនទី ៦។ |

## ការរៀបចំរដ្ឋបាលដែនដីក្រោមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ






**បញ្ហាដែលត្រូវដោះស្រាយ**

ទោះបីជាមានច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ និងលិខិតបទដ្ឋានស្តីពីទំនាក់ទំនងអន្តររដ្ឋបាលក្តី ក៏នៅមានបញ្ហា ដែលត្រូវដោះស្រាយនៅក្នុងលិខិតបទដ្ឋាននៅពេលខាងមុខ ឬតាមរយៈការអនុវត្តជាក់ស្តែង។ បញ្ហាទាំងនោះរួមមាន:

- តើទំនាក់ទំនងទីប្រជុំជន ជនបទ ត្រូវបង្កើតឡើងយ៉ាងដូចម្តេចរវាងក្រុមប្រឹក្សាស្រុក និងក្រុមប្រឹក្សាក្រុងនៅក្នុងខេត្ត?
- នៅក្នុងការអនុវត្ត តើក្រុមប្រឹក្សាសង្កាត់ អាចមានគណនេយ្យភាពតាមបែបប្រជាធិបតេយ្យយ៉ាងដូចម្តេចចំពោះប្រជាពលរដ្ឋរបស់ខ្លួននៅពេលដែលក្រុមប្រឹក្សានេះ ស្ថិតនៅក្រោមការត្រួតពិនិត្យ និងការគ្រប់គ្រងរបស់ក្រុមប្រឹក្សារាជធានី ឬក្រុមប្រឹក្សាក្រុង?
- តើស្រុក នឹងសម្របសម្រួល និងសហប្រតិបត្តិការយ៉ាងដូចម្តេចជាមួយស្រុកនៅជិតខាង (ការសម្របសម្រួលតាមខ្សែទទឹង) ឧទាហរណ៍ សម្រាប់សេវា ឬសកម្មភាពដែលគ្របដណ្តប់ច្រើនជាងមួយស្រុក (ដូចជានៅជុំវិញទន្លេបាសាក់)? តើខេត្ត នឹងសម្របសម្រួល និងសហប្រតិបត្តិការយ៉ាងដូចម្តេចជាមួយខេត្តនៅជិតខាង?
- តើផែនការអភិវឌ្ឍ នឹងត្រូវធ្វើឱ្យមានសុខដុមនីយកម្មយ៉ាងដូចម្តេចនៅក្នុងចំណោមខេត្ត ក្រុង ស្រុក ឃុំ សង្កាត់?
- តើនឹងទៅជាយ៉ាងណាប្រសិនបើក្រុមប្រឹក្សាស្រុក មិនឯកភាពជាមួយសកម្មភាពនៅក្នុងផែនការអភិវឌ្ឍខេត្ត និងសកម្មភាពដែលមានផលប៉ះពាល់ដោយផ្ទាល់មកលើស្រុក? តើនឹងទៅជាយ៉ាងណា ប្រសិនបើក្រុមប្រឹក្សាឃុំ សង្កាត់ មិនឯកភាពជាមួយផែនការអភិវឌ្ឍរបស់ក្រុមប្រឹក្សាមួយទៀត?
- តើក្រុមប្រឹក្សាឃុំ សង្កាត់ ឬក្រុមប្រឹក្សាស្រុក ខណ្ឌ នឹងជួបផលវិបាកអ្វីប្រសិនបើក្រុមប្រឹក្សាមិនឯកភាពជាមួយនឹងលទ្ធផលនៃការពិនិត្យនីត្យានុកូលភាព?
- តើក្រុមប្រឹក្សាសង្កាត់ នឹងជួបផលវិបាកអ្វីប្រសិនបើក្រុមប្រឹក្សាសង្កាត់ មិនឯកភាពជាមួយសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាក្រុងអំពីមុខងារ និងធនធានដែលគួរធ្វើប្រតិភូកម្មដល់ក្រុមប្រឹក្សាសង្កាត់?
- តើអ្នកចូលរួមនៅក្នុងវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់នឹងជួបផលវិបាកអ្វី ប្រសិនបើក្រុមប្រឹក្សាមិនពិចារណាសំណើសំណូមពរ និងមតិយោបល់របស់ខ្លួន?
- តើសាធារណជនអាចចូលរួមនៅក្នុងវេទិកាពិគ្រោះយោបល់ និងផ្សព្វផ្សាយបានឬទេ ឬចាំបាច់ត្រូវមានលិខិតអញ្ជើញ?

## វគ្គទី ២៖

## មេរៀនសង្ខេប

✓ ក្រុមប្រឹក្សានៅថ្នាក់ក្រោមជាតិ មានស្វ័យភាពនៅក្នុងដែនដីរបស់ខ្លួន ប៉ុន្តែនៅតែមានទំនាក់ទំនងយ៉ាងរឹងមាំជាមួយក្រុមប្រឹក្សាផ្សេងទៀត។ ក្រុមប្រឹក្សាត្រូវពិគ្រោះយោបល់ សហប្រតិបត្តិការ និងសហការជាមួយគ្នា។

✓ ទោះបីជាក្រុមប្រឹក្សាឃុំ សង្កាត់ គឺជាក្រុមប្រឹក្សានៅថ្នាក់ "ទាបបំផុត" ក្តី ក៏ក្រុមប្រឹក្សាឃុំ សង្កាត់មានតួនាទីជាក់លាក់ក្នុងការធ្វើឱ្យក្រុមប្រឹក្សា "ថ្នាក់លើ" មានគណនេយ្យភាព និង ធានាថា តម្រូវការរបស់ប្រជាពលរដ្ឋរបស់ខ្លួន ត្រូវបានឆ្លើយតប ។

✓ ក្រៅពីការអនុវត្តការងាររបស់ខ្លួន ក្រុមប្រឹក្សាខេត្ត មានភារកិច្ចគាំទ្រ និង ផ្តល់អំណាចដល់ក្រុមប្រឹក្សាផ្សេងទៀតនៅក្នុងខេត្ត ។ ក្រុមប្រឹក្សាខេត្ត ត្រូវបំពេញការងារជាមួយក្រុមប្រឹក្សាក្រុង និងក្រុមប្រឹក្សាស្រុកដើម្បីឆ្លើយតបនឹងតម្រូវការរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ។

✓ ក្រុមប្រឹក្សាខេត្តត្រូវបានធ្វើប្រតិភូកម្មមុខងារដើម្បីធានាថាក្រុមប្រឹក្សាផ្សេងទៀតអនុវត្តទៅតាមរដ្ឋធម្មនុញ្ញ ច្បាប់ លិខិតបទដ្ឋាន និងគោលនយោបាយជាតិ។ ទោះបីជាយ៉ាងណាក៏ដោយ ក្រុមប្រឹក្សាស្រុក និងក្រុមប្រឹក្សាក្រុងមានការទទួលខុសត្រូវចំពោះការពិនិត្យនីត្យានុកូលភាពលើដីកា និងសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ។

✓ ជារៀងរាល់ឆ្នាំក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាស្រុក និងក្រុមប្រឹក្សាក្រុងត្រូវរៀបចំវេទិកាពិគ្រោះយោបល់ និងផ្សព្វផ្សាយនៅក្នុងដែនដីរបស់ខ្លួន។ វេទិកាទាំងនេះ គឺជាយន្តការសម្រាប់តម្លាភាព ការចូលរួមចំណែករបស់ប្រជាពលរដ្ឋ ភាពពេញលេញ និងគណនេយ្យភាពតាមបែបប្រជាធិបតេយ្យ។

✓ ក្រៅពីនេះ នៅក្នុងពេលរៀបចំ និងអនុវត្តផែនការអភិវឌ្ឍ ក្រុមប្រឹក្សាត្រូវពិគ្រោះយោបល់ជាមួយក្រុមប្រឹក្សាផ្សេងទៀតនៅក្នុងដែនដី។

✓ ក្រុមប្រឹក្សាថ្មីទាំងអស់ នឹងមានទំនាក់ទំនងយ៉ាងជិតស្និទ្ធិជាមួយមន្ទីរ/ការិយាល័យខ្សែបណ្តោយនៅក្នុងដែនដីរបស់ខ្លួន។ ទំនាក់ទំនងនេះគឺជាចំណុចដ៏សំខាន់នៅក្នុងរដ្ឋបាលឯកភាព។

✓ មានទំនាក់ទំនងយ៉ាងជិតស្និទ្ធរវាងក្រុមប្រឹក្សាស្រុក និងក្រុមប្រឹក្សាឃុំ សង្កាត់នៅក្នុងស្រុក។ ឧទាហរណ៍ មេឃុំ ចៅ សង្កាត់ មានសិទ្ធិចូលរួម និងមានមតិនៅក្នុងកិច្ចប្រជុំរបស់ក្រុមប្រឹក្សាស្រុក។

- ✓ ដូចគ្នានឹងឃុំ សង្កាត់ និងស្រុកដែរមានទំនាក់ទំនងយ៉ាងជិតស្និទ្ធរវាងក្រុមប្រឹក្សាក្រុង និងក្រុមប្រឹក្សាសង្កាត់នៅក្នុងក្រុង។ ទោះបីជាយ៉ាងណាក៏ដោយ មិនដូចក្រុមប្រឹក្សាឃុំសង្កាត់នៅក្នុងស្រុក ក្រុមប្រឹក្សាសង្កាត់ស្ថិតនៅក្រោមការត្រួតពិនិត្យ និងគ្រប់គ្រងរបស់ក្រុមប្រឹក្សាក្រុង។

## វគ្គទី ៣ :

## ការងារជាក្រុម

**ការងារជាក្រុម ដូចមានពិពណ៌នាខាងក្រោមអាចមានលក្ខណៈមិនសមស្របសំរាប់ការបណ្តុះបណ្តាលទាំងអស់ ។ សូមចាត់ទុកការងារជាក្រុមខាងក្រោមជាសំណូមពរតែប៉ុណ្ណោះ ។**

១. ចែកសិក្ខាកាមជាក្រុមដែលមានសមាជិកមិនលើសពី៨នាក់ ។

២. ផ្តល់លំហាត់ខាងក្រោមដល់ក្រុមនីមួយៗ ។

**លំហាត់ទីមួយ: ទំនាក់ទំនងរវាងក្រុមប្រឹក្សាស្រុក និងក្រុមប្រឹក្សាឃុំ សង្កាត់**

**ពិភាក្សានៅក្នុងក្រុមតូចៈ**

- តើការគាំទ្រប្រភេទអ្វីដែលក្រុមប្រឹក្សាឃុំ សង្កាត់អាចចង់បានពីអង្គភាពរបស់ក្រុមប្រឹក្សាស្រុកដែលគាំទ្រក្រុមប្រឹក្សាឃុំ សង្កាត់?
- តើវិធីអ្វីខ្លះដែលក្រុមប្រឹក្សាឃុំ សង្កាត់អាចធ្វើឱ្យក្រុមប្រឹក្សាស្រុកមានគណនេយ្យភាព? (ពិនិត្យមើលនិយមន័យនៃគណនេយ្យភាពនៅក្នុងមេរៀននេះ) ។

**លំហាត់ទីពីរ: ទំនាក់ទំនងរវាងក្រុមប្រឹក្សាសង្កាត់ និងក្រុមប្រឹក្សាក្រុង**

**ពិភាក្សានៅក្នុងក្រុមតូចៈ**

- ដោយយល់ឃើញថា ក្រុមប្រឹក្សាសង្កាត់ ត្រូវបានបោះឆ្នោតជ្រើសរើសឡើងដោយផ្ទាល់ ហើយក្រុមប្រឹក្សានេះស្ថិតនៅកៀកនឹងប្រជាពលរដ្ឋ តើក្រុមប្រឹក្សាសង្កាត់គួរមានតួនាទីអ្វីនៅក្នុងក្រុង?
- តើវិធីអ្វីខ្លះដែលក្រុមប្រឹក្សាសង្កាត់អាចធ្វើឱ្យក្រុមប្រឹក្សាក្រុងមានគណនេយ្យភាពក្នុងការឆ្លើយតបនឹងតម្រូវការនៅមូលដ្ឋាន?
- តើមុខងារអ្វីដែលក្រុមប្រឹក្សាក្រុង គួរធ្វើប្រតិភូកម្មដល់ក្រុមប្រឹក្សាសង្កាត់?

# មេរៀនសម្រាប់ការយល់ដឹង និង
# ការបណ្តុះបណ្តាលអំពី
# ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល រាជធានី
# ខេត្ត ក្រុង ស្រុក ខណ្ឌ

## មេរៀនទី ១២:
## តួនាទី និងរចនាសម្ព័ន្ធរបស់
## រដ្ឋបាលថ្នាក់ក្រោមជាតិ

## វគ្គទី ១:

១. សេចក្តីផ្តើម

២. ខេត្ត

៣. ក្រុង

៤. ស្រុក

៥. ការចាត់ចែងអន្តរកាល

## ផ្នែកទី ១: សេចក្តីផ្តើម

ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ តម្រូវឱ្យបុគ្គលិករបស់ក្រុមប្រឹក្សា ត្រូវរៀបចំឱ្យទៅជាអង្គភាព ហើយអង្គភាពនីមួយៗមានតួនាទីដែលបានកំណត់។ ការបង្កើតរចនាសម្ព័ន្ធចាត់តាំងច្បាស់លាស់បែបនេះសម្រាប់រដ្ឋបាលនៅថ្នាក់ក្រោមជាតិទាំងអស់មានសារៈសំខាន់ណាស់ដើម្បីឱ្យបុគ្គលិកមានភាពច្បាស់លាស់អំពីតួនាទី និងការទទួលខុសត្រូវរបស់ខ្លួន។ តាមវិធីនេះ បុគ្គលិករបស់ក្រុមប្រឹក្សាអាចបំពេញការងារយ៉ាងមានប្រសិទ្ធិភាព និងមានប្រសិទ្ធិផលដើម្បីជួយក្រុមប្រឹក្សា និងអនុវត្តសេចក្តីសម្រេចរបស់ក្រុមប្រឹក្សា។

រចនាសម្ព័ន្ធចាត់តាំងរបស់រដ្ឋបាលនៅថ្នាក់ក្រោមជាតិនីមួយៗមានលក្ខណៈប្រហាក់ប្រហែលគ្នា។ ទោះជាយ៉ាងណាក្តី ដោយសារតួនាទីរបស់ថ្នាក់នីមួយៗមានភាពខុសគ្នាទៅតាមទិដ្ឋភាពសំខាន់ៗមួយចំនួនមានភាពខុសគ្នាខ្លះលើរចនាសម្ព័ន្ធរបស់រដ្ឋបាលតាមថ្នាក់នីមួយៗ។

មេរៀននេះ ពិនិត្យមើលរចនាសម្ព័ន្ធរបស់រដ្ឋបាលនៅថ្នាក់ក្រោមជាតិនីមួយៗ និងតួនាទី និងការទទួលខុសត្រូវរបស់អង្គភាពនីមួយៗ។ មេរៀននេះក៏ពិនិត្យមើលផងដែរអំពីរបៀបដែលគណៈអភិបាល អភិបាល និងនាយករដ្ឋបាលប្រាស្រ័យទាក់ទងជាមួយអង្គភាពរបស់រដ្ឋបាល។

នៅទំព័រខាងក្រោម ទិដ្ឋភាពទូទៅលើរចនាសម្ព័ន្ធរបស់រដ្ឋបាលនៅថ្នាក់ក្រោមជាតិនីមួយៗ នឹងត្រូវផ្តល់ជូន (នៃអនុក្រឹត្យលេខ២១៦ អ.ន.ក្រ.បក ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក)។

| រដ្ឋបាលខេត្ត | រដ្ឋបាលខេត្តក្រុង | រដ្ឋបាលស្រុក |
|---|---|---|
| **ទីចាត់ការរដ្ឋបាល**<br>• ការិយាល័យរបៀប និងឯកសារ<br>• ការិយាល័យទំនាក់ទំនងសាធារណៈ និងសហប្រតិបត្តិការអន្តរជាតិ<br>• ការិយាល័យសរុប និងព័ត៌មាន<br>• ការិយាល័យស្ថិតិ និងអគ្រានុកូលដ្ឋាន<br>• ការិយាល័យលេខាធិការក្រុមប្រឹក្សា | **ការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុ** | **ការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុ** |
| **ទីចាត់ការផែនការ និងវិនិយោគ**<br>• ការិយាល័យផែនការ<br>• ការិយាល័យគាំទ្រមូលដ្ឋាន<br>• ការិយាល័យវិនិយោគ | **ការិយាល័យផែនការ និងគាំទ្រសង្កាត់** | **ការិយាល័យផែនការ និងគាំទ្រឃុំ សង្កាត់** |

| **ទីចាត់ការហិរញ្ញវត្ថុ**<br>• ការិយាល័យហិរញ្ញកិច្ច<br>• ការិយាល័យគណនេយ្យ<br>• ការិយាល័យគ្រប់គ្រងទ្រព្យសម្បត្តិ<br>• ការិយាល័យលទ្ធកម្ម<br>**ទីចាត់ការគ្រប់គ្រងធនធានមនុស្ស**<br>• ការិយាល័យគ្រប់គ្រងបុគ្គលិក<br>• ការិយាល័យអភិវឌ្ឍសមត្ថភាព<br>**ទីចាត់ការអន្តរវិស័យ**<br>• ការិយាល័យសេដ្ឋកិច្ច និងសង្គមកិច្ច<br>• ការិយាល័យគ្រប់គ្រងការអភិវឌ្ឍ និងសំណង់<br>• ការិយាល័យកិច្ចការច្បាប់ និងសុវត្ថិភាពសាធារណៈ | **ការិយាល័យអភិវឌ្ឍន៍ក្រុង** | **ការិយាល័យគាំទ្រអន្តរវិស័យ** |
| --- | --- | --- |

**ផ្នែកទី ២៖ ខេត្ត**

**ប្រជាពលរដ្ឋមានសិទ្ធិទៅកាន់សាលាខេត្តដើម្បី**

- **ទំនាក់ទំនង និងបំពេញការងារជាមួយក្រុមប្រឹក្សា និងគណៈអភិបាល**
- **ទទួលព័ត៌មានអំពីសំណើនានាទៅរដ្ឋបាលខេត្ត**
- **ចូលរួមយោបល់ ឬសំណូមពរលើបញ្ហាណាមួយ ។**

✓ សាលាខេត្តមាន**ទីចាត់ការចំនួន ៥** ដូចខាងក្រោម៖

- ទីចាត់ការរដ្ឋបាល
- ទីចាត់ការផែនការ និងវិនិយោគ
- ទីចាត់ការហិរញ្ញវត្ថុ
- ទីចាត់ការគ្រប់គ្រងធនធានមនុស្ស
- ទីចាត់ការអន្តរវិស័យ

(មាត្រា ៥៥ នៃអនុក្រឹត្យលេខ២១៦ អ.ន.ក្រ.បក ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក)

✓ ទីចាត់ការនីមួយៗមាន**នាយកទីចាត់ការ**មួយរូប និង**នាយករងទីចាត់ការ**យ៉ាងច្រើនពីររូបជាជំនួយការ (មាត្រា ៥៥ នៃអនុក្រឹត្យលេខ២១៦ អ.ន.ក្រ.បក ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក) ។

✓ ទីចាត់ការនីមួយៗ**ត្រូវចែកចេញជាការិយាល័យ**មួយចំនួន។ ការិយាល័យនីមួយៗមាន**ប្រធានការិយាល័យមួយរូប** និង**អនុប្រធានការិយាល័យ**យ៉ាងច្រើនពីររូបជាជំនួយការ។

- ✓ ប្រធានការិយាល័យម្នាក់ៗមាន**គណនេយ្យភាព**ចំពោះនាយកទីចាត់ការ។ នាយកទីចាត់ការមានគណនេយ្យភាពចំពោះនាយករដ្ឋបាល។ នាយករដ្ឋបាលមានគណនេយ្យភាពចំពោះក្រុមប្រឹក្សា និងគណៈអភិបាល (មាត្រា ១៧៤, ១៩០ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។
- ✓ ប្រសិនបើក្រុមប្រឹក្សាខេត្តមានបំណងបង្កើត**ទីចាត់ការថ្មី** ឬការិយាល័យថ្មី ឬរៀបចំឡើងវិញ ឬរំសាយទីចាត់ការដែលមានស្រាប់អភិបាលខេត្តត្រូវធ្វើសំណើទៅក្រសួងមហាផ្ទៃដើម្បី។

| **ការិយាល័យរបស់<u>ទីចាត់ការរដ្ឋបាល</u> និងការទទួលខុសត្រូវចំបង** |
|---|
| **ការិយាល័យរបៀប និងឯកសារ**<br>- ទទួល និងបែងចែកលិខិតចេញចូល ទូរស័ព្ទ ទូរសារ<br>- ទទួលពិនិត្យសំណើសុំធ្វើនីត្យានុកូលកម្មលើលិខិតស្នាម និងឯកសារផ្សេងៗ<br>- ទទួលខុសត្រូវលើការងារគ្រប់គ្រង និងថែរក្សាត្រា<br>- ការងារបណ្ណាល័យ និងតម្កល់ឯកសារ<br>- រៀបចំកម្មវិធីការងារប្រចាំសប្តាហ៍របស់គណៈអភិបាល<br>- ការងារសន្តិសុខសណ្តាប់ធ្នាប់ក្នុងសាលាខេត្ត |
| **ការិយាល័យទំនាក់ទំនងសាធារណៈ និងសហប្រតិបត្តិការអន្តរជាតិ**<br>- ទទួល និងផ្តល់ព័ត៌មានជូនសាធារណជន<br>- ទទួលបន្ទុកការងារពិធីការ និងរៀបចំពិធីបដិសណ្ឋារកិច្ច<br>- កិច្ចសហប្រតិបត្តិការ និងគាំទ្រពីក្រុង ខេត្តសម្ព័ន្ធមេត្រីភាព និងពីអង្គការជាតិ អន្តរជាតិ |
| **ការិយាល័យសរុប និងព័ត៌មាន**<br>- ប្រមូលផ្តុំព័ត៌មានអំពីមតិសាធារណៈ ដើម្បីផ្តល់ជូនក្រុមប្រឹក្សា និងគណៈអភិបាល<br>- ប្រមូលផ្តុំព័ត៌មានពីទីចាត់ការរបស់សាលាខេត្ត ពីគ្រប់វិស័យ ក្រុង ស្រុក ឃុំ សង្កាត់ជាមូលដ្ឋានសម្រាប់រៀបចំ |

របាយការណ៍

- រៀបចំ និងបិទផ្សាយព័ត៌មាននៅលើក្ដារព័ត៌មានសាធារណៈ
- សហការរៀបចំព័ត៌មានសម្រាប់ផ្សព្វផ្សាយតាមស្ថានីយ៍វិទ្យុ ទូរទស្សន៍ ទស្សនាវដ្ដី គេហទំព័រ និងប្រព័ន្ធផ្សព្វផ្សាយផ្សេងទៀត
- រៀបចំការប្រជុំ និងកំណត់ហេតុប្រជុំរបស់គណៈអភិបាលខេត្ត។

**ការិយាល័យស្ថិតិ និងអត្រានុកូលដ្ឋាន**

- ទទួលខុសត្រូវលើជំរឿន និងស្ថិតិប្រជាពលរដ្ឋ
- វិភាគ វាយតំលៃអំពីស្ថានភាពនៃចំណូល និងចំណាកស្រុករបស់ប្រជាពលរដ្ឋនៅក្នុងខេត្ត
- គាំទ្រ តាមដាន និងធ្វើការស្រាវជ្រាវទាក់ទងនឹងអត្រានុកូលដ្ឋាន
- ផ្ដល់អត្តសញ្ញាណប័ណ្ណ

**ការិយាល័យលេខាធិការក្រុមប្រឹក្សា**

- រៀបចំរបៀបវារៈនៃកិច្ចប្រជុំ លិខិតអញ្ជើញប្រជុំ ឯកសារផ្សេងទៀត និងកំណត់ហេតុនៃកិច្ចប្រជុំរបស់ក្រុមប្រឹក្សា និងគណៈអភិបាល និងរៀបចំកន្លែងប្រជុំរបសក្រុមប្រឹក្សា និងគណៈអភិបាលហើយថែរក្សាទាំងនេះ
- សហការជាមួយការិយាល័យផ្សេងទៀត ដើម្បីផ្សព្វផ្សាយព័ត៌មានអំពីសេចក្ដីសម្រេចរបស់ក្រុមប្រឹក្សា និងព័ត៌មានផ្សេងទៀតរបស់ក្រុមប្រឹក្សា
- សហការរៀបចំ និងរាយការណ៍អំពីវេទិកាផ្សព្វផ្សាយនៅក្នុងក្រុង និងស្រុក។

## ការិយាល័យរបស់ទីចាត់ការផែនការ និងវិនិយោគ និងការទទួលខុសត្រូវចំបង

### ការិយាល័យផែនការ

- សហការ និងសម្របសម្រួលក្នុងការរៀបចំផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ សេចក្តីព្រាងផែនការអភិវឌ្ឍ និងកម្មវិធីវិនិយោគរំកិល
- សហការនៅក្នុងការអនុវត្តផែនការអភិវឌ្ឍ និងកម្មវិធីវិនិយោគរំកិល និងរៀបចំរបាយការណ៍រីកចំរើនអំពីការអនុវត្តផែនការ និងកម្មវិធីនេះ
- ពិនិត្យរបាយការណ៍អនុវត្តផែនការអភិវឌ្ឍរបស់ក្រុមប្រឹក្សាទាំងអស់នៅក្នុងខេត្ត
- ចងក្រងទិន្នន័យទាក់ទងនឹងគំរោងអភិវឌ្ឍនៅគ្រប់ថ្នាក់នៅក្នុងខេត្ត
- ទំនាក់ទំនង និងសហការជាមួយមន្ទីរនានាអំពីតម្រូវការជាអាទិភាពរបស់ខេត្ត ក្រុង ស្រុក ឃុំ សង្កាត់
- ផ្តល់អនុសាសន៍ជូនអភិបាលខេត្តទាក់ទងនឹងការធ្វើអនុលោមភាពផែនការអភិវឌ្ឍរបស់ក្រុង ស្រុក ឃុំ សង្កាត់
- គ្រប់គ្រង និងត្រួតពិនិត្យកិច្ចសន្យាទាក់ទងនឹងកម្មវិធីវិនិយោគខេត្ត
- សហការសិក្សាគម្រោង រៀបចំប្លង់ ប៉ាន់ស្មានតំលៃ និងរៀបចំសំណើគម្រោង។

### ការិយាល័យគាំទ្រមូលដ្ឋាន

- សម្របសម្រួល និងគាំទ្រដល់ក្រុង ស្រុក ឃុំ សង្កាត់ក្នុងការរៀបចំ និងអនុវត្តផែនការអភិវឌ្ឍ និងកម្មវិធីវិនិយោគរំកិល
- គាំទ្រក្រុង ស្រុក ឃុំ សង្កាត់ក្នុងការសិក្សាគម្រោង រៀបចំប្លង់ ការប៉ាន់ស្មានតំលៃ និងរៀបចំសំណើគម្រោង
- ពិនិត្យតាមដាន វាយតំលៃ និងគាំទ្រការអភិវឌ្ឍសមត្ថភាព និងការបំពេញការងាររបស់ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាឃុំ សង្កាត់
- វាយតំលៃការឆ្លើយតបរបស់ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុកចំពោះតម្រូវការរបស់ក្រុមប្រឹក្សាឃុំ សង្កាត់
- ឆ្លើយតបនឹងតម្រូវការរបស់ក្រុមប្រឹក្សាក្រុង និងក្រុមប្រឹក្សាស្រុក

- ពិនិត្យនីត្យានុកូលភាពលើដីកា និងសេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាក្រុង និងក្រុមប្រឹក្សាស្រុក
- គាំទ្រដល់ក្រុង ស្រុកក្នុងការពិនិត្យនីត្យានុកូលភាពលើដីកា និងសេចក្ដីសម្រេចរបស់ឃុំ សង្កាត់
- សិក្សាស្រាវជ្រាវអំពីការបង្កើត រំសាយ បំបែក បង្រួមភូមិ ឃុំ សង្កាត់ ស្រុក និងក្រុង

**ការិយាល័យវិនិយោគ**

- សហការជាមួយមន្ទីរជំនាញពាក់ព័ន្ធ ដើម្បីសិក្សា និងផ្ដល់យោបល់អំពីរបៀបលើកទឹកចិត្តវិនិយោគនៅក្នុងខេត្ត
- សហការជាមួយមន្ទីរជំនាញពាក់ព័ន្ធ ដើម្បីពិនិត្យ និងអនុវត្តយន្តការលើកទឹកចិត្តវិនិយោគនៅក្នុងខេត្ត
- រៀបចំកម្មវិធី និងឯកសារទាក់ទងនឹងការវិនិយោគ
- ពិនិត្យ និងផ្ដល់យោបល់លើសំណើវិនិយោគ និងអភិវឌ្ឍន៍ពិសិស័យឯកជននៅក្នុងខេត្ត ។

**ការិយាល័យរបស់ទីចាត់ការហិរញ្ញវត្ថុ និងការទទួលខុសត្រូវចំបង**

**ការិយាល័យហិរញ្ញកិច្ច**

- រៀបចំថវិកាប្រចាំឆ្នាំ និងក្របខ័ណ្ឌចំណាយ
- រៀបចំនីតិវិធីហិរញ្ញវត្ថុអំពីការប្រើប្រាស់ថវិកា និងវាយតំលៃការអនុវត្ត
- រៀបចំរបាយការណ៍ហិរញ្ញវត្ថុ
- រៀបចំលិខិតបទដ្ឋានសម្រាប់ការប្រមូលចំណូល និងជំរុញការប្រមូលចំណូល
- ពិនិត្យអាណត្តិបើកប្រាក់ និងសំណើចំណាយ
- គាំទ្រក្រុង និងស្រុក ដើម្បីរៀបចំ និងអនុវត្តថវិការបស់ខ្លួន
- គាំទ្រក្រុង និងស្រុក ដើម្បីគាំទ្រឃុំ សង្កាត់ក្នុងការរៀបចំ និងអនុវត្តថវិកាឃុំ សង្កាត់
- ផ្ដល់អនុសាសន៍ជូនអភិបាលអំពីការធ្វើអនុលោមភាពថវិកាក្រុមប្រឹក្សាក្រុង ស្រុក ឃុំ សង្កាត់

**ការិយាល័យគណនេយ្យ**

- គ្រប់គ្រងបេឡាសាច់ប្រាក់ និងគណនី
- ចុះបញ្ជី និងគ្រប់គ្រងប្រាក់ចំណូលគ្រប់ប្រភេទ
- ធ្វើសេចក្តីរាយការណ៍អំពីចំណូល ចំណាយ និងថវិកា
- រៀបចំ និងបើកប្រាក់បៀវត្សជូនមន្ត្រី បុគ្គលិកក្នុងសាលាខេត្ត
- ត្រួតពិនិត្យ និងទូទាត់រាល់ការចំណាយ
- រៀបចំរបាយការណ៍អំពីការទូទាត់ថវិកាខេត្ត ។

**ការិយាល័យគ្រប់គ្រងទ្រព្យសម្បត្តិ**

- គ្រប់គ្រងចលនទ្រព្យ អចលនទ្រព្យគ្រប់ប្រភេទរបស់រដ្ឋបាលខេត្ត

ធ្វើសារពើភ័ណ្ឌ និងគ្រប់គ្រងបញ្ជីសារពើភ័ណ្ឌចលនទ្រព្យ និងអចលនទ្រព្យ

- រៀបចំគោលការណ៍សម្រាប់គ្រប់គ្រងទ្រព្យសម្បត្តិ និងនីតិវិធីសម្រាប់លក់ ជួល និងវិនិយោគទ្រព្យសម្បត្តិ ។

**ការិយាល័យលទ្ធកម្ម**

- គ្រប់គ្រង និងធ្វើរបាយរបាយការណ៍អំពីការងារលទ្ធកម្មរបស់រដ្ឋបាលខេត្ត

**ការិយាល័យរបស់ទីចាត់ការគ្រប់គ្រងធនធានមនុស្ស និងការទទួលខុសត្រូវចំបង**

**ការិយាល័យគ្រប់គ្រងបុគ្គលិក**

- រៀបចំផែនការប្រើប្រាស់ក្របខ័ណ្ឌ និងមន្ត្រី បុគ្គលិករបស់ក្រុមប្រឹក្សា
- រៀបចំតួនាទី ភារកិច្ច និង នីតិវិធីរដ្ឋបាលសម្រាប់ទីចាត់ការ និងការិយាល័យនានា និងពិនិត្យតាមដាន និង វាយតំលៃការអនុវត្តតួនាទី ភារកិច្ច និងនីតិវិធី
- ជ្រើសរើសបុគ្គលិក ហើយរៀបចំ និងរក្សាទុកសំណុំលិខិតរបស់បុគ្គលិក
- រៀបចំល័ក្ខខ័ណ្ឌការងាររបស់បុគ្គលិក ហើយពិនិត្យតាមដាន និងវាយតំលៃការអនុវត្តល័ក្ខខ័ណ្ឌការងារនេះ

- រៀបចំផែនការប្រើប្រាស់ និងជ្រើសរើសទីប្រឹក្សាបច្ចេកទេស និងមន្ត្រីជាប់កិច្ចសន្យា
- លើកយោបល់លើសំណើសុំតែងតាំង ការតំឡើងឋានៈ ការដាក់ទណ្ឌកម្ម ការបញ្ឈប់ ការផ្លាស់ប្តូរភារកិច្ច និងការស្នើសុំច្បាប់សំរាក
- គាំទ្រក្រុង និងស្រុកអំពីការគ្រប់គ្រងបុគ្គលិកក្រុង ស្រុក ឃុំ សង្កាត់
- រៀបចំសំណើបង្កើត ឬកែសម្រួល ឬ រំសាយទីចាត់ការ ឬការិយាល័យរបស់សាលាខេត្ត
- លើកយោបល់លើសំណើបង្កើត ឬកែសម្រួល ឬរំសាយការិយាល័យរបស់សាលាក្រុង និងសាលាស្រុក
- លើកយោបល់អំពីសមាសភាពនៅក្នុងគណៈកម្មាធិការ ឬអនុគណៈកម្មាធិការរបស់ក្រុមប្រឹក្សា ។

**ការិយាល័យកសាងសមត្ថភាព**

- កំណត់យុទ្ធសាស្ត្រ និងកម្មវិធីសម្រាប់អភិវឌ្ឍសមត្ថភាពបុគ្គលិក
- វាយតំលៃអំពីតម្រូវការបណ្តុះបណ្តាល និងរៀបចំកម្មវិធីបណ្តុះបណ្តាលបុគ្គលិក
- ផ្សព្វផ្សាយច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀត នីតិវិធីរដ្ឋបាល ក៏ដូចជាព័ត៌មានអំពីភារកិច្ចរបស់ទីចាត់ការ និងការិយាល័យនានា រួមទាំងល័ក្ខខ័ណ្ឌការងាររបស់បុគ្គលិក
- គាំទ្រការកសាងសមត្ថភាពដល់បុគ្គលិករបស់រដ្ឋបាលក្រុង ស្រុក ឃុំ និងសង្កាត់ ។

**ការិយាល័យរបស់ទីចាត់ការអន្តរវិស័យ និងការទទួលខុសត្រូវចំបង**

**ការិយាល័យសេដ្ឋកិច្ច និងសង្គមកិច្ច**

- គ្រប់គ្រងស្ថិតិអំពីអាជីវកម្មនៅក្នុងខេត្ត ហើយសហការជាមួយមន្ទីរនានា ដើម្បីពិនិត្យតាមដាន និងវាយតំលៃការធ្វើអាជីវកម្ម
- លើកយោបល់លើការអភិវឌ្ឍសេដ្ឋកិច្ចនៅមូលដ្ឋាន និងសកម្មភាពអាជីវកម្មនៅក្នុងខេត្ត
- រៀបចំគោលការណ៍ ដើម្បីគ្រប់គ្រងទីផ្សារ និងទីសត្តឃាដ
- សហការ និង សម្របសម្រួលការពិនិត្យមើលឡើងវិញលើមុខងារ និងធនធានដែលត្រូវផ្ទេរឱ្យក្រុមប្រឹក្សាខេត្ត

| |
|---|
| និងក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក និងក្រុមប្រឹក្សាឃុំ សង្កាត់<br>- លើកកម្ពស់ការផ្តល់សេវាទាក់ទងនឹងការអប់រំ សុខភាព និងអនាម័យនៅក្នុងខេត្ត<br>- សហការនៅក្នុងការអប់រំ និងការផ្សព្វផ្សាយព័ត៌មានអំពីសេវាសុខភាពសាធារណៈ<br>- លើកកំពស់ការថែទាំសុខភាពសម្រាប់ស្ត្រី និងកុមារ<br>- ការពារទ្រព្យសម្បត្តិសាធារណៈ ថែរក្សាសម្បត្តិវប្បធម៌ និងបេតិកភ័ណ្ឌជាតិ ធនធានធម្មជាតិ និងបរិស្ថាន<br>- ដោះស្រាយបញ្ហាទាក់ទងនឹងជនក្រីក្រ និវត្តន៍ជន ជនពិការ ក្មេងកំព្រា<br>- បង្ការគ្រោះធម្មជាតិ គ្រោះថ្នាក់សង្គម និងការជួយសង្គ្រោះ<br>- ដោះស្រាយបញ្ហាទាក់ទងពលកម្ម ការងារ និងការបណ្តុះបណ្តាលវិជ្ជាជីវៈ<br>- លើកកំពស់ការបញ្ជ្រាបយេនឌ័រទៅក្នុងសកម្មភាពទាំងអស់របស់សង្គម<br>- សម្របសម្រួល និងបង្កលក្ខណៈងាយស្រួលដល់ការថែរក្សាវប្បធម៌ សាសនា និងប្រពៃណី<br>- សម្របសម្រួលសកម្មភាពអន្តរវិស័យ ជាពិសេសលើកកំពស់ការអភិវឌ្ឍវិស័យឯកជន ។ |
| **ការិយាល័យគ្រប់គ្រងការអភិវឌ្ឍ និងសំណង់**<br>- សហការរៀបចំផែនការរៀបចំដែនដីខេត្ត<br>- ផ្តល់យោបល់អំពីគម្រោងអភិវឌ្ឍន៍ ដើម្បីឱ្យគម្រោងនេះស្របតាមផែនការរៀបចំដែនដីខេត្ត<br>- អនុវត្តភារកិច្ចទាក់ទងនឹងសិទ្ធិកាន់កាប់ដីធ្លី<br>- ពិនិត្យតាមដាន វាយតំលៃ និងរាយការណ៍អំពីការអនុវត្តផែនការរៀបចំដែនដីខេត្ត និងប្លង់សំណង់<br>- រៀបចំគោលការណ៍សម្រាប់ការគ្រប់គ្រងអគារចាស់ៗ និងបេតិកភ័ណ្ឌ<br>- លើកយោបល់លើបទល្មើសនៃការសាងសង់សំណង់នានា<br>- សហការកំណត់អំពីគោលការណ៍ក្នុងការអភិវឌ្ឍ ថែទាំ និងជួសជុលហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូននៅក្នុងខេត្ត<br>- អនុវត្តភារកិច្ចទាក់ទងនឹងការតាំងទីលំនៅថ្មី ថែរក្សាសណ្តាប់ធ្នាប់ នគរូបនីយកម្ម និងការដោះស្រាយវិវាទនៅក្រៅប្រព័ន្ធតុលាការ |

**ការិយាល័យកិច្ចការច្បាប់ និងសុវត្ថិភាពសាធារណៈ**

- កំណត់គោលការណ៍ទាក់ទងនឹងមធ្យោបាយដឹកជញ្ជូន និងសុវត្ថិភាពចរាចរ
- គ្រប់គ្រងប្រព័ន្ធចរាចរ និងមធ្យោបាយដឹកជញ្ជូននៅក្នុងខេត្ត
- កំណត់វិធានការទប់ស្កាត់ឧក្រិដ្ឋកម្ម និងរក្សាសុវត្ថិភាពនៅក្នុងខេត្ត
- រៀបចំគោលនយោបាយ ដើម្បីបង្ការទប់ស្កាត់ការប្រើប្រាស់គ្រឿងញៀន និងគ្រប់គ្រងមជ្ឈមណ្ឌលព្យាបាលគ្រឿងញៀន
- អំពីការរំលោភអំណាចនៅក្នុងដែនសមត្ថកិច្ចរបស់ខេត្ត
- ទទួល ពិនិត្យ និងលើកយោបល់លើសំណើអំពីការដោះស្រាយវិវាទនានានៅមូលដ្ឋាន
- ទទួល ពិនិត្យ និងលើកយោបល់លើពាក្យបណ្ដឹងពីសាធារណជនអំពីរដ្ឋបាលនានានៅក្នុងខេត្ត
- ផ្សព្វផ្សាយច្បាប់ និងលិខិតបទដ្ឋាន និង ពិនិត្យតាមដាន និង វាយតំលៃការយល់ដឹង និងការអនុវត្តច្បាប់ និងលិខិតបទដ្ឋាន
- ផ្សព្វផ្សាយព័ត៌មាន និងអប់រំអំពីការគោរពសិទ្ធិមនុស្ស
- ចូលរួមនៅក្នុងការប្រជុំគណៈបញ្ជាការឯកភាពខេត្ត និងពិនិត្យតាមដានការអនុវត្តសេចក្ដីសម្រេចដែលធ្វើឡើងនៅក្នុងកិច្ចប្រជុំនោះ

## ផ្នែកទី ៣: ក្រុង

**ប្រជាពលរដ្ឋមានសិទ្ធិទៅកាន់សាលាក្រុងដើម្បី**

- **ទំនាក់ទំនង និងបំពេញការងារជាមួយក្រុមប្រឹក្សា និងគណៈអភិបាល**
- **ទទួលព័ត៌មានអំពីសំណើ និងការងារនានាពីរដ្ឋបាលក្រុង**
- **ចូលរួមយោបល់ ឬសំណូមពរលើបញ្ហាណាមួយ**

(មាត្រា ១០៧ នៃអនុក្រឹត្យលេខ២១៦)

✓ សាលាក្រុងមាន**ការិយាល័យចំនួន ៣** ដូចខាងក្រោម:

- ការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុ
- ការិយាល័យផែនការ និងគាំទ្រសង្កាត់
- ការិយាល័យអភិវឌ្ឍក្រុង

✓ ការិយាល័យនីមួយៗមាន**ប្រធាន**មួយរូប និង**អនុប្រធាន**មួយរូប (ប្រការ ១៧ នៃប្រកាសលេខ៤២៧៤)។

✓ ប្រធានការិយាល័យម្នាក់ៗមាន**គណនេយ្យភាព**ចំពោះនាយករដ្ឋបាល។ នាយករដ្ឋបាលមានគណនេយ្យភាពចំពោះក្រុមប្រឹក្សា និងគណៈអភិបាល (មាត្រា ១៧៤, ១៩០ នៃច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

✓ ប្រសិនបើក្រុមប្រឹក្សាក្រុងមានបំណងបង្កើត**ការិយាល័យថ្មី** ឬរៀបចំឡើងវិញ ឬរំសាយការិយាល័យដែលមានស្រាប់ អភិបាលត្រូវធ្វើសំណើទៅក្រសួងមហាផ្ទៃដើម្បីសម្រេច។

✓ ក្រុងដែលបានដំណើរការ**ការិយាល័យច្រកចេញចូលតែមួយ** និង**ការិយាល័យប្រជាពលរដ្ឋរួចហើយ** ត្រូវបន្តដំណើរការការិយាល័យទាំងនេះទៀត។

## ការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុ

- មានភារកិច្ចរដ្ឋបាល គ្រប់គ្រងលិខិត ទំនាក់ទំនងសាធារណៈ និងការងារពិធីការ
- ទទួលខុសត្រូវលើការងារគ្រប់គ្រង និងថែរក្សាត្រា
- គ្រប់គ្រងស្ថិតិប្រជាពលរដ្ឋ និងអត្រានុកូលដ្ឋាន
- គ្រប់គ្រងបុគ្គលិក និងបៀវត្ស និងកម្រៃផ្សេងៗ របស់បុគ្គលិកក្រុមប្រឹក្សា
- សហការរៀបចំនីតិវិធីរដ្ឋបាល និងហិរញ្ញវត្ថុ និងល័ក្ខខ័ណ្ឌការងារបុគ្គលិក
- ផ្តល់ការបណ្តុះបណ្តាល និងការកសាងសមត្ថភាពបុគ្គលិក
- សិក្សា និងលើកយោបល់លើការបង្កើត ការកែសម្រួល និងការរំសាយការិយាល័យចំណុះសាលាក្រុង
- រៀបចំសេចក្តីព្រាងរបៀបវារៈ និងឯកសារសម្រាប់កិច្ចប្រជុំរបស់ក្រុមប្រឹក្សា និងគណៈកម្មាធិការរបស់ក្រុមប្រឹក្សា
- រៀបចំ និងបែងចែកលិខិតអញ្ជើញប្រជុំ រៀបចំកន្លែងប្រជុំ និងកំណត់ហេតុនៃកិច្ចប្រជុំទាំងអស់របស់ក្រុមប្រឹក្សា គណៈកម្មាធិការរបស់ក្រុមប្រឹក្សាក៏ដូចជាគណៈអភិបាល
- រក្សាទុកដាក់ឱ្យបានត្រឹមត្រូវ និងគង់វង្សនូវឯកសារ និងលិខិតបទដ្ឋានទាំងអស់របស់ក្រុមប្រឹក្សា គណៈអភិបាល និងរដ្ឋបាល
- រៀបចំរបាយការណ៍ប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំ
- រៀបចំ និងបិទផ្សាយព័ត៌មាននៅលើក្តារព័ត៌មាន និង ស្វះស្វែងរកមធ្យោបាយផ្សព្វផ្សាយព័ត៌មាននានាជូនសាធារណជន
- សហការរៀបចំវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់
- សិក្សា និងលើកយោបល់លើនីត្យានុកូលភាពនៃសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសង្កាត់
- ទទួលខុសត្រូវលើភារកិច្ចហិរញ្ញវត្ថុ ថវិកា និងការគ្រប់គ្រងទ្រព្យសម្បត្តិ
- គ្រប់គ្រងបេឡាសាច់ប្រាក់របស់ក្រុង
- សហការក្នុងការទូទាត់ការចំណាយ និងត្រួតពិនិត្យការចំណាយទាំងអស់
- ទទួលខុសត្រូវលើលទ្ធកម្ម សវនកម្ម និងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ

## ការិយាល័យផែនការ និងគាំទ្រសង្កាត់

- សិក្សា និងរៀបចំផែនការអភិវឌ្ឍ និងកម្មវិធីវិនិយោគ
- អនុវត្តគំរោង និងកម្មវិធីអភិវឌ្ឍ
- សម្របសម្រួលកិច្ចសហប្រតិបត្តិការអភិវឌ្ឍ និងការផ្តល់សេវានៅក្នុងចំណោមសង្កាត់
- សិក្សាវាយតំលៃនិងលើកមតិយោបល់លើតម្រូវការសមត្ថភាព និងការគាំទ្ររបស់សមាជិកក្រុមប្រឹក្សាសង្កាត់
- ឆ្លើយតបនឹងសំណើ សំណូមពរ និងបញ្ហាប្រឈមរបស់សង្កាត់
- គាំទ្រក្រុមប្រឹក្សាសង្កាត់ ដើម្បីរៀបចំ និងអនុវត្តផែនការអភិវឌ្ឍសង្កាត់
- ទំនាក់ទំនង និងសហការជាមួយអង្គភាពខ្សែបណ្តោយដើម្បីឆ្លើយតបនឹងតម្រូវការជាអាទិភាពរបស់សង្កាត់និងក្រុង
- បញ្ចូល និងធ្វើបច្ចុប្បន្នភាពទិន្នន័យទាក់ទងនឹងក្រុង និងសង្កាត់
- ពិនិត្យមើលរបាយការណ៍លើការអនុវត្តផែនការអភិវឌ្ឍរបស់ក្រុង និងសង្កាត់
- កៀរគរធនធានសម្រាប់ការអភិវឌ្ឍក្រុង និងសង្កាត់
- ពិនិត្យមើលកាលៈទេសៈរបស់សង្កាត់ ដោយមានទស្សនៈផ្ទេរមុខងារ និងធនធានដល់ក្រុមប្រឹក្សាសង្កាត់
- ពិនិត្យតាមដាន និងវាយតំលៃការប្រើប្រាស់មូលនិធិវិនិយោគក្រុង និងសង្កាត់

## ការិយាល័យអភិវឌ្ឍក្រុង

- សហការជាមួយអង្គភាពខ្សែបណ្ដោយ ដើម្បីធ្វើការស្រាវជ្រាវ និងលើកយោបល់លើការអភិវឌ្ឍក្រុង
- សហការ ដើម្បីរៀបចំប្លង់គោលប្រើប្រាស់ដីធ្លី និងផែនការប្រើប្រាស់ដីធ្លី
- មានការទទួលខុសត្រូវចំពោះភារកិច្ចពាក់ព័ន្ធនឹងកម្មសិទ្ធិដីធ្លី ការសាងសង់អគារ និងការជួសជុលកែលម្អអគារ រួមទាំងការសហការដោះស្រាយបទល្មើសសំណង់
- សិក្សា និងវាយតំលៃអំពីស្ថានភាពនៃការតាំងទីលំនៅបណ្ដោះអាសន្នក្នុងក្រុង រៀបចំតំបន់ទាំងទីលំនៅថ្មី និងសាងសង់លំនៅដ្ឋាន
- សិក្សា និងវិភាគទិន្នន័យអំពីកំណើនប្រជាជន កំណើនសេដ្ឋកិច្ចនៅមូលដ្ឋាន ភាពក្រីក្រនៅក្នុងក្រុង និងផលប៉ះពាល់មកលើការអភិវឌ្ឍក្រុង
- អនុវត្តមុខងារដែលបានផ្ទេរ និងដែលបានធ្វើប្រតិភូកម្ម
- សហការ និងសម្របសម្រួលការធ្វើប្រតិភូកម្មមុខងារ និងធនធានដល់ក្រុមប្រឹក្សាសង្កាត់
- ទទួលខុសត្រូវលើសណ្ដាប់ធ្នាប់សាធារណៈ កិច្ចការច្បាប់ និងសិទ្ធិមនុស្ស
- ទទួលខុសត្រូវលើការដោះស្រាយវិវាទនៅក្នុងក្រុង
- ទទួលខុសត្រូវលើភារកិច្ចទាក់ទងនឹងការអភិវឌ្ឍសេដ្ឋកិច្ច សង្គមកិច្ច វប្បធម៌ សាសនា ការការពារបរិស្ថាន ធនធានធម្មជាតិ បេតិកភ័ណ្ឌ រមណីដ្ឋាន និងតំបន់ប្រវត្តិសាស្ត្រ ។

## ផ្នែកទី ៤: ស្រុក

**ប្រជាពលរដ្ឋមានសិទ្ធិទៅកាន់សាលាស្រុកដើម្បី**

- **ទំនាក់ទំនង និងបំពេញការងារជាមួយក្រុមប្រឹក្សា និងគណៈអភិបាល**
- **ទទួលព័ត៌មានអំពីសំណើពីរដ្ឋបាលក្រុង**
- **ចូលរួមយោបល់ ឬសំណូមពរលើបញ្ហាណាមួយ**

✓ សាលាស្រុកមាន**ការិយាល័យចំនួន ៣** ដូចខាងក្រោម:

- ការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុ
- ការិយាល័យផែនការ និងគាំទ្រឃុំ សង្កាត់
- ការិយាល័យគាំទ្រអន្តរវិស័យ

✓ ការិយាល័យនីមួយៗមាន**ប្រធាន**មួយរូប និង**អនុប្រធាន**មួយរូប ។

✓ ប្រធានការិយាល័យម្នាក់ៗមាន**គណនេយ្យភាព**ចំពោះនាយករដ្ឋបាល ។ នាយករដ្ឋបាលមានគណនេយ្យភាពចំពោះក្រុមប្រឹក្សា និងគណៈអភិបាល ( មាត្រា ១៧៤, ១៩០ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

✓ ប្រសិនបើក្រុមប្រឹក្សាស្រុក មានបំណងបង្កើត**ការិយាល័យថ្មី** ឬរៀបចំឡើងវិញ ឬរំសាយការិយាល័យដែលមានស្រាប់ អភិបាល ត្រូវធ្វើសំណើទៅក្រសួងមហាផ្ទៃ ដើម្បីសម្រេច ។

✓ ក្រុងដែលបានដំណើរការ**ការិយាល័យច្រកចេញចូលតែមួយ** និង**ការិយាល័យប្រជាពលរដ្ឋរួចហើយ** ត្រូវបន្តដំណើរការការិយាល័យទាំងនេះទៀត។

## ការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុ

- មានភារកិច្ចរដ្ឋបាល គ្រប់គ្រងលិខិត ទំនាក់ទំនងសាធារណៈ និងការងារពិធីការ
- ទទួលខុសត្រូវលើការងារគ្រប់គ្រង និងថែរក្សាត្រា
- គ្រប់គ្រងស្ថិតិប្រជាពលរដ្ឋ និងអគ្រានុកូលដ្ឋាន
- គ្រប់គ្រងបុគ្គលិក និងប្រវត្តិរូប និងកម្រៃផ្សេងៗរបស់បុគ្គលិកក្រុមប្រឹក្សា
- សហការរៀបចំនីតិវិធីរដ្ឋបាល និងហិរញ្ញវត្ថុ និងល័ក្ខខ័ណ្ឌការងារបុគ្គលិក
- ផ្តល់ការបណ្តុះបណ្តាល និងការកសាងសមត្ថភាពបុគ្គលិក
- សិក្សា និងលើកយោបល់លើការបង្កើត ការកែសម្រួល និងការរំសាយការិយាល័យចំណុះសាលាស្រុក
- រៀបចំសេចក្តីព្រាងរបៀបវារៈ និងឯកសារសម្រាប់កិច្ចប្រជុំរបស់ក្រុមប្រឹក្សា និងគណៈកម្មាធិការរបស់ក្រុមប្រឹក្សា
- រៀបចំ និងបែងចែកលិខិតអញ្ជើញប្រជុំ រៀបចំកន្លែងប្រជុំ និងកំណត់ហេតុនៃកិច្ចប្រជុំទាំងអស់របស់ក្រុមប្រឹក្សា គណៈកម្មាធិការរបស់ក្រុមប្រឹក្សា និងកិច្ចប្រជុំរបស់គណៈអភិបាល
- រក្សាទុកដាក់ឱ្យបានត្រឹមត្រូវ និងគង់វង្សនូវឯកសារ និងលិខិតបទដ្ឋានទាំងអស់របស់ក្រុមប្រឹក្សា គណៈអភិបាល និងរដ្ឋបាល
- រៀបចំរបាយការណ៍ប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំ
- រៀបចំ និងបិទផ្សាយព័ត៌មាននៅលើក្តារព័ត៌មាន និងស្វះស្វែងរកមធ្យោបាយផ្សព្វផ្សាយព័ត៌មាននានាជូនសាធារណជន
- សហការរៀបចំវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់
- សិក្សា និងលើកយោបល់លើនីត្យានុកូលភាពនៃសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់
- ទទួលខុសត្រូវលើភារកិច្ចហិរញ្ញវត្ថុ ថវិកា និងការគ្រប់គ្រងទ្រព្យសម្បត្តិ
- គ្រប់គ្រងបេឡាសាច់ប្រាក់របស់ស្រុក
- សហការក្នុងការទូទាត់ការចំណាយ និងត្រួតពិនិត្យការចំណាយទាំងអស់
- ទទួលខុសត្រូវលើលទ្ធកម្ម សវនកម្ម និងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ

## ការិយាល័យផែនការ និងគាំទ្រឃុំ សង្កាត់

- សិក្សា និងរៀបចំផែនការអភិវឌ្ឍ និងកម្មវិធីវិនិយោគ
- អនុវត្តគំរោង និងកម្មវិធីអភិវឌ្ឍ
- សម្របសម្រួលកិច្ចសហប្រតិបត្តិការអភិវឌ្ឍ និងការផ្តល់សេវានៅក្នុងចំណោមឃុំ សង្កាត់
- គាំទ្រឃុំ សង្កាត់នៅក្នុងការវិភាគ និងវាយតំលៃការរីកចំរើននៅក្នុងការអភិវឌ្ឍរបស់ខ្លួន
- គាំទ្រឃុំ សង្កាត់ ដើម្បីរៀបចំថវិការបស់ខ្លួន
- សហការក្នុងការពិនិត្យមើល និងលើកមតិយោបល់ជូនអភិបាលអំពីការធ្វើអនុលោមភាពថវិកាឃុំ សង្កាត់
- សិក្សា វាយតំលៃ និងលើកមតិយោបល់លើតម្រូវការសមត្ថភាព និងការគាំទ្ររបស់ក្រុមប្រឹក្សាឃុំ សង្កាត់
- ឆ្លើយតបនឹងសំណើ សំណូមពរ និងបញ្ហាប្រឈមរបស់ឃុំ សង្កាត់
- គាំទ្រក្រុមប្រឹក្សាឃុំ សង្កាត់ ដើម្បីរៀបចំ និងអនុវត្តផែនការអភិវឌ្ឍរបស់ខ្លួន
- ទំនាក់ទំនង និងសហការជាមួយអង្គភាពខ្សែបណ្តោយ ដើម្បីឆ្លើយតបនឹងតម្រូវការជាអាទិភាពរបស់ស្រុក ឃុំ សង្កាត់
- ពិនិត្យមើលរបាយការណ៍លើការអនុវត្តផែនការអភិវឌ្ឍរបស់ស្រុក និងឃុំ សង្កាត់
- កៀរគរធនធានសម្រាប់ការអភិវឌ្ឍស្រុក និងឃុំ សង្កាត់
- គាំទ្រឃុំ សង្កាត់ឱ្យទទួលបានមុខងារ និងធនធានថែមទៀត
- ពិនិត្យតាមដាន និងវាយតំលៃការប្រើប្រាស់មូលនិធិវិនិយោគស្រុក និងឃុំ សង្កាត់

## ការិយាល័យអន្តរវិស័យ

- សិក្សា និងលើកយោបល់លើយុទ្ធសាស្ត្រ និងការបង្កើតរចនាសម្ព័ន្ធ ប្រព័ន្ធ និងធនធាន ដើម្បីទទួលយកមុខងារ និងធនធានថ្មី
- មានការទទួលខុសត្រូវចំពោះភារកិច្ចអំពីដីធ្លី និងសំណង់ រួមទាំងការស្នើសុំកាន់កាប់ដីធ្លី ការសាងសង់ ការជួសជុល ការវាយកំទេច និងការកែលម្អអាគារ
- អនុវត្តមុខងារដែលបានផ្ទេរ ឬដែលបានធ្វើប្រតិភូកម្មឱ្យ
- សហការទាក់ទងនឹងការធ្វើប្រតិភូកម្មមុខងារ និងធនធានដល់ក្រុមប្រឹក្សាសង្កាត់
- ទទួលខុសត្រូវលើសណ្តាប់ធ្នាប់សាធារណៈ កិច្ចការច្បាប់ និងសិទ្ធិមនុស្ស
- ទទួលខុសត្រូវលើការដោះស្រាយវិវាទនៅក្នុងស្រុក
- ទទួលខុសត្រូវលើភារកិច្ចទាក់ទងនឹងការអភិវឌ្ឍសេដ្ឋកិច្ច សង្គមកិច្ច វប្បធម៌ សាសនា ការការពារបរិស្ថាន ធនធានធម្មជាតិ បេតិកភ័ណ្ឌ រមណីដ្ឋាន និងតំបន់ប្រវត្តិសាស្ត្រ ។

## ផ្នែកទី ៦: ការចាត់ចែងអន្តរកាល

✓ បន្ទាប់ពីការបោះឆ្នោតនៅខែឧសភា ឆ្នាំ២០០៩ ក្រុមប្រឹក្សាថ្មី បានជំនួសរដ្ឋបាលដែលបានតែងតាំងពីមុនមកនៅរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។ ឧទាហរណ៍ ក្រុមប្រឹក្សាថ្មីនៅខេត្តស្វាយរៀងជំនួសរដ្ឋបាលដែលបានតែងតាំងពីមុនមកនៅខេត្តស្វាយរៀង (មាត្រា ២៧៧ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ប្រការ ៧ នៃប្រកាសលេខ ១២៤៩ ស្តីពីកិច្ចប្រជុំចូលកាន់តំណែង)។

✓ ក្រសួងមហាផ្ទៃមានការទទួលខុសត្រូវក្នុងការ**ផ្ទេរសមាហរណកម្មបុគ្គលិកដែលមានស្រាប់នៅក្នុងក្របខ័ណ្ឌមន្ត្រីរាជការនៅថ្នាក់ក្រោមជាតិរបស់ក្រសួងមហាផ្ទៃ** ទៅក្នុងរដ្ឋបាលថ្នាក់ក្រោមជាតិថ្មី (ការរៀបចំកែសម្រួលបុគ្គលិកឡើងវិញ)។ ដូច្នេះបុគ្គលិករបស់រដ្ឋបាលដែលបានតែងតាំងពីមុនមក ត្រូវបានរៀបចំកែសម្រួលឡើងវិញឱ្យទៅជាបុគ្គលិករបស់ក្រុមប្រឹក្សា និងរដ្ឋបាលថ្មី។ បុគ្គលិកទាំងនេះភាគច្រើនមានការទទួលខុសត្រូវលើមុខងារផ្នែករដ្ឋបាលដែលត្រូវបានអនុវត្តដោយរដ្ឋបាលពីមុននៅថ្នាក់ខេត្ត និងស្រុក។ ឧទាហរណ៍ បុគ្គលិកពីមុនរបស់រដ្ឋបាលខេត្តស្វាយរៀងនៅពេលនេះគឺជាបុគ្គលិករបស់រដ្ឋបាលថ្មីនៅខេត្តស្វាយរៀង (មាត្រា ២៨១ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

✓ បុគ្គលិករបស់ក្រសួងមហាផ្ទៃដែលត្រូវបានរៀបចំកែសម្រួលឡើងវិញ ត្រូវបាន**ត្រួតពិនិត្យ និងគ្រប់គ្រងដោយក្រុមប្រឹក្សា និងគណៈអភិបាល**។ នៅពេលមិនទាន់មានលក្ខន្តិកៈសម្រាប់បុគ្គលិកនៅថ្នាក់ក្រោមជាតិ ក្រុមប្រឹក្សាត្រូវអនុម័តលើការ**តែងតាំង**បុគ្គលិក **តំឡើងឋានៈ** កែប្រែលើ**ប្រាក់បៀវត្ស** ឬផលប្រយោជន៍ផ្សេងទៀត ហើយក្រុមប្រឹក្សាត្រូវអនុម័តការជ្រើសរើសបុគ្គលិកកិច្ចសន្យា និងបុគ្គលិកផ្សេងទៀត រួមទាំងទីប្រឹក្សាបច្ចេកទេស។ នៅពេលមានការឯកភាពរបស់ក្រុមប្រឹក្សា អភិបាលត្រូវស្នើសុំក្រសួងមហាផ្ទៃឱ្យចាត់វិធានការចាំបាច់ដើម្បីអនុវត្តសេចក្តីសម្រេចរបស់ក្រុមប្រឹក្សា។

✓ ប្រសិនបើបុគ្គលិកដែលត្រូវបានរៀបចំកែសម្រួលឡើងវិញមិនអាចឆ្លើយតបនឹងតម្រូវការរបស់ក្រុមប្រឹក្សា ក្រុមប្រឹក្សា និងគណៈអភិបាលត្រូវជ្រើសរើសបុគ្គលិកក្រោមក្របខ័ណ្ឌមន្ត្រីរាជការរបស់ក្រសួងផ្សេងៗ។

**បញ្ហាដែលត្រូវដោះស្រាយ**

មានបញ្ហាមួយចំនួនដែលលេចចេញពីប្រកាសស្តីពីការបង្កើតការិយាល័យ ខេត្ត ដែលនឹងត្រូវដោះស្រាយនៅពេលសមស្របមួយ ។ បញ្ហាទាំងនោះគឺ:

- ប្រកាសចែងថា អភិបាលខេត្តធ្វើអនុលោមភាពលើផែនការអភិវឌ្ឍ និងថវិការបស់ក្រុមប្រឹក្សាទាំងអស់ផ្សេងទៀតនៅក្នុងខេត្ត និងថាអភិបាលស្រុកធ្វើអនុលោមភាពលើថវិកាបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ( ប្រការ ៤, ៥, ២នៃប្រកាសលេខ៤២៧៤)។ តើប្រការនេះមានន័យថា អភិបាលពិនិត្យនីត្យានុកូលភាព ឬមានន័យថាអភិបាលអាចជ្រៀតជ្រែកលើ*ជម្រើសផ្នែកនយោបាយ* ដែលបានធ្វើឡើងដោយក្រុមប្រឹក្សាមួយទៀត?
- រដ្ឋបាលស្រុកមានភារកិច្ចសិក្សា និងសម្របសម្រួល *"ការធ្វើប្រតិភូកម្ម"* មុខងារ និងធនធានដល់សង្កាត់។ តើប្រការនេះមានន័យថា សង្កាត់នៅក្នុងស្រុកនឹងទទួលបានមុខងារដែលត្រូវធ្វើប្រតិភូកម្ម តែប៉ុណ្ណោះឬ ?
- តើប្រធានហិរញ្ញវត្ថុកាន់មុខតំណែងជាអ្វី? តើគាត់ជានាយកទីចាត់ការហិរញ្ញវត្ថុនៅក្នុងខេត្ត និងជាប្រធានការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុនៅក្នុងស្រុក?
- ហាក់ដូចជាមានការទទួលខុសត្រូវត្រួតគ្នានៅក្នុងចំណោមការិយាល័យនៅក្នុងរដ្ឋបាលមួយ។ ឧទាហរណ៍ ហាក់ដូចជាមានតួនាទីត្រួតគ្នាទាក់ទងនឹងការទទួលខុសត្រូវលើការគាំទ្ររបស់ខេត្ត ក្រុង និងស្រុក។ តើភាពត្រួតគ្នានេះនឹងត្រូវដោះស្រាយយ៉ាងដូចម្តេច?

- មុខងារត្រូវបានផ្ទេរឱ្យអង្គភាពរដ្ឋបាលជាជាងទៅក្រុមប្រឹក្សា ។

មុខងារខ្លះ ទំនងជាមុខងាររបស់ក្រសួងវិស័យ ឧទាហរណ៍ "ការទទួលខុសត្រូវលើសំណង់អគារ" និង "សង្គមកិច្ច វប្បធម៌ សាសនា"។ មិនមានភាពច្បាស់លាស់ ថាតើមានការពិគ្រោះយោបល់ជាមួយក្រសួងវិស័យនៅក្នុងការផ្តល់មុខងារនេះដល់រដ្ឋបាល ។

- ប្រកាស មិនបានបញ្ជាក់ថាតើមុខងារត្រូវបានប្រគល់ ឬធ្វើប្រតិភូកម្ម ជាកាតព្វកិច្ច ឬជាជម្រើស ឬធនធានអ្វីដែលក្រុមប្រឹក្សានឹងទទួលបានដើម្បីអនុវត្តមុខងារ
- មុខងារខ្លះលើកឡើងជាលក្ខណៈទូលំទូលាយ ដូច្នេះអាចនាំទៅដល់ភាពមិនច្បាស់លាស់អំពីអ្វីដែលអាច និងមិនអាចធ្វើបាន ឧទាហរណ៍ "ដោះស្រាយបញ្ហាទាក់ទងនឹងពលកម្ម" ។

- ប្រកាសហាក់ដូចជាចែងថា ក្រុមប្រឹក្សាត្រូវទទួលបានការអនុញ្ញាតពីក្រសួងមហាផ្ទៃ ដើម្បីបង្កើត រំសាយ ឬកែសម្រួលអង្គភាពនៅក្នុងរដ្ឋបាលរបស់ខ្លួន។ ទោះជាយ៉ាងក៏ដោយ ក្រោមច្បាប់ស្តីពី ការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ក្រុមប្រឹក្សា មានស្វ័យភាពក្នុងការបង្កើត និង រំសាយអង្គភាពរបស់ខ្លួនផ្ទាល់ (មាត្រា ១៨៩ នៃច្បាប់គ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ)។ តើបទបញ្ញត្តិនេះ មានភាពមិនស្របគ្នាឬទេ? ប្រសិនបើមែន តើត្រូវដោះស្រាយភាពមិនស្របគ្នានេះយ៉ាងដូចម្តេច? ដោយគិតថាច្បាប់មានអានុភាពលើប្រកាស?
- នៅក្នុងអន្តរបញ្ញត្តិនៃប្រកាស (ប្រការ ៣៥ នៃប្រកាសលេខ៤២៧៤) មានភាពមិនច្បាស់លាស់ថាតើបុគ្គលិកដែលត្រូវតែងតាំងមុនពេលអនុម័តលក្ខន្តិកៈស្តីពីមន្ត្រីរាជការនៅថ្នាក់ក្រោមជាតិ ត្រូវមានការយល់ព្រមពីក្រសួងមហាផ្ទៃ ។ ប្រសិនបើបែបនេះមែន វាជាការជ្រៀតជ្រែកជាដុំកំភួនទៅលើស្វ័យភាពរបស់ក្រុមប្រឹក្សា ហើយមិនស្របនឹងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រង់មាត្រា ១៧៧ ។ តើបទប្បញ្ញត្តិទាំងនេះ មិនស៊ីសង្វាក់គ្នាឬទេ? ប្រសិនបើមែន តើត្រូវ ដោះស្រាយភាពមិនស៊ីសង្វាក់គ្នានេះយ៉ាងដូចម្តេច ដោយគិតថាច្បាប់មានអានុភាពលើប្រកាស?

## វគ្គទី ២:

## មេរៀនសង្ខេប

- ✓ រចនាសម្ព័ន្ធចាត់តាំងរបស់រដ្ឋបាលនៅថ្នាក់ក្រោមជាតិនីមួយៗ មានលក្ខណៈប្រហាក់ប្រហែលគ្នា។ ទោះជាយ៉ាងណាក្តី ដោយសារតួនាទីរបស់ថ្នាក់នីមួយៗ មានភាពខុសគ្នាទៅតាមទិដ្ឋភាពសំខាន់ៗមួយចំនួនមានភាពខុសគ្នាខ្លះលើរចនាសម្ព័ន្ធរបស់រដ្ឋបាលតាមថ្នាក់នីមួយៗ។

- ✓ រដ្ឋបាលខេត្តមានទីចាត់ការដែលត្រូវចែកជាការិយាល័យ។ ទីចាត់ការនីមួយៗ មាននាយក និងនាយករងមិនលើសពីពីរនាក់។ ការិយាល័យនីមួយៗ មានប្រធាន និងអនុប្រធានមិនលើសពីពីរនាក់។

- ✓ ប្រធានការិយាល័យនៅក្នុងសាលាខេត្តមានគណនេយ្យភាពចំពោះនាយកទីចាត់ការ។ នាយកទីចាត់ការមានគណនេយ្យភាពចំពោះនាយករដ្ឋបាល។ នាយករដ្ឋបាលមានគណនេយ្យភាពចំពោះក្រុមប្រឹក្សា និងគណៈអភិបាល ។

- ✓ សាលាក្រុង និងស្រុកមានការិយាល័យ។ ការិយាល័យនីមួយៗមានប្រធាន និងអនុប្រធានមិនលើសពីពីរនាក់ ។

- ✓ ប្រធានការិយាល័យសាលាក្រុង ឬសាលាស្រុកមានគណនេយ្យភាពចំពោះនាយករដ្ឋបាល។ នាយករដ្ឋបាលមានគណនេយ្យភាពចំពោះក្រុមប្រឹក្សា និងគណៈអភិបាល។

- ✓ ប្រសិនបើក្រុមប្រឹក្សាមានបំណងបង្កើតទីចាត់ការ ឬការិយាល័យថ្មី ឬរៀបចំឡើងវិញ ឬរំសាយទីចាត់ការ ឬការិយាល័យដែលមានស្រាប់ អភិបាល ត្រូវធ្វើសំណើទៅក្រសួងមហាផ្ទៃដើម្បីសម្រេច។

- ✓ ក្រុង ឬស្រុកដែលបានដំណើរការការិយាល័យច្រកចេញចូលតែមួយ និងការិយាល័យប្រជាពលរដ្ឋរួចហើយ ត្រូវបន្តដំណើរការការិយាល័យទាំងនេះទៀត។

- ✓ ក្រសួងមហាផ្ទៃមានការទទួលខុសត្រូវក្នុងការផ្ទេរសមាហរណកម្មបុគ្គលិកដែលមានស្រាប់នៅក្នុងក្របខ័ណ្ឌមន្ត្រីរាជការនៅថ្នាក់ក្រោមជាតិរបស់ក្រសួងមហាផ្ទៃទៅក្នុងរដ្ឋបាលថ្នាក់ក្រោមជាតិថ្មី (ការរៀបចំកែសម្រួលបុគ្គលិកឡើងវិញ)។ ដូច្នេះបុគ្គលិករបស់រដ្ឋបាលដែលបានតែងតាំងពីមុនមកត្រូវបានរៀបចំកែសម្រួលឡើងវិញឱ្យទៅជាបុគ្គលិករបស់ក្រុមប្រឹក្សា និងរដ្ឋបាលថ្មី។

# មេរៀនសម្រាប់ការយល់ដឹង និង ការបណ្តុះបណ្តាលអំពី ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

## មេរៀនទី ១៣៖

## ការផ្ទេរមុខងារឱ្យក្រុមប្រឹក្សា

**វគ្គទី ១ :**

១. សេចក្តីផ្តើម

២. ដំណើរការនៅថ្នាក់ជាតិសម្រាប់ការពិនិត្យមុខងារឡើងវិញ

៣. ការធ្វើឱ្យក្រុមប្រឹក្សាឃុំ សង្កាត់ ត្រៀមខ្លួនទទួលមុខងារថ្មី

៤. ការអនុវត្តមុខងាររបស់ក្រុមប្រឹក្សា

## ផ្នែកទី ១: សេចក្តីផ្តើម

✓ បន្ទាប់ពីការបោះឆ្នោតលើកទីមួយដើម្បីជ្រើសរើសក្រុមប្រឹក្សាថ្មី ក្រុមប្រឹក្សាថ្មីបានជំនួសរដ្ឋបាលដែលត្រូវតែងតាំងឡើងនៅក្នុងដែនដីរបស់ខ្លួន។ ក្រុមប្រឹក្សាថ្មី និងគណៈអភិបាលថ្មី**បានជំនួសមុខងាររបស់អភិបាល**។ បុគ្គលិកដែលបំពេញការងារនៅក្នុងអង្គភាពរបស់រដ្ឋបាលដែលត្រូវតែងតាំងនៅរាជធានីភ្នំពេញ ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវបានរៀបចំកែសម្រួលរៀបចំឡើងវិញឱ្យក្រុមប្រឹក្សាថ្មី (មាត្រា ២៧៧, ២៧៨, ២៨១ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ប្រការ ៦, ៧ នៃប្រកាស ១២៤៩ ស្តីពីកិច្ចប្រជុំចូលកាន់តំណែង)។

✓ ក្រៅពីនេះ នៅក្នុងបណ្តាឆ្នាំខាងមុខ កម្ពុជានឹងឆ្លងកាត់**ដំណើរការពិនិត្យមើលឡើងវិញលើមុខងារគ្រប់គ្រងនៅក្នុងវិស័យទាំងអស់**។ គោលបំណងនៃដំណើរការនេះ គឺដើម្បីកំណត់មុខងារណាដែលគួរផ្ទេរឱ្យ និងអនុវត្តដោយក្រុមប្រឹក្សានៅថ្នាក់ក្រោមជាតិ (**រួមទាំងក្រុមប្រឹក្សាឃុំ សង្កាត់**) ហើយមុខងារណាដែលគួររក្សាទុក ហើយអនុវត្តដោយក្រសួងខ្សែបណ្តោយ និងអង្គភាពនៅថ្នាក់ក្រោមជាតិរបស់ខ្លួន។ ដំណើរការពិនិត្យមើលឡើងវិញលើមុខងារគ្រប់គ្រងសម្រាប់ផ្ទេរឱ្យក្រុមប្រឹក្សា **អាចចំណាយ ពេលរហូតដល់ ឬច្រើនជាង ១០ ឆ្នាំ** (មាត្រា ២០០, ២១៣-២៤០ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មាត្រា ៣ នៃអនុក្រឹត្យស្តីពីការបង្កើត គ.ជ.អ.ប)។

**ឧទាហរណ៍នៃមុខងារដែលអាចមាន**

- ផ្តល់ការអប់រំនៅបឋមសិក្សា
- ធ្វើឱ្យទទួលបានទឹកស្អាត
- ផ្តល់ការទទួលស្គាល់លើឱសថស្ថាន
- អនុវត្តបទបញ្ជាលើការនេសាទខុសច្បាប់
- សាងសង់ និងជួសជុលប្រព័ន្ធស្រោចស្រព
- ផ្តល់លិខិតអនុញ្ញាតអនាម័យ...

✓ **ហេតុអ្វីបានជាផ្តល់មុខងារគ្រប់គ្រងនៅក្នុងវិស័យផ្សេងៗ ឱ្យក្រុមប្រឹក្សា?** ការផ្តល់មុខងារគ្រប់គ្រងច្រើនដល់ក្រុមប្រឹក្សានៅថ្នាក់ក្រោមជាតិដើម្បីអនុវត្ត គឺក្នុងបំណងបំរើឱ្យ**ទិសដៅសំខាន់ៗ ទាំងពីរនៃកំណែទម្រង់ វិមជ្ឈការ និងវិសហមជ្ឈការ**គឺ:

- ពង្រឹង និងពង្រីកលទ្ធិប្រជាធិបតេយ្យនៅមូលដ្ឋាន
- ជំរុញការអភិវឌ្ឍនៅមូលដ្ឋាន និងរួមចំណែកចំពោះការកាត់បន្ថយភាពក្រីក្រ ( ក្របខ័ណ្ឌយុទ្ធសាស្ត្រ ទំព័រទី ៨) ។

✓ **ក្រុមប្រឹក្សានៅថ្នាក់ក្រោមជាតិ**ដែលមានមុខងារច្រើន អាច **ពង្រឹង និងពង្រីកលទ្ធិប្រជាធិបតេយ្យនៅមូលដ្ឋាន**ពីព្រោះ:

- នៅពេលមុខងារត្រូវបានផ្ទេរឱ្យក្រុមប្រឹក្សា ការទទួលខុសត្រូវលើការធ្វើសេចក្តីសម្រេចអំពីមុខងារទាំងនេះ ក៏ត្រូវផ្ទេរផងដែរ ។
- ប្រជាពលរដ្ឋស្ថិតនៅកាន់តែកៀកនឹងក្រុមប្រឹក្សានៅថ្នាក់ក្រោមជាតិ ជាងនៅថ្នាក់ជាតិ ហើយជាលទ្ធផល ប្រជាពលរដ្ឋមាន**ឱកាសកាន់តែច្រើននៅថ្នាក់ក្រោមជាតិដើម្បីសំដែងមតិ និងធ្វើឱ្យមានឥទ្ធិពលទៅលើការធ្វើសេចក្តីសម្រេច ។**

> **ឧទាហរណ៍**
>
> ប្រសិនបើមុខងារប្រតិបត្តិគ្លីនិកសុខភាព ត្រូវបានផ្ទេរឱ្យក្រុមប្រឹក្សាស្រុក ប្រជាពលរដ្ឋនៅក្នុងស្រុកនឹងមានឱកាសដើម្បីចូលរួមនៅក្នុងការធ្វើសេចក្តីសម្រេចអំពីរបៀបចាត់ចែងគ្លីនិកសុខភាព ដូចជាតាមរយៈការចូលរួមនៅក្នុងកិច្ចប្រជុំរបស់ក្រុមប្រឹក្សា ។
>
> នៅក្នុងសេចក្តីសម្រេចទាំងអស់របស់ខ្លួនអំពីរបៀបប្រតិបត្តិគ្លីនិកសុខភាព ក្រុមប្រឹក្សាស្រុកនឹងមានគណនេយ្យភាពចំពោះប្រជាពលរដ្ឋរបស់ខ្លួន ។ ប្រជាពលរដ្ឋអាចទទួលបានផលប្រយោជន៍ពីយន្តការគណនេយ្យភាព ដើម្បីត្អូញត្អែរអំពីការខ្វះខាត រួមទាំងការបោះឆ្នោតទំលាក់ក្រុមប្រឹក្សាស្រុក នៅពេលបោះឆ្នោតលើកក្រោយ ។

- ដើម្បីឱ្យប្រជាពលរដ្ឋ អាចមានឥទ្ធិពលទៅលើការធ្វើសេចក្តីសម្រេចនៅមូលដ្ឋាន និងដើម្បីឱ្យក្រុមប្រឹក្សាអាចឆ្លើយតបនឹងតម្រូវការនៅមូលដ្ឋាន ក្រុមប្រឹក្សាត្រូវមាន**សិទ្ធិអំណាច និងឆន្ទានុសិទ្ធិ**គ្រប់គ្រាន់ក្នុងការអនុវត្តមុខងាររបស់ខ្លួន និងប្រើប្រាស់ធនធានរបស់ខ្លួន ។ ការមិនមានសិទ្ធិអំណាច និងឆន្ទានុសិទ្ធិ ក្រុមប្រឹក្សានឹងមិនមាន**ឱកាសប្រកាន់យកជម្រើស និងធ្វើសេចក្តីសម្រេចផ្អែកនយោបាយ**ដែលឆ្លើយតបនឹងតម្រូវការពិតប្រាកដរបស់ប្រជាពលរដ្ឋខ្លួនឡើយ ។

✓ **ក្រុមប្រឹក្សានៅថ្នាក់ក្រោមជាតិ**ដែលមានមុខងារគ្រប់គ្រងច្រើនក៏អាច**ជំរុញការអភិវឌ្ឍមូលដ្ឋាន និងរួមចំណែកចំពោះការកាត់បន្ថយភាពក្រីក្រផងដែរ**ពីព្រោះ

- ក្រុមប្រឹក្សានៅថ្នាក់ក្រោមជាតិ **ត្រូវពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋរបស់ខ្លួន** និងផ្តល់ឱកាសឱ្យប្រជាពលរដ្ឋ **បង្ហាញពីតម្រូវការរបស់ខ្លួន**។ ដូច្នេះតម្រូវការនៅមូលដ្ឋានអាចត្រូវកំណត់។

- នៅពេលស្គាល់តម្រូវការនៅមូលដ្ឋាន ក្រុមប្រឹក្សាអាចអភិវឌ្ឍយុទ្ធសាស្ត្រដើម្បីឆ្លើយតបនឹងតម្រូវការទាំងនេះទៅតាមរបៀបដែលស្របទៅតាម**លក្ខខណ្ឌស្ថានភាព និងចំណង់ចំណូលចិត្តជាក់ស្តែងនៅមូលដ្ឋាន**។ ការមានមុខងារនៅក្នុងវិស័យផ្សេងៗ មានន័យថាក្រុមប្រឹក្សាអាច**កំណត់អាទិភាពនៅតាមវិស័យនានា**។ ឧទាហរណ៍ ប្រសិនបើពិនិត្យឃើញច្បាស់ថា ប្រជាពលរដ្ឋចង់បានគ្លីនិកសុខភាពជាងអាគារ សាលារៀនថ្មី ក្រុមប្រឹក្សាអាចផ្តោតការយកចិត្តទុកដាក់ និងធនធានហិរញ្ញវត្ថុឆន្ទានុសិទ្ធិរបស់ខ្លួនទៅលើការបង្កើតគ្លីនិកសុខភាព។

**ដំណោះស្រាយនៅមូលដ្ឋាន ចំពោះតម្រូវការនៅមូលដ្ឋាន**

ស្រុកចំនួនបីដោយឡែកពីគ្នា ជួបបញ្ហាដូចគ្នាគឺ **កុមារនៅក្នុងស្រុកមិនចូលសាលារៀន**។

នៅក្នុងស្រុកទីមួយ សិស្សមិនចូលសាលារៀនពីព្រោះសម្រាប់កុមារជាច្រើនព្រោះផ្លូវដីឆ្ងាយទៅកាន់សាលារៀនឆ្ងាយមិនបានក្រាលកៅស៊ូ និងមានគ្រោះថ្នាក់នៅរដូវវស្សា។ ក្រុមប្រឹក្សាស្រុកបានសម្រេចក្រាលកៅស៊ូដើម្បីដោះស្រាយបញ្ហាកុមារមិនចូលសាលារៀន។

នៅក្នុងស្រុកទីពីរ គឺកុមារីភាគច្រើនមិនចូលសាលារៀនពីព្រោះមិនមានបង្គន់អនាម័យនៅសាលារៀនក្នុងស្រុក។ ក្រុមប្រឹក្សាស្រុកបានសម្រេចធ្វើបង្គន់អនាម័យនៅសាលារៀន ដើម្បីដោះស្រាយបញ្ហាកុមារីមិនចូលសាលារៀន។

ស្រុកទីបីមានទំហំធំ ហើយកុមារមួយចំនួនត្រូវធ្វើដំណើរឆ្ងាយដើម្បីទៅសាលារៀនរបស់ខ្លួន។ ក្រុមប្រឹក្សាស្រុកសម្រេចថាតើត្រូវទិញរថយន្តមួយ ឬច្រើនគ្រឿងដើម្បីដឹកកុមារទៅសាលារៀន។ ត្រូវសាងសង់សាលារៀនមួយទៀត។

- ការមានអ្នកធ្វើសេចក្តីសម្រេចនៅមូលដ្ឋានក៏អាចមានន័យផងដែរថា អភិបាលកិច្ចមានលក្ខណៈកាន់តែ**តម្លាភាព**។ ប្រជាពលរដ្ឋគួរស្ថិតនៅក្នុងទីតាំងកាន់តែប្រសើរក្នុងការពិនិត្យមើលអ្វីដែលក្រុមប្រឹក្សានៅថ្នាក់ក្រោមជាតិរបស់ខ្លួនកំពុងធ្វើ ឬមិនធ្វើ និងពីរបៀបដែលក្រុមប្រឹក្សាបំពេញការងារ។ ប្រការនេះធ្វើឱ្យប្រជាពលរដ្ឋមានជំហរកាន់តែប្រសើរក្នុងការធ្វើឱ្យក្រុមប្រឹក្សារបស់ខ្លួនមាន**គណនេយ្យភាព** ដើម្បីឱ្យក្រុមប្រឹក្សាអាចកែលំអការងាររបស់ខ្លួនដើម្បីឆ្លើយតបនឹងតម្រូវការរបស់ប្រជាពលរដ្ឋកាន់តែប្រសើរ។

✓ **តើការផ្ទេរមុខងារគ្រប់គ្រងមានផលប៉ះពាល់ដូចម្តេចមកលើក្រសួង?**

- ជាការសំខាន់ណាស់ដែលវិស័យនីមួយៗ គិតថាមាន**ក្រុមប្រឹក្សាថ្មីនៅថ្នាក់ក្រោមជាតិ** ជាពិសេសនៅពេលរៀបចំយុទ្ធសាស្ត្រកំណែទម្រង់របស់ខ្លួន។
- ក្រសួងនៅថ្នាក់ជាតិ គួរទទួលស្គាល់ថាក្រុមប្រឹក្សានៅមូលដ្ឋានស្ថិតនៅក្នុងទីតាំងយ៉ាងល្អក្នុងការ**មើលយល់និងឆ្លើយតប**ចំពោះតម្រូវការពិតប្រាកដរបស់ប្រជាពលរដ្ឋ។
- ក្រសួងនៅថ្នាក់ជាតិ ត្រូវ**អនុវត្តតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ** ដែលតម្រូវថាមុខងារគ្រប់គ្រងនៅក្នុងវិស័យនានាត្រូវពិចារណាសម្រាប់ផ្ទេរផែនការដែលសមស្របឱ្យក្រុមប្រឹក្សា។
- គេរំពឹងថាការផ្ទេរមុខងារឱ្យក្រុមប្រឹក្សាថ្មីពាក់ព័ន្ធនឹង**ការកែប្រែជាជុំកំភួនលើរបៀបដែលក្រសួងគិត**អំពីវិស័យរបស់ខ្លួន។

"រូបមន្ត" ខាងក្រោមបកស្រាយបន្ថែមទៀតអំពី**របៀបមុខងារគ្រប់គ្រង ទាក់ទងជាមួយនឹងការអភិវឌ្ឍ**។ "រូបមន្ត" បង្ហាញថាមានធាតុផ្សំសំខាន់ៗចំនួនបួនសម្រាប់កែលំអការផ្តល់សេវាសាធារណៈ និងគុណភាពនៃជីវិតរបស់ប្រជាពលរដ្ឋ និងរួមចំណែកចំពោះការអភិវឌ្ឍ។

### "ធាតុ" សំខាន់ៗ សម្រាប់កែលំអសេវា និងគុណភាពនៃជីវិតរបស់ប្រជាពលរដ្ឋ

**ក្រុមប្រឹក្សានៅមូលដ្ឋាន**

**+ មុខងាររបស់ក្រុមប្រឹក្សាច្បាស់លាស់ក្នុងការផ្តល់សេវា**

**+ ធនធានស្របតាមមុខងារ (ហិរញ្ញវត្ថុ បុគ្គលិក ទ្រព្យសម្បត្តិ)**

**+ ឱកាសសម្រាប់ឱ្យប្រជាពលរដ្ឋ មានឥទ្ធិពលទៅលើសេចក្តីសម្រេច**

**+ យន្តការសម្រាប់តម្លាភាព និងគណនេយ្យភាពចំពោះប្រជាពលរដ្ឋ**

**= ការកែលំអសេវា និងគុណភាពនៃជីវិតរបស់ប្រជាពលរដ្ឋ**

✓ មេរៀននេះ ផ្តោតទៅលើធាតុផ្សំពីរដំបូងគឺៈ មុខងារច្បាស់លាស់របស់ក្រុមប្រឹក្សាក្នុងការផ្តល់សេវា និងធនធានស្របតាមមុខងារ។

## ផ្នែកទី ២៖ ដំណើរការនៅថ្នាក់ជាតិសម្រាប់ការពិនិត្យមើលឡើងវិញលើមុខងារ

**ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ**

**មាត្រា ១៩២ ដល់ ២០០, ២១៣ ដល់ ២៤០**

### គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

✓ គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប) ត្រូវបានបង្កើតឡើងដោយព្រះរាជក្រឹត្យ ។ គ.ជ.អ.ប **មានការទទួលខុសត្រូវលើការអនុវត្តច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ** ។ គ.ជ.អ.ប ជំនួសគណៈកម្មាធិការជាតិដឹកនាំការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការមានឈ្មោះជាភាសាអង់គ្លេស ថា NCDD ដែលមាននៅពេលសព្វថ្ងៃ (មាត្រា ១៩២ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មាត្រា ១ នៃព្រះរាជក្រឹត្យស្តីពីការបង្កើត គ.ជ.អ.ប) ។

✓ **សមាជិករបស់** គ.ជ.អ.ប មាន

- រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ប្រធាន
- រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អនុប្រធាន
- រដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី អនុប្រធាន
- រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- រដ្ឋមន្ត្រីក្រសួងផែនការ
- រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ
- រដ្ឋមន្ត្រីក្រសួងកិច្ចការនារី
- រដ្ឋមន្ត្រីក្រសួងសុខាភិបាល
- រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា
- រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

- រដ្ឋលេខាធិការមួយរូបមកពីក្រសួងមហាផ្ទៃ
- រដ្ឋលេខាធិការមួយរូបមកពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- តំណាងមួយរូបមកពីក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ប្រធានលេខាធិការដ្ឋាន គ.ជ.អ.ប

(មាត្រា ២ នៃព្រះរាជក្រឹត្យស្តីពីការបង្កើត គ.ជ.អ.ប)។

✓ គ.ជ.អ.ប អាចស្នើសុំសមាជិកបន្ថែមទៀតទៅតាមការចាំបាច់។ គ.ជ.អ.ប ក៏អាចអញ្ជើញរដ្ឋមន្ត្រីក្រសួងផ្សេងទៀត ឬ អាជ្ញាធរផ្សេងទៀតឱ្យចូលរួមនៅក្នុងកិច្ចប្រជុំរបស់ គ.ជ.អ.ប ឬ សហការជាមួយ គ.ជ.អ.ប ផងដែរ (មាត្រា ២ នៃព្រះរាជក្រឹត្យស្តីពីការបង្កើត គ.ជ.អ.ប)។

✓ គ.ជ.អ.ប មាន **អនុគណៈកម្មាធិការ** ចំនួនបួន គឺៈ

- **អនុគណៈកម្មាធិការមុខងារ និងធនធានៈ** ជួយ និងផ្តល់យោបល់ដល់ គ.ជ.អ.ប អំពីការងារទាក់ទងនឹងការកំណត់ និងការផ្ទេរមុខងារ និងធនធានដល់ក្រុមប្រឹក្សាថ្នាក់ក្រោមជាតិ
- **អនុគណៈកម្មាធិការកិច្ចការសារពើពន្ធ និងហិរញ្ញវត្ថុៈ** ជួយ និងផ្តល់យោបល់ដល់ គ.ជ.អ.ប អំពីការងារទាក់ទងនឹងកិច្ចការសារពើពន្ធ និងហិរញ្ញវត្ថុរបស់ក្រុមប្រឹក្សាថ្នាក់ក្រោមជាតិ
- **អនុគណៈកម្មាធិការបុគ្គលិករបស់រដ្ឋបាលនៅថ្នាក់ក្រោមជាតិៈ** ជួយ និងផ្តល់យោបល់ដល់ គ.ជ.អ.ប អំពីការងារទាក់ទងនឹងការរៀបចំកែសម្រួលបុគ្គលិកឡើងវិញ និងក្របខ័ណ្ឌបុគ្គលិកសម្រាប់ក្រុមប្រឹក្សាថ្នាក់ក្រោមជាតិ និងទាក់ទងនឹងការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្សសម្រាប់ក្រុមប្រឹក្សាថ្នាក់ក្រោមជាតិ។
- **អនុគណៈកម្មាធិការផែនការអភិវឌ្ឍន៍ថ្នាក់ក្រោមជាតិៈ** ជួយ និងផ្តល់យោបល់ដល់ គ.ជ.អ.ប អំពីការងារទាក់ទងនឹងផែនការអភិវឌ្ឍ និងកម្មវិធីវិនិយោគរបស់ក្រុមប្រឹក្សាថ្នាក់ក្រោមជាតិ។

  (មាត្រា ២, ៩-១២ នៃអនុក្រឹត្យស្តីពីការបង្កើតអនុគណៈកម្មាធិការ គ.ជ.អ.ប)។

✓ សមាជិករបស់អនុគណៈកម្មាធិការនីមួយៗមានចែងនៅក្នុងអនុក្រឹត្យ។ អនុគណៈកម្មាធិការនីមួយៗមានតំណាងរបស់សមាគមអាជ្ញាធរមូលដ្ឋានដែលបង្កើតឡើងសម្រាប់ក្រុមប្រឹក្សានៅតាមថ្នាក់នីមួយៗជាសមាជិក។ បច្ចុប្បន្ននេះមានសមាគមអាជ្ញាធរមូលដ្ឋានមួយគឺ**សម្ព័ន្ធភាពជាតិឃុំ សង្កាត់**។ ដូច្នេះ តំណាងរបស់សម្ព័ន្ធភាព

ជាតិឃុំ សង្កាត់ ជាសមាជិករបស់អនុគណៈកម្មាធិការនីមួយៗ របស់ គ.ជ.អ.ប (មាត្រា ៣, ៥ នៃអនុក្រឹត្យស្តីពីការបង្កើតអនុគណៈកម្មាធិការរបស់ គ.ជ.អ.ប)។

- ✓ មុនពេលផ្តល់អនុសាសន៍ដល់ គ.ជ.អ.ប អនុគណៈកម្មាធិការត្រូវពិគ្រោះយោបល់ជាមួយក្រសួងពាក់ព័ន្ធ និងស្ថាប័នផ្សេងទៀតរបស់រាជរដ្ឋាភិបាល។ ដូច្នេះ មុនពេលផ្តល់អនុសាសន៍អំពីការផ្ទេរមុខងារតាមវិស័យ អនុគណៈកម្មាធិការមុខងារ និងធនធានត្រូវពិគ្រោះយោបល់ជាមួយក្រសួងវិស័យដែលពាក់ព័ន្ធ ឬក្រសួងនានា (មាត្រា ១៧ នៃអនុក្រឹត្យស្តីពីការបង្កើតអនុគណៈកម្មាធិការរបស់ គ.ជ.អ.ប)។
- ✓ អនុគណៈកម្មកាធិការអាចបង្កើត**ក្រុមការងារបច្ចេកទេស**ដើម្បីសិក្សា និងរាយការណ៍លើកិច្ចការដែលស្ថិត នៅក្នុងវិសាលភាពនៃសិទ្ធិអំណាចរបស់អនុគណៈកម្មាធិការ (មាត្រា ១៩៦ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មាត្រា ១៦ នៃព្រះរាជក្រឹត្យស្តីពីការបង្កើត គ.ជ.អ.ប មាត្រា ៧នៃ អនុក្រឹត្យស្តីពីការបង្កើតអនុគណៈកម្មាធិការរបស់ គ.ជ.អ.ប )។
- ✓ ក្រសួងនីមួយៗ ដែលជាសមាជិករបស់ គ.ជ.អ.ប ត្រូវបង្កើត**ក្រុមការងារវិមជ្ឈការ និងវិសហមជ្ឈការ**។ ក្រុមការងារមានការទទួលខុសត្រូវចំពោះការរៀបចំគោលនយោបាយ និងយុទ្ធសាស្ត្រដើម្បីអនុវត្តច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងកម្មវិធីរបស់រាជរដ្ឋាភិបាលដើម្បីអនុវត្តច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។ ក្រុមការងារក៏ត្រូវគាំទ្រផងដែរដល់សកម្មភាពរបស់ គ.ជ.អ.ប និងអនុគណៈកម្មាធិការរបស់ គ.ជ.អ.ប(មាត្រា ៨ នៃអនុក្រឹត្យស្តីពីការបង្កើតអនុគណៈកម្មាធិការ គ.ជ.អ.ប)។
- ✓ ក្រសួងពាក់ព័ន្ធផ្សេងទៀតក៏ត្រូវបានតម្រូវឱ្យបង្កើតក្រុមការងារវិមជ្ឈការ និងវិសហមជ្ឈការផងដែរ ដើម្បីសម្របសម្រួល និងគាំទ្រការអនុវត្តច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌនៅក្នុងក្រសួង (មាត្រា ១៧ នៃព្រះរាជក្រឹត្យស្តីពីការបង្កើត គ.ជ.អ.ប)។
- ✓ ការទទួលខុសត្រូវជាគន្លឹះរបស់ គ.ជ.អ.ប គឺត្រូវដឹកនាំ និងត្រួតពិនិត្យដំណើរការ**ពិនិត្យមើលឡើងវិញលើមុខងារគ្រប់គ្រង**សម្រាប់ផ្ទេរឱ្យក្រុមប្រឹក្សា (មាត្រា ២០០ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មាត្រា ៣ (៤) នៃព្រះរាជក្រឹត្យស្តីពីការបង្កើត គ.ជ.អ.ប )។

## ដំណើរការសម្រាប់ការពិនិត្យមើលឡើងវិញលើមុខងារ

✓ ជាការច្បាស់ណាស់ថាអនុគណៈកម្មាធិការមុខងារ និងធនធានរបស់ គ.ជ.អ.ប នឹងមានការពាក់ព័ន្ធនៅក្នុងដំណើរការពិនិត្យមើលឡើងវិញលើមុខងារ ។ គ.ជ.អ.ប ក៏ត្រូវសម្រេចផងដែរប្រសិនបើអនុគណៈកម្មាធិការផ្សេងទៀតត្រូវដើរតួនាទី និងរបៀបពាក់ព័ន្ធជាមួយក្រុមការងារបច្ចេកទេសរបស់អនុគណៈកម្មការ ។

✓ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ កំណត់ថា**ក្រសួងតាមវិស័យ**ត្រូវ**ចូលរួម**នៅក្នុងដំណើរការពិនិត្យមើលឡើងវិញលើមុខងារដែលអាចផ្ទេរឱ្យក្រុមប្រឹក្សា ( មាត្រា ១៩៥ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មាត្រា ៣ (៤) នៃព្រះរាជក្រឹត្យស្តីពីការបង្កើត គ.ជ.អ.ប មាត្រា ១៧ នៃអនុក្រឹត្យស្តីពីការបង្កើតអនុគណៈកម្មាធិការ គ.ជ.អ.ប )។ ការចូលរួមរបស់ក្រសួងតាមវិស័យមានសារៈសំខាន់ណាស់ ពីព្រោះមុខងារដែលកំពុងអនុវត្តដោយក្រសួងតាមវិស័យនឹងត្រូវពិនិត្យមើលឡើងវិញសម្រាប់ផ្ទេរឱ្យក្រុមប្រឹក្សា។ គេនឹងកំណត់ថាតើតួនាទីអ្វីដែលក្រុមការងារវិមជ្ឈការ និងវិសហមជ្ឈការត្រូវប្រកាន់យកនៅក្នុងដំណើរការ ។




## សិទ្ធិទទួលបានមុខងារ

- ✓ **ក្រុមប្រឹក្សារាជធានីភ្នំពេញ និងក្រុមប្រឹក្សាខេត្ត ក្រុង ស្រុក និង ឃុំទាំងអស់** ទទួលបានមុខងារដោយផ្ទាល់ពីថ្នាក់ជាតិ ( មាត្រា ២១៧ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ) ។

- ✓ **ខណ្ឌ** ក៏ដូចជា**សង្កាត់**នៅរាជធានីភ្នំពេញ និងសង្កាត់នៅក្នុងក្រុងទទួលបានមុខងារដោយប្រយោល (តាមរយៈការធ្វើប្រតិភូកម្ម) ពីក្រុមប្រឹក្សារាជធានីភ្នំពេញ ឬក្រុមប្រឹក្សាក្រុង (មាត្រា ១០៨, ១១២ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ) ។ តាមវិធីនេះ ក្រុមប្រឹក្សារាជធានីភ្នំពេញ ឬក្រុមប្រឹក្សាក្រុងអាចធានាបានកាន់តែប្រសើរឱ្យមានការអភិវឌ្ឍទីប្រជុំជនដែលមានលក្ខណៈស៊ីសង្វាក់គ្នា និងមានលក្ខណៈឯកភាពគ្នា ។

- ✓ **សង្កាត់នៅក្នុងស្រុក** នឹងត្រូវចាត់ទុកដូចជាឃុំ ហើយនឹងមានសិទ្ធិទទួលបានមុខងារដោយផ្ទាល់ពីថ្នាក់ជាតិ ។

## ជំហាននៅក្នុងការពិនិត្យមើលឡើងវិញលើមុខងារដែលអាចផ្ទេរឱ្យក្រុមប្រឹក្សា

**ជំហានទី ១** គឺត្រូវ**ជ្រើសរើសវិស័យ** ដើម្បីធ្វើការពិនិត្យមើលឡើងវិញ។ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ កំណត់វិស័យជាអាទិភាពមួយចំនួនសម្រាប់ពិនិត្យមើលឡើងវិញ។ វិស័យជាអាទិភាពដែលបានកំណត់នៅក្នុងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ស្របទៅនឹងអាទិភាពដែលមានចែងនៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ឆ្នាំ ២០០៦-២០១០ គឺ

- ✓ កសិកម្ម
- ✓ ការអប់រំ
- ✓ ព្រៃឈើ ធនធានធម្មជាតិ និងបរិស្ថាន
- ✓ សុខាភិបាល អាហារូបត្ថម្ភ និងសេវាដល់ប្រជាពលរដ្ឋ
- ✓ ឧស្សាហកម្ម ការគាំទ្រដល់ការអភិវឌ្ឍសេដ្ឋកិច្ច
- ✓ ការប្រើប្រាស់ដីធ្លី
- ✓ ការផលិត និងការចែកចាយអគ្គីសនី
- ✓ ការគ្រប់គ្រងទឹក
- ✓ ហេដ្ឋារចនាសម្ព័ន្ធ និងមធ្យោបាយដែលចាំបាច់ដើម្បីគាំទ្រ និងសំរបសំរួលការទទួលខុសត្រូវទាំងនេះ
- ✓ តម្រូវការពិសេសរបស់រាជធានីភ្នំពេញ ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ រួមទាំងតម្រូវការទាក់ទងនឹងទេសចរណ៍ តំបន់ប្រវត្តិសាស្ត្រ និងបេតិកភ័ណ្ឌវប្បធម៌ ។

(មាត្រា ២១៥ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ)

**ជំហានទី២** គឺត្រូវ**កំណត់អ្នកដែលមានការពាក់ព័ន្ធនៅក្នុងដំណើរការ** រួមមានតួអង្គរបស់អាជ្ញាធរនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និងអ្នកពាក់ព័ន្ធមិនមែនរដ្ឋាភិបាល ។

**ជំហានទី៣** គឺទីមួយត្រូវ**កំណត់មុខងារ**នៅក្នុងវិស័យ។ ទីពីរត្រូវមានការសម្រេចថាតើ**មុខងារនីមួយៗនេះ ត្រូវផ្ទេរឱ្យក្រុមប្រឹក្សានៅថ្នាក់ណា**។

សម្រាប់មុខងារនីមួយៗ ត្រូវមានការសម្រេច ថាតើក្រុមប្រឹក្សានៅថ្នាក់ណាអាចអនុវត្តមុខងារយ៉ាងមានប្រសិទ្ធិភាព។ បន្ទាប់មកមុខងារ ត្រូវផ្ទេរឱ្យក្រុមប្រឹក្សានៅថ្នាក់នោះ។ ប្រសិនបើមិនមានក្រុមប្រឹក្សាដែលអាចអនុវត្តមុខងារយ៉ាងមានប្រសិទ្ធិភាពទេ មុខងារនោះត្រូវរក្សាទុកនៅថ្នាក់ជាតិ (មាត្រា ២០០, ២១៧, ២២០) នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ)។

**ក្របខ័ណ្ឌយុទ្ធសាស្រ្តសម្រាប់កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ និងផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិ គោលការណ៍សាប់ស៊ីឌីយ៉ារីធី**

ក្របខ័ណ្ឌយុទ្ធសាស្រ្តសម្រាប់កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការរបស់រាជរដ្ឋាភិបាល អនុម័តយកគោលការណ៍សាប់ស៊ីឌីយ៉ារីទី ហើយផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិ ក៏អនុម័តយកគោលការណ៍នេះដែរ។

ជាលក្ខណៈអន្តរជាតិ គោលការណ៍សាប់ស៊ីឌីយ៉ារីទីកំណត់ថា

✓ **មុខងារមួយ គួរផ្ទេរឱ្យថ្នាក់ក្រោមបំផុត** (ក្រុមប្រឹក្សាដែលនៅក្បែរនឹងប្រជាពលរដ្ឋ) **ដែលអាចអនុវត្តមុខងារនោះប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផល។**

ដូច្នេះ គេសង្ឃឹមថានៅពេលខាងមុខ មុខងារជាដុំកំភួន នឹងត្រូវផ្ទេរឱ្យក្រុមប្រឹក្សានៅថ្នាក់ក្រោមជាតិ។

**ជំហានទី៤** គឺត្រូវ**កំណត់ថាតើ**មុខងារនោះ មានលក្ខណៈជាកាតព្វកិច្ច ឬជាជម្រើស ។ **មុខងារជាកាតព្វកិច្ច** គឺជាមុខងារកំណត់ដោយលិខិតបទដ្ឋានដែលបង្ហាញយ៉ាងច្បាស់ពីតម្រូវការជាកាតព្វកិច្ចសម្រាប់ឱ្យក្រុមប្រឹក្សាអនុវត្តមុខងារ។ គេសង្ឃឹមថាមុខងារជាច្រើនទាក់ទងនឹងសេវាជាមូលដ្ឋាន និងសេវាសំខាន់ៗ នឹងត្រូវកំណត់ថាជាមុខងារជាកាតព្វកិច្ច ដែលក្រុមប្រឹក្សាត្រូវតែអនុវត្ត។

**មុខងារជាជម្រើស** គឺជាមុខងារដែលក្រុមប្រឹក្សាអាចជ្រើសរើសអនុវត្ត ឬជ្រើសរើសមិនអនុវត្ត (មាត្រា ២២១, ២២២, ២២៧ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ)។

**ឧទាហរណ៍**

ការផ្តល់ការអប់រំនៅបឋមសិក្សា គឺជាមុខងារដែលជាទូទៅមានលក្ខណៈ**ជាកាតព្វកិច្ច**។

ការសាងសង់សារៈមន្ទីរ គឺជាមុខងារដែលទំនងជាមានលក្ខណៈ**ជាជម្រើស**។

- **ជំហានទី៥ គឺត្រូវកំណត់ថាតើ** មុខងារមួយគួរត្រូវប្រគល់ ឱ្យក្រុមប្រឹក្សា(វិមជ្ឈការ) ឬធ្វើប្រតិភូកម្មឱ្យក្រុមប្រឹក្សា (វិសហមជ្ឈការឱ្យក្រុមប្រឹក្សា)។ នៅពេល**មុខងារដែលត្រូវបានប្រគល់**ត្រូវបានផ្ទេរ "ភាពជាម្ចាស់" លើមុខងារក៏ត្រូវផ្ទេរឱ្យក្រុមប្រឹក្សាផងដែរ(**វិមជ្ឈការ**)។ ក្រុមប្រឹក្សាមានឆន្ទានុសិទ្ធិជាអតិបរមា (ប៉ុន្តែមិនមែនទាំងស្រុង) នៅក្នុងការអនុវត្តមុខងារដែលបានប្រគល់។ **មុខងារដែលបានធ្វើប្រតិភូកម្ម** គឺត្រូវផ្ទេរឱ្យក្រុមប្រឹក្សាដោយក្រសួងដែលធ្វើប្រតិភូកម្ម។ ក្រសួងដែលធ្វើប្រតិភូកម្ម រក្សាទុកភាពជាម្ចាស់លើមុខងារ។ ដូច្នេះមុខងារដែលបានធ្វើប្រតិភូកម្មត្រូវអនុវត្តដោយក្រុមប្រឹក្សាក្នុងនាមក្រសួងដែលបានធ្វើប្រតិភូកម្ម។ ជាធម្មតា ក្រសួងដែលបានធ្វើប្រតិភូកម្មតម្រូវឱ្យក្រុមប្រឹក្សាអនុវត្តមុខងារអនុលោមទៅតាម *លក្ខខណ្ឌនៃប្រតិភូកម្ម* ដែលកម្រិតឆន្ទានុសិទ្ធិរបស់ក្រុមប្រឹក្សានៅក្នុងការអនុវត្តមុខងារនោះ។ **មុខងារជាកាតព្វកិច្ច** ត្រូវប្រគល់ឱ្យក្រុមប្រឹក្សា ប្រសិនបើក្រុមប្រឹក្សាមិនតម្រូវឱ្យមានការរួមចំណែកជាប្រចាំពីក្រសួងពាក់ព័ន្ធ។ បើមិនដូច្នេះទេ មុខងារជាកាតព្វកិច្ចនេះត្រូវធ្វើប្រតិភូកម្មវិញ។ **មុខងារជាជម្រើស**ត្រូវប្រគល់ឱ្យក្រុមប្រឹក្សា។ ដូច្នេះ មុខងារត្រូវផ្ទេរឱ្យក្រុមប្រឹក្សាតាមរយៈការប្រគល់ (វិមជ្ឈការ) ឬតាមរយៈប្រតិភូកម្ម (មាត្រា ២២៣ ដល់ ២២៨ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ)។

| | **មុខងារជាកាតព្វកិច្ច** | **មុខងារជាជម្រើស** |
|---|---|---|
| **មុខងារត្រូវផ្ទេរតាមការប្រគល់** (វិមជ្ឈការ) | មិនតម្រូវឱ្យមានការរួមចំណែកជាអចិន្ត្រៃយ៍ពីក្រសួងពាក់ព័ន្ធ | មុខងារជាជម្រើសទាំងអស់ត្រូវបានប្រគល់ |
| **មុខងារត្រូវផ្ទេរតាមការធ្វើប្រតិភូកម្ម** (វិសហមជ្ឈការទៅក្រុមប្រឹក្សា) | តម្រូវឱ្យមានការរួមចំណែកជាអចិន្ត្រៃយ៍ពីក្រសួងពាក់ព័ន្ធ | ∅ |
| | មាត្រា ២២២ ដល់ ២២៦ | មាត្រា ២២៧ ដល់ ២៣២ |

**ជំហានទី ៦** គឺត្រូវ**កំណត់ធនធាន**ដែលស្របនឹងមុខងារ ។ ធនធានដែលស្របនឹងហិរញ្ញវត្ថុ ត្រូវ "មានអម" ហើយផ្ទេរឱ្យក្រុមប្រឹក្សាទន្ទឹមនឹងពេលផ្ទេរមុខងារ។ ធនធានរួមមាន **ហិរញ្ញវត្ថុ** ដែលតម្រូវឱ្យមានដើម្បីអនុវត្តមុខងារ។

ហិរញ្ញវត្ថុដែលបានផ្ទេរក្លាយទៅជាហិរញ្ញវត្ថុរបស់ក្រុមប្រឹក្សា (មាត្រា ២០០, ២៣៥, ២៥០, ២៥១ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ)។ ធនធានរួមមាន**បុគ្គលិក**។ ក្រុមប្រឹក្សានឹងតម្រូវឱ្យមានបុគ្គលិកជំនាញដើម្បីអនុវត្តមុខងារដែលបានផ្ទេរ។ បុគ្គលិកជំនាញមានស្រាប់ដែលកំពុងបំពេញការងារជាមួយក្រសួងនឹងត្រូវផ្ទេរឱ្យក្រុមប្រឹក្សា។ បុគ្គលិកជំនាញទាំងនេះ នឹងក្លាយទៅជាបុគ្គលិករបស់ក្រុមប្រឹក្សា (មាត្រា ២០០, ២៣៥, ២៦២, ២៦៦ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ )។ ធនធានក៏មានបញ្ចូល**ទ្រព្យសម្បត្តិ**ផងដែរ។ ដើម្បីអនុវត្តមុខងារមួយចំនួនតម្រូវឱ្យមានទ្រព្យសម្បត្តិជាក់លាក់។ ទ្រព្យសម្បត្តិទាំងនេះត្រូវ "មានអម" ហើយផ្ទេរទៅឱ្យក្រុមប្រឹក្សាទន្ទឹមនឹងពេលផ្ទេរមុខងារ (មាត្រា ២០០, ២៣៥, ២៥៤ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ)។ ក្រៅពីនេះ នៅពេលផ្ទេរមុខងារ ក្រុមប្រឹក្សាអាចតម្រូវឱ្យមាន**ការអភិវឌ្ឍសមត្ថភាព**មួយចំនួនដើម្បីឱ្យក្រុមប្រឹក្សា អាចធ្វើសេចក្តីសម្រេចល្អប្រសើរ និងសេចក្តីសម្រេចដោយមានព័ត៌មានពេញលេញអំពីមុខងារដែលបានផ្ទេរឱ្យក្រុមប្រឹក្សា (មាត្រា ២០០, ២៣៥ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ )។

**ឧទាហរណ៍ - វិស័យកសិកម្ម**

ស្រមៃមើលថា ក្រុមប្រឹក្សាស្រុកទទួលបានមុខងារដើម្បីផ្តល់សេវាផ្សព្វផ្សាយកសិកម្ម។ នៅពេលមុខងារនេះត្រូវផ្ទេរឱ្យក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាស្រុកក៏ត្រូវទទួលបានផងដែរនូវៈ

- ***ហិរញ្ញវត្ថុ*** ដើម្បីផ្តល់សេវា រួមមានការចំណាយរដ្ឋបាល ការចំណាយប្រតិបត្តិការ (រួមទាំងប្រាក់បៀវត្ស) ការចំណាយទុន ការចំណាយលើការថែទាំជាប្រចាំ និងការចំណាយផ្សេងទៀត។
- ***បុគ្គលិក*** ដូចជាបុគ្គលិកផ្សព្វផ្សាយកសិកម្មមានស្រាប់ដែលកំពុងបំពេញការងារឱ្យក្រសួង។
- ***ទ្រព្យសម្បត្តិ*** ដែលទាក់ទងនឹងការងារផ្សព្វផ្សាយកសិកម្ម ដូចជា ឧបករណ៍ផ្សេងៗ។

**ជំហានទី ៧** គឺត្រូវ**អនុវត្តការផ្ទេរ**ជាក់ស្តែងលើមុខងារ និងធនធានដែលក្រសួងផ្តល់អោយក្រុមប្រឹក្សា។

ដំណើរការដែលមាន ៧ ជំហាននៅក្នុងការពិនិត្យមើលឡើងវិញលើមុខងារសម្រាប់ផ្ទេរឱ្យក្រុមប្រឹក្សា ត្រូវបានសង្ខេបនៅក្នុងដ្យាក្រាមខាងក្រោម។

## ការផ្ទេរមុខងារឱ្យក្រុមប្រឹក្សា



## ការទទួលខុសត្រូវផ្សេងទៀតរបស់ក្រសួងវិស័យ

✓ ក្រសួងត្រូវអភិវឌ្ឍ**គោលនយោបាយ ក្របខ័ណ្ឌច្បាប់ និងបទដ្ឋានតាមវិស័យដើម្បីដឹកនាំក្រុមប្រឹក្សាថ្មី**នៅក្នុងការអនុវត្តមុខងារដែលក្រសួងផ្ទេរឱ្យក្រុមប្រឹក្សា។ បទដ្ឋានអាចមានបញ្ចូលការកំណត់**បទដ្ឋានជាតិសម្រាប់សុវត្ថិភាព និងគុណភាព**។

| **ឧទាហរណ៍** |
|---|
| ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ នឹងមានបទដ្ឋានជាតិទាក់ទងនឹងសុវត្ថិភាពសម្រាប់ការសាងសង់អគារ។ បទដ្ឋានទាំងនេះ នឹងអនុវត្តនៅទូទាំងប្រទេស ពីព្រោះសុវត្ថិភាពនៃសំណង់អគារ មិនផ្អែកលើកាលៈទេសៈនៅមូលដ្ឋានឡើយ។ |
| ឧទាហរណ៍មួយទៀត ក្រសួងសុខាភិបាលអាចមានបទដ្ឋានជាតិទាក់ទងនឹងរបៀបស្តុកទុកវ៉ាក់សាំង។ ស្តង់ដារនេះក៏នឹងត្រូវអនុវត្តនៅទូទាំងប្រទេសផងដែរ ពីព្រោះការស្តុកទុកវ៉ាក់សាំងត្រឹមត្រូវ មិនផ្អែកលើកាលៈទេសៈនៅមូលដ្ឋានឡើយ។ |

**បញ្ហាដែលត្រូវដោះស្រាយ**

ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ចែងថា ក្រសួងវិស័យត្រូវចូលរួមនៅក្នុងដំណើការពិនិត្យមើលឡើងវិញ និងការផ្ទេរមុខងារ។ បទពិសោធន៍អន្តរជាតិបង្ហាញពី**សារៈសំខាន់ជាសារវ័ន្តនៅក្នុងការរួមចំណែករបស់ក្រសួងវិស័យ**ដោយសារមុខងារតាមវិស័យនឹងត្រូវពិនិត្យមើលឡើងវិញសម្រាប់ផ្ទេរឱ្យក្រុមប្រឹក្សា។ វាក៏ជាការសំខាន់ផងដែរដែលក្រសួងតាមវិស័យមានការចូលរួមចំណែកពីព្រោះក្រសួងតាមវិស័យនឹងផ្តល់ការអភិវឌ្ឍសមត្ថភាពនៅពេលខាងមុខ និងផ្តល់ការគាំទ្រដល់ក្រុមប្រឹក្សាដែលទទួលមុខងារនៅក្នុងវិស័យ។

នៅក្នុងគោលការណ៍ណែនាំសម្រាប់ដំណើរការពិនិត្យមើលឡើងវិញ និងការផ្ទេរមុខងារ តួនាទីរបស់ក្រសួងតាមវិស័យ និង**អ្នកពាក់ព័ន្ធផ្សេងទៀត** គួរត្រូវបានគូសបញ្ជាក់រួមមាន:

- តំណាងរបស់ក្រុមប្រឹក្សានៅថ្នាក់ក្រោមជាតិ
- តំណាងរបស់អង្គភាពក្រសួងខ្សែបណ្តោយនៅថ្នាក់ក្រោមជាតិ
- សមាគមអាជ្ញាធរមូលដ្ឋាន
- ស្ថាប័នសិក្សាទាក់ទងនឹងវិស័យជាក់លាក់ដែលត្រូវពិនិត្យមើលឡើងវិញ
- អង្គការសង្គមស៊ីវិលទាក់ទងនឹងវិស័យជាក់លាក់ដែលត្រូវពិនិត្យមើលឡើងវិញ
- អង្គការសង្គមស៊ីវិលដែលអាចបង្កើតសំលេងរបស់ស្ត្រី និងសម្លេងរបស់ក្រុមជនងាយរងគ្រោះរួមទាំងជនក្រីក្រ។

ការពិចារណាជាគន្លឹះបន្ថែមទៀតរួមមាន:

- ដំណើរការពិនិត្យមើលឡើងវិញលើមុខងារនៅក្នុង**ចក្ខុវិស័យរយៈពេលវែងសម្រាប់អភិបាលកិច្ចនៅថ្នាក់ក្រោមជាតិ** រួមមានទាក់ទងនឹង:

- ទំនាក់ទំនងនៅក្នុងចំណោមវិមជ្ឈការ ប្រតិភូកម្ម (វិសហមជ្ឈការទៅក្រុមប្រឹក្សា) និងវិសហមជ្ឈការទៅអង្គភាពក្រសួងខ្សែបណ្តោយ។
- ថាតើក្រុមប្រឹក្សានៅតាមថ្នាក់នីមួយៗ គួរមានតួនាទីច្រើនទៅលើអ្វីមួយ (ឧទាហរណ៍ ឃុំ ឬស្រុក គឺជាក្រុមប្រឹក្សាដែលមានតួនាទីច្រើនទៅលើការផ្តល់សេវា)

- ការធានាថា **គណនេយ្យភាពតាមបែបប្រជាធិបតេយ្យ** ត្រូវបានជំរុញតាមរយៈការផ្ទេរមុខងារ និងធនធានរួមជាមួយនឹងសិទ្ធិអំណាច និង**ឆន្ទានុសិទ្ធិ**គ្រប់គ្រាន់ដើម្បីអនុវត្តមុខងារ និងប្រើប្រាស់ធនធាន។
- ការយកចិត្តទុកដាក់ថា **សមធម៌** មិនទទួលផលប៉ះពាល់ជាអវិជ្ជមាន និងថាគោលការណ៍នៃ**ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ** ដឹកនាំការផ្ទេរសេចក្តីសម្រេច
- ការធានាថាមាន**និរន្តរភាពនៃសេវាដែលមានស្រាប់**នៅពេលពិនិត្យមើលឡើងវិញ និងផ្ទេរមុខងារ
- ការកំណត់នៅពេលដំបូងថាតើមានការងារអ្វីដែល**ត្រូវដកចេញពីការពិនិត្យមើលឡើងវិញ** ដូចជាការពារជាតិ ឬទំនាក់ទំនងអន្តរជាតិ
- ការអនុម័តយក**វិធីសាស្ត្រជាយុទ្ធសាស្ត្រចំពោះដំណាក់កាល**ពិនិត្យមើលឡើងវិញ និងផ្ទេរមុខងារ
- ការបង្កើត**សមត្ថភាពនៅក្នុងប្រទេស**ដើម្បីពិនិត្យមើលមុខងារឡើងវិញ។

## ផ្នែកទី ៣៖ ការធ្វើឱ្យក្រុមប្រឹក្សាឃុំ សង្កាត់ត្រៀមខ្លួនទទួលមុខងារថ្មី

✓ ដើម្បីធានាថា **ក្រុមប្រឹក្សាឃុំ សង្កាត់ ទទួលបានមុខងារ និងធនធានរបស់ខ្លួនផ្ទាល់** ក្រុមប្រឹក្សាស្រុក ត្រូវពិគ្រោះយោបល់ជាមួយក្រុមប្រឹក្សាឃុំ សង្កាត់នៅក្នុងស្រុកដើម្បី

- វាយតម្លៃសមត្ថភាពរបស់ក្រុមប្រឹក្សាឃុំ សង្កាត់នីមួយៗយ៉ាងតិចម្តងក្នុងមួយឆ្នាំ
- ធ្វើការអភិវឌ្ឍសមត្ថភាព និងការបណ្តុះបណ្តាលក្រុមប្រឹក្សាឃុំ សង្កាត់ និងបុគ្គលិករបស់ខ្លួនដោយផ្អែកលើលទ្ធផលនៃការវាយតម្លៃ។

(មាត្រា ១២២ នៃអនុក្រឹត្យ២១៦ អ.ន.ក្រ.បក ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក)។

✓ ដូចគ្នានេះដែរ **ក្រុមប្រឹក្សាក្រុង ត្រូវពិគ្រោះយោបល់ជាមួយក្រុមប្រឹក្សាសង្កាត់** នៅក្នុងក្រុង ដើម្បីឱ្យក្រុមប្រឹក្សាសង្កាត់ ទទួលបានការគាំទ្រដែលខ្លួនត្រូវការ ដើម្បីទទួលបានមុខងារដែលធ្វើប្រតិភូកម្មកាន់តែច្រើនថែមទៀតពីក្រុមប្រឹក្សាក្រុង ។

✓ នៅក្នុងការសម្រេចថាតើមុខងារអ្វីដែលត្រូវធ្វើប្រតិភូកម្មដល់ក្រុមប្រឹក្សាសង្កាត់ ក្រុមប្រឹក្សាក្រុង ត្រូវពិគ្រោះយោបល់ជាមួយក្រុមប្រឹក្សាសង្កាត់ ដើម្បីពិភាក្សា**ថាតើមុខងារណាដែលសមស្រប**សម្រាប់ធ្វើប្រតិភូកម្ម និងមុខងារណាដែលអាចអនុវត្តយ៉ាងមានប្រសិទ្ធិភាពដោយក្រុមប្រឹក្សាសង្កាត់។

✓ ក្រុមប្រឹក្សាក្រុង ត្រូវផ្តល់**មធ្យោបាយសំភារៈ និងធនធាន** (រួមទាំងធនធានហិរញ្ញវត្ថុ និងមនុស្ស ការបណ្តុះបណ្តាល

> ដោយហេតុថា ក្រុមប្រឹក្សាសង្កាត់ ត្រូវបានបោះឆ្នោតជ្រើសរើសឡើងដោយប្រជាពលរដ្ឋផ្ទាល់ ហើយក្រុមប្រឹក្សាក្រុង ត្រូវបោះឆ្នោតជ្រើសឡើងជាអសកល ជាការសំខាន់ដែលក្រុមប្រឹក្សាសង្កាត់មាន**សិទ្ធិអំណាច និងឆន្ទានុសិទ្ធិ**គ្រប់គ្រាន់ដើម្បីអនុវត្តមុខងាររបស់ខ្លួន ហើយប្រើប្រាស់ធនធានរបស់ខ្លួនទៅតាមរបៀបដែលឆ្លើយតបនឹងតម្រូវការពិតប្រាកដរបស់ប្រជាពលរដ្ឋរបស់ខ្លួន។ **មុខងារដែលបានធ្វើប្រតិភូកម្មអាចដាក់បញ្ចូលសិទ្ធិអំណាច និងឆន្ទានុសិទ្ធិប្រភេទនោះ។**
>
> វាក៏ជាការសំខាន់ផងដែរដែលក្រុមប្រឹក្សាសង្កាត់ មានមតិយោបល់ក្នុងនាមប្រជាពលរដ្ឋរបស់ខ្លួនទៅលើរបៀបដែលក្រុមប្រឹក្សាក្រុងអនុវត្តមុខងារក្រុង និងប្រើប្រាស់ធនធានក្រុង។

និង ការកសាងសមត្ថភាព) ដល់ក្រុមប្រឹក្សាសង្កាត់ និងបុគ្គលិករបស់សង្កាត់ដើម្បីឱ្យសង្កាត់អាចអនុវត្ត មុខងារ និងភារកិច្ចដែលបានធ្វើប្រតិភូកម្មដោយក្រុងប្រឹក្សាក្រុង។

✓ ក្រុមប្រឹក្សាក្រុង គាំទ្រក្រុមប្រឹក្សាសង្កាត់ ដើម្បីធានាឱ្យបានថា ក្រុមប្រឹក្សាសង្កាត់ អនុវត្តមុខងាររបស់ខ្លួននៅក្នុង**ក្របខ័ណ្ឌនៃវិមជ្ឈការ** ក៏ដូចជាអនុលោមទៅតាមច្បាប់ និងលិខិតបទដ្ឋាន។ ក្រុមប្រឹក្សាក្រុងក៏ត្រូវធានាឱ្យបានផងដែរថា ក្រុមប្រឹក្សាសង្កាត់ មានការឆ្លើយតបចំពោះតម្រូវការរបស់ប្រជាពលរដ្ឋ (មាត្រា ១៨៣ នៃអនុក្រឹត្យ២១៦ អ.ន.ក្រ.បក ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក)។

## ផ្នែកទី ៤: ការអនុវត្តមុខងាររបស់ក្រុមប្រឹក្សា

✓ នៅពេលខាងមុខ គេសង្ឃឹមថា ក្រុមប្រឹក្សា នឹងទទួលបានមុខងារជាច្រើននៅក្នុងវិស័យមួយចំនួន។

✓ សមាជិកក្រុមប្រឹក្សា មិនមានពេលវេលា ឬជំនាញ ដើម្បីអនុវត្តមុខងារទាំងនេះដោយខ្លួនឯងផ្ទាល់ឡើយ។ គឺ **បុគ្គលិក**របស់ក្រុមប្រឹក្សាដែលមានការទទួលខុសត្រូវចំពោះ**ការអនុវត្ត**មុខងាររបស់ក្រុមប្រឹក្សា។ **បុគ្គលិករបស់ក្រុមប្រឹក្សា មានគណនេយ្យភាព**ចំពោះក្រុមប្រឹក្សាតាមរយៈនាយករដ្ឋបាលរបស់ក្រុមប្រឹក្សា និងគណៈអភិបាល (មាត្រា ១៧៤, ១៧៨, ១៨២, ១៩០ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ)។

✓ នៅគ្រប់ការប្រជុំរបស់ក្រុមប្រឹក្សា **ក្រុមប្រឹក្សា** ត្រូវពិចារណាមុខងាររបស់ខ្លួន និងធ្វើ**សេចក្តីសម្រេច**ចាំបាច់ ឬសមស្របរួមទាំងសេចក្តីសម្រេចផ្នែកហិរញ្ញវត្ថុ។

> ចំពោះព័ត៌មានបន្ថែមស្តីពីតួនាទី និង រចនាសម្ព័ន្ធរបស់ក្រុមប្រឹក្សា សូមអានមេរៀនទី ១២

ក្រុមប្រឹក្សា ក៏ត្រូវពិនិត្យតាមដាន និងវាយតំលៃការអនុវត្ត មុខងាររបស់ខ្លួន និងរាយការណ៍ជូនប្រជាពលរដ្ឋអំពីការរីកចំរើននៅក្នុង**របាយការណ៍ប្រចាំឆ្នាំ**របស់ក្រុមប្រឹក្សា (មាត្រា ៣៦, ៤០, ៤២, ៥០, ១៥៦ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ)។

## វគ្គទី ២:

## មេរៀនសង្ខេប

- ✓ កម្ពុជានឹងអនុវត្តដំណើរការពិនិត្យមើលឡើងវិញលើមុខងារគ្រប់គ្រងនៅក្នុងវិស័យទាំងអស់ដើម្បីកំណត់ថាតើមុខងារណា នឹងត្រូវផ្ទេរឱ្យក្រុមប្រឹក្សានៅថ្នាក់ក្រោមជាតិ ។

- ✓ គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប) ត្រូវបានបង្កើតដោយព្រះរាជក្រឹត្យ ។ ការទទួលខុសត្រូវជាគន្លឹះរបស់ គ.ជ.អ.ប គឺត្រូវដឹកនាំ និងពិនិត្យមើលដំណើរការនៃការពិនិត្យមើលឡើងវិញលើមុខងារដែលអាចផ្ទេរឱ្យក្រុមប្រឹក្សា ។

- ✓ ក្រសួងតាមវិស័យ ត្រូវចូលរួមនៅក្នុងដំណើរការពិនិត្យមើលឡើងវិញលើមុខងារដែលអាចផ្ទេរ ។

- ✓ ក្រុមប្រឹក្សារាជធានីភ្នំពេញ និងក្រុមប្រឹក្សាខេត្ត ក្រុង ស្រុក និងឃុំទាំងអស់ទទួលបានមុខងារដោយផ្ទាល់ពីថ្នាក់ជាតិ ។ ខណ្ឌ និងសង្កាត់នៅរាជធានីភ្នំពេញ និងក្រុងទទួលបានមុខងារដោយប្រយោលតាមរយៈការធ្វើប្រតិភូកម្មពីក្រុមប្រឹក្សារាជធានីភ្នំពេញ ឬក្រុមប្រឹក្សាក្រុង ។

- ✓ ជំហាននៅក្នុងដំណើរការពិនិត្យមើលឡើងវិញលើមុខងារដែលអាចផ្ទេរឱ្យក្រុមប្រឹក្សាៈ
    - ជ្រើសរើសវិស័យសម្រាប់ការពិនិត្យមើលឡើងវិញ
    - កំណត់អ្នកដែលនឹងចូលរួមចំណែកនៅក្នុងដំណើរការ
    - កំណត់មុខងារនៅក្នុងវិស័យ និងសម្រេចថាតើក្រុមប្រឹក្សានៅថ្នាក់ណាដែលត្រូវទទួលបានការផ្ទេរមុខងារ (ឬកំណត់មុខងារដែលត្រូវរក្សាទុកថាជាមុខងារនៅថ្នាក់ជាតិ)
    - កំណត់ថាតើមុខងារដែលត្រូវផ្ទេរគួរមានលក្ខណៈជាកាតព្វកិច្ច ឬ ជាជំរើស
    - កំណត់ថាតើមុខងារគួរប្រគល់ (ធ្វើវិមជ្ឈការ) ឬធ្វើប្រតិភូកម្មឱ្យក្រុមប្រឹក្សា (ធ្វើវិសហមជ្ឈការឱ្យក្រុមប្រឹក្សា)
    - កំណត់ធនធានដែលស្របទៅនឹងមុខងារ
    - អនុវត្តការផ្ទេរមុខងារ និងធនធានដែលផ្ទេរពីក្រសួងឱ្យក្រុមប្រឹក្សា ។

–

- ✓ មានការគ្រោងទុកថា ក្រុមប្រឹក្សាក៏នឹងមានអាណត្តិទូទៅផងដែរ បន្ថែមពីលើការទទួលបានមុខងារជាក់លាក់តាមវិស័យ ឧទាហរណ៍ ដើម្បីលើកកម្ពស់ការអភិវឌ្ឍសេដ្ឋកិច្ចនៅមូលដ្ឋាន។
- ✓ នៅគ្រប់ការប្រជុំរបស់ក្រុមប្រឹក្សា ក្រុមប្រឹក្សាត្រូវពិចារណាលើមុខងាររបស់ខ្លួន ហើយធ្វើសេចក្តីសម្រេចចាំបាច់ឬសមស្រប រួមទាំងសេចក្តីសម្រេចផ្នែកហិរញ្ញវត្ថុ។

- បុគ្គលិករបស់ក្រុមប្រឹក្សាមានការទទួលខុសត្រូវចំពោះការអនុវត្តសេចក្តីសម្រេចរបស់ក្រុមប្រឹក្សា។

# វគ្គទី ៤:

# ការងារជាក្រុម

**ការងារជាក្រុម ដូចមានពិពណ៌នាខាងក្រោម អាចមានលក្ខណៈមិនសមស្របសម្រាប់ការបណ្តុះបណ្តាលទាំងអស់។ សូមចាត់ទុកការងារជាក្រុមខាងក្រោមជាសំណូមពរតែប៉ុណ្ណោះ។**

១. ចែកសិក្ខាកាមជាក្រុមដែលមានសមាជិកមិនលើសពី ៨ នាក់

២. ផ្តល់លំហាត់ខាងក្រោមអោយក្រុមនីមួយៗ។

**លំហាត់ទី ១ :** ការពិភាក្សាអំពីការពិនិត្យមើលឡើងវិញលើមុខងារ

ក្រុមនីមួយៗមានរយៈពេល ២០ នាទី ដើម្បីរៀបចំការបង្ហាញពិភាក្សាដែលមានរយៈពេលជាអតិបរមា ១០ នាទី។ ការបង្ហាញពិភាក្សានឹងត្រូវធ្វើនៅក្នុងការប្រជុំពេញអង្គដោយតំណាងមួយរូបមកពីក្រុមនីមួយៗ។ ក្រុមនីមួយៗត្រូវជ្រើសរើសតំណាងមួយរូបរបស់ខ្លួន។

**ប្រធានបទនៃការពិភាក្សាគឺៈ**

ហេតុអ្វីបានយើង គឺជាក្រុមប្រឹក្សាដែលសមស្របបំផុតក្នុងការទទួលបានមុខងារ និងធនធានដើម្បី

១. ចាត់ចែងគ្រប់គ្រង និងប្រតិបត្តិមណ្ឌលសុខភាព

២. ជួល គ្រប់គ្រង និងពិនិត្យមើលគ្រូបង្រៀន និងនាយកសាលា

- ក្រុមទី ១ គឺជាសមាជិកក្រុមប្រឹក្សាឃុំដែលត្រូវជជែកតវ៉ាថាហេតុអ្វីបានជាក្រុមប្រឹក្សាឃុំ អាចអនុវត្តមុខងារទាំងនេះយ៉ាងមានប្រសិទ្ធភាព និងមានប្រសិទ្ធផលបំផុត ។

- ក្រុមទី ២ គឺជាសមាជិកក្រុមប្រឹក្សាស្រុក ដែលត្រូវជជែកតវ៉ាថាហេតុអ្វីបានជាក្រុមប្រឹក្សាស្រុក អាចអនុវត្តមុខងារទាំងនេះយ៉ាងមានប្រសិទ្ធភាព និងមានប្រសិទ្ធផលបំផុត ។
- ក្រុមទី ៣ គឺជាសមាជិកក្រុមប្រឹក្សាខេត្តដែលត្រូវជជែកតវ៉ាថាហេតុអ្វីបានជាក្រុមប្រឹក្សាខេត្ត អាចអនុវត្តមុខងារទាំងនេះយ៉ាងមានប្រសិទ្ធភាព និងមានប្រសិទ្ធផលបំផុត ។

(ជាផ្នែកមួយនៃការពិចារណា សូមពិនិត្យឡើងវិញផងដែរអំពីសមាសភាគនៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ)

**លំហាត់ទី ២:** មុខងារជាដំណាក់កាល

រៀបកៅអី ៥ ជារង្វង់តូចមួយ ។ ឱ្យអ្នកស្ម័គ្រចិត្ត ៤ នាក់មកអង្គុយលើកៅអី ៤ ។ ទុកកៅអី ១ឱ្យនៅទំនេរ ។

អ្នកស្ម័គ្រចិត្តទាំង ៤ នឹងពិភាក្សាសំណួរមួយ ឬច្រើនជាង ១ ដូចមានខាងក្រោម ។

ប្រសិនបើអ្នកស្ម័គ្រចិត្តមានបំណងចាកចេញពីការពិភាក្សា គាត់ត្រូវអញ្ជើញអ្នកជំនួសឱ្យមកចូលរួមនៅក្នុងការពិភាក្សា ។

កៅអីទំនេរត្រូវទុកអោយអ្នកដែលចង់ចូលរួមនៅក្នុងការពិភាក្សា (ទោះបីជាមិនត្រូវបានអញ្ជើញក្តី) ។

បទបញ្ជា: ត្រូវមានមនុស្សអង្គុយនៅលើកៅអីយ៉ាងហោចណាស់ ៤ នៅគ្រប់ពេលទាំងអស់ (កៅអីទំនេរ មិនត្រូវលើសពី ១)

**សំណួរពិភាក្សា:**

- តើវិស័យមួយណាដែលអ្នកគិតថា គួរត្រូវពិនិត្យមើលមុនគេសម្រាប់ការផ្ទេរជាអាទិភាព? ហេតុអ្វី?
- តើគុណសម្បត្តិ និងគុណវិបត្តិអ្វីខ្លះដែលមាននៅក្នុងការផ្ទេរមុខងារជាដំណាក់កាល ដោយដំបូងផ្តោតទៅលើតំបន់ភូមិសាស្ត្រជាក់លាក់មួយ ? (ឧទាហរណ៍ មុនដំបូង មុខងារ ត្រូវផ្ទេរតែនៅក្នុងខេត្តស្ថិតនៅភាពពាយ័ព្យ) ។
- តើគុណសម្បត្តិ និងគុណវិបត្តិអ្វីខ្លះដែលមាននៅក្នុងការផ្ទេរមុខងារជាដំណាក់កាល ដោយដំបូងផ្តោតទៅលើថ្នាក់ក្រោមជាតិជាក់លាក់មួយ ? (ឧទាហរណ៍ មុនដំបូង មុខងារ ត្រូវផ្ទេរឱ្យតែក្រុមប្រឹក្សាស្រុក) ។
- តើអ្នកគិតថា ភាពខុសគ្នាជាខ្លាំងនៅក្នុងទំហំរបស់ខេត្ត ឬស្រុក គួរប៉ះពាល់ដល់ការផ្ទេរមុខងារ ឬទេ? (ឧទាហរណ៍ ប្រសិនបើមុខងារផ្តល់ការអប់រំបឋម ត្រូវផ្ទេរឱ្យស្រុក តើមុខងារនេះ គួរផ្ទេរឱ្យតែស្រុកដែលមានទំហំណាមួយប៉ុណ្ណោះឬ?)

**លំហាត់ទីបី៖ មុខងារជាកាតព្វកិច្ច**

ពិភាក្សាសំណួរខាងក្រោម

- តើសេវាជាមូលដ្ឋាន និងសំខាន់ៗអ្វីខ្លះ ដែលអ្នកគិតថាគួរមានលក្ខណៈជាមុខងារជាកាតព្វកិច្ច?
- តើអ្នកគិតថាសេវាខាងក្រោមនេះគួរមានលក្ខណៈជាកាតព្វកិច្ចឬទេ? ហេតុអ្វីបានកាតព្វកិច្ច? ហេតុអ្វីបានមិនមែនកាតព្វកិច្ច?
  - អគ្គីភ័យ?
  - សេវាបន្ទប់សង្គ្រោះបន្ទាន់?
  - ការផ្គត់ផ្គង់ទឹកស្អាត?
  - ការផ្តល់អាហារពេលព្រឹកដល់សិស្សសាលាបឋមសិក្សា?

# មេរៀនសំរាប់ការយល់ដឹង និង ការបណ្តុះបណ្តាលអំពី ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

## មេរៀនទី ១៤:

## ការកសាងផែនការ

## វគ្គទី ១:

១. សេចក្តីផ្តើម

២. ឧបករណ៍កសាងផែនការនៅពេលបច្ចុប្បន្ន

៣. ការកសាងផែនការនៅក្នុងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

## ផ្នែកទី ១: សេចក្តីផ្តើម

### ការកសាងផែនការ

✓ **ការកសាងផែនការ គឺជាសកម្មភាពដែលយើងធ្វើគ្រប់ពេល**។ ជួនកាល យើងធ្វើផែនការសម្រាប់រយៈពេលតែមួយថ្ងៃ - *តើការប្រជុំអ្វីដែលខ្ញុំចង់រៀបចំនៅថ្ងៃនេះ? តើខ្ញុំនឹងហូបអ្វីសម្រាប់អាហារថ្ងៃត្រង់នេះ?* ជួនកាល យើងធ្វើផែនការសម្រាប់រយៈពេលកាន់តែវែង - *តើការឈប់សម្រាកបែបណាដែលខ្ញុំត្រូវប្រកាន់យកនៅឆ្នាំនេះ? តើខ្ញុំអាចសាងសង់ផ្ទះថ្មីតាមរបៀបណា?*

✓ យើងត្រូវធ្វើផែនការ ដើម្បីជ្រើសរើសយកសកម្មភាពខ្លះពីក្នុងចំណោមសកម្មភាពជាច្រើន ដើម្បីអនុវត្តដោយសារតែធនធាន ដូចជាប្រាក់ និងពេលវេលាមានកម្រិត។ ដោយហេតុថា ការកសាងផែនការគឺជាការប្រកាន់យកជម្រើសមួយចំនួនក្នុងចំណោមជម្រើសជាច្រើន **ការកសាងផែនការ គឺជាការកំណត់អាទិភាព**។

### ការកសាងផែនការអភិវឌ្ឍ

✓ នៅក្នុងបរិបទនៃការគ្រប់គ្រង ការកសាងផែនការ ត្រូវធ្វើឡើងពីព្រោះធនធានមានកម្រិត ទោះបីជាមានតម្រូវការបន្ទាន់ជាសាធារណៈជាច្រើនក្តី។ ដូច្នេះ រដ្ឋាភិបាល ត្រូវធ្វើផែនការ ដើម្បី**ប្រើប្រាស់ធនធានដ៏មានកម្រិតរបស់ខ្លួន ដើម្បីឆ្លើយតបជាអតិបរមា**ចំពោះតម្រូវការរបស់ប្រជាពលរដ្ឋ។ ដោយសារការកសាងផែនការពាក់ព័ន្ធនឹងរបៀបបែងចែកធនធាន **ការកសាងផែនការ គឺជាដំណើរការផ្នែកនយោបាយ**។

### ការចូលរួមនៅក្នុងការកសាងផែនការ

✓ ដោយសារគោលបំណងនៃការកសាងផែនការ គឺដើម្បីឆ្លើយតបនឹងតម្រូវការរបស់ប្រជាពលរដ្ឋ ជា**ការសំខាន់ណាស់ដែលប្រជាពលរដ្ឋត្រូវចូលរួម**នៅក្នុងដំណើរការនេះ ដើម្បីកំណត់ និងលើកឡើងពីតម្រូវការរបស់ខ្លួន។

✓ បញ្ហាប្រឈមមួយនៅក្នុងដំណើរការកសាងផែនការ គឺត្រូវធានាឱ្យបានថា **មនុស្សដែលមានការពាក់ព័ន្ធពិតប្រាកដត្រូវចូលរួមអោយបានត្រឹមត្រូវទៅតាមទីកន្លែង និងតាមពេលវេលា**។ ការធ្វើឱ្យមនុស្សដែលមានការពាក់ព័ន្ធពិតប្រាកដចូលរួមឱ្យបានត្រឹមត្រូវទៅតាមទីកន្លែង និងតាមពេលវេលា (ជាជាងគ្រប់ទីកន្លែង និងគ្រប់ពេលវេលា) គឺជាភារកិច្ចដែលមានបញ្ហាប្រឈម។ កម្រិតនៃការចូលរួម មានការប្រែប្រួលអាស្រ័យលើបរិបទ។ ឧទាហរណ៍

ជាធម្មតា ការចូលរួមដោយផ្ទាល់របស់ប្រជាពលរដ្ឋនៅក្នុងការធ្វើផែនការឃុំ សង្កាត់ មានភាពរឹងមាំជាងនៅក្នុងការធ្វើផែនការជាតិ ។

**ការកសាងផែនការ និងហិរញ្ញប្បទាន**

ជាធម្មតា ផែនការមួយអាចត្រូវអនុវត្តទៅបានប្រសិនបើមានហិរញ្ញវត្ថុអមជាមួយ ។ ដូច្នេះ ការកសាងផែនការ និងថវិកាគួរត្រូវចាត់ទុកថាជាផ្នែកទាំងសងខាងនៃកាក់មួយ ។ ដំណើរការនៃការកសាងផែនការ និងដំណើរការនៃការកសាងថវិកា មានការពាក់ព័ន្ធគ្នាជាខ្លាំង ។

## ផ្នែកទី ២: ឧបករណ៍កសាងផែនការនៅពេលបច្ចុប្បន្ន

### ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ឆ្នាំ ២០០៦-២០១០ និងបច្ចុប្បន្នភាពឆ្នាំ ២០០៩-២០១៣

✓ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ គឺជាផែនការយុទ្ធសាស្ត្រជាតិរបស់កម្ពុជា ដោយមាន**គោលបំណងកាត់បន្ថយភាពក្រីក្រ**។ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិដែលបានធ្វើបច្ចុប្បន្នភាពនៅពេលបច្ចុប្បន្ន គ្របដណ្តប់រយៈពេលពីឆ្នាំ ២០០៩ ដល់ឆ្នាំ ២០១៣។

✓ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ផ្តល់ក្របខ័ណ្ឌ ដើម្បី**ដឹកនាំសេចក្តីសម្រេចផ្នែកគោលនយោបាយ និងការបែងចែកថវិកា**ដោយមានទស្សនៈកាត់បន្ថយភាពក្រីក្រ។ ជាគោលការណ៍ ដៃគូអភិវឌ្ឍន៍ជាច្រើន បន្សុីសកម្មភាពរបស់ខ្លួនឱ្យស្របទៅតាមផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ។

> ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ទទួលស្គាល់ថា **អភិបាលកិច្ចល្អ** គឺជាគន្លឹះចំពោះការអភិវឌ្ឍសេដ្ឋកិច្ច សង្គមប្រកបដោយចីរភាព និងមានសមធម៌។ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ក៏ទទួលស្គាល់ផងដែរថា កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ គឺជាមធ្យោបាយសម្រាប់កែលម្អ និងបង្កើនការផ្តល់សេវាសាធារណៈ និងពង្រឹងការអភិវឌ្ឍនៅមូលដ្ឋាន។

✓ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ត្រូវពិនិត្យមើលឡើងវិញជារៀងរាល់ឆ្នាំ។ ការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ មានបញ្ហាប្រឈមដោយសារមូលនិធិដ៏មានកម្រិត និងតម្រូវការដើម្បីបង្កើនទំនុកចិត្ត និងភាពជាម្ចាស់របស់ក្រសួងតាមវិស័យ។ មានករណីតិចតួចប៉ុណ្ណោះដែលផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិត្រូវបានបំបែកដើម្បីផ្តល់លទ្ធភាពដល់ការអនុវត្តដោយមន្ទីរខេត្តរបណ្តោយ។

### កម្មវិធីវិនិយោគសាធារណៈ (PIP)

✓ កម្មវិធីវិនិយោគសាធារណៈ (PIP) គឺជាផែនការប្រចាំឆ្នាំដែលត្រូវសម្របសម្រួលដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងផែនការ ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ និងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា។ មូលនិធិសម្រាប់ PIP ច្រើនជាងពីរភាគបីបានមកពីជំនួយរបស់ដៃគូអភិវឌ្ឍពីខាងក្រៅ។

✓ ដំណើរការកសាងផែនការ ចាប់ផ្តើមជាមួយនឹងការវាយតម្លៃលើការចំណាយនៅបណ្តាឆ្នាំមុន។ បន្ទាប់មក ផែនការនេះ ត្រូវធ្វើបច្ចុប្បន្នភាពដោយក្រសួងខ្សែបណ្តោយ និងស្ថាប័នផ្សេងទៀតរបស់រាជរដ្ឋាភិបាល។ ក្រសួងនីមួយៗ ធ្វើបច្ចុប្បន្នភាពគម្រោងរបស់ខ្លួនផ្អែកលើសមិទ្ធផលនៅឆ្នាំមុន។

**ផែនការតាមវិស័យ**

- ✓ ការកសាងផែនការបន្ថែម ត្រូវធ្វើឡើងដោយ**ក្រសួងខ្សែបណ្តោយនីមួយៗ** ជាញឹកញាប់ ដោយមានការគាំទ្រពីដៃគូអភិវឌ្ឍ ។ ផែនការយុទ្ធសាស្ត្រវិស័យសុខាភិបាល គឺជាឧទាហរណ៍នៃផែនការតាមវិស័យ។

**ផែនការតាមខេត្ត ក្រុង**

- ✓ ពីមុន **ផែនការខេត្ត ក្រុង មានកម្រិតជាខ្លាំង** ពីព្រោះប្រភពមូលនិធិសំខាន់ៗ ត្រូវគ្រប់គ្រង និងត្រួតពិនិត្យដោយថ្នាក់កណ្តាល ។

- ✓ **ផែនការសាលាខេត្ត:** សាលាខេត្ត បានរៀបចំផែនការអភិវឌ្ឍខេត្តរយៈពេល ៥ ឆ្នាំ (PDP) និងកម្មវិធីវិនិយោគអភិវឌ្ឍន៍ខេត្តរយៈពេលបីឆ្នាំ (PDIP)។ អភិបាលខេត្ត ដោយមានការគាំទ្រពីមន្ទីរផែនការខេត្ត បានរៀបចំផែនការអភិវឌ្ឍខេត្ត (PDP) ដោយដាក់បញ្ចូលផែនការរបស់មន្ទីរទាំងអស់នៅក្នុងខេត្ត។ ការលំបាកជាចំបងចំនួនពីរ គឺជាញឹកញាប់ PDP មិនត្រូវបានផ្សារភ្ជាប់ជាមួយមូលនិធិណាមួយ ដូច្នេះ មិនអាចអនុវត្តបានឡើយ និងមានការសម្របសម្រួលតិចតួចនៅក្នុងចំណោមមន្ទីរតាមខេត្តក្នុងការរៀបចំផែនការនីមួយៗរបស់ខ្លួន ។

- ✓ **មូលនិធិវិនិយោគខេត្ត** (PIF) ផ្តល់ការត្រួតពិនិត្យដោយផ្ទាល់ដល់ខេត្ត ក្រុងលើមូលនិធិសម្រាប់គម្រោងមួយចំនួនដែលត្រូវអនុវត្តនៅក្នុងខេត្ត។ PIF ត្រូវផ្តល់មូលនិធិដោយរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍ ហើយត្រូវគ្រប់គ្រងដោយគណៈកម្មាធិការអភិវឌ្ឍជនបទខេត្ត ក្រុង។

- ✓ **ផែនការមន្ទីរតាមខេត្ត:** ជាធម្មតា មន្ទីរនីមួយៗនៅតាមខេត្ត រាជធានី ត្រូវរៀបចំ និងផ្ញើផែនការរយៈពេល៥ឆ្នាំមកក្រសួងរបស់ខ្លួន ហើយផែនការវិនិយោគរំកិលរយៈពេលបីឆ្នាំស្ទើរតែទាំងអស់ លើកលែងតែ**អាទិភាព និងថវិកានៅក្នុងផែនការ ត្រូវសម្រេចដោយក្រសួងខ្សែបណ្តោយនៅថ្នាក់ជាតិ**។ ដូច្នេះ មានចន្លោះដ៏មានកម្រិតបំផុតសម្រាប់ឱ្យអភិបាលខេត្ត ឬអភិបាលស្រុកសម្របសម្រួលពីរបៀបប្រើប្រាស់មូលនិធិនៅក្នុងចំណោមអង្គភាពទាំងនេះ ឬសម្រាប់ឱ្យអង្គភាពទាំងនេះសម្របសម្រួលនៅក្នុងចំណោមគ្នាឯង។ ជាមួយនឹងមូលនិធិ និងអាទិភាពធ្លាក់មកពីថ្នាក់ជាតិ អង្គភាពនៅថ្នាក់ក្រោមជាតិទាំងនេះ**មានគណនេយ្យភាពឡើងលើ**ចំពោះក្រសួងខ្សែបណ្តោយរបស់ខ្លួន។

### **ផែនការវិនិយោគឃុំ (CDP) / កម្មវិធីវិនិយោគឃុំ (CIP)**

✓ ផ្អែកតាមជំពូកទី ៦ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់បានតម្រូវអោយគ្រប់ឃុំ សង្កាត់ទាំងអស់ត្រូវរៀបចំអនុម័ត និងអនុវត្ត**ផែនការអភិវឌ្ឍឃុំ សង្កាត់** (CDP)។ CDP គឺជាផែនការរយៈពេល ៥ ឆ្នាំ ដែលត្រូវពិនិត្យមើលឡើងវិញជារៀងរាល់ឆ្នាំ។ CDP ត្រូវស្របទៅតាមផែនការអភិវឌ្ឍសេដ្ឋកិច្ចសង្គមរបស់ជាតិ (មាត្រា ៦០ ដល់ ៧២ នៃ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់)។

✓ មេឃុំ ចៅសង្កាត់ ត្រូវបង្កើត**គណៈកម្មាធិការកសាងផែនការ និងថវិកា** ដែលត្រូវអនុវត្តតាម**ជំហានមួយចំនួននៃការកសាងផែនការ** ដូចជា:

- ការវិភាគព័ត៌មាន
- ការលើកឡើង និងការកំណត់តម្រូវការ
- ការរៀបចំកម្មវិធី
- ការផ្តល់សេវា
- ការពិនិត្យតាមដាន និងវាយតម្លៃ។

> មានតម្រូវការខ្ពស់ក្នុងការសម្របសម្រួលវិធី និងប្រព័ន្ធកសាងផែនការផ្សេងគ្នានៅពេលបច្ចុប្បន្ន។ មានតម្រូវការខ្ពស់ដូចគ្នានេះដែរក្នុងការផ្សារភ្ជាប់ផែនការជាមួយថវិកា។
>
> ច្បាប់ស្តីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ព្យាយាមដោះស្រាយបញ្ហាប្រឈមទាំងនេះ។

✓ កម្មវិធីវិនិយោគឃុំ(CIP) **គឺជាកម្មវិធីវិនិយោគរយៈ**ប្រចាំឆ្នាំដែលត្រូវផ្សារភ្ជាប់ជាមួយ CDP ។

✓ សមាសធាតុជាគន្លឹះមួយនៅក្នុងដំណើរការកសាង ផែនការឃុំ សង្កាត់ **គឺសិក្ខាសាលាសមាហរណកម្មថ្នាក់ស្រុក**ធ្វើឡើងជារៀងរាល់ឆ្នាំនៅគ្រប់ស្រុក/ ខណ្ឌ។ សិក្ខាសាលាសមាហរណកម្មថ្នាក់ស្រុក ផ្តល់ឱកាសដល់ក្រុមប្រឹក្សាឃុំ សង្កាត់ឱ្យបង្ហាញអាទិភាពរបស់ខ្លួនដល់មន្ទីរខ្សែបណ្តោយ និងអ្នកផ្តល់មូលនិធិជាសក្តានុពលផ្សេងទៀត (ដូចជាអង្គការមិនមែនរដ្ឋាភិបាល) សម្រាប់ផ្តល់មូលនិធិ និងការគាំទ្រ។ សិក្ខាសាលាសមាហរណកម្មថ្នាក់ស្រុក ក៏អាចប្រើប្រាស់ជាឱកាសសម្រាប់មន្ទីរខ្សែបណ្តោយ និងអ្នកផ្តល់មូលនិធិផ្សេងទៀតសម្របសម្រួលការគាំទ្ររបស់ខ្លួនដល់ឃុំ សង្កាត់ផងដែរ។ **ការលំបាក**របស់សិក្ខាសាលាសមាហរណកម្មថ្នាក់ស្រុកគឺវិសាលភាពដ៏មានកម្រិតរបស់មន្ទីរខ្សែបណ្តោយ និងអង្គការមិនមែនរដ្ឋាភិបាល ដើម្បីឆ្លើយតបនឹងអាទិភាពរបស់ឃុំ សង្កាត់។

### **ផែនការដៃគូអភិវឌ្ឍ**

✓ ដៃគូអភិវឌ្ឍច្រើនមានតម្រូវការកសាងផែនការ ពេលវេលា និងដំណើរការរបស់ខ្លួនផ្ទាល់។ ជាញឹកញាប់ដៃគូអភិវឌ្ឍមានវិស័យ និងសកម្មភាពដែលបានកំណត់ទុកជាមុនដែលខ្លួនអាចគាំទ្រនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

## ផ្នែកទី ៣: ការកសាងផែនការក្រោមច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

**ច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ**

មាត្រា ៣៦ ដល់ ៤១. ៥០. ១០០. ១២៤.១៦៣ ដល់ ១៦៦. ២០១. ២៤៥

### សេចក្ដីផ្ដើម

✓ ក្រុមប្រឹក្សារាជធានី និងក្រុមប្រឹក្សាខេត្ត ក្រុង ស្រុក និងខណ្ឌ ត្រូវរៀបចំ និងអនុម័ត**ផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ**។ គ្រប់ក្រុមប្រឹក្សា ត្រូវរៀបចំ និងអនុម័ត**កម្មវិធីវិនិយោគបីឆ្នាំរំកិល**។ ផែនការអភិវឌ្ឍ និងកម្មវិធីវិនិយោគត្រូវធ្វើបច្ចុប្បន្នភាពជារៀងរាល់ឆ្នាំ ។ (មាត្រា ៣៧ នៃច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និង មាត្រា ១២ នៃអនុក្រឹត្យស្ដីពី ផែនការអភិវឌ្ឍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ) ។

✓ ផែនការអភិវឌ្ឍរបស់ក្រុមប្រឹក្សា ត្រូវដាក់បញ្ចូលផ្នែកដែលស្ថិតនៅក្រោមការគ្រប់គ្រង និងការត្រួតពិនិត្យរបស់ក្រុមប្រឹក្សា និងផ្នែកដែលស្ថិតនៅក្រោមការគ្រប់គ្រង និងការត្រួតពិនិត្យរបស់:

- ក្រុមប្រឹក្សាប្រភេទរួមគ្នា
- ប្រភេទក្រុមប្រឹក្សាផ្សេងៗ ទៀត
- ក្រសួង ស្ថាប័ន អង្គភាពនានារបស់រាជរដ្ឋាភិបាល
- អ្នកពាក់ព័ន្ធនានា ។

( មាត្រា ៤០ នៃច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ )

✓ ដូច្នេះ ផែនការអភិវឌ្ឍរបស់ក្រុមប្រឹក្សា ត្រូវដាក់បញ្ចូលសកម្មភាពអភិវឌ្ឍទាំងអស់របស់វិស័យនានានៅក្នុងតំបន់របស់ក្រុមប្រឹក្សា (**សមាហរណកម្មតាមវិស័យ**)។ ( មាត្រា ៤០. ១២៤ នៃច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ) ។

✓ ផែនការអភិវឌ្ឍ និងកម្មវិធីវិនិយោគក្រុង ត្រូវដាក់បញ្ចូលផែនការអភិវឌ្ឍ និងកម្មវិធីវិនិយោគរបស់សង្កាត់ទាំងអស់នៅក្នុងក្រុង (មាត្រា៣. ៤ នៃអនុក្រឹត្យស្ដីពី ផែនការអភិវឌ្ឍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ) ។

- ✓ ក្រុមប្រឹក្សាស្រុក និងក្រុមប្រឹក្សាឃុំ សង្កាត់នៅក្នុងស្រុក ត្រូវដាក់បញ្ចូលទៅក្នុងផែនការអភិវឌ្ឍ និងកម្មវិធីវិនិយោគ និងថវិការបស់ខ្លួននូវយុទ្ធសាស្ត្រ កម្មវិធី និងសកម្មភាពដែលបានកំណត់សម្រាប់ឆ្លើយតបនឹងតម្រូវការ និងសំណូមពររបស់ក្រុមប្រឹក្សាឃុំ សង្កាត់។ ( មាត្រា ១០០ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ) ។

✓ គ្រប់ក្រុមប្រឹក្សា ក៏ត្រូវរៀបចំ និងអនុម័ត**ថវិកាប្រចាំឆ្នាំ** និង**ក្របខ័ណ្ឌចំណាយរយៈពេលមធ្យម**ផងដែរ។ ( មាត្រា ៤៤ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងមាត្រា ៤ នៃអនុក្រឹត្យស្តីពីការកសាងផែនការ) ។

| |
|---|
| ចំពោះព័ត៌មានបន្ថែមស្តីពីហិរញ្ញវត្ថុ សូមអានមេរៀនទី ១៥។ |

✓ ក្រសួងមហាផ្ទៃ និងក្រសួងផែនការ មានការទទួលខុសត្រូវក្នុងការដាក់ចេញ**គោលការណ៍ណែនាំ**សម្រាប់ការរៀបចំ និងការអនុវត្តផែនការអភិវឌ្ឍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល។ គោលការណ៍ណែនាំត្រូវបានរំពឹងថា នឹងត្រូវដាក់ចេញនៅពេលឆាប់ៗខាងមុខនេះ។ ( មាត្រា ២៨ នៃអនុក្រឹត្យស្តីពីផែនការអភិវឌ្ឍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ) ។

## មាតិកានៃផែនការអភិវឌ្ឍ

✓ ផែនការអភិវឌ្ឍ ត្រូវមានបញ្ចូលៈ

- ចក្ខុវិស័យរបស់ក្រុមប្រឹក្សាសម្រាប់ការអភិវឌ្ឍនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។
- គោលដៅ និងគោលបំណងរបស់ក្រុមប្រឹក្សាសម្រាប់ការអភិវឌ្ឍ។
- ការប៉ាន់ប្រមាណពីកម្រិតនៃការអភិវឌ្ឍដែលមានស្រាប់នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។
- ការប៉ាន់ប្រមាណពីតម្រូវការអភិវឌ្ឍសំខាន់ៗ រួមមានៈ
    - តម្រូវការរបស់ក្រុមប្រឹក្សានៅក្នុងការរៀបចំទទួលយកនូវការផ្ទេរមុខងារ ភារកិច្ច និងធនធានថ្មីៗ។
    - សេវាមធ្យោបាយ សម្ភារៈ និងហេដ្ឋារចនាសម្ព័ន្ធសាធារណៈជាមូលដ្ឋាន និងចាំបាច់នានា។
    - ការកាត់បន្ថយភាពក្រីក្រ។
    - តម្រូវការផ្សេងៗ របស់ស្ត្រី បុរស យុវវ័យ កុមារ ក្រុមជនងាយរងគ្រោះ រួមទាំងជនក្រីក្រ និងជនជាតិដើមភាគតិច។
- ក្របខ័ណ្ឌអភិវឌ្ឍដែលត្រូវចែងអំពីគោលការណ៍ណែនាំជាមូលដ្ឋានក្នុងការប្រើប្រាស់ និងគ្រប់គ្រងការប្រើប្រាស់ដីធ្លី និងធនធានធម្មជាតិនៅតំបន់នោះ។
- ផែនការគ្រប់គ្រងគ្រោះមហន្តរាយ។
- ផែនការហិរញ្ញវត្ថុ ដោយត្រូវរាប់បញ្ចូលទាំងការអភិវឌ្ឍមូលធន ការគ្រោងថវិកាសម្រាប់រយៈពេលដប់ពីរខែ និងសម្រាប់រយៈពេលបីឆ្នាំ។
- យុទ្ធសាស្ត្រសម្រាប់អនុវត្តផែនការអភិវឌ្ឍ ដើម្បីធានាឱ្យមានតម្លាភាព និងគណនេយ្យភាពចំពោះប្រជាពលរដ្ឋ។
- សូចនាករបំពេញការងារសំខាន់ៗ និងគោលដៅនានាសម្រាប់ការអនុវត្តផែនការអភិវឌ្ឍ។

> **នៅពេលរៀបចំផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគ ត្រូវអនុវត្តទៅតាមគោលការណ៍ខាងក្រោមៈ**
>
> - ការចែករំលែកព័ត៌មាន
> - តម្លាភាព
> - សង្គតិភាព និងសុខដុមនីយកម្ម
> - ការឆ្លើយតបចំពោះតម្រូវការ
> - គណនេយ្យភាពតាមបែបប្រជាធិបតេយ្យ
> - ប្រសិទ្ធិភាព និងស័ក្តិសិទ្ធិភាពផ្នែកសេដ្ឋកិច្ច សង្គម
> - ការធានាដល់ចីរភាពធនធានធម្មជាតិ និងបរិស្ថាន
> - ការធានាដល់សមធម៌
> - ការចូលរួមពិគ្រោះយោបល់ទូទៅ

( មាត្រា៣៩ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ )

## ការរៀបចំផែនការ

✓ ក្នុងការរៀបចំ និងការអនុវត្តផែនការអភិវឌ្ឍន៍ **ក្រុមប្រឹក្សា ត្រូវពិគ្រោះយោបល់**ជាមួយៈ

- ប្រជាពលរដ្ឋនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន
- ប្រភេទក្រុមប្រឹក្សាផ្សេងទៀតនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន
- ក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធនានារបស់រាជរដ្ឋាភិបាលនិង
- អ្នកពាក់ព័ន្ធនានា។

(មាត្រា ៣៨ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ)

✓ គណៈអភិបាល ត្រូវលើកសំណើទៅក្រុមប្រឹក្សា ដើម្បីកំណត់អំពីយុទ្ធសាស្ត្រ និងរបៀបនៃការពិគ្រោះយោបល់។ (មាត្រា ១៦៤នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ)

✓ ការពិគ្រោះយោបល់ អាចធ្វើឡើងដោយក្រុមប្រឹក្សា ឬក្រុមប្រឹក្សា អាចសម្រេចឱ្យគណៈអភិបាលធ្វើការពិគ្រោះយោបល់ក្នុងនាមក្រុមប្រឹក្សា។ (មាត្រា ១៦៤ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ)

**របាយការណ៍ប្រចាំឆ្នាំរបស់ក្រុមប្រឹក្សា**

លទ្ធផលនៃការពិនិត្យតាមដាន និងវាយតម្លៃលើផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគរបស់ក្រុមប្រឹក្សា ត្រូវដាក់បញ្ចូលទៅក្នុងរបាយការណ៍ប្រចាំឆ្នាំរបស់ក្រុមប្រឹក្សា។

កិច្ចការផ្សេងទៀតដែលត្រូវដាក់បញ្ចូលទៅក្នុងរបាយការណ៍ប្រចាំឆ្នាំរបស់ក្រុមប្រឹក្សាគឺ

- ដីកា និងសេចក្តីសម្រេចនានាដែលបានដាក់ចេញនៅក្នុងឆ្នាំ
- សកម្មភាពនានាដែលបានអនុវត្តនៅក្នុងឆ្នាំ
- របាយការណ៍ហិរញ្ញវត្ថុ
- ការវាយតម្លៃការបំពេញការងាររបស់គណៈអភិបាល និងមន្ត្រីក្រុមប្រឹក្សា
- វិធានការណ៍ចាំបាច់ដើម្បីធ្វើឱ្យប្រសើរឡើងនូវការអនុវត្តការងាររបស់ក្រុមប្រឹក្សា
- ការណែនាំសម្រាប់អនុវត្តនីផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគសម្រាប់ឆ្នាំក្រោយ។

(មាត្រា ៥០ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងមាត្រា ២៦ នៃអនុក្រឹត្យស្តីពីការកសាងផែនការ)។

✓ គ្រប់ក្រុមប្រឹក្សា ត្រូវរៀបចំ**កិច្ចប្រជុំពិគ្រោះយោបល់ពិសេស**អំពីការរៀបចំផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគរបស់ខ្លួន។ នៅថ្នាក់ខេត្ត ត្រូវមានការចូលរួមពីប្រធានក្រុមប្រឹក្សាក្រុង និងស្រុកទាំងអស់ ក៏ដូចជាប្រធានគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការនារី និងកុមាររបស់ក្រុង និងស្រុក។ ចំពោះកិច្ចប្រជុំពិគ្រោះយោបល់ពិសេសនៅថ្នាក់ក្រុង និងស្រុក មេឃុំ និងចៅសង្កាត់ ត្រូវចូលរួម រួមជាមួយនឹងជនបង្គោលទទួលបន្ទុកកិច្ចការនារី និងកុមាររបស់ឃុំ សង្កាត់។

**ការទទួលខុសត្រូវក្នុងការកសាងផែនការ**

✓ **ការទទួលខុសត្រូវរបស់ក្រុមប្រឹក្សា**ក្នុងការកសាងផែនការ រួមមាន:

- ដាក់ចេញសេចក្តីណែនាំផ្នែកគោលនយោបាយជាទូទៅ ដើម្បីរៀបចំផែនការអភិវឌ្ឍ និងកម្មវិធីវិនិយោគ
- អនុម័តយុទ្ធសាស្ត្រសម្រាប់ការពិគ្រោះយោបល់នៅក្នុងអំឡុងពេលនៃការរៀបចំផែនការអភិវឌ្ឍន៍របស់ក្រុមប្រឹក្សា ( មាត្រា ១៦៤ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ )
- អនុវត្តដំណើរការពិគ្រោះយោបល់ក្នុងពេលរៀបចំផែនការអភិវឌ្ឍន៍របស់ខ្លួន ឬស្នើសុំឱ្យគណៈអភិបាល ធ្វើការពិគ្រោះយោបល់ក្នុងនាមក្រុមប្រឹក្សា ( មាត្រា ៣៨ និង ១៦៤ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ )
- រៀបចំ និងអនុម័តផែនការអភិវឌ្ឍរយៈពេល ៥ ឆ្នាំ និងកម្មវិធីវិនិយោគរយៈពេល ៣ ឆ្នាំ ( មាត្រា ៣៧ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ )។ ពិនិត្យតាមដាន និងវាយតម្លៃលើការអនុវត្តផែនការអភិវឌ្ឍរបស់ខ្លួន និងផ្តល់សុពលភាពលើលទ្ធផលនៃការពិនិត្យតាមដាន និងវាយតម្លៃ ( មាត្រា ៤០ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និង មាត្រា ៦ នៃអនុក្រឹត្យស្តីពីការកសាងផែនការ)
- ធ្វើបច្ចុប្បន្នភាពលើផែនការអភិវឌ្ឍ និងកម្មវិធីវិនិយោគជារៀងរាល់ឆ្នាំ និងធ្វើវិសោធនកម្មលើផែនការអភិវឌ្ឍប្រសិនបើចាំបាច់ ( មាត្រា ៣៧ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ )
- បិទផ្សាយផែនការអភិវឌ្ឍន៍ជាសាធារណៈ ។ ( មាត្រា ៤១ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ )

✓ **ការទទួលខុសត្រូវជាគន្លឹះរបស់គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស**នៅក្នុងការកសាងផែនការ គឺត្រូវធានាឱ្យមានការធ្វើសមាហរណកម្មវិស័យនានា នៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សា។ ប្រការនេះមានន័យថា គណៈកម្មាធិការ ត្រូវធានាឱ្យបានថាផែនការ និងថវិការរបស់ក្រសួង និងអង្គភាពតាមខ្សែបណ្តោយរបស់ខ្លួនដែលប្រតិបត្តិការនៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សា ត្រូវបានធ្វើសមាហរណកម្មទៅក្នុងផែនការអភិវឌ្ឍរយៈពេល ៥ឆ្នាំ និងកម្មវិធីវិនិយោគរយៈពេលបីឆ្នាំរំកិលរបស់ក្រុមប្រឹក្សា ក៏ដូចជាក្របខ័ណ្ឌចំណាយរយៈពេលមធ្យម និងថវិកាប្រចាំឆ្នាំរបស់ក្រុមប្រឹក្សា។ សមាហរណកម្មផែនការ និងថវិកាទាំងនេះ ត្រូវធ្វើបច្ចុប្បន្នភាពជារៀងរាល់ឆ្នាំ។ ( មាត្រា ១២៤ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ) ។

✓ ក្រៅពីនេះ **គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស** មានការទទួលខុសត្រូវក្នុងការ

- សម្របសម្រួលការចូលរួមរបស់អ្នកពាក់ព័ន្ធនៅក្នុងដំណើរការរៀបចំ
- ផ្តល់មតិយោបល់ដល់ក្រុមប្រឹក្សាលើសេចក្តីព្រាងផែនការអភិវឌ្ឍ និងកម្មវិធីវិនិយោគ
- ផ្តល់មតិយោបល់ដល់ក្រុមប្រឹក្សាអំពីការរីកចំរើននៅក្នុងការអនុវត្តផែនការអភិវឌ្ឍ និងកម្មវិធីវិនិយោគ

✓ **ការទទួលខុសត្រូវរបស់គណៈអភិបាល**ក្នុងការកសាងផែនការរួមមានៈ

- ស្នើយុទ្ធសាស្ត្រដល់ក្រុមប្រឹក្សាសម្រាប់ដំណើរការពិគ្រោះយោបល់ និងការរៀបចំផែនការអភិវឌ្ឍរបស់ក្រុមប្រឹក្សា ។
- ប្រសិនបើត្រូវបានស្នើសុំដោយក្រុមប្រឹក្សា គណៈអភិបាលអាចអនុវត្តដំណើរការពិគ្រោះយោបល់ក្នុងនាមក្រុមប្រឹក្សារបស់ខ្លួន( មាត្រា ១៦៤ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- ដឹកនាំសិក្ខាសាលា និងវេទិកាពិគ្រោះយោបល់នៅក្នុងអំឡុងពេលនៃដំណើរការរៀបចំផែនការ ។
- រៀបចំសេចក្តីព្រាងផែនការអភិវឌ្ឍរយៈពេល ៥ ឆ្នាំ និងកម្មវិធីវិនិយោគរយៈពេល ៣ ឆ្នាំ និងបច្ចុប្បន្នភាពប្រចាំឆ្នាំ ហើយដាក់ឯកសារទាំងនេះជូនក្រុមប្រឹក្សាសម្រាប់ពិចារណា និងអនុម័ត ( មាត្រា ១៦៣ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ)
- ដោយពិគ្រោះយោបល់ជាមួយគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសគណៈអភិបាលត្រូវធានាឱ្យមានការធ្វើសមាហរណកម្មតាមវិស័យនៅក្នុងផែនការអភិវឌ្ឍ (មាត្រា ១២៤ និង ១៦៦ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ)
- ធានាឱ្យមានសង្គតិភាពរវាងផែនការអភិវឌ្ឍ និងកម្មវិធីវិនិយោគរបស់ក្រុមប្រឹក្សា និងគោលការណ៍របស់ថ្នាក់ជាតិ ឬក្រុមប្រឹក្សានៅថ្នាក់ខ្ពស់ជាង ។

ចំពោះព័ត៌មានបន្ថែមស្តីពីគណៈអភិបាល សូមអានមេរៀនទី ៦។

- ពិនិត្យតាមដានការអនុវត្តផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគ
- រាយការណ៍នៅក្នុងកិច្ចប្រជុំរបស់ក្រុមប្រឹក្សាដោយមានអនុសាសន៍ ដើម្បីកែលម្អការអនុវត្តផែនការអភិវឌ្ឍរយៈពេល ៥ ឆ្នាំ និងកម្មវិធីវិនិយោគរយៈពេល ៣ ឆ្នាំរបស់ក្រុមប្រឹក្សា រួមទាំងផ្នែកដែលស្ថិតនៅក្រោមការគ្រប់គ្រង និងការត្រួតពិនិត្យរបស់អ្នកពាក់ព័ន្ធផ្សេងទៀត ( មាត្រា១៦៥ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

- ធានាឱ្យមានការធ្វើអន្តរាគមន៍យ៉ាងរហ័ស ដើម្បីដោះស្រាយការលំបាកដែលមិនអាចព្យាករណ៍នៅក្នុងការអនុវត្តផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគ ។

✓ ដោយមានការឯកភាពពីក្រុមប្រឹក្សា និងដោយមានការគាំទ្រពីគណៈកម្មាធិការសម្របសម្រួលបច្ចេកទេស គណៈអភិបាលត្រូវបង្កើត**ក្រុមការងារ**មួយសម្រាប់ធ្វើជាសេនាធិការក្នុងការទទួលខុសត្រូវចំពោះការរៀបចំសេចក្តីព្រាងផែនការអភិវឌ្ឍ និងកម្មវិធីវិនិយោគ ដោយផ្អែកលើមតិត្រឡប់មកវិញនៅក្នុងអំឡុងពេល**សិក្ខាសាលាវេទិកា និងកិច្ចប្រជុំពិគ្រោះយោបល់**។ នាយក ប្រធាន ឬតំណាងរបស់អង្គភាពខ្សែបណ្តោយជាសមាជិករបស់ក្រុមការងារ។ សមាសភាពក្រុមការងារកសាងផែនការ ដូចគ្នានឹងសមាសភាពគណៈកម្មាធិការសម្របសម្រួលបច្ចេកទេស ។

✓ ក្រុមការងារ មានការទទួលខុសត្រូវចំពោះការរៀបចំផែនការការងារក្នុងការរៀបចំផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគសម្រាប់ដាក់ជូនគណៈអភិបាល។ ក្រុមការងារនេះ ក៏ត្រូវជួយគណៈអភិបាលផងដែរក្នុងការរៀបចំសិក្ខា-សាលា និងវេទិកាពិគ្រោះយោបល់ ។

✓ **គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការនារី និងកុមារ** មានភារកិច្ចចូលរួមនៅក្នុងកិច្ចប្រជុំទាំងអស់ទាក់ទងនឹងដំណើរការកសាងផែនការ។ អាណត្តិរបស់គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការនារី និងកុមារ គឺត្រូវផ្តល់អនុសាសន៍ដល់ក្រុមប្រឹក្សា អភិបាល គណៈអភិបាល និងគណៈកម្មាធិការផ្សេងទៀតរបស់ក្រុមប្រឹក្សា ដើម្បីធានាឱ្យបានថា តម្រូវការ និងផលប្រយោជន៍របស់ស្ត្រី និងកុមារ ត្រូវបានពិចារណា និងផ្តល់អាទិភាព (មាត្រា ១២៨ និង ១២៩ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ) ។

✓ ក្រុមប្រឹក្សា អាចបង្កើតគណៈកម្មាធិការ ដើម្បីជួយការងាររបស់ក្រុមប្រឹក្សា។ ឧទាហរណ៍ នៅក្នុងបរិបទនៃការកសាងផែនការ ក្រុមប្រឹក្សាអាចសម្រេចបង្កើតគណៈកម្មាធិការកសាងផែនការឬ គណៈកម្មាធិការកសាង ផែនការ និងថវិកា (មាត្រា ១១៥ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ) ។

> ចំពោះព័ត៌មានបន្ថែមស្តីពីគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការនារី និងកុមារ សូមអានមេរៀនទី ៧។

## ប្រព័ន្ធកសាងផែនការ

✓ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ បង្កើតឱ្យមាន**រដ្ឋបាលឯកភាព** ដោយមានបំណងពង្រឹងឯកភាពរបស់រដ្ឋ ដើម្បីសម្របសម្រួលសកម្មភាពរដ្ឋបាលសាធារណៈទាំងអស់នៅក្នុងដែនសមត្ថកិច្ចរបស់

ខ្លួន។ ផែនការអភិវឌ្ឍដែលដាក់បញ្ចូលផ្នែកនានាក្រោមការគ្រប់គ្រង និងការត្រួតពិនិត្យរបស់ក្រសួង ស្ថាប័ន មន្ទីរ និងអង្គភាព រួមចំណែកដល់**ការធ្វើសមាហរណកម្មតាមវិស័យ** ដែលជាការសម្រួលដល់រដ្ឋបាលសាធារណៈនៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សា។

✓ នៅក្នុងបណ្តាឆ្នាំដំបូងនៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ មុនពេលមុខងារតាមវិស័យត្រូវបានផ្ទេរដល់ក្រុមប្រឹក្សា តម្រូវការឱ្យក្រុមប្រឹក្សា**សម្របសម្រួលជាមួយក្រសួង** ស្ថាប័ន មន្ទីរ និងអង្គភាពនានា នឹងមានកម្រិតខ្ពស់។ នៅពេលមុខងារមួយត្រូវបានផ្ទេររួមជាមួយនឹងធនធានសមស្រប (ហិរញ្ញវត្ថុ បុគ្គលិក និងទ្រព្យសម្បត្តិ) ក្រុមប្រឹក្សានឹងមានលទ្ធភាពកាន់តែប្រសើរក្នុងការរៀបចំផែនការ និងថវិកាដោយខ្លួនឯងផ្ទាល់ ពីព្រោះមុខងារ និងធនធាន នឹងក្លាយទៅជា "កម្មសិទ្ធិ"របស់ក្រុមប្រឹក្សា។

✓ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ក៏មានចែងផងដែរអំពី**ការធ្វើសមាហរណកម្មផែនការរបស់ក្រុមប្រឹក្សាស្រុក និងផែនការរបស់ក្រុមប្រឹក្សាឃុំ សង្កាត់**។ នៅក្នុងផែនការអភិវឌ្ឍរយៈពេល ៥ ឆ្នាំ និងកម្មវិធីវិនិយោគរយៈពេលបីឆ្នាំ ក្របខ័ណ្ឌចំណាយរយៈពេលមធ្យម និងថវិកាប្រចាំឆ្នាំរបស់ខ្លួន ក្រុមប្រឹក្សាស្រុកត្រូវដាក់បញ្ចូលតម្រូវការ និងសំណូមពររបស់ក្រុមប្រឹក្សាឃុំ សង្កាត់នៅក្នុងដែនសមត្ថកិច្ចរបស់ស្រុក។ ក្រុមប្រឹក្សាស្រុក អាចលើកតម្រូវការ និងសំណូមពររបស់ក្រុមប្រឹក្សាឃុំ សង្កាត់ជូនទៅក្រសួង ស្ថាប័ន មន្ទីរ និងអង្គភាពនានានៅក្នុងដែនសមត្ថកិច្ចរបស់ស្រុក តាមរយៈគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសរបស់ ក្រុមប្រឹក្សាស្រុក។

ចំពោះព័ត៌មានបន្ថែមស្តីពីទំនាក់ទំនងរវាងស្រុកជាមួយឃុំ សង្កាត់ សូមអានមេរៀនទី ១១។

✓ **គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ** (គ.ជ.អ.ប) ដើរតួនាទីជាគន្លឹះទាក់ទងនឹងការកសាងផែនការនៅថ្នាក់ក្រោមជាតិ:

ចំពោះព័ត៌មានបន្ថែមស្តីពី គ.ជ.អ.ប សូមអានមេរៀនទី ១០។

- គ.ជ.អ.ប មាន**អនុគណៈកម្មាធិការផែនការអភិវឌ្ឍន៍នៅថ្នាក់ក្រោមជាតិ** ដែលមានតួនាទីជួយ និងផ្តល់យោបល់ដល់ គ.ជ.អ.ប អំពីការងារទាក់ទងនឹងផែនការអភិវឌ្ឍ និងកម្មវិធីវិនិយោគរបស់ក្រុមប្រឹក្សានៅថ្នាក់ក្រោមជាតិ។
- គ.ជ.អ.ប មានការទទួលខុសត្រូវក្នុងការធានាឱ្យបានថា ក្រសួង និងស្ថាប័ននៅថ្នាក់ជាតិ ដាក់បញ្ចូលផែនការ និងថវិកាអភិវឌ្ឍនៅថ្នាក់ក្រោមជាតិរបស់ខ្លួនទៅក្នុងផែនការ និងថវិកាអភិវឌ្ឍរបស់ក្រុមប្រឹក្សានៅតាមថ្នាក់នីមួយៗ ។

(មាត្រា ២០១ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ)

**ការអនុវត្ត និងការពិនិត្យតាមដាន**

✓ ក្រុមប្រឹក្សា មានការទទួលខុសត្រូវចំពោះការណែនាំគណៈអភិបាលអំពីរបៀបអនុវត្តផែនការអភិវឌ្ឍ និងកម្មវិធីវិនិយោគដែលបានអនុម័ត ដោយមានតម្លាភាព មានគណនេយ្យភាព មានការចូលរួម និងមានប្រសិទ្ធិភាព។

✓ ក្រុមប្រឹក្សា ក៏ត្រូវចាត់ចែងឱ្យមានការពិនិត្យតាមដានលើការរីកចំរើនទៅក្នុងការអនុវត្តផែនការអភិវឌ្ឍ និងកម្មវិធីវិនិយោគ។

✓ គណៈអភិបាល ត្រូវដាក់ជូនក្រុមប្រឹក្សានូវរបាយការណ៍ប្រចាំឆ្នាំស្តីពីការអនុវត្តកម្មវិធីវិនិយោគ។

**ឧទាហរណ៍នៃ**

**សមាហរណកម្មស្រុក-ឃុំ សង្កាត់**

នៅក្នុងស្រុកមួយមាន១១ ឃុំ។ ក្នុងនោះឃុំចំនួន ៨ នៃឃុំទាំង ១១ មានបញ្ហាគ្រោះរាំងស្ងួតជារៀងរាល់ឆ្នាំ ពីព្រោះមិនមានប្រភពទឹកសម្រាប់ស្រោចស្រព។

ក្រុមប្រឹក្សាស្រុកទូកទឹក បានដាក់បញ្ចូលតម្រូវការរបស់ឃុំឱ្យមានប្រព័ន្ធធារាសាស្ត្រនៅក្នុងផែនការអភិវឌ្ឍន៍។ ការពិត ក្រុមប្រឹក្សាស្រុក បានពិភាក្សាបញ្ហានេះអស់រយៈពេលជាយូរមកហើយ ហើយមានការព្រមព្រៀងគ្នាជាបណ្ដោះអាសន្នថា ក្រុមប្រឹក្សាស្រុក នឹងផ្ដល់មូលនិធិ និងកសាងប្រព័ន្ធធារាសាស្ត្រដោយខ្លួនឯង ដើម្បីបំរើឃុំទាំង ៨។ ទោះជាយ៉ាងក៏ដោយ ដោយសារធនធានមានកម្រិត គេគិត ថាការងារនេះ អាចធ្វើបានយ៉ាងច្រើនបំផុតត្រឹមពីរឃុំក្នុងមួយឆ្នាំ។ ក្រុមប្រឹក្សា បានប្រមើលមើលថា គំរោងនេះនឹងត្រូវចំណាយរយៈពេលប្រហែល ៥ ឆ្នាំ ដើម្បីបញ្ចប់។

នៅក្នុងអំឡុងពេលនៃការប្រជុំរបស់គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស គណៈអភិបាល បានដឹងថា ក្រសួងធនធានទឹកមានផែនការរួចហើយ ដើម្បីសាងសង់ប្រព័ន្ធធារាសាស្ត្រនៅក្នុងតំបន់ខ្លះនៅក្នុងខេត្ត។ តំបន់ជាគោលដៅរបស់ខេត្ត នៅមិនទាន់បានសម្រេចនៅឡើយ។

បន្ទាប់ពីមានការប្រជុំមួយចំនួនមក ក្រុមប្រឹក្សាស្រុក បានទទួលជោគជ័យនៅក្នុងការចរចារជាមួយក្រសួង និងមន្ទីរធនធានទឹកដើម្បីជ្រើសរើសយកស្រុករបស់ខ្លួនជាតំបន់គោលដៅមួយខ្លួន។ ទោះជាយ៉ាងណាក៏ដោយ ដោយសារធនធានរបស់ខ្លួនមានកម្រិត ក្រសួងមិនអាចធ្វើការនៅឃុំទាំង ៨ បានឡើយ។

ក្រុមប្រឹក្សាស្រុក និងក្រសួងបានឯកភាពគ្នា:

- ក្រសួងនឹងធ្វើការនៅក្នុងឃុំចំនួន ៦ ហើយក្រុមប្រឹក្សាស្រុក នឹងធ្វើការនៅក្នុងឃុំដែលនៅសល់ចំនួន២។
- ក្រសួង និងក្រុមប្រឹក្សាស្រុក នឹងសម្របសម្រួលការងាររបស់ខ្លួន ហើយប្រើប្រាស់វិធី និងបទដ្ឋានបច្ចេកទេសដូចគ្នា
- ប្រព័ន្ធធារាសាស្ត្រដែលក្រសួង និងស្រុកបានសាងសង់ នឹងត្រូវភ្ជាប់គ្នានៅកន្លែងសមស្រប។

ក្រសួងបានដាក់បញ្ចូលការចាត់ចែងនេះនៅក្នុងផែនការ និងថវិកាតាមវិស័យរបស់ខ្លួន។ មន្ទីរធនធានទឹកបានដាក់បញ្ចូលគំរោងនៅក្នុងផែនការ និងថវិការបស់មន្ទីរ។ ក្រុមប្រឹក្សាស្រុក បានបញ្ចូលគំរោងទាំងមូល (ផ្នែកដែលត្រូវអនុវត្តដោយក្រុមប្រឹក្សាស្រុក និងផ្នែកដែលត្រូវអនុវត្តដោយក្រសួង និងមន្ទីរ) នៅក្នុងផែនការអភិវឌ្ឍន៍ ផែនការវិនិយោគពាឆ្នាំរំកិល ផែនការចំណាយ និងថវិកាដែលបានធ្វើបច្ចុប្បន្នភាពរបស់ក្រុមប្រឹក្សាស្រុក។

ទាំងក្រុមប្រឹក្សាស្រុក និងក្រសួង បានចាប់ផ្ដើមការងាររបស់ខ្លួន។ ជំនាញការបច្ចេកទេសរបស់ខ្លួន ជួបប្រជុំជាទៀងទាត់។ គេប្រមើលមើលថា គម្រោង នឹងត្រូវបញ្ចប់នៅក្នុងរយៈពេលពីរឆ្នាំ។

## ការពិចារណាជាគន្លឹះមួយចំនួន

### ការកសាងផែនការពីក្រោមឡើងលើ ឬពីលើចុះក្រោម

- ដូចនៅប្រទេសដទៃទៀតដែរ កម្ពុជា បានកំណត់អាទិភាពជាតិសម្រាប់ការអភិវឌ្ឍ។ អាទិភាពទាំងនេះ ត្រូវបានឆ្លុះបញ្ចាំងនៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងផែនការរបស់វិស័យជាក់លាក់។ ទន្ទឹមនឹងនេះ ក្រុមប្រឹក្សាឃុំ សង្កាត់ និងក្រុមប្រឹក្សាថ្មី ត្រូវអនុវត្តដំណើរការកសាងផែនការរបស់ខ្លួនផ្ទាល់នៅថ្នាក់ក្រោមជាតិ។
- ដូច្នេះ ត្រូវការឱ្យមានយុទ្ធសាស្ត្រ ដើម្បីធ្វើសមាហរណកម្មប្រកបដោយអត្ថន័យនូវដំណើរការកសាងផែនការនៅក្នុងចំណោមថ្នាក់ទាំងអស់។
- ដោយពិចារណាថា ក្រុមប្រឹក្សាឃុំ សង្កាត់ គឺជាក្រុមប្រឹក្សាតែមួយគត់ដែលត្រូវបោះឆ្នោតជ្រើសរើសដោយផ្ទាល់ និងដោយពិចារណាថា ក្រុមប្រឹក្សានេះ ស្ថិតនៅកៀកនឹងប្រជាពលរដ្ឋបំផុតនោះ ជាការត្រឹមត្រូវដែលការកសាងផែនការនៅថ្នាក់ក្រោមជាតិត្រូវចាប់ផ្ដើមពីតម្រូវការ និងអាទិភាពដែលលើកឡើងដោយប្រជាពលរដ្ឋនៅក្នុងអំឡុងពេលនៃដំណើរការកសាងផែនការឃុំ សង្កាត់។
- បន្ទាប់មក ផែនការរបស់ក្រុមប្រឹក្សាស្រុក អាចសំយោគតម្រូវការរបស់ឃុំ សង្កាត់ដែលមិនអាចឆ្លើយតបដោយឃុំ សង្កាត់ខ្លួនឯងផ្ទាល់។ បន្ទាប់មក ក្រុមប្រឹក្សាខេត្ត អាចជាទីប្រជុំនៃអាទិភាពជាតិ និងតម្រូវការនៅមូលដ្ឋាន។ ទោះបីជាយ៉ាងណាក្ដី តំបន់ប្រជុំជន នឹងត្រូវមានការដោះស្រាយដោយឡែក។

### ការកសាងផែនការ និងគណនេយ្យភាព

- ជាការសំខាន់ដែលត្រូវរៀបចំប្រព័ន្ធកសាងផែនការអន្តររដ្ឋបាលដែលលើកទឹកចិត្តក្រុមប្រឹក្សាថ្នាក់លើ និងថ្នាក់ជាតិឱ្យឆ្លើយតបនឹងតម្រូវការដែលបានលើកឡើងនៅថ្នាក់មូលដ្ឋាន (គណនេយ្យភាពចុះក្រោម)។
- ក៏ជាការសំខាន់ផងដែរក្នុងការលើកទឹកចិត្តឱ្យមានគណនេយ្យភាពមួយចំនួនពីក្រោមឡើងលើ ដើម្បីឱ្យក្រុមប្រឹក្សានៅថ្នាក់ក្រោមជាតិ រួមចំណែកចំពោះការសម្រេចបានអាទិភាពរបស់ជាតិ។

## វគ្គទី ២:

## សង្ខេបមេរៀន

- ក្រុមប្រឹក្សា ត្រូវរៀបចំ និងអនុម័តផែនការអភិវឌ្ឍរយៈពេល ៥ ឆ្នាំ។ គ្រប់ក្រុមប្រឹក្សា ក៏ត្រូវរៀបចំ និងអនុម័តកម្មវិធីវិនិយោគរយៈពេល ៣ ឆ្នាំផងដែរ។ ផែនការអភិវឌ្ឍ និងកម្មវិធីវិនិយោគ ត្រូវពិនិត្យតាមដាន វាយតម្លៃ និងធ្វើបច្ចុប្បន្នភាពជារៀងរាល់ឆ្នាំ។
- នៅក្នុងការរៀបចំផែនការអភិវឌ្ឍរបស់ខ្លួន ក្រុមប្រឹក្សាត្រូវកំណត់តម្រូវការរបស់ស្ត្រី និងបុរស យុវជន កុមារ និងក្រុមងាយរងគ្រោះ រួមទាំងជនក្រីក្រ និងជនជាតិដើមភាគតិច។
- នៅក្នុងការរៀបចំ និងការអនុវត្តផែនការអភិវឌ្ឍ ក្រុមប្រឹក្សា ត្រូវពិគ្រោះយោបល់យ៉ាងទូលំទូលាយ រួមមានជាមួយប្រជាពលរដ្ឋនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ក្រុមប្រឹក្សាផ្សេងទៀតក្រសួងស្ថាប័នពាក់ព័ន្ធ និងអ្នកពាក់ព័ន្ធផ្សេងទៀត។
- ផែនការអភិវឌ្ឍរបស់ក្រុមប្រឹក្សា ត្រូវឆ្លុះបញ្ចាំងសកម្មភាពទាំងអស់នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ ដូច្នេះផែនការអភិវឌ្ឍ ត្រូវដាក់បញ្ចូលសកម្មភាពរបស់វិស័យទាំងអស់នៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សា ទោះបីជាសកម្មភាពទាំងនេះ មិនស្ថិតនៅក្រោមការគ្រប់គ្រង និងការត្រួតពិនិត្យរបស់ក្រុមប្រឹក្សាក្តី។
- មានតម្រូវការយ៉ាងធំធេងក្នុងការដាក់បញ្ចូលដំណើរការកសាងផែនការនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និងនៅក្នុងចំណោមថ្នាក់ក្រោមជាតិ។

## ឧបសម្ព័ន្ធ ៣៖

## ធនធានឯកសារ

១. ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ឆ្នាំ ២០០៦-២០១០

២. ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ដែលបានធ្វើបច្ចុប្បន្នភាព ឆ្នាំ ២០០៦-២០១០

៣. គណនេយ្យភាព និងការកសាងផែនការនៅក្នុងវិមជ្ឈការនៅកម្ពុជា ដោយលោក ហ៊ិន វុទ្ធី និងលោក ដាវីដ ក្រេដ (David Craig) វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កម្ពុជា ឆ្នាំ ២០០៨

៤. ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់

៥. គោលការណ៍ណែនាំដែលបានកែសម្រួលស្តីពីផែនការអភិវឌ្ឍឃុំ និងកម្មវិធីវិនិយោគឃុំ ក្រសួងផែនការ និងក្រសួងមហាផ្ទៃ ឆ្នាំ ២០០៦។

## វគ្គទី ៥:

## ការងារជាក្រុម

**ការងារជាក្រុមដែលបានពិពណ៌នាខាងក្រោម អាចមានភាពមិនសមស្របសម្រាប់ការបណ្តុះបណ្តាលទាំងអស់។ សូមចាត់ទុកការងារជាក្រុមខាងក្រោមថាគ្រាន់តែជាសំណូមពរប៉ុណ្ណោះ។**

១. បែងចែកសិក្ខាកាមជាក្រុមដែលមានសមាជិកមិនលើសពី ៨ នាក់។

**លំហាត់: ករណីសិក្សា និងការពិភាក្សាតាមក្រុម**

- កម្ពុជា មានរដ្ឋបាលបួនថ្នាក់គឺ ថ្នាក់ជាតិ ថ្នាក់ខេត្ត/រាជធានីភ្នំពេញ ថ្នាក់ក្រុង/ស្រុក/ខណ្ឌ និងថ្នាក់ឃុំ សង្កាត់។
- សមាសធាតុដ៏សំខាន់មួយនៃប្រព័ន្ធកសាងផែនការ គឺផែនការអភិវឌ្ឍន៍ឃុំ សង្កាត់។ ផែនការអភិវឌ្ឍន៍រយៈពេល ៥ ឆ្នាំនេះ ត្រូវរៀបចំឡើងដោយមានការពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋ។ បន្ទាប់មក ផែនការអភិវឌ្ឍន៍ត្រូវធ្វើបច្ចុប្បន្នភាពជារៀងរាល់ឆ្នាំ ដោយផ្អែកលើការវាយតម្លៃលើការអនុវត្តនៅឆ្នាំកន្លងមក។
- ផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ ត្រូវបានបង្ហាញ និងពិភាក្សានៅក្នុងកិច្ចប្រជុំដែលរៀបចំដោយក្រុមប្រឹក្សាស្រុក។ ក្រុមប្រឹក្សាស្រុក និងក្រុមប្រឹក្សាឃុំនៅក្នុងស្រុក ចូលរួមនៅក្នុងកិច្ចប្រជុំនេះ។
- នៅក្នុងកិច្ចប្រជុំនៅស្រុក បុគ្គលិកផែនការរបស់ក្រុមប្រឹក្សាស្រុក សម្របសម្រួលដំណើរការ ដើម្បីកំណត់តម្រូវការដែលមានផលប៉ះពាល់មកលើឃុំច្រើនជាងមួយ។ តម្រូវការទាំងនេះ អាចត្រូវដោះស្រាយតាមរយៈកិច្ចសហប្រតិបត្តិការអន្តរឃុំ ឬប្រសិនបើឃុំស្ទើរតែទាំងអស់ មានតម្រូវការដូចគ្នា តម្រូវការនេះ អាចត្រូវដោះស្រាយដោយក្រុមប្រឹក្សាស្រុក។
- ក្រុមប្រឹក្សាស្រុក ក៏អាចលើកឡើងពីសេវា ឬសកម្មភាពបន្ថែមដែលខ្លួនគិតថាជាអាទិភាព។ វាអាស្រ័យលើក្រុមប្រឹក្សាឃុំក្នុងការសម្រេចថាតើខ្លួនទទួល ឬមិនទទួលយកសំណើរបស់ក្រុមប្រឹក្សាស្រុក។
- បុគ្គលិកផែនការ ក៏នឹងសម្របសម្រួលផងដែរលើការកំណត់ប្រភពមូលនិធិ (ពីវិស័យ និងដៃគូអភិវឌ្ឍន៍) សម្រាប់អាទិភាពដែលក្រុមប្រឹក្សាឃុំ បានកំណត់។

- នៅពេលមិនអាចរកមូលនិធិបានសម្រាប់គាំទ្រអាទិភាពរបស់ឃុំ បញ្ហាត្រូវចងក្រងជាឯកសារ ហើយព័ត៌មានត្រូវផ្តល់ជូនក្រុមប្រឹក្សាខេត្ត។ នៅពេលក្រុមប្រឹក្សាខេត្ត មិនអាចជួយស្វែងរកមូលនិធិ ព័ត៌មានត្រូវផ្តល់ជូនទៅក្រសួងខ្សែបណ្តោយ។ ដូច្នេះ ក្រសួងខ្សែបណ្តោយ នឹងអាចដឹងអំពីអាទិភាពនៅមូលដ្ឋានដែលមិនបានឆ្លើយតប។
- ជាចុងក្រោយ ក្រុមប្រឹក្សាស្រុក នឹងកំណត់ និងពិភាក្សាជាមួយក្រុមប្រឹក្សាឃុំអំពីតម្រូវការគាំទ្រអ្វីដែលឃុំ នឹងត្រូវការពីក្រុមប្រឹក្សាស្រុក ដើម្បីអនុវត្តផែនការអភិវឌ្ឍឃុំ សង្កាត់របស់ខ្លួន។
- ផែនការអភិវឌ្ឍស្រុក នឹងមានបញ្ចូលៈ
    - អាទិភាពទាំងអស់ដែលបានកំណត់ដោយឃុំដែលមានមូលនិធិគាំទ្រ
    - បញ្ជីគម្រោងអន្តរឃុំដែលមានមូលនិធិគាំទ្រ
    - អាទិភាពឃុំដែលនឹងត្រូវដោះស្រាយដោយក្រុមប្រឹក្សាស្រុក
    - អាទិភាពដែលមិនមានមូលនិធិគាំទ្រ ហើយត្រូវបានបញ្ជូនទៅក្រុមប្រឹក្សាខេត្តសម្រាប់ពិចារណាផ្តល់មូលនិធិគាំទ្រ
    - ទិដ្ឋភាពទូទៅនៃសេវាដែលក្រុមប្រឹក្សាស្រុក នឹងផ្តល់ ដើម្បីគាំទ្រឃុំក្នុងការអនុវត្តផែនការអភិវឌ្ឍរបស់ខ្លួន។

**សូមពិភាក្សានៅក្នុងក្រុមៈ**

- តើលោក អ្នកគិតថា តួនាទីរបស់ឃុំ សមស្របឬទេ?
- តើលោក អ្នកគិតថា តួនាទីរបស់ស្រុក សមស្របឬទេ?
- ជារួម តើលោក អ្នកគិតថា គុណសម្បត្តិ និងគុណវិបត្តិនៃការកសាងផែនការតាមវិធីនេះ មានអ្វីខ្លះ?

# មេរៀនសំរាប់ការយល់ដឹង និង
# ការបណ្តុះបណ្តាលអំពី
# ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល រាជធានី
# ខេត្ត ក្រុង ស្រុក ខណ្ឌ

## មេរៀនទី ១៥:
## វិមជ្ឈការសារពើពន្ធ និង
## ការគ្រប់គ្រងហិរញ្ញវត្ថុ

វគ្គទី ១:

១. សេចក្តីផ្តើម

២. វិមជ្ឈការសារពើពន្ធ

៣. ការគ្រប់គ្រងហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិ

៤. ការចាត់ចែងហិរញ្ញវត្ថុរបស់ឃុំ សង្កាត់

## ផ្នែកទី ១: សេចក្តីផ្តើម

- ✓ វិមជ្ឈការសារពើពន្ធ គឺជាផ្នែកដ៏សំខាន់ **និងជាផ្នែកដែលមិនអាចខ្វះបាននៅក្នុងកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ**។ វិមជ្ឈការសារពើពន្ធ សំដៅលើសិទ្ធិរបស់ក្រុមប្រឹក្សានៅថ្នាក់ក្រោមជាតិក្នុងការគ្រប់គ្រងប្រមូលចំណូលរបស់ខ្លួនផ្ទាល់ និងការគ្រប់គ្រងហិរញ្ញវត្ថុរបស់ខ្លួនដោយមានស្វ័យភាពបង្គួរ។ វិមជ្ឈការសារពើពន្ធគួរធានាថាក្រុមប្រឹក្សានីមួយៗមានធនធានហិរញ្ញវត្ថុ និងមានឆន្ទានុសិទ្ធិចាំបាច់ ដើម្បីប្រកាន់យកជម្រើសដែលឆ្លើយតបនឹងតម្រូវការពិតប្រាកដរបស់ប្រជាពលរដ្ឋ។
- ✓ **ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ** ឆ្នាំ ២០០៦-២០១០ គូសបញ្ជាក់ពីសារៈសំខាន់របស់ក្រុមប្រឹក្សាក្នុងការមាន**ហិរញ្ញវត្ថុគ្រប់គ្រាន់** (រួមមានចំណូលរបស់ខ្លួនផ្ទាល់ពីពន្ធ និងកម្រៃ)។ (ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ២០០៦-២០១០)។
- ✓ ប្រជាពលរដ្ឋ មានឱកាសកាន់តែធំទូលាយ ដើម្បីចូលរួមចំណែកជាមួយក្រុមប្រឹក្សាដែលបានជាប់ឆ្នោតរបស់ខ្លួន ដើម្បីមានឱកាសធ្វើឱ្យមានឥទ្ធិពលទៅលើរបៀបចំណាយមូលនិធិសាធារណៈនៅថ្នាក់ក្រោមជាតិ។ ក្រៅពីនេះ ប្រជាពលរដ្ឋអាចមើលឃើញយ៉ាងងាយអំពីរបៀបដែលក្រុមប្រឹក្សានៅមូលដ្ឋាន ធ្វើការចំណាយ ឬមិនចំណាយមូលនិធិសាធារណៈ។
- ✓ ជាមួយនឹង**ការលើកកម្ពស់តម្លាភាព** និង **ឱកាសកាន់តែធំទូលាយដើម្បីធ្វើឱ្យមានឥទ្ធិពល**លើសេចក្តីសម្រេចនោះ ប្រជាពលរដ្ឋ គួរស្ថិតនៅក្នុងទីតាំងដ៏ល្អក្នុងធ្វើឱ្យ**ក្រុមប្រឹក្សាមានគណនេយ្យភាព**ចំពោះរបៀបដែលក្រុមប្រឹក្សាចំណាយធនធានហិរញ្ញវត្ថុរបស់ខ្លួន។

**ចំណុចល្អ និងមិនល្អនៃស្វ័យភាពហិរញ្ញវត្ថុ**

ជាមួយនឹងការប្តេជ្ញាចិត្តរបស់ខ្លួនក្នុងការលុបបំបាត់អំពើពុករលួយ រាជរដ្ឋាភិបាលមានការខ្វល់ខ្វាយយ៉ាងត្រឹមត្រូវអំពីសុចរិតភាពនៃមូលនិធិដែលបានផ្ទេរឱ្យថ្នាក់ក្រោមជាតិ។ ជាការសំខាន់ដែលត្រូវមានយន្តការ ដើម្បីចៀសវាងអំពើពុករលួយ និងដើម្បីលាតត្រដាង និងដាក់ទណ្ឌកម្មអំពើពុករលួយនៅពេលដែលអំពើនេះកើតមានឡើង។ ទោះបីជាយ៉ាងក៏ដោយ គ្មានប្រទេសណាមួយនៅលើពិភពលោកដែលមិនមានអំពើពុករលួយនោះឡើយ។

អ្វីដែលសំខាន់នោះ ការខ្វល់ខ្វាយអំពីអំពើពុករលួយ មិនគួរមានអានុភាពលើការចាំបាច់ក្នុងការផ្តល់ដល់ក្រុមប្រឹក្សានូវស្វ័យភាពផ្នែកហិរញ្ញវត្ថុពេញលេញឡើយ។ ក្រុមប្រឹក្សាត្រូវការស្វ័យភាពផ្នែកហិរញ្ញវត្ថុពេញលេញ ដើម្បីមានលទ្ធភាពឆ្លើយតបនឹងតម្រូវការពិតប្រាកដរបស់ប្រជាពលរដ្ឋ។

- ✓ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ផ្តល់ការចង្អុលបង្ហាញយ៉ាងទូលំទូលាយអំពីហិរញ្ញវត្ថុ និងការគ្រប់គ្រងហិរញ្ញវត្ថុរបស់ក្រុមប្រឹក្សា។ ទោះបីជាយ៉ាងណាក៏ដោយ ត្រូវមានការបកស្រាយលើខ្លឹមសារលំអិតជាច្រើនទៀតទាក់ទងនឹងហិរញ្ញវត្ថុ និងការគ្រប់គ្រងហិរញ្ញវត្ថុរបស់ក្រុមប្រឹក្សានៅក្នុងច្បាប់ និងលិខិតបទដ្ឋាន រួមមាន *ច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលនៅថ្នាក់ក្រោមជាតិ* (មាត្រា ៤៤-៤៦, ២៤៤, ២៤៥, ២៤៨, ២៥៣, ២៥៥នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ)។
- ✓ គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប) មានអនុគណៈកម្មាធិការកិច្ចការសារពើពន្ធ និងហិរញ្ញវត្ថុ ដែលជួយ និងផ្តល់យោបល់ គ.ជ.អ.ប អំពីការងារទាក់ទងនឹងកិច្ចការហិរញ្ញវត្ថុ និងសារពើពន្ធរបស់ក្រុមប្រឹក្សានៅថ្នាក់ក្រោមជាតិ (មាត្រា ១០ នៃអនុក្រឹត្យស្តីពីការបង្កើតអនុគណៈកម្មាធិការ គ.ជ.អ.ប)។

**កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (PFM)**

វិមជ្ឈការហិរញ្ញវត្ថុ មានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយនឹងកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (PFM)។ ទិសដៅមួយនៅក្នុងកម្មវិធីគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (ដំណាក់កាលទី២ ឆ្នាំ២០០៨ ដល់ឆ្នាំ២០១០) គឺដើម្បី *ពង្រឹង និងអភិវឌ្ឍគោលនយោបាយ និងយុទ្ធសាស្ត្រវិមជ្ឈការសារពើពន្ធ*។ ទិសដៅនេះ នឹងត្រូវសម្រេចបានតាមរយៈការធានាឱ្យបានថា គោលនយោបាយ វិមជ្ឈការរបស់រាជរដ្ឋាភិបាល និងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវបានអនុវត្ត និងថាគោលនយោបាយ និងច្បាប់នេះ មានបញ្ចូល**គណនេយ្យភាព**។ កំណែទម្រង់ពីរ គឺកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ និងកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ត្រូវដំណើរការព្រមគ្នា និងមានសុខដុមជាមួយគ្នា។

នៅថ្នាក់ឃុំ សង្កាត់ ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ មានបំណងកែលម្អការរៀបចំ និងការអនុវត្តថវិកា ក៏ដូចជាប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុរបស់ក្រុមប្រឹក្សា។ ក្តីសង្ឃឹមគឺថា ជាការចាប់ផ្តើមការប្រមូលចំណូលមិនមែនជាពន្ធ នឹងមានការកើនឡើង (សូមអានកម្មវិធីកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី ២ ទំព័រ ៤២ ទិសដៅទី ២៧)។

**ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មាត្រា ២៤១-២៥៣, ២៨០**

## សេចក្តីផ្តើម

✓ សមាសធាតុដ៏សំខាន់នៅក្នុងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ បានកំណត់អោយមានការ**មុខងារគ្រប់គ្រង** ត្រូវបាន**ផ្ទេរ**ឱ្យក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ និងក្រុមប្រឹក្សា ឃុំ (មាត្រា ២១៤, ២១៧, ២៧៧, ២៧៨, ២៨១ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ)។

- **ឧទាហរណ៍** ក្រុមប្រឹក្សាក្រុងអាចទទួលបានការផ្ទេរមុខងារឱ្យប្រមូលសម្រាម សាងសង់ ជួសជុល និងថែទាំប្រព័ន្ធលូបង្ហូរទឹកកខ្វក់ និងផ្តល់ទីជម្រកដល់ជនអនាថា។ ក្រុមប្រឹក្សាស្រុក អាចទទួលបានការផ្ទេរមុខងារក្នុងនោះផ្តល់ការអប់រំនៅបឋមសិក្សា និងគ្រប់គ្រងមន្ទីរពេទ្យបង្អែកស្រុក។ ក្រុមប្រឹក្សាឃុំ អាចទទួលបានការផ្ទេរមុខងារ ឱ្យផ្តល់សេវាផ្សព្វផ្សាយកសិកម្ម និងផ្គត់ផ្គង់ទឹកស្អាត និងគ្រប់គ្រងមណ្ឌលសុខភាព។

> ចំពោះព័តិមានបន្ថែមស្តីពីការផ្ទេរមុខងារដល់ក្រុមប្រឹក្សា សូមអានមេរៀនទី ១៣។

✓ ជាការគ្មានន័យអ្វីឡើយក្នុងការផ្ទេរមុខងារ (ទោះបីជាមុខងាររដ្ឋបាល ឬមុខងារតាមវិស័យក្តី) ដោយមិនផ្ទេរឱ្យក្រុមប្រឹក្សាក្នុងពេលជាមួយគ្នានូវធនធានដែលក្រុមប្រឹក្សាត្រូវការដើម្បីអនុវត្តមុខងារថ្មីទាំងនោះ។ ដូច្នេះ សមាសធាតុដ៏សំខាន់ទីពីរនៅក្នុងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ គឺថាធនធាន **ត្រូវតែមានអមជាមួយមុខងារ**។ ប្រការនេះ មានន័យថា នៅពេលមុខងារ ត្រូវបានផ្ទេរឱ្យក្រុមប្រឹក្សា ក្រុមប្រឹក្សាក៏ត្រូវតែទទួលបានធនធានសមស្រប (ហិរញ្ញវត្ថុ បុគ្គលិក និងទ្រព្យសម្បត្តិ) ដើម្បីធ្វើឱ្យក្រុមប្រឹក្សា មានលទ្ធភាពអនុវត្តមុខងារ (មាត្រា ២១៧, ២៤២, ២៨០ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ)។

✓ សមាសធាតុដ៏សំខាន់ទីបីនៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ គឺថា ក្រុមប្រឹក្សា ត្រូវមាន**ចំណូលគ្រប់គ្រាន់** ដើម្បីអនុវត្តកិច្ចការទូទៅរបស់ខ្លួន (មាត្រា ២៤២ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ)។

✓ ការដាក់សមាសធាតុទីពីរ និងទីបីជាមួយគ្នា មានន័យថា ក្រុមប្រឹក្សា ត្រូវមាន**ចំណូលគ្រប់គ្រាន់** ដើម្បីឱ្យក្រុមប្រឹក្សាមានលទ្ធភាព:

- អនុវត្តមុខងារជាកាតព្វកិច្ចរបស់ខ្លួន
- អនុវត្តមុខងារជាជម្រើសមួយចំនួន
- បំពេញភារកិច្ចតាមផ្លូវច្បាប់របស់ខ្លួន
- ទូទាត់ការចំណាយផ្នែករដ្ឋបាលសមស្របរបស់ខ្លួន
- អនុវត្តមុខងារ និងភារកិច្ចរបស់ខ្លួនទៅតាមរបៀបដែលជំរុញការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ។ (មាត្រា ២៤២ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ)

**មុខងារជាកាតព្វកិច្ច**

មុខងារដែលកំណត់ដោយលិខិតបទដ្ឋានថាជាមុខងារដែលតម្រូវឱ្យក្រុមប្រឹក្សាអនុវត្ត។

**មុខងារជាជម្រើស**

មុខងារដែលក្រុមប្រឹក្សាអាចជ្រើសរើសអនុវត្ត ឬអាចជ្រើសរើសមិនអនុវត្ត។

**ថវិកា**

✓ **ភ្នំពេញ** និងគ្រប់**ខេត្ត ក្រុង** និង**ស្រុក** មានថវិកាប្រចាំឆ្នាំរបស់ខ្លួនផ្ទាល់។ (មាត្រា ៤៤ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ)។

✓ **ឃុំ** និង**សង្កាត់ទាំងអស់នៅក្នុងស្រុក** មានថវិការបស់ខ្លួនផ្ទាល់ ដូចមានចែងនៅក្នុងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ (មាត្រា ៧៣ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់)។

✓ ថវិការបស់**ខណ្ឌ និងសង្កាត់**នៅរាជធានីភ្នំពេញ គឺជាផ្នែកមួយនៃថវិការបស់រាជធានីភ្នំពេញ។ ថវិការបស់សង្កាត់នៅក្នុងក្រុង គឺជាផ្នែកមួយនៃថវិការបស់ក្រុង។ (មាត្រា ៤៤, ២៤៤ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ)។ ការកំណត់បែបនេះ ធ្វើឱ្យរាជធានីភ្នំពេញ និងក្រុង មានលទ្ធភាពធានាឱ្យមានការអភិវឌ្ឍទីប្រជុំជនដែលមានសង្គតិភាព និងមានលក្ខណៈឯកភាពគ្នា។

✓ ក្រុមប្រឹក្សា អនុម័តថវិការបស់ខ្លួនអនុលោមទៅតាមដំណើរការប្រចាំឆ្នាំនៃការរៀបចំថវិការដ្ឋ។ ក្រុមប្រឹក្សា ក៏ត្រូវអនុម័តផងដែរនូវ**ក្របខ័ណ្ឌចំណាយរយៈពេលមធ្យម**ដែលត្រូវធ្វើបច្ចុប្បន្នភាពជារៀងរាល់ឆ្នាំ (មាត្រា ៤៤ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ)។

✓ ថវិការបស់ក្រុមប្រឹក្សា ត្រូវមានតុល្យភាពរវាងចំណូល និងចំណាយ (មាត្រា ៤៤ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ)។

✓ **គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស**របស់ក្រុមប្រឹក្សា ត្រូវធានាឱ្យបានថា ថវិការបស់ក្រសួងដែលផ្តល់សេវានៅក្នុងដែនសមត្ថកិច្ចរបស់ក្រុម

ចំពោះព័ត៌មានបន្ថែមស្តីពីគណៈកម្មាធិការសម្របសម្រួលបច្ចេកទេស សូមអានមេរៀនទី ៧។

ប្រឹក្សា ត្រូវបានដាក់បញ្ចូលទៅក្នុងថវិកា-កម្មវិធី វិនិយោគ និងក្របខ័ណ្ឌចំណាយរយៈពេលមធ្យមរបស់ក្រុមប្រឹក្សា។

> **តើការបង់ពន្ធ ឬកម្រៃសេវា អាចបង្កើនគណនេយ្យភាពតាមវិធីណា?**
>
> នៅពេលលោក អ្នកបង់ពន្ធ ឬកម្រៃសេវាពីហោប៉ៅរបស់លោក អ្នក លោកអ្នកទំនងជាមានក្តីរំពឹងខ្ពស់ពីសេវាដែលលោក អ្នកនឹងទទួលបាន។ ដូច្នេះ លោក អ្នកទំនងជាតម្រូវឱ្យសមាជិកក្រុមប្រឹក្សាដែលជាប់ឆ្នោតរបស់លោក អ្នក ឆ្លើយតបចំពោះសេវាដែលមិនស្របទៅនឹងក្តីរំពឹងរបស់លោក អ្នក។ នៅពេលរដ្ឋាភិបាលប្រមូលពន្ធ និងកម្រៃផ្ទាល់ពីប្រជាពលរដ្ឋរបស់ខ្លួន រដ្ឋាភិបាលមានអារម្មណ៍មានការទទួលខុសត្រូវកាន់តែខ្ពស់ក្នុងការប្រើប្រាស់មូលនិធិ ទៅតាមរបៀបដែលមានការឆ្លើយតបចំពោះតម្រូវការពិតប្រាកដរបស់ប្រជាពលរដ្ឋ។

**ប្រភពចំណូលរបស់ក្រុមប្រឹក្សា**

✓ ក្រុមប្រឹក្សារាជធានីភ្នំពេញ និងក្រុមប្រឹក្សាខេត្ត ក្រុង និងស្រុក មានសិទ្ធិទទួលបាន**ចំណូលពីបីប្រភពគឺ**

- ចំណូលផ្ទាល់ខ្លួននៅមូលដ្ឋាន
- ចំណូលពីថ្នាក់ជាតិ
- ចំណូលផ្សេងទៀត (មាត្រា ២៤៤ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ)

✓ **ចំណូលផ្ទាល់ខ្លួននៅមូលដ្ឋាន អាចត្រូវប្រមូលតាមរយៈ**

- ពន្ធនៅមូលដ្ឋាន (នឹងត្រូវកំណត់នៅក្នុងច្បាប់នៅពេលខាងមុខ)
- កម្រៃ និងឈ្នួល (នឹងត្រូវកំណត់នៅក្នុងច្បាប់ ឬលិខិតបទដ្ឋាននានានៅពេលខាងមុខ)
- ចំណូលរបស់ក្រុមប្រឹក្សាស្រុកពីពន្ធ ដែលត្រូវចែករំលែកជាមួយក្រុមប្រឹក្សាឃុំ សង្កាត់ (នឹងត្រូវកំណត់នៅក្នុងច្បាប់នៅពេលខាងមុខ)
- អំណោយស្ម័គ្រចិត្ត
- ប្រភពផ្សេងទៀតដែលមានចែងនៅក្នុងច្បាប់ ឬអនុក្រឹត្យនៅពេលខាងមុខ (មាត្រា ២៤៦ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ)។

✓ ក្រុមប្រឹក្សា ត្រូវប្រើប្រាស់ចំណូលរបស់ខ្លួន ដើម្បីផ្តោតទៅលើតម្រូវការអភិវឌ្ឍន៍សំខាន់បំផុត រួមមាន **តម្រូវការខុសគ្នារបស់ស្ត្រី យុវជន កុមារ និងក្រុមងាយរងគ្រោះ**រួមទាំងជនក្រីក្រ និងជនជាតិដើមភាគតិច (មាត្រា ៤២ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ)។

✓ ក្រៅពីនេះ ជាការសំខាន់ដែលត្រូវធានាថា ពន្ធ កម្រៃ និងឈ្នួល មិនមាន**ផលប៉ះពាល់ដោយមិនសមាមាត្រ និងដោយមិនយុត្តិធម៌មកលើស្ត្រី ឬមកលើជនក្រីក្រ ឬក្រុមងាយរងគ្រោះផ្សេងទៀត**។

✓ **ចំណូលពីថ្នាក់ជាតិ** មានតាមរយៈ:

- ការចែករំលែកចំណូលជាតិ (នឹងត្រូវកំណត់នៅក្នុងច្បាប់នៅពេលខាងមុខ)
- មូលនិធិផ្ទេរពីថវិកាជាតិ (នឹងត្រូវកំណត់នៅក្នុងច្បាប់នៅពេលខាងមុខ)
- កម្រៃជាភ្នាក់ងារសម្រាប់សេវាពិសេសដែលអនុវត្តដោយក្រុមប្រឹក្សាក្នុងនាមក្រសួង (មាត្រា ២៤៧ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ)។

✓ **មូលនិធិផ្ទេរពីថវិការជាតិ**ឡើងតាមរយៈ**ប្រាក់ផ្ទេរដោយមានភ្ជាប់ល័ក្ខខ័ណ្ឌ និងគ្មានភ្ជាប់ល័ក្ខខ័ណ្ឌ** (មាត្រា ២៤៩ ដល់ ២៥១ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ)។

**ប្រាក់ផ្ទេរជាតិដល់ក្រុមប្រឹក្សា**

| **ប្រាក់ផ្ទេរគ្មានល័ក្ខខ័ណ្ឌ** | **ប្រាក់ផ្ទេរមានល័ក្ខខ័ណ្ឌ** |
|---|---|
| ✓ ដើម្បីបំពេញភារកិច្ចតាមផ្លូវច្បាប់របស់ក្រុមប្រឹក្សា | ✓ ដើម្បីអនុវត្តមុខងារជាកាតព្វកិច្ច |
| ✓ ដើម្បីអនុវត្តមុខងារជាជម្រើស | ✓ ដើម្បីអនុវត្តមុខងារជាជម្រើសដែលកំពុងដំណើរការ |
| ✓ ដើម្បីទូទាត់ការចំណាយផ្នែករដ្ឋបាល | ✓ សម្រាប់គោលបំណងជាកាតព្វកិច្ចដែលបានកំណត់ផ្សេងទៀត |
| ✓ ដើម្បីអនុវត្តមុខងារ និងភារកិច្ចទៅតាមរបៀបដែលជំរុញការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ | |

# សេចក្តីសង្ខេបអំពីប្រភពចំណូល

## ទាំងបីរបស់ក្រុមប្រឹក្សា



## ផ្នែកទី ៣៖ ការគ្រប់គ្រងហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិ

### ការគ្រប់គ្រងហិរញ្ញវត្ថុ

**ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ**

**មាត្រា** ៤២. ៤៥. ២៤១. ២៥២

- ✓ ក្រុមប្រឹក្សា ត្រូវគ្រប់គ្រង និងប្រើប្រាស់ហិរញ្ញវត្ថុរបស់ខ្លួន ដើម្បី**ជំរុញការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ**។ ក្រុមប្រឹក្សាក៏ត្រូវផ្តោតផងដែរទៅលើតម្រូវការអភិវឌ្ឍន៍ជាក់លាក់ រួមមាន **សេវាជាមូលដ្ឋាន និងចាំបាច់** និងតម្រូវការខុសៗ គ្នារបស់ស្ត្រី យុវជន កុមារ និងក្រុមងាយរងគ្រោះ (មាត្រា ៤២. ២៤១ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ)។
- ✓ ហិរញ្ញវត្ថុរបស់ក្រុមប្រឹក្សា គឺជាហិរញ្ញវត្ថុរបស់រដ្ឋ ដូច្នេះ **គឺជាហិរញ្ញវត្ថុរបស់ប្រជាពលរដ្ឋកម្ពុជាទាំងអស់**។
- ✓ ដូច្នេះ ក្រុមប្រឹក្សា ត្រូវគ្រប់គ្រងកិច្ចការហិរញ្ញវត្ថុរបស់ខ្លួនទៅតាមរបៀបដែលមាន**តម្លាភាព និងគណនេយ្យភាព**ចំពោះប្រជាពលរដ្ឋរបស់ខ្លួន (មាត្រា ៤៣ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ)។
- ✓ ក្រុមប្រឹក្សា ត្រូវអនុវត្តទៅតាមបទបញ្ជា ប្រព័ន្ធ និងនីតិវិធីទាក់ទងនឹងការគ្រប់គ្រងហិរញ្ញវត្ថុ ដូចជា ទាក់ទងនឹង**ការរៀបចំបញ្ជីគណនេយ្យ** និង**របាយការណ៍ លទ្ធកម្ម** និង**សវនកម្ម**ផ្ទៃក្នុង និងផ្ទៃក្រៅ (មាត្រា ៤៥ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ)។។
- ✓ ក្រុមប្រឹក្សា មិនត្រូវបានអនុញ្ញាតឱ្យខ្ចីប្រាក់ឡើយ (មាត្រា ២៥២ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ)។

**ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ**

**មាត្រា ៤៦. ២៥៤ - ២៦១**

- ✓ ក្រុមប្រឹក្សា មានការទទួលខុសត្រូវចំពោះការប្រើប្រាស់ និងការគ្រប់គ្រងយ៉ាងមានប្រសិទ្ធិភាពលើទ្រព្យសម្បត្តិរដ្ឋ ដែលបានផ្ទេរមកឱ្យក្រុមប្រឹក្សា ឬដែលបានទទួលដោយមធ្យោបាយផ្ទាល់ខ្លួន។ ក្រុមប្រឹក្សា**មានគណនេយ្យភាពចំពោះប្រជាពលរដ្ឋ**អំពីរបៀបដែលក្រុមប្រឹក្សាគ្រប់គ្រង និងប្រើប្រាស់ទ្រព្យសម្បត្តិរបស់ខ្លួន (មាត្រា ៤៣.៤៦ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ)។

- ✓ ក្រុមប្រឹក្សាទទួលទ្រព្យសម្បត្តិស្របទៅនឹងមុខងារដែលបានផ្ទេរឱ្យក្រុមប្រឹក្សា ពោលគឺ **ទ្រព្យសម្បត្តិអមជាមួយនឹងមុខងារ**។ ក្នុងករណីដែលមុខងារ ត្រូវបានផ្ទេរ ហើយទ្រព្យសម្បត្តិចាំបាច់ មានបរិមាណមិនគ្រប់គ្រាន់ ឬ គ្មានតែម្តង ក្រុមប្រឹក្សា ត្រូវទទួលបានធនធានហិរញ្ញវត្ថុ ដើម្បីដោះស្រាយមធ្យោបាយចាំបាច់សម្រាប់បំពេញសេចក្តីត្រូវការរបស់ខ្លួន (មាត្រា ២១៧.២៥៦.២៥៨ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ)។

**ឧទាហរណ៍**

**មុខងារវិស័យអប់រំ**

អាចមានសេចក្តីសម្រេចថា ក្រុមប្រឹក្សាឃុំ នឹងទទួលបានការផ្ទេរមុខងារ ដើម្បី*បង្កើត និងប្រតិបត្តិមត្តេយ្យសាលា*។ ប្រសិនបើមុខងារនេះ ត្រូវបានផ្ទេរឱ្យក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាឃុំ ក៏ត្រូវទទួលបានផងដែរនូវ:

- *ហិរញ្ញវត្ថុចាំបាច់*
- *បុគ្គលិកដែលមានជំនាញចាំបាច់*
- ***ទ្រព្យសម្បត្តិ*** ដែលទាក់ទងនឹងមត្តេយ្យសាលា ដូចជា អគារមត្តេយ្យសាលាដែលមានស្រាប់និងសំភារៈឧបទ្ទេស។

- ✓ ក្រុមប្រឹក្សា អាចគ្រប់គ្រង ប្រើប្រាស់ និង**ទាញយកចំណូល**ពីទ្រព្យសម្បត្តិរដ្ឋដែលបានផ្ទេរមកឱ្យក្រុមប្រឹក្សា(មាត្រា ២៥៩ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ)។

- ✓ ក្រុមប្រឹក្សាគ្មានសិទ្ធិលក់ទ្រព្យសម្បត្តិរដ្ឋ ដោយគ្មានការយល់ព្រមពីក្រសួងមហាផ្ទៃ និងសេដ្ឋកិច្ច និងហិរញ្ញវត្ថុឡើយ (មាត្រា ២៥៥ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ)។

**តួអង្គពាក់ព័ន្ធ**

✓ **ក្រុមប្រឹក្សា** មានសិទ្ធិទាំងស្រុងលើការអនុម័តថវិកា កម្មវិធីវិនិយោគ និងក្របខ័ណ្ឌចំណាយរយៈពេលមធ្យមរបស់ក្រុមប្រឹក្សា (មាត្រា ៤៤, ២៤៥ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ)។

✓ **អភិបាល** គឺជាអាណាប័កក្នុងនាមក្រុមប្រឹក្សារបស់ខ្លួន។ (មាត្រា ២៤៥ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ)។

វាជា**ការរំលោភអំណាច** ប្រសិនបើសមាជិកក្រុមប្រឹក្សា អភិបាល គណៈអភិបាល ប្រធានហិរញ្ញវត្ថុ ឬបុគ្គលិករបស់ក្រុមប្រឹក្សា យក ឬប្រើប្រាស់មូលនិធិ ឬទ្រព្យសម្បត្តិរបស់ក្រុមប្រឹក្សាជាប្រយោជន៍ផ្ទាល់ខ្លួន។

✓ **គណៈអភិបាល** ជួយក្រុមប្រឹក្សាក្នុងការអនុវត្តភារកិច្ចរបស់ខ្លួនទាក់ទងនឹងហិរញ្ញវត្ថុ។ គណៈអភិបាល រៀបចំសេចក្តីព្រាងថវិកា កម្មវិធីវិនិយោគ និងក្របខ័ណ្ឌចំណាយរយៈពេលមធ្យម ហើយដាក់ជូនក្រុមប្រឹក្សាសម្រាប់ពិចារណា និងសម្រេច។ គណៈអភិបាល រាយការណ៍ និងផ្តល់អនុសាសន៍ដល់ក្រុមប្រឹក្សានៅក្នុងកិច្ចប្រជុំទាំងអស់ទាក់ទងនឹងហិរញ្ញវត្ថុរបស់ក្រុមប្រឹក្សា។ គណៈអភិបាល ក៏ត្រូវបំពេញការងារជាមួយគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសផងដែរ *(សូមអានខាងក្រោម)* (មាត្រា ១៥៦, ១៦៣, ១៦៥ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ)។

✓ ក្រុមប្រឹក្សា មាន**ប្រធានហិរញ្ញវត្ថុ**មួយរូបដែលត្រូវតែងតាំងដោយក្រុមប្រឹក្សា បន្ទាប់ពីមានការយល់ព្រមពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមសំណើរបស់ក្រសួងមហាផ្ទៃ។ ប្រធានហិរញ្ញវត្ថុ មានការទទួលខុសត្រូវចំពោះការគ្រប់គ្រងហិរញ្ញវត្ថុ និងការងារលទ្ធកម្ម ហើយត្រូវធានាឱ្យមានការធ្វើសវនកម្មហិរញ្ញវត្ថុត្រឹមត្រូវ (មាត្រា ១៧៩,១៨០ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ)។

✓ ក្រុមប្រឹក្សា ត្រូវមាន**គណៈកម្មាធិការលទ្ធកម្ម**។ គណៈកម្មាធិការលទ្ធកម្ម ធានាថា ការងារលទ្ធកម្មទាំងអស់ ត្រូវធ្វើឡើងដោយភាពស្មោះត្រង់ មានតម្លាភាព និងមិនលំអៀង និងអនុលោមទៅតាមច្បាប់ស្តីពីលទ្ធកម្មសាធារណៈ (មាត្រា ១៣៦,១៣៧ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ)។

✓ **គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស** មានតួនាទីនៅក្នុងការរៀបចំថវិកា កម្មវិធីវិនិយោគ និងក្របខ័ណ្ឌចំណាយរយៈពេលមធ្យមរបស់ក្រុមប្រឹក្សា។ គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស បំពេញការងារ ដើម្បីធានាថា ផែនការ និងថវិការបស់ក្រសួង ស្ថាប័ន មន្ទីរ និងអង្គភាពរបស់រាជរដ្ឋាភិបាលកម្ពុជាដែលប្រតិបត្តិការនៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សា ត្រូវបានដាក់បញ្ចូលទៅក្នុងផែនការអភិវឌ្ឍន៍ ថវិកា និងកម្មវិធីវិនិយោគរបស់ក្រុមប្រឹក្សា។

ចំពោះព័ត៌មានបន្ថែមស្តីពីគណៈកម្មាធិការសម្របសម្រួលបច្ចេកទេស សូមអានមេរៀនទី ៧។

✓ រដ្ឋបាលទាំងអស់ មានអង្គភាពមួយដែលបំពេញការងារលើការគ្រប់គ្រងហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិ (មាត្រា ៥៨, ១១២, ១៧៣ នៃអនុក្រឹត្យស្តីពីតួនាទីខេត្ត)

ចំពោះព័ត៌មានបន្ថែមស្តីពីអង្គភាពរដ្ឋបាល សូមអានមេរៀនទី ១២។

## តួអង្គផ្នែកហិរញ្ញវត្ថុនៅថ្នាក់ក្រោមជាតិ



គណៈកម្មាធិការ
លទ្ធកម្ម



អភិបាល



ក្រុមប្រឹក្សា



គណៈអភិបាល



គណៈកម្មាធិការ
សម្របសម្រួល
បច្ចេកទេស



ប្រធានហិរញ្ញវត្ថុ

✓ ដូចដែលបានលើកឡើង ខ្លឹមសារលំអិតជាច្រើនទាក់ទងនឹងហិរញ្ញវត្ថុរបស់ក្រុមប្រឹក្សា និងការគ្រប់គ្រងហិរញ្ញវត្ថុ ត្រូវចែងនៅក្នុងច្បាប់ និងលិខិតបទដ្ឋានបន្ថែមទៀត រួមមាន *ច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលនៅថ្នាក់ក្រោមជាតិ* (មាត្រា ៤៤-៤៦, ២៤៤, ២៤៥, ២៤៨, ២៥៣, ២៥៥ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ)។

## ផ្នែកទី ៤: ការចាត់ចែងផ្នែកហិរញ្ញវត្ថុរបស់ឃុំ សង្កាត់

✓ **ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់** ចែងថា:

- ក្រុមប្រឹក្សាឃុំ សង្កាត់នីមួយៗ មាន**ធនធានហិរញ្ញវត្ថុ ទ្រព្យសម្បត្តិ និងថវិការបស់ខ្លួនផ្ទាល់** (មាត្រា ៧៣ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់)។
- ក្រុមប្រឹក្សាឃុំ សង្កាត់ មាន**សិទ្ធិប្រមូលចំណូលផ្ទាល់ខ្លួន**ពីចំណូលពន្ធ ចំណូលមិនមែនពន្ធ និងកម្រៃ (ការប្រមូលពន្ធត្រូវធ្វើឡើងអនុលោមទៅតាមច្បាប់) (មាត្រា៧៤នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់)។
- ក្រុមប្រឹក្សាឃុំ សង្កាត់ មានសិទ្ធិទទួលបាន:
    - **ការបែងចែកចំណូលជាតិ**
    - កម្រៃពីការអនុវត្ត**មុខងារជាភ្នាក់ងារ**
    - មូលនិធិបន្ថែមពីប្រភពខាងក្នុង និងក្រៅប្រទេស (មាត្រា ៧៥,៧៦ និង៧៨ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់) រួមទាំងមូលនិធិពីដៃគូអភិវឌ្ឍន៍ និងអង្គការមិនមែនរដ្ឋាភិបាល។

> **មុខងារជាភ្នាក់ងារ**
>
> មុខងារដែលត្រូវបានធ្វើប្រតិភូកម្ម ដោយក្រសួងខ្សែបណ្តោយ ឬស្ថាប័នរបស់រាជរដ្ឋាភិបាលដល់ក្រុមប្រឹក្សាឃុំ សង្កាត់។ មុខងារត្រូវអនុវត្តដោយក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងនាមក្រសួងខ្សែបណ្តោយ ឬស្ថាប័នរបស់រាជរដ្ឋាភិបាល។

- **មូលនិធិឃុំ សង្កាត់** ត្រូវបានបង្កើតឡើងនៅថ្នាក់ជាតិជាយន្តការសម្រាប់ការផ្ទេរមូលនិធិពីថ្នាក់ជាតិដល់ក្រុមប្រឹក្សាឃុំ សង្កាត់ ដោយមានបដិភាគរបស់រាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍ (មាត្រា ៧៧ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់)
- ក្រុមប្រឹក្សាឃុំ សង្កាត់ ទទួលបាន**ទ្រព្យសម្បត្តិ**រដ្ឋ ដែលក្រុមប្រឹក្សាអាចប្រើប្រាស់ និងបង្កើតចំណូល (មាត្រា ៨១ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់)។

✓ ក្រុមប្រឹក្សាឃុំ សង្កាត់ ក៏មានសិទ្ធិប្រមូល**ចំណូលនៅមូលដ្ឋាន**មួយចំនួនផងដែរ ដូចជាកម្រៃពីការចុះអត្រានុកូលដ្ឋាន។

✓ បរិមាណនៃមូលនិធិដែលក្រុមប្រឹក្សាឃុំ សង្កាត់បានទទួលតាមរយៈការផ្ទេរពីថ្នាក់ជាតិ មានលក្ខណៈបង្គួរ ប៉ុន្តែមានការកើនឡើងជារៀងរាល់ឆ្នាំ។ នៅឆ្នាំ ២០០២ ក្រុមប្រឹក្សាទទួលបាន ១.២% នៃចំណូលជាតិ។ សម្រាប់ឆ្នាំ ២០០៨ ក្រុមប្រឹក្សា ទទួលបាន**២,៧៥% នៃចំណូលជាតិ**។ នៅឆ្នាំ ២០០៨ ទឹកប្រាក់**ជាមធ្យម**នៅក្នុងថវិកាអភិវឌ្ឍន៍របស់ក្រុមប្រឹក្សាឃុំ សង្កាត់ មានប្រហែល **១០.០០០ ដុល្លារអាមេរិក**។

- ✓ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ នឹងបន្តគ្រប់គ្រងក្រុមប្រឹក្សាឃុំនៅក្នុងស្រុកទាក់ទងនឹងហិរញ្ញវត្ថុ។ ទោះជាយ៉ាងណាក្តី ថវិការបស់សង្កាត់នៅរាជធានីភ្នំពេញ និងនៅក្រុង នឹងត្រូវដាក់បញ្ចូលទៅក្នុងថវិការបស់រាជធានីភ្នំពេញ និងថវិការបស់ក្រុង។ ( មាត្រា ២៤៤, ២៨៣នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ) ។
- ✓ ក្រៅពីនេះ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ចែងថា នៅពេលឃុំ ទទួលមុខងារពីថ្នាក់ជាតិ ឃុំក៏ត្រូវទទួលបានធនធានផងដែរ គឺហិរញ្ញវត្ថុ បុគ្គលិក និងទ្រព្យសម្បត្តិ ដែលចាំបាច់ដើម្បីអនុវត្តមុខងារ ( មាត្រា២១៧ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ) ។

> ក្រុមប្រឹក្សាឃុំ សង្កាត់ភាគច្រើន បានប្រើប្រាស់ធនធានហិរញ្ញវត្ថុរបស់ខ្លួនសម្រាប់គម្រោងហេដ្ឋារចនាសម្ព័ន្ធ។

- ✓ ដូចគ្នានេះដែរ នៅពេលក្រុមប្រឹក្សារាជធានីភ្នំពេញ ឬក្រុមប្រឹក្សាក្រុង ធ្វើប្រតិភូកម្មមុខងារដល់សង្កាត់ ធនធានបន្ថែមដែលសង្កាត់ត្រូវការ ដើម្បីអនុវត្តមុខងារឱ្យមានប្រសិទ្ធិភាព គួរផ្ទេរឱ្យសង្កាត់។

**បញ្ហាដែលត្រូវដោះស្រាយ**

ខ្លឹមសារលម្អិតជាច្រើនទាក់ទងនឹងហិរញ្ញវត្ថុ និងការគ្រប់គ្រងហិរញ្ញវត្ថុរបស់ក្រុមប្រឹក្សា នឹងត្រូវចែងនៅក្នុងច្បាប់ និងលិខិតបទដ្ឋាន រួមមាន *ច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលនៅថ្នាក់ក្រោមជាតិ* ( មាត្រា ៤៤-៤៦. ២៤៤. ២៤៥. ២៤៨. ២៥៣. ២៥៥ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ) ។

ជាការសំខាន់ដែលត្រូវពិចារណាសារនៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិៈ ដើម្បីធ្វើឱ្យមានភាពខុសគ្នាពិតប្រាកដនៅក្នុងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ក្រុមប្រឹក្សា ត្រូវការ**ហិរញ្ញវត្ថុគ្រប់គ្រាន់** និង**ចំណូលរបស់ខ្លួនផ្ទាល់** និងមានសិទ្ធិគ្រប់គ្រងការប្រមូលចំណូលផ្ទាល់ខ្លួន ក៏ដូចជា**ស្វ័យភាពផ្នែកហិរញ្ញវត្ថុពេញលេញ**។ ដើម្បីឆ្លើយតប ទៅនឹងតម្រូវការនៅមូលដ្ឋាន ក្រុមប្រឹក្សា ត្រូវមាន**មូលនិធិឆន្ទានុសិទ្ធិ** ដែលក្រុមប្រឹក្សាអាចប្រើប្រាស់ទៅ តាមការយល់ឃើញរបស់ខ្លួនថាជាការសមស្រប។

ក៏ជាការសំខាន់ផងដែរដែលច្បាប់ និងលិខិតបទដ្ឋាន មានបញ្ចូលយន្តការដ៏រឹងមាំសម្រាប់**តម្លាភាព ការចូលរួមរបស់ប្រជាពលរដ្ឋ** និង**យន្តការគណនេយ្យភាព** ដើម្បីផ្តល់លទ្ធភាពឱ្យប្រជាពលរដ្ឋធ្វើឱ្យក្រុមប្រឹក្សារបស់ខ្លួនមានគណនេយ្យភាពចំពោះរបៀបប្រើប្រាស់មូលនិធិសាធារណៈ។

ដើម្បីឱ្យយន្តការទាំងនោះមានន័យ **ក្រុមប្រឹក្សាខ្លួនឯងផ្ទាល់ ត្រូវមានយន្តការដ៏រឹងមាំ** ដើម្បីធានាឱ្យមានតម្លាភាព និងធ្វើឱ្យ**តួអង្គពាក់ព័ន្ធផ្សេងទៀត**នៅក្នុងហិរញ្ញវត្ថុ និងការគ្រប់គ្រងហិរញ្ញវត្ថុរបស់ក្រុមប្រឹក្សាមានគណនេយ្យភាព។ តួអង្គផ្សេងទៀត រួមមាន អភិបាល គណៈអភិបាល ប្រធានហិរញ្ញវត្ថុ និងគណៈកម្មាធិការលទ្ធកម្ម។ ឧទាហរណ៍ ជាការសំខាន់ដែលត្រូវមានសមាជិកក្រុមប្រឹក្សានៅក្នុង**គណៈកម្មាធិការលទ្ធកម្ម** ពីព្រោះសមាជិកក្រុមប្រឹក្សា មានគណនេយ្យភាពដោយផ្ទាល់ចំពោះប្រជាពលរដ្ឋអំពីរបៀបចំណាយមូលនិធិសាធារណៈ។

## វគ្គទី ២ៈ

## សង្ខេបមេរៀន

- ភ្នំពេញ ខេត្ត ក្រុង ស្រុក ឃុំនៅក្នុងស្រុក មានថវិការបស់ខ្លួនផ្ទាល់។ ខណ្ឌ និងសង្កាត់នៅភ្នំពេញ ទទួលថវិកាពីក្រុមប្រឹក្សារាជធានីភ្នំពេញ។ សង្កាត់នៅក្នុងក្រុង ទទួលថវិកាពីក្រុមប្រឹក្សាក្រុង។

- ក្រុមប្រឹក្សា ត្រូវអនុម័តថវិកាប្រចាំឆ្នាំរបស់ខ្លួន ហើយត្រូវអនុម័តក្របខ័ណ្ឌចំណាយរយៈពេលមធ្យមដែលត្រូវធ្វើបច្ចុប្បន្នភាពជារៀងរាល់ឆ្នាំ។

- ក្រៅពីក្រុមប្រឹក្សា តួអង្គខាងក្រោម មានការពាក់ព័ន្ធនៅក្នុងការគ្រប់គ្រងហិរញ្ញវត្ថុ។ អភិបាល គណៈអភិបាល ប្រធានហិរញ្ញវត្ថុ គណៈកម្មាធិការលទ្ធកម្ម។ គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស ក៏ដើរតួនាទីផងដែរ។

- វិមជ្ឈការសារពើពន្ធ ធានាថា ក្រុមប្រឹក្សាមានហិរញ្ញវត្ថុ និងស្វ័យភាពផ្នែកហិរញ្ញវត្ថុដែលចាំបាច់ដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋ។

- សមាសធាតុដ៏សំខាន់នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ គឺថា ក្រុមប្រឹក្សា ទទួលបានការផ្ទេរមុខងារតាមវិស័យ ដើម្បីអនុវត្ត។ មុខងារ ត្រូវផ្ទេរទន្ទឹមគ្នានឹងការផ្ទេរហិរញ្ញវត្ថុ បុគ្គលិក និងទ្រព្យសម្បត្តិសមស្របដែលចាំបាច់ ដើម្បីអនុវត្តមុខងារឱ្យមានប្រសិទ្ធភាព។

- ក្រុមប្រឹក្សា មានសិទ្ធិទទួលបានធនធានហិរញ្ញវត្ថុគ្រប់គ្រាន់ ដើម្បីអនុវត្តមុខងាររបស់ខ្លួន បំពេញភារកិច្ចតាមផ្លូវច្បាប់ ទូទាត់ការចំណាយផ្នែករដ្ឋបាល និងអនុវត្តភារកិច្ច និងមុខងាររបស់ខ្លួនទៅតាមរបៀបដែលជំរុញការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ។

- ក្រុមប្រឹក្សា មានប្រភពចំណូលបីគឺ ចំណូលផ្ទាល់ខ្លួននៅមូលដ្ឋាន (រួមមាន ពន្ធ កម្រៃ និងឈ្នួលនៅមូលដ្ឋាន) ចំណូលពីថ្នាក់ជាតិ (រួមមានការចែករំលែកចំណូលជាតិ និងការផ្ទេរពីថ្នាក់ជាតិ) និងចំណូលផ្សេងទៀត។

- ចំណូលមួយចំនួនរបស់ក្រុមប្រឹក្សា ត្រូវបានបម្រុងដោយឡែកសម្រាប់គោលបំណងជាក់លាក់ (ដូចជា ដើម្បីអនុវត្តមុខងារជាកាតព្វកិច្ច)។ ទោះជាយ៉ាងណាក៏ដោយ ចំណូលមួយចំនួនរបស់ក្រុមប្រឹក្សា គឺជាចំណូលតាមឆន្ទានុសិទ្ធិដែលក្រុមប្រឹក្សា អាចចំណាយទៅតាមការយល់ឃើញរបស់ខ្លួនថាជាការសមស្រប។

- ជាមួយនឹងកំណើនចំណូល និងជាមួយនឹងចំណូលឆន្ទានុសិទ្ធិ ជាការសំខាន់ដែលក្រុមប្រឹក្សា ត្រូវមានតម្លាភាព និងមានគណនេយ្យភាពចំពោះប្រជាពលរដ្ឋ។

## វគ្គទី ៣៖

## ឯកសារយោង

១. វិមជ្ឈការសារពើពន្ធៈ គោលការណ៍ ទម្លាប់ និងការអនុវត្តនៅកម្ពុជា វគ្គបណ្តុះបណ្តាលស្តីពីវិមជ្ឈការ និងវិសហមជ្ឈការនៅក្នុងវិស័យសង្គម សាស្ត្រាចារ្យ រ៉យ ខែលលី (Roy Kelly) ខែឧសភា ឆ្នាំ ២០០៧

## វគ្គទី ៤:

## ការងារជាក្រុម

**ការងារជាក្រុមដែលបានពិពណ៌នាខាងក្រោម អាចមានភាពមិនសមស្របសម្រាប់ការបណ្តុះបណ្តាលទាំងអស់។ សូមចាត់ទុកការងារជាក្រុមខាងក្រោមថាគ្រាន់តែជាសំណូមពរប៉ុណ្ណោះ។**

១. ចែងចែកសិក្ខាកាមជាក្រុមដែលមានសមាជិកមិនលើសពី ៨ នាក់។

២. ផ្តល់លំហាត់មួយក្នុងចំណោមលំហាត់ខាងក្រោមដល់ក្រុម:

**លំហាត់ទី ១: សង្កាត់ និងខណ្ឌ**

ថវិការបស់ក្រុមប្រឹក្សាខណ្ឌ និងសង្កាត់នៅរាជធានីភ្នំពេញ គឺជាផ្នែកមួយនៃថវិការបស់ក្រុមប្រឹក្សារាជធានីភ្នំ-ពេញ។ ដូចគ្នានេះដែរ ថវិការបស់ក្រុមប្រឹក្សាសង្កាត់នៅក្នុងក្រុង គឺជាផ្នែកមួយនៃថវិការបស់ក្រុមប្រឹក្សាក្រុង។ ដូច្នេះ ខណ្ឌ និងសង្កាត់នៅរាជធានីភ្នំពេញ និងនៅក្នុងក្រុង នឹងទទួលថវិការបស់ខ្លួនពីក្រុមប្រឹក្សារាជធានី ឬក្រុង។

**ពិភាក្សាសំណួរខាងក្រោម:**

- តើលោក អ្នកគិតថាមានការលំបាកពិតប្រាកដអ្វីខ្លះសម្រាប់ខណ្ឌ និងសង្កាត់ដែលទទួលថវិការបស់ខ្លួនពីក្រុមប្រឹក្សារាជធានីភ្នំពេញ ឬក្រុមប្រឹក្សាក្រុង?
- តើសិទ្ធិអំណាច និងឆន្ទានុសិទ្ធិកម្រិតណាដែលខណ្ឌ និងសង្កាត់នឹងមានលើថវិការបស់ខ្លួន?

**លំហាត់ទី ២: បរិញ្ញវត្ថុ និងការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ**

ពិភាក្សាសំណួរខាងក្រោម :

- តើយុទ្ធសាស្ត្រជាក់ស្តែងអ្វីខ្លះ ដើម្បីធានាថា ចំណូល និងចំណាយរបស់ក្រុមប្រឹក្សា មានតម្លាភាពចំពោះប្រជាពលរដ្ឋ ( *ក្រៅពីការបិទផ្សាយព័ត៌មាននៅលើក្តារខៀន* ) ?

- ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ចែងថា ក្រុមប្រឹក្សា ត្រូវគ្រប់គ្រងហិរញ្ញវត្ថុរបស់ខ្លួន ដើម្បីឆ្លើយនឹងតម្រូវការរបស់ស្ត្រី យុវជន កុមារ និងក្រុមងាយរងគ្រោះ ដែលរួមមាន ជនក្រីក្រ និងជនជាតិដើមភាគតិច។ តើវិធីជាក់ស្តែងអ្វីខ្លះដែលក្រុមប្រឹក្សាអាចធានាថា ហិរញ្ញវត្ថុរបស់ខ្លួន ពិតជាដោះស្រាយតម្រូវការរបស់ក្រុមទាំងនេះ?
- តើលោក អ្នកគិតថាមានឧបសគ្គអ្វីខ្លះ ដើម្បីឱ្យប្រជាពលរដ្ឋធ្វើឱ្យក្រុមប្រឹក្សារបស់ខ្លួនមានគណនេយ្យភាពចំពោះរបៀបចំណាយមូលនិធិសាធារណៈ?
- ដោយគិតពីឧបសគ្គទាំងនេះ តើមានយន្តការអ្វីដែលអាចបង្កើតឡើង ដើម្បីផ្តល់លទ្ធផលកាន់តែប្រសើរដល់ប្រជាពលរដ្ឋក្នុងការធ្វើឱ្យក្រុមប្រឹក្សារបស់ខ្លួន មានគណនេយ្យភាពចំពោះរបៀបចំណាយមូលនិធិសាធារណៈ?

**លំហាត់ទី ៣៖ ចំណូលផ្ទាល់**

របៀបចំសំណើលើប្រភពចំណូលសមស្របសម្រាប់ក្រុមប្រឹក្សាតាមថ្នាក់នីមួយៗ។

ដាក់ចំណងជើងសម្រាប់ក្រុមប្រឹក្សាដែលបានរាយខាងក្រោម។ សម្រាប់ក្រុមប្រឹក្សានីមួយៗ កំណត់ប្រភពចំណូលដោយឡែកដែលលោក អ្នកគិតថាសមស្របសម្រាប់ក្រុមប្រឹក្សានោះ។ ត្រៀមបកស្រាយជម្រើសរបស់លោក អ្នក។

- ក្រុមប្រឹក្សាឃុំ
- ក្រុមប្រឹក្សាស្រុក
- ក្រុមប្រឹក្សាក្រុង
- ក្រុមប្រឹក្សាខេត្ត
- ក្រុមប្រឹក្សារាជធានីភ្នំពេញ

**ឧទាហរណ៍លើលទ្ធភាពមួយចំនួនៈ**

| | |
|---|---|
| កម្រៃ ឬឈ្នួលពីសេវាដែលបានផ្តល់ | ភាសីផ្សារ |
| កម្រៃចំពោះអាជ្ញាប័ណ្ណអាជីវកម្ម | ពន្ធលើដីមិនប្រើប្រាស់ |
| ពន្ធលើដីប្រើប្រាស់ | កម្រៃពីការផ្ទេរម្ចាស់កម្មសិទ្ធិដីធ្លី |
| កម្រៃពីការចុះបញ្ជីយានយន្ត | កម្រៃពីការផ្ទេរម្ចាស់កម្មសិទ្ធិយានយន្ត |
| កម្រៃចំណត | ពន្ធលើចំណូល |
| ពន្ធលើតម្លៃបន្ថែម | ឈ្នួលពីការប្រើប្រាស់ធនធានធម្មជាតិ |
| ឈ្នួលពីការប្រើប្រាស់ទ្រព្យសម្បត្តិរបស់ក្រុមប្រឹក្សា | កម្រៃពីការចុះបញ្ជីអត្រានុកូលដ្ឋាន |

# មេរៀនសំរាប់ការយល់ដឹង និង
# ការបណ្តុះបណ្តាលអំពី
# ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល រាជធានី
# ខេត្ត ក្រុង ស្រុក ខណ្ឌ

## មេរៀនទី ១៦:

## ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា

## វគ្គទី ១:

១. ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់

២. ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាថ្មី

## ផ្នែកទី ១: ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់

ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវធ្វើឡើងតាម គ្រប់គ្រងដោយ**ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុម ប្រឹក្សាឃុំ សង្កាត់**ដែលបានធ្វើវិសោធនកម្ម។

**ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ គឺជាគ្រឹះនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាថ្មីនៅរាជធានីភ្នំពេញ ខេត្ត ក្រុង ស្រុក ខណ្ឌ ។**

**វាជាគ្រឹះពីព្រោះសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ជាអ្នកបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាថ្មី។**

- ✓ ក្រុមប្រឹក្សាឃុំ សង្កាត់ **ត្រូវបោះឆ្នោតជ្រើសរើសដោយផ្ទាល់ពីសំណាក់ប្រជាពលរដ្ឋនៅមូលដ្ឋានរបស់ខ្លួន** (មាត្រា ២ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុម ប្រឹក្សាឃុំ សង្កាត់)។
- ✓ ក្រុមប្រឹក្សាឃុំ សង្កាត់ **ត្រូវបោះឆ្នោតជ្រើសរើសឡើងរៀងរាល់ ៥ ឆ្នាំ** (មាត្រា ៣ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់)។
- ✓ ក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវបោះឆ្នោតជ្រើសរើសឡើងអនុលោមទៅតាម**ប្រព័ន្ធសមាមាត្រ** (មាត្រា ៥ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់)។
- ✓ ដើម្បីឈរឈ្មោះជាបេក្ខជនបោះឆ្នោត បុគ្គលនោះត្រូវចុះឈ្មោះ

**តំណាងសមាមាត្រ** គឺជាប្រព័ន្ធបោះឆ្នោត ដែលជាធម្មតានៅក្នុងប្រព័ន្ធនោះ គណបក្សនយោបាយច្រើនជាងមួយទទួលបានអាសនៈ។ ប្រព័ន្ធ ផ្តល់អាសនៈដល់គណបក្សនីមួយៗ ផ្អែកលើសមាមាត្រនៃចំនួនសម្លេងឆ្នោតសរុបដែលគណបក្សនីមួយៗ ទទួលបាននៅក្នុងការបោះឆ្នោត។ ជាឧទាហរណ៍សាមញ្ញ ប្រសិនបើគណបក្សមួយទទួលបានសម្លេងឆ្នោត ៤៥% គណបក្សនោះ ទទួលបានអាសនៈចំនួន ៤៥%។ ប្រសិនបើគណបក្សមួយទទួលបានសម្លេងឆ្នោត ១០% គណបក្សនោះ ទទួលបានអាសនៈ ១០%។

ជាទូទៅ ប្រព័ន្ធតំណាងសមាមាត្រផ្តល់: លទ្ធផលសម្រាប់គណបក្សនយោបាយដែលឆ្លុះបញ្ចាំងយ៉ាងប្រសើរអំពីការពេញចិត្តរបស់ប្រជាពលរដ្ឋ ភាពជាអ្នកតំណាងមានលក្ខណៈប្រសើរសម្រាប់បក្សនយោបាយដែលមានសម្លេងតិច អ្នកទៅបោះឆ្នោតមានចំនួនច្រើន និងឱកាសកាន់តែច្រើនសម្រាប់ស្ត្រីឈរឈ្មោះ។

ក្នុងចំណោមប្រទេសប្រជាធិបតេយ្យនៅលោកខាងលិច ប្រព័ន្ធតំសមាមាត្របានក្លាយទៅជាប្រព័ន្ធបោះឆ្នោតដែលត្រូវអនុវត្តលើសលុប។ ប្រព័ន្ធនេះ ត្រូវបានប្រើប្រាស់នៅក្នុងប្រទេសនៅជុំវិញពិភពលោក ដូចជា អាល្លឺម៉ង់ ស៊ុយអែត អូស្ត្រាលី អាព្រិចខាងត្បូង ប្រេស៊ីល និងប្រទេសជាច្រើនទៀត។

នៅលើ**បញ្ជីឈ្មោះបេក្ខជនរបស់គណបក្សនយោបាយ** (មាត្រា ៤៩ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់) ។

✓ នៅពេលបោះឆ្នោត ប្រជាពលរដ្ឋ ជ្រើសរើសគណបក្សនយោបាយ មិនមែនបេក្ខជនជាបុគ្គលឡើយ (មាត្រា ២១ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុម ប្រឹក្សាឃុំ សង្កាត់) ។

**ព័ត៌មានសំខាន់ៗ មួយចំនួនអំពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់**

| **ការបោះឆ្នោតនៅឆ្នាំ ២០០២** | **ការបោះឆ្នោតនៅឆ្នាំ ២០០៧** |
|---|---|
| គណបក្សនយោបាយចំនួន **៨** ចូលរួម | គណបក្សនយោបាយចំនួន **១២** ចូលរួម |
| បេក្ខជន **៧៥៦៩៥** នាក់ | បេក្ខជន **១០២២៦៦** នាក់ |
| អ្នកបោះឆ្នោត **៤.៥** លាននាក់ | អ្នកបោះឆ្នោត **៥.៣** លាននាក់ |
| សមាជិកក្រុមប្រឹក្សាជាប់ឆ្នោតជាស្ត្រី **៩៥១** នាក់ | សមាជិកក្រុមប្រឹក្សាជាប់ឆ្នោតជាស្ត្រី**១៦៦១** នាក់ |
| សមាជិកក្រុមប្រឹក្សាជាប់ឆ្នោតជាបុរស**១០៣១០**នាក់ | សមាជិកក្រុមប្រឹក្សាជាប់ឆ្នោតជាបុរស**៩៦៩២**នាក់ |
| សមាជិកក្រុមប្រឹក្សាជាប់ឆ្នោតសរុប **១១២៦១** នាក់ | សមាជិកក្រុមប្រឹក្សាជាប់ឆ្នោតសរុប**១១៣៥៣**នាក់ |

ឯកឧត្តម លេង វី *លិខិតបទដ្ឋានក្រោមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ខែឧសភា ឆ្នាំ ២០០៨*

## ផ្នែកទី ២: ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាថ្មី

ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាថ្មី ត្រូវធ្វើឡើងតាម**ច្បាប់ស្ដីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក និងខណ្ឌ** ដែលត្រូវបានអនុម័តនៅឆ្នាំ ២០០៨។

- ✓ ក្រុមប្រឹក្សាថ្មីនីមួយៗ **ត្រូវបោះឆ្នោតជ្រើសរើសឡើងជាអសកល** (មាត្រា ៤ នៃច្បាប់ស្ដីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក និងខណ្ឌ)។
- ✓ ក្រុមប្រឹក្សាថ្មី **ត្រូវបោះឆ្នោតជ្រើសរើសឡើងជាអសកល**ដោយ**សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់**នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន (មាត្រា ២៧ នៃច្បាប់ស្ដីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក និងខណ្ឌ)។
  - **ឧទាហរណ៍** សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ទាំងអស់នៅខេត្តកណ្ដាល នឹងបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាខេត្តកណ្ដាល។ មានតែសមាជិកក្រុមប្រឹក្សាឃុំនៅស្រុកល្វាឯមប៉ុណ្ណោះដែលបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាស្រុកល្វាឯម។
- ✓ **ការបោះឆ្នោតលើកទី១** ដើម្បីជ្រើសរើសក្រុមប្រឹក្សាថ្មី បានប្រព្រឹត្តទៅនៅថ្ងៃទី **១៧ ខែឧសភា ឆ្នាំ ២០០៩** (មាត្រា ៨៩ នៃច្បាប់ស្ដីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក និងខណ្ឌ)។

**ការបោះឆ្នោតសកល និងអសកល**

នៅក្នុង *ការបោះឆ្នោតសកល* ប្រជាពលរដ្ឋខ្លួនឯងផ្ទាល់បោះឆ្នោតជ្រើសរើសតំណាងរបស់ខ្លួន។ ការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រ គឺជាការបោះឆ្នោត*សកល*។ ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ក៏ជាការបោះឆ្នោត*សកល*ដែរ។

មិនដូចរដ្ឋសភា ព្រឹទ្ធសភា ត្រូវបោះឆ្នោត*ជាអសកល*ដោយសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់។ ដូច្នេះ សមាជិកក្រុមប្រឹក្សាដែលជាប់ឆ្នោតជាសកល បោះឆ្នោតជ្រើសរើសសមាជិកព្រឹទ្ធសភា *ក្នុងនាមប្រជាពលរដ្ឋរបស់ខ្លួន*។ ដូច្នេះ នៅក្នុងការបោះឆ្នោតអសកល តំណាងរបស់ប្រជាពលរដ្ឋបោះឆ្នោតជ្រើសរើសតំណាងរបស់ប្រជាពលរដ្ឋបន្ថែមទៀត។

មានការបោះឆ្នោត *អសកល* ដើម្បីជ្រើសរើសក្រុមប្រឹក្សាថ្មីនៅថ្នាក់ក្រោមជាតិ។ ដូច្នេះ អ្នកបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាថ្មី មិនមែនជាប្រជាពលរដ្ឋឡើយ។ ជាជំនួស សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ បោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាថ្មីក្នុងនាមប្រជាពលរដ្ឋរបស់ខ្លួន។

- ✓ ក្រុមប្រឹក្សា នឹង**ត្រូវបោះឆ្នោតជ្រើសរើសឡើងវិញរៀងរាល់ ៥ ឆ្នាំ** ម្តង (មាត្រា ២ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក និងខណ្ឌ)។
- ✓ ដូចគ្នានឹងការបោះឆ្នោតទាំងអស់នៅកម្ពុជាដែរ ក្រុមប្រឹក្សាត្រូវបោះឆ្នោតជ្រើសរើសឡើង អនុលោមតាមប្រព័ន្ធ**តំណាងសមាមាត្រ** (មាត្រា ១៣ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក និងខណ្ឌ)។
- ✓ ដើម្បីឈរឈ្មោះជាបេក្ខជនបោះឆ្នោត បុគ្គលម្នាក់ ត្រូវចុះឈ្មោះនៅលើ**បញ្ជីឈ្មោះបេក្ខជនរបស់គណបក្សនយោបាយ** (មាត្រា ១៦ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក និងខណ្ឌ)។
- ✓ **សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ មិនមានសិទ្ធិ**ឈរឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានីភ្នំពេញ ខេត្ត ក្រុង ស្រុក ខណ្ឌឡើយ (មាត្រា ១៧ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក និងខណ្ឌ)។
- ✓ អ្នកបោះឆ្នោតជ្រើសរើសគណបក្សនយោបាយ មិនមែនជ្រើសរើសបេក្ខជនជាបុគ្គលឡើយ (មាត្រា ៥៣ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក និងខណ្ឌ)។
- ✓ ចំនួនសមាជិកក្រុមប្រឹក្សានៅក្នុងក្រុមប្រឹក្សានីមួយៗ ត្រូវកំណត់ដោយអនុក្រឹត្យ ផ្អែកលើកត្តាប្រជាសាស្ត្រ និងភូមិសាស្ត្រនៅក្នុងតំបន់។ ទោះបីជាយ៉ាងណាក៏ដោយ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មានកំណត់រង្វង់ចំនួនសមាជិកក្រុមប្រឹក្សានីមួយៗ ដូចមានបង្ហាញខាងក្រោម (មាត្រា ១៨ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក និងខណ្ឌ)។

| **រង្វង់ចំនួនសមាជិកក្រុមប្រឹក្សានៅក្នុងក្រុមប្រឹក្សានីមួយៗ** | | | | |
|---|---|---|---|---|
| **ភ្នំពេញ** | **ខេត្ត** | **ស្រុក** | **ក្រុង** | **ខណ្ឌ** |
| អតិបរមា **២១** | **៩ ដល់ ២១** | **៧ ដល់១៩** | **៧ ដល់ ១៥** | **៧ ដល់ ១៩** |

✓ នៅពេលជាប់ឆ្នោត ក្រុមប្រឹក្សា គឺជាតំណាងសាធារណៈ **ជាអ្នកការពារ និងជាអ្នកបំរើ**ផលប្រយោជន៍របស់ប្រជាពលរដ្ឋទាំងអស់នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន (មាត្រា ៦, ៦១, ១១៣ អនុក្រឹត្យលេខ២១៦ អ.ន.ក្រ.បក ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក)

**ហេតុអ្វីបានជាសមាជិកក្រុមប្រឹក្សាដែលជាប់ឆ្នោត មានគណនេយ្យភាពជាលក្ខណៈប្រជាធិបតេយ្យចំពោះប្រជាពលរដ្ឋ?**

**រដ្ឋធម្មនុញ្ញ**នៃព្រះរាជាណាចក្រកម្ពុជា ចែងថា **អំណាចរដ្ឋទាំងអស់ជាកម្មសិទ្ធិរបស់ប្រជាជន**។ ការពិត វាមិនអាចធ្វើបានឡើយ ប្រសិនបើប្រជាជនកម្ពុជាទាំង ១៤លាននាក់ មានការពាក់ព័ន្ធដោយផ្ទាល់គ្រប់គ្នានៅក្នុងការអនុវត្តអំណាចរដ្ឋ។ ដូច្នេះ ប្រជាពលរដ្ឋបោះឆ្នោតជ្រើសរើសតំណាងរបស់ខ្លួន។ តំណាងទាំងនេះ អនុវត្តអំណាចរបស់ប្រជាពលរដ្ឋក្នុងនាមប្រជាជន។

សមាជិកក្រុមប្រឹក្សានៅថ្នាក់ក្រោមជាតិ គឺជាតំណាងដែលបានជាប់ឆ្នោតរបស់ប្រជាពលរដ្ឋ។ ជាតំណាងរបស់ប្រជាជន **សមាជិកក្រុមប្រឹក្សា អនុវត្តអំណាចក្នុងនាមប្រជាជន នៅក្នុងផលប្រយោជន៍របស់ប្រជាជន** និង**ដើម្បីផ្តល់ផលប្រយោជន៍ដល់ប្រជាជន**។

ក្នុងករណីដែលប្រជាពលរដ្ឋ មិនសប្បាយចិត្តនឹងរបៀបដែលសមាជិកក្រុមប្រឹក្សារបស់ខ្លួនអនុវត្តអំណាចរបស់ប្រជាជន ប្រជាពលរដ្ឋ អាចបោះឆ្នោតជ្រើសរើសតំណាងផ្សេងនៅពេលបោះឆ្នោតលើកក្រោយ។ នេះគឺជាវិធីមួយក្នុងការធ្វើឱ្យសមាជិកក្រុមប្រឹក្សា មានគណនេយ្យភាព។

ទោះជាយ៉ាងក៏ដោយ ទាមទារឱ្យមានយន្តការផ្សេងទៀត ដើម្បីធ្វើឱ្យសមាជិកក្រុមប្រឹក្សា មានគណនេយ្យភាព ដើម្បីឱ្យប្រជាពលរដ្ឋ អាចសំដែងការពេញចិត្ត របស់ខ្លួន ឬដាក់ទណ្ឌកម្មក្នុងករណីដែលគាត់មិនពេញចិត្តឱ្យបានញឹកញាប់ជាងការបោះឆ្នោត។

# ការចាត់ចែងបោះឆ្នោតនៅពេលបច្ចុប្បន្ន



## ការបែងចែករដ្ឋបាលដែនដីក្រោមច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ



## វគ្គទី ២:

## សង្ខេបមេរៀន

- ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវបោះឆ្នោតជ្រើសរើសឡើងជាសកលដោយប្រជាពលរដ្ឋ។
- ក្រុមប្រឹក្សារាជធានីភ្នំពេញ និងក្រុមប្រឹក្សាខេត្ត ក្រុង ស្រុក និងខណ្ឌ ត្រូវបោះឆ្នោតជ្រើសរើសឡើងជាអសកល ដោយសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់។
- ក្រុមប្រឹក្សាទាំងអស់នៅថ្នាក់ក្រោមជាតិ រួមទាំងក្រុមប្រឹក្សាឃុំ សង្កាត់ មានអាណត្តិប្រាំឆ្នាំ។
- ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាទាំងអស់នៅថ្នាក់ក្រោមជាតិ រួមទាំងក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវធ្វើឡើង អនុលោមទៅតាមប្រព័ន្ធសមាមាត្រ។ គណបក្សនយោបាយនីមួយៗ ទទួលបានអាសនៈទៅតាមសមាមាត្រនៃ សម្លេងឆ្នោតដែលខ្លួនទទួលបាននៅក្នុងការបោះឆ្នោត។
- បេក្ខជនឈរឈ្មោះបោះឆ្នោតនៅក្នុងក្រុមប្រឹក្សានៅថ្នាក់ក្រោមជាតិទាំងអស់ រួមទាំងក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវ ចុះឈ្មោះនៅលើបញ្ជីឈ្មោះគណបក្សនយោបាយ ហើយអ្នកបោះឆ្នោត ជ្រើសរើសគណបក្សនយោបាយ ជាជាង ជ្រើសរើសបេក្ខជនជាបុគ្គល។

## វគ្គទី ៣៖

## ធនធានឯកសារ

១. រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដែលបានធ្វើវិសោធនកម្ម

២. ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រ ដែលបានធ្វើវិសោធនកម្ម ឆ្នាំ ២០០៧

៣. ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ដែលបានធ្វើវិសោធនកម្ម ឆ្នាំ ២០០៦

៤. ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក និងខណ្ឌ ឆ្នាំ ២០០៨

៥. ឯកឧត្តម លេង វី *លិខិតបទដ្ឋានក្រោមច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់* ខែ ឧសភា ឆ្នាំ ២០០៨។

## វគ្គទី ៤:

## ការងារជាក្រុម

**ការងារជាក្រុមដែលបានពិពណ៌នាខាងក្រោម អាចមានភាពមិនសមស្របសម្រាប់ការបណ្តុះបណ្តាលទាំងអស់ ។ សូមចាត់ទុកការងារជាក្រុមខាងក្រោមថាគ្រាន់តែជាសំណូមពរប៉ុណ្ណោះ ។**

១. បែងចែកសិក្ខាកាមជាក្រុមដែលមានសមាជិកមិនលើសពី ៨ នាក់ ។

**ការបោះឆ្នោតជាសកល និងអសកលៈ**

ពិភាក្សាសំណួរខាងក្រោមៈ

- តើលោក អ្នក គិតថាគុណសម្បត្តិ និងគុណវិបត្តិនៃការបោះឆ្នោតអសកល ដើម្បីជ្រើសរើសក្រុមប្រឹក្សាថ្មី មានអ្វីខ្លះ?

## ឯកសារយោង

១. ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

២. ច្បាប់គ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់

៣. អនុក្រឹត្យលេខ២១៥ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលរាជធានីភ្នំពេញ និងក្រុមប្រឹក្សា គណៈអភិបាលខណ្ឌនៃរាជធានីភ្នំពេញ

៤. អនុក្រឹត្យលេខ២១៦ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក

៥. អនុក្រឹត្យលេខ២១៧ ស្តីពីការបង្កើត ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសក្រុមប្រឹក្សារាជធានីភ្នំពេញ និងគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសក្រុមប្រឹក្សាខណ្ឌនៃរាជធានីភ្នំពេញ

៦. អនុក្រឹត្យលេខ២១៨ ស្តីពីស្តីពីការបង្កើត ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសក្រុមប្រឹក្សាខេត្ត គណៈកម្មាធិការសម្របសម្រួលបច្ចេកទេសក្រុមប្រឹក្សាក្រុង និង គណៈកម្មាធិការសម្របសម្រួលបច្ចេកទេសក្រុមប្រឹក្សាស្រុក

៧. អនុក្រឹត្យលេខ២១៩ ស្តីពីផែនការអភិវឌ្ឍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

៨. ប្រកាសលេខ៤២៧៣ ស្តីពីការបង្កើតការិយាល័យចំណុះទីចាត់ការនៃសាលារាជធានីភ្នំពេញ ការបង្កើតការិយាល័យនៃសាលាខណ្ឌ និងការកំណត់តួនាទី ភារកិច្ច របៀបរបបការងារនៃការិយាល័យទាំងនោះ

៩. ប្រកាសលេខ៤២៧៤ ស្តីពីការបង្កើតការិយាល័យចំណុះទីចាត់ការនៃសាលាខេត្ត ការបង្កើតការិយាល័យនៃសាលាក្រុង ការបង្កើតការិយាល័យនៃសាលាស្រុក និងការកំណត់តួនាទី ភារកិច្ច របៀបរបបការងារនៃការិយាល័យទាំងនោះ

១០. ប្រកាសលេខ៤២៧៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការ ស្ត្រី និងកុមារនៅក្នុងក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ

១១. កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ២០១០-២០១៩

១២. ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០០៩-២០១៣